


# ទស្សនាវដ្ដី
# វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម




ឆ្នាំទី៣
លេខ២

ចេញផ្សាយប្រចាំឆមាស
ការផ្សាយរបស់វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម

ខែកក្កដា-ធ្នូ
ឆ្នាំ២០២៤

# និពន្ធនាយក

*ដោយៈ ឯកឧត្តមបណ្ឌិត* **ផុន កសិកា**

# រៀបចំចងក្រង

*ដោយៈ លោក* **ប៉ាន់ សំណាង**

# រចនាក្រប

*ដោយៈ លោក* **ហ៊ាង សុចិត្រា**

*អាសយដ្ឋាន* : *មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់អូរបែកក្អម ខណ្ឌសែនសុខ រាជធានីភ្នំពេញ*
*(ជាប់បរិវេណសាកលវិទ្យាល័យភូមិន្ទភ្នំពេញ មណ្ឌល២)*

*គេហទំព័រ* (Website) : https://ihss.rac.gov.kh

*ហ្វេសប៊ុក*(Facebook) : https://web.facebook.com/
*វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម*

# អារម្ភកថា

រាជបណ្ឌិត្យសភាកម្ពុជា ជាស្ថាប័នស្រាវជ្រាវវិទ្យាសាស្ត្ររបស់ជាតិ ដែលប្រមូលផ្ដុំដោយបញ្ញវន្ត និងអ្នកស្រាវជ្រាវជាន់ខ្ពស់ពីគ្រប់មជ្ឈដ្ឋានក្នុងព្រះរាជាណាចក្រកម្ពុជា ហើយត្រូវបានរាជរដ្ឋាភិបាលចាត់ទុកជាធនាគារខួរក្បាលដ៏សំខាន់របស់ជាតិ។

រាជបណ្ឌិត្យសភាកម្ពុជា មានតួនាទីយ៉ាងសំខាន់ក្នុងការសិក្សាស្រាវជ្រាវលើគ្រប់វិស័យទាំងអស់ ដើម្បីផ្ដល់ធាតុចូលជូនរាជរដ្ឋាភិបាលសម្រាប់បម្រើដល់កិច្ចការស្ដារ និងអភិវឌ្ឍសេដ្ឋកិច្ចសង្គម។ ជាមួយគ្នានេះដែរ វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម គឺជាសេនាធិការមួយរបស់រាជបណ្ឌិត្យសភាកម្ពុជា ដែលមានភារកិច្ចជាច្រើនស្រាវជ្រាវលើវិស័យមនុស្សសាស្ត្រ និងវិទ្យាសាស្ត្រសង្គម ក្នុងគោលបំណងរួមចំណែក អភិវឌ្ឍប្រទេសកម្ពុជា អភិវឌ្ឍស្មារតី ចំណេះដឹង ពង្រីកសមត្ថភាពធនធានមនុស្ស ព្រមទាំងបោះពុម្ពផ្សព្វផ្សាយលទ្ធផលនៃការសិក្សាស្រាវជ្រាវរបស់ខ្លួនក្នុងស្មារតីសន្តិភាព អភិវឌ្ឍនភាព ភាពសុខដុមរមនា ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ក៏ដូចជារាជបណ្ឌិត្យសភាកម្ពុជា។

ស្របតាមតួនាទីភារកិច្ចរបស់ខ្លួន វិទ្យាស្ថានមនុស្សសាស្ត្រ និងវិទ្យាសាស្ត្រសង្គមបានបង្កើតទស្សនាវដ្ដីមួយដែលមានឈ្មោះថា «**ទស្សនាវដ្ដីមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម**» ដើម្បីរៀបចំចងក្រង និងបោះពុម្ពផ្សាយលទ្ធផលស្រាវជ្រាវរបស់ថ្នាក់ដឹកនាំ មន្ត្រីវិទ្យាស្ថាន អ្នកស្រាវជ្រាវរបស់រាជបណ្ឌិត្យសភាកម្ពុជា ក៏ដូចជាលទ្ធផលស្រាវជ្រាវបែបវិទ្យាសាស្ត្រពីគ្រប់មជ្ឈដ្ឋានផងដែរ។ **ទស្សនាវដ្ដីមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម** ប្រមូលផ្ដុំដោយអត្ថបទទាក់ទងទៅនឹងប្រធានបទណាមួយ របកគំហើញថ្មីៗ និងអត្ថបទទស្សនៈរបស់អ្នកនិពន្ធជាដើម ក្នុងគោលបំណងចែករំលែកចំណេះដឹងទៅកាន់មជ្ឈដ្ឋានអ្នកស្រាវជ្រាវ សិស្ស និស្សិត ក៏ដូចជា អ្នកអានទូទៅផងដែរ។

យើងខ្ញុំសង្ឃឹម និងជឿជាក់ថា «**ទស្សនាវដ្ដីមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម**» នៃវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គមនៃរាជបណ្ឌិត្យសភាកម្ពុជា ពិតជាផ្ដល់នូវមូលដ្ឋានឯកសារសម្រាប់សិស្ស និស្សិត អ្នកស្រាវជ្រាវទូទៅ ធ្វើការសិក្សាស្រាវជ្រាវបន្តទៀត។

ថ្ងៃព្រហស្បតិ៍ ៨កើត ខែអស្សុជ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែតុលា ឆ្នាំ២០២៤

**ប្រធានវិទ្យាស្ថាន**



**បណ្ឌិត ផុន កសិកា**

# មាតិកា

*ទំព័រ*


១- សំណង់ស្ថាបត្យកម្មនិងរចនាបថនៃប្រាសាទត្រពាំងប្រាសាទ..........................................................១

បណ្ឌិត ផុន កសិកា

២-ភស្តុតាងបុរាណវត្ថុនៅស្ថានីយស្រែអំពិល...........................................................................២០

បណ្ឌិត ផុន កសិកា

៣-ទិដ្ឋភាពមួយចំនួនស្តីពីមេដឹកនាំ.....................................................................................៣៣

បណ្ឌិត អ៊ុំ ប៉ុម

៤- ធម្មចរិយានៃស្មាដៃគតិលោក.......................................................................................៤៩

លោកស្រីបណ្ឌិត ជា វណ្ណី

៥- ឥទ្ធិពលព្រះពុទ្ធសាសនាក្នុងសង្គមខ្មែរ..............................................................................៧២

បណ្ឌិត ហែម ឡាច

៦-ទស្សនវិទូក្រិកបុរាណសម័យ( សូក្រាត ប្លាតុង អារីស្តូត) ..................................................៩៥

បណ្ឌិត ហែម ឡាច

៧-ទស្សនវិជ្ជាខ្មែរអំពីអាបោធាតុ.........................................................................................១១៥

បណ្ឌិត ប៉ាន់ វុត្ថា

៨-ទស្សនវិជ្ជាខ្មែរអំពីលំហ(ទេសភាពឬទីកន្លែង)................................................................១២៤

បណ្ឌិត ប៉ាន់ វុត្ថា

៩-ទស្សនៈមូលដ្ឋាននៃប្រជាសាស្ត្រ...................................................................................១៣០

លោក ហៃ សុគន្ធា

១០- មូលដ្ឋាននៃចិត្តវិទ្យាព្រះពុទ្ធសាសនា........................................................................១៤២

បណ្ឌិត សូ សុធីរ

១១-ប្រសិទ្ធភាពនៃការសិក្សារបស់សិស្ស.......................................................................................១៦៩

បណ្ឌិត សូ សុធីរ

១២-សេចក្តីផ្តើមនៃចិត្តវិទ្យាព្រះពុទ្ធសាសនា................................................................................១៧៩

បណ្ឌិត សូ សុធីរ

១៣-កត្តាចម្បងនៃការបោះបង់ការសិក្សារបស់ជនជាតិដើមភាគតិចថ្ងូនក្នុងខេត្តមណ្ឌលគិរី..................១៩៥

លោក ប៉ាន់ សំណាង

១៤-អត្ថប្រយោជន៍នៃការអប់រំមត្តេយ្យសិក្សាដល់កុមារតូច...........................................................២០៨

លោក ប៉ាន់ សំណាង

១៥-ការអប់រំប្រែកបដោយគុណតម្លៃព្រះពុទ្ធសាសនាដល់ព្រះសង្ឃ.................................................២២១

លោក ប៉ាន់ សំណាង

១៦-ទម្លាប់( custom ) ...............................................................................................................២៣៨

បណ្ឌិត ក្លាន់ ធុល

១៧-ការវិនិយោគនាំជោគជ័យដល់កម្ពុជា........................................................................................២៥៥

បណ្ឌិត មិន ប្រុសបញ្ញាវិទ្ធិ

១៨-ការរៀបចំនិងប្រព្រឹត្តទៅនៃតួនាទី និងអំណាចរដ្ឋបាលឃុំ សង្កាត់...............................................២៨៤

បណ្ឌិត ហ៊ឹម ញាណារិទ្ធ

១៩-មូលដ្ឋានគ្រឹះពុទ្ធសាសនា..........................................................................................................៣០០

លោក ឈុន ផារ៉េង

២០-ទស្សនវិជ្ជាសង្គម........................................................................................................................៣៣១

លោក ឈុន ផារ៉េង

២១-របបមាតាធិបតេយ្យក្នុងសង្គមខ្មែរ..........................................................................................៣៤៦

លោក ឈុន ផារ៉េង

# សំណង់ស្ថាបត្យកម្ម និង រចនាបថនៃប្រាសាទត្រពាំងប្រាសាទ

*ដោយៈ ឯកឧត្តមបណ្ឌិត* **ផុន កសិកា**
*ប្រធានវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម*

## សេចក្តីផ្តើម

*ការសិក្សាស្រាវជ្រាវ បានចាប់ផ្តើមនៅដើមសតវត្សទី២០ ដោយមានអ្នកប្រាជ្ញជនជាតិបារាំបានសិក្សាចុះបញ្ជីប្រាសាទ ទូទាំងប្រទេសកម្ពុជា រួមមានលោក* Lunet De Lajonquière *លោក* Etienne Aymonier *និងលោក* Bernard Phillipes Grossllier *ជាដើម។ នាពេលថ្មីៗនេះ មន្ត្រីជំនាញបុរាណវត្ថុវិទ្យានៃក្រសួងវប្បធម៌និងវិចិត្រសិល្បៈ រួមសហការណ៍ជាមួយស្ថាប័នអន្តរជាតិមួយចំនួនកំពុងសិក្សានិងចុះបញ្ជីប្រាសាទ និងស្ថានីយបុរាណក្នុងបញ្ជីបេតិកភណ្ឌជាតិ។ ទោះជាយ៉ាងនេះហើយក្តី នៅមានប្រាសាទមួយចំនួនក្នុងព្រះរាជាណាចក្រកម្ពុជាពុំទាន់បានចុះបញ្ជីនៅឡើយទេ ដោយសារនៅពេលនោះប្រាសាទទាំងនោះស្ថិតក្នុងព្រៃជ្រៅ អ្នកស្រាវជ្រាវមិនអាចចូលដល់។ ក្រោយមកទៀត ប្រទេសកម្ពុជាត្រូវរអូសបន្លាយដោយសង្គ្រាមរាំរ៉ៃ ធ្វើឲ្យដំណើរការស្រាវជ្រាវ និងចុះបញ្ជីត្រូវអាក់ខាន ដូច្នេះហើយបានជាមានប្រាសាទមួយចំនួននៅមិនទាន់មានការសិក្សា និងចុះបញ្ជីនៅឡើយ តួយ៉ាងប្រាសាទដែលមានព្រៃក្រាស់ស្ថិតនៅតាមជួរភ្នំដងរែកជាដើម។*

*ប្រាសាទត្រពាំងប្រាសាទ ស្ថិតក្នុងភូមិត្រពាំងប្រាសាទ ឃុំត្រពាំងប្រាសាទ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ គឺស្ថិតនៅតាមបណ្តោយជួរភ្នំដងរែក។ ស្រុកត្រពាំងប្រាសាទមានព្រំប្រទល់ខាងត្បូងជាប់ខេត្តសៀមរាប ខាងកើតជាប់ខេត្តព្រះវិហារ ខាងជើងជាប់ព្រំដែនប្រទេសសៀម និងខាងលិចជាប់ស្រុកអន្លង់វែងនៃខេត្តឧត្តរមានជ័យ ដែលមានផ្ទៃដីសរុប៣២៦៥២ហិចតា* (National Committee for Sub-National Democratic Development (NCDD), 2009)*។ ទឹកដីដែលគ្របដណ្តប់ដោយព្រៃឈើក្រាស់មិនមានការតាំងទីរបស់ប្រជាជនច្រើនដូចនៅតំបន់ទំនាបកណ្តាលនោះ មានវត្តមានប្រាសាទបុរាណ ដែលបច្ចុប្បន្នបានក្លាយជាទីតាំងផ្តល់ឱកាសដល់អ្នកសិក្សាស្រាវជ្រាវស្វែងយល់ពីវប្បធម៌ និងអារ្យធម៌នៅសម័យបុរាណ។*

*ប្រាសាទត្រពាំងប្រាសាទជាបណ្តុំប្រាសាទពីរ ខណ្ឌដាច់ដោយផ្លូវលំមួយខ្សែ*

ផ្លាប់ពីវត្តត្រពាំងប្រាសាទ ទៅទីប្រជុំជន។ តាមរយៈការសិក្សាសង្កេតរយៈពេលខ្លី ប្រាសាទទាំងពីរកសាងក្នុងរជ្ជកាលខុសគ្នា។ ទោះបី ប្រាសាទទាំងពីរកសាងក្នុងពេលខុសគ្នា ប៉ុន្តែគឺក្នុងសម័យអង្គរដូចគ្នា។ យើងសន្មតហៅ ឈ្មោះប្រាសាទទាំងពីរ គឺ ប្រាសាទខាងជើងផ្លូវ និងប្រាសាទខាងត្បូងផ្លូវ។




ផែនទីភូមិសាស្ត្រស្រុកត្រពាំងប្រាសាទ

## ១. ប្រាសាទត្រពាំងប្រាសាទខាងត្បូង

ប្រាសាទត្រពាំងប្រាសាទមានពីរ ដែលមានចម្ងាយប្រមាណ៣០០ម៉ែត្រពីគ្នា។ នៅចន្លោះប្រាសាទទាំងពីរមានផ្លូវមួយភ្ជាប់ទៅកាន់ទីប្រជុំជនទីរួមស្រុក។ ទាក់ទងនឹងឈ្មោះប្រាសាទទាំងពីរ អ្នកស្រុកហៅឈ្មោះផ្សេងៗគ្នា។ ប្រាសាទនៅខាងត្បូងផ្លូវ មានឈ្មោះ **ប្រាសាទខាងត្បូង** ឬ **ប្រាសាទតូច**។ ចំណែកប្រាសាទខាងជើងផ្លូវមានឈ្មោះមួយថា **ប្រាសាទខាងជើង** ឬ **ប្រាសាទធំ**។

ប្រាសាទខាងត្បូង មានទីតាំងស្ថិតនៅខាងជើងទីប្រជុំជននៃទីរួមស្រុកត្រពាំងប្រាសាទ។ ការរៀបចំទីរួមស្រុក បន្ទាប់ពីសង្គ្រាមស៊ីវិលអូសបន្លាយអស់ជាច្រើនឆ្នាំ វត្តមួយបានរៀបចំកសាងឡើងនៅខាងលិចនៃប្រាសាទ។ នៅខាងជើងប្រាសាទខាងត្បូង ឬប្រាសាទខ្នាចារ (មានអ្នកស្រុកខ្លះហៅប្រាសាទខាងត្បូងថា "ប្រាសាទខ្នាចារ") មានប្រាសាទមួយទៀតដូចដែលបានរៀបរាប់ខាងលើ គឺ ប្រាសាទខាងជើង។ ប្រាសាទទាំងពីរសុទ្ធតែមានតដាក (បារាយណ៍) នៅចំពីមុខ គឺនៅចំទិសខាងកើតនៃប្រាសាទ។ តដាកស្ថិតនៅមុខប្រាសាទខាងត្បូងមានទំហំធំជាងតដាកនៅខាងកើតប្រាសាទខាងជើង។ ប្រាសាទខាងត្បូងជាប្រាសាទមានតួបីដែលតួទាំងបីសង់លើខឿនតែមួយ ហោត្រៃមានកសិណទឹកព័ទ្ធជុំវិញកំពែងថ្មបាយក្រៀម និងមានខ្លោងទ្វារនៅគ្រប់ទិសទាំងបួនទិសខាងកើត លិច ជើង និងនៅខាងត្បូង។



គំនូរប្លង់លេខ១៖ រូបពំនុះកាត់អ័ក្សជើងត្បូងនៃប្រាសាទត្រពាំងប្រាសាទខាងត្បូង



## ១. ១. កស្រិណទឹក

កស្រិណទឹក ឬគូទឹកនៃប្រាសាទគឺជាសមាសភាពមួយនៃរចនាសម្ព័ន្ធប្រាសាទខ្មែរ។ គូទឹកជា និមិត្តរូបនៃសមុទ្រ ដែលក្នុងលិទ្ធិព្រហ្មញ្ញសាសនា ទីស្ថានរបស់ព្រះឥសូរគឺភ្នំព្រះសុមេរុដែលព័ទ្ធជុំវិញដោយមហាសមុទ្រមួយ។ ប្រាសាទគឺជានិមិត្តរូបរបស់ទីស្ថាននៃព្រះឥសូរ ដូច្នេះប្រាសាទគឺជាភ្នំ រីឯគូទឹកគឺជាមហាសមុទ្រព័ទ្ធជុំវិញ។ ជាទូទៅគូទឹករមែងសង់ព័ទ្ធជុំវិញប្រាសាទចាប់តាំងពីសម័យមុនអង្គរ រហូតដល់សម័យអង្គរ។ ករណីខ្លះដែលគេមិនអាចកសាងគូទឹកបាន ដោយសារប្រាសាទសង់លើភ្នំ គេក៏អាចសង់ត្រពាំងមួយនៅក្បែរនោះ ឬនៅក្បែរភ្នំនោះមានប្រព័ន្ធទឹកធម្មជាតិ គេមិនចាំបាច់កសាងត្រពាំងឡើយ។ នៅតំបន់ភាគខាងត្បូងប្រទេសកម្ពុជា យើងសង្កេតឃើញមានទួលប្រាសាទបាក់បែក ឬទួលប្រាសាទច្រើនសង់នៅសម័យមុនអង្គរ សុទ្ធតែមានគូទឹកព័ទ្ធជុំវិញ (មន្ត្រីវិទ្យាស្ថានវប្បធម៌និងវិចិត្រសិល្បៈ ២០០៦)។



*រូបលេខ១៖ កស្រិណទឹកប្រាសាទខាងត្បូង ជ្រុងឦសាន*

ប្រាសាទខាងត្បូងមានគូទឹកព័ទ្ធស្ទើតែជុំវិញ ទុកតែច្រកចូលប្រាសាទនៅទិសខាងកើត។ គូទឹកនេះមានជម្រៅជ្រៅនិងរាក់ទៅតាមកន្លែង។ នៅជ្រុងខាងជើងឈៀងខាងកើតនៅមានទឹកដក់។ នៅពេលបច្ចុប្បន្ន គោក្របីអ្នកភូមិមកផឹកទឹក និងដេកត្រាំទឹកនៅក្នុងគូទឹកនេះ។ គូទឹកនេះមានទទឹងពីជើងទៅត្បូងប្រវែង១០៥ម៉ែត្រ និងបណ្ដោយពីកើតទៅលិចប្រវែង ១០៨ម៉ែត្រ។

## ១. ២. កំពែងនិងខ្លោងទ្វារ

*កំពែងជាសមាសធាតុមួយនៃប្រាសាទ។ រហូតដល់សម័យអង្គរ ទើបមានលេចចេញ ថែវប្រាសាទ។ កំពែងប្រាសាទខាងត្បូងសង់ពីថ្មបាយក្រៀម។ កំពែងនេះមានទទឹងពីជើងទៅត្បូងប្រវែង៣៧ម៉ែត្រ និងបណ្ដោយពីកើតទៅលិចប្រវែង៤០ម៉ែត្រ។*

*នៅគ្រប់ជ្រុងនៃកំពែង មានខ្លោងទ្វារចូលប្រាសាទ។ ប្រាសាទខាងត្បូងមានខ្លោងទ្វារចូលបួននៅគ្រប់ទិស។ ខ្លោងទ្វារប្រាសាទធ្វើពីឥដ្ឋ និងស៊ុំទ្វារធ្វើពីថ្មភក់។ ខ្លោងទ្វារខាងលិចនិងខាងកើត សង់ចំពាក់កណ្ដាលកំពែង ចំណែកខ្លោងទ្វារខាងជើង និងត្បូងសង់មិនចំពាក់កណ្ដាលនៃកំពែងទេ។*



*រូបលេខ២៖ កំពែងប្រាសាទខាងត្បូង ជ្រុងឦសាន*

## ១. ៣. ខឿនប្រាសាទ

*ប្រាសាទខាងត្បូងមានតួប្រាសាទបី។ តួប្រាសាទទាំងបីសង់លើខឿនរួមមួយដែលមានប្រវែង ប្រហាក់ប្រហែល គឺពីជើងទៅត្បូងប្រវែង២៦ម៉ែត្រ និងពីកើតទៅលិចប្រវែង២០ម៉ែត្រ។ ខឿនប្រាសាទសង់ពីថ្មបាយក្រៀមព័ទ្ធជុំវិញ។ ខឿនប្រាសាទនេះលយចេញនៅចំពីមុខតួប្រាសាទកណ្ដាល។ នៅកន្លែងលយនេះ មានជណ្ដើរឡើងឆ្ពោះទៅកាន់តួកណ្ដាលនិងតួប្រាសាទពីរទៀត។ ដោយសារការបាក់បែកខ្លាំង នៅខឿននេះ យើងពិបាកសន្និដ្ឋានថា តើមានជណ្ដើរនៅចំពីមុខតួប្រាសាទពីរទៀត ឬក៏គ្មាន។ យើងអាចដឹងបាន ដរាបណា យើងធ្វើកំណាយនៅខាងកើតនៃខឿននេះ។*



*រូបលេខ៣៖ ទិដ្ឋភាពខឿនប្រាសាទខាងត្បូង នៅទិសខាងកើត*

## ១. ៤. ប្រាង្គនៃប្រាសាទ

### ១. ៤. ១. ប្រាង្គកណ្តាល

ប្រាង្គកណ្តាលជាប្រាង្គសំខាន់ជាងគេបំផុត ហើយជាទូទៅមានទំហំធំជាង និងខ្ពស់ជាងប្រាង្គដ៏ទៃទៀត។ ប្រាង្គកណ្តាលនៃប្រាសាទខាងត្បូងមានកំពស់ ៦.៣ម៉ែត្រ និងកម្រាស់ជញ្ជាំង ១.៣ ម៉ែត្រ ប្រាង្គនេះទទួលរងការបំផ្លាញច្រើន។ ដំបូលប្រាសាទដែលជាទូទៅធ្វើពីថ្មភក់ មានរាងដូចផ្កាឈូកក្រពុំ បានជ្រុះបាត់ រីឯសំណល់ដំបូលប្រាសាទនេះ ប្រហែលជាក្នុងបរិវេណវត្តបច្ចុប្បន្ន។ ប្រាង្គនេះសង់ពីឥដ្ឋសម្រាប់តួប្រាសាទទាំងមូល លើកលែងគ្រឿងលម្អ ដូចជា ផ្តែរ មេទ្វារ សសរផ្តោប កាំជណ្តើរ និងទ្រនាប់ជណ្តើ ធ្វើពីថ្មភក់។ ការប្រើថ្មភក់សម្រាប់គ្រឿងលម្អប្រាសាទបែបនេះ ជាលក្ខណៈទូទៅសម្រាប់សំណង់ប្រាសាទក្នុងប្រទេសកម្ពុជា និងប្រាសាទផ្សេងៗក្នុងតំបន់អាស៊ីអាគ្នេយ៍ នេះ។ មានការប្រើថ្មភក់នៅទ្វារបញ្ឆោតនៅជ្រុងខាងលិច។ គួរកត់សម្គាល់ថា នៅគ្រប់ប្រាង្គទាំងបីនៃប្រាសាទខាងត្បូង មិនមានយកថ្មភក់មានសង់នៅត្រង់ទ្វារបញ្ឆោតនោះទេ លើកលែងតែទ្វារបញ្ឆោតនៅតួកណ្តាល ហើយមានតែនៅជ្រុងខាងកើតមួយគត់ដែលប្រើថ្មភក់នៅលើទ្វារបញ្ឆោត។ ទ្វារបញ្ឆោតនៅជ្រុងខាងជើង និងខាងត្បូងប្រាសាទត្រូវធ្លាក់ និងជាប់នៅលើឥដ្ឋនៃជញ្ជាំងប្រាសាទឲ្យចេញជារាងទ្វារបញ្ឆោត។ យើងសង្កេតឃើញថា នៅរចនាសម្ព័ន្ធផ្នែកខាងក្រោមនៅជាប់ដី គេក៏ប្រើថ្មភក់ដែរ ហើយមានលម្អដោយឆ្លាក់ក្បាច់នៅលើថ្មទាំងនោះ។ ការយកថ្មភក់មកប្រើនៅ

រចនាសម្ព័ន្ធក្រោមនៃប្រាសាទជាការមួយងាយស្រួលធ្លាក់លម្អក្បាច់ ជាងនេះទៀត។ ថ្មភក់អាចជួយទ្រនិងទប់កម្លាំងសង្កត់របស់តួប្រាសាទ ជួយពង្រឹងរចនាសម្ព័ន្ធប្រាសាទឲ្យរឹងមាំល្អ។ ក្រៅពីគ្រឹះនៅខាងក្រោមប្រាសាទនិងខឿនដែលជួយទប់ដល់ការបាក់ស្រុតបច្ចេកទេសយកថ្មភក់មកប្រើនៅរចនាសម្ព័ន្ធក្រោមអាចជួយកម្លាំងទ្របន្ថែមទៀត។



រូបលេខ៤៖ ប្រាង្គកណ្ដាលនៃប្រាសាទខាងត្បូង

### ១. ៤. ២. ប្រាង្គខាងត្បូង

ក្រៅពីប្រាង្គកណ្ដាលជាប្រាង្គសំខាន់ នៅមានប្រាង្គពីរទៀតនៅអមសងខាងប្រាង្គកណ្ដាល។ ប្រាង្គខាងត្បូងមានកំពស់២.៥ ម៉ែត្រ និងមានកម្រាស់ជញ្ជាំង ១.៣ ម៉ែត្រ។ ប្រាង្គនេះក៏ទទួលរងការបំផ្លាញខ្លាំងដែរមានសភាពទ្រុឌទ្រោមខ្លាំងជាងប្រាង្គកណ្ដាល។ រចនាសម្ព័ន្ធខាងលើ គឺដំបូលប្រាសាទបានជ្រុះបាត់។ ប្រាង្គនេះសង់ពីឥដ្ឋ លើកលែងគ្រឿងលម្អ ដូចជា ផ្តែរ មេទ្វារ សសរផ្អោបជណ្តើរ និងទ្រនាប់ជណ្តើរធ្វើពីថ្មភក់។ ចំពោះប្រាង្គខាងត្បូងវិញ គ្រឿងលម្អធ្វើពីថ្មភក់មាននៅសេសសល់តែសសរផ្អោបមួយនិងបំណែកសសរពេជ្រមួយប៉ុណ្ណោះ។ សម្រាប់ទ្វារបញ្ឆោតវិញ គេប្រើបច្ចេកទេសដូចគ្នានឹងទ្វារបញ្ឆោតនៃប្រាង្គកណ្ដាលដែរ តែមិនមានប្រើថ្មភក់ជាមួយទេ។

បើនិយាយពីការខូចខាតវិញប្រាង្គនេះទទួលរងការបំផ្លាញខ្លាំង។ ផ្តែរ ស៊ុំទ្វារ សសរពេជ្របានជ្រុះបាត់ពីប្រាសាទ រីឯជញ្ជាំងខាងកើតបាត់ទាំងស្រុង។ នៅគ្រប់ជញ្ជាំងផ្នែកខាងលើបាក់បែកទាំងស្រុង។ ប្រាង្គនេះរកកល់នឹងរលំទៅខាងទិសខាងត្បូង។ យើងឃើញថា ប្រាង្គនេះទ្រេតខ្លាំងទៅទិស

ខាងត្បូង។ ជញ្ជាំងខាងត្បូងបានរហែកញែកដាច់ចេញពីជញ្ជាំងខាងលិចទាំងស្រុង។

បន្ទាប់ពីធ្វើការសិក្សាវិភាគ និងគូរផែនទីប្លង់ប្រាសាទរួចមក យើងអាចស្វែងយល់ពីមូលហេតុដែលបណ្ដាលឲ្យជញ្ជាំងខាងត្បូងប្រេះទ្រេតទៅខាងត្បូង។ បញ្ហានេះកើតដោយសារការស្ថាបនាខឿនប្រាសាទមិនបានធំល្មសម្រាប់ទ្រប្រាង្គទាំងបី។ ខឿនប្រាសាទសង់ខ្ពស់ ប៉ុន្តែតូច ហើយមានកសាងប្រាង្គបីនៅពីលើបន្ថែមទៀត។ ពីប្រាង្គទៅចុងខឿនមានចម្ងាយខ្លី ដូច្នេះនៅពេលខឿនបាក់ កម្លាំងទប់ប្រាង្គក៏ចុះខ្សោយ។ នៅពេលមានភ្លៀងធ្លាក់ ទឹកភ្លៀងនាំហូរដីចេញពីខឿន បានធ្វើឲ្យគ្រឹះនៃប្រាង្គលែងមានអ្វីទប់ ហើយក៏ទ្រេត ទៅតាមតាមទិសដែលខឿនបាក់បែក។ ករណីនេះ កើតឡើងចំពោះ ប្រាង្គខាងត្បូង និងប្រាង្គខាងជើង ដោយសារ ខឿននៅជ្រុងខាងត្បូង និងខាងជើងស្ថាបនានៅជិតប្រាង្គទាំងពីរ ដល់ពេលខឿនបាក់បែក ប្រាង្គទាំងពីរក៏លែងមានខឿនទប់ទៀតហើយក៏បាក់បែកបន្ទាប់ពីខឿននោះដែរ។



*រូបលេខ៥៖ ប្រាង្គខាងត្បូងនៃប្រាសាទខាងត្បូង*

### ១. ៤. ៣. ប្រាង្គខាងជើង

ប្រាង្គទីបីគឺប្រាង្គខាងជើងនៃជញ្ជាំងខាងជើងមានកំពស់៦ម៉ែត្រ ចំណែកជញ្ជាំងខាងត្បូងមានកំពស់៤.៨ម៉ែត្រ និងកម្រាស់ជញ្ជាំង១.៣ម៉ែត្រ ប្រាង្គនេះទទួលរងការបំផ្លាញខ្លាំងជាងគេក្នុងចំណោមប្រាង្គទាំងបីនៃប្រាសាទត្រពាំងប្រាសាទខាងត្បូង។ រចនាសម្ព័ន្ធខាងលើ គឺដំបូលប្រាសាទបានជ្រុះបាត់ស្ទើតែទាំងអស់ តួប្រាសាទទាំងមូលនៅសេសសល់តិចតួចបំផុត។ ប្រាង្គនេះក៏ដូចជាប្រាង្គដទៃទៀតដែរ គឺសង់ពីឥដ្ឋ លើកលែងគ្រឿងលម្អ ដូចជា ផ្តែរ មេទ្វារ សសរផ្អោបកាំជណ្ដើរ និងទ្រនាប់ជណ្ដើរ ធ្វើពីថ្មភក់។ ប្រាង្គខាងជើង គ្រឿងលម្អធ្វើពីថ្មភក់មាននៅសេសសល់តែមេទ្វារមួយប៉ុណ្ណោះ ចំណែកគ្រឿងលម្អផ្សេងៗមិនមានសេសសល់ឡើយ។

បើនិយាយពីការខូចខាតវិញប្រាង្គខាងជើងនេះទទួលរងការបំផ្លាញខ្លាំងបំផុត។ ផ្ដេរស៊ុំទ្វារសសរពេជ្របានជ្រុះបាត់ពីប្រាសាទ រីឯជញ្ជាំងខាងកើតបាត់ទាំងស្រុងដូចប្រាង្គខាងត្បូងដែរ។ នៅគ្រប់ជញ្ជាំងផ្នែកខាងលើបាក់បែកទាំងស្រុង។ ប្រាង្គខាងជើងមានលក្ខណៈបំផ្លាញដូចគ្នានឹងប្រាង្គខាងត្បូងដែរ។ ដូចបានលើកឡើងពីខាងលើរួចមកហើយ បញ្ហាចម្បងបណ្ដាលឲ្យប្រាង្គទ្រុឌទ្រោមខ្លាំង គឺដោយសារខឿននៃប្រាសាទបានបាក់បែក។ ដោយហេតុថា ប្រាង្គនេះសង់ក្បែរខឿន ហើយខឿនទៀតសោតតូច តែខ្ពស់។ ដូច្នេះនៅពេលខឿនទទួលរងការបាក់បែក ប្រាង្គដែលសង់ពីលើខឿនក៏ទទួលរងការបំផ្លាញស្របគ្នាដែរ។ ប្រាង្គខាង ជើងទ្រេតទៅទិសខាងជើង គឺទ្រេតទៅរកខឿនដែលទទួលរងការបាក់បែក។ ចំណែកជញ្ជាំងខាងជើងទ្រេតខ្លាំង ជាងគេ និងទទួលរងការបំផ្លាញខ្លាំងជាងគេដែរ។



រូបលេខ៦៖ ប្រាង្គខាងជើងនៃប្រាសាទខាងត្បូង

### ១. ៥. ហោជាង

ប្រាសាទខាងត្បូងត្រូវបាក់ទ្រុឌទ្រោមយ៉ាងខ្លាំង។ គ្រឿងលម្អប្រាសាទដូចជាហោជាង ផ្ដេរ និងសសរស្ដម្ភជាដើម ត្រូវធ្លាក់ចុះពីប្រាសាទនិងបាក់បែកជាបំណែក។ យើងសង្កេតឃើញមានបំណែកហោជាងពីរបំណែកស្ថិតក្នុងបរិវេណប្រាសាទ។ តាមរយៈបំណែកហោជាងទាំងពីរ ហោជាងនោះប្រហែលមានទំហំធំ ហើយបំណែកទាំងពីរជាបំណែកខ្ទះនៃហោជាង។ យើងឃើញមានរចនាលម្អជាបែបរចនាបថសម័យអង្គរ និងមានលម្អសត្វស្វាបមួយ ប្រហែលជាសត្វសេក។



រូបលេខ៧៖ បំណែកហោជាងប្រាសាទខាងត្បូង

### ១. ៦. សសរស្តម្ភ

សសរស្តម្ភ ឬសសរពេជ្រ គឺជាគ្រឿងលម្អស្ថាបត្យកម្មមួយ ប្រើសម្រាប់ទ្រផ្តែរ។ ជាទូទៅសសរស្តម្ភរបស់ប្រាសាទបុរាណខ្មែរធ្វើពីថ្មភក់។ លោកហ្វីលីព ស្ទែន Phillipe Stern និងអ្នកស្រីស្សីលប៉ែ ដឺ កូរាល រេមុយស្សា (Gilbert de Coral Rémusat) បានបែកសសរស្តម្ភសម័យមុនអង្គរជាបី៖ សសរស្តម្ភក្នុងរចនាបថសម្បូណ៌ព្រៃគុក នៅកំលុងសតវត្សទី៧ សសរស្តម្ភសម័យព្រៃក្មេងនៅកំលុងភាគទី១នៃសតវត្សទី៨ និងសសរស្តម្ភក្នុងរចនាបថកំពង់ព្រះ នៅកំលុងពាក់កណ្តាលសតវត្សទី៨។ សសរស្តម្ភក្នុងរចនាបថទាំងបីខាងលើជាទូទៅរាងមូលហើយតូច។ សសរស្តម្ភក្នុងរចនាបថក្រោយៗកាន់តែធំ និងមានក្បាច់លម្អកាន់តែស្មុគស្មាញ។ ម្យ៉ាងទៀតក្បាច់រចនារបស់សសរស្តម្ភតែងតែវិវត្តស្របគ្នាជាមួយនឹងក្បាច់លម្អរបស់ផ្តែរ (Brigg, 1951)។ អ្នកស្រីស្សីលប៉ែ ដឺ កូរាល រេមុយស្សា (Gilbert de Coral Rémusat) បានកត់សម្គាល់ពីការវិវត្តន៍ ដោយសង្ខេបតាមដំណាក់កាលនីមួយៗនៃសិល្បៈរួចមកហើយ (Rémusat, 1951)។

ជាទូទៅសសរស្តម្ភធ្វើឡើងអំពីថ្មភក់តែមួយដុំ ហើយមានតួនាទីសម្រាប់ទ្រផ្តែរទ្វារផង និងបង្កើនសោភណ័ភាពប្រាសាទផង។ នៅសម័យមុនអង្គរសសរស្តម្ភមានរាងមូលដូចជាបំពង់។ ជាក់ស្តែងដូចជានៅក្រុមប្រាសាទសម្បូណ៌ព្រៃគុកលើកលែងប្រាសាទតោ ដែលជាប្រាសាទស្ថិតនៅក្នុងរចនាបថអន្តរកាលពីសម័យមុនអង្គរមកដើមសម័យអង្គរ។ នៅសម័យអង្គរសសរស្តម្ភមានរាងប្រាំបីជ្រុងដូចជា ប្រាសាទវត្តឯកភ្នំ ប្រាសាទក្រវ៉ាន់ ជាដើម។



រូបលេខ៨និង៩៖ សសរស្តម្ភប្រាសាទខាងត្បូង

### ១. ៧. សសរផ្តោប

សសរផ្តោបក៏ដូចជាសសរស្តម្ភ និងគ្រឿងលម្អផ្សេងទៀតដែរ គេស្ថាបនាឡើងនៅបន្ទាប់ពីសសរស្តម្ភ និងមានរចនាក្បាច់លម្អដូចជាក្បាច់ភ្ញីផ្សេងៗជាដើម។ សសរផ្តោបមានបីប្រភេទខុសៗគ្នាគឺ សសរផ្តោបសំខាន់ (មេ) សសរផ្តោបសារពើសូត្រ និងសសរផ្តោបជ្រុងដែលមានតាំងពីសម័យមុនអង្គរហូតមកដល់សម័យក្រោយៗទៀតរហូតដល់សម័យអង្គរ។ សសរផ្តោបអាចសាងពីថ្មកក់ដាច់ដោយឡែកពីសសរស្តម្ភ។ ទំនោរបែបនេះច្រើនកើតមាននៅទ្វារចូលនៃប្រាង្គប្រាសាទដែលយើងអាចមើលឃើញមេទ្វារ ឬស៊ុំទ្វារ ផ្តែរ ហោជាង សសរស្តម្ភ និងបន្តដោយសសរផ្តោប។ សសរផ្តោបខ្លះទៀតអាចកសាងនៅជាប់ជាមួយទ្វារបញ្ឆោតនៃប្រាង្គ។ ចំពោះប្រាសាទត្រពាំងប្រាសាទវិញ គេជ្រើសរើសករណីទាំងពីរមកប្រើ។ នេះមានន័យថា បច្ចេកទេសស្ថាបនាប្រាសាទមានការរីកចម្រើន។ តែដោយឡែក សសរផ្តោបនៅតួប៉មនៃប្រាសាទស្វាប់ប្តីវិញសាងនៅជាប់ទ្វារបញ្ឆោត ហើយពុំមានឆ្លាក់ក្បាច់អ្វីទេនៅឯតួសសរ តែនៅក្បាលសសរមានចិតជាក្បាច់ខ្សែវន្ទ័បីជាន់តែប៉ុណ្ណោះ (កើត គឹមហៃ ២០០៦)។

### ១. ៨. ផ្តែរ

ផ្តែរជាគ្រឿងលម្អមួយផ្នែកសំណង់ស្ថាបត្យកម្ម ដាក់ពីលើសសរស្តម្ភ លើខ្លោងទ្វារចូលប្រាសាទ។ សិល្បៈសំណង់ប្រាសាទបុរាណខ្មែរតាំងពីសម័យហ្វូណនមកម្ល៉េះ ហើយស្នាដៃសិល្បៈនេះចេះតែវិវត្តហូរហៃ មករហូតដល់សម័យបាយ័ន។ ដើម្បី

សម្រួលដល់ការសិក្សា គេនិយមចែកសិល្បៈជារចនាបថ ដោយយកឈ្មោះប្រាសាទសំខាន់ៗមកដាក់ឈ្មោះរចនាបថទាំងនោះ។ ផ្តែរក្នុងសិល្បៈខ្មែរក៏ចែកទៅតាមសម័យកាល និងរចនាបថដែរ។ តាមទ្រឹស្តីសិល្បៈ គេអាចចែកសម័យកាលប្រវត្តិសាស្ត្រដោយសារការវិវត្តន៍ក្បាច់លម្អរបស់គ្រឿងសំណង់ស្ថាបត្យកម្ម។ ផ្តែរជាផ្នែកមួយសំខាន់សម្រាប់សិក្សារចនាបថប្រាសាទនីមួយៗ ហើយលោក ហ្វីលីពស្តែន (P. Stern) បានសិក្សាពីការវិវត្តន៍របស់វា។

មានសំណល់បំណែកផ្តែរមួយផ្ទាំងស្ថិតក្នុងបរិវេណខាងក្នុងប្រាសាទត្រពាំងប្រាសាទខាងត្បូង។ ផ្តែរបាក់ជាបួនបំណែក។ បំណែកពីរនៅខាងលើបាត់ គឺនៅសល់តែបំណែកពីរខាងក្រោម។ ការបាក់បែកនេះអាចបណ្តាលមកពីការបាក់រលំនៃសសរស្តម្ភធ្វើឲ្យផ្តែរនៅខាងលើធ្លាក់មកក្រោមបាក់ជាបំណែក។ ករណីបាក់បែកមួយទៀតអាចទាក់ទងនឹងការលួចវត្ថុបុរាណរបស់ពួកក្រុមចោរ។ អំពើរចោរកម្មលើប្រាសាទបុរាណបដិមា គ្រឿងលម្អប្រាសាទបុរាណកើតមាននៅពេញផ្ទៃប្រទេសក្នុងពេលស្រុកកំពុងមានសង្គ្រាមផ្ទៃក្នុង។ ម្ល៉ោះហើយ ផ្តែរនេះអាចមានករណី វាយបំបែកជាបំណែកមុននឹងលួចយកចេញទៅ។

ចម្លាក់នៅលើផ្តែរ៖ មានរូបព្រះកាលស្ថិតនៅចំកណ្តាល ប៉ុន្តែធ្លាក់ចុះក្រោម។ ព្រះកាល មានដៃកាន់កម្រងផ្កាដាក់នៅក្បែរមាត់។ ក្បាលព្រះកាលមានសក់រួញដូចសត្វសឹង្ហ។ ភ្នែកព្រះកាល ធំៗ និងលៀនចេញមកក្រៅ។ ច្រមុះធំរីក មានរន្ធធំៗ។ ធ្មេញបង្ហាញយ៉ាងច្បាស់លាស់ ទាំងធ្មេញលើ និងធ្មេញក្រោម។ កាយវិការមាត់បើកធំបញ្ចេញធ្មេញ និងចង្កូម ព្រមជាមួយដៃកាន់កម្រងផ្កាបែបនេះ អាចជាកាយវិការលេប ឬខ្ជាក់កម្រងផ្កា។ នៅសងខាងរូបព្រះកាល គឺជាកម្រងផ្ការដែលព្រះកាលកំពុងលេប ឬខ្ជាក់នោះ។ ផ្កាជាប្រភេទផ្កាមានសន្ទឹកធំៗ ហើយរីកទល់ខ្នងគ្នា។ ចំណែកនៅខាងចុងផ្តែរទាំងសងខាង គឺជាសន្ទឹកផ្ការីកបែរចេញក្រៅ។



រូបលេខ១០៖ បំណែកផ្តែរពីរផ្ទាំងផ្គុំគ្នា ស្ថិតក្នុងបរិវេណប្រាសាទខាងត្បូង

### ១. ៩. លិង្គ

លិង្គគឺជាតំណាងអង្គជាតិរបស់ព្រះឥសូរ និងជាតំណាងឲ្យអំណាចនៃការបង្កើតលោក។ លិង្គគឺជា និមិត្តរូបសាសនាមួយដែលមានតួនាទីចម្បងសម្រាប់គោរពសក្ការៈ។ នៅក្នុងរាជព្រះមហាក្សត្រខ្មែរ លិង្គកសាងឡើងជានិមិត្តរូបរបស់ព្រះមហាក្សត្រផ្ទាល់ និងតម្កល់នៅក្នុងប្រាង្គប្រាសាទរបស់ព្រះអង្គដែលបានកសាង សន្មតថាព្រះអង្គគឺជាព្រះឥសូរ។ ការកសាងលិង្គចាប់ផ្តើមមានតាំងពីសម័យមុនអង្គររហូតដល់សម័យអង្គរ។ លិង្គនៅសម័យអង្គរមានច្រើនប្រភេទៈ លិង្គខ្លះដាក់តម្កល់លើយោនី, លិង្គខ្លះមានឆ្លាក់មុខរបស់ព្រះឥសូរដែល គេច្រើនហៅថា មុខលិង្គ(mukhalinga) និងលិង្គខ្លះទៀតសាងជាបីផ្នែកគឺ នៅបាតរាងបួនជ្រុងតំណាងឲ្យព្រះព្រហ្ម, នៅផ្នែកកណ្តាលរាងប្រាំមួយជ្រុង តំណាងឲ្យព្រះនារាយណ៍ និងផ្នែកខាងលើបំផុតរាងមូល តំណាងឲ្យ ព្រះឥសូរ។

នៅប្រាសាទត្រពាំងប្រាសាទ មានសល់បំណែកលិង្គតែមួយគត់នៅក្នុងបរិវេណប្រាសាទ។ លិង្គនេះ ជាប្រភេទលិង្គទីបីដែលមានបីផ្នែកគឺ នៅបាតរាងបួនជ្រុងតំណាងឲ្យព្រះព្រហ្ម, នៅផ្នែកកណ្តាលរាងប្រាំមួយជ្រុង តំណាងឲ្យព្រះនារាយណ៍ និងផ្នែកខាងលើបំផុតរាងមូល តំណាងឲ្យព្រះឥសូរ។ ក៏ប៉ុន្តែផ្នែកខាងលើបានបែក នៅសល់ផ្នែកខាងក្រោម និងកណ្តាល។



រូបលេខ១១៖ លិង្គដែលស្ថិតក្នុងបរិវេណប្រាសាទត្រពាំងប្រាសាទខាងត្បូង

## ២. ប្រាសាទត្រពាំងប្រាសាទខាងជើង

ប្រាសាទខាងជើង ឬប្រាសាទធំ ស្ថិតនៅខាងជើងទីប្រជុំជនស្រុកត្រពាំងប្រាសាទ ហើយក៏ស្ថិតនៅខាងជើងនៃប្រាសាទខាងត្បូងដែរ។ ប្រាសាទខាងជើងជាប្រាសាទមានប្រាង្គទោល មានកំពែងថ្មបាយក្រៀមព័ទ្ធជុំវិញ ហោត្រៃស្ថិតនៅទិសឦសាន និងមានខ្លោងទ្វារតែមួយគត់ ស្ថិតនៅទិសខាងកើត។

ប្រាសាទខាងជើងពុំមានកសិណទឹកព័ទ្ធជុំវិញដូចប្រាសាទខាងត្បូងទេ តែមានតដាក (បារាយណ៍) មួយស្ថិតនៅខាងកើតប្រាសាទ។ តដាកនេះមានបណ្ដោយប្រវែង២០០ម៉ែត្រ និងទទឹង៩១ម៉ែត្រ និងផ្ទៃក្រឡាជាង ២០០០០ម៉ែត្រក្រឡា។




ប្លង់បាតនៃប្រាសាទត្រពាំងប្រាសាទខាងជើង និង បារាយណ៍នៅខាងកើតប្រាសាទ

### ២. ១. កំពែងនិងខ្លោងទ្វារ

ប្រាសាទខាងជើងក៏មានកំពែងដូចប្រាសាទខាងត្បូងដែរ។ កំពែងប្រាសាទខាងជើងសង់ពីថ្មបាយក្រៀម។ កំពែងនេះមានទទឹងពីជើងទៅត្បូងប្រវែង ២៣ម៉ែត្រ និងបណ្ដោយពីកើតទៅលិច ប្រវែង ៣៩ ម៉ែត្រ។ ប្រាសាទខាងជើងពុំមានខ្លោងទ្វារចូលបួននៅគ្រប់ទិស គឺមានតែខ្លោងទ្វារតែមួយគត់នៅជ្រុងខាងកើត។ ខ្លោងទ្វារខាងកើតធ្វើពីថ្មបាយក្រៀមនិងស៊ុំទ្វារធ្វើពីថ្មភក់។



រូបលេខ១១២៖ ខ្លោងទ្វារខាងកើតនៃប្រាសាទខាងជើងសង់ពីថ្មបាយក្រៀម

## ២. ២. ប្រាង្គប្រាសាទ

ប្រាសាទខាងជើងមានប្រាង្គតែមួយ គត់មានកម្ពស់៦ម៉ែត្រ សង់ពីថ្មបាយក្រៀម និងថ្មភក់សម្រាប់ស៊ុំទ្វារ។ ប្រាង្គនេះមិនមានក្បាច់រចនាលើទេ។ យើងមិនប្រទះឃើញបំណែកហោជាង ផ្តែរ សសរស្តម្ភនៅក្នុងបរិវេណប្រាសាទទេ។ សូម្បីខ្លោងទ្វារនៃប្រាសាទក៏មិនមានក្បាច់លម្អណាមួយដែរ។

ទាក់ទងនឹងការពុកផុយនៃប្រាសាទ ជញ្ជាំងខាងជើងនៃប្រាង្គបានធ្លាក់បាក់រលំ ដុំថ្មបាយក្រៀមនៃប្រាង្គ ធ្លាក់គលើគ្នានៅជ្រុងខាងជើងនេះ។ តាមការសង្កេតពីសណ្ឋានដីជុំវិញប្រាសាទ យើងឃើញថា ប្រាសាទនេះសង់នៅលើដីធម្មជាតិ ដោយមិនមានលើកដីជាថ្នាទេ។ នៅភាគខាងជើងជិតប្រាសាទ ដីជម្រាលចុះ។ សណ្ឋានដីបែបនេះអាចប៉ះពាល់ដល់សំណង់ប្រាសាទ ពីព្រោះនៅពេលមានភ្លៀងធ្លាក់ ទឹកបាននាំដីហូរច្រោះទៅភាគខាងជើង។ ទឹកហូរពីទីខ្ពស់មកទាប គឺហូរពីប្រាង្គទៅភាគខាងជើងធ្វើឲ្យដីហូរដាច់។ ដូច្នេះហើយបានជា កំពែងជ្រុងខាងជើង និងជញ្ជាំងប្រាង្គខាងជើងបាក់បែកខ្ទាំង។



រូបលេខ១១៣៖ ប្រាង្គកណ្តាលនៃប្រាសាទខាងជើង មើលពីទិសខាងកើត សង់ពីថ្មបាយក្រៀម

## ២. ៣. ហោត្រៃ

ហោត្រៃជាអគារបុរាណនៅក្នុងបរិវេណប្រាសាទ ជាទូទៅបែរមុខបញ្ច្រាសទិសនឹងប្រាង្គកណ្តាលនៃ ប្រាសាទ។ ហោត្រៃនៃប្រាសាទខាងជើងសង់ពីថ្មបាយក្រៀម និងមានថ្មភក់សង់សម្រាប់ស៊ុំទ្វារ។ ហោត្រៃនេះទំហំ៥ម៉ែត្រពីកើតទៅលិច និង៣ម៉ែត្រពីជើងទៅត្បូង។



រូបលេខ១៤៖ ហោត្រៃប្រាសាទខាងជើង

## សន្និដ្ឋាន

ប្រាសាទត្រពាំងប្រាសាទមិនមានសិលាចារឹក និងមិនមានគ្រឿងលម្អច្រើននោះទេ។ អ្វីដែលយើងអាចសិក្សាពីអាយុកាលរបស់ប្រាសាទខាងត្បូងបានគឺផ្តែរនៃប្រាសាទខាងត្បូងតែមួយប៉ុណ្ណោះ។ ចំណែកការសិក្សាពីអាយុរបស់ប្រាសាទខាងជើងមិនអាចសិក្សាបានទេ ដោយសារមិនមានសិលាចារឹក ហើយក៏មិនមានហោជាង សសរពេជ្រ និងផ្តែរទេ។ ម្យ៉ាងទៀត ប្រាសាទនេះកសាងឡើងដោយមិនមានរចនាក្បាច់លម្អអ្វីទាំងអស់។ អាយុកាលដែលអាចកំណត់បានចំពោះប្រាសាទខាងជើង គឺស្ថិតក្នុងសម័យអង្គរ។ ហើយបើតាម គុណភាពថ្មភក់ ប្រាសាទខាងជើងប្រហែលអាចកសាងលឡើងក្នុងសតវត្សទី១៣ ស្ថិតនៅចុងសម័យអង្គរ។ នេះជាការសន្និដ្ឋានជំហានដំបូង។

ចំពោះប្រាសាទខាងត្បូង អាចសិក្សាពីអាយុកាលបានតាមរយៈផ្តែរពីរបំណែកក្នុងបរិវេណប្រាសាទ។ ផ្តែរពីរបំណែកនេះបែកចេញពីផ្តែរតែមួយ។ បំណែកទាំងពីរជាផ្នែកកណ្តាលនិងក្រោមនៃផ្តែរ។ បើយើងវិភាគទៅលើក្បាច់លម្អនៅលើផ្តែរ ផ្តែរនេះមានក្បាច់លម្អប្រហែលគ្នានឹងផ្តែររចនាបថកោះកេរ និងផ្តែររចនាបថប្រែរូប។

ប្លង់ប្រាសាទក៏ជាភស្តុតាងមួយអាចឲ្យយើងសិក្សាបានពីអាយុកាលដែរ។ ប្រាសាទខាងត្បូងសង់ឡើង ដោយមានប្រាង្គបីលើទួលលើកខ្ពស់មួយ ព័ទ្ធជុំវិញដោយកំពែងថ្មបាយក្រៀម និងកសិណទឹក។ កំពែងថ្មបាយក្រៀម មានខ្លោងទ្វារបួនដែលខ្លោងទ្វារធំស្ថិតនៅខាងកើតដែលជាច្រកសំខាន់ជាងគេ។ ប្លង់ប្រាសាទបែបនេះអាចដូចគ្នា នឹងប្លង់ប្រាសាទសង់ក្នុងរចនាបថប្រែរូប។

សរុបមក ការសន្និដ្ឋានឲ្យជាក់ច្បាស់ពីអាយុកាលនៃប្រាសាទខាងត្បូងមិនអាចធ្វើបានឡើយ។ ការសន្និដ្ឋានដំបូងពីអាយុកាលនៃប្រាសាទនេះ គឺប្រហែលក្នុងសតវត្សទី១០ ក្នុងរចនាបថកោះកេរ និងប្រែរូប។

ប្រាសាទត្រពាំងប្រាសាទខាងជើងមានរូបរាង និងប្លង់ដូចគ្នានឹងមន្ទីរពេទ្យរបស់ព្រះបាទជ័យវរ្ម័នទី៧ ដែលព្រះអង្គបានកសាងនៅតាមផ្លូវបុរាណក្នុងរាជរបស់ព្រះអង្គ។ យើងអាចដឹងថា ប្រាសាទក្នុងរាជរបស់ព្រះបាទជ័យវរ្ម័នទី៧ ក្នុងសតវត្សទី១៣។ ដូច្នេះ ប្រាសាទត្រពាំងប្រាសាទខាងជើងប្រហែលជាសាងសង់ក្នុងសតវត្សទី១៣ ក្នុងរាជរបស់ព្រះបាទជ័យវរ្ម័នទី៧។

ប្រាសាទត្រពាំងប្រាសាទទាំងពីរទទួលរងការខូចខាតពីកត្តាធម្មជាតិ ដោយទទួលរងការទន្ទ្រានពីព្រៃឈើដុះពីលើ ទឹកភ្លៀងហូរច្រោះបំផ្លាញខឿនប្រាសាទ។ កត្តាបំផ្លាញប្រាសាទមួយទៀតគឺការបំផ្លាញរបស់ មនុស្ស។ ប្រទេសកម្ពុជាអូសបន្លាយដោយសង្គ្រាមផ្ទៃក្នុងបានធ្វើឲ្យមានអំពើចោរកម្មទៅលើប្រាសាទបុរាណ ការជីកកកាយរកវត្ថុបុរាណនៅតាមផ្នូរបុរាណ ការជីកគាស់ទួលគ្រឹះប្រាសាទ និងអំពើលួចវត្ថុបុរាណផ្សេងៗទៀត។ សកម្មភាពបែបនេះក៏មានកើតឡើងនៅប្រាសាទត្រពាំងប្រាសាទដែរ។ ក្រុមចោរលួចវត្ថុបុរាណបានគាស់ និងជីករកវត្ថុបុរាណក្នុងបរិវេណប្រាសាទ ធ្វើឲ្យខឿនប្រាសាទជ្រុងអាគ្នេយ៍។ ប្រហែលត្រូវក្រុមចោរលួចគ្រឿងស្ថាបត្យកម្មនៃប្រាសាទបានជាមិនមានក្នុងបរិវេណប្រាសាទ។

ការពុកផុយនៃប្រាសាទត្រពាំងប្រាសាទក៏រួមចំណែកកើតឡើងដោយសារបច្ចេកទេសសំណង់ដែរ។ តួប្រាសាទខាងជើង និងខាងត្បូងនៃប្រាសាទត្រពាំងប្រាសាទខាងត្បូងសង់លើខឿនប្រាសាទដែលខឿននោះមានទំហំតូច មិនអាចទ្រកម្លាំងសង្កត់របស់តួប្រាសាទបាន។ នៅពេលខឿនប្រាសាទសឹករិចរឹលដោយសារទឹកភ្លៀង ហូរច្រោះ តួប្រាសាទទាំងលែងមានលំនឹង ហើយទ្រេតទៅតាមទិសដែលខឿនប្រាសាទខូច។ តួខាងត្បូងទ្រេតរកកលនឹងរលំទៅទិសខាងត្បូង រីឯតួខាងជើងទ្រេតទៅទិសខាងជើង។

បើយើងមើលវិភាគទៅលើប្លង់នៃប្រាសាទ ប្រាសាទនេះគឺសង់ក្នុងរចនាបថកោះកេរ ឬប្រែរូប ក្នុងសតវត្សទី១០ គឺក្នុងរាជព្រះបាទជ័យវរ្ម័នទី៤ និងព្រះបាទ

ពជេន្ទ្រវរ្ម័នទី២។ នៅពេលព្រះជ័យវរ្ម័នទី៤ ប្ដូររាជធានីមករាជធានីកោះកេរ្ដិ៍ ព្រះអង្គបានពង្រីកឥទ្ធិពលរបស់ព្រះអង្គទៅភាគខាងជើង ក្នុងគោលបំណងគ្រប់គ្រងធនធានធម្មជាតិនៅតំបន់ភាគខាងជើង ជាពិសេសតំបន់ជួរភ្នំដងរែក។ ទោះបីព្រះបាទរាជេន្ទ្រវរ្ម័នទី២ប្ដូររាជធានីមកក្រុងអង្គរវត្ដិ ការរស់នៅរបស់មនុស្សដែលបន្ដពីព្រះបាទជ័យវរ្ម័នទី៤ នៅតែមាន។ ចំណែកប្រាសាទត្រពាំងប្រាសាទខាងជើង ប្រហែលជាមន្ទីរពេទ្យរបស់ព្រះបាទជ័យវរ្ម័នទី៧ កសាងក្នុងសតវត្សទី១៣។ ដោយសារភាពសម្បូណ៌បែបនៃធនធានធម្មជាតិនៅតំបន់ភាគខាងជើងជាពិសេសតំបន់ជួរភ្នំដងរ៉ែក ព្រះបាទជ័យវរ្ម័នទី៧ នៅបន្ដគ្រប់គ្រងតំបន់ទៀតដើម្បីប្រមូលផលពីធនធានធម្មជាតិពីតំបន់ខាងជើងនេះ។

## ឯកសារពិគ្រោះ

*មន្ត្រីវិទ្យាស្ថានវប្បធម៌និងវិចិត្រសិល្បៈ,*

*២០០៩"ការសិក្សាផ្ទៃលើស្ថានីយ និងការធ្វើផែនទីសារពើភ័ណ្ឌបុរាណវត្ថុ (ទួលបុរាណ) ក្នុងឃុំក្អាក់ ស្រុកអង្គស្នួល ខេត្តកណ្តាល" រាជបណ្ឌិត្យសភាកម្ពុជា។*

*កើត គឹមហៃ,*

*២០០៦"ប្រាសាទស្វាប់" ក្នុងសន្និសីទជាតិស្តីពី "អភិរក្សនិងអភិវឌ្ឍវប្បធម៌-សិល្បៈខ្មែរ" លើកទី៣, រាជបណ្ឌិត្យសភាកម្ពុជា។*

Etienne Aymonier,

1901 "Le Cambodge II Les Provinces Siamese", Paris.

Gilbert de Coral Rémusat,

1951 "L'Art Khmer Les grandes étapes de son évolution", Paris.

Lawrence Palmer Brigg,

1951 "The Ancient Khmer Empire" The American Philosophical Society, Independent Square Philadelphia 6.

Lunet De Lajonquière,

1907 "Inventaire Descriptive des Monuments du Cambodge", Tome dexième, Paris

National Committee for Sub-National Democratic Development (NCDD),

2009 "Trapeang Prasat District Data Book 2009" Otdor Meanchey Province.

# ភស្តុតាងបុរាណវត្ថុនៅស្ថានីយស្រែអំពិល

ដោយ៖ **ឯកឧត្តមបណ្ឌិត ផុន កសិកា**
ប្រធានវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម, រាជបណ្ឌិត្យសភាកម្ពុជា
និង លោក៖ ផុន ជាកុសល[1]
សមាជិកក្រុមប្រឹក្សាស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ

## សេចក្តីផ្តើម

ស្រែអំពិល គឺជាឈ្មោះភូមិមួយស្ថិតនៅក្នុងឃុំឈើទាល ស្រុកគៀនស្វាយ ខេត្តកណ្ដាល ហើយក៏ជាភូមិមួយបន្សល់ទុកគ្រឹះប្រាសាទយ៉ាងច្រើន ដែលនៅពាយពាសពេញបរិវេណនៃតំបន់ទាំងមូល ព្រមទាំងបំណែកកុលាលភាជន៍ ជាច្រើននៅពាយប៉ាយតាមទីទួលដែលអាចជាទិន្នន័យសម្រាប់សិក្សាស្រាវជ្រាវពីបុរាណវត្ថុវិទ្យា និងប្រវត្តិសាស្ត្រ នៅតំបន់នោះ។

ក្នុងកំឡុងពេលដែលប្រទេសកម្ពុជាស្ថិតក្រោមអាណានិគមបារាំង គឺជាពេលចាប់ផ្ដើមក្នុងការស្រាវ ជ្រាវតំបូងទាក់ទងទៅនឹងវិស័យបុរាណវត្ថុវិទ្យា។ អ្នកស្រាវជ្រាវជនជាតិបារាំងជាច្រើនបានសិក្សាកត់ត្រា និងឱ្យចំណាត់ថ្នាក់ដល់វត្ថុសិល្បៈ ស្ថានីយបុរាណវត្ថុវិទ្យា សិលាចារឹក ពិសេសប្រាង្គប្រាសាទចូលក្នុងបញ្ជីសារពើភ័ណ្ឌ ដូចជាលោក Lunet de Lajonquière, លោក E. Aymonier, លោក George Cœdès, លោក Henri Parmentier, លោក Jacque du Marçai, លោក Henri Marchal, លោក Phillipe Sterme...ជាដើម។

ដោយឡែកតំបន់ស្រែអំពិល ពុំទាន់ត្រូវបានទទួលការចាប់អារម្មណ៍ និងធ្វើការសិក្សាស្រាវជ្រាវណាមួយ ឱ្យមានលក្ខណៈល្អិតល្អន់ និងស៊ីជម្រៅគួរឱ្យកត់សម្គាល់នៅឡើយ។ ការសិក្សាខ្លះៗដែលធ្វើឡើងរួមមានការសិក្សា និងបកប្រែសិលាចារឹកមួយយកមកពីស្រែអំពិល ដោយអ្នកស្រាវជ្រាវជនជាតិបារាំង លោក **George Cœdès**។ លោក **Lunet de Lajonquière** និង លោក **E. Aymonier** បានធ្វើការសិក្សាវែកញែកពីសិលាចារឹកស្រែអំពិលដែលចុះក្នុងលេខបញ្ជីគឺ K.៧៧។ លោក **Robert Dalet** បានចូលរួមសិក្សាអំពីគ្រែទេសនៅ វត្តស្រែអំពិល។ ក្រោយមក មានបុរាណវត្ថុវិទូខ្មែរមួយចំនួនដូចជា សាស្ត្រាចារ្យ សឺន ស៊ូប៊ែរ្ត៍ បាន

[1] លោក ផុន ជាកុសល គឺជាអតីតនិស្សិតបុរាណវិទ្យា ជំនាន់ទី១០ នៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ។

សិក្សាបន្ត ដោយរៀបរាប់អំពីរចនាបថនៃវត្ថុសិល្បៈដែលប្រមូលបានពីតំបន់ស្រែអំពិល។ លោកសាស្ត្រាចារ្យ អាំង ជូលាន បានសិក្សាស្រាវជ្រាវអំពីរឿងព្រះគោព្រះកែវ ដែលទាក់ទងនឹងតំបន់ស្រែអំពិល។ ចំណែកលោក ព្រាប ចាន់ម៉ា៉ ក៏បានរួមចំណែកសិក្សា បង្ហាញពីតំបន់ប្រវត្តិសាស្ត្រមួយត្រូវបានទុកចោលគ្មានការសិក្សាស្រាវជ្រាវ។ ថ្វីត្បិតការ សិក្សាស្រាវជ្រាវលើរមណីយដ្ឋានស្រែអំពិលកន្លងមក មានទ្រង់ទ្រាយតូច តែអាចជាប្រភពទិន្នន័យមួយសម្រាប់ជាជំនួយដល់ការសិក្សាស្រាវជ្រាវពីអាយុកាលស្ថានីយនេះ។ ឆ្នាំ២០០៣ លោក ផុន ដាកុសល បានលើកយកប្រធានបទ "បុរាណដ្ឋានស្រែអំពិល" មកធ្វើការសិក្សាដើម្បី បញ្ចប់ថ្នាក់បរិញ្ញាបត្របុរាណវិទ្យារបស់លោក។ មួយឆ្នាំបន្ទាប់ទៀត ដោយមានជំនួយឧបត្ថម្ភរបស់ក្រុមហ៊ុនរថយន្តហ្វត (Ford Motor Company) លោក ផុន ដាកុសល បានធ្វើការសិក្សាចុះផ្ទាល់ដល់ទីកន្លែងដើម្បីគូរផែនទីស្ថានីយបុរាណវត្ថុវិទ្យា។ នៅឆ្នាំ២០០៦ និង២០០៧ ការងារនេះត្រូវបានធ្វើការសិក្សាបន្តទៀត ដោយអ្នកសិក្សាស្រាវជ្រាវបុរាណវត្ថុវិទ្យាមួយក្រុមដឹកនាំដោយលោក ផុន កសិកា ដោយបានទទួលការឧបត្ថម្ភពីមជ្ឈមណ្ឌលខេមរសិក្សា (Center for Khmer Studies) រយៈពេលពីរឆ្នាំ ដើម្បីសាងសង់សារមន្ទីរ និងកំណាយស្រាវជ្រាវនៅស្ថានីយស្រែអំពិល។



ក្នុងអត្ថបទនេះ គឺចង់បង្ហាញពីប្រវត្តិសាស្ត្រនៅស្ថានីយបុរាណវត្ថុវិទ្យាស្រែអំពិល ដោយផ្អែកលើទិន្នន័យ ដែលប្រមូលបានពីស្ថានីយ តាមរយៈការប្រមូលវត្ថុសិល្បៈនៅស្រទាប់លើនៃស្ថានីយ ដែលភាសាអង់គ្លេសថា (Surface Collection) រួមទាំងបុរាណអចលនវត្ថុ (Feature) មាននៅស្ថានីយនេះ។ តាមរយៈការសិក្សាបែប នេះ វិធីសាស្ត្រដែលយើងយកមកប្រើប្រាស់ដើម្បីកំណត់អាយុកាលនិងប្រវត្តិសាស្ត្ររបស់ស្ថានីយគឺវិធីសាស្ត្រប្រៀបធៀប (Relative Dating)។

បុរាណអចលវត្ថុនៅស្ថានីយស្រែអំពិលមានទួលគ្រឹះប្រាសាទ ដែលជាអតីតប្រាសាទបុរាណសង់ឧទ្ទិសដល់ព្រះផ្សេងៗក្នុងហិណ្ឌូសាសនា បច្ចុប្បន្នត្រូវបានដួលរលំនៅក្នុងសម័យកាលណាមួយដែលយើងមិនបានដឹង។ សម័យក្រោយមកទីនោះក៏ក្លាយជាដីទួលខ្ពស់ ជួនកាលមានគូទឹកព័ទ្ធជុំវិញ តែជួនកាលគ្មានគូទឹក។ នៅលើទួលគ្រឹះប្រាសាទរមែងមានសំណល់ឥដ្ឋប្រាសាទ និងថ្មភក់នៅរាយប៉ាយ។ ចំណែកឯវត្ថុសិល្បៈនៅលើស្ថានីយដែលយើង ប្រមូលបានដើម្បីសិក្សាស្រាវជ្រាវរួមមាន សិលាចារឹក ពូថៅថ្ម និងកុលាលភាជន៍។

### ១. បុរាណវត្ថុអចលត

បុរាណវត្ថុអចលត[2] ដែលយើងលើកយកមកបង្ហាញនៅទីនេះ គឺជាទួលបុរាណដែលអាចជាទីទួលសក្ការបូជា ឬទួលគ្រឹះប្រាសាទ និងទួលមនុស្សរស់នៅ។ តាមការសិក្សារបស់លោក ផុន ដាកុសល ដែលធ្វើការសិក្សាគូរផែនទីស្ថានីយបុរាណវត្ថុវិទ្យាក្នុងតំបន់នេះ ឃើញថាទួលនៅតំបន់នេះភាគច្រើនស្ថិតក្នុងភូមិ តាមបណ្ដោយផ្លូវលំក្នុងភូមិ ខ្លះនៅក្នុងព្រៃ ខ្លះនៅកណ្ដាលបឹង ឯខ្លះទៀតត្រូវបានឈូសឆាយពង្រាបឱ្យស្មើនឹងដីដើម្បីធ្វើថ្នល់ និងយកដីសង់លំនៅដ្ឋាន។ ទួលគ្រឹះប្រាសាទទាំងអស់មានចំនួនលើសពីចិតសិប(៧០)ទួល។ បើយើងមើលទីតាំងភូមិសាស្ត្របច្ចុប្បន្ន យើងឃើញថា ទីតាំងទួលទាំងនេះ ស្ថិតនៅលើភូមិសាស្ត្រមួយរាងខ្ពស់ ហើយពទ្ធ័ជុំវិញទៅដោយវាលស្រែ និងបឹងយ៉ាងធំល្វឹងល្វើយ។ ទួលទាំងអស់នោះ មានរាងជាទួលប្រាសាទមានតួទោល ឬទួលមានគ្រឹះប្រាសាទមានតួច្រើន។ ទួលមានគ្រឹះប្រាសាទទោលមានលក្ខណៈ ប្រហាក់ប្រហែលគ្នានឹងក្រុមប្រាសាទសម្បូរណ៍ព្រៃគុក ប៉ុន្តែហេតុអ្វីក៏នៅប្រាសាទសម្បូរព្រៃគុកនៅមានរូបរាងនៅឡើយ? ចុះហេតុអ្វីនៅទីនេះទួលនៃគ្រឹះប្រាសាទ យ៉ាងច្រើនពុំមាន

[2] ប្រភេទបុរាណវត្ថុដែលមិនអាចផ្លាស់ប្ដូរទីតាំងបាន មានដូចជាប្រាសាទ ឡកុលាលភាជន៍ គូទឹក ភូមិមូល ទួលប្រាសាទ ទួលគ្រឹះប្រាសាទ ជាដើម។

សំណង់ណាមួយមានរូបរាងជាប្រាសាទ។ ទួលមួយចំនួនមានឥដ្ឋបុរាណជាច្រើន ឯមួយចំនួនទៀតមិនឃើញមានសំណល់ឥដ្ឋ ឬស្នាមគ្រឹះប្រាសាទឡើយ។

យើងបានចែកទួលនៅតំបន់ស្រែអំពិលជាពីរប្រភេទ៖

### ១.១. ទួលគ្រឹះប្រាសាទ

ជាទូទៅទួលប្រភេទនេះសម្បូរឥដ្ឋបំផុត យើងឃើញមានពាសពេញទួល ហើយ ប្រសិនបើមានការភ្ជួររាស់ដើម្បីធ្វើចម្ការទៀតនោះ គឺឥដ្ឋដែលគេរើសគរទុកមានចំនួនច្រើនលើសលប់។ ទួលទាំងនេះក៏មានបំណែកកុលាលភាជន៍ផងដែរ។ ក្រៅពីឥដ្ឋ និងភាជន៍ យើងឃើញមានបំណែកស៊ុមទ្វារប្រាសាទ ប៉ុន្តែសរសរពេជ្រ និងផ្តែរដែលជាគ្រឿងលម្អសំណង់ប្រាសាទពុំបន្សល់ទុកនៅលើស្ថានីយឡើយ។



រូបលេខ១៖ ទួលគ្រឹះប្រាសាទ

### ១.២. ទួលមនុស្សរស់នៅ

ទួលមួយប្រភេទនេះ គ្មានស្នាមគ្រឹះប្រាសាទទេ តែមានបំណែកភាជន៍ និងរបស់របរប្រើប្រាស់ផ្សេងៗ ហើយមានទំហំធំជាងទួលដែលមានឥដ្ឋ។ ដូច្នេះទួលនេះទំនងមិនមែនជាទីតាំងប្រាសាទទេ ប្រហែលជាទីតាំងលំនៅស្ថានរបស់មនុស្សទៅវិញ។



រូបលេខ២៖ ទួលយាយរិនជាប្រភេទទួលមនុស្សរស់នៅ

## ២. វត្ថុសិល្បៈ

### ២.១. ពូថៅថ្ម

ស្រែអំពិលជាស្ថានីយដែលមានសំណល់ឧបករណ៍ថ្មដល់ទៅ៦ (អ្នកស្រុកនិយមហៅថាគ្រាប់រន្ទះ) ដែលយើងចែកជាពីរគឺពូថៅ និងដឹង សព្វថ្ងៃស្ថិតនៅក្នុងមជ្ឈមណ្ឌលកុមារកំព្រាសន្តិភាព។ ឧបករណ៍ទាំងពីរជាប្រភេទដឹង ដែលឧបករណ៍រាងវែងធ្វើអំពីថ្មម៉ាប មានប្រវែង២៥ ទៅ៣០ សង់ទីម៉ែត្រ (មានស្នាមបែកបាក់)។ ថ្មប្រភេទនេះ យើងមិនដែលប្រទះសោះក្នុងការយកមកប្រើជាឧបករណ៍ថ្ម ដោយហេតុថាកម្រ

នឹងមានថ្មប្រភេទនេះណាស់នៅប្រទេសកម្ពុជា។ ហើយម្យ៉ាងទៀតជាប្រភេទថ្មងាយបាក់បែក។ វាប្រហែលជាមិនមែនធ្វើឡើងដើម្បីប្រើប្រាស់នោះទេ ប្រហែលជាការធ្វើនៅសម័យក្រោយ ដើម្បីតំណាងឱ្យវត្ថុសក្តិសិទ្ធអ្វីមួយ ដោយសារគេជឿថាជាគ្រាប់រន្ទះ។ យើងពុំមានឃើញស្នាកស្នាមនៃការប្រើប្រាស់ទេ។

ឧបករណ៍មួយទៀត ទំនងជាប្រភេទដឹងខ្វីធ្វើអំពីថ្ម ដែលមានស្នាកស្នាមនៃការប្រើប្រាស់មានលក្ខណៈដូចទៅនឹងឧបករណ៍ថ្មនៅស្ថានីយក្រែកមេមត់ ខេត្តកំពង់ចាម។

ចំណែកឯឧបករណ៍ពីរទៀតដែលនៅនឹងផ្ទះ យាយ រិន អ្នកស្រុកនៅទីនេះរើសពីទួលយាយខាន់។ ឧបករណ៍ ថ្មទាំងពីរនេះជាប្រភេទពូថៅធ្វើពីថ្មបាសាល់ដែលមានស្នាកស្នាមនៃការប្រើប្រាស់ ហើយក៏ជាប្រភេទឧបករណ៍ ដែល ដូចទៅនឹងឧបករណ៍ថ្មនៅស្ថានីយក្រែកមេមត់ដែរ។

ចំពោះការរកឃើញពូថៅថ្មទាំងអស់គឺសុទ្ធតែរើសបាននៅទីទួល ឬដោយការជីកកកាយ។ យើងមិនអាចដឹងថាជាសំណល់ដែលមនុស្សបុរេប្រវត្តិប្រើប្រាស់នៅក្នុងតំបន់នេះ ឬដោយសារការនាំយកមកដោយរបស់មនុស្ស សម័យក្រោយនោះទេ។ ប៉ុន្តែដោយសារមានសំណល់នៃឧបករណ៍ប្រើប្រាស់ប្រភេទពូថៅថ្មនេះរហូតដល់ទៅ៦ដែលរកឃើញ យើងគិតថាអាចជារបស់ដែលមាននៅក្នុងតំបន់នេះច្រើនជាង។ ដូច្នេះស្ថានីយស្រែអំពិលដែលមានវត្ថុថ្មសម័យបុរេប្រវត្តិ ក៏អាចជាស្ថានីយបុរេប្រវត្តិសាស្ត្រមួយដែរ។



រូបទី៣៖ ពូថៅ



រូបទី៤៖ ពូថៅថ្ម

## ២. ២. សិលាចារឹក

សិលាចារឹកជាប្រភពព័ត៌មានមួយដ៏សំខាន់សម្រាប់ការសិក្សាប្រវត្តិសាស្ត្រខ្មែរបុរាណ។ តាមការស្រាវជ្រាវរបស់លោក Claudes Jacque បានឱ្យដឹងថា សិលាចារឹកខ្មែរមានចំនួនសរុបទាំងអស់១១៥០ផ្ទាំង សរសេរជាពីរភាសាគឺភាសាសំស្ក្រឹត និងភាសាខ្មែរ (Claude Jacques ១៩៩៧៖ ទំព័រ ១)។

ចំពោះស្ថានីយស្រែអំពិល ពុំមានបន្សល់អ្វីខាន់ឱ្យដឹងពីប្រវត្តិសាស្ត្រ និងអាយុកាលស្ថានីយនោះទេ លើកលែងតែសិលាចារឹកដែលរកឃើញដោយក្រុមសាលាបារាំងចុងបូព៌ា (EFEO) និងសិលាចារឹករកឃើញដោយកុមារកំព្រានៅមជ្ឈមណ្ឌលកុមារសន្តិភាពស្រែអំពិល។ សិលាចារឹកទាំងពីរ គឺជាទិន្នន័យយ៉ាងសំខាន់សម្រាប់សិក្សាវិភាគពីតួអក្សរ ស្ថាននាម ឋានន្តរនាម ព្រះ

នាមរបស់ព្រះជា ក៏ដូចជាកាលបរិច្ឆេទនៃសិលាចារឹកដែរ។

### ក. សិលាចារឹក K.៧៧

កាលពីឆ្នាំ១៩៣៩ ក្រុមស្រាវជ្រាវសាលាបារាំងចុងបូព៌ា (EFEO) បានចុះធ្វើការស្រាវជ្រាវពីវិស័យបុរាណវត្ថុវិទ្យាតាមដងទន្លេមេគង្គធ្វងកាត់តំបន់ស្រែអំពិល ក៏ប្រទះឃើញវត្ថុបុរាណខ្លះ (បច្ចុប្បន្នរក្សាទុកក្នុងវត្តស្រែអំពិល) និងសិលាចារឹកមួយផ្ទាំងត្រូវបានដឹកយកមកទុកនៅវត្តបុទុមវត្តី។

តាមលោក E. Aymonier ដែលបានសិក្សាពីសិលាចារឹកនៅក្នុងវត្តបុទុមវត្តីក្រុងភ្នំពេញ បង្ហាញថា ក្នុងសិលាចារឹកដែលមានក្នុងវត្ត មានសិលាចារឹកមួយយកមកពីស្ថានីយស្រែអំពិល (Cœdès 1953 : 46) ចុះបញ្ជីសារពើភណ្ឌ K.៧៧ រៀបរាប់ពីការធ្វើស្រែចម្ការ ទាសាទាសី និងការប្រទានដង្វាយរបស់អទិទេព។

អត្ថន័យសិលាចារឹកគឺ (Lim Siv Choan 1970: 18)៖ ព្រះមហាក្សត្រ និងប្រជារាស្ត្រមានសេចក្តីរីករាយនឹងការកសាងពិភពឱ្យដល់ព្រះហរិ (ព្រះនារាយណ៍) ដើម្បីឱ្យការពារទ្វីបបសុបទិ (*Paçupati*)។ ដំបូងឡើយមានព្រាហ្មណ៍ឈ្មោះ ធូលិ (*Dhuli*) ដែលជាព្រាហ្មណ៍ចាស់ជាងគេមានតួនាទីចាត់ចែងនិងផ្គត់ផ្គង់ឱ្យដល់ព្រាហ្មណ៍ដទៃ ព្រមទាំងការងារប្រតិបត្តិសាសនា ចាត់ចែងតាមការប្រកាសរបស់បសុបទិ (*Paçupati*) ដើម្បីគោរពបូជាដល់ព្រះគោ ហើយបន្ទាប់មកព្រាហ្មណ៍ទាំងអស់ត្រូវសាងលិង្គសម្ភុ (*çambhu*) ដើម្បីធ្វើពិធីសាសនា ដែលគេបានផ្តល់ឱ្យសិទ្ធេស្វរៈ (*Siddheçvara*) នូវទ្រព្យសម្បត្តិគ្រប់បែបយ៉ាងផ្ទាល់ខ្លួន ដែលចាប់ពីអ្នកស្រែ និង ទាសកររហូតដល់មន្ត្រី។ ចំពោះសិលាចារឹកនេះនៅមានភាពស្មុគស្មាញនៅឡើយ តម្រូវឱ្យមានការសិក្សាស្រាវជ្រាវជាច្រើនលើកច្រើនសារ ព្រោះថាពេលដែលគេឃើញសិលាចារឹកនៅក្នុងវត្តបុទុមវត្តី គឺទាំងអស់មានបីផ្ទាំង ដែលមានចុះបញ្ជីរៀងៗខ្លួន ហើយក៏ដឹងប្រភពច្បាស់លាស់ដែរ គឺមួយមកពីភ្នំបាសិត មួយមកពីស្រែអំពិល និងមួយទៀតមកពីលង្វែក (E. Lunet de Lajonquière 1902: 82)។ ក្នុងចំណោមសិលាចារឹកទាំងបីនេះ សិលាចារឹកលង្វែកមានតឹកតាងបញ្ជាក់ពីប្រភពច្បាស់លាស់ជាងគេ ប៉ុន្តែសិលាចារឹកបាសិតនិងស្រែអំពិលនៅមានការភាន់ច្រលំគ្នានៅឡើយ ព្រោះថាក្នុងចំណោមសិលាចារឹកទាំងពីរនេះ មានមួយត្រូវបានបាត់បង់ ហើយសិលាចារឹកដែលនៅនេះ គឺសិលាចារឹកស្រែអំពិល (G. Cœdès 1953: 46)។ ប៉ុន្តែ លោក ហង់រី ប៉ាម៉ង់ជេ (Henri Parmentier) បានអះអាងថាជាសិលាចារឹកដែលយកមកពីភ្នំបាសិតទៅវិញ ព្រោះនៅក្នុងអត្ថបទសិលាចារឹកបង្ហាញពីឈ្មោះ សិទ្

ធេស្វរ (Siddheçvara) ជាប្រភពច្បាស់ បង្ហាញពីភ្នំបាសិត។ បើតាមលោក លុយណេ ដឺ ឡាហ្សង់គៀ (Lunet de La jonquière) បានបញ្ជាក់អំពីលក្ខណៈ និងទម្រង់នៃសិលាចារឹកទាំងនោះថាអត្ថបទសិលាចារឹកមកពីស្រែអំពិលមាន១៦បន្ទាត់ ឯសិលាចារឹកមកពីភ្នំបាសិតមាន២៩បន្ទាត់ មានវត្ថុធាតុ និងទំហំនៃថ្មមានលក្ខណៈ ដូចគ្នា (E. Lunet de Lajonquière 1902: 82)។

## ខ. សិលាចារឹកដែលមានពាក្យ កុ និង វា

សិលាចារឹកមួយផ្ទាំងនេះ លោក ផុន ជាកុសល បានប្រទះឃើញនៅទួលរំលេច។ សិលាចារឹកនេះត្រូវបានវាយកម្ទេច នៅពេលដែលមានការជីកកកាយ ដោយនៅសល់តែបំណែកថ្មតូចមួយ មានតួរអក្សរតែពីរប៉ុណ្ណោះ គឺ "កុ" និង "វា"។ "កុ" មានន័យថាជា «នារី ស្រ្តី ប្រពន្ធ» ជាពាក្យសម្រាប់ហៅនារី ដែលជាអ្នកបម្រើនៅប្រាសាទ ឬវិហារនានា។ ចំណែកឯពាក្យ "វា" មានន័យថា «ប្រុស បុរស» ពាក្យប្រើសម្រាប់ ហៅអ្នកបំរើភេទប្រុស នាសម័យមុនអង្គរ (ឡុង សៀម ២០០០៖ ៥១៦)។



រូបទី៥៖ បំណែកសិលាចារឹកមានពាក្យ កុ និង វា

## គ. សិលាចារឹកដែលរកឃើញដោយកុមារសន្តិភាពស្រែអំពិល

សិលាចារឹកមួយផ្ទាំងទៀត សរសេរជាភាសាសំស្រ្កឹតរកឃើញដោយកុមារសន្តិភាពស្រែអំពិល នៅត្រង់ម្តុំទួលក្រសាំង។ សិលាចារឹកនេះធ្វើអំពីថ្មស៊ីស ឬថ្មថ្មើមអណ្តើក។ សិលាចារឹកនេះគឺជាសិលាចារឹករកឃើញថ្មី មិនទាន់បានចុះក្នុងបញ្ជីសារពើភណ្ឌនៅឡើយទេ។ តាមលក្ខណៈអក្សរដែលកំណត់ឱ្យដឹងពីកាលបរិច្ឆេទគឺជាទម្រង់អក្សរនៅក្នុងសតវត្សទី៧ ឬទី៨ (Son Soubert, 2000, p.237) ព្រមទាំងមានព្រះនាមរបស់ព្រះរាជា ព្រះបាទភវវរ្ម័នទី២ និងជ័យវរ្ម័នទី១។

សិលាចារឹកនេះប្រហែល ជាចារនៅក្នុងរាជ្យស្តេចជ័យវរ្ម័នទី១ ដើម្បីរំលឹកដល់ព្រះបាទភវវរ្ម័នទី២។ ម៉្យាងទៀតនៅក្នុងអត្ថបទនេះ ក៏បានបង្ហាញពីការឧទ្ទិសបូជារបស់ព្រះមហាក្សត្រ ចំពោះព្រហ្មញ្ញ

ញសាសនា[3] និងបញ្ជាក់ឱ្យដឹងថាទីនេះជាជម្រុកនៃគ្រាប់ធញ្ញជាតិ (ជាន្យ)។

ក្រៅពីសិលាចារឹករកឃើញនៅតំបន់ស្រែអំពិល ដែលមានព្រះនាមមហាក្សត្រទាំងពីរអង្គរនេះ គឺនៅមានសិលាចារឹកនៅលើស៊ុមទ្វារបញ្ឈរប្រាសាទ N20 នៃក្រុមប្រាសាទខាងជើង (សម្បូរណ៍ព្រៃគុក) ចុះក្នុងបញ្ជី សារពើភណ្ឌ K.៤៣៩ ដោយលោក Henri Parmentier ឆ្នាំ១៩១១ (G. Cœdès 1952 : 30) សរសេរជាភាសាសំស្ក្រឹត និងកំណាព្យក្នុងរាជ្យព្រះបាទជ័យវរ្ម័នទី១ រៀបរាប់ពីខ្សែស្រឡាយរបស់ព្រះបាទភវវរ្ម័នទី២ និងការប្រារព្ធពិធី នៅក្នុងប្រាសាទនេះដោយតម្កល់ព្រះសីវលិង្គមានឈ្មោះថា ប្រភាសោមេស្វរ (Prabhasomeçvara)។ តាមរយៈសិលាចារឹកនេះឃើញថា មានលក្ខណៈដូចគ្នានឹងសិលាចារឹកស្ថានីយស្រែអំពិល គឺសិលាចារឹកនៅវត្តបុទុមវត្តី និង សិលាចារឹកដែលប្រទះឃើញនៅនឹងស្ថានីយដែលនិយាយពីការបញ្ជារបស់ព្រះមហាក្សត្រទៅព្រាហ្មណ៍ឈ្មោះ ធូលី ឱ្យរៀបចំពិធីតែងតាំងព្រះនាមព្រះសីវលិង្គថា សិទ្ធីស្វរ (Siddheçvara) និងពីការធ្វើដង្វាយ។ សិលាចារឹកដែលរកឃើញនៅនឹងកន្លែងក្នុងពេលថ្មីៗនេះមានបង្ហាញពីព្រះនាមក្សត្រទាំងពីរ គឺព្រះបាទជ័យវរ្ម័នទី១ ចារសិលាចារឹកដើម្បីរំលឹកដល់ព្រះបាទភវវរ្ម័នទី២ ដែលជាបិតា។

សរុបសេចក្តីមក ទិន្នន័យដែលបានមកពីស្ថានីយនេះតាមរយៈសិលាចារឹក គឺជាតឹកតាងមួយអាចបញ្ជាក់បានថាជាស្ថានីយមានកាលបរិច្ឆេទក្នុងសម័យមុនអង្គររវាងសតវត្សទី៧-៨ ក្នុងរាជ្យព្រះបាទជ័យវរ្ម័នទី១។



រូបទី៦៖ បំណែកសិលាចារឹករកឃើញដោយកុមារសន្តិភាពស្រែអំពិល

## ២. ៣. កុលាលភាជន៍

គឺជាប្រភេទវត្ថុដែលគេប្រើសម្រាប់ផ្ទុកគ្រឿងម្ហូបអាហារ ទឹក និងស្រា ដែលប្រើសម្រាប់ជីវភាពប្រចាំថ្ងៃ ឬនៅក្នុងពិធីសាសនា។ ក្រៅពីនេះក៏មានប្រភេទកុលាលភាជន៍ដែលគេប្រើប្រាស់សម្រាប់សំណង់ស្ថាបត្យកម្ម ដែរ ដូចជា រងស្បូវ ព្រំ

[3] តាមការបកប្រែរបស់លោកសាស្ត្រាចារ្យបណ្ឌិត ឡុងសៀម: នៅក្នុងបន្ទាត់ទីប្រាំ គឺពាក្យ សម្មាន មានន័យថាដង្ហើមចេញ (ជាចលនាដង្ហើមមួយកង្ហំចំណោមដង្ហើមទាំងប្រាំពីរក្នុងព្រហ្មញ្ញសាសនា)។

ដំបូល គ្រឿង ។ល។ បច្ចេកទេសផលិតកុលាលភាជន៍អំពីដីដុតត្រូវបានគេស្គាល់នៅជុំវិញពិភពលោក ចាប់តាំងពីមនុស្សមានការចាប់ផ្ដើមជីវិតរស់នៅដ៏ជាក់លាក់។

លោក B. Groslier យល់ថាការដុតភាជន៍នៅសម័យសម្បូរណ៍ព្រៃគុកប្រហែលជាគេមិនប្រើឡទេ (អាំង ជូលាន ២០០០៖ ១៩៥-១៩៨)។ ក្នុងន័យនេះចង់បញ្ជាក់ថាស្រែអំពិលប្រហែលជាកន្លែងធ្វើ និងដុតកុលាលភាជន៍ ថ្វីត្បិតតែយើងគ្មានស្នាកស្នាមណាមួយបញ្ជាក់ថាមានឡ ប៉ុន្តែយើងបានជួបប្រទះនូវឧបករណ៍ សម្រាប់ធ្វើកុលាលភាជន៍។

ម្យ៉ាងទៀត ឃុំឈើទាលស្ថិតជាប់នឹងឃុំមួយគឺ ឃុំដីឥដ្ឋ បើយើងគិតពីពាក្យដីឥដ្ឋគឺមាននៅតំបន់ផ្សេងៗប៉ុន្តែនៅទីនេះប្រហែលជាដីឥដ្ឋមានលក្ខណៈពិសេសអ្វីមួយ។ ដូចយើងដឹងស្រាប់ហើយថា ប្រជាពលរដ្ឋខ្មែរហៅតំបន់ ណាមួយដោយយោងទៅតាមការនិយមហៅតៗគ្នា តាមរយៈគ្រាមភាសា ឬយោលទៅលើអ្វីដែលមានហើយឃើញ ជាក់ស្ដែង។ បំណែកកុលាលភាជ៍ទាំងនោះមាន ថូ ផើង ពែង ខួច ក្អម ឆ្នាំង ខ្លះតូច ខ្លះធំ ខ្លះក្រាស់ ខ្លះស្ដើង ខ្លះមានក្បាច់ លម្អ និងខ្លះទៀតមានស្រទាប់រលោងពណ៌បៃតង និងពណ៌ត្នោត។ កន្លងមកគេបានជួបប្រទះតំបន់ដែលមានកុលាលភាជន៍បុរាណ ដូចជា ក្រែក មេមត់ (កំពង់ចាម) បាភ្នំ (ព្រៃវែង) តានី (សៀមរាប) អង្គរបុរី (តាកែវ) ជើងឯក (រាជធានីភ្នំពេញ) ដែលកន្លែងខ្លះមានឡសម្រាប់ដុត ដូចជានៅតំបន់តានី និងជើងឯកជាដើម។



រូបទី៥៖ ឆ្នាំង

យើងសូមប្រៀបធៀបប្រភេទកុលាលភាជន៍ខ្លះ ដែលធ្លាប់ឃើញប្រហាក់ប្រហែលនៅនឹងភាជន៍នៅតំបន់អង្គរ ដែលមាន រូបរាងជាខួច គម្រប ជន្ទាប់ និងប្រភេទផ្សេងៗទៀតជាច្រើនដែលមានស្រទាប់រលោង។

ចំណែកឯកុលាលភាជន៍មួយប្រភេទទៀត ដែលយើងជួបប្រទះនៅនឹងស្ថានីយ ហើយមានលក្ខណៈប្រហាក់ប្រហែលទៅនឹងភាជន៍នៅអង្គរបុរី។ ឯមួយប្រភេទទៀតយើងប្រហែលគេប្រើប្រាស់ក្នុងពិធីនៃសាសនា ហើយក៏ប្រហែលជាត្រូវបានកប់ជាមួយសព (នៅពេលដែលគេកាយយកដីដើម្បីទប់ទំនប់)។ គេក៏ប្រទះឃើញប្រភេទនេះជាមួយ ឆ្នឹង ភាជន៍តូចៗ សម្រាប់សំណៃន មានកូនក្អម និងពែង ទាំងអស់នេះសុទ្ធតែធ្វើពីដីដុត

ដែលស្ថិតនៅក្នុងជម្រៅ ប្រហែល៣ម៉ែត្រ។ ចំណែកឯភាជន៍មួយប្រភេទទៀត ដែលជួបប្រទះនៅស្រែអំពិលដែរ មានរូបរាង និងសមាសភាពប្រហាក់ប្រហែលនឹងកុលាលភាជន៍ដែលលោក John N. Miksic បានបង្ហាញនៅក្នុងអត្ថបទរបស់លោក (Miksic 1984: 63) គឺជាប្រភេទកុលាលភាជន៍ដែលធ្វើពីដីឥដ្ឋលាយជាមួយក្វាតមានទំហំគ្រាប់ចាប់ពី១ទៅ២មីលីម៉ែត្រមានសភាពគ្រើមមិនសូវរលោង ដុតនៅសីតុណ្ហភាពទាប។

## ២.៤. ឥដ្ឋប្រាសាទ

ឥដ្ឋជាវត្ថុសំណង់ប្រាសាទយ៉ាងសំខាន់បំផុត សម្រាប់ជាគ្រឿងរចនាសម្ព័ន្ធប្រាសាទ។ គេប្រើធ្វើជាខឿន សសរ ជញ្ជាំង ដំបូល និងក្បាច់លម្អផ្សេងៗ។ ឥដ្ឋដែលយើងជួបប្រទះនៅក្នុងតំបន់នេះជាប្រភេទដីដុតឆ្អិនមានពណ៌ទឹកក្រូច ប្រផេះដែលមានលាយគ្រាប់ខ្សាច់តូចៗ និងគ្រួសល្អិត។ ទំហំឥដ្ឋមានលក្ខណៈខុសៗគ្នាទៅតាមតម្រូវការប្រើប្រាស់ក្នុងសំណង់។ ឥដ្ឋខ្លះមានបណ្តោយទំហំចាប់ពី២៦រហូតដល់៣០សង់ទីម៉ែត្រ ដែលទំហំនេះប្រហាក់ប្រហែលទៅនឹង ឥដ្ឋនៅប្រាសាទជ្រៃ (សម្បូរព្រៃគុក ខេត្តកំពង់ធំ)។ ឥដ្ឋមួយចំនួនទៀតមានក្បាច់ចម្លាក់ដូចនៅសម្បូរណ៍ព្រៃគុក មានលក្ខណៈផុយជាងឥដ្ឋដែលប្រើជាជញ្ជាំង ឬខឿន ដោយសារមានសមាសធាតុខ្សាច់យ៉ាងច្រើន មានបណ្តោយ២៤ សង់ទីម៉ែត្រ ទទឹង១៤.៥ សង់ទីម៉ែត្រ និងកម្រាស់៧ សង់ទីម៉ែត្រ។ លក្ខណៈនៃឥដ្ឋដែលប្លែកនៅទីនេះ គឺមានសញ្ញាសម្គាល់រាងអក្សរ "ក" សម័យទំនើប។ ឥដ្ឋប្រភេទនេះមានប្រវែងបណ្តោយ ៣០.៥ សង់ទីម៉ែត្រ ទទឹង១៦.៥ សង់ទីម៉ែត្រ ឯកម្រាស់វិញ ៨សង់ទីម៉ែត្រ។ មានសញ្ញាសម្គាល់លើឥដ្ឋខ្លះផ្សេងទៀត យើងមើល ពុំយល់។ យើងបានជួបប្រទះឥដ្ឋទាំងនោះដោយចៃដន្យនៅពេលដែលម្ចាស់ទួលឈូសឆាយធ្វើលំនៅដ្ឋាន។

ចាប់តាំងពីមានការសិក្សាស្រាវជ្រាវរហូតដល់បច្ចុប្បន្ន ពុំមានឯកសារ ឬអ្នកស្រាវជ្រាវណាមួយសិក្សារបង្ហាញអំពីបច្ចេកទេសនៃការផលិតឥដ្ឋនៅឡើយទេ។ តើគេអាចដុតឥដ្ឋជាមួយភាជន៍ដែរឬទេ? ទើបបានជាឥដ្ឋមានជាប់ស្រទាប់រលោងដូច្នេះ?



រូបទី៦៖ ឥដ្ឋប្រាសាទ

# សន្និដ្ឋាន

ជាសេចក្តីសន្និដ្ឋាន ភូមិស្រែអំពិល ឬតំបន់ស្រែអំពិល គឺជាស្ថានីយបុរាណវត្ថុវិទ្យា ឬស្ថានីយប្រវត្តិសាស្ត្រ ដែលបង្កប់នូវប្រវត្តិសាស្ត្រដ៏យូរអង្វែងចាប់តាំងពីសម័យបុរេប្រវត្តិសាស្ត្រ សម័យមុនអង្គរ សម័យអង្គរ និងសម័យបច្ចុប្បន្ន។

ដោយហេតុថាប្រទេសកម្ពុជា ជាប្រទេសមួយដែលមានសង្គ្រាមរ៉ាំរ៉ៃជាច្រើនជំនាន់ និងច្រើនទសវត្សមកនោះ ធ្វើឱ្យស្ថានីយបុរាណវត្ថុវិទ្យាស្រែអំពិលរងការបំផ្លាញ។ ជាពិសេសក្នុងកំឡុងឆ្នាំ១៩៧០ រហូតដល់ឆ្នាំ១៩៧៩ ដោយសារសង្គ្រាមបានបង្ករឱ្យមានរណ្តៅគ្រាប់កាន់ជាច្រើនស្ថិតនៅក្នុងទីតាំងនៃស្ថានីយ។ សំណង់អាគាររមណីយដ្ឋាន បុរាណដ្ឋាន នានាក្នុងប្រទេសត្រូវរងនូវការខូចខាត និងបំផ្លាញ ។

មនុស្សក៏ជាមូលហេតុនាំឱ្យមានការបំផ្លាញកាន់តែខ្លាំង ព្រោះក្រោយពីត្រូវបានបោះបង់មួយរយៈកាលមក ប្រជាពលរដ្ឋបានមកតាំងលំនៅដ្ឋានជាថ្មី និងពង្រីកដី ធ្វើកសិកម្មនៅលើទីតាំងទួលតែម្តង។ ការជីកកកាយយកឥដ្ឋ ដើម្បីការប្រើប្រាស់ផ្សេងៗ ព្រមទាំងជីកគាស់កកាយរកវត្ថុបុរាណដែលកប់នៅក្នុងទីទួល គឺធ្វើឱ្យបាត់បង់នូវវត្ថុសិល្បៈ និងបំផ្លាញទ្រង់ទ្រាយដើមរបស់ទួលទាំងស្រុង។ ជួនកាលគេបានប្រទះឃើញវត្ថុសិល្បៈនៅពេលធ្វើកសិកម្ម ក៏ប៉ុន្តែពួកគេបានលក់វត្ថុទាំងនោះទៅឱ្យឈ្មួញ។ ថ្មីៗនេះមានគ្រួសារមួយក្នុងភូមិស្រែអំពិលបានពង្រីកដី ដើម្បីសាងសង់ផ្ទះក៏បានប្រទះឃើញលិង្គ និងស្នាទ្រានី ប៉ុន្តែគួរឱ្យសោកស្តាយ ដែលពួកគាត់បានលក់វត្ថុ ទាំងនោះមុនពេលក្រុមការងារបានចុះទៅដល់។

ការអភិវឌ្ឍន៍ ជាបញ្ហាសំខាន់ដែលនាំឱ្យមានការខូចខាតដល់ស្ថានីយផងដែរ។ ជាក់ស្តែងមានផ្លូវមួយខ្សែ បានស្កាបនាកាត់ទួលជាច្រើន ជាហេតុនាំឱ្យសំណល់នៃគ្រឹះប្រាសាទ និងទួលទាំងនោះឈានទៅរកការបាត់បង់។

ស្ថានីយបុរាណវត្ថុស្រែអំពិល គឺជាប្រភពទិន្នន័យដ៏សំខាន់ក្នុងការប្រមូល និងផ្តល់ព័ត៌មានអំពីការតាំងទីរបស់មនុស្ស វប្បធម៌ អារ្យធម៌ និងការធ្វើជំនួញនៅសម័យបុរាណ។ ស្ថានីយនេះចាំបាច់ត្រូវធ្វើការសិក្សាស្រាវជ្រាវ និងសង្គ្រោះឱ្យផុតពីការបំផ្លាញ។ សំខាន់ជាងនេះទៅទៀត ទិន្នន័យដែលកប់ក្នុងដីត្រូវចាំបាច់ធ្វើការសិក្សាឱ្យបានហ្មត់ចត់ដោយអ្នកជំនាញ និងមានបច្ចេកទេសផ្នែកបុរាណវិទ្យាដើម្បីយល់ដឹងឱ្យច្បាស់ពីវប្បធម៌ដ៏ចំណាស់ និងការវិវត្តរបស់ស្ថានីយ។

## ឯកសារពិគ្រោះ


- ផុន កសិកា

២០០២ "ស្ថានីយបុរាណនៅតំបន់ជើងឯក" និក្ខេបបទថ្នាក់បរិញ្ញាប័ត្រជាន់ខ្ពស់ ភ្នំពេញ

- ព្រាប ម៉ារ៉ា

ខែវិច្ឆកា ២០០០ "បុរាណដ្ឋានស្រែអំពិល" អត្ថបទចុះផ្សាយក្នុងព្រឹត្តិបត្រនិស្សិតមហាវិទ្យាល័យ បុរាណវិទ្យាលេខ១

- ឡុង សៀម

១៩៩៧ "ស្ថាននាមវិទ្យាខ្មែរ" ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត ភ្នំពេញ ព.ស ២៥២១ គ្រិស្តសករាជ

- អាំង ជូលាន

២០០០ ទស្សនាវដ្ដីឧទ័យថ្មី លេខ១ ទំព័រ ១៥៥- ១៩៨។

- អាំង ជូលាន អេរិកប្រេណ្ជវិក្ស អាស៊ី ចមសុន

១៩៩៨ "អង្គរ អតីត-បច្ចុប្បន្ន-អនាគត" អាជ្ញាធរអប្សរា

- **Ang Choulean,**

1997 *Angkor et dix Siècles d'art khmer.*

- **Boisselier Jean,**

1966 *Le Cambodge,* Tome I, Paris.

- **Dalet Robert,**

1935, Dix-huit mis de rechercher archéologie du Cambodge, *BEFEO*, Volume XXXV, fac 1, Paris.

- **E. Lunet de Lajonquière,**

1902 *Inventaire Descriptif de Monument du Cambodge,* Tome I, Paris.

- **E. Aymonier,**

1900 *Le Cambodge,* Tome I, Paris.

- **G. Cœdès,**

1953 *Inscription du Cambodge,* BEFEO, Volume V, Paris.

1964 *The Indianized States of Southeast Asia,* Paris.

*Inscription du Cambodge,* BEFEO, Tome IV, fasc.2, Paris.

1964 *The Indianized States of Southeast Asia,* Paris.

**- John N. Miksic,**

1984 *Archeaological Rechearch on The "Forbidden Hill of Singapore: Excavations at Fort Canning",* National Museum Singapore.

**- Lim Sivchoan,**

1970 *Memoire de Fin D'étude de Licence Monographie du Phnom Baset.*

**- Lawrance Palmer Briggs,**

1951 *The Ancient Khmer Empire,* Volume XXXXI, Part I.

# ទិដ្ឋភាពមួយចំនួន ស្ដីពី មេដឹកនាំ

( Some Overviews on Leaders )

*ដោយៈ ឯកឧត្តមបណ្ឌិត* **អ៊ុំ ប៉ុម**
*ជំនួយការរាជបណ្ឌិត្យសភាកម្ពុជា*

**សេចក្ដីផ្ដើម**

*ជាទូទៅបើគេនិយាយពីធម្មជាតិ នៃការរស់នៅ របស់មនុស្សក្នុងសង្គមគេតែងតែជួបប្រទះនឹងមនុស្សពីរប្រភេទ ដែលមានឋានៈសង្គមខុសប្លែកគ្នា ពោលគឺ មនុស្សមួយប្រភេទមានឋានៈជាមេដឹកនាំ ហើយមនុស្សមួយប្រភេទទៀតជាអ្នកនៅក្រោមបង្គាប់។ ជាធម្មតាមនុស្សទាំងពីរប្រភេទនេះតែងរស់នៅជាមួយគ្នា មានទំនាក់ទំនងគ្នា ក្រោមកិច្ចសន្យាសង្គមមួយច្បាស់លាស់។ ដោយឡែកបើគេនិយាយពីបរិមាណវិញ ក៏យ៉ាងនេះដែរ មនុស្សចាប់ពីបីនាក់ឡើងទៅជាក្រឹត្យក្រមត្រូវមានមនុស្សម្នាក់ធ្វើជាមេដឹកនាំ អាស្រ័យទៅលើការស្រុះស្រួលគ្នារបស់អ្នករស់នៅក្នុងក្រុម។ ដូច្នេះ ទាក់ទងទៅនឹងបញ្ហាមេដឹកនាំសំណួរអាចចោទសួរឡើងថា តើមេដឹកនាំជានរណា? មានលក្ខណៈវិនិច្ឆ័យបែបណា? មានអ្វីខ្លះទៅជាមុខងារ? ហើយមាននិន្នាការនយោបាយបែបណា? តើកត្តាអ្វីខ្លះដែលជម្រុញឱ្យមនុស្សក្លាយទៅជាមេដឹកនាំបាន? ខាងក្រោមនេះគឺជាចម្លើយ ឆ្លើយតបទៅនឹងសំណួរដែលបានចោទឡើងខាងលើ។*

**១- និយមន័យ**

*ពាក្យ«មេដឹកនាំ» ត្រូវនឹងពាក្យជាភាសាអង់គ្លេសថា* Leader*។ ពាក្យ* Leader *ចេញមកពីកិរិយាស័ព្ទថា* to lead *ប្រែមកជាភាសាខ្មែរថា ដឹកនាំ។ អាចមានពាក្យមួយទៀតដែលប្រើជំនួសគ្នាបានគឺ* to guide *ប្រែជាភាសាខ្មែរថា នាំផ្លូវ។*

Leader<To lead or to guide

*មេដឹកនាំ<ដឹកនាំឬនាំផ្លូវ*

*ដូច្នេះ មេដឹកនាំ គឺជាមនុស្សដែលមានតួនាទីជាអ្នកដឹកនាំឬហៅម្យ៉ាងទៀតថា ជាអ្នកនាំផ្លូវគេ។*

*តើដឹកនាំ ឬនាំផ្លូវគេទៅឯណា? ចម្លើយអាចឆ្លើយបានយ៉ាងនេះថា ដឹកនាំគេឬនាំផ្លូវគេឆ្ពោះទៅរកគោលដៅណាមួយ ដែលទាំងអស់គ្នាចង់បានគឺភាពសំបូរសប្បាយចម្រើនរុងរឿងនោះឯង។ ដោយឡែក បើសិនជាមេដឹកនាំស្ថិតក្នុងសភាព ជាមេដឹកនាំខាងនយោបាយផងនោះ មេដឹកនាំប្រភេទនេះត្រូវតែបរិបូរណ៌ទៅដោយចំណេះដឹងខាងទ្រឹស្តី ព្រមទាំងមានសិល្បៈឬភាពប៉ិនប្រសប់ក្នុងការដឹកនាំ ធ្វើឱ្យមនុស្សទាំងអស់ជឿជាក់ ដោយក្តីស្រុះស្រួលគ្នាថែមទៀតមុននឹងឈានទៅដល់ការសម្រេចគោលដៅ។ មកដល់ត្រឹមនេះ គេអាចកត់សម្គាល់បានថា តើនរណាទៅជាមេដឹកនាំ។ ជាបន្តទៅទៀត យើងនឹងអាចយល់ដឹងបានថាតើមេដឹកនាំមានលក្ខណៈពិសេសអ្វីខ្លះ ហើយខុសប្លែកពីមនុស្សធម្មតាដូចម្តេច គិតទាំងមេដឹកនាំក្នុងអតីតកាលក៏ដូចជាក្នុងបច្ចុប្បន្នកាល។*

## ២- លក្ខណៈវិនិច្ឆ័យ

*ក្នុងករណីនេះយើងអាចលើកយកមកបង្ហាញម្តងមួយៗនូវទស្សនៈពីអតីតកាលស្តីពីមេដឹកនាំរួមមាន៖ ទស្សនៈសេណូហ្វុង ស៊ីស៊ីរ៉ូ, ម៉ាគីយ៉ាវែល, មហាត្មៈ គន្ធី, ទស្សនៈរបស់ខ្មែរសម័យអង្គរក៏ដូចជាទស្សនៈសាកលមួយចំនួនក្នុងសម័យបច្ចុប្បន្នស្តីពីមេដឹកនាំ។*

### ២.១.លក្ខណៈវិនិច្ឆ័យក្នុងអតីតកាល

**២.១.១-លក្ខណៈវិនិច្ឆ័យតាមទស្សនៈ សេណូហ្វុង (Xénophon ៤៣០-៣៥៥)**

*គួររំលឹកឡើងវិញថា សេណូហ្វុង គឺជាកូនទាហានដ៏សាមញ្ញម្នាក់ ដែលត្រូវបានក្រុមទាហានចំនួន មួយម៉ឺននាក់ ស្រុះស្រួលគ្នាផ្តល់ទំនុកចិត្ត ឱ្យលោកធ្វើជាមេដឹកនាំ ដើម្បីនាំផ្លូវពួកគេដកថយត្រឡប់មកប្រទេសក្រិកវិញ ក្នុងខណៈ ដែលមេទ័ពត្រូវបានសម្លាប់ដោយពួកពែរស៍ នៅលើសមរភូមិប្រយុទ្ធ។ សូមបញ្ជាក់ថា លោកបានទទួលខុសត្រូវដឹកនាំទ័ពត្រឡប់មកបុរីអាតែន (ប្រទេសក្រិក) វិញ ក្នុងចម្ងាយផ្លូវ២៤១២គីឡូម៉ែត្រ ប្រកបដោយគ្រោះថ្នាក់ ធ្លងកាត់អាកាសធាតុដ៏អាក្រក់ នៃវាលខ្សាច់ មានការដេញតាមពីសត្រូវ ព្រមទាំងខ្វះខាតស្បៀងអាហារ ហើយធ្វើដំណើរក្នុងរយៈពេល៩ខែ។ លោកបានរំលឹកពីអនុស្សាវរីយ៍ដ៏សោកសៅអស់ទាំងនោះ ក្នុងសៀវភៅជាស្នាដៃនិពន្ធមួយឈ្មោះ*

ថា អាណាបាស៊ីស (Anabasis)។ ជារួមលោក សេណូហ្វុង ត្រូវបានសមូហភាពក្នុងក្រុម ទទួលស្គាល់ថា ជាមនុស្សម្នាក់មានលក្ខណៈ សាមញ្ញ ស្និទ្ធស្នាល ហើយត្រូវបានមនុស្ស ទាំងអស់ចាត់ទុកថា ជាជនគំរូម្នាក់ ប្រកបដោយគុណធម៌ មានភាពឈ្លាសវៃ និង ប៉ិនប្រសប់។ ទាក់ទងទៅនឹងលក្ខណៈវិនិច្ឆ័យ របស់មេដឹកនាំលោកបានកំណត់យ៉ាងដូច្នេះ ថា មេដឹកនាំជាមនុស្សប្រកបដោយគុណធម៌ និងមានភាពទៀងត្រង់។ លោកបានអះអាង បន្តទៅទៀតថា មិនមែនមនុស្សណាក៏អាចធ្វើ ជាមេដឹកនាំបានទាំងអស់គ្នានោះទេ ប៉ុន្តែមេ ដឹកនាំ គឺជាអ្នកដែលចេះបញ្ជា។ ទន្ទឹមនឹងនេះ មេដឹកនាំក៏ជាមនុស្សដែលគេទាំងអស់គ្នា ទទួលស្គាល់ថា ជាអ្នកខ្ពង់ខ្ពស់គួរឱ្យគោរព ថែមទាំងប៉ិនប្រសប់និយាយបញ្ចុះបញ្ចូល និង ចេះធ្វើឱ្យគេជឿជាក់។ មិនតែប៉ុណ្ណោះ មេ ដឹកនាំជាមនុស្សដែលចេះគិតគូរពីផល ប្រយោជន៍រួម និងជួយការពារផលប្រយោជន៍ របស់មនុស្សស្ថិតនៅក្រោមបង្គាប់។ មេដឹកនាំ ក៏ជា មនុស្សដែលមានគុណធម៌អាចជំនះបាន នូវសភាវគតិ និងតណ្ហា មិនសមស្រប ទាំងឡាយរបស់ខ្លួន។ ជាចុងក្រោយលោក បានសង្កត់ធ្ងន់ថា មេដឹកនាំជាអ្នកដែលមិនប្រើ អំណាចចាប់បង្ខំទៅលើអ្នកនៅក្រោមបង្គាប់ បានន័យថា ត្រូវធ្វើយ៉ាងណាឱ្យអ្នកទាំងនោះ ធ្វើតាមប្រកបដោយក្ដីគោរព[1]។

**២.១.២- លក្ខណៈវិនិច្ឆ័យតាមទស្សនៈរបស់ ស៊ីសឺរ៉ូ (Cicero ១០៦-៤៣)**

លោកត្រូវបានគេចាត់ទុកថា ជា ទស្សនវិទូ ជាអ្នកនយោបាយ ជារដ្ឋបុរស និង ជាវាគ្មិនមួយរូបប្រចាំទីក្រុងរ៉ូម នាសម័យ នោះ។ ក្នុងមួយជីវិតរបស់ខ្លួន លោកបានលើក ឡើង នូវគំនិតនយោបាយជាច្រើនទាក់ទងទៅ នឹងច្បាប់, ចៅក្រម, រដ្ឋនិងរូបភាពរបស់រដ្ឋ ព្រមទាំងលក្ខណៈវិនិច្ឆ័យរបស់មេដឹកនាំរដ្ឋ។ តាមទស្សនៈរបស់លោក មេដឹកនាំត្រូវមាន លក្ខណៈវិនិច្ឆ័យ៥យ៉ាងពោលគឺ ជាមនុស្ស ឆ្លាតវៃមានគតិបណ្ឌិត មានយុត្តិធម៌ចំពោះ អ្នកនៅក្រោមបង្គាប់ មានពាក្យសម្ដីគួរឱ្យកក់

---

[1]- សូមមើល អ៊ុំ ប៉ុម *ប្រវត្តិគំនិតនយោបាយបស្ចិម ប្រទេស* គ្រឹះស្ថានបោះពុម្ពផ្សាយអង្គរ ឆ្នាំ២០០៨ ទំព័រ ២៤-២៥។

ក្តៅ ព្រមទាំងបានធ្វងកាត់ការរៀនសូត្រលើមុខវិជ្ជាស្តីពី ច្បាប់និងរដ្ឋថែមទៀតផង[២]។

**២.១.៣- លក្ខណៈវិនិច្ឆ័យតាមទស្សនៈម៉ាគីយ៉ាវ៉ែល (Machiavel ១៤៩៦-១៥២៧)**

លោកត្រូវបានគេទទួលស្គាល់ថាជាទស្សនៈវិទូនយោបាយ ជាប្រវត្តិវិទូ ជាអ្នកទ្រឹស្តីខាងសង្គ្រាម ហើយក៏ជាស្ថាបនិកខាងវិទ្យាសាស្ត្រនយោបាយ។ ទាក់ទងទៅនឹងការដឹកនាំរដ្ឋលោកបានអះអាងថា ដើម្បីជានានូវឯកភាពរដ្ឋនិងធ្វើឲ្យរដ្ឋមួយខ្លាំងក្លាទៅបានរដ្ឋនោះត្រូវមានអ្នកដឹកនាំមួយរូបមានឈ្មោះថា «សម្តេច»[៣] ដែលជាអ្នកដឹកនាំដ៏ខ្លាំងពូកែជានាបាននូវឯកភាពអំណាចនិងឯកភាពរដ្ឋហើយសម្តេចត្រូវមានលក្ខណៈវិនិច្ឆ័យ៧ប្រការៈ

- លក្ខណៈវិនិច្ឆ័យទី១៖ ត្រូវប្រកាន់យកនូវភាពប្រាកដនិយមធ្វើជាគោល។ បានន័យថា ត្រូវគិតពីអ្វីដែលកំពុងតែធ្វើមិនត្រូវជឿទុកចិត្តទៅលើអ្វីដែលគេនិយាយប្រាប់នោះទេ ត្រូវពិនិត្យសង្កេត និងតាមឃ្លាំមើលជាប់ជានិច្ច។ ពេលមានអ្វីកើតឡើងមិនត្រូវស្ទន់ស្ទាពេកទេ ត្រូវចាត់ទុកដូច ជារឿងធម្មតាមិនត្រូវធ្លាក់ក្នុងសទ្ធិភាពនិយម ហើយក៏មិនត្រូវជឿខ្លួនឯងឱ្យហួសហេតុពេកដែរ។
- លក្ខណៈវិនិច្ឆ័យទី២៖ មេដឹកនាំត្រូវមានអត្តទត្ត គឺការស្រឡាញ់ខ្លួនក៏ដូចជាលើកតម្កើងខ្លួនផងដែរ ពីព្រោះធម្មតាមនុស្សតែងតែគិតគូរពីផលប្រយោជន៍ផ្ទាល់ខ្លួន ហើយចេះលើកតម្កើងខ្លួនឯងដោយការបង្ហាញឱ្យគេស្គាល់តាមរយៈសកម្មភាពឬតាមស្នាដៃរបស់ខ្លួន។ ម្យ៉ាងទៀត ជាមួយមជ្ឈដ្ឋានអាក្រក់យើងមិនអាចយកអ្វីដែលល្អ ទៅប្រើប្រាស់បានទេ។ ដូច្នេះសុខចិត្តធ្វើចិត្តឱ្យកាចសាហាវ ប្រសើរជាងធ្វើចិត្តជាអ្នកល្អ ពីព្រោះថាកាចសាហាវធ្វើឱ្យមនុស្សពាលតិចតួចឈឺចាប់ហើយបើសន្តោសវិញនឹងនាំឱ្យសង្គមជាតិឥតសណ្តាប់ធ្នាប់ ហើយជាចុងក្រោយធ្វើឱ្យប្រជាជនរងទុក្ខវេទនា។

[២]- ដ.ឯ.ម. ទំព័រ៦៧

[៣]- ពាក្យនេះត្រូវបានបណ្ឌិត ឃូគិមទូយ អ្នកបកប្រែសៀវភៅ តម្រូវទៅតាមពាក្យអង់គ្លេស ថា Prince ។

- *លក្ខណៈវិនិច្ឆ័យទី៣៖ មេដឹកនាំត្រូវចេះគន់គូរមើលពីការយកមនុស្សមកប្រើប្រាស់ត្រូវសួរខ្លួនឯងថា តើមនុស្សនោះអាចបំពេញអ្វីខ្វះដល់យើង។ ទាក់ទងទៅនឹងរឿងនេះដដែល លោកបានពន្យល់ថា អ្នកដែលដង្ហែយើងឬបម្រើយើងដោយឥតលោភលន់ត្រូវផ្តល់ដំរង្វាន់ដល់គេនិងស្រលាញ់គេ។ បើចង់បានមនុស្សមកធ្វើជាទីប្រឹក្សា ត្រូវរកមនុស្សដែលដាច់តែឯងមិនពាក់ព័ន្ធនឹងអ្នកដទៃពីព្រោះមនុស្សប្រភេទនេះអាចជួយយើងពេលមានអាសន្ន។ ផ្ទុយទៅវិញអ្នកដែលមិនពាក់ព័ន្ធនឹងយើង ក្នុងគោលការណ៍អ្វីមួយ គួរកុំយកមកប្រើ ព្រោះមនុស្សប្រភេទនេះគិតផលប្រយោជន៍គេជាងផលប្រយោជន៍យើង។ បើពេលមានអាសន្ន អនក្រផងនោះគេនឹងបំផ្លាញយើងតែម្តង។ សូវធ្វើឱ្យគេខ្លាចនិងគោរពយើងជាជាង ឲ្យគេស្រឡាញ់យើង[៤]។*
- *លក្ខណៈវិនិច្ឆ័យទី៤៖ ក្នុងការអនុវត្តការងារយើងមិនត្រូវចាប់អារម្មណ៍ទៅលើអ្វីដែលល្អ អ្វីដែលអាក្រក់នោះទេ ប៉ុន្តែត្រូវចេះប្រើប្រាស់នូវសកម្មភាពទាំងពីរកាលណាកាលៈទេសៈ តម្រូវឱ្យពីព្រោះការសម្រេចគោលដៅបញ្ជាក់ពីមធ្យោបាយដែលយើងយកទៅប្រើប្រាស់បានន័យថា គេមិនខ្វល់ខ្វាយសួរនាំយើង ពីមធ្យោបាយយកមកប្រើប្រាស់នោះទេ សំខាន់ គឺគេគត់សម្គាល់តែទៅលើការសម្រេចបានគោលដៅនោះប៉ុណ្ណោះ ដែលជារឿងចាំបាច់។*
- *លក្ខណៈវិនិច្ឆ័យទី៥ គឺភាពប៉ិនប្រសប់៖ លោកបានលើកឡើងថា មេដឹកនាំត្រូវមានភាពប៉ិនប្រសប់ ពោលគឺចេះប្រើល្បិច ពីព្រោះអ្វីៗទាំងអស់តែងតែមានភាពតានតឹងមុននឹងទៅដល់គោល*

---

[៤] - *សូមមើល នីកូឡូ ម៉ាកាវែល្លី «សម្តេច» ប្រែពីភាសាអង់គ្លេស មកជាភាសាខ្មែរដោយបណ្ឌិត យូ គិមទូយ ឆ្នាំ ១៩៩៦ ទំព័រ៥៦, ៥៧, ៨៩, ៩០។*

ដៅ។ ល្បិចឬភាពបុិនប្រសប់ដែលលោកចូលចិត្តឲ្យប្រើប្រាស់ជាងគេគឺ «បំបែកបំបាក់ដើម្បីត្រួតត្រា»។

- លក្ខណៈវិនិច្ឆ័យទី៦៖ ត្រូវចេះដើរតួពោលគឺត្រូវចេះលាក់នូវអាថ៌កំបាំង ឬចេះលាក់ពុតយ៉ាងបុិនប្រសប់[5]។
- លក្ខណៈវិនិច្ឆ័យទី៧ ត្រូវមានអំណាច ឬអានុភាព៖ ត្រូវមានអំណាចឬអានុភាពទៅលើអ្នកដទៃពោលគឺត្រូវមើលខ្លួនឯងស្ថិតនៅពីលើគេទាំងអស់។

គួរកត់សម្គាល់ថា លក្ខណៈវិនិច្ឆ័យដែលលើកឡើងដោយលោក ម៉ាគីយ៉ាវែល បើគិតពីគុណធម៌គឺពុំសូវជាមានប៉ុន្មានទេ ពីព្រោះអ្វីៗទាំងនោះភាគច្រើនគឺស្ថិតនៅលើកាលទេសៈនិងសង្គមបរិយាកាសតម្រូវឱ្យ ហើយពេលខ្លះ ហាក់ដូចជាធ្លាក់ទៅក្នុងសភាពអត្តទត្ថទុទិដ្ឋិនិងក្នុងលក្ខណៈ «ធ្មិនត្រង់ណាធីត្រង់នោះ» ឬ «ធ្មិនក្បាលស៊ីក្បាល ធ្មិនកន្ទុយស៊ីកន្ទុយ» ថែមទៀតផង។

**២.១.៤- លក្ខណៈវិនិច្ឆ័យតាមទស្សនៈរបស់មហាត្មៈគន្ធី ( Mohatma Gandhi) ១៨៦៩-១៩៤៨)**

ដូចដែលលោក អាល់បឺត អាញស្តាញ (Albert Einstein) បានពោលបញ្ជាក់ស្រាប់ មហាត្មៈគន្ធី គឺជា «មហាបុរសក្នុងប្រវត្តិសាស្ត្រនយោបាយរបស់ប្រទេសឥណ្ឌា។ គាត់បានប្រើនូវកលវិធីដែលពោរពេញទៅដោយធម៌អហិង្សាយ៉ាងពិតប្រាកដ សម្រាប់ការតស៊ូដើម្បីរំដោះប្រជាជនចេញពីការជិះជាន់របស់ពួកអាណានិគមហើយសម្រេចបានដោយកម្លាំងនិងការលះបង់ដ៏ធំធេងរបស់ខ្លួនក្រោមឥទ្ធិពលសីលធម៌ដែលគាត់បានប្រើសម្រាប់មនុស្សជាតិនៅក្នុងពិភពលោកដ៏ស៊ីវិល័យមួយនេះ»[6]។ ទាក់ទងទៅលក្ខណៈវិនិច្ឆ័យរបស់មេដឹកនាំគេឃើញមានទស្សនៈជាលក្ខណៈវិនិច្ឆ័យចំនួន៦ រួមមាន ៖

- លក្ខណៈវិនិច្ឆ័យទី១៖ ត្រូវចេះគ្រប់គ្រងសរីរាង្គវិញ្ញាណទាំងអស់តាមរយៈការ

[5]- សូមមើល នីកូឡូ ម៉ាកាវែល្លី «សម្តេច» បកប្រែពីភាសាអង់គ្លេសមកជាភាសាខ្មែរ ដោយបណ្ឌិត យូ គិមទូយ ឆ្នាំ ១៩៩៦ ទំព័រ៩៥។

[6]- មហាត្មៈ គន្ធី ជីវិត និងគំនិត បកប្រែដោយឡេង ចិន្តា គ្រឹះស្ថានបោះពុម្ពផ្សាយ Idea Book ឆ្នាំ២០១៣ ទំព័រ៨។

អត់អាហារ ពីព្រោះការអត់អាហារនឹងធ្វើឲ្យចិត្តកាន់តែបរិសុទ្ធឡើង។

- លក្ខណៈវិនិច្ឆ័យទី២៖ មិនលួចប្លន់ក្រៅពីការដណ្ដើមយកទ្រព្យសម្បត្តិអ្នកដទៃដោយកម្លាំងបាយឬដោយអំណាច ការលោភលន់ អត្តទត្តភាព ការមិនធ្វើទាន ការចង់បានរបស់ដែលមិនត្រូវការភ្លាមៗ គឺជាបាបធម៌ ជាអំពើប្លន់។ លោកបានលើកឡើងយ៉ាងដូច្នេះថា «ខ្ញុំយល់ថាយើងជាចោរតាមបែបណាមួយបើសិនជាខ្ញុំយករបស់អ្វីមួយដែលខ្ញុំមិនត្រូវការប្រើប្រាស់ភ្លាមៗមកទុកជារបស់ខ្លួនផ្ទាល់ខ្ញុំលួចវាពីអ្នកដទៃទៀត»។
- លក្ខណៈវិនិច្ឆ័យទី៣ មិនចង់បានទ្រព្យសម្បត្តិអ្នកដទៃ៖ ការមិនចង់បានទ្រព្យសម្បត្តិអ្នកដទៃជាគំនិតហើយសកម្មភាពជាការចាំបាច់។ តាមទស្សនៈរបស់លោក មនុស្សមានទ្រព្យច្រើនគ្រាន់តែជាអ្នកទទួលគ្រប់គ្រងប៉ុណ្ណោះ មិនមែនជាម្ចាស់នៃទ្រព្យសម្បត្តិនោះឡើយ។ គេត្រូវចេះប្រើប្រាស់វាឱ្យបានសមស្របសម្រាប់មនុស្សជាតិ និងសុខុមាលភាពសង្គម។
- លក្ខណៈវិនិច្ឆ័យទី៤ មិនភ័យខ្លាច៖ ការមិនភ័យខ្លាចជាសញ្ញាមួយនៃភាពអង់អាចក្លាហាន។ ផ្ទុយទៅវិញការភ័យខ្លាចជាលទ្ធផលនៃការមន្ទិលសង្ស័យឬការមិនច្បាស់លាស់របស់មេដឹកនាំ។
- លក្ខណៈវិនិច្ឆ័យទី៥ មិនប្រកាន់វណ្ណៈ៖ ការប្រកាន់វណ្ណៈជាអំពើប្រឡាក់ប្រឡូសមួយនៅក្នុងសង្គម។ ដូច្នេះមនុស្សគ្រប់រូបត្រូវមានករណីយកិច្ចលុបបំបាត់វាចោល។ ប៉ុន្តែគេមិនគប្បីយល់ច្រឡំឬប្រែក្លាយការបែងចែកការងារនូវក្នុងសង្គម ទៅតាមសមត្ថភាពម្នាក់ៗថាជាការបែងចែកវណ្ណៈឡើយ។ លោកប្រឆាំងទៅនឹងការរើសអើងវណ្ណៈជាពិសេសទៅលើក្រុមមនុស្សដែលគេចាត់ទុកថាជោកទាបគួរឱ្យខ្ពើមរអើមនិងមិនអាចប៉ះពាល់បាន (The untouchables) ដូចជាអ្នកបោសសំរាម ប្រមូលសំរាមជាដើម។

## ២.១.៥- លក្ខណៈវិនិច្ឆ័យតាមទស្សនៈខ្មែរសម័យអង្គរ

គួររំលឹកឡើងវិញថា សម័យអង្គរបាន ចាប់ផ្តើមពីឆ្នាំ៨០២ រហូតដល់ឆ្នាំ១៤៣១។ ជាលក្ខណៈទូទៅសម័យអង្គរ ត្រូវបានប្រវត្តិវិទូចាត់ទុកថាជាសម័យកាលមួយដ៏រុងរឿងក្នុងប្រវត្តិសាស្ត្រកម្ពុជា។ ក្នុងសម័យនេះ ខ្មែរយើងបានប្រកាន់យកយ៉ាងខ្ជាប់ខ្ជួននូវលក្ខណៈវិនិច្ឆ័យ១០ ប្រការសម្រាប់អប់រំមនុស្សទូទៅ ដើម្បីចង់ឱ្យពួកគេក្លាយទៅជា មេដឹកនាំដ៏ល្អប្រពៃរបស់ចក្រភពនេះ[៨]។ លក្ខណៈវិនិច្ឆ័យទាំង១០ប្រការ នោះរួមមាន៖

- *លក្ខណៈវិនិច្ឆ័យទី១ គឺធ្វើទាន៖ មេដឹកនាំត្រូវចេះធ្វើទានជាសម្ភារៈនិងស្មារតី ចំពោះប្រជារាស្ត្ររបស់ខ្លួន ដើម្បីឱ្យពួកគេមានធនធានសម្ភារៈនិងស្មារតីគ្រប់គ្រាន់ប្រកបដោយកិត្តិយសនិងសេចក្តីថ្លៃថ្នូរ។*
- *លក្ខណៈវិនិច្ឆ័យទី២ គឺរក្សាសីល៖ មេដឹកនាំត្រូវប្រកាន់ខ្ជាប់នូវសីល៥ ក្នុង*
- *លក្ខណៈវិនិច្ឆ័យទី៦ ប្រកាន់យកអំពើអហិង្សា៖ តាមទស្សនៈរបស់លោក អំពើអហិង្សាគឺជាច្បាប់របស់មនុស្ស។ រីឯអំពើហិង្សាគឺជាច្បាប់របស់សត្តិរច្ឆានឬនិយាយម្យ៉ាងទៀតថា អហិង្សាជាមធ្យោបាយហើយសច្ចធម៌គឺជាគោលដៅ។ មិនត្រូវធ្វើឲ្យអ្នកដទៃមានរបួសដោយអំពើហិង្សាទាំងបីនោះគឺ ហិង្សាផ្នែកគំនិតហិង្សាផ្នែកពាក្យសំដីនិងហិង្សា ផ្នែកសកម្មភាព។ ត្រូវប្រកាន់ខ្ជាប់នូវអំពើអហិង្សា រួមមានការស្រឡាញ់ ការអាណិតមេត្តា ការមិនភ័យខ្លាច និងការមិនធ្វើសហប្រតិបត្តិការ[7]។ រូបភាពនៃអំពើអហិង្សាចុងក្រោយនេះត្រូវបាន មហាត្មៈ គន្ធីយកមកប្រើប្រាស់ ដើម្បីដឹកនាំប្រជាជនឥណ្ឌា ទាមទារឯករាជ្យពីពួកអាណានិគមអង់គ្លេសរហូតទាល់តែបានសម្រេចជោគជ័យ ក្នុងឆ្នាំ១៩៤៨។*

[7] - *សូមមើលសុខសាធកំណាប់សីលធម៌គ្រឹះស្ថានបោះពុម្ពផ្សាយអង្គរបោះពុម្ពលើកទី២ ឆ្នាំ២០១២ ទំព័រ ៩៦-១០២។*

[៨] - *គេអាចហៅថា «ទសពិធរាជធម៌» ក៏បាន។*

ជីវិតប្រចាំថ្ងៃរបស់ខ្លួនគឺ ការមិនប្រមាថ ឬសម្លាប់ជីវិត ការវៀរចាកនូវអំពើលួចប្លន់ អំពើប្រព្រឹត្តខុសក្នុងកាម (បៀតបៀនទៅលើកូនប្រពន្ធអ្នកដទៃ) មិនប្រព្រឹត្តអំពើកូតករកុហក និងអំពើមិនត្រេកត្រអាលទៅលើគ្រឿងស្រវឹង។ ទន្ទឹមនឹងនេះក៏ត្រូវប្រកាន់ខ្ជាប់នូវព្រហ្មវិហារធម៌ទាំងបួនគឺ មេត្តា ករុណា មុទិតា ឧបេក្ខា[១]។

- លក្ខណៈវិនិច្ឆ័យទី៣ គឺបរិច្ចាគៈ ជាតិជាមេដឹកនាំត្រូវចេះចែករំលែកនូវទ្រព្យសម្បត្តិដែលខ្លួនមានដើម្បីជួយសង្គ្រោះចំពោះជនក្រីក្រលំបាកវេទនាក៏ដូចជាជួយឧបត្ថម្ភចំពោះប្រទេសជាតិ។
- លក្ខណៈវិនិច្ឆ័យទី៤ គឺអាជ្ជវៈ មេដឹកនាំត្រូវមានចិត្តស្មោះត្រង់ទៀងត្រង់មិនវៀចវេរក្នុងការបម្រើជាតិមាតុភូមិនិងប្រជាពលរដ្ឋមិនកេងប្រវ័ញ្ចន៍ទ្រព្យសម្បត្តិរបស់ជាតិនិងប្រជាជន។
- លក្ខណៈវិនិច្ឆ័យទី៥ គឺមទ្ទវៈ មេដឹកនាំ ត្រូវមានអាកប្បកិរិយា ពាក្យសម្ដី ឱ្យបានទន់ភ្លន់សុភាពរាបសា និងថ្លៃថ្នូរ។
- លក្ខណៈវិនិច្ឆ័យទី៦ គឺតបៈ មេដឹកនាំត្រូវចេះរម្ងាប់អារម្មណ៍ ដុសខាត់គំនិតឱ្យល្អផូរផង់ វៀរចាកនូវអវិជ្ជាដែលជាប្រភពនាំមកនូវសេចក្ដីទុក្ខ។
- លក្ខណៈវិនិច្ឆ័យទី៧ គឺអក្កោធនៈ មេដឹកនាំមិនត្រូវមានចិត្តក្រេវក្រោធក្ដៅក្រហាយចំពោះអ្នកដទៃ បង្កជាកំហឹងជាអំពើសងសឹកគ្នាធ្វើឱ្យបែកបាក់សាមគ្គីផ្ទៃក្នុង។
- លក្ខណៈវិនិច្ឆ័យទី៨ គឺអវិហឹសាៈ មេដឹកនាំត្រូវប្រកាន់ខ្ជាប់នូវអំពើ អហិង្សា ដើម្បីដោះស្រាយបញ្ហា។
- លក្ខណៈវិនិច្ឆ័យទី៩ គឺខន្តីៈ មេដឹកនាំត្រូវមានអំណត់ព្យាយាមក្នុងការបំពេញភារកិច្ចនិងដំណោះស្រាយបញ្ហាធំៗរបស់ប្រទេសជាតិ។

[១] - មេត្តាៈ សេចក្ដីអាណិតស្រឡាញ់, ករុណាៈ សេចក្ដីសន្ដោសប្រណី, មុទិតាៈ ការត្រេកអរចំពោះសេចក្ដីសុខអ្នកដទៃ, ឧបេក្ខាៈ សេចក្ដីស្រឡាញ់រាប់អានស្មើៗគ្នា។

- *លក្ខណៈវិនិច្ឆ័យទី១០ គឺអវិរោធនៈ មេដឹកនាំត្រូវគោរពច្បាប់របស់ប្រទេស ឲ្យបានភ្ជាប់ខ្លួននិងមិនបំពានទៅលើ ច្បាប់ទាំងនោះ។ ត្រូវចាត់ទុកច្បាប់ធំ ជាងបុគ្គលនិងត្រូវបានគោរពដោយ ស្មើភាព។*

*លក្ខណៈវិនិច្ឆ័យទាំង១០ ដូចបាន រៀបរាប់មកខាងលើមានឥទ្ធិពលពីព្រះពុទ្ធ សាសនាដែលខ្មែរធ្លាប់បានគោរពបូជានា ពេលនោះ ម៉្លោះហើយប្រជាជនច្រើនមាន ជំនឿថាបើមេដឹកនាំគោរពបានយ៉ាងម៉ត់ចត់ នោះប្រទេសជាតិនឹងទទួលបាននូវសេចក្ដី សុខចម្រើនគ្រប់ប្រការ។*

**២.១.៦- លក្ខណៈវិនិច្ឆ័យសម័យបច្ចុប្បន្ន**

*តាមទស្សនៈសម័យបច្ចុប្បន្ន មេដឹកនាំ ត្រូវមានជាបឋមនូវសុខភាពល្អបរិបូរណ៍ កាយសម្បទារឹងមាំស្រឡាញ់សន្តិភាព និង សេចក្ដីសុខស្ងប់ ចេះធ្វើឱ្យប្រជាជនស្រឡាញ់ និងជឿទុកចិត្តមានឆន្ទៈនយោបាយមោះមុត មានការទទួលខុសត្រូវខ្ពស់ចំពោះសកម្មភាព ការងារ។ ជាមនុស្សមានចំណេះដឹងទូទៅ ច្រើនមានបទពិសោធន៍ព្រមទាំងមានចំណេះ ដឹងខាងបច្ចេកវិទ្យាទំនើប។ ទន្ទឹមនឹងនេះត្រូវ តែជាមនុស្សចេះត្រៀមបម្រុងនិងឈ្លាសវៃក្នុង នយោបាយ ឆ្លើយតបបានភ្លាមៗចំពោះ សភាពការណ៍។ ជាមនុស្សមានទេពកោសល្យ និងពូកែខាងវោហារនិងជាអ្នកមានកម្មវិធី នយោបាយច្បាស់លាស់។ ជាងនេះទៅទៀត មេដឹកនាំក៏ជាអ្នកដែលចេះកំណត់គោលដៅ បានត្រឹមត្រូវចេះធ្វើគំរូល្អចំពោះអ្នកនៅក្រោម បង្គាប់ ចេះធ្វើសកម្មភាព ឱ្យបានល្អប្រសើរ ឡើង ជាប់ជានិច្ច[10] មានពេលវេលាគ្រប់គ្រាន់ ដើម្បីប្រមើលមើលទៅមុខមានកម្មវិធី ដឹកនាំ ការងារដោយចុះទៅធ្វើបង្ហាញផ្ទាល់ មិនមែន គ្រាន់តែប្រាប់ដោយប្រយោល ចេះវិនិច្ឆ័យកិច្ច ការ ដោយផ្អែកលើលទ្ធផល និងប្រសិទ្ធភាព ការងារមិនមើលស្រាលបរិស្ថាន ខាងក្រោមមាន អភិបាលកិច្ចជាប់ជាប្រចាំ មានទំនុកចិត្ត ចំពោះខ្លួនឯងនិងអ្នកនៅក្រោមបង្គាប់មាន សីលធម៌វិជ្ជាជីវៈខ្ពស់ទទួលយកនូវការទិតៀន*

---

[១០] - *ទស្សនវិជ្ជាជប៉ុនបានលើកឡើងថា «ថ្ងៃនេះថ្មី ថ្ងៃស្អែកថ្មីជាងថ្ងៃនេះ» ទាក់ទងជាសំខាន់ទៅលើគំនិតច្នៃប្រឌិតថ្មី។*

កែលម្អពីអ្នកដទៃដើម្បីយកមកពិចារណាគិតគូរជាប់ជាប្រចាំចំពោះអនាគតរបស់អង្គភាព ហើយជាចុងក្រោយត្រូវតាំងខ្លួនជាអ្នកឈ្នះលើអ្វីៗទាំងអស់។ ប៉ុន្តែទោះបីជាមានយ៉ាងនេះក្តី ក៏ក្នុងសកម្មភាពបំពេញការងារច្រើនឬតិច មេដឹកនាំរមែងជួបប្រទះនឹងបរាជ័យដោយជៀសមិនផុត។ តើបរាជ័យទាំងនោះបណ្តាលមកពីអ្វី?

តាមទស្សនៈរបស់លោករីឆាដ ឌែនទី (Richard Denney) ដែលជាអ្នកនិពន្ធសៀវភៅមួយឈ្មោះថា «ជំរុញទឹកចិត្តដើម្បីឈ្នះ» (Motivate towin) បានរកឃើញនូវមូលហេតុបរាជ័យ១២ យ៉ាងគឺ កង្វះភាពប៉ិនប្រសប់ក្នុងការរៀបចំព័ត៌មានឬសេចក្តីរាយការណ៍ ខ្វះឆន្ទៈដើម្បីចលនាអ្នកនៅក្រោមបង្គាប់របស់ខ្លួន ខ្វះការគិតពិចារណាដោយសតិបញ្ញា (common sense) ខ្វះគំនិតច្នៃប្រឌិត ខ្វះកក្តីភាព ខ្វះការសន្តោសប្រណី មិនចេះប្រមាណ ប្រកាន់រឹងត្អឹងពេក នូវអំណាចជាមេដឹកនាំ ប្រមូលឥណទានរបស់ក្រុមយកមកគ្រប់គ្រងដោយខ្លួនឯងផ្ទាល់ បារម្ភខ្លាចថ្នាក់ក្រោមលូតលាស់ជាងខ្លួននិងដណ្តើមអំណាចពីខ្លួន មិនបង្កលក្ខណៈឱ្យអ្នកនៅក្រោមបង្គាប់ មានចំណេះធ្វើ ហើយជាចុងក្រោយមិនបានដឹង ឬមើលស្រាលឥទ្ធិពលបំផ្លិចបំផ្លាញអង្គភាពពីខាងក្រៅ។

## ៣- មុខងាររបស់មេដឹកនាំ

ក្រៅពីលក្ខណៈវិនិច្ឆ័យដែលបានរៀបរាប់រួចមកហើយ មេដឹកនាំម្នាក់ៗ គប្បីមានមុខងារចាំបាច់ត្រូវបំពេញ ដែលផ្តោតជាសំខាន់ទៅលើកម្រិតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។ ជាទូទៅមេដឹកនាំគប្បីមានមុខងារសំខាន់ចំនួន៦ គឺមុខងារបង្រួបបង្រួមមុខងារវិភាគនិងវាយតម្លៃមុខងារតម្រង់ទិសមុខងារជាយន្តការមុខងារប្រមូលផ្តុំឆន្ទៈនិងស្មារតីអ្នកនៅក្រោមបង្គាប់និងមុខងារអភិបាលកិច្ច។

### ៣.១- មុខងារបង្រួបបង្រួម

ក្នុងឋានៈជាមេដឹកនាំត្រូវមានទស្សនៈបង្រួបបង្រួមឱ្យបានល្អរវាងក្រុមមនុស្សដែលមានតម្រូវការផ្សេងៗពីគ្នា ធ្វើឱ្យក្រុមមនុស្សក្នុងអង្គភាពដែលខ្លួនទទួលខុសត្រូវស្ថិតក្នុងឧត្តមគតិតែមួយចំពោះតម្រូវការផ្ទាល់របស់គេ។ គួរកត់សម្គាល់ថាភាពតានតឹងដែលកើតមានក្នុងអង្គភាពដែលខ្លួនទទួលខុសត្រូវគឺជាសក្ខីភាពធ្ងុះបញ្ចាំងឱ្យឃើញពី អសមត្ថភាព

របស់មេដឹកនាំក្នុងការអនុវត្តនូវមុខងារបង្រួបបង្រួម។

### ៣.២- មុខងារវិភាគនិងវាយតម្លៃ

នៅចំពោះមុខស្ថានភាពនយោបាយដែលកើតមានឡើង មេដឹកនាំគប្បីធ្វើការវិភាគនិងវាយតម្លៃឲ្យបានត្រឹមត្រូវ។ ជាក់ស្តែងត្រូវរកឱ្យឃើញពីមូលហេតុដែលនាំឱ្យកើតវិបត្តិនយោបាយនិងវិបត្តិសង្គម។ ត្រូវចេះប៉ាន់ប្រមាណនិងប្រមើលមើលនូវរាល់ហេតុការណ៍ដែលអាចកើតមានឡើង ដើម្បីមានវិធានការត្រៀមបម្រុងទុកជាមុន។ មេដឹកនាំដែលព្រងើយកន្តើយចំពោះហេតុការណ៍ដែលកើតមានឡើងអាចចាត់ទុកថាពុំបានបំពេញនូវមុខងារវិភាគនិងវាយតម្លៃរបស់ខ្លួនឡើយ។

### ៣.៣- មុខងារតម្រង់ទិស

ផ្អែកលើទិដ្ឋភាពរីកចម្រើនរបស់សកលលោក មេដឹកនាំតែងបានរៀបចំជ្រើសរើសនិងកំណត់ទិសដៅនយោបាយរបស់ខ្លួនប្រកបដោយយុទ្ធសាស្រ្តនិងយុទ្ធវិធីច្បាស់លាស់ ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់មនុស្សគ្រប់រូប។ មានពេលខ្លះការកំណត់ទិសដៅនយោបាយអាចឃ្លាតឆ្ងាយពីតម្រូវការរបស់មនុស្សភាគច្រើន ក្នុងករណីបែបនេះមេដឹកនាំត្រូវតម្រង់ទិសនយោបាយរបស់ខ្លួនឡើងវិញ ដើម្បីឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងរបស់មនុស្សទូទៅក្នុងសង្គម។

### ៣.៤- មុខងារជាយន្តការ

ដើម្បីអនុវត្តកម្មវិធីនយោបាយរបស់ខ្លួនឲ្យបានជោគជ័យមេដឹកនាំម្នាក់ៗគប្បីបង្កើតជាយន្តការ។ បង្កើតបានហើយមេដឹកនាំគប្បីប្រឹងប្រែងឲ្យអស់ពីសមត្ថភាពប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ជាមួយនឹងសហការីក្នុងយន្តការទាំងនោះដើម្បីឈានទៅសម្រេចគោលដៅឬដោះស្រាយបញ្ហាដែលកើតមានក្នុងដែនសមត្ថកិច្ចឬក្នុងអាណត្តិរបស់ខ្លួន។

### ៣.៥- មុខងារប្រមូលផ្តុំឆន្ទៈនិងស្មារតី

ដូចបានពិចារណារួចមកហើយ បរាជ័យមួយក្នុងចំណោមបរាជ័យទាំងឡាយរបស់មេដឹកនាំ កើតមានពីកំហុសឆ្គងនៃកង្វះឆន្ទៈ ក្នុងការប្រមូលផ្តុំឆន្ទៈ និងស្មារតីរបស់មហាជន។ ដូច្នេះមេដឹកនាំគប្បីមានឆន្ទៈ មានភាពប៉ិនប្រសប់ដើម្បីប្រមូលផ្តុំកម្លាំងប្រកបដោយជំនឿជឿជាក់មកលើខ្លួនហើយ

ប្រែក្លាយជំនឿទាំងនោះឱ្យទៅជាចលនាសង្គមមួយយ៉ាងផុលផុសដើម្បីអនុវត្តនូវកម្មវិធីនយោបាយឲ្យទទួលបានជោគជ័យ។

### ៣.៦- មុខងារអភិបាលកិច្ច

មុខងារនេះកើតមាននៅក្នុងប្រទេសដែលអំណាចច្បាប់មានកម្រិតខ្ពស់ជាងអ្វីៗទាំងអស់។ ដោយសារមុខងារនេះបានធ្វើឲ្យប្រជាជនចេញផុតពីភាពល្មើសច្បាប់ ភាពអនាធិបតេយ្យ គ្មានច្បាប់ទម្លាប់និងការរំលោកបំពានគ្រប់បែបយ៉ាង។ មុខងារនេះអាចសម្រេចទៅបានអាស្រ័យដោយមានការត្រួតពិនិត្យការជំរុញលើកទឹកចិត្តនិងការដាក់ទណ្ឌកម្ម។

## ៤. និន្នាការរបស់មេដឹកនាំ

ពួកអ្នកវិទ្យាសាស្ត្រនយោបាយបានឯកភាពគ្នាបែងចែកនិន្នាការរបស់មេដឹកនាំជាបីប្រភេទៈ មេដឹកនាំប្រភេទអភិរក្ស កំណែទម្រង់និងប្រភេទធ្វើបដិវត្តន៍។

### ៤.១- មេដឹកនាំប្រភេទអភិរក្ស

មេដឹកនាំប្រភេទនេះតែងចូលចិត្តថែរក្សាបេតិកភណ្ឌរូបីនិងអរូបីទាំងឡាយរួមមានវត្ថុសំភារៈនិងការគិតគូរដ៏សំខាន់ចាំបាច់ទាំងឡាយដែលប្រទេសជាតិធ្លាប់មានរួចមកហើយឲ្យបន្តស្ថិតស្ថេរគង់វង្សជាមួយនឹងសង្គមទំនើប។ គួរកត់សម្គាល់ថាមេដឹកនាំប្រភេទនេះមិនមែនជាមេដឹកនាំបែបអភិរក្សនិយមជ្រុលនូវអ្វីៗដែលមិនសមទំនងនឹងសម័យកាលនោះឡើយ។

### ៤.២- មេដឹកនាំប្រភេទកំណែទម្រង់

មេដឹកនាំប្រភេទនេះបានខិតខំធ្វើកំណែទម្រង់ក្នុងគោលដៅធ្វើឱ្យប្រទេសជាតិរស់រានមានជីវិតបន្តទៅទៀត តាមរយៈការកែលម្អរូបភាពរចនាសម្ព័ន្ធដែលមានស្រាប់ដើម្បីឱ្យមានលក្ខណៈកាន់តែសមស្របទៅនឹងសង្វាក់រីកចម្រើនថ្មីរបស់សង្គម។

### ៤.៣- មេដឹកនាំប្រភេទធ្វើបដិវត្តន៍

មេដឹកនាំប្រភេទនេះបានប្រកាន់យកអាកប្បកិរិយាកំណត់ទិសដៅកសាងសង្គមជាតិដោយយកភាពចម្រើនជឿនលឿននិយមធ្វើជាគោលដៅ។ ម្ល៉ោះហើយគេបានប្រើមធ្យោបាយផ្ដួលរំលំរបបចាស់ដែលគេយល់ថាហួសសម័យមិនជឿនលឿនទៅមុខតាមរយៈការធ្វើបដិវត្តន៍ហិង្សាដោយប្រើកម្លាំងប្រដាប់អាវុធបន្ទាប់មករៀបចំបង្កើត

នយោបាយថ្មីដែលគេពេញចិត្តនិងមានលក្ខណៈសមស្របទៅនឹងសម័យកាល។

### ៥. កត្តាជំរុញមនុស្សឲ្យក្លាយទៅជាមេដឹកនាំ

ឋានៈជាមេដឹកនាំមិនមែនជារឿងសាមញ្ញពេកទេ ប៉ុន្តែកើតឡើងពីក្តីស្រមៃនិងប្រាថ្នាចង់បានរបស់បុគ្គល ម្នាក់ៗក៏ដូចជាទំនុកចិត្តរបស់មនុស្សភាគច្រើន។ ដើម្បីក្លាយទៅជាមេដឹកនាំមួយរូបបានគេអាចឆ្វេងកាត់កត្តាទាំងឡាយរួមមានៈ

កត្តាបន្តវង្សៈ គេឃើញមានករណីបែបនេះក្នុងរបបរាជាធិបតេយ្យ។ ជាក់ស្តែងក្នុងកាលៈទេសៈសមស្របណាមួយបិតាបង្កើតបានផ្ទេររាជសម្បត្តិទៅឱ្យបុត្រាច្បងបង្អស់របស់អគ្គមហេសីដើម្បីស្នងរាជ្យបន្តតាមវ័យកំណត់ដែលបានចែងដោយច្បាប់រាជវង្សរបស់នគរ។

កត្តារៀនសូត្រច្រើនឆ្នាំៈ ដើម្បីមានលទ្ធភាពធ្វើជាមេដឹកនាំបាន សាម៉ីខ្លួនត្រូវឆ្លងកាត់ការរៀនសូត្រច្រើនឆ្នាំទៅលើមុខវិជ្ជាជាច្រើននិងរៀនពីបទពិសោធន៍ជាក់ស្តែងដើម្បីបង្កើនសមត្ថភាពតាមរយៈចំណេះដឹងនិងចំណេះធ្វើឱ្យបានគ្រប់គ្រាន់គួរឱ្យជឿទុកចិត្តបាន។

កត្តាបោះឆ្នោតៈ ប្រជាពលរដ្ឋក្នុងបរិមាណដ៏ច្រើនលើសលប់បោះឆ្នោតសម្តែងមតិឬឆន្ទៈគាំទ្រ ធ្វើជាមេដឹកនាំតាមរូបភាពប្រជាធិបតេយ្យ។

កត្តាប្រើប្រាស់កម្លាំងៈ កត្តានេះជាសកម្មភាពមិនស្របច្បាប់តាមរយៈការធ្វើរដ្ឋប្រហារដោយប្រើកម្លាំងយោធាដណ្តើមអំណាចពីបុគ្គលដឹកនាំស្របច្បាប់ណាម្នាក់។

កត្តាតែងតាំងៈ យោងតាមសកម្មភាពនិងតម្រូវការចាំបាច់គេអាចតែងតាំងបុគ្គលណាម្នាក់ឱ្យធ្វើជាមេដឹកនាំស្ថាប័ន ដោយព្រះរាជក្រឹត្យរបស់ព្រះមហាក្សត្រក្រឹត្យ ឬអនុក្រឹត្យរបស់ប្រមុខរាជរដ្ឋាភិបាលផ្អែកទៅតាមគោលការណ៍«ភាពស័ក្តិសមនឹងទទួល» របស់បុគ្គលណាម្នាក់ដែលត្រូវតែងតាំង។

## សេចក្តីសន្និដ្ឋាន

សរុបសេចក្តីមក មេដឹកនាំគឺជាបុគ្គលដែលមានសមត្ថភាពដឹកនាំនិងគ្រប់គ្រងមនុស្សឆ្ពោះទៅរកសេចក្តីចម្រើនរុងរឿងសម្បូរសប្បាយសម្រាប់ពួកគេក៏ដូចជាប្រទេស

ទាំងមូលប្រកបដោយក្តីជឿជាក់និងស្រុះស្រួលគ្នាទៅវិញទៅមក។

មនុស្សមិនអាចធ្វើជាមេដឹកនាំបានទាំងអស់គ្នានោះទេ ហើយក៏មិនអាចធ្វើជាមេដឹកនាំ លើគ្រប់វិស័យបានដែរ។ លទ្ធភាពជាមេដឹកនាំត្រូវពឹងអាស្រ័យទៅលើ ទេពកោសល្យពីធម្មជាតិ ក៏ដូចជា ការខិតខំប្រឹងប្រែងរៀនសូត្របន្ថែមរបស់បុគ្គលម្នាក់ៗ ដើម្បីកសាងសមត្ថភាព និងគុណធម៌ ក្នុងភាពជាមេដឹកនាំ អស់រយៈពេលជាច្រើនឆ្នាំ។ទោះបីជាយ៉ាងនេះក្តី ក្នុងសម័យកាលបច្ចុប្បន្នមនុស្សម្នាក់ៗ គប្បីរៀនធ្វើខ្លួនជាមេដឹកនាំ ដើម្បីបន្តនិរន្តរភាពពីអ្នកដឹកនាំជំនាន់មុន ក្នុងពេលវេលាដ៏សមស្របណាមួយ អាស្រ័យទៅលើសមត្ថភាពការជឿជាក់លើខ្លួនឯងផ្ទាល់ និងទំនុកចិត្តពីអ្នកដទៃ ដើម្បីធ្វើជាមេដឹកនាំដោយស្របច្បាប់។ ម្យ៉ាងទៀត មេដឹកនាំក៏ជាស្នូលនៃការរីកចម្រើនរបស់សង្គមជាតិ។ មេដឹកនាំជាអ្នកនាំផ្លូវ និងបំភ្លឺផ្លូវឆ្ពោះទៅរកវឌ្ឍនភាព។ យ៉ាងណាមិញភាពមិនទទួលខុសត្រូវរបស់មេដឹកនាំស្របទៅតាមទំនុកចិត្តនិងក្តីសង្ឃឹមរបស់មនុស្សភាគច្រើន អាចនាំទៅដល់ភាពរលំរលាយចំពោះប្រទេសជាតិនោះ។ ដូច្នេះហើយ ការជ្រើសរើសមេដឹកនាំ បានត្រឹមត្រូវសម្រាប់ប្រទេសជាតិនីមួយៗ គឺជាកាតព្វកិច្ចដ៏សំខាន់បំផុតរបស់ប្រជាពលរដ្ឋគ្រប់ៗរូប៕

**គន្ថនិទ្ទេស**

១- ឃុតិមទូយ សម្តេច បកប្រែជាភាសាខ្មែរពីសៀវភៅដើមរបស់ នីកូឡូ ម៉ាកាវែល្លី គ្រឹះស្ថានបោះពុម្ព?, ឆ្នាំ១៩៩៦។

២- សុខ គាង់ *«វិទ្យាសាស្ត្រនយោបាយ»* សៀវភៅសម្រាប់បង្រៀន ឆ្នាំ២០០២

៣- សុខ សាធ *«កំណាប់សីលធម៌»* គឺជាគ្រឹះស្ថានបោះពុម្ពផ្សាយអង្គរ បោះពុម្ព លើកទី២ ឆ្នាំ២០១២

៤- ឡេង ចិន្តា *«មហាត្ម: គន្ធី និងគំនិត»* បកប្រែជាភាសាខ្មែរ គ្រឹះស្ថានបោះពុម្ពផ្សាយ Idea Book ឆ្នាំ២០១៣។

៥- អ៊ុំ ប៊ុម *«ប្រវត្តិគំនិតនយោបាយបស្ចិមប្រទេស»* គ្រឹះស្ថានបោះពុម្ពផ្សាយអង្គរឆ្នាំ២០០៨។

៦- Denny Richard Motivate to win, Edition Kogan Page London N19JN, year…?

# ធម្មចរិយានៃស្នាដៃគតិលោក

*ដោយៈ លោកស្រីបណ្ឌិត* **ជា វណ្ណី**
*ប្រធាននាយកដ្ឋានធម្មសាស្ត្រ ចរិយាសាស្ត្រ និង យេនឌ័រ*
*នៃវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គមនៃរាជបណ្ឌិត្យសភាកម្ពុជា*

## សេចក្តីផ្តើម

***ឧកញ៉ាសុត្តន្តប្រីជាឥន្ទ*** *បានរៀបរៀងស្នាដៃមួយដ៏ល្បីល្បាញ មានឈ្មោះថា «**គតិលោក**»។ ស្នាដៃនេះជាឃ្លាំងផ្ទុកចំណេះដឹងយ៉ាងទូលំទូលាយសម្រាប់អ្នកសិក្សាគ្រប់ស្រទាប់វណ្ណៈដែលអាចបណ្តុះការយល់ដឹងរបស់គេឱ្យកាន់តែស៊ីជម្រៅនិងកាន់តែប្រសើរឡើងថែមទៀត។ ដោយមើលឃើញពីគុណតម្លៃនៃស្នាដៃគតិលោករបស់លោកឧកញ៉ាសុត្តន្តប្រីជាឥន្ទ មានវិសាលភាពធំធេងយ៉ាងដូច្នេះហើយ ទើបស្មេរមានគំនិតសិក្សាវិភាគពីធម្មចរិយាដែលមាននៅក្នុងរឿងតំណាលនៃគតិលោកពីភាគទី១ ដល់ភាគទី១០ ដើម្បីជាចំណែកនៃការផ្សព្វផ្សាយចែករំលែកទៅអ្នកសិក្សាទុកគ្រាន់ជាសេចក្តីត្រិះរិះពិចារណាបន្ថែមសម្រាប់ការកសាងមាគ៌ាជីវិតរបស់ខ្លួនឱ្យកាន់តែល្អ កាន់តែប្រសើរនៃធម្មចរិយា ពោលគឺការសិក្សាស្នាដៃនេះនឹងអាចក្លាយជាគតិ ជាស្ពានមួយនៃពន្លឺទៅកាន់អ្វីដែលល្អត្រឹមត្រូវ និងជួយដាស់តឿនក្រើនរំឭកស្មារតីកូនចៅជំនាន់ក្រោយ ក៏ដូចជាយុវជនសម័យនេះឱ្យងាកមកចាប់អារម្មណ៍ធម្មចរិយា ដែលជាផ្នែកមួយនៃអត្តសញ្ញាណជាតិនិងនាំមនុស្សទៅរកវិបុលសុខនិងភាពរីកចម្រើន។*

*តាមទ្រឹស្តីនៃអក្សរសិល្ប៍ គេថាសង្គមបែបណាអក្សរសិល្ប៍បែបនោះ ដ្បិតអ្នកនិពន្ធគឺជាអ្នកនាំពាក្យ ជាមគ្គុទេស ជាភ្នែក ជាច្រមុះក្នុងការឆ្លុះបញ្ចាំងពីការពិតដែលកើតមានឡើងនៅក្នុងសង្គមតាមរយៈការតាក់តែងចងក្រងជានិម្មិតកម្មស្នាដៃឡើង។ យ៉ាងណាមិញ នៅក្នុងស្នាដៃតែងនិពន្ធ ឬអត្ថបទខ្លីៗ (គតិលោក) របស់ឧកញ៉ាសុត្តន្តប្រីជាឥន្ទទាំង១០ភាគ ក៏បានបង្កប់ទៅដោយទស្សនវិជ្ជាគតិបណ្ឌិតល្អៗដែលលាតត្រដាងនូវការពិតនៃតថភាពសង្គមផងដែរ។ តើស្នាដៃគតិលោករបស់ឧកញ៉ាសុត្តន្តប្រីជាឥន្ទទាំង១០ភាគមានរឿងអ្វីខ្លះ? ហើយរឿងទាំងនោះបានបង្ហាញពីតថភាពសង្គមនៃធម្មចរិយាដូចម្តេចដែរ?*

*មុននឹងយើងធ្វើការសិក្សាបកស្រាយពីលក្ខណៈនៃធម្មចរិយាតាមរយៈស្នាដៃគតិលោក យើងគោងយល់និងស្គាល់ពីជីវប្រវត្តិអ្នកនិពន្ធ និងស្នាដៃក៏ដូចជាពាក្យគន្លឹះមួយចំនួនជាមុនសិន។*

## ១- ជីវប្រវត្តិឧកញ៉ាសុត្តន្តប្រីជាឥន្ទ [១]

### វង្សត្រកូល

*ឧកញ៉ាសុត្តន្តប្រីជាឥន្ទ* កើតនៅថ្ងៃចន្ទ ខែអាសាឍ ឆ្នាំវក ព.ស.២៤០៣ ត្រូវនឹងថ្ងៃទី២២ ខែកក្កដា ឆ្នាំ១៨៥៩ នៅភូមិរកាកោង ស្រុកមុខកំពូល ខេត្តកណ្ដាល។ មាតាលោកនាម មុំ ឯបិតាលោកវិញនាម បញ្ចង់កែ ជាកសិករ និងជាអាចារ្យវត្ត។ កាលមិនទាន់មានងារជាឧកញ៉ានោះគេហៅបានលោកថា លោកអាចារ្យឥន្ទ ឬកវីឥន្ទ។ លោកអាចារ្យមានលក្ខណៈខាងក្រៅគួរជាទីស្រឡាញ់រាប់អានក្រៃលែង លោកចូលចិត្តនិយាយក្រមាច់ក្រមើមច្រើន តែអ្នកមានស្មារតីរឹងប៉ឹង មិនរវល់នឹងការងារឥតប្រយោជន៍ទេ។ ទៅណាមកណាលោកតែងស្លៀកសំពត់ ចងក្បិនពាក់អាវកត្រង់កាន់ដំបងប្រាក់ ពាក់មួកកាស ហើយបង្ហូសស្បែកជើងផ្ទាត់រលុង។ លោកសុត្តន្តប្រីជាឥន្ទជាអ្នកមានកិត្តិយសក្នុងសតវត្សទី២០ ជាកវីឯក ជាអ្នកចេះដឹងផ្នែកអក្សរសាស្ត្រខ្មែរ ជាអ្នកជំនាញប៉ិនប្រសប់ខាងតែងកាព្យឃ្លាឃ្លោងដ៏ពីរោះជាប់ចិត្ត ទាំងជាអ្នកព្យាយាមមុតមាំក្នុងការតែងកាព្យ និងតែងរឿងផ្សេងៗទុកជាច្រើន។

### ការសិក្សានិងការងារ

កាលដែលលោកមានអាយុប្រមាណជា១០ឆ្នាំ លោកបានទៅសិក្សាអក្សរខ្មែរនៅឯវត្តជាភូមិកំណើត លុះអាយុបាន១៥ឆ្នាំ លោកក៏បានបួសជាសាមណេរនៅវត្តព្រែកពោធិ៍ ដើម្បីរៀនប្រែព្រះបរិយត្តិបាលី។ បួសបានត្រឹម ១វស្សា លោកក៏បានសឹកចាកភេទជាសាមណេរ។ រួចទៅរៀននឹងគ្រូអាចារ្យពេជ នៅស្រុកព្រះត្រពាំង។ អាយុ១៨ឆ្នាំ លោកបានទៅរៀនជាមួយនឹងលោកព្រះពុទ្ធឃោសាចារ្យ ព្រះនាមប្រាក់ នៅឯវត្តឧណ្ណាលោម នាក្រុងភ្នំពេញ។ លុះអាយុបាន១៩ឆ្នាំ លោកក៏បានធ្វើដំណើរមករស់នៅឯស្រុកបាត់ដំបង ដោយស្នាក់នៅរៀនសូត្រជាមួយលោកគ្រូព្រះអាចារ្យសុខ នាវត្តកែវហើយក៏បានបួសជាភិក្ខុបាន១វស្សា ទើបលាព្រះឧបជ្ឈាយាចារ្យទៅរៀនសូត្រនៅក្រុងបាងកក ប្រទេសសៀម។ បាន៧ឆ្នាំ ក៏បានវិលមកស្រុកខ្មែរ ដែលជាមាតុភូមិកំណើតរបស់លោកវិញ ក្នុងអំណាចលោកកថាថនញ៉ុញ។ លោកគង់នៅវត្តកណ្ដាល ស្រុកបាត់ដំបងបាន១០វស្សា ក៏បានលាចាកសិក្ខាបទមកជាគ្រហស្ថវិញក្នុងអាយុ៣៧ឆ្នាំ ដោយបានរៀបការមានគ្រួសារនៅឯភូមិថ្លាធំ។ យើងពុំដឹងថាលោកមានបុត្រប៉ុន្មាននាក់ទេ តែយើងដឹងថាលោកមានបុត្រាម្នាក់នាម ឥន្ទសុន្ទរ៍។ ដោយលោកឥន្ទ គឺជាអ្នកចេះដឹងមួយរូបនៅក្នុងខេត្តដែលមានថ្វីដៃពូកែខាងតែងកំណាព្យ និងចេះដឹងលើរឿងធម៌អាថ៌បាលីបានជ្រៅជ្រះទៀតផងនោះ ត្រូវបានលោកកថាថនឈុំ ស្រឡាញ់រាប់អានរូបលោកណាស់ ដោយបានតែងតាំងរូបលោកជា «ហ្លួងវិចិត្រ

[១] *គតិលោក ឬច្បាប់ទូន្មានខ្លួន*ភាគ១ ព.ស.២៥៣៩ ទំ.២

វោហារ» ជាទីប្រឹក្សាកិច្ចការផ្សេងៗ ត្បិតលោកបានតាក់តែងកំណាព្យ និងបានប្រែបាលីជាសម្រាយមានទាំងអស់ ៤៤មុខជាសៀវភៅខ្លះចារស្លឹករឹតខ្លះៗ។

ក្រោយពេលដែលលោកកថាថនឈុំកាន់អំណាចគ្រប់គ្រងខេត្តបាត់ដំបងបានត្រឹមតែ១០ឆ្នាំ ពោលគឺនៅឆ្នាំ១៩០៧ ស្តេចសៀមក៏បានប្រគល់ខេត្តបាត់ដំបង សៀមរាប និងស៊ីសុផុនមកឱ្យខ្មែរវិញ តាមសន្ធិសញ្ញាចុះថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ១៩០៧ រវាងភាគីសៀមជាមួយនឹងភាគីរដ្ឋាភិបាលបារាំង ហើយក្រោយមកបន្តិច រដ្ឋាភិបាលបារាំងក៏បានប្រគល់ឥស្សរភាពផែនដីទាំងនេះមកឱ្យព្រះមហាក្សត្រខ្មែរវិញផងដែរ។ លោកកថាថនឈុំ និងគ្រួសារក៏បានចាកចោលខេត្តបាត់ដំបងទៅរស់នៅឯខេត្តបស្ចិមបុរី នាប្រទេសសៀមវិញ ហើយលោកឥន្ទ ដែលអ្នកស្រុកបាត់ដំបងនិយមហៅលោកថា «អាចារ្យឥន្ទ» មានអាយុប្រមាណជា៥៥ឆ្នាំ ហើយនោះក៏ត្រូវបានរាជការសុំឱ្យមកបំពេញកិច្ចការនៅឯរាជធានីភ្នំពេញវិញ ដោយមាននាទីជា «ឧកញ៉ាសុត្តន្តប្រីជាឥន្ទ»។ លោកឧកញ៉ាសុត្តន្តប្រីជាឥន្ទបានមកបំពេញកិច្ចការរាជការនៅឯរាជធានីអស់រយៈពេល១០ឆ្នាំ ពោលគឺចាប់ពីឆ្នាំ១៩១៤ ដល់ឆ្នាំ១៩២៤។ រាជការបានប្រោសឱ្យលោកជួយតែងចប់វចនាធិប្បាយខ្មែរ (ឬវចនានុក្រមខ្មែរ) នៅទីសាលាបាលីក្នុងវាំងអាយុ៥៥ឆ្នាំ ដល់អាយុ៦៥ឆ្នាំ។ នៅពេលដែលលោកអាយុ៦៥ឆ្នាំ លោកបានលារាជការវិលមករស់នៅឯស្រុកបាត់ដំបងដើមវិញ។ លុះដល់ថ្ងៃ១០កើត ខែអស្សុជ ឆ្នាំជូត ឆស័ក លោកកើតរោគក្អក បណ្តាកូនចៅរាល់គ្នា នាំគ្នាប្រតិបត្តិប្រកបថ្នាំរកគ្រូរក្សាពុំចេះធូរស្បើយឡើយ។ ក្រោមមកនៅថ្ងៃអាទិត្យ១២កើត ខែកត្តិក ឆ្នាំជូត ឆស័ក លោកឧកញ៉ាក៏ទទួលអានិច្ចកម្មនៅវេលាម៉ោង ៨ព្រឹក គឺត្រូវនឹងថ្ងៃទី៨ខែវិច្ឆិកាឆ្នាំ១៩២៤ ដោយរោគាពាធ។

លោកឧកញ៉ាសុត្តន្តប្រីជាឥន្ទ គឺជាកវីនិពន្ធខ្មែរដ៏ឆ្នើមមួយរូបនារវាងចុងសតវត្សទី១៩ និងដើមសតវត្សទី២០ ដែលអ្នកផងទូទៅរមែងតែងរាប់អាននិងគោរពលោកណាស់ ក្នុងនាមរូបលោកជាអ្នកមានចំណេះចេះដឹងជ្រៅជ្រះមួយរូប ជាពិសេសនេះស្រុកបាត់ដំបងនេះតែម្តង។ លោកបានបន្សល់ទុកស្នាដៃជាច្រើន ហើយក្នុងនោះមានស្នាដៃសំខាន់២ ដែលជាកញ្ចក់ឆ្លុះអំពីជីវភាពអ្នកស្រុកខ្មែរនាសម័យជំនាន់គ្រួសារត្រកូលអភិវង្ស ដែលបានបានត្រួតត្រាខេត្តបាត់ដំបង ពោលគឺសៀវភៅរឿងចម្បាំងតាកែវ និងគតិលោក។

កាលជំនាន់លោក ប៉ៃណា តង់ដារ បេសកសង្ឃកាតូលិកនៅខេត្តបាត់ដំបង ពីឆ្នាំ១៩០១ ដល់១៩០៤ ក៏ធ្លាប់បានទៅប្រឹក្សារៀនសូត្រអក្សរខ្មែរពីសំណាក់លោកអាចារ្យឥន្ទផងដែរ។ បេសកម្មសង្ឃកាតូលិករូបនេះបានចងក្រងវចនានុក្រមខ្មែរ-បារាំង ដែលមាន

ឈ្មោះថា វចនានុក្រមតង់ដារ ដោយមានជំនួយយ៉ាងច្រើនពីលោកឧកញ៉ា សុត្តន្តប្រីជាឥន្ទ នៅក្នុងការចងក្រងវចនានុក្រមមួយនេះឡើង។

លោកឧកញ៉ា សុត្តន្តប្រីជាឥន្ទ ជាកិត្តិយសដ៏ធំណាស់សម្រាប់ខេត្តបាត់ដំបង នៅសម័យខេត្តនេះនៅក្រោមអំណាចសៀមអស់ជាងមួយសតវត្ស។ គាត់ជាកស្តុតាងបញ្ជាក់ថា សៀមអាចជ្រៀតជ្រែកបានតែក្នុងវិស័យរដ្ឋបាលតែប៉ុណ្ណោះ តែមិនអាចជ្រៀតជ្រែកផ្នត់គំនិតខ្មែរនៅបាត់ដំបងដែលជាខ្មែរបាននោះទេ។

លោកឧកញ៉ាសុត្តន្តប្រីជាឥន្ទ ជាជនគំរូអ្នកប្រាជ្ញទំនៀមនៅសម័យនោះ លោកចេះដឹងយ៉ាងច្បាស់លាស់នូវព្រះពុទ្ធសាសនា ចេះស្ទាត់នូវភាសាថៃ និងភាសាបាលីថែមទៀតផង។ នៅខេត្តបាត់ដំបង លោកឧកញ៉ាសុត្តន្តប្រីជាឥន្ទ មានមិត្តស្និទ្ធស្នាលម្នាក់នាមឈឹម ជាហោរនៅក្នុងស្រុកភូមិនោះដែលមានសំនួនវោហារខាងកាព្យឃ្លោងម្នាក់។ លោកតាឈឹម នេះតែងតែប្រឹក្សាចោទឆ្លើយជាមួយលោកសុត្តន្តប្រីជាឥន្ទជាញឹកញាប់។[2]

## ស្នាដៃរបស់លោកសុត្តន្តប្រីជាឥន្ទ

តាមរយៈការសិក្សាស្រាវជ្រាវនាពេលកន្លងមកបានរកឃើញថាលោកឧកញ៉ាសុត្តន្តប្រីជាឥន្ទ បានតាក់តែងស្នាដៃមានទាំងអស់ ៤៤មុខ។ ស្នាដៃសំខាន់ៗមានដូចជា៖

. គតិលោក ឬច្បាប់ទូន្មានខ្លួនពាក្យរាយ ១០ភាគ។ តាក់តែងចប់ថ្ងៃព្រហស្បតិ៍ ៥រោច ខែអស្សុជ ឆ្នាំរកា ទោស័ក ព.ស.២៤៦៤ ត្រូវនឹងគ.ស.១៩២១។ សៀវភៅនេះបោះពុម្ពលើកទី២ ឆ្នាំ១៩៧១ ដោយពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ។ ស្នាដៃគតិលោកទាំង១០ភាគនោះ មានចំនួន១១៧រឿង៖

គតិលោកភាគទី១ មាន១០រឿង៖

១- ប្រវត្តិឧកញ៉ាសុត្តន្តប្រីជាឥន្ទ

២- ស្នាដៃអំពីគតិលោក

៣- ធម៌ដែលគ្រហស្ថត្រូវប្រព្រឹត្ត

៤- រឿងស្រីល្អ ទឹកផ្អែម ត្រីដែលមានរសពីសាលើសត្រីនានា

៥- ទោសកើតអំពីជក់អាភៀននិងកញ្ឆា

៦- ប្រស្នារឿងពាលគួរឱ្យខ្លាច

៧- រឿងឃុនរ៉ាត់ចាញ់បោកចៅពាល

៨- រឿងចៅពាលក្លែងភេទជាសង្ឃធ្វើគ្រូមើលស្ពន់

៩- រឿងពាលសង្រួមហួសប្រមាណ

១០- រឿងតាថេននិងសិស្សបីនាក់

គតិលោកភាគ២

១- សិស្សនិងគ្រូចោទឆ្លើយលក្ខណៈរបស់មនុស្សពាល

២- រឿងចៅឡុចនិងចៅប្រាក់

៣- រឿងចៅអធិការវត្តកោះ(ទន្លេធំ)

៤- រឿងលោកសង្ឃសាងវិហារ

---

[2] តូច ឈួង *បាត់ដំបងសម័យលោកម្ចាស់១៩៧៤។*

៥- រឿងឧកញ៉ាញៀនអាភៀនប្រើអំណាច

៦- រឿងកូនចៀមនិងឆ្កែព្រៃ

៧- រឿងភិក្ខុសុខជាពួងគ្រូ

៨- រឿងបណ្ឌិតវត្ត

៩- រឿងអរិយទ្រព្យ៧ ប្រការ

១០- រឿងសប្បុរសធម៌៧ ប្រការ

១១- រឿព្រាហ្មណ៍ចាស់មានភរិយាក្រមុំ

១២- រឿងសត្វសំពោចនិងមាន់ចៃ

១៣- រឿងសត្វឥន្ទ្រីរបស់ព្រះឥសូរចង់ស៊ីស្តេចដំរី

១៤- រឿងក្មេងកំព្រានិងព្រះចៅផែនដី

១៥-រឿងព្រះចៅផែនដីនិងក្មេងឃ្វាលក្របី

គតិលោកភាគ៣ មាន១៨រឿង៖

១- រឿងសត្វកន្ទង់និងគីង្គក់

២- រឿងធនញ្ជ័យបណ្ឌិតនិងអ្នកប្រាជ្ញកោះលង្កា

៣- រឿងអាមាត្យព្រះបាទពិម្ពិសារាជ្យ

៤- រឿងព្រះធនិយថេរ និងនាយសមុហបញ្ជី

៥-លោកធម៌៨ប្រការសក្ការៈបូជាទឹកបឹង

៦- សក្ការៈបូជាដើមដង្កោ

៧- គោស្នារខ្មៅ

៨- សក្ការៈបូជាយាយទេព

៩- រឿងភ្នំក្រោមនៅខេត្តសៀមរាប

១០- រឿងតាហូលាន

១១- រឿងចៅឆោតជិះក្របីទូលស្រូវ

១២-រឿងសឹង្ហតោចង់បានកូនក្រមុំដង្ហោម្នាក់

១៣- រឿងនាងអមរាទេវី

១៤- រឿងក្រពើនិងអ្នកបររទេះ

១៥- រឿងក្រពើផើមចង់ស៊ីថ្ងៃមស្វា

១៦- រឿងក្អែកនិងសំពោច

១៧- រឿងចចក និងរាជសីហ៍

១៨-រឿងព្រានព្រៃនិងសត្វសេក

គតិលោកភាគ៤ មាន១០រឿង៖

១- ពណ៌នាសេចក្តីឆោត

២- រឿងនិទានពីយាយចាស់ល្មោភកាម

៣- រឿងព្រះចម្រើនពលទិព្យ

៤- និទានពីសត្វវៃកំដិល

៥- និទានពីក្អែកគោកត្រាប់ក្អែកទឹក

៦- និទានពីចចក ស្វា ឆ្កែព្រៃ

៧- និទានពីកណ្តុរពីរជាសំឡាញ់គ្នា

៨- និទានពីរចចកល្មោភ

៩- និទានពីឆ្កែស្រុកមានប្រឡោក

១០- និទានពីមេឆ្កែផើម

គតិលោកភាគ៥ មាន១៦រឿង៖

១- រឿងចចកនិងទុង

២- រឿងសត្វទុងនិងត្រី

៣- រឿងសត្វកណ្តូបនិងដើមសង្កែ

៤- រឿងសត្វក្អែកនិងខ្មោចឆ្កែ

៥- រឿងចៅអធិការនិងសិស្សពីរនាក់

៦- រឿងព្រះមហិស្សរាធិបតីសាងលោក

៧- រឿងចក្រាមហិស្សរាធិបតី និងស្រមោចខ្មៅ

៨-រឿងស្មាន់ក្អែកអណ្តើកជាសំឡាញ់គ្នា

៩- រឿងសត្វស្មាន់ក្អែក និងចចក

១០- រឿងស្ដេចព្រាបនិងបរិវារ

១១- រឿងចចកនិងដំរី

១២- រឿងសត្វកណ្ដុរនិងមេឆ្មា

១៣- រឿងកាឡុកិណីជាសំឡាញ់នឹងគ្នា

១៤- រឿងពពែពីរគូដណ្ដើមផ្លូវគ្នា

១៥- រឿងរាជសីហ៍និងកង្កែប

១៦- រឿងទន្សាយនិងមេខ្លា

គតិលោកភាគ៦ មាន១១រឿង៖

១- រឿងសត្វកង្កែបនិងគោឈ្មោលត្រាប់តាមកូនខ្លែ

២- រឿងចៅគង្វាលពពែ

៣- រឿងចៅមាណពនិងមេឆ្មា

៤- រឿងចៅមាណពចិញ្ចឹមសុខនតឿ

៥- រឿងខ្លែរង្វេងម្ចាស់និងមហាឥសី

៦- រឿងឧកញ៉ា យោមរាជ និងឧកញ៉ាពលទេព

៧- រឿងឆ្មាស្រុកនិងចាបពូក

៨- រឿងសត្វសំពោចក្នុងជង្រុកស្រូវ

៩- រឿងឈ្មួញលក់លានិងពួកចោរព្រៃ

១០- រឿងលា និងខ្លែមានចៅហ្វាយជាមួយគ្នា

១១- រឿងដៃជើងប្រណែននឹងមាត់

គតិលោកភាគ៧ មាន៨រឿង៖

១- រឿងមេខ្លែនិងខ្មោចអសុព

២- រឿងរឿងនាយដង្ហោនិងកូនឈ្នួល

៣- រឿងបុរសចុះវាយគង

៤- រឿងឪពុកនិងកូននាំលាទៅលក់

៥- រឿងចៅចាក់ស្នូគ

៦- រឿងសត្វហង្សនិងអណ្ដើក

៧- រឿងរាជសីហ៍ស្រឡាញ់មេគោ

៨- រឿងស្វាពឹសលិង្គនឹងមហាឥសី

គតិលោកភាគ៨ មាន១២រឿង៖

១- រឿងតាភោគនិងក្មេងវត្ត

២- រឿងចៅខ្ញុំគេសម្លាប់មាន់រងាវ

៣- រឿងស្ត្រីមានប្ដីជក់អាភៀន

៤- រឿងបុរសប្ដីប្រពន្ធចិញ្ចឹមសត្វស្កា

៥- រឿងបុរសចិញ្ចឹមខ្លាឃ្មុំ

៦- រឿងខ្លាឃ្មុំនិងដើមពជ្រ

៧- រឿងគ្រលេងគ្រលោងនិងស្វា

៨- រឿងពស់ក្បាលច្រើនកន្ទុយមួយនិងពស់ក្បាលមួយកន្ទុយច្រើន

៩- រឿងគីសមុទ្រនិងកង្កែបថ្មុក

១០- រឿងចៅរ៉ែនរកទិញរ៉ែនតា

១១- រឿងចៅទ្រិសបានប្រពន្ធក្នុងវាំង

១២- រឿងរឿងទន្សាយនិងផ្លែញ្ញោ

គតិលោកភាគ៩ មាន៩រឿង៖

១- រឿងសត្វស្កាពីរបែកផ្លូវគ្នារកចំណី

២- រឿងត្របៀកកាំនិងគ្រាប់ផ្លែ

៣- រឿងព្រានសន្ទូច

៤- រឿងអទិន្នបុព្វកព្រាហ្មណ៍

៥- រឿងមនុស្សចង់ស្លាប់ស្រមោចនិងសិង្ហតោ

៦- រឿងបង្គួយនៅក្លោងទ្វារព្រះបាទវិទេហរាជ្យ

៧- រឿងព្រានព្រៃចាប់សារិកា

៨- រឿងចៅសញ្ជីវមាណពប្រស់ខ្លា

៩- រឿងខ្មោចចូលជប

គតិលោកភាគ១០ មាន៨រឿង៖

១- រឿងសត្វកេពីរបែកផ្លូវគ្នារកអាហារ

២- រឿងបុរសម្នាក់ស្លាប់ទៅកើតជាហង្ស មាស

៣- រឿងបុរសចិញ្ចឹមមេមាន់ចចកចេះ មន្តអាគមន៍

៤- រឿងពលសត្វទៅដណ្ដើមយកនគរ ពារាណសី

៥- រឿងនន្ទកយក្សនិងអ្នករក្សាខ្លោងទ្វារ ព្រះឥសូរ

៦- រឿងស្វាព្រាមមួយបានមេស្វាឪជា ភរិយា

៧- រឿងស្រីផិតប្ដីមិនឱ្យប្ដីដឹង

៨- រឿងភរិយានាយសំពៅនៅស្រុកយា វ័ណរតី។

. និរាសអង្គរវត្ត ពាក្យកាព្យ (ប្រភេទបទ ពាក្យ៨) តែងនៅថ្ងៃព្រហស្បតិ៍ ៩កើត ខែ កត្រូបទ ឆ្នាំរកា គ.ស.១៩០៩ ភ្នំពេញ ពុទ្ធ សាសនបណ្ឌិត្យ ១៩៦៩។

. សុភាសិតច្បាប់ស្រី ពាក្យកាព្យកម្ពុជ សុរិយា ឆ្នាំ១៩៣៤ (ក្បាលទី៣ ចាប់ពីខ្សែ ៧ ៨ ៩ រួមគ្នា) ចាប់ពីទំព័រ៥៨១។

. រឿងអំបែងបែក ឬព្រះសោនន្ទរាជ ពាក្យកាព្យ តែងនៅថ្ងៃ១៥កើត ខែកត្តិក ឆ្នាំឆ្លូវ ត្រីស័កព.ស.២៤៤៤ ត្រូវនឹងថ្ងៃច័ន្ទ ទី២៥ ខែ វិច្ឆិកា គ.ស.១៩០១ ២ភាគ ភ្នំពេញបណ្ណាគារ ជីង ង្វួនហ៊ួត គ.ស.១៩៥៣។

. លោកនីតិបករណ៍ ភ្នំពេញ ពុទ្ធ សាសនបណ្ឌិត្យបោះពុម្ពលើកទី២ ឆ្នាំ ១៩៥៣។

. ព្រះរាជពង្សាវតារខ្មែរ បកពីភាសា សៀម មកជាខេមរភាសា។

. រឿងបឋមសម្ពោធិបទល្ខោន កម្ពុជ សុរិយាលេខ ១០ ១១ ១២ រួមគ្នា ឆ្នាំ១៩៣៤ ទំព័រ៥៣៨។

. កាព្យសារវិសារវិលានី ក្បួនតែងកាព្យ ឃ្លោងផ្សេងៗ របស់លោកឧកញ៉ាសុត្តន្តប្រីជា ឥន្ទ កាលធ្វើការនៅឯបាត់ដំបង ក្នុងគោរម្យ ងារជាទីហ្លួងវិចិត្រវោហារឥន្ទ តែងក្នុងរវាងព. ស.២៤៣២ ត្រូវនឹងគ.ស.១៨៨៩។

. រឿងចម្បាំងតាកែវ (មិនច្បាស់កាលបរិច្ឆេទ) តែងនៅក្នុងជំនាន់លោកកថាថន ឈុំ។[៣]

## ២. ធម្មចរិយានៃស្នាដៃគតិលោក

តាមរយៈការសិក្សាស្នាដៃគតិលោកនៃ ឧកញ៉ាសុត្តន្តប្រីជាឥន្ទ ឃើញថាស្នាដៃនេះ បានលាតត្រដាងឱ្យឃើញពីទស្សនាទានពិត នៃគំនិតគតិនិយមដោយបង្កប់នូវតម្លៃអប់រំល្អ ពិតៗនៃធម្មចរិយា ពោលគឺជួយណែនាំឱ្យ យើងបានស្គាល់ពីប្រភេទឬលក្ខណៈនៃ មនុស្ស ដែលជាស្ពានឬជាកញ្ចក់ឆ្លុះបញ្ចាំងពី ដំណើរជីវិតពិតរបស់យើងក្នុងការស្វែងរក សេចក្ដីសុខសុភមង្គលក្នុងជីវិត ដូចតទៅ៖

[៣] យីង ហុកឌី *សុត្តន្តប្រីជាឥន្ទ* និងស្នាដៃ ២០១២។

### ២.១- លក្ខណៈមនុស្សជាជនពាល

ជនពាល គឺជនកាចដែលកាចឬសាហាវ។ នៅក្នុងសង្គមលក្ខណៈមនុស្សមានច្រើនប្រភេទ ច្រើនសណ្ឋានដែលយើងត្រូវស្គាល់និងត្រូវសិក្សាស្វែងយល់ឱ្យបានច្បាស់លាស់។ ជនពាលមានលក្ខណៈផ្សេងៗពីគ្នា។ ជនពាលមួយចំនួនក៏មានលក្ខណៈជាជនពាល គឺសម្គាល់ជនកិរិយាមារយាទដែលវញ្ចេញមកត្រង់ៗ ដូចជាដឹងតែពីផឹកស្រា ជក់គ្រឿងញៀន ស្លៀកពាក់មិនចុះចំណោមនឹងគេ ដើរក្រលៃក្រលបង្កពាក្យជំលោះឈ្លោះប្រកែកប្រកាប់ប្រចាក់គ្នារកទីបំផុតគ្មានពោលគឺបញ្ចេញចរិតចំជាជនពាល។ ឯជនពាលមួយចំនួនទៀត គឺជនពាលដែលវាក្លែងធ្វើកិរិយា ប្រើអាការស្លៀកពាក់សមរម្យរៀបរយសំដែងកិរិយាសុភាពរាបសា ឬក៏បន្ទំកោរក្បាល ស្លៀកស្បង់ពាក់ចីវរ ហើយតាំងខ្លួនជាមនុស្សត្រឹមត្រូវបរិសុទ្ធគួរជាទីទុកចិត្តជឿរាប់អាននៃមនុស្សទាំងពួង ពោលគឺពួកពាលវាក្លែងលួចភេទនោះ មកធ្វើជាភិក្ខុ ឬសាមណេរ ដើរកុហកបញ្ឆោតអ្នកនគរឱ្យខូចផលប្រយោជន៍ទៅដោយប្រការផ្សេងៗក៏មាន។ ដូច្នេះការស្គាល់មនុស្សមិនច្បាស់លាស់អាចនាំឱ្យយើងសម្រេចចិត្តខុស ឬនាំឱ្យខូចផលប្រយោជន៍ស្ដាយក្រោយ ដែលលោកឧកញ៉ាសុត្តន្តប្រីជាឥន្ទ លោកបានណែនាំនិងចង្អុលបង្ហាញពីលក្ខណៈមនុស្សនេះ ទុកឱ្យយើងយកជាគតិពិចារណាស្វែងយល់ដោយធ្លុះបញ្ចាំងតាមរយៈស្នាដៃគតិលោករបស់លោកក្នុងភាគទី១ ដល់ភាគទី១០ ជាពិសេសគឺលក្ខណៈនៃជនពាលដែលមានដូចមានខាងក្រោម៖

#### *២.១.១- លក្ខណៈមនុស្សពាលព្រោះមានចិត្តលោភលន់*

បើយើងក្រឡេកមកមើលជនពាលមាននៅគ្រប់ទីកន្លែង មិនថាបងប្អូនកូនចៅសាច់សាលោហិត ឬជាញាតិផៅជិតឆ្ងាយឡើយ សូម្បីបុព្វជិតបួសជាអ្នកកាន់សីលហើយក៏នៅមានកិលេសតណ្ហាដែលមិនទាន់អាចកាត់ផ្ដាច់បាន គឺនៅមានចិត្តសាមាន្យលោភលន់ចង់បានទ្រព្យសម្បត្តិគេដោយឥតខ្មាស់ទៀតផង។

នៅក្នុងរឿងតំណាលពាលសង្រ្គមហួសប្រមាណ គតិលោកភាគទី១ តាបសជាតួអង្គតំណាងឱ្យមនុស្សលោភលន់ មានចិត្តមិនទៀងត្រង់ ភូតកុហក និងជាមនុស្សដែលមិនស្គាល់បុណ្យបាប បោកប្រាស់ម្ចាស់ទ្រព្យដោយគ្មានអៀនខ្មាស។ សំដីតាបសបាននិយាយថា «...អញនឹងលួចយកទៅធ្វើជាដើមទុន ប្រកបការខាងផ្លូវលោកិយក៏បានហើយ តែនឹងលួចយកទៅឥឡូវនេះ ឧបាសកនឹងសង្ស័យ។ បន្ទាប់មកក៏គិតឃើញឧបាយមួយដោយបង្វែងដានម្ចាស់គេ ក៏យកហិបទៅកប់កន្លែងផ្សេង ហើយបានរៀបចំសំពាយទៅផ្ទះឧបាសកដែលផ្ញើហិបនោះ។ នៅពេលទៅដល់ផ្ទះឧបាសកម្ចាស់ហិប គាត់ក៏ប្រាប់ថានឹងលា

អ្នកទាំងអស់គ្នាទៅនៅក្នុងព្រៃព្រះហេមពាន្តឡិតទីលំនៅសព្វថ្ងៃនេះនៅជិតទៀបស្រុកមនុស្សម្នាទៅមកមិនដាច់ នាំឱ្យកង្វល់រវល់ក្នុងការលោកិយច្រើន»។ លុះពេលលាចេញមកវិញហើយ តាបសឆ្មៀតធ្វើជាបង្ហាញថាខ្លួនល្អ ស្មោះសទៀងត្រង់ ក៏ត្រឡប់ចូលទៅជូនម្ចាស់ផ្ទះវិញនូវស្មឹកស្បូវដែលជាប់បាក់ជាប់នឹងសក់របស់លោក។ យ៉ាងណាមិញ នាពេលបច្ចុប្បន្ននេះក៏មានតាបស ឬអ្នកកាន់សីលដែលដើរតួជាអ្នកទ្រទ្រង់ព្រះពុទ្ធសាសនាមួយចំនួននោះ បានយកព្រះពុទ្ធសាសនាមកធ្វើជាខែលបិទបាំងអំពើអាក្រក់របស់ខ្លួន ហើយដើររែអង្គាសបច្ច័យតាមគ្រប់រូបភាព ឬនិមន្តបិណ្ឌបាតដើម្បីយកប្រាក់រក្សាទុកធ្វើកម្មសិទ្ធិផ្ទាល់ខ្លួ និងដើម្បីធ្វើជាមានបាន។

រីឯក្នុងរឿង ទុង និងត្រី នៃគតិលោកភាគទី៥ ទុងជាសត្វដែលមានទិដ្ឋិរើសអើងតម្កើងខ្លួនហួសប្រមាណ។ ត្រីតូចៗ មានដូចជា ពួកត្រីក្អិត ត្រីចង្វា ត្រីចង្វាភ្លៀងជាដើម ទុងមិនខ្ចីស៊ីជាអាហារឡើយ ព្រោះខ្លួនយល់ថាមិនសក្តិសមនឹងខ្លួនដែលជាសត្វធំ។ ទុងគិតថា អាត្មាអញនេះជាបក្សីរូបធំត្រូវបរិភោគត្រីធំៗ តួយ៉ាងត្រីរ៉ស ត្រីឆ្តោ ត្រីប្រាជាដើមនោះ ទើបសមនឹងសក្តិយសរូបអញនេះ។ ថាហើយទុងក៏តាំងហែលរកចាប់ត្រីណាធំៗតាមដែលខ្លួនប្រាថ្នា កាលបើចាប់បានត្រីតូចៗគេលែងទៅវិញជារឿយៗ។ លុះវេលាល្ងាចមកដល់ ការរង់ចាំចាប់ត្រីធំៗមិនបានដូចបំណងឡើយ ឯថ្ងៃក៏កាន់តែរៀបអស្តង្គតងងឹតមកដល់ ទុងសោកស្តាយព្រោះសេចក្តីស្រេកឃ្លានក៏កាន់តែមានខ្លាំងឡើងៗ។ លក្ខណៈសក្កាយទិដ្ឋិរបស់សត្វទុងនេះ គឺលោកចង់ប្រៀបធៀបដូចកូនអ្នកមានត្រកូលខ្ពស់បានទៅរៀនចេះជ្រៅជ្រះមកពីប្រទេសក្រៅហើយចូលមកប្រទេសខ្លួនវិញ រាជការបានតាំងឱ្យធ្វើការបើកប្រាក់ខែត្រឹមល្មមៗ ខ្លួនមិនទទួលធ្វើ ដោយប្រកាន់ខ្លួនថាខ្លួនជាត្រកូលធំប្រាក់ខែប៉ុណ្ណេះមិនសមនឹងចំណេះដឹងត្រកូលខ្លួន គិតចាំយកប្រាក់ខែច្រើនជាទុនធំតែម្តង ដូចទុងចាំយកត្រីរ៉ស ត្រីឆ្តោ ត្រីប្រា ដល់រកមិនបាន កើតការស្តាយក្រោយនូវទុនតូចដែលគេប្រុងឱ្យក្នុងកាលមុននោះឯង។ តម្រានេះជាគតិ «រកស៊ីមិនសន្សំពីវត្ថុតូចៗ» ។

## ២.១.២- លក្ខណៈមនុស្សពាលព្រោះកាមតណ្ហានិងផិតក្បត់

នៅក្នុងរឿងនិទានពីស្ត្រីនៅភូមិស្រុកស្មោង ដីក្រែង ស្ត្រីនោះឯងទៅសាហាយនឹងចៅអធិការមួយអង្គនៅក្នុងវត្ត បណ្តាលឱ្យកើតការស្អប់ប្តីអាត្មា ទើបវាទៅជួលអ្នកលេងឱ្យបាញ់មេឃុំជាប្តីស្លាប់ទៅ។ អំពើបែបនេះសុទ្ធតែកើតឡើងដោយសារកាមគុណជាធំ។ យើងចាត់ទុកការប្រព្រឹត្តបែបនេះថាជាកំហុសដ៏ធ្ងន់ធ្ងរមិនអាចអត់ឱនឱ្យបានឡើយ គឺជាភាពល្ងង់ខ្លៅមួយនៃមនុស្សស្រីដែលនាំគ្រួសារឱ្យខ្ទេចខ្ទាំ បាត់បង់អស់នូវកិត្តិយសកេរ្តិ៍ឈ្មោះគ្រួសារ ហើយបើនាងមានកូនផងនោះ

កូនក្នុងបន្ទុកនឹងរងភាពអាមាស ខ្មាសអស់ញាតិសន្តាន មិត្តភក្តិ ក្លាយទៅជាជនរងគ្រោះដោយមិនដឹងខ្លួន។ ថាគ្រហស្ថទៅនៅមានកិលេសកាត់មិនបាន ចុះហេតុអ្វីចៅអធិការវត្តបួសជាព្រះសង្ឃទៅហើយនៅជិតដាមដោយកាមគុណដែរ? ការនេះគឺជាគំរូអាក្រក់មួយដែលព្រះសង្ឃហ៊ានប្រព្រឹត្តស្នេហាលួចលាក់បណ្តាលឱ្យកើតរឿងអាស្រូវគ្រប់ទិសទី។ ជាទូទៅសង្គមខ្មែរយើងតែងតែគោរពព្រះពុទ្ធសាសនា ហើយដែលមានព្រះសង្ឃជាពំនាក់ជាទីគោរពរបស់ពុទ្ធបរិស័ទ ដល់ពេលព្រះសង្ឃប្រព្រឹត្តអំពើបែបនេះតើ វានឹងនាំឱ្យព្រះពុទ្ធសាសនាទៅជាបែបណា? នេះជាគំរូអាក្រក់ដែលតែងតែកើតមានជាញឹកញយនៅក្នុងសង្គមខ្មែរយើងនាពេលបច្ចុប្បន្ន ព្រោះតែការមិនអប់រំចិត្តឱ្យនៅក្រៅអំពើអាក្រក់ មិនបានបែងចែកឱ្យដាច់ស្រេចរវាងគុណនឹងទោសនៃកាមគុណខុសសីលធម៌ និងច្បាប់សង្គមទាំងមូល។

បើតាមផ្លូវពុទ្ធចក្រ ទីអារាមសាសនាគឺជាយានមួយដែលទុកដូចជាកន្លែងគោរពសក្ការៈ ជាទីពំនាក់របស់អ្នកគោរព ពិសេសជាកន្លែងដែលផ្តល់ការអប់រំចិត្តគំនិត បណ្តុះបណ្តាលចំណេះដឹងដល់មនុស្សគ្រប់ស្រទាប់វណ្ណៈមិនរើសរីងស្ងួត ទុកដូចជាសាលាពហុបច្ចេកទេសផង ជាបណ្តុំវប្បធម៌របស់ប្រទេសយើងផង ហេតុដូច្នេះហើយ យើងមិនត្រូវយកសាសនាមកលេងសើចយកធ្វើជាខែលដើម្បីទាញយកផលប្រយោជន៍ ឬដើរបោកបញ្ឆោតអ្នកដទៃឱ្យគេលង់ ឱ្យគេជឿគោរពបូជា តែសំបកក្រៅឱ្យសោះ។ ប្រសិនបើយើងយកមកធ្វើដូច្នេះនោះថ្ងៃខាងមុខសាសនានឹងកាន់តែសាបរលាបបន្តិចម្តងៗ គ្មានអ្នកគោរពបូជាទៀតឡើយ តួយ៉ាងដូចជាតួអង្គតាបស ខំតាំងខ្លួនជាអ្នកមានសីល ស្លៀកស ពាក់ស ឱ្យល្អមើលពីខាងក្រៅតែចិត្តគំនិតពោរពេញដោយការបោកប្រាស់ ដូចករណី បោកប្រាស់ឧបាសក ដោយមិនបានខ្លាចញញើតនូវទោសដែលខ្លួនបានប្រព្រឹត្ត។ ម្យ៉ាងវិញទៀតនៅក្នុងទស្សនៈព្រះពុទ្ធសាសនា តែងទូន្មានថា អ្នកធ្វើល្អបានល្អ អ្នកធ្វើអាក្រក់បានអាក្រក់ ដែលជាការអប់រំទៅដល់មនុស្សទូទៅឱ្យចេះសាងអំពើល្អ ជៀសវាងការប្រព្រឹត្តខ្លួនខុសត្លងអកុសលកម្ម។

កាមរាគនេះបានធ្វើឱ្យមនុស្សវង្វេងមិនស្គាល់បងប្អូន បងថ្លៃប្អូនថ្លៃ ដូចស្រីជាបងថ្លៃបានត្រូវអំណាចនៃកាមតណ្ហាអូសទាញបាន ហើយទៅងប់ងល់នឹងបុរសជាប្អូនថ្លៃរហូតដល់ហ៊ានប្រព្រឹត្តអំពើឃាតកម្ម គឺស្រីជាភរិយាបញ្ជាឱ្យបុរសជាសហាយរកវិធីសម្លាប់ប្តីដើមចោល។ រីឯស្ត្រីម្នាក់នៅស្រុកចក ខេត្តត្នោត ដែលជាកូននាយជាងមាសក៏ពោរពេញដោយកាមរាគ នាងមិនខុសពីស្រីជាបងថ្លៃបុរសខាងលើឡើយ។ ស្ត្រីជាកូននាយជាងមាសរូបនេះក៏បានប្រើល្បិចដើម្បីសម្លាប់ប្តីដើម ហើយទៅរស់នៅជាមួយសហាយរបស់

នាង។ ការប្រព្រឹត្តរបៀបនេះគឺជាការបង្ហាញពីភាពសាហាវឃោរឃៅពន់ពេកមកលើប្តីរបស់នាង ដែលជាជនស្លូតត្រង់ព្រោះតែកាមេដឹកនាំ។ ដរាបណាមនុស្សយើងគ្រប់រូបគ្រប់អាត្មា បណ្តោតបណ្តោយឱ្យអំណាចនៃកាមតណ្ហាគ្របសង្កត់បាន ដរាបនោះភាពវង្វេងវង្វាន់នឹងកើតមានឡើងដូចករណីស្ត្រីនៅស្រុកចក ខេត្តត្នោត បានរកឧបាយកលឱ្យសហាយសម្លាប់ប្តីនាងចោលហើយទៅនៅរួមរស់ជាមួយសហាយនាងយ៉ាងដូច្នោះ។ លក្ខណៈស្ត្រីទាំងពីររូបខាងលើមិនសូវខុសគ្នាប៉ុន្មានឡើយ នាងបានយកសេចក្តីស្នេហាជាធំគឺការប្រព្រឹត្តខុសពីទំនៀមទម្លាប់ប្រពៃណីខ្មែរយើង ដែលអ្នកទាំងពីរសុទ្ធតែមានគ្រួសាររួចហើយ ប៉ុន្តែអ្វីដែលសង្គមមនុស្សទាំងមូលរិះគន់ និន្ទាគឺនាងមានកេរ្តិ៍ឈ្មោះអាស្រូវកោសទាំងនេះគឺព្រោះតែភាពល្មោភកាមគុណ ងប់ងល់នឹងល្បែងស្នេហាជាមួយប្រុសផ្សេងដែលមិនមែនជាប្តីខ្លួនដើម្បីបំពេញតែចំណង់តណ្ហាតែប៉ុណ្ណោះ។

*២.១.៣- លក្ខណៈមនុស្សពាលព្រោះភាពរមិលគុណ*

នៅក្នុងរឿងនិទានពីកូនពាលអវជាតិបុត្រ អកតញ្ញូ គឺកូនមិនត្រឹមតែពុំដឹងគុណមាតាបិតាទេ គេថែមទាំងបានយកមាតាបិតារបស់ខ្លួនទៅសម្លាប់ចោលក្នុងព្រៃស្មសានដែលមាណពនោះត្រូវទោសអនន្តរិយកម្មធ្លាក់ទៅសោយទុក្ខវេទនាក្នុងមហាអវចីនរកអស់កំណត់ លុះដល់កទ្ទកប្បនេះ។ ជាការត្រឹមត្រូវ ការលើកពីតម្លៃគ្រួសារត្រូវ ផ្តើមចេញពីការជឿទុកចិត្តគ្នារវាងឪពុកម្តាយចំពោះកូន កូនចំពោះឪពុកម្តាយ ហើយដរាបណាកូនមិនដើរតាមគន្លងធម៌ មិនស្តាប់បង្គាប់ឪពុកម្តាយ ពេលនោះសុកមង្គលគ្រួសារនឹងបាត់បង់ បាត់ភាពកក់ក្តៅ បាត់ទំនុកចិត្តអស់ជំនួសមកវិញនូវសេចក្តីទុក្ខព្រួយទាំងផ្លូវកាយផ្លូវចិត្តរបស់ឪពុកម្តាយដោយសារមានកូនអកត្តញ្ញូ បែបនេះ។ កូនដែលមិនប្រកបដោយគន្លងធម៌បែបនេះភាគច្រើនគឺជាកូនដែលឪពុកម្តាយប្រៀនប្រដៅមិនស្តាប់ ជាកូនដែលមិនខិតខំសិក្សារៀនសូត្រ ហើយភ្លើតភ្លើននឹងអំពើអបាយមុខ មានស្រី ស្រា ល្បែងពាលាដែលជាប្រភពនាំឱ្យគេហ៊ានធ្វើអំពើគ្រប់យ៉ាងមកលើក្រុមគ្រួសារ ឬឪពុកម្តាយ រហូតដល់ពេលខ្លះគេហ៊ានលើកដៃសម្លាប់ឪពុលម្តាយរបស់ខ្លួនដើម្បីបំពេញមហិច្ឆិតារបស់គេថែមទៀតផង។ កូនអវជាតិបុត្រច្រើនជាកូនពាលមិនងាយប្រដៅ កំណើតរបស់កូនជំពូកនេះកាលបើកើតឡើងមកហើយបានធ្វើទុក្ខមាតាបិតាគ្រប់ដង្ហើមចេញចូល ធ្វើឱ្យមាតាបិតាពិបាកខ្វល់ខ្វាយពីរឿងចិញ្ចឹមបីបាច់ថែរក្សាប្រដៅទូន្មានអប់រំមិនស្តាប់បង្គាប់ ឱ្យចូលសាលារៀនសូត្រមិនបានចេះចាំឱ្យធ្វើកិច្ចការរាក់ជ្រៅមិនទទួលបានផលព្រោះតែគេមានចិត្តអន្ធពាល កាចសាហាវឃោរឃៅតាមធម្មជាតិជានិស្ស័យកំណើតរបស់គេតាំងពីកើត

ឡើងមកៗ លុះធំដឹងក្តីពេញកម្លាំង គេហ៊ានប្រព្រឹត្តអំពើអកុសលលួចឆក់ប្លន់កាប់សម្លាប់មិនញញើតដៃមិនខ្លាចអ្វីសោះឡើយ។

នៅក្នុងរឿងក្រពើ និងអ្នកបររទេះ បានបរិយាយពីសត្វក្រពើដែលជាសត្វរមិលគុណ ពេលគេបានជួយខ្លួនរួចពីសេចក្តីស្លាប់ហើយ ក៏មានបំណងចង់ស៊ីគោ និងតាចាស់ទៅវិញ។ រមិលគុណនៅត្រង់តាចាស់បានខំជួយយកអាសារដោយជួយនាំក្រពើរមិលគុណនេះទៅរកទឹកបឹងសម្រាប់ឱ្យស្នាក់អាស្រ័យហើយ គេបែរជារកស៊ីគោនិងតាចាស់ទៅវិញ។ វាជាសត្វឆោតហើយល្ងង់ទៀត ឆោតនៅត្រង់ហ៊ានឱ្យតាចាស់ចងរឹតយ៉ាងតឹងណែន នៅចំពោះមុខសុភាទន្សាយ ដើម្បីឱ្យសុភាទន្សាយបានឃើញថាតាចាស់ពិតជាបានធ្វើខុសមកលើខ្លួនមែនហើយ ដើម្បីឱ្យសុភាទន្សាយកាត់ក្តីឱ្យខ្លួនបានស៊ីតាចាស់តាមបំណង។ វាជាការខុសឆ្គងស្រឡះដែលសេចក្តីស្រេកឃ្លានរបស់ក្រពើខុសបែបបទប្រព្រឹត្តទៅលើតាចាស់បណ្តាលឱ្យកើតមហន្តរាយដល់ខ្លួនយ៉ាងតន់ហន់។ ដូច្នេះដរាបណាយើងបណ្តោយឱ្យសេចក្តីស្រេកឃ្លានគ្របសង្កត់ចិត្តយើងបានឬយើងប្រាថ្នាចង់ធ្វើអ្វីដោយខ្វះគតិពិចារណាឱ្យបានត្រឹមត្រូវ ដរាបនោះសេចក្តីវិនាស នឹងកើតមានដល់ខ្លួនយើងវិញមិនខាន ដូចក្រពើរមិលគុណនេះហេតុតែសេចក្តីស្រេកឃ្លានដោយសារអត់អាហារយូរថ្ងៃបណ្តាលឱ្យចិត្តចង់ស៊ីគោតាចាស់ និងតាចាស់បំបាត់សេចក្តីស្រេកឃ្លានរបស់ខ្លួន គេមិនបានគិតថាតាចាស់ជាអ្នកមានគុណលើខ្លួនឡើយ។ គប្បីបុគ្គលម្នាក់ៗកុំធ្វើអ្វីតាមសេចក្តីស្រេកឃ្លាន បើហួបកុំឱ្យតាមឃ្លាន។ តើរឿងនេះមានគតិចង់បង្កប់អត្ថន័យដូចម្តេច?

-ធ្វើគុណបានទោស។

-កុំសាបព្រោះខ្យល់ប្រយ័ត្នបានផលជាព្យុះភ្លៀង។

-ការជួយយកអាសារគេហើយ បែរជាត្រូវអ្នកនោះរមិលគុណវិញជាគតិថាយើងត្រូវចេះសង្កេតពិនិត្យចរិតលក្ខណៈមនុស្ស ចេះស្គាល់ប្រភេទមនុស្សឱ្យបានច្បាស់មុននឹងយើងសេពគប់ជៀសវាងការគប់មនុស្សខុសបណ្តាលឱ្យមានទុក្ខទោសដល់ខ្លួនវិញ។

### ២.១.៤- លក្ខណៈមនុស្សពាលព្រោះអំនួត តម្កើងឫទ្ធិ

លក្ខណៈមនុស្សពាលជំពូកនេះ គឺគេប្រើពាក្យសំដីថ្វីមាត់ជាមធ្យោបាយ ដើម្បីយកឈ្នះយកប្រៀបលើគូសត្រូវរបស់ខ្លួន។ ការអួតក្អេងក្អាងហួសពីសមត្ថភាព និងលទ្ធភាពដែលខ្លួនមាន និងមិនអាចធ្វើបានវានឹងនាំឱ្យយើងអាប់ឱនយស រងភាពអាម៉ាស់ដូចសុភាសិតបុរាណលោកលើកឡើងថា «ស្លាប់ព្រោះមាត់ ឬថាអណ្តាតជាអាទឹកន្ទង បានសុខទុក្ខផងពីព្រោះអណ្តាត»។ នៅក្នុងរឿងសត្វបង្កួយនៅខ្លោងទ្វាព្រះបាទវិទេហរាជ សត្វបង្កួយបានក្ងោចជាតុដើមកាលនៅក្រលំបាក លំបាកវេទនាផ្សេងៗ ក្រោយពេលបាន

មាសពីព្រះបាទវិទេហរាជបន្តិចបន្តួចក៏តាំងដំឡើងឫកប្រើអាកប្បកិរិយាមិនសមរម្យអំនួតអួតអាងដោយឈ្លក់វង្វេងនឹងមាសរបស់ខ្លួននេះក៏លែងគោរពព្រះរាជារហូតធ្វើឱ្យព្រះរាជាយកទៅប្រហារព្រោះតែវង្វេងជាមួយអំនួតខ្លួនឯង និងប្រាក់ជាប់និងខ្លួនគិតថាស្មើព្រះរាជា។ ជាងនេះទៅទៀតនៅក្នុងសាច់រឿងពិតជាបានឆ្លុះបញ្ចាំងពីចិត្តរបស់មនុស្សមួយចំនួនដែលមាននៅក្នុងសង្គមប្រៀបធៀបទៅនឹងមនុស្សដែលឆាប់ភ្លេចកំណើតរបស់ខ្លួនភ្លេចអ្នកដែលធ្លាប់ជួយ ភ្លេចគ្រាក្រលំបាកដោយសាតែលុយកាក់មាសប្រាក់បន្តិចបន្តួចហើយពេលមានយសមានសក្តិមានកេរ្តិ៍ឈ្មោះក៏ក្លាយទៅជាមនុស្សអំនួតអួតអាងលែងស្គាល់ល្អអាក្រក់បែរជាទៅមើលងាយអ្នកដទៃវាយតម្លៃអ្នកដទៃឡើងឫកពាលែងស្គាល់បងស្គាល់ប្អូន ប្រើអាកប្បកិរិយាមិនគប្បី និងលែងចេះប្រមាណខ្លួនគិតថាខ្លួនល្អហួសអ្នកដទៃ គិតថាខ្លួនល្អជាងគេ និងអួតក្អេងក្អាងខ្វះការពិចារណា។ ទង្វើទាំងនេះហើយដែលដឹកនាំឱ្យមនុស្សធ្លាក់ក្នុងសេចក្តីវិនាសអន្តរាយផ្សេងៗ ព្រោះមនុស្សប្រភេទនេះពេលដែលមានបញ្ហាមានសេចក្តីលំបាក គឺលែងមាននរណាជាទីពឹងតទៅទៀត។

សត្វគីង្គក់ដែលខំអួតឫទ្ធិដើម្បីឱ្យកន្ធង់កោតខ្លាចខ្លួននោះ ទីបំផុតសត្វកន្ធង់ដឹងពីអំណួតរបស់គីង្គក់ ហើយខ្លួនក៏រកវិធីផ្ចាញ់កន្ធង់វិញ ជាហេតុធ្វើឱ្យកន្ធង់ត្រូវរងភាពអាមាស់លែងហ៊ានហើបមាត់អួតអាងតទៅទៀត។ នៅក្នុងសង្គមមនុស្សបច្ចុប្បន្នក៏មានមនុស្សមិនតិចដែរ ដែលពូកែអួតក្អេងក្អាងតម្កើងឫកដោយយកឥទ្ធិពលនៃបុណ្យសក្តិ ទ្រព្យសម្បត្តិរបស់ខ្លួនទៅបង្អួតគេឯង ដើម្បីឱ្យគេគោរពកោតខ្លាច។ ជនខ្លះទៀតមិនមែនជាអ្នកមានបុណ្យសក្តិធំ ឬមានទ្រព្យសម្បត្តិច្រើនអ្វីទេ ប៉ុន្តែវាជាចរិតលក្ខណៈមនុស្សដែលពូកែអួតតែម្តង ជនជំពូកនេះច្រើនធ្វើឱ្យគេដឹងពីចរិតលក្ខណៈរបស់ខ្លួន ធ្វើឱ្យគេមើលងាយគេដឹងពីសារជាតិពិត ហើយគេស្អប់ខ្ពើមមិនផ្តល់តម្លៃឱ្យឡើយ។ យើងគួរមិនគប្បីយកខ្លួនទៅបៀត ឬឆាប់ជឿមនុស្សពូកែអួតក្អេងក្អាងឡើយ ព្រោះវាអាចនាំឱ្យខូចផលប្រយោជន៍ចាញ់បោកគេ ឬរងទុក្ខទោសដោយសារពាក្យអួតរបស់ជននោះ។ មនុស្សដែលចេះដឹងជ្រៅជ្រះពិតប្រាកដជាគេកម្រនឹងនិយាយអួតដោយខ្វះការពិចារណាណាស់ ព្រោះគេយល់ច្បាស់ពីការប្រើវោហា សាស្ត្រ ឬពាក្យសំដីដែលឥតប្រយោជន៍ ដែលនាំឱ្យអាប់ឱនតម្លៃរបស់គេដោយងាយៗ គឺភាគច្រើនមានតែជនល្ងង់ខ្លៅ ខ្វះការយល់ដឹងទេដែលច្រើនតែប្រកាន់ចរិតអួតក្អេងក្អាងតម្កើងឫទ្ធិ។ ពាក្យតំណាលខ្មែរបាននិយាយទុកតៗគ្នាថា «អួតច្រើន ច្រើនបាក់អំណួត ឬអង្គុយលើចង្អេរលើកខ្លួនឯង»។ ពាក្យទាំងនេះដូនតាយើងលោកបង្កើតឡើងដើម្បីទុកជាសារអប់រំកុំឱ្យជនជំនាន់ក្រោយពូកែអួត ឬតម្កើងឫកពាក្នុង

*ការនិយាយស្តីទៅកាន់អ្នកដទៃទោះបីជាយើងមានឫក្រណាក៏ដោយ។*

### *២.១.៥- លក្ខណៈមនុស្សពាលព្រោះចរិតកោងកាច*

*លក្ខណៈមនុស្សពាលក្នុងប្រភេទនេះ គឺ ជាមនុស្សដែលប្រើល្បិចកលអូសទាញ ជនណាម្នាក់ឱ្យឈ្លក់វង្វេងតាមការចង់បានរបស់ខ្លួន ដូចជាការប្រើពាក្យសំដីផ្អែមល្ហែមពីរោះពិសា ប្រើការល្បួងលោមតាមរូបភាពផ្សេងៗ ឬយករបស់មានតម្លៃ ឬលុយកាក់ជាផ្លាក់ទាក់ចិត្តអ្នកណាម្នាក់ឱ្យចូលអន្ទាក់របស់ខ្លួន។ ក្នុងរឿងតំណាលនៃគតិលោកភាគទី៣ គឺរឿងសំពោចនិងមាន់ចៃ សត្វសំពោចធ្វើកលជាចងមិត្តជាមួយសត្វដែលជាសត្រូវរបស់ខ្លួនគឺមាន់ចៃ។ សត្វសំពោចបានប្រើសំដីល្បួងលោមដោយភាសាទន់ភ្លន់ទៅកាន់មាន់ចៃដើម្បីចងមិត្ត ឈប់បង្កើតសត្រូវនឹងគ្នា តែមាន់ចៃជាសត្វមានប្រាជ្ញា ឆាប់យល់ការណ៍ក៏ប្រើភាពឈ្លាសវៃរបស់ខ្លួន ដើម្បីទប់ទល់នឹងល្បិចកលរបស់សំពោចរហូតសំពោចរត់ចូលព្រៃបាត់ស្រមោល។*

## ២.២. លក្ខណៈមនុស្សល្ងង់

*ពាក្យល្ងង់ គឺមានន័យថា មិនចេះ មិនយល់ ដែលមិនចេះ ឬមិនយល់។ ពាក្យទំនឹមទំនៀមបុរាណបានលើកឡើងថា ស្អប់ល្ងង់ស្រឡាញ់ចេះ ទើបមានចំណេះតាមសម័យនិយម។ បើល្ងង់កុំធ្វើចេះ បើឥតចំណេះត្រូវខំប្រឹងរៀន។ ល្ងង់ឬល្ងង់ខ្លៅឬខ្លៅល្ងង់ គឺល្ងង់ព្រោះឥតបានរៀនសោះ។ ងងឹតល្ងង់ ល្ងង់ឈឹងសូន្យដូចគេនៅក្នុងទីងងឹត។ ឆោតល្ងង់ ឆោតផងល្ងង់ផង។ ល្ងេល្ងង់ ល្ងង់ល្ងេល្ងើពុំយល់ការខុសត្រូវ...ជាដើម។*

*ដូច្នេះមនុស្សល្ងង់ គឺសំដៅយកមនុស្សមិនបានសិក្សារៀនសូត្រ ខ្វះការគិតពិចារណាឆាប់ជឿពាក្យសំដីគេ ងាយនឹងរងគ្រោះនឹងការបញ្ឆោតរបស់អ្នកដទៃ ឬធ្លាក់ចូលទៅក្នុងអន្ទាក់គេបានដោយងាយ។ ម្យ៉ាងទៀតមនុស្សល្ងង់ច្រើនធ្វើអ្វីមិនត្រូវតាមទំនងខុសបែបបទដែលអាចនាំឱ្យមិនទទួលបានជោគជ័យ។ នៅក្នុងសង្គមរស់នៅ ជាទូទៅមនុស្សល្ងង់ច្រើនជួបប្រទះនូវការលំបាកតោកយ៉ាក ឬរងទុក្ខវេទនាដោយសារចាញ់បោកគេដោយគេអូសទាញឱ្យធ្លាក់ទៅក្នុងផ្លូវអាក្រក់ដោយប្រការណាមួយ។ ឧទាហរណ៍ដូចជា រឿងបុរសចិញ្ចឹមខ្លាឃ្មុំ ខណៈពេលដែលបុរសជាម្ចាស់កំពុងដេកលក់ ដោយម្ចាស់បានចាត់ខ្លាឃ្មុំឱ្យនៅយាមខ្លួន។ ដោយសារតែភាពល្ងង់ខ្លៅរបស់ខ្លួន ខ្លាឃ្មុំបានយកដុំថ្មទៅគប់សម្លាប់រុយដែលហើរមករំខានម្ចាស់ខ្លួនជារឿយៗ ដែលបណ្តាលឱ្យត្រូវមុខបុរសជាម្ចាស់បែកឈាមហូររហាម។ ទង្វើនេះអាចកើតឡោះឯបាន គឺដោយសារខ្លាឃ្មុំមិនមានសតិក្នុងការយល់ដឹងក៏ដូចជាពិចារណាឱ្យល្អិតល្អន់។ នៅក្នុងរឿងបុរសម្នាក់ស្លាប់ទៅកើតជាហង្សមាស នាងព្រាហ្មណីជាប្រពន្ធដោយហេតុតែនាងល្ងង់*

គួបផ្សំនិងសេចក្ដីលោភលន់ផងនោះ នាងបានក្រសោបចាប់សុវណ្ណហង្សដកស្លាបក្នុងពេលដែលសុវណ្ណហង្សវិលមកជាលើកទី២ ទាល់តែអស់រលីង ក្នុងគោលបំណងដើម្បីយកស្លាបមាសទៅលក់យកប្រាក់មកធ្វើមានបានតាមចិត្តប្រាថ្នាចង់បានរបស់ខ្លួន។ ទីបំផុតស្លាបសុវណ្ណហង្សក៏ប្រែក្លាយជាពណ៌សដូចស្លាបកុកទៅវិញ។

## ២.៣- លក្ខណៈមនុស្សពូកែឆ្លាតវាងវៃ

ឆ្លាតវាងវៃ មានន័យថា ប៉ិនប្រសប់ ស្ទាត់ជំនាញលើកិច្ចការអ្វី១ ដោយឈ្លាសវៃ ប៉ិនរហ័ស វាងវៃ ដែលមានប្រាជ្ញាវាងកែលកុងទាំងរហ័សផងដែរ គឺដែលឈ្លាសវៃ ដែលដឹងផ្លូវដឹងឧបាយ។

មនុស្សឆ្លាតវាងវៃ គឺជាមនុស្សមានប្រាជ្ញាឈ្លាសវៃឆាប់យល់កិច្ចការពក់ជ្រៅ ឬឆាប់ចាប់បាននូវរាល់បញ្ហាដែលកើតមានឡើង។ ភាពឆ្លាតវៃរបស់មនុស្សមានសារៈសំខាន់ណាស់សម្រាប់ការដោះស្រាយបញ្ហាចំពោះមុខ។ យើងត្រូវខិតខំប្រឹងប្រែងសិក្សារៀនសូត្រឱ្យមានចំណេះដឹងជ្រៅជ្រះដើម្បីឱ្យយើងទទួលបាននូវគំនិតល្អៗសម្រាប់បំភ្លឺផ្លូវខ្លួនឯង និងពង្រីកវិចារណញ្ញាណរបស់យើងឱ្យបានឆ្លាតវៃទុកសម្រាប់ទប់ទល់នឹងហេតុការណ៍ផ្សេងៗដែលកើតមានឡើង។ មនុស្សឆ្លាតវៃគឺជាមនុស្សពូកែដោះស្រាយបញ្ហា មានប្រាជ្ញាមុតស្រួចមនុស្សមានភាពរហ័សរហួនក្នុងការការងារ ច្រើនជាមនុស្សទទួលបានជោគជ័យក្នុងជីវិត បើជាអ្នកសិក្សារៀនសូត្រគឺពូកែ បើជាអ្នកធ្វើការគឺមានភាពអំណត់តស៊ូព្យាយាម មានចក្ខុវិស័យច្បាស់លាស់ក្នុងការកំណត់គោលដៅជីវិតរបស់គេបានល្អ ហើយជាប្រភេទមនុស្សទទួលបានការគោរព ស្រឡាញ់ពីមនុស្សនៅជុំវិញខ្លួន ប្រាថ្នាផលប្រយោជន៍អ្វីច្រើនបានសម្រេច និងជាទីពឹងពាក់អាស្រ័យបាន ពេលខ្លះអ្នកឆ្លាតគឺជាមនុស្សឆាប់យល់ដឹងពីកាលៈទេសៈបានច្បាស់ថែមទៀតផង។

នៅក្នុងរឿងតំណាលភាគទី៨ គឺរឿងគ្រលេងគ្រលោងនិងស្វា សត្វគ្រលេងគ្រលោងដែលជាសកុណបក្សី មានតែចំពុះនិងជើងពីរ តែដោយសារគេមានភាពឆ្លាតវៃ គេអាចធ្វើសំបុកជាជម្រកសម្រាប់ស្នាក់អាស្រ័យបានយ៉ាងគត់មត់ក្នុងការការពារភ្លៀងរលឹមនិងឧបសគ្គផ្សេងៗ ដើម្បីគ្រួសារកូនប្រពន្ធរស់នៅបានសុខក្សេមក្សាន្ត ខុសពីសត្វពានរ ដែលមានដៃជើងដល់ទៅជើង៤ តែដោយសារតែភាពខ្ជិលច្រអូសនិងខ្វះសតិបញ្ញា ស្វាបានរត់ទៅជ្រកកោនក្រោមសំបុកសត្វគ្រលេងគ្រលោង។ លុះជ្រកញឹកញយពេក គេក៏ធុញទ្រាន់ហើយគេក៏ដាស់តឿនឱ្យខិតខំធ្វើសំបុកសម្រាប់ស្នាក់អាស្រ័យនឹងគេ បែរជាមានចិត្តខឹង ចចេសមានៈ ហើយគោចសំបុកគ្រលេងគ្រលោងចោលទៅវិញ។ ក្នុងភាគទី១០ គឺរឿងនាយ

ព្រានព្រៃចាប់សត្វសារិកា សត្វកុកជាសត្វឆ្លាតវៃបានធ្វើពុតជាមិនចេះរាំ កុកដឹងកាលៈទេសៈច្បាស់ថា មិនគួរប្រើចំណេះដឹងនៅទីនេះទេ កាលណាកុកសម្តែងវិជ្ជា ច្បាស់ណាស់ថា ស្តេចប្រាកដជាចាប់ដាក់ក្នុងទ្រុង មិនឱ្យមានសេរីភាព មិនបានជួបជុំញាតិមិត្តខ្លួន ហើយមិនមានក្តីសុខជាក់ជាមិនខាន ដោយហេតុនេះហើយបានជាកុកមិនរាំតាមព្រានព្រៃប្រាប់នោះឡើយ។ ដោយមើលឃើញថាសត្វកុកមិនចេះរាំ ព្រះមហាក្សត្រក៏បញ្ជា ឱ្យអាមាត្យដោះលែងកុកឱ្យមានសេរីភាពឡើងវិញ។ កុករួចខ្លួនពីការឃាត់ឃាំងក្នុងទ្រុង ខុសពីសត្វសេក សារិកាបានបញ្ចេញសមត្ថភាពរបស់ខ្លួនទៅតាមជំនាញគឺសារិកាបញ្ចេញសមត្ថភាពនិយាយភាសាមនុស្ស មានសូរសព្ទសូរសៀងពីរោះគួរឱ្យចង់ស្តាប់។ ឯសត្វក្ងោកចេះរាំល្វតល្វន់ទន់អស់ទាំងខ្លួនប្រាណ ធ្វើឱ្យព្រះមហាក្សត្រសព្វព្រះរាជហឫទ័យ ក៏ត្រាស់បង្គាប់ឱ្យអាមាត្យចាប់សត្វសារិកា និងសត្វក្ងោកដាក់ក្នុងទ្រុងទុកចិញ្ចឹមបង្ហាត់បង្រៀន ធ្វើឱ្យសត្វទាំង២បាត់អស់នូវសិទ្ធិសេរីភាពរបស់ខ្លួន។

## ២.៤. លក្ខណៈមនុស្សកំណាញ់ក្រៅតម្រា

កំណាញ់មានន័យថាការកាញ់គ្នេរ ដែលហួងហែងទ្រព្យរបស់ទុកមិនចាយ មិនប្រើ ឬមិនឱ្យសាធារណ៍ទូទៅដល់អ្នកឯទៀត មនុស្សកំណាញ់។

ក្រៅតម្រា មានសេចក្តីថា ក្រៅពីការកត់ត្រា ទុករឿងដែលមិនមានកត់ទុកដោយសង្ខេប ក្រៅក្បួន។ កំណាញ់ ក្រៅតម្រា សោតសឹងអាប់ប្រយោជន៍យស។ មនុស្សកំណាញ់ក្រៅតម្រា គឺសំដៅលើមនុស្សដែលកំណាញ់ហួសហេតុ មានសម្បត្តិច្រើនឬតិច តែមិនព្រមចំណាយ ស៊ីចាយ បំពេញក្រពះខ្លួនឱ្យបានឆ្អែត និងមិនព្រមចាយប្រាក់នោះដើម្បីបំពេញការស្រេចឃ្លានរបស់កូនប្រពន្ធនោះទេ បណ្តោយទៅតាមយថាហេតុ សុខចិត្តអត់។ មនុស្សកំណាញ់ ច្រើនមានលក្ខណៈដូចតទៅ៖

. មិនងាយចំណាយប្រាក់ឱ្យដល់អ្នកណាម្នាក់ សូម្បីបន្តិចបន្តួច ក៏មិនចំណាយដែរ

. ចូលចិត្តកេងចំណេញលើគេ សូម្បីបន្តិចបន្តួចក៏ស្រវាច្បាមយក

. បើទៅបរិភោគអាហារនៅភោជនីដ្ឋានណាមួយជាមួយមិត្តភក្តិ មិនងាយចេញប្រាក់ប៉ាវគេទេ ទោះបីជាគេធ្លាប់ចេញជួសខ្លួនប៉ុន្មានដងរួចមកហើយក៏ដោយ។

ទង្វើទាំងអស់ខាងលើនេះហើយ ដែលបណ្តាលឱ្យមនុស្សកំណាញ់ក្រៅតម្រានេះរស់នៅខ្វះមិត្តសម្លាញ់ ច្រើនជាមនុស្សឯកោបាត់បង់ប្រយោជន៍ដែលត្រូវទទួល ព្រោះគ្មានអ្នកណាប្រាប់ឱ្យដឹង ឬក៏ហៅទៅជាមួយនឹងនាំឱ្យបាត់បង់កិត្តិយស (ចរិយាមិនថ្លៃ) អ្នកផងមិនចូលចិត្ត។

មនុស្សជំពូកកំណាញ់ក្រៀតម្រានេះ មិនល្អប្រសើរឡើយ ទាំងកេរ្តិ៍ឈ្មោះនិង កិត្តិយសក្នុងការរស់នៅ ព្រោះតែភាព កំណាញ់ស្វិត ខ្លាចគេដណ្តើមយកទ្រព្យ សម្បត្តិនិងផលប្រយោជន៍ខ្លួន ពោលគឺគេ ហ៊ានប្រព្រឹត្តអំពើខុសឆ្គងទៅលើអ្នកដទៃ ដូច ជាបង្កជាជម្លោះជាមួយមនុស្សនៅជុំវិញខ្លួន ដើម្បីឱ្យគេស្អប់កុំមកទំនាក់ទំនងនឹងគ្រួសារ ខ្លួន ខ្លាចក្រែងគេដណ្តើមយកលាភខ្លួន។ ក្នុង រឿងព្រានសន្ធូច បុរសព្រានសន្ធូចបានប្រាប់ ឱ្យប្រពន្ធខ្លួនទៅបង្កជម្លោះជាមួយអ្នកស្រុក ដើម្បីកុំឱ្យអ្នកស្រុកមកសុំត្រីរបស់ខ្លួនយកទៅ បរិភោគ ដែលគំនិតបែបនេះបានបង្កនូវសេច ក្តីស្អប់ខ្ពើមពីមនុស្សនៅជុំវិញខ្លួន និងព្រោះ តែភាពកំណាញ់ក្រៀតម្រារបស់គាត់គួបផ្សំ នឹងសេចក្តីល្ងង់ខ្លៅផង។

## ២.៥. លក្ខណៈមនុស្សឆោត

ឆោត មានន័យថា ដែលងាយបញ្ឆោត មនុស្សឆោត គំនិតឆោត។ ឆោតឆៅ ដែល ឆោតខ្លៅឆៅគំនិត។

ឆោតគឺល្ងង់។ មនុស្សឆោតសឹងមានគ្រប់ រូបគ្រប់អាត្មា តែយើងអាចកាត់បន្ថយ សេចក្តី ឆោតនេះឱ្យនៅតិច ហើយខំបង្កើនភាពឆ្លាតវៃ ឱ្យបានច្រើនជាអតិបរមា។ មនុស្សឆោតច្រើន ជាប់ជំពាក់នឹងកត្តាជាច្រើនដូចជា៖

- ឆោតព្រោះសេចក្តីស្រេកឃ្លានលោភ រឿងបុរសម្នាក់ស្លាប់ទៅកើតជាហង្សមាស

- ឆោតព្រោះភាពរមិលគុណ រឿង ក្រពើនិងអ្នកបររទេះ រឿងចៅសញ្ជ័យមោណព ប្រស់ខ្លា

- ឆោតព្រោះចចេសមានះ គេពីរចែក ផ្លូវគ្នារកអាហារ រឿងគ្រលេងគ្រលោងនិងស្វា

- ឆោតព្រោះកំណាញ់ៈ រឿងចៅព្រាន សន្ធូច រឿងអទិន្នបុព្វកព្រាហ្មណ៍

- ឆោតព្រោះឃ្លានអាហារញ៉ាមមាត់ រឿងឆ្មាស្រុក១ និងចាបពូក១

- ឆោតព្រោះវង្វេងក្នុងកាម រឿងស្វា ព្រាមមួយបានស្វាឱជាភរិយា។

## ២.៦. លក្ខណៈមនុស្សមានះរឹងរូស

មានះរឹងរូស គឺសំដៅទៅលើសេចក្តី ប្រកាន់ ដំណើរប្រកាន់ខ្លួន សេចក្តីរឹងត្អឹង។ មនុស្សមានះរឹងរូស គឺមនុស្សមុខរឹង មនុស្ស ចចេស រឹងគគ្រីសគគ្រូស រឹងមិនព្រមចុះ សម្រុង មិនព្រមទន់តាម ពោលគឺជាមនុស្ស រឹងរូស ដែលរឹងរូសទាំងការនិយាយស្តី និង រឹងរូសទាំងចិត្តគំនិត។ ដូចពាក្យចាស់ថា មនុស្សរឹងរូស ច្រើនតែប្រទូស្ត ប្រទាំងឱវាទ នៅក្នុងទីណា ច្រើនតែវាតអាទិ៍ ត្រាតែវាត ឃ្លាតចាកទីនោះ។

មានះមាន៣យ៉ាងគឺ ប្រកាន់មាំស៊ប់ថា មានតែខ្លួនឯងដែលជាអ្នកប្រសើរជាងគេក៏ មើលងាយគេឥតជឿស្តាប់គោរពអ្នកណា ឡើយ ប្រកាន់មាំស៊ប់ថាគេនិងអញស្មើៗតែ គ្នាក៏ឥតមានការសេពគប់រាប់រកយកគេជាគ្នា

និងប្រកាន់មាំស៊ប់ថា អញឯងជាអ្នកទន់ខ្សោយថយថោកជាងគេ គេដោយគេ អញដោយអញ ក៏ឥតមានការប្រាស្រ័យនឹងគ្នា។

បើយើងធ្វើការឆ្លុះបញ្ចាំងលក្ខណៈមានះក្នុងស្នាដៃគតិលោក គឺមានបង្ហាញក្នុងភាគទី៧ គឺរឿងសត្វគ្រលេងគ្រលោងនិងស្វា។ យើងឃើញថាដំណើររឿងបានបង្ហាញពីសត្វគ្រលេងគ្រលោង ដែលជាសកុណបក្សីមានតែជើងពី២និងចំពុះ១ បានខិតខំកសាងសុកមង្គលគ្រួសារបានយ៉ាងល្អ គឺចេះរៀបចំសំបុកប្រៀបដូចផ្ទះសម្បែងសម្រាកជ្រកនៅរបស់កូនប្រពន្ធបានគត់មត់ ដើម្បីការពារភ្លៀងរលឹមនិងអាកាសធាតុផ្សេងៗទៅតាមរដូវកាល។ នេះសបញ្ជាក់ថា សេចក្ដីសុខសុភមង្គលរបស់គ្រួសារសត្វគ្រលេងគ្រលោងពិតជាអាចកើតមានឡើងគ្រប់ពេល។ សត្វញីឈ្មោលទាំងពីរបានរួមសហការគ្នាធ្វើសំបុកខិតខំរកស៊ី រកស្បៀងអាហារមកចិញ្ចឹមកូនបានល្អប្រពៃណាស់។ ខុសពីសត្វពានរ មានដៃជើងដល់ទៅ៤ មានភាពរហ័សរហួន និងកម្លាំងខ្លាំងតែមិនមានគំនិតសូម្បីគិតធ្វើផ្ទះសម្បែងទីជម្រកសម្រាប់ស្នាក់អាស្រ័យខ្លួនឯង និងកូនប្រពន្ធសោះឡើយ។ ពេលមានភ្លៀងធ្លាក់មកក៏តាំងរត់ទៅជ្រកកោនផ្ទះគេយករួចខ្លួន ទុកឱ្យកូនប្រពន្ធរងទុក្ខវេទនារងាញាប់ញ័រឥតយកភ្នែកមើលសោះឡើយ។ ដល់ពេលទៅជ្រកកោនជាមួយគេញឹកញយ ពេកគេក៏សាកសួរស្ដីថា ប្រដៅឱ្យកែទម្លាប់អាក្រក់នេះចោល ក៏តាំងមានចិត្តខឹងគេ ហើយប្រព្រឹត្តអំពើខុសឆ្គងទៅលើគេទាំងកំរោល ដោយហក់ទៅគោចបោចសំបុកសត្វគ្រលេងគ្រលោងចោលខ្ទេចខ្ទីរគ្មានសល់ ហើយរអៀសខ្លួនបោលចូលព្រៃបាត់ទៅ។ បុគ្គលដែលចចេសមានះមិនស្ដាប់យោបល់គេដែលណែនាំខ្លួនឱ្យល្អ បែរជាខឹងគេគឺជាមនុស្សមិនបានការកុំប្រាថ្នាយកធ្វើជាមិត្រ។

## ២.៧. លក្ខណៈមនុស្សជាមិត្តទ្រុស្តមិត្ត

ទ្រូស្ដ មានន័យថា ប្រទូស្ដ ធ្វើអាក្រក់។ មិតតទ្រូស្ដមិត្ត គឺមិត្តធ្វើអាក្រក់ដាក់មិត្តឬហៅថា មនុស្សទ្រុស្ដមិត្រ។

ការរាប់អានមិត្តមានច្រើនសណ្ឋានច្រើនបែបយ៉ាងដែលយើងគួរកត់សម្គាល់និងចងចាំទុក។ អ្នកខ្លះរាប់អានយើងដោយផ្ដើមចេញពីទឹកចិត្តល្អជាចំពោះគ្នា មិនសម្លឹងឃើញអ្វីក្រៅពីសេចក្ដីស្រឡាញ់រាប់អាននោះឡើយ ដែលបែបនេះគេហៅថាមិត្តភាពឬជាកល្យាណមិត្ត ដែលមានភាពស្អិតស្មួរយូរអង្វែងបាន ហើយពេលខ្លះមិត្តភាពអាចឱ្យយើងបន្សល់ទុកនូវរឿងល្អៗជាមួយគ្នា អាចនិយាយបានថា ពេលខ្លះល្អប្រសើរជាងបងប្អូនបង្កើតថែមទៀត។ ដោយឡែកមិត្តមួយប្រភេទទៀត រាប់អានយើងដោយមានគោលបំណងអ្វីមួយក្នុងផ្លូវអាក្រក់ ដែលយើងអាចសម្គាល់បានហៅថាមិត្តទ្រុស្ដមិត្ត ឬបាបមិត្ត។

មិត្តប្រភេទនេះយើងអាចកត់សម្គាល់បានទៅលើចំណុចមួយចំនួនដូចជាៈ

- រាប់អានគ្នាជាមិត្តតែមាត់ ចិត្តមិនបានចង់មិត្ត

- សុំរាប់អានគ្នាជាមិត្តដោយស្ថិតនៅក្រោមឥទ្ធិពលទ្រព្យសម្បត្តិ

- សុំរាប់អានគ្នាដោយស្ថិតនៅក្រោមឥទ្ធិពលនៃសេចក្ដីស្រឡាញ់បោកប្រាស់

- សុំស្គាល់រាប់អានគ្នាដោយស្ថិតនៅក្រោមឥទ្ធិពលខ្លាចអំណាចបុណ្យស័ក្តិ

- មិត្តភាពនឹងគ្នាដោយសម្លឹងឃើញផលប្រយោជន៍ពីដៃគូភាគីណាម្នាក់។

តាមរយៈលក្ខណៈសម្គាល់ខាងលើនេះ មនុស្សដែលយើងរាប់អានគ្នាជាមិត្ត គឺមិននាំយើងទៅរកសេចក្ដសុខយូរអង្វែងបានឡើយ។ ពេលវេលាណាមួយអាចនឹងកើតឡើងនូវមហន្តរាយ ឬទំនាស់វិបត្តិផ្សេងៗជាមួយគ្នាមិនខាន។ មិត្តទ្រូស្តមិត្ត ឬមិត្តអាក្រក់មាន៤ប្រភេទគឺ មិត្តគិតតែពីខាងបាន (គិតយកប្រយោជន៍តែម្នាក់ឯង ព្រមខូចប្រយោជន៍តែបន្តិចបន្តួចនិងតែងចង់បានតែពីខាងច្រើន ពេលខ្លួនមានភ័យទើបស្ទុះទៅជួយធ្វើកិច្ចរបស់មិត្ត សេពគប់មិត្តព្រោះសម្លឹងឃើញប្រយោជន៍) មិត្តបានតែខាងនិយាយ (ពូកែតែលើកយករឿងដែលអស់ហើយមកនិយាយ ពូកែតែលើកយករឿងដែលមិនទាន់មកដល់មកប្រាស្រ័យ ជួយសង្គ្រោះដោយរបស់គ្មានបានប្រយោជន៍ និងពេលមិត្តមានធុរៈអាងលេសថាខ្លួនរវល់ឬមានកិច្ចការជានិច្ច) មិត្តប្រចុប (ពេលមិត្តធ្វើអាក្រក់ក៏សាទរ ពេលមិត្តធ្វើល្អក៏សាទរ នៅពីមុខមិត្តពោលសរសើរ នៅកំបាំងមុខមិត្តរិះគន់និន្ទា) និងមិត្តនាំទៅរកតែរឿងវិនាស (ពេលផឹកគ្រឿងស្រវឹងក៏ផឹកជាមួយ ពេលមិត្តដើរលេងយប់ក៏ដើរលេងជាមួយ)។

ដោយមើលឃើញទោសនៃការសេពគប់មិត្តទ្រូស្តមិត្ត ឬមិត្តអាក្រក់នាំមកនូវសេចក្ដីវិនាសដូច្នេះ គប្បីយើងត្រូវគិតពិចារណាឱ្យបានគ្រប់ជ្រុងជ្រោយមុននឹងសេពគប់មិត្ត។ នៅក្នុងរឿង ឆ្មាស្រុក១ និងចាបពូក១ បានបង្ហាញពីមិត្តភាពតែសំបកក្រៅ។ ពីដំបូងសត្វទាំងពីរស្រឡាញ់រាប់អានគ្នាជាប្រក្រតី លុះដល់ពេលមួយដែលឆ្មាស្រុករកចាប់ចាបព្រៃជាអាហារមិនបាន ទើបក្លាយជាមិត្តប្រហារមិត្ត គឺឆ្មាស្រុកបានចាប់ចាបពូកយកទៅធ្វើជាចំណី ព្រោះតែញ៉ាមមាត់។ រឿង ភេពីររកស៊ីចូលគ្នា ភេទាំងពីរជាមិត្តនឹងគ្នាទបានព្រមព្រៀងគ្នាសហការគ្នារកចាប់ត្រីជាអាហារក្នុងបឹងមួយ លុះដល់ពេលចាប់ត្រីបានហើយ ភេទាំងពីរបានខ្វែងគំនិតគ្នាក្នុងការចែកត្រីគ្នាមិនដាច់ស្រេចដោយសំអាងថាខ្លួនមានប្រៀបជាងម្ខាងៗ។ ក្នុងន័យនេះដោយសារតែភេនីមួយៗគិតពីផលប្រយោជន៍ចង់បានចំណេញរៀងៗខ្លួន ទើបត្រូវបែកបាក់មិត្តភាពហើយត្រូវរកអាជ្ញាកណ្ដាលមកធ្វើជាមេចំណែក ទីបំផុតភាគីទាំងពីរត្រូវខាតលាភ

កើតវិប្បដិសារីស្ដាយក្រោយព្រោះតែមិនចេះអធ្យាស្រ័យគ្នា ធ្វើឱ្យបែកបាក់សាមគ្គីថែមទៀតផង។

## ២. ៨. លក្ខណៈមនុស្សមានគុណធម៌

គុណធម៌ ជាសេចក្ដីល្អ សេចក្ដីបរិសុទ្ធិ សេចក្ដីអាណិត សេចក្ដីសន្ដោសប្រណី...។ មនុស្សដែលមានគុណធម៌ជាមនុស្សចិត្តជា ដូចពាក្យបុរាណបានពោលថា «មនុស្សចិត្តជា តែងមានគ្នាជាទីពឹង» ដែលបកស្រាយពីគុណសម្បត្តិនៃលក្ខណៈមនុស្សដែលមានទឹកចិត្តស្មោះត្រង់ចំពោះមនុស្សដូចគ្នា ដែលតែងតែមានមនុស្សជិតឆ្ងាយចាំជួយយកអាសារ អាចពឹងពាក់បានទោះក្នុងកាលៈទេសៈក៏ដោយ។

ដូចករណី ឧបាសកក្នុងនិទានរឿងពាលសង្រ្គមហួសប្រមាណ លោកគឺជាតួអង្គតំណាងមនុស្សស្លូតបូត មានចិត្តស្មោះត្រង់ ឆាប់ជឿទុកចិត្តអ្នកដទៃ ត្រូវបានព្រះពោធិសត្វដែលមានប្រាជ្ញាខ្ពង់ខ្ពស់ បានជួយយកអាសារខណៈពេលដែលដឹងថាតាបសប្រើល្បិចបោកប្រាស់យកហិបប្រាក់របស់គាត់ ទីបំផុតឧបាសកដឹងខ្លួនវិញ យល់ថាតាបសជាជនពាលដែលប៉ុនប៉ងបញ្ឆោតយកប្រាក់របស់គាត់។ ទន្ទឹមនឹងនេះព្រះពោធិសត្វតំណាងឱ្យជនដែលមានឧត្តមគតិ និងសេចក្ដីប៉ងប្រាថ្នារបស់ប្រជាជន ដែលត្រូវការមនុស្សដែលមានចំណេះវិជ្ជា វៃឆ្លាត ស្មោះត្រង់ មានចិត្តមនុស្សធម៌ចេះជួយអ្នកដទៃប្រកាន់ខ្ជាប់នូវអំពើយុត្តិធម៌។ ព្រះពោធិសត្វ ដែលជាឈ្មួញបានជួយសង្គ្រោះឧបាសកពីការបោកប្រាស់របស់តាបស និងបានអប់រំទូន្មានដល់ប្រជាជន ហើយអ្នកស្រុកបានចាត់ទុកព្រះពោធិសត្វជាគ្រូបាធ្យាយជាដរាប។ រួមសេចក្ដីមករឿងពាលសង្រ្គមហួសប្រមាណ ពិតជាបានលើកយកបញ្ហាមនុស្សនៅក្នុងសង្គមមកចោទ និងធ្វើការដោះស្រាយបានយ៉ាងត្រឹមត្រូវ ហើយតាមរយៈរឿងនេះ គឺបានបង្កប់នូវគំនិតទស្សនវិជ្ជាល្អៗជាច្រើនដោយបង្ហាញឃើញនូវតម្លៃមនុស្ស និងគតិល្អៗសម្រាប់ជនគ្រប់រូប។ តម្លៃរបស់មនុស្សម្នាក់ៗគឺស្ថិតលើចំណេះវិជ្ជា ដូចក្នុងរឿងតួអង្គព្រះពោធិសត្វបានយោងកំណើតជាឈ្មួញ១នាក់ បានឃើញតាបសបោកបញ្ឆោតឧបាសកបែបនេះ ដោយដឹងពីកលល្បិចរបស់តាបសក៏ចូលមកជួយសង្គ្រោះឧបាសក។ ធ្វើជាមនុស្សកុំឱ្យជឿពាក្យភូតកុហករបស់ជនទុច្ចរិត ដែលមានគំនិតបោកបញ្ឆោតដោយប្រើគ្រប់ល្បិចគ្រប់វិធីសាស្ត្រ ដើម្បីតែចង់បានទ្រព្យសម្បត្តិអ្នកដទៃ ដោយគ្មានគិតពីទុក្ខវេទនារបស់ម្ចាស់ទ្រព្យឡើយ ចង់បានតែសេចក្ដីមានបានតែខ្លួនឯង។ ម្យ៉ាងវិញទៀត បានដាស់តឿនក្រើនរំឭកទៅដល់មនុស្សគ្រប់រូប ឱ្យចេះគិតគូពិចារណាឱ្យបានគ្រប់ជ្រុងជ្រោយ កុំឆាប់ទុកចិត្តទៅលើបុគ្គលដែលចិត្តល្អជាមួយយើងតែសម្បកក្រៅ ត្រូវរៀនស្វែងយល់បានច្បាស់លាស់ជាមុនសិន ព្រោះថាមនុស្សពាលនេះ ទោះបីជាយើងមាន

ចំណោះវិជ្ជាក៏ដោយ ពេលខ្លះក៏ពិបាកនឹងមើលដឹងដែរដោយសារតែគេល្បិចគ្រប់ជំពូក ហើយបន្ទំយើងមិនអាចយើងមើលដឹងដោយភ្នែកទទេបានឡើយ។ ក្នុងសាច់រឿងនេះក៏បានផ្តល់ឧត្តមគតិសម្រាប់អប់រំទូន្មានមនុស្សកុំឱ្យជឿទៅលើពាក្យសម្តីមនុស្សបោកប្រាស់ដោយគ្រាន់តែពាក្យសម្តីដែលគេប្រាប់ តែឱ្យជឿទៅលើទង្វើទើបជាការប្រសើរ។

រឿងថៅសញ្ជីវមាណពប្រស់ខ្លា ថៅសញ្ជីវមាណពគឺជាមនុស្សដែលមានគុណធម៌មនុស្សធម៌ចំពោះសព្វសត្វលោក។ គេបានសិក្សារៀនសូត្រសិល្បសាស្ត្របានចេះចប់មានចំណេះដឹងជ្រៅជ្រះ ក៏ចិត្តអាណិតមេត្តាដល់សត្វលោក មិនត្រឹមតែមនុស្សនៅជុំវិញខ្លួននោះទេ សូម្បីតែសត្វខ្លាស្លាប់ទៅហើយក៏មានចិត្តប្រស់ឱ្យរស់ឡើងវិញដែរ។

រឿងបុរសម្នាក់ស្លាប់ទៅកើតជាសុវណ្ណហង្ស ដោយក្តីអាណិតស្រឡាញ់ប្រពន្ធកូនពន់ពេកសូម្បីតែគាត់បានស្លាប់ទៅហើយក្តីក៏បុរសជាប្តីបានរកវិធីមកជួយចិញ្ចឹមគ្រួសារផងដែរ។ គាត់បានទៅកើតជាសុវណ្ណហង្សហើយបានមកជម្រុះស្លាបមាសទុកឱ្យកូនប្រពន្ធយកទៅលក់គ្រាន់បានប្រាក់ចិញ្ចឹមជីវិតជាប្រចាំ។ ទឹកចិត្តបែបនេះបានបង្ហាញពីគុណធម៌មនុស្សធម៌ដ៏ប្រពៃរបស់លោកចំពោះគ្រួសារ សូម្បីលោកបានស្លាប់ទៅហើយក្តី ក៏នៅមានចិត្តមេត្តាដល់គ្រួសាររបស់ខ្លួនគឺជាទឹកចិត្តស្រឡាញ់ អាណិត ប្រាថ្នាចង់ឱ្យគ្រួសាររួចផុតពីទុក្ខលំបាកនេះឯង។

លក្ខណៈសម្បត្តិមនុស្សបែបនេះ គឺជាគុណតម្លៃដ៏វិសេសវិសាលមួយដែលយើងទាំងអស់គ្នា និងសង្គមមនុស្សប្រាថ្នាចង់បាន។ នៅក្នុងសង្គមមួយដែលមានសុខសន្តិភាពនិងការអភិវឌ្ឍន៍ យើងពិតជាត្រូវការលក្ខណៈមនុស្សដែលមានគុណធម៌ មនុស្សធម៌សម្រាប់ធ្វើជាអ្នកគ្រប់គ្រង និងជាមេដឹកនាំប្រទេសបន្ថែមពីលើចំណេះដឹងរបស់គេ។ គុណធម៌មនុស្សធម៌បានធ្វើឱ្យយើងអាចកាត់បន្ថយបាននូវជម្លោះអធិករណ៍ចំពោះគ្នាទៅវិញទៅមក មិនតែប៉ុណ្ណោះផ្នែកទាំងពីរនេះ គឺជារបស់ដ៏ពិសិដ្ឋមិនអាចខ្វះបានសម្រាប់មនុស្សម្នាក់ៗដែលត្រូវមាននៅជាប់នឹងខ្លួន វាអាចជួយយើងឱ្យទទួលបាននូវសេចក្តីគោរពស្រឡាញ់រាប់អានពីអ្នកដទៃតាមរយៈការប្រព្រឹត្តល្អរបស់យើងតាមផ្លូវកាយ វាចា និងផ្លូវចិត្ត។

## សន្និដ្ឋាន

ដូច្នេះជាសរុបសេចក្តីមក ការបកស្រាយអំពី ធម្មចរិយានៃគតិលោកប៉ុន្មានចំណុចខាងលើមក យើងឃើញថា ស្នាដៃរបស់លោកឧកញ៉ា សុត្តន្តប្រីជាឥន្ទ្រ គឺសុទ្ធតែជាគតិសម្រាប់ឱ្យយើងមើលពីលក្ខណៈមនុស្សគ្រប់ប្រភេទ ដែលក្នុងនោះយើងប្រាថ្នាចង់បានឱ្យសង្គមបច្ចុប្បន្ននេះសំបូរដោយធនធានមនុស្ស

ដែលមានលក្ខណៈគុណធម៌ មនុស្សធម៌ ដើម្បីរួមចំណែកកសាង និងអភិវឌ្ឍសង្គមជាតិយើងឱ្យរីកចម្រើនលូតលាស់ទៅមុខទាន់អរិយប្រទេសលើសកលលោក។ ដើម្បីសម្រេចបាននូវបំណងប្រាថ្នានេះ គឺទាមទារឱ្យសង្គមមនុស្ស ត្រូវយកចិត្តទុកដាក់ក្នុងអភិវឌ្ឍសមត្ថភាពរបស់មនុស្សឱ្យបានល្អប្រសើរដូចជាៈ

- បណ្តុះបណ្តាលធនធានមនុស្សឱ្យមានចំណេះដឹងទូលំទូលាយលើគ្រប់ផ្នែក គ្រប់វិស័យ

- កែប្រែនិងតម្រង់នូវលក្ខណៈមនុស្សមិនល្អ ដោយផ្តល់ការអប់រំផ្នែកសីលធម៌សង្គម សុជីវធម៌ ទស្សនវិជ្ជា ដើម្បីឱ្យមនុស្សមានឥរិយាបថល្អក្នុងការប្រព្រឹត្ត

- លុបបំបាត់ភាពអវិជ្ជមាននានានៅក្នុងសង្គមដែលនាំឱ្យមនុស្សភ្លើតភ្លើន ត្រេកត្រអាល វង្វេងស្មារតីដូចជា គ្រឿងស្រវឹង គ្រឿងញៀន ល្បែងភ្នាល់ ល្បែងស៊ីសង ភាពយន្តអាសអាភាស...។

- បណ្តុះវប្បធម៌សន្តិភាពផ្លូវចិត្តតាមវិធីអហិង្សាឱ្យមនុស្សស្គាល់ខុសត្រូវ ស្គាល់គុណទោសជាដើម។

បច្ចុប្បន្ននេះយើងកំពុងកសាងបាននូវធនធានមនុស្សល្អៗជាច្រើនដែលមានសមត្ថភាព ខ្ពស់ មានសីលធម៌ល្អសម្រាប់តម្រូវការសង្គមជាតិយើង តាមរយៈការអប់រំតាមសាលារៀន អង្គការ ស្ថាប័នរដ្ឋ និងឯកជន អង្គការមនុស្សធម៌ជាតិ អន្តរជាតិនានាដើម្បីឆ្ពោះទៅរកសង្គមមនុស្សល្អប្រកបដោយវឌ្ឍនភាព។

## គន្ថនិទ្ទេស


- ក្រសួងអប់រំ **ភាសាខ្មែរ ថ្នាក់ទី១១** ភ្នំពេញ ឆ្នាំ២០១១។
- ក្រសួងអប់រំ **ភាសាខ្មែរ ថ្នាក់ទី១២** ភ្នំពេញ ឆ្នាំ២០១២។
- ឃីង ហុកឌី **សុត្តន្តប្រីជាឥន្ទ** និងស្នាដៃ ភ្នំពេញ ឆ្នាំ២០១២។
- ជួន ណាត **វចនានុក្រមខ្មែរភាគ១-២** ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ ឆ្នាំ១៩៦៧។
- ត្រឹង ង៉ា **វប្បធម៌ អរិយធម៌ខ្មែរ** ឆ្នាំ១៩៧៤។
- សរ សារុន **វប្បធម៌ អរិយធម៌ខ្មែរ** ឆ្នាំ១៩៧០។
- ធ សោ **វិធីសាស្ត្រនៃការសិក្សាស្នាដៃអក្សរសិល្ប៍** សាកលវិទ្យាល័យភូមិន្ទភ្នំពេញ ឆ្នាំ ១៩៩៣។
- ពៅ សាមី **ទ្រឹស្តីអក្សរសិល្ប៍ភាគ១ ភាគ២ និងភាគ៣** ប្រើប្រាស់ផ្ទៃក្នុងសាលាគរុវិជ្ជាជាន់ខ្ពស់ សាធារណរដ្ឋប្រជាមានិតកម្ពុជា ក្រសួងអប់រំ ឆ្នាំ១៩៨៧។
- លាង ហាប់អាន **សិក្សាប្រវត្តិអក្សរសិល្ប៍ខ្មែរសម័យនគរភ្នំ ដល់ឧត្តុង្គ** ភ្នំពេញ ឆ្នាំ១៩៦៧។
- សុត្តន្តប្រីជាឥន្ទ **គតិលោក ភាគ១**ដល់១០ ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ ឆ្នាំ១៩៩៥។
- សៅ វាសនា **តម្លៃអប់រំក្នុងគតិលោក** និក្ខេបបទសម្រាប់បញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ភ្នំពេញ ឆ្នាំ២០១៩។
- វ៉ាន់ ឌីកាអុន **សង្គមសាស្ត្រ** ការផ្សាយរបស់អ្នកនិពន្ធ ភ្នំពេញ ឆ្នាំ១៩៧៣។
- សរ សារុន **អត្ថាធិប្បាយទស្សនវិជ្ជា** ការផ្សាយរបស់អ្នកនិពន្ធ ភ្នំពេញ ឆ្នាំ១៩៧៤។
- សរ សារុន **ល្បងសិក្សាសង្គមវិជ្ជាខ្មែរ** បោះពុម្ពលើកទី១ ឆ្នាំ១៩៧៣។
- ហ៊ុន គឹមសៀ **មូលដ្ឋានដើម្បីយល់ពីអក្សរសាស្ត្រសម្រាប់ថ្នាក់ទី៤-៣-២-១** នៃមធ្យមសិក្សាទំនើប
- Longman Dictionary of English Language and Culture, new edition, Printed in Spain, 1998, P.1169.
- Petit Larousse en Couperus p. 1130.m9-
- The World Book Enclopedia, M. volume 13, 1995
-Website: www.google.com

# ឥទ្ធិពលព្រះពុទ្ធសាសនាក្នុងសង្គមខ្មែរ

*ដោយៈ បណ្ឌិត* **ហែម ឡាច**
*ប្រធានស្តីទីនាយកដ្ឋាននីតិសាស្ត្រ*
*នៃវិទ្យាស្ថានមនុសាស្ត្រនិងវិទ្យាសង្គម*
*រាជបណ្ឌិត្យសភាកម្ពុជា*

ប្រជាជាតិខ្មែរជាជាតិសាសន៍មួយមានគ្រឹះ មានមូលដ្ឋានជាតិនិងលក្ខណៈជាតិច្បាស់លាស់ រឹងមាំជាងជាតិនានានៅជ្រោយសុវណ្ណភូមិនេះ។ ខ្មែរមានវប្បធម៌ អរិយធម៌ចាស់ទុំពិតប្រាកដជាងគេទាំងអស់។ មានភស្តុតាងបញ្ជាក់ច្បាស់លាស់ដែលបានបន្សល់ទុករហូតមកដល់សព្វថ្ងៃគឺតាមរយៈសិលាចារឹកនានា។ ទោះបីខ្មែរបានទទួលវប្បធម៌អរិយធម៌បរទេសខ្លះក៏ដោយ ក៏វប្បធម៌ អរិយធម៌ខ្មែរ នៅតែរក្សាបាននូវលក្ខណៈ រឹងមាំនិងបុគ្គលភាពរបស់ខ្លួនដដែល។

ព្រះពុទ្ធសាសនា គឺជាសាសនាដ៏ចំណាស់មួយដែលបានជ្រាបចូលក្នុងសតិអារម្មណ៍ប្រជាជនខ្មែរយើងរាប់ពាន់ឆ្នាំមកហើយ។ ទោះបីជាទ្រឹស្តីសាសនានេះមានពេលខ្លះរីកចម្រើនខ្លាំង មានពេលខ្លះរេចរិល អន់ថយបែបណាក៏ដោយ ក៏ទ្រឹស្តីនេះនៅតែមានឥទ្ធិពលគ្របដណ្តប់លើផ្នត់គំនិតរបស់កូនខ្មែរយើងជាដរាប រហូតដល់យើងនាំគ្នាយកសាសនានេះជាសាសនារបស់រដ្ឋទៀតផង(ធម្មនុញ្ញឆ្នាំ១៩៩៣ ជំពូកទី៣ មាត្រា៤៣)។ ឥទ្ធិពលសាសនានេះស្ទើរតែគ្របជិតលើសកម្មភាព ជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាជនខ្មែរ ដូចជា ការធ្វើបុណ្យទានតាមគន្លងប្រពៃណី ការលះបង់ ការបរិច្ចាគទ្រព្យសម្បត្តិគ្រប់បែបយ៉ាងក្នុងការសាងសង់ផ្លូវថ្នល់ មន្ទីរពេទ្យ សាលារៀន ស្រះទឹក អណ្តូង ជាដើម។ ក្រៅពីនេះក៏នៅមានការចែករំលែកទ្រព្យសម្បត្តិ ដើម្បីជួយអ្នកក្រីក្រ ប្រជាជនដែលទទួលរងគ្រោះធម្មជាតិផ្សេងៗ មានលុយកាក់ជាសម្ភារៈប្រើប្រាស់ជាស្បៀងអាហារ ជាដើម។

បច្ចុប្បន្ននេះ នៅទូទាំងប្រទេសយើងមានវត្តអារាមសរុបជាងប្រាំពាន់វត្ត និងមានព្រះសង្ឃជាងប្រាំពីរម៉ឺនអង្គ។ ប្រជារាស្ត្រខ្មែរជាង៩០% ជាអ្នកកាន់ព្រះពុទ្ធសាសនា។ ការគោរពព្រះពុទ្ធសាស

នានេះមានតាំងពីសម័យបុរាណមកគឺតាំងពីមុនសម័យអង្គរទៅទៀត។ ការគោរពព្រះពុទ្ធសាសនាតៗគ្នារាប់ស. វ. បែបនេះបានធ្វើឱ្យទស្សនវិជ្ជាពុទ្ធសាសនាជ្រួតជ្រាបនិងជិតជាប់ក្នុងផ្នត់គំនិតប្រជាពលរដ្ឋខ្មែរទូទាំងប្រទេស។ ផ្នត់គំនិតនេះបានក្លាយទៅជាទស្សនៈរួមរបស់ជាតិទៅហើយ។ ប្រជាពលរដ្ឋខ្មែរទាំងប្រុសទាំងស្រីទោះបីជាមិនបានទៅរៀនធម៌អាថ៌ក៏ដោយក៏ទស្សនៈរបស់ព្រះពុទ្ធដែលបន្តពីឪពុកម្តាយបានជ្រាបចូលទៅដល់កូនចៅរួចស្រេចទៅហើយៗមិនអាចប្តូរផ្លាស់ដោយងាយៗបានឡើយ។ ប្រជាពលរដ្ឋភាគច្រើនជាពិសេស អ្នកដែលរស់នៅជនបទរមែងផ្សារភ្ជាប់ខ្លួនទៅនឹងវត្តអារាម។ ទីណាមានប្រជារាស្ត្រខ្មែររស់នៅទីនោះមានវត្តអារាមជាទីតាំងនៃព្រះពុទ្ធសាសនា។

## ១-ប្រវត្តិព្រះពុទ្ធសាសនា

### ១.១-កំណើតព្រះពុទ្ធសមណគោតម

ព្រះបិតាមានព្រះនាមថា សុទ្ធោទន៍ ជាព្រះរាជានៃបក្សសម្ព័ន្ធសាក្យៈ សោយរាជ្យនៅនគរកបិលភស្តុ។ ព្រះមាតាព្រះនាមសិរិមហាមាយា ជាបុត្រីក្សត្រនៃបក្សសម្ព័ន្ធកោឡ្យៈ សើយរាជ្យនៅនគរទេវទហៈ ជាប់ព្រំដែននគរកបិលភស្តុ។

ព្រះពុទ្ធមានព្រះមានថា សិទ្ធត្ថ ឬសិទ្ធាថ៌ នៅក្នុងត្រកូលគោតម។ ឯព្រះរាជអគ្គមហេសី ព្រះនាមពិម្ពាយសោធរា ជាបុត្រីនៃព្រះបាទសុប្បពុទ្ធ។ ព្រះពុទ្ធមានព្រះរាជបុត្រមួយព្រះអង្គព្រះនាមរាហុលកុមារ។

ព្រះពុទ្ធទ្រង់ប្រសូតនៅថ្ងៃសុក្រ ១៥កើត ជាថ្ងៃពេញបូណ៌មី ខែពិសាខ ឆ្នាំច នៅក្រោមដើម
សាលព្រឹក្ស ក្នុងព្រៃលុម្ពិនី បិតចំព្រំប្រទល់នៃនគរកបិលភស្តុនិងនគរទេវ ទហៈ។ ប្រសូតបាន៥ថ្ងៃ មានព្រាហ្មណ៍៨នាក់បានថ្វាយព្រះនាមព្រះអង្គថាសិទ្ធាថ៌ ដែលមានន័យថាអ្នកសម្រេច បានផលប្រយោជន៍គ្រប់បែបយ៉ាង។ ព្រាហ្មណ៍៧នាក់ក្នុងចំណោមព្រាហ្មណ៍៨នាក់ បានលើកម្រាមដៃពីរទាយថាបើព្រះកុមារស្ថិតនៅជាក្សត្រនឹងទៅជាស្តេចចក្រពត្តិ បើចេញសាងផ្នួសនឹងបានត្រាស់ជាព្រះពុទ្ធ។ ចំណែកព្រាហ្មណ៍កោណ្ឌញ្ញៈមានវ័យក្មេងជាងគេលើកម្រាមដៃតែមួយ ហើយទាយថា ព្រះរាជកុមារនឹងបានត្រាស់ជាព្រះពុទ្ធ។

នៅពេលព្រះជន្មបាន១៦ព្រះវស្សា ទ្រង់បានរៀបអភិសេកជាមួយព្រះនាងពិម្ពាយសោធរា។ ព្រះបិតាចាត់ឱ្យគេសង់ប្រាសាទបីថ្វាយព្រះអង្គ តម្រូវតាម

រដូវទាំងបី ដើម្បីទប់ស្កាត់កុំឱ្យព្រះអង្គចេញទៅជួបជីវិត មនុស្សខាងក្រៅ។ ដោយសារមានការអផ្សុកពេក ទ្រង់ចេញក្រសាលក្នុងឧទ្យានក៏ជួបនឹងទេពនិមិត្ត៤យ៉ាង លើកទី១ទតឃើញមនុស្សជរា លើកទី២ទតឃើញមនុស្សឈឺ លើកទី៣ទតឃើញមនុស្សស្លាប់ លើកទី៤ ទតឃើញមនុស្សបួស។ ទេពនិមិត្តទី៤នេះជំរុញឱ្យព្រះអង្គចេញសាងព្រះផ្នួស។ ប៉ុន្តែ ពេលព្រះអង្គ ទ្រង់សម្រេចព្រះទ័យចេញសាងផ្នួសពេលនោះទ្រង់ជ្រាបថាព្រះនាងពិម្ពាប្រសូតរាហុល តែទ្រង់នៅតែកាត់ព្រះទ័យចេញសាងផ្នួសដដែល។ ក្នុងព្រះជន្ម២៩ព្រះវស្សាព្រះអង្គទ្រង់យាងសាងផ្នួសទាំងកណ្ដាលអាធ្រាត្រ ដោយមានព្រាហ្មណ៍កោណ្ឌញ្ញ និងកូន ៤ នាក់តាមបម្រើផងដែរ ហៅថា បញ្ចវគ្គិយ។

ព្រះអង្គបានលះបង់រាជវង្ស មហេសី បុត្រ ហើយលួចរត់ទៅសាងព្រះផ្នួសនៅវេលាកណ្ដាលរាត្រីស្ងាត់។ ដំបូងទ្រង់សិក្សាជាមួយព្រាហ្មណ៍ឈ្មោះអាឡារតាបស និងឧទកតាបស តែដោយពុំទទួលបានលទ្ធផលល្អ ទ្រង់ក៏ស្វែងរកសច្ចធម៌ តែមួយព្រះអង្គឯងរហូតបានត្រាស់ដឹងជាព្រះពុទ្ធព្រះនាម សមណគោតម។

ព្រះអង្គបានត្រាស់ដឹងជាព្រះពុទ្ធនៅថ្ងៃពុធ ១៥កើតខែពិសាខ ឆ្នាំរកា ក្នុងជន្មាយុ៣៥វស្សា។ បន្ទាប់ពីបានត្រាស់ដឹងនូវសម្មាសម្ពោធិញ្ញាណហើយ ព្រះពុទ្ធទ្រង់សំដែងធម្មទេសនាទូន្មានសត្វលោកដោយពុំប្រកាន់វណ្ណៈឡើយ។ អស់រយៈពេល៤៥ឆ្នាំ ព្រះអង្គតែងបំពេញពុទ្ធកិច្ច ៥ប្រការជានិច្ច គឺ៖

ពេលព្រឹក ទ្រង់និមន្តបិណ្ឌបាត ប្រោសសត្វលោក

ពេលរសៀល ទ្រង់សម្ដែងធម្មទេសនាដល់សាធារណជន

ពេលព្រលប់ ទ្រង់ប្រទានឱវាទដល់ភិក្ខុសង្ឃ

ពេលកណ្ដាលអាធ្រាត្រ ទ្រង់ដោះស្រាយប្រស្នានៃពួកទេវតា

ពេលជិតភ្លឺ ទ្រង់ប្រមើលទតភ័ព្វសំណាងរបស់សត្វលោក។

នៅថ្ងៃ១៥កើតខែមាឃ ក្នុងវស្សាទី៤៥ ព្រះអង្គបានដាក់អាយុសង្ខារ ដោយប្រកាសប្រាប់មារថា ៣ខែទៀត ព្រះអង្គនឹងចូលបរិនិព្វាន។

ព្រះអង្គចូលបរិនិព្វាននៅថ្ងៃអង្គារ ១៥កើតខែពិសាខ ឆ្នាំម្សាញ់ ក្នុងព្រះជន្ម៨០ វស្សា។

**១.២-ប្រវត្តិព្រះពុទ្ធសាសនា**

ព្រះពុទ្ធសាសនាមានដើមកំណើតនៅប្រទេសឥណ្ឌា នៅស.វ.ទី៦

មុនគ.ស.។ កំណើតនេះប្រហាក់ប្រហែលគ្នានឹងកំណើតព្រហ្មញ្ញសាសនាដែរ (សម័យទីពីរនៃលទ្ធិព្រហ្មញ្ញសាសនា)។ លុះក្រោយមកក្នុងរជ្ជកាលព្រះបាទ កនិស្កៈ ប្រមាណ ស.វ. ទី១ នៃគ.ស. ព្រះពុទ្ធសាសនាបានបែងចែកជាពីរនិកាយធំៗគឺ និកាយហីនយាន និងនិកាយមហាយាន។

និកាយហីនយានបែកចេញទៅទិសខាងត្បូងនៃប្រទេសឥណ្ឌា គេហៅថា «ទក្ខិណនិកាយ» ជាយានតូចចង្អៀតតាមន័យប្រៀបធៀបអាចផ្ទុកសត្វលោកទៅកាន់និព្វានបានតិចតួចណាស់ ពោលគឺ កម្របានសម្រេចដោយនិកាយនេះមានធម៌វិន័យហ្មត់ចត់បំផុត។ និកាយ ហីនយាននិយមធម៌ចាស់ គឺត្រូវគោរពប្រតិបត្តិតាមពុទ្ធឱវាទទាំងអស់ នៃព្រះពុទ្ធដែលទ្រង់បានសម្ដែងរួចមកហើយពោលគឺមាននៅក្នុងគម្ពីរព្រះត្រៃបិដក។ និកាយនេះគោរពព្រះពុទ្ធសមណគោតម ដែលបានត្រាស់ដឹងនូវព្រះសម្មាសម្ពោធិញ្ញាណ ហើយដែលបានបរិនិព្វានទៅហើយ។ និកាយហីនយានចែកចេញជា៣៤និកាយ ប៉ុន្តែសព្វថ្ងៃនេះប្រទេសដែលនិយមនិកាយហីនយានផ្នែកថេរវាទ ដែលជានិកាយមួយក្នុង ចំណោមនិកាយទាំង៣៤របស់ហីនយាន នោះមានប្រទេសកម្ពុជា លាវ ភូមា សិរីលង្កា និងប្រទេសថៃជាដើម។

និកាយមហាយាន បែកចេញទៅទិសខាងជើង ឬយើងហៅថា ឧត្តរនិកាយ ជាយានធំដែល អាចផ្ទុកសត្វលោកបានចំនួនច្រើនទៅកាន់គោលដៅ គឺការជឿត្រឹមព្រះពោធិសត្វ ដែលអាចជួយណែនាំ ប្រោសសត្វលោកឱ្យរួចចាកផុតពីទុក្ខបាបកម្មទាំងឡាយ។ និកាយនេះ និយមធម៌ថ្មី គឺជាធម៌ដែល មានវិន័យធូរស្រាលគោរពតាមលទ្ធិ «អាចរិយវាទ» មានន័យថា គោរពតាមគ្រូអាចារ្យរបស់ខ្លួនតៗគ្នា ពុំមែនគោរពតាមព្រះពុទ្ធ ឱវាទរបស់ព្រះពុទ្ធសមណគោតមដូចនិកាយហីនយានទេ។ គេគោរពត្រឹមព្រះពោធិសត្វដូចជា៖

-**អវលោកិតេស្វរៈ** ជាព្រះពោធិសត្វដែលជួយសង្គ្រោះ និងផ្ដល់នូវសេចក្ដីសុខដល់សត្វលោក

-មញ្ជុស្រី ជាព្រះពោធិសត្វដែលកាន់សៀវភៅមួយ ព្រះរនៃមួយ ជួនកាលកាន់ផ្កាឈូក មានតួនាទី ជាអ្នកស្វែងរកយុត្តិធម៌ គង់លើព្រះទីនាំងជាសត្វគោ និងមានរូបរាងក្មេងជានិច្ច

-**សមន្តភទ្រ** ជាព្រះពោធិសត្វដែលគ្រប់គ្រងអ្នកកាន់សាសនា គង់លើដំរីជាយានជំនិះ

-**មៃត្រេយ្យ** ជាព្រះពោធិសត្វដែលនឹងបានត្រាស់ដឹងជាព្រះពុទ្ធទៅអនាគត បន្ទាប់ពី ព្រះសមណគោតម

-**ក្សិតិគតិ** ជាពោធិសត្វសម្រាប់ស្រង់មនុស្សពីស្ថាននរក

-**ប្រាជ្ញាបារមិតា** ជាពោធិសត្វភេទស្រី តំណាងឱ្យប្រាជ្ញាដ៏ឧត្តម មានរូបរាងជាទេពធិតាមួយព្រះអង្គ។

**១.៣-លំហូរចូលនៃព្រះពុទ្ធសាសនាសាសនាមកកម្ពុជា**

ឆ្លងកាត់តាមរយៈនៃការសិក្សាពុទ្ធសាសនប្រវត្តិ បានឱ្យយើងដឹងថា នៅក្នុងពុទ្ធស. វ. ទី៣ មានព្រះអរហន្តពីព្រះអង្គ គឺព្រះភិក្ខុសោណត្ថេរ និងព្រះឧត្តរត្ថេរ បាននិមន្តចេញមកផ្សព្វផ្សាយពុទ្ធវចនៈ របស់ព្រះពុទ្ធជាអង្គម្ចាស់ នៅដែនដីសុវណ្ណភូមិ តាមសេចក្តីក្រាបបង្គំនិមន្តរបស់ព្រះបាទអសោក និងតាមព្រះរាជបញ្ជារបស់ព្រះមោគ្គលិបុត្តិស្សត្ថេរៈ។ នៅក្នុងគម្ពីរនោះ នៅបានបញ្ជាក់ទៀតថា ពីស. វ. ទី១ដល់ស. វ. ទី៥ នៃគ. ស. ព្រះពុទ្ធសាសនាត្រូវបានផ្សព្វផ្សាយចេញពីប្រទេសឥណ្ឌាជាច្រើនលើក ទៅភាគខាងកើតទៅដល់ មេហ្គាល់ ក្នុងជំនាន់នៃព្រះរាជវង្សកុប្តៈ ឯទិសអាគ្នេយ៍ផ្សាយទៅដល់ជ្រោយសុវណ្ណភូមិ ដែលរួមទាំងនគរហ្វូណនផងដែរ។

ប្រទេសខ្មែរយើងបានទទួលអរិយធម៌ឥណ្ឌាទុកជាមត៌កតាំងពីបុរាណកាលមក។ ព្រះពុទ្ធសាសនា ដែលបានមកប្រតិស្ឋាននៅលើដែនដីខ្មែរ ក៏ក្លាយទៅជាអរិយធម៌សម្រាប់ប្រទេស។ ខ្មែរបានរក្សាអរិយធម៌នេះ ទុកជាប្រពៃណីតពូជពង្ស រហូតមក។ សម័យដើមបុព្វជនខ្មែរតែងតែគោរពលោកធាតុ គឺទឹក ដី ភ្លើង ខ្យល់ អារក្ខ អ្នកតា ព្រះធរណី ព្រះពាយ ភ្នំ ដើមឈើជាទីពឹងទីរឭក សម្រាប់បង្ក្រាបភ័យតក់ស្លុត។

សម័យក្រោយមក ប្រជាជនខ្មែរបានជ្រើសរើសយកសាសនា ដែលខ្លួនយល់ឃើញថា ជាសរណៈឧត្តម អាច បង្ក្រាបភ័យតក់ស្លុតបាន អាចសម្រេចសេចក្តីប្រាថ្នា និងសេចក្តីសង្ឃឹមបាន ក៏យកព្រះពុទ្ធសាសនាជាទីពំនឹងរបស់ខ្លួន ពីព្រោះព្រះពុទ្ធសាសនាបានប្រៀន ប្រដៅមនុស្សឱ្យចេះប្រើជីវិត តស៊ូយកឈ្នះជំនឿនៃបាតុភូតនិយមទាំងឡាយ។

តាមសិលាចារឹកវ៉ូកាញ់ នៅ វៀតណាមខាងត្បូងបច្ចុប្បន្ន បញ្ជាក់ថា ព្រះពុទ្ធសាសនាទំនងជាចូលមកប្រតិស្ឋាន

ក្នុងប្រទេសខ្មែរនៅស. វ.ទី២នៃគ.ស. ក្នុងរជ្ជកាលព្រះបាទស្រីមារៈឬហ្វាន់ ចេម័ន[1]។

## ២-ទ្រឹស្ដីសំខាន់ៗក្នុងព្រះពុទ្ធសាសនា

ព្រះពុទ្ធសាសនាជាសាសនាមនុស្សនិយម មិនមែនជាសាសនាទេវនិយមនោះទេ។ ព្រះពុទ្ធគឺជាមនុស្សធម្មតាដែលកើតឡើងក្នុងត្រកូលក្សត្រនាប្រទេសឥណ្ឌា។ ហេតុផលដែលនាំឱ្យទ្រង់ចេញសាង ព្រះផ្នួសនោះ ក្នុងគោលបំណងតែមួយ គឺការជួយសង្គ្រោះជីវិតមនុស្ស។ យ៉ាងនេះ ទើបយើងសង្កេតឃើញថាទ្រឹស្ដីទស្សនៈរបស់ព្រះអង្គសុទ្ធតែទាក់ទងទៅនឹងជីវិតរស់នៅរបស់មនុស្សទាំងអស់[2]។

គោលសំខាន់ៗនៃទស្សនៈរបស់ព្រះពុទ្ធអង្គក្នុងការអប់រំមានដូចជា៖

### ២.១-អរិយសច្ចៈ

គឺការពិតដ៏ប្រសើរ ដ៏ខ្ពង់ខ្ពស់ដែលព្រះពុទ្ធអង្គទ្រង់ពិចារណារក ឃើញ។ អរិយសច្ចៈមាន៤គឺ៖

### ២.១.១-ទុក្ខអរិយសច្ចៈ

គឺទុក្ខជាសេចក្ដីពិតដែលរមែងកើតដល់មនុស្សសត្វគ្រប់ៗគ្នាហើយពុំអាចជៀសផុតបានឡើយគ្រាន់តែខុសគ្នាត្រង់អ្នកខ្លះមានទុក្ខតិច អ្នកខ្លះមានទុក្ខច្រើនប៉ុណ្ណោះ។ ទុក្ខធំៗមាន៤គឺ៖

**-ជាតិទុក្ខ** គឺទុកព្រោះមានកំណើត

**-ព្យាធិទុក្ខ** គឺទុកព្រោះមានជំងឺផ្សេងៗមកបៀតបៀន

**-ជរាទុក្ខ** គឺទុកព្រោះចាស់គ្រាំគ្រាទ្រុឌទ្រោម

**-មរណទុក្ខ** គឺទុក្ខព្រោះស្លាប់។

ក្រៅពីទុក្ខធំៗ ៤យ៉ាងនេះនៅមានទុក្ខជាច្រើនប្រភេទទៀតដូចជាទុក្ខកើតឡើងដោយការព្រាត់ប្រាស់មិនបានសម្រេចបំណងអ្វីមួយ ទុក្ខព្រោះមិនមានទ្រព្យ ទុក្ខព្រោះសោកស្ដាយ[3]។ល។

### ២.១.២-សមុទយអរិយសច្ចៈ

គឺទុក្ខជាសេចក្ដីពិតដែលកើតឡើងមកអំពហេតុឬឫសគល់ពិតប្រាកដ។ ហេតុដែលនាំឱ្យមានទុក្ខមានពីរធំៗគឺ តណ្ហា និងអវិជ្ជា។ តណ្ហា គឺសេចក្ដីស្រេកឃ្លាន សេចក្ដីប្រាថ្នា សេចក្ដីលោភលន់ចង់មានចង់បានអ្វីៗគ្រប់បែបយ៉ាងមិនចេះឆ្អែត មិនចេះចប់។ អវិជ្ជា គឺជាសេចក្ដីល្ងង់ខ្លៅឬមិនដឹងមិនយល់នូវ

---

[1] ត្រឹង ងា៖ *អរិយធម៌ខ្មែរ* ការផ្សាយរបស់អ្នក និពន្ធ គ.ស.១៩៧៥ ទំព័រទី៣១

[2] សាកលវិទ្យាល័យបៀលប្រាយ៖ *សិល្បៈនៃការរស់នៅ* ឯកសារប្រើប្រាស់ផ្ទៃក្នុង ឆ្នាំ២០១៩ ទំព័រ ២០

[3] ប៉ាង ខាត់៖ *ព្រះត្រៃបិដកជាភាសាខ្មែរ* ភ្នំពេញ ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ ព.ស. ២៥៣៨ គ.ស. ១៩៩៥

ហេតុដែលនាំឱ្យមានទុក្ខ។ អវិជ្ជានេះ នាំឱ្យកើតមានតណ្ហាឡើង។ តណ្ហារបស់មនុស្សគ្មានព្រំដែនកំណត់នោះទេ។

**២.១.៣-និរោធអរិយសច្ចៈ**

គឺជាការរួចស្រលះ ឬការរំលត់ទុក្ខជាសេចក្ដីពិត។ កន្លែងរំលត់ទុក្ខគឺនិព្វាន។ ដើម្បីរំលត់ទុក្ខឱ្យអស់រលីងត្រូវបំបាត់ឬរំលើងឫសគល់នៃទុក្ខ ពោលគឺបំបាត់អវិជ្ជារំលាយតណ្ហាប្រៀបបានទៅនឹងការរំលើងឫសកែវដើមឈើឱ្យអស់ ទើបដើមឈើនោះលែងដុះលូតលាស់បាន។ តើយើងត្រូវធ្វើដូចម្ដេចដើម្បីរំលត់ទុក្ខ?

**២.១.៤-មគ្គអរិយសច្ចៈ**

គឺផ្លូវឬមធ្យោបាយនាំឱ្យផុតទុក្ខជាសេចក្ដីពិត។ដើម្បីរំលត់ទុក្ខហើយទៅដល់និព្វាន ព្រះពុទ្ធបានបញ្ជាក់ថាត្រូវប្រកាន់ផ្លូវកណ្ដាល(មជ្ឈិមប្បដិបទា) ហើយប្រតិបត្តិយ៉ាងខ្ជាប់ខ្ជួននូវមគ្គ៨យ៉ាង(អដ្ឋង្គិកមគ្គ) គឺ៖

**-សម្មាទិដ្ឋិ** ការយល់ឃើញត្រូវ។ ការយល់ឃើញពិតនូវសភាវធម៌ទាំងពួងឃើញតាមអរិយសច្ចៈទាំង៤ហើយពេញចិត្តនឹងប្រតិបត្តិតាមផ្លូវត្រូវដើម្បីបំបាត់នូវអវិជ្ជា និងតណ្ហា។

**-សម្មាសង្កប្ប** ការត្រិះរិះត្រូវ។ គឺត្រិះរិះក្នុងការមិព្យាបាទមិនបៀតបៀនចំពោះមនុស្សសត្វទូទៅ។ ការត្រិះរិះត្រឹមត្រូវនាំឱ្យជួបប្រទះផលល្អ និងសេចក្ដីសុខចម្រើន។

**-សម្មាវាចា** វាចាត្រឹមត្រូវ។ គឺសំដីត្រឹមត្រូវវៀចាកវចីទុច្ចរិត៤យ៉ាងគឺ៖

មុសាវាទ គឺពាក្យមិនពិត ពាក្យកុហកបោកប្រាស់។

បិសុនាវាទ គឺពាក្យស៊កសៀតញុះញង់ បំបែកបំបាក់។

ផរុសវាទ គឺពាក្យជេរប្រទេចតិះដៀល ដៀមដាម។

សម្ផប្បលាបាវាទគឺពាក្យ ផ្ដេសផ្ដាស ឡេះឡោះ អត់ប្រយោជន៍។

**-សម្មាកម្មន្ត** ការងារត្រឹមត្រូវ។ គឺប្រព្រឹត្តល្អ វៀរចាកកាយទុច្ចរិត៣យ៉ាងគឺ៖

បាណាគឺការសម្លាប់សត្វមានជីវិត។

អទិន្នា គឺការលួចទ្រព្យអ្នកដទៃ។

កាមេ គឺការប្រព្រឹត្តខុសខាងផ្លូវកាមជាមួយកូន ប្ដី ឬប្រពន្ធអ្នកដទៃ។

**-សម្មាអាជីវ** ការចិញ្ចឹមជីវិតត្រឹមត្រូវ។ គឺវៀរចាកការចិញ្ចឹមខុសគន្លងធម៌ដូចជា លួចប្លន់ទ្រព្យសម្បត្តិ ធ្វើជំនួញទុច្ចរិតជាដើម។

**-សម្មាវាយាម** ការព្យាយាមត្រឹមត្រូវ។ គឺព្យាយាមតាមផ្លូវចិត្តគំនិតដូចជា

ការពារកុំឱ្យមានបាបអកុសលឬសៅហ្មងកើតឡើងក្នុងសន្តានចិត្ត និងព្យាយាមខាងផ្លូវកាយដូចជាការព្យាយាមធ្វើអំពើល្អគ្រប់បែបយ៉ាង ព្យាយាមរក្សាអំពើល្អគ្រប់បែបយ៉ាងដែលកើតឡើងជាដើម។

-**សម្មាសតិ** សតិត្រឹមត្រូវ។ គឺការរំលឹកនឹកឃើញនិងដឹងខ្លួនជានិច្ច។ គេចាត់ទុកសតិជាឆ្មាំទ្វារដ៏ប្រសើរក្នុងការឃ្លាំមើល ការពារកុំឱ្យគ្រឿងវិញ្ញាណ ផ្សេងៗ មានភ្នែក ត្រចៀក អណ្ដាតច្រមុះ កាយទទួលអារម្មណ៍អាក្រក់បាន។

-**សម្មាសមាធិ** ការធ្វើសមាធិត្រឹមត្រូវ។ គឺការចម្រើនភាវនាដើម្បីតម្កល់ចិត្តឱ្យនឹងមិនឱ្យរវើរវាយ អណ្ដែតអណ្ដូងពោលគឺតាំងចិត្តឱ្យស៊ប់ជានិច្ចក្នុងអារម្មណ៍តែមួយ។

អរិយសច្ចៈទាំង៤ខាងលើប្រៀបដូចជា "ជំងឺ ហេតុនៃជំងឺ ថ្នាំព្យាបាលនិងវិធីព្យាបាល"[4]។

**២.២-ទស្សនៈកម្មផល**

តាមភាសាសម្រាប់ក្មេង កម្ម និងផលត្រូវបានគេពន្យល់ថា "ធ្វើល្អ អំពើល្អនឹងកើតចំពោះអ្នក" នៅក្នុងបច្ចុប្បន្នជាតិ និងអនាគតជាតិ។ កម្ម និងផលត្រូវគេប្រដូចទៅនឹងការដាំដុះដែលថា "បើអ្នកសាបព្រោះ គ្រាប់ពូជល្អ អ្នកនឹងប្រមូលបាននូវភោគផលល្អ"។ បើតាមលក្ខណៈវិទ្យាសាស្ត្រ កម្ម និងផលត្រូវបានគេពន្យល់ថា បើហេតុល្អ ផលក៏ល្អដែរ បើហេតុអាក្រក់ ផលក៏អាក្រក់ដែរ"[5]។

ពាក្យថា "កម្ម" មានន័យថា អំពើការងារ ឬកិច្ចការ ដែលមនុស្សម្នាក់បានប្រព្រឹត្តដោយកាយក្ដី វាចាក្ដី ចិត្តក្ដី។ ពាក្យថា "ផល" មានន័យថា ផ្លែផ្កាដែលលេចចេញមកអំពីកម្ម។ មនុស្សជាអ្នកសាងកម្មដោយខ្លួនឯង ហើយត្រូវទទួលយកផលនៃកម្មនោះដោយខ្លួនឯងដែរ។

ដូច្នេះ តាមទស្សនៈពុទ្ធនិយម មនុស្សដែលមានលក្ខណៈអាក្រក់ល្អ មានក្រ សខ្មៅ ខ្ញៅប្រាជ្ញ កាចស្លូត។ល។ គឺមកពីការកសាងឬអំពើរបស់មនុស្សម្នាក់ៗនេះឯង។ អំពើល្អ និងអំពើអាក្រក់ពុំអាចលុបលាងឬសងគ្នាបានទេ។ អំពើល្អរមែងផលិតផលល្អ អំពើអាក្រក់រមែងផលិតផលអាក្រក់។ ផលនៃកម្មមិនសាបសូន្យទេ គ្រាន់តែទទួលយូរឬឆាប់ប៉ុណ្

---

[4] ឆយ យីហ៊ាង៖ ***ពុទ្ធសាសនានិងបញ្ហាអប់រំ*** បទន្ទរាគមន៍ក្នុងសិក្ខាសាលាជាតិស្ដីពី "***ស្ថានភាពសាសនានៅកម្ពុជានាពេលបច្ចុប្បន្ន***" រៀបចំដោយវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម នៃរាជបណ្ឌិត្យសភាកម្ពុជា ឆ្នាំ២០០២

[5] K.Sri Dhammanada : ***What Buddhists Believe***, Expanded & revised edition edition, Taiwan 1993 p.88

ណោះ។ កម្មខ្លះផ្តល់ផលភ្លាមៗក្នុង បច្ចុប្បន្នជាតិ។ កម្មខ្លះទៀតផ្តល់ផលនូវជាតិខាងមុខ បន្ទាប់ពីជាតិបច្ចុប្បន្ននេះ ឬក្នុងជាតិជាលំដាប់តៗទៅទៀត[6] ។

## ២.៣-ទ្រឹស្តីបដិច្ចសមុប្បាទ

ទ្រឹស្តីនេះ គឺជាការបង្រៀនដ៏សំខាន់បំផុតរបស់ព្រះសម្មាសម្ពុទ្ធ ហើយមានលក្ខណៈជ្រាលជ្រៅទៀត ផង។ ជាញឹកញាប់ ព្រះអង្គទ្រង់បានសំដែងអំពីបទពិសោធន៍នៃការត្រាស់ដឹងរបស់ទ្រង់តាមរបៀបពីរយ៉ាងគឺៈទីមួយគឺទ្រង់ឈ្វេងយល់នូវអរិយសច្ចៈបួន មួយទៀតទ្រង់ឈ្វេងយល់អំពីទ្រឹស្តីបដិច្ចសមុប្បាទ។ ទ្រឹស្តីនេះបញ្ជាក់ថា បើនេះមាន នោះក៏មាន បើនេះរលត់ នោះក៏រលត់ បើនេះកើតឡើង នោះក៏កើតឡើង[7] ។

ដូច្នេះ ពុំមានភាវៈណាមួយកើតឡើងដាច់តែឯងដោយគ្មានហេតុបច្ច័យទាក់ទងគ្នានោះទេ។ ចំពោះដំណើរកើត-ស្លាប់នៃមនុស្ស ទ្រឹស្តីបដិច្ចសមុប្បាទបានលើកយកការទាក់ទងគ្នារវាងបុព្វហេតុទាំង១២ មកពន្យល់ដូចតទៅៈ

អវិជ្ជា នាំឱ្យកើត សង្ខារ
សង្ខារ នាំឱ្យកើត វិញ្ញាណ
វិញ្ញាណ នាំឱ្យកើត នាមរូប
នាមរូប នាំឱ្យកើត អាយតនៈ
អាយតនៈ នាំឱ្យកើត ផស្សៈ
ផស្សៈ នាំឱ្យកើត វេទនា
វេទនា នាំឱ្យកើត តណ្ហា
តណ្ហា នាំឱ្យកើត ឧបាទាន
ឧបាទាន នាំឱ្យកើត ភព
ភព នាំឱ្យកើត ជាតិ
ជាតិ នាំឱ្យកើត ជរា
ជរា នាំឱ្យកើត មរណៈ។

បើមានធាតុណាមួយកើតឡើង ធាតុឯទៀតៗ ឬភាវៈឯទៀតៗ ក៏កើតឡើងបន្តបន្ទាប់គ្នា។ នោះ មានន័យថា កាលបើអវិជ្ជាកើតមានហើយ អវិជ្ជានោះនាំឱ្យកើតសង្ខារ ឯសង្ខារនោះនាំឱ្យកើតវិញ្ញាណ ហើយបន្តគ្នារហូតដល់ជរា មរណៈ។ ផ្ទុយទៅវិញ បើអវិជ្ជារលត់ សង្ខារក៏រលត់ រលត់តៗគ្នាលុះត្រាតែអស់រលីង។ ទំនាក់ទំនងគ្នាទៅវិញទៅមកបែបនេះមានសភាពដូចច្រវាក់ ដែលប្រទាក់គ្នាជាកម្រងឬជារង្វង់ពុំមានចុងពុំមានដើម ហើយមានចលនាវិលចុះវិលឡើងមិនចេះចប់[8]។

## ២.៤-ទស្សនៈអនត្តា

អនត្តាមានន័យថា គ្មានអ្វីដែលជារបស់ខ្លួន អ្វីៗដែលកើតមាននៅលើ

---

៦ ត្រឹង ងា៖ ***អរិយធម៌ខ្មែរ*** ជ.ឯ.ម. ទំព័រទី៣៤

៧ K.Sri Dhammanada : ***What Buddhists Believe***, op. cit. p.106

៨ ត្រឹង ងា៖ ***អរិយធម៌ខ្មែរ*** ជ.ឯ.ម. ទំព័រទី៤០-៤១

ខ្លួនយើងទាំងដៃ ជើង សក់ ជីវិតសុទ្ធតែជារបស់ពុំស្ថិតនៅក្នុងខ្លួនយើងទេ ព្រោះសក់អាចស្កូវធ្មេញអាចបាក់ ដោយមិនស្រប តាមបំណងប្រាថ្នារបស់មនុស្សឡើយ។

តាមទស្សនៈនេះ ព្រះពុទ្ធអង្គទ្រង់ទូន្មានមនុស្សដែលគិតតែលោភលន់ គិតតែបំពេញតែតណ្ហា របស់ខ្លួននោះថាទីបញ្ចប់ទៅខ្លួនមនុស្សក៏ត្រូវរលាយបាត់បង់ទៅវិញជាមិនខាន។ ការពោលបែបនេះធ្វើឱ្យមនុស្សចេះបើកចិត្តឱ្យទូលាយកុំចង្អៀតចង្អល់ត្រូវចេះពិចារណា ចេះគិតដល់អ្នកដទៃផងកុំគិតតែខ្លួន ឯងពេក។ កាលណាបុគ្គលណាមួយគិតតែអត្ត(គិតតែខ្លួន) ផលប្រយោជន៍ខ្លួននោះវានឹងបង្កើតភាពលោភលន់ ហើយភាពលោភលន់នេះបង្កើតបានទៅជាគ្រោះថ្នាក់នៃជីវិត ធ្វើជីវិតមិនឱ្យបានសុខសាន្ត។

អ្វីៗដែលបានលើកយកមកសិក្សានេះ គ្រាន់តែជាការលើកយកទស្សនៈសំខាន់ៗរបស់ព្រះពុទ្ធសាសនា ដើម្បីជាគោលឆ្ពោះទៅរកការប្រតិបត្តិនៅក្នុងជីវិតរស់នៅរបស់មនុស្ស ដើម្បីមនុស្សនិងសង្គមមនុស្សតែប៉ុណ្ណោះ។

**ធម្មសង្វេគទាក់ទងនឹងអនត្តា៖**

*អនិច្ចារសង្ខាររូបយើងអើយ*
*កើតបានមកហើយមិនទៀងទាត់*
*តែងតែប្រទះក្តីវិបត្តិ*
*ប្រែប្រួលច្រាស់ព្រាត់ជាប្រាកដ។*
*ដើមឡើយរូបអើយកត្រូវផូរផង់*
*សម្បុរសមទ្រង់ប្រុសស្រីក័ត្ត*
*ល្អល្អះអស់អង្គសាច់បរិសុទ្ធ*
*រូបអើយនេះព្រាត់ប្រែគ្មានសល់។*
*បាក់ធ្មេញសក់ស្កូវភ្នែកងងឹត*
*ប្រែស្បែកជ្រីវស្ងិតសព្វសាកល*
*ប្រែទាំងរូបកាយយើងទុព្វល*
*សាច់ឈាមសោកសល់ដល់រូបស្លាប់។*

**២.៥-ការរក្សាសីល**

ប្រជាជនដែលបានថ្វាយខ្លួនចូលក្នុងសំណាក់ព្រះពុទ្ធសាសនា គេហៅថាឧបាសក ឧបាសិកា ជាអ្នករក្សានូវសីលទាននិងភាវនា។ អ្នកខ្លះរក្សាសីលប្រាំហៅថានិច្ចសីលឬបញ្ចសីល។ អ្នកខ្លះទៀតរក្សានូវសីលប្រាំបី ហៅថាឧបោសថសីលឬអដ្ឋសីល។ ចំណែកអ្នកមួយចំនួនទៀត អាចរក្សាបានរហូតដល់សីលដប់ដែលគេហៅថាអតិរេកសីលឬទសសីល។

**២.៥.១-សីល៥**

១-បាណាតិបាតា វេរមណី សិក្ខាបទំ សមាទិយាមិ ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយាធ្វើសត្វមានជីវិតឱ្យធ្លាក់ចុះកន្ទង់ គឺសម្លាប់សត្វ។

២-អទិន្នាទានា វេរមណី សិក្ខាបទំ សមាទិយាមិ ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនា ជាហេតុវៀរចាកកិរិយាកាន់យកនូវវត្ថុដែលគេមិនបានឱ្យដោយកាយ ឬដោយវាចា។

៣-កាមេសុ មិច្ឆាចារា វេរមណី សិក្ខាបទំ សមាទិយាមិ ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនា ជាហេតុវៀរចាកកិរិយាប្រព្រឹត្តខុសក្នុងកាមទាំងឡាយ។

៤-មុសាវាទា វេរមណី សិក្ខាបទំ សមាទិយាមិ ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនា ជាហេតុវៀរចាកកិរិយាពោលនូវពាក្យកុហក។

៥-សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណី សិក្ខាបទំ សមាទិយាមិ ខ្ញុំព្រះករុណាសូមសមាទាននូវសិក្ខាបទគឺចេតនាជាហេតុវៀរចាកកិរិយាជាទីតាំងនៃសេចក្ដីប្រមាទគឺផឹកនូវទឹកស្រវឹងគឺសុរានិងមេរ័យ។

**២. ៥. ២- សីល៨**

១-បាណាតិបាតា វេរមណី សិក្ខាបទំ សមាទិយាមិ ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយាធ្វើសត្វមានជីវិតឱ្យធ្លាក់ចុះកន្ទង់ គឺសម្លាប់សត្វ។

២-អទិន្នាទានា វេរមណី សិក្ខាបទំ សមាទិយាមិ ខ្ញុំព្រះករុណា សូមសមាទាននូវ សិក្ខាបទ គឺចេតនា ជាហេតុវៀរចាកកិរិយា កាន់យកនូវវត្ថុដែលគេមិនបានឱ្យដោយកាយឬដោយវាចា។

៣-អព្រហ្មចរិយា វេរមណី សិក្ខាបទំ សមាទិយាមិ ខ្ញុំព្រះករុណា សូមសមាទាននូវ សិក្ខាបទ គឺចេតនា ជាហេតុវៀរចាកកិរិយាប្រព្រឹត្តនូវធម៌មិនប្រសើរ គឺសេពនូវមេថុនធម្ម។

៤-មុសាវាទា វេរមណី សិក្ខាបទំ សមាទិយាមិ ខ្ញុំព្រះករុណា សូមសមាទាននូវ សិក្ខាបទ គឺចេតនា ជាហេតុវៀរចាកកិរិយាពោលនូវពាក្យកុហក។

៥-សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណី សិក្ខាបទំ សមាទិយាមិ ខ្ញុំព្រះករុណា សូមសមាទានសិក្ខាបទគឺចេតនាជាហេតុវៀរចាកកិរិយាជាទីតាំងនៃសេចក្ដីប្រមាទគឺផឹកនូវទឹកស្រវឹងគឺសុរានិងមេរយ។

៦-វិកាលភោជនា វេរមណី សិក្ខាបទំ សមាទិយាមិ ខ្ញុំព្រះករុណា សូមសមាទាននូវ សិក្ខាបទ គឺចេតនា ជាហេតុ

វៀរចាកកិរិយាបរិភោគនូវភោជនាហារក្នុងកាលខុស។

៧-នច្ច គីត វាទិត វិសូកទស្សន មាលា គន្ធ វិលេបន ធារណ មណ្ឌន វិភូសនដ្ឋានា វេរមណី សិក្ខាបទំ សមាទិយាមិ ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនា ជាហេតុវៀរចាកកិរិយារាំ ច្រៀង ប្រគុំ និងមើលនូវល្បែងដែលជាសត្រូវដល់កុសលធម៌និងកិរិយាទ្រទ្រង់នូវប្រដាប់តាក់តែង ស្អិតស្អាង រាងកាយ ដោយផ្កាកម្រង គ្រឿងក្រអូបនិងគ្រឿងលាបផ្សេងៗ។

៨-ឧច្ចាសយន មហាសយនា វេរមណី សិក្ខាបទំ សមាទិយាមិ ខ្ញុំព្រះករុណាសូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកទីសេនាសនៈដ៏ខ្ពស់ហួសប្រមាណនិងទីសេនាសនៈដ៏ប្រសើរ។

**២. ៥. ៣- សីល១០**

១-បាណាតិបាតា វេរមណី សិក្ខាបទំ សមាទិយាមិ ខ្ញុំព្រះករុណា សូមសមាទាននូវ សិក្ខាបទ គឺចេតនាជាហេតុវៀចាកកិរិយាធ្វើសត្វមានជីវិតឱ្យធ្លាក់ចុះកន្លង គឺសម្លាប់សត្វ។

២-អទិន្នាទានា វេរមណី សិក្ខាបទំ សមាទិយាមិ ខ្ញុំព្រះករុណា សូមសមាទាននូវ សិក្ខាបទ គឺចេតនា ជាហេតុវៀរចាកកិរិយាកាន់យកនូវវត្ថុដែលគេមិនបានឱ្យដោយកាយ ឬដោយវាចា។

៣-អព្រហ្មចរិយា វេរមណី សិក្ខាបទំ សមាទិយាមិ ខ្ញុំព្រះករុណា សូមសមាទាននូវ សិក្ខាបទ គឺចេតនា ជាហេតុវៀរចាកកិរិយាប្រព្រឹត្តនូវធម៌មិនប្រសើរ គឺសេពនូវមេថុនធម្ម។

៤-មុសាវាទា វេរមណី សិក្ខាបទំ សមាទិយាមិ ខ្ញុំព្រះករុណា សូមសមាទាននូវ សិក្ខាបទ គឺចេតនា ជាហេតុវៀរចាកកិរិយាពោលនូវពាក្យកុហក។

៥-សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណី សិក្ខាបទំ សមាទិយាមិ ខ្ញុំព្រះករុណាសូមសមាទាននូវសិក្ខាបទគឺចេតនាជាហេតុវៀរចាកកិរិយាជាទីតាំងនៃសេចក្តីប្រមាទគឺផឹកនូវទឹកស្រវឹងគឺសុរានិងមេរ័យ។

៦-វិកាលភោជនា វេរមណី សិក្ខាបទំ សមាទិយាមិ ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺ ចេតនា ជាហេតុវៀរចាកកិរិយាបរិភោគនូវភោជនាហារក្នុងកាលខុស។

៧-នច្ច គីត វាទិត វិសូកទស្សន វេរមណី សិក្ខាបទំ សមាទិយាមិ ខ្ញុំព្រះករុណាសូមសមាទានសិក្ខាបទគឺចេតនាជាហេតុវៀរចាកកិរិយារាំច្រៀងប្រគុំនិង

មើលនូវល្បែងដែលជាសត្រូវដល់កុសលធម៌។

៨-មាលាគន្ធ វិលេបន ធារណ មណ្ឌន វិភូសនដ្ឋានា វេរមណី សិក្ខាបទំ សមាទិយាមិ ខ្ញុំព្រះករុណា សូមសមាទាននូវ សិក្ខាបទ គឺចេតនា ជាហេតុវៀរចាកកិរិយាទ្រទ្រង់នូវប្រដាប់តាក់តែងស្អិតស្អាង រាងកាយ ដោយផ្កាកម្រង និងគ្រឿងលាបផ្សេងៗ។

៩-ឧច្ចាសយន មហាសយនា វេរមណី សិក្ខាបទំ សមាទិយាមិ ខ្ញុំព្រះករុណា សូមសមាទាននូវ សិក្ខាបទ គឺចេតនា ជាហេតុវៀរចាកទីសេនាសនៈដ៏ខ្ពស់ហួសប្រមាណ និងទីសេនាសនៈដ៏ប្រសើរ។

១០-ជាតរូប រជតប្បដិគ្គហណា វេរមណី សិក្ខាបទំ សមាទិយាមិ ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទគឺចេតនាជាហេតុវៀរចាកកិរិយាទទួលកាន់យកនូវមាសនិងប្រាក់ដោយខ្លួនឯងឬប្រើអ្នកដទៃឱ្យទទួលកាន់យកហើយត្រេកអរចំពោះមាសនិងប្រាក់នោះ[៩]។

## ៣-ឥទ្ធិពលព្រះពុទ្ធសាសនាក្នុងសង្គមខ្មែរ

ឥទ្ធិពលព្រះពុទ្ធសាសនបានចាក់ឫសយ៉ាងរឹងមាំក្នុងសង្គមខ្មែរ ទំនោរខ្មែរ និងព្រលឹងខ្មែរតាំងពីសាសនានេះមានអត្ថិភាពក្នុងសង្គមខ្មែររហូតមកដល់ បច្ចុប្បន្ន។ ជាពិសេស ឥទ្ធិពលនៃលទ្ធិពុទ្ធនិយមនេះមានជាអាទិ៍នៅក្នុងជំនឿ ទំនៀមទម្លាប់ប្រពៃណី សិល្បៈ និងអក្សរសិល្ប៍។

### ៣.១-ជំនឿ

ឥទ្ធិពលព្រះពុទ្ធសាសនា បានបណ្តាលឱ្យកើតមានជំនឿផ្សេងៗជាច្រើន ដូចជា ជំនឿលើបុណ្យ បាប កម្ម ផល ស្ថានសួគ៌ ស្ថាននរក សច្ចៈ សុចរិត និងយុត្តិធម៌។ល។

**ជំនឿបុណ្យ បាប:** ធ្វើបុណ្យបានបុណ្យ ធ្វើបាបបានបាប ឬធ្វើល្អបានល្អ ធ្វើអាក្រក់បានអាក្រក់។ ជំនឿបែបនេះធ្វើឱ្យមនុស្សប្រព្រឹត្តនូវអំពើល្អ ស្គាល់បុណ្យ ស្គាល់បាប គុណ ទោស និងរស់នៅប្រកបដោយសីលធម៌ ព្រហ្មវិហារធម៌និងមនុស្សធម៌។ ទ្រឹស្តីព្រះពុទ្ធសាសនាបានបញ្ជាក់ឱ្យឃើញច្បាស់ក្នុងគតិយុត្តិធម៌ថា ធ្វើបុណ្យបានបុណ្យ ធ្វើបាបបានបាប[10]។

[៩] វ៉ា យ៉ាវ៖ *នមស្ការព្រះរតនត្រ័យ* ការផ្សាយរបស់អង្គការសន្តិសេនា គ.ស. ២០១១ទំព័រទី១៦-២៥

[១០] យូ ឌួន៖ *ទស្សនគតិពុទ្ធសាសនា* ភ្នំពេញ ការផ្សាយរបស់អ្នកនិពន្ធ ឆ្នាំ១៩៩៧ ទំព័រទី២៦

**ជំនឿកម្ម ផល:** តាមលទ្ធិពុទ្ធសាសនា អ្នកដែលធ្វើកម្មល្អរមែងបានទទួលនូវផលល្អ ចំណែកអ្នកដែលធ្វើកម្មអាក្រក់ តែងទទួលបាននូវផលអាក្រក់ៗ ទ្រឹស្តីព្រះពុទ្ធសាសនា បង្រៀនមនុស្សឱ្យ វៀរចាកអំពើអាក្រក់ ដែលជាអកុសលកម្ម ហើយឱ្យប្រព្រឹត្តតែអំពើល្អដែលជាកុសលកម្មគ្រប់ច្រកផ្លូវទាំងបី គឺកាយ វាចា ចិត្តៗ ព្រះពុទ្ធទ្រង់បានប្រទានឱវាទបីយ៉ាងគឺះ

ឱ្យវៀរចាកទុច្ចរិត គឺការដែលប្រព្រឹត្តអាក្រក់ ដោយកាយ វាចា ចិត្តៗ

ឱ្យប្រកបសុចរិត គឺប្រព្រឹត្តល្អដោយកាយ វាចា ចិត្តៗ

ធ្វើចិត្តឱ្យបរិសុទ្ធហ្មត់ចត់ ចាកគ្រឿងសៅហ្មងមានលោភៈ ទោសៈ មោហៈជាដើមៗ

ជំនឿលើកម្ម ផល ជាទស្សនៈទ្រឹស្តីនៃលទ្ធិព្រះពុទ្ធសាសនាដែលមានចែងបញ្ជាក់យ៉ាងច្បាស់ថាបើធ្វើកម្មល្អរមែងបានទទួលនូវផលល្អ បើធ្វើកម្មអាក្រក់ រមែងទទួលនូវផលអាក្រក់ដោយចៀសមិនផុតៗ នៅក្នុងរឿងគូលីកំណែន យាយម៉ុកបាននិយាយត្អូញត្អែប្រាប់តាង៉ែតថា កម្មរបស់យើងទេ! ឪវាអើយៗ យើងរាស្ត្រត្រូវតែទទួលកម្មនេះ ព្រោះយើងបានធ្វើបុណ្យពីជាតិមុនមិនបានល្អ[11]ៗ

**ជំនឿស្ថានសួគ៌ ស្ថាននរកះ** តាំងពីយូរលង់ណាល់មកហើយ ពុទ្ធសាសនិកខ្មែរយើងមានជំនឿថាពុំមែនមានតែស្ថានមនុស្សប៉ុណ្ណោះទេ គឺនៅមានស្ថានសួគ៌និងស្ថាននរកទៀតៗ អ្នកដែលប្រព្រឹត្តនូវអំពើល្អ នៅពេលស្លាប់ទៅបានទៅកើតនៅស្ថានសួគ៌សោយសម្បត្តិទិព្វ រីឯអ្នកដែលប្រព្រឹត្តអំពើអាក្រក់វិញ នៅពេលស្លាប់ទៅត្រូវចុះទៅស្ថាននរក រងទុក្ខវេទនាជាក់ជាមិនខានៗ ដោយមានជំនឿដូច្នេះហើយ បានជាប្រជារាស្ត្រខ្មែរដែលគោរព និងជឿជាក់លើព្រះពុទ្ធសាសនា ពុំហ៊ានប្រព្រឹត្តអំពើអាក្រក់ ព្រោះខ្លាចពេលដែលខ្លួនស្លាប់ទៅត្រូវចុះទៅស្ថាននរកៗ

**ជំនឿសច្ចៈ សុចរិត យុត្តិធម៌ៈ** ប្រជារាស្ត្រខ្មែរតែងមានជំនឿទៅលើអ្វីដែលជាការពិត អ្វីដែលត្រឹមត្រូវ និងសមរម្យៗ អ្នកណាក៏ស្រឡាញ់ សច្ចៈ សុចរិត និងយុត្តិធម៌ដែរ ៗ ជំនឿទាំងនេះកើតមាននៅក្នុងសង្គមខ្មែរតាំងពីយូរណាស់មកហើយ ហើយជាកត្តាយ៉ាង

---

[11] អ៊ឹម ថុកះ *គូលីកំណែន* ភ្នំពេញ ការផ្សាយរបស់ក្រសួងអប់រំ យុវជននិងកីឡា ឆ្នាំ២០០២ ទំព័រទី៦

សំខាន់មួយដែលជួយរុញច្រានមនុស្សខ្មែរឱ្យមានសីលធម៌ មនុស្សធម៌ ស្គាល់អំពើល្អអាក្រក់ និងប្រកាន់នូវពាក្យពិតទៀងត្រង់។ លោកសូក្រាត ជាទស្សនវិទូជនជាតិក្រិច សុខចិត្តលះបង់ជីវិតដើម្បីការពារនូវសេចក្តីពិតទៀងត្រង់។

### ៣.២-ទំនៀមទម្លាប់ប្រពៃណី

មានទំនៀមទម្លាប់ប្រពៃណីជាច្រើន ជាប់ទាក់ទងទៅនឹងព្រះពុទ្ធសាសនាដូចជាពិធីរៀបមង្គលការ ពិធីបុណ្យសព និងពិធីបុណ្យផ្សេងៗទៀត។

**ពិធីរៀបមង្គលការ:**តាមប្រពៃណីបុរាណ ពិធីរៀបមង្គលការប្រព្រឹត្តទៅចំនួនបីថ្ងៃគឺថ្ងៃចូលរោង ថ្ងៃស៊ីកំណត់ និងថ្ងៃសំពះ។ នៅថ្ងៃទី២នៃពិធីមង្គលការគេនិមន្តព្រះសង្ឃចម្រើនព្រះបរិត្តដើម្បីឱ្យមានសិរីសួស្តីដល់គូស្វាមីភរិយាថ្មី។ នៅពេលព្រះសង្ឃចម្រើនព្រះបរិត្តនោះ សាមីខ្លួនទាំងពីរនាក់ត្រូវចេញមកស្តាប់ហើយទទួលទឹកមន្តដើម្បីឱ្យជ្រះចង្រៃនិងពេគាផ្សេងៗហើយឱ្យបានសេចក្តីសុខចម្រើនផង។

ក្រោយរៀបការបានបីថ្ងៃគេនាំគូស្វាមីភរិយាថ្មីនេះ ដោយយកផ្កាស្លាប្បងចំអាបបង្អែម ស្លាបារីទៅថ្វាយបង្គំសុំពរពីព្រះសង្ឃនៅឯវត្ត ហើយឱ្យព្រះសង្ឃបាចផ្កាស្លានោះ ដើម្បីប្រសិទ្ធពរជ័យឱ្យបានសេចក្តីសុខចម្រើនតរៀងទៅ។

**នៅពេលស្លាប់:** នៅក្នុងគ្រួសារខ្មែរ កាលបើមានមនុស្សស្លាប់ គេតែងរៀបចំធ្វើបុណ្យ ជូនដំណើរខ្មោចនោះតាមទំនៀមទម្លាប់ ដែលប្រែប្រួលទៅតាមសម័យកាល និងប្លែកៗគ្នាតាមតំបន់ នីមួយៗ។ ខ្មែរចាត់ទុកពិធីបុណ្យខ្មោច ឬបូជាសពជាករណីយកិច្ចមួយដែលគ្រួសារសពត្រូវបំពេញ។ កាលណាគេរំលងប្រពៃណីនេះ ដោយទុកឱ្យឪពុក ម្តាយ ជីដូនជីតា បង ប្អូន ស្លាប់ដូចសត្វជាតុនោះ គេនឹងត្រូវទទួលការ រិះគន់ពីសង្គមហើយនឹងមានការស្តាយក្រោយជាមិនខាន។

នៅពេលជិតស្លាប់គេនិមន្តព្រះសង្ឃ៤អង្គ ឬមួយអង្គក៏បាន មកសូត្រធម៌ឱ្យអ្នកជំងឺស្តាប់។ នៅពេលធ្វើបុណ្យសព និងពេលហែសពយកទៅបូជា សុទ្ធតែត្រូវការព្រះសង្ឃចូលរួម។

**ពិធីបុណ្យផ្សេងៗ** ប្រជារាស្ត្រខ្មែរជាអ្នកកាន់ព្រះពុទ្ធសាសនា។ គេតែងមានជំនឿលើកម្មផល បាប នរក សួគ៌ និព្វាន ។ល។ ជាពិសេសគេជឿថាមានជាតិខាងមុខទៀតបានសេចក្តីថាមនុស្សយើង កាលណាស្លាប់ទៅមិនសូន្យទេ គឺត្រូវទៅកើតទៀត។ ដូច្នេះ ដើម្បីរចនាខ្សែជីវិតគេឱ្យបានល្អប្រសើរទៅអនាគត គេនិយមធ្វើបុណ្យទានផ្សេងៗ។ ពិធី

បុណ្យដែលជាប់ទាក់ទងទៅនឹងព្រះពុទ្ធសាសនាមានច្រើនណាស់ដូចជា បុណ្យចូលព្រះវស្សា ចេញព្រះវស្សា ពិសាខបូជា មាឃបូជា ភ្ជុំបិណ្ឌ។ល។

### ៣.៣-សិល្បៈ

មានសំណង់សិល្បៈខ្មែរជាច្រើនដែលមានទំនាក់ទំនងនឹងព្រះពុទ្ធសាសនាដូចជា គំនូរ ចម្លាក់ ប្រាសាទ ស្តូប ចេតិយ ព្រះវិហារ។ល។

**គំនូរ ចម្លាក់៖** មានគំនូរចម្លាក់ជាច្រើនគេគូរឆ្លាក់យកលំនាំតាមបែបរឿងរ៉ាវក្នុងព្រះពុទ្ធសាសនាដូចជាការប្រសូត ការធ្វើទុក្ករកិរិយា ការសម្តែងធម្មចក្រ បរិនិព្វាន[12]។ល។

**ប្រាសាទ៖** នៅប្រទេសកម្ពុជាយើង មានប្រាសាទជាច្រើនដែលគេសាងសង់ឡើងដើម្បីឧទ្ទិសថ្វាយព្រះពុទ្ធសាសនា។ ប្រាសាទទាំងនោះមានដូចជា ប្រាសាទបាយ័ន ប្រាសាទតាព្រហ្ម ប្រាសាទព្រះខាន់ ប្រាសាទនាគព័ន្ធ ប្រាសាទបន្ទាយក្តី។ល។

**ស្តូប៖** ស្តូបជាគារវវត្ថុ ជាទីបញ្ចុះសព ឬអដ្ឋិធាតុរបស់បុគ្គល មានមាតាបិតាជាដើមដែលគេគួរតែគោរព។ រូបភាពស្តូបមានរាងមូល ខាងក្រោមរីកធំត្រអាកខាងលើរាវស្រួចដូចអកកំប៉ោក៏មាន មានរាងទាលដូចផ្តិលផ្កាប់ក៏មានដែលគេ ក សាងដោយពូនដីជាពំនូកក៏មាន ក សាងដោយឥដ្ឋដោយថ្មក៏មាន។

**ចេតិយ:** ចេតិយច្រើនមានរាងបួនជ្រុង ឬរាងមូល បិតត្រួតលើគ្នាជាជាន់ថ្នាក់ៗ បាតក្រោមរីកធំ ហើយរៀវតូចបន្តិចម្តងៗរហូតដល់កំពូល មានរាងជាឆ័ត្ររួតៗ តាមជម្មតា គេសាងចេតិយឱ្យមាន៣ ថ្នាក់ដែលមានន័យតំណាងព្រះរតនត្រ័យគឺព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ។

**ព្រះវិហារ:** ព្រះវិហារ ឬឧបោសថាគារ ជាកន្លែងសម្រាប់តម្កល់ព្រះបដិមា ដែលមានមួយព្រះអង្គធំជាងគេនិងជាកន្លែងសម្រាប់ព្រះសង្ឃធ្វើសង្ឃកម្មផ្សេងៗ មានឧបោសថកម្ម ឧបសម្បទាកម្មជាដើម។ ព្រះវិហារតាំងនៅចំកណ្តាលទីវត្ត ឬទិសខាងកើតនៃទីវត្តនៅលើខឿនខ្ពស់។

### ៣.៤-អក្សរសិល្ប៍

អក្សរសិល្ប៍ពុទ្ធនិយម គឺជាផ្នែកមួយនៃអក្សរសិល្ប៍ជាតិ ដែលបានរួមចំណែកធ្វើឱ្យខឿនអក្សរ សាស្ត្រជាតិរីកចម្រើន។អក្សរសិល្ប៍ពុទ្ធនិយម គេអាចហៅបានថា អក្សរសិល្ប៍ចលនាពុទ្ធ

---

[១២] ទាវ ឆៃសុក៖ *វប្បធម៌ អរិយធម៌ខ្មែរ-ឥណ្ឌា* ភ្នំពេញ ការផ្សាយរបស់អ្នកនិពន្ធ ឆ្នាំ១៩៧១-៧២ ទំព័រទី១៣៨-១៣៩

និយម ឬអក្សរសិល្ប៍ចរន្តពុទ្ធនិយមដែលគេហៅបានតាមការនិយមរបស់អ្នកសិក្សាម្នាក់ៗ។ អក្សរសិល្ប៍ពុទ្ធនិយមមានបីប្រភេទគឺអក្សរសិល្ប៍ពុទ្ធនិយមសុទ្ធសាធ អក្សរសិល្ប៍ពុទ្ធនិយមក្លែងក្លាយ និងអក្សរសិល្ប៍ពុទ្ធនិយមក្លែងក្លាយហួសហេតុ។

**អក្សរសិល្ប៍ពុទ្ធនិយមសុទ្ធសាធ៖** អក្សរសិល្ប៍ពុទ្ធនិយមសុទ្ធសាធសម្គាល់លើស្នាដៃអក្សរសិល្ប៍នៅក្នុងរឿងទសជាតកដែលគេចាត់ទុកជាជាគម្ពីរដ៏ សំខាន់នៃលទ្ធិព្រះពុទ្ធសាសនា។ រឿងទាំង ១០ក្នុងគម្ពីរទសជាតកនេះបានលើកឡើងពីការតស៊ូរបស់ព្រះសម្មាសម្ពុទ្ធ ក្នុងពេលដែលព្រះអង្គយោនយក កំណើតជាតួអង្គព្រះពោធិសត្វក្នុងជាតិផ្សេងៗ ក្នុងការកសាងបារមី ដើម្បីសម្រេចនូវបំណងដ៏ខ្ពស់របស់ព្រះអង្គគឺបានត្រាស់ជាព្រះសម្មា សម្ពុទ្ធ។

រឿងទសជាតកនេះ មានកំណើតតាំងពីសម័យពុទ្ធកាលម្ល៉េះ ពោលគឺព្រះពុទ្ធអង្គជាអ្នកតំណាលប្រាប់ព្រះភិក្ខុសង្ឃ និងពុទ្ធបរិស័ទទាំងឡាយដើម្បីបានឃើញពីការតស៊ូដ៏អស្ចារ្យរបស់ព្រះអង្គក្នុងអតីតជាតិ។ ដើមឡើយរឿងទសជាតកនេះត្រូវបានចារទុកជាភាសាបាលីក្នុងគម្ពីរខុទ្ទកនិកាយជាតកដែលគេប្រកាន់ជឿថាជាពុទ្ធវចនៈ ហើយនិងក្នុងគម្ពីរជាតកដ្ឋកថា ដែលមានមកជាង ២០០០ឆ្នាំ មកហើយ។ អ្នកប្រាជ្ញបុរាណនៃប្រទេសខ្មែរយើង ក៏បានប្រែសម្រាយយ៉ាងពិស្តារតាមអដ្ឋកថាដែលជាពាក្យអធិប្បាយសេចក្តីឱ្យងាយយល់។

រឿងដែលជាអក្សរសិល្ប៍ពុទ្ធនិយមសុទ្ធសាធបានបង្ហាញអំពីបារមីទាំង១០គឺ នេក្ខម្មបារមី វិរិយបារមី មេត្តាបារមី អធិដ្ឋានបារមី បញ្ញាបារមី សីលបារមី ខន្តិបារមី ឧបេក្ខាបារមី សច្ចៈបារមី និងទាន បារមី។ ក្នុងចំណោមជាតកទាំង ១០រឿង វេស្សន្តរជាតក ដែលអធិប្បាយអំពីទានបារមី ត្រូវបានប្រជា ពលរដ្ឋខ្មែរជាពុទ្ធសាសនិកនិយមរាប់អានខ្លាំងជាងគេ។

**អក្សរសិល្ប៍ពុទ្ធនិយមក្លែងក្លាយ៖** អក្សរសិល្ប៍ពុទ្ធនិយមក្លែងក្លាយគឺជាស្នាដៃអក្សរសិល្ប៍ក្នុងគម្ពីរបញ្ញាសជាតក។ គម្ពីរនេះត្រូវបាននិម្មិតឡើងនៅសម័យក្រោយ ក្នុងពេលដែលព្រះពុទ្ធសាសនាថេរវាទរីកចម្រើន និងជះឥទ្ធិពលយ៉ាងខ្លាំងក្លា ជាទីគោរពរាប់អានរបស់ប្រជាជននៅតំបន់អាស៊ីអាគ្នេយ៍យើងនេះ។ អ្នកនិពន្ធបានខិតខំបង្កើតស្នាដៃនេះឡើង ដោយពឹងផ្អែកទៅលើគោល ទស្សនៈ និងទ្រឹស្តីនៃលទ្ធិព្រះពុទ្ធសាសនាក្នុងគោលបំណងផ្សព្វផ្សាយនូវលទ្ធិព្រះពុទ្ធសាសនានេះផង និងអប់រំប្រជាពល

រដ្ឋផង។ ប៉ុន្តែ នៅក្នុងរឿងទាំងអស់នោះ ពុំមែនសុទ្ធតែបំពាក់ទាំងស្រុងទៅលើទស្សនៈទ្រឹស្តីពុទ្ធនិយមទាំងអស់នោះទេ តែអ្នកនិពន្ធក៏បានបញ្ចូលបន្ថែមនូវគោលនិយមនៃលទ្ធិព្រហ្មញ្ញសាសនាខ្លះ ដែលគេធ្លាប់អនុវត្តពីមុនៗមកនិងជាទីចាប់អារម្មណ៍របស់ប្រជាពលរដ្ឋ។ មិនត្រឹមតែប៉ុណ្ណោះ អ្នកនិពន្ធបានបញ្ចូលបន្ថែមនូវរឿងរ៉ាវខ្លះៗដែលជាប់ទាក់ទងនឹងទំនៀមទម្លាប់ស្រុកទេស ជំនឿរបស់អ្នកស្រុក ឥទ្ធិពលរាជានិយម និងអ្វីៗដែលប្រជាពលរដ្ឋធ្លាប់និយមរាប់អានក្នុងជីវភាពរស់នៅ ដើម្បីតម្រូវតាមស្ថានភាពសង្គមមនុស្សក្នុងសម័យនីមួយៗ។

រឿងក្នុងគម្ពីរបញ្ញាសជាតកមានជាអាទិ៍ សុធនកុមារ សុវណ្ណកុមារ សព្វសិទ្ធិ។ល។

***អក្សរសិល្ប៍ពុទ្ធនិយមក្លែងក្លាយហួសហេតុ:*** អក្សរសិល្ប៍ពុទ្ធនិយមក្លែងក្លាយហួសហេតុ ឬគេហៅថា ពុទ្ធនិយមផ្ទុម ជាអក្សរសិល្ប៍ពុទ្ធនិយម មួយបែបដែលពុំមែនជារឿងទសជាតក និងពុំមែនជារឿងបញ្ញាសជាតក។ អក្សរសិល្ប៍ពុទ្ធនិយមក្លែងក្លាយហួសហេតុ គឺជាស្នាដៃអក្សរសិល្ប៍ខ្មែរ ដែលកើតឡើងនៅសម័យកណ្តាល ហើយដែលទទួលឥទ្ធិពលតិចឬច្រើនពីលទ្ធិព្រះពុទ្ធសាសនា។ អក្សរសិល្ប៍ពុទ្ធនិយមក្លែងក្លាយហួសហេតុ អ្នកនិពន្ធច្រើនលើកយកទស្សនៈកម្មផល នៃលទ្ធិព្រះពុទ្ធសាសនា មករួមផ្សំនឹងដំណើរជីវិតលោកិយសច្ចៈ និងសកម្មភាពអច្ឆរិយៈ ការហោះហើរ ដើរលើអាកាស មន្តអាគម នៃលទ្ធិព្រហ្មញ្ញសាសនា ដែលជនជាតិខ្មែរយើងធ្លាប់និយមពីមុនមក។

អក្សរសិល្ប៍ពុទ្ធនិយមក្លែងក្លាយហួសហេតុភាគច្រើន ជាសាស្ត្រាល្បែងដែលកើតឡើងនៅស.វ. ១៨-១៩ ដែលមានឈ្មោះអ្នកនិពន្ធច្បាស់លាស់ដូចជារឿងក្រុងសុភមិត្រ និពន្ធដោយកោសាធិបតីកៅ ឆ្នាំ១៧៩៨។ រឿងកាកី និពន្ធដោយព្រះបាទអង្គដួងឆ្នាំ១៨១០ រឿងមរណមាតា និពន្ធដោយឥន្ទបញ្ញោ អ៊ុក ឆ្នាំ១៨៧៧[13]។ល។

### ៣.៥-នយោបាយគ្រប់គ្រងនិងដឹកនាំប្រទេស

ព្រះពុទ្ធសាសនា មានឥទ្ធិពលលើនយោបាយ ការគ្រប់គ្រង និងការដឹកនាំប្រទេសជាតិគ្រប់របបសង្គមដែលគោរពព្រះពុទ្ធសាសនា។ អ្នកដឹកនាំប្រទេសជាតិ ជាពិសេសព្រះមហាក្សត្រ

---

[១៣] ធ សោះ ***អក្សរសិល្ប៍ពុទ្ធនិយម*** ភ្នំពេញ ការផ្សាយរបស់អ្នកនិពន្ធ ឆ្នាំ១៩៩៤ ទំព័រទី២-៦

ខ្មែរ សុទ្ធតែផ្សារភ្ជាប់ខ្លួនទៅនឹងព្រះពុទ្ធសាសនា។

នៅសម័យអង្គរ ព្រះមហាក្សត្រនានាដែលគោរពព្រះពុទ្ធសាសនា សុទ្ធតែបានលើកតម្កើង ព្រះពុទ្ធសាសនា សំដៅធ្វើឱ្យនយោបាយគ្រប់គ្រងរបស់ព្រះអង្គមានលំនឹង មានស្ថេរភាព និងធ្វើឱ្យប្រជាពលរដ្ឋមានសាមគ្គីភាព និងមានស្ថេរភាពជីវភាព ជុំវិញព្រះរាជបល្ល័ង្ក។ គេសង្កេតឃើញព្រះរាជាទ្រង់បានអនុវត្តដោយគោរពពិធីពុទ្ធរាជ ដែលជាមធ្យោបាយមួយដ៏សំខាន់ធ្វើឱ្យព្រះមហាក្សត្រមានលក្ខណៈប្រហាក់ប្រហែលនឹងតួអង្គព្រះពោធិសត្វមួយព្រះអង្គ តំណាងឱ្យអ្នកមានសុចរិត យុត្តិធម៌មានព្រហ្មវិហារធម៌ និងទសពិធរាជធម៌ ធានាសុខសុវត្ថិភាព និងការរីកចម្រើនរបស់ប្រជាពលរដ្ឋ។

ក្នុងសម័យក្រោយៗមកទៀត លើកលែងតែរបបកម្ពុជាប្រជាធិបតេយ្យ ព្រះពុទ្ធសាសនានៅតែមានឥទ្ធិពលយ៉ាងខ្លាំងដល់នយោបាយគ្រប់គ្រង និងដឹកនាំប្រទេស។ ជាពិសេស សម័យបច្ចុប្បន្ននេះយើងសង្កេតឃើញថា ទាំងព្រះមហាក្សត្រ ទាំងថ្នាក់ដឹកនាំព្រឹទ្ធសភា រដ្ឋសភា រាជរដ្ឋាភិបាល។ល។ សុទ្ធតែបានផ្សារភ្ជាប់ខ្លួននឹងព្រះពុទ្ធសាសនាដោយបានខិតខំកសាងព្រះវិហារ កុដិសាលា ខ្លោងទ្វារនិងស្រះទឹកជាដើម។ ម៉្យាងទៀត ឥស្សរជនជាតិខ្មែរទាំងអស់នោះ ក៏បានចូលរួមដោយផ្ទាល់ក្នុងពិធីបុណ្យទានបែបព្រះពុទ្ធសាសនាដូចជា បុណ្យចូលព្រះវស្សា ចេញព្រះវស្សា បុណ្យកឋិន បុណ្យកាន់បិណ្ឌ បុណ្យពិសាខបូជា មាឃបូជា។ល។

**៣.៦-វត្តអារាមនិងការចូលរួមចំណែកអភិវឌ្ឍសង្គម**

ប្រទេសកម្ពុជាយើងបានកំណត់យកព្រះពុទ្ធសាសនាថាជាសាសនារបស់រដ្ឋ តាមរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣(ជំពូកទី៣ មាត្រា៤៣)។

ឆ្នាំ២០២៣នេះ នៅទូទាំងប្រទេសមានវត្តអារាមសរុបចំនួន ៥១៣៣វត្ត(គណៈមហានិកាយ ៤៨៦៦វត្ត និងគណៈធម្មយុត្តិកនិកាយ ២៦៧វត្ត) និងមានព្រះសង្ឃ៦៨៩៦៧អង្គ (គណៈមហានិកាយ ៦៦៦០៩អង្គ និង គណៈធម្មយុត្តិកនិកាយ ២៣៥៨អង្គ)។

វត្តអារាមដើរតួនាទីយ៉ាងសំខាន់ក្នុងការអភិរក្ស និងអភិវឌ្ឍសង្គមជាតិ។

***-វត្តអារាមជាទីប្រជុំនៃមហាជន និងជាកន្លែងបម្រើសេវាសាធារណៈ***

ការសន្ទនាពីធម៌អាថ៌ ឬព្រឹត្តិការណ៍ណាមួយតាមសេចក្តីចេះដឹងរបស់ជនជាតិខ្មែរ ក្នុងសម័យមុនរហូត

ដល់សម័យនេះ តែងយកវត្តអារាមជាទីប្រជុំ។ ម៉្យាងទៀត វត្តអារាមទុកដូចជាពេងហត្ថកម្មមួយរបស់ជាងគ្រប់ប្រភេទមានជាងឈើ កសាងវិហារ កុដិ សាលាជាដើម។ វត្តអារាមក៏ត្រូវបានប្រើប្រាស់ជាកន្លែងប្រជុំ សិក្ខាសាលា និងវេទិកានានាផងដែរ។ ក្នុងការរៀបចំការបោះឆ្នោតកន្លងមក វត្តអារាមមួយចំនួនក៏បានក្លាយទៅជាកន្លែងសម្រាប់ចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងជាមណ្ឌលរាប់សន្លឹកឆ្នោតទៀតផង។

### -វត្តអារាមជាសាលារៀន

វត្តអារាមជាកន្លែងសិក្សាវិជ្ជា ផ្សេងៗមានអក្សរសាស្ត្រ គណិតសាស្ត្រ និងសិល្បសាស្ត្រជាដើម ព្រោះក្នុងសម័យបុរាណមិនមានសាលាសិក្សាក្រៅពីវត្តអារាមឡើយ។ នៅពេលដែលកូនចៅប្រជាពលរដ្ឋដល់វ័យសិក្សា គេតែងតែយកទៅផ្ញើនឹងព្រះសង្ឃដើម្បីឱ្យព្រះសង្ឃបង្ហាត់បង្រៀន។ អ្នកខ្លះក៏បានបួសជាសាមណេរ និងភិក្ខុដើម្បីជាការតបស្នងសងគុណដល់មាតាបិតា និងមានឱកាសសិក្សារៀនសូត្រ។ បួសកាន់តែយូរមានឱកាសសិក្សាកាន់តែច្រើន។ អ្នកដែលបានបួសរៀន លុះពេលលាចាកសិក្ខាបទមកវិញនឹងត្រូវបានប្រជាពលរដ្ឋគោរពស្រឡាញ់ និងឱ្យតម្លៃខ្ពស់។

### -វត្តអារាមជាអន្តេវាសិកដ្ឋានសម្រាប់សិស្ស និស្សិតក្រីក្រ និងជនគ្មានទីពំនឹង

វត្តអារាមជាច្រើន ជាពិសេសវត្តនៅរាជធានីភ្នំពេញ និងទីប្រជុំជនខេត្តផ្សេងៗទៀត ជាវត្តទទួលបន្ទុកនៃពួកភិក្ខុសាមណេរ និងសិស្ស និស្សិតបានច្រើនណាស់។ វត្តនីមួយៗមានភិក្ខុ សាមណេរ និងក្មេងវត្តដែលមកពីភូមិស្រុកផ្សេងៗមករស់នៅជាមួយគ្នាដើម្បីសិក្សារៀនសូត្រ។ ក្រៅពីភិក្ខុ សាមណេរ សិស្ស និស្សិត នៅមានជនក្រីក្រតោកយ៉ាក ជនអនាថា ជនគ្មានទីពំនឹង ដូនជី តាជី បានពឹងពាក់អាស្រ័យនៅក្នុងវត្តអារាម។ លើសពីនេះទៅទៀត សាធារណជនទូទៅដែលធ្វើដំណើរមកពីកន្លែងផ្សេងៗក៏អាចស្នាក់នៅក្នុងវត្តអារាមបានមួយ រយៈដែរ។

### -វត្តអារាមជាមន្ទីរពេទ្យ

កាលពីសម័យដើម ប្រជាពលរដ្ឋតែងទៅវត្តអារាមនៅពេលដែលពួកគាត់មានសេចក្តីទុក្ខព្រួយ។ កាលបើព្រះសង្ឃបានយល់ជ្រួតជ្រាបអំពីទុក្ខព្រួយរបស់ពួកគាត់ហើយ ព្រះអង្គក៏ពន្យល់អំពីព្រះធម៌តាមផ្លូវព្រះពុទ្ធសាសនាដើម្បីរំលត់ទុក្ខព្រួយ។ ព្រះសង្ឃអង្គខ្លះមានចំណេះខាងវិជ្ជាពេទ្យបុរាណ ព្រះអង្គក៏ជួយ

ព្យាបាលជូនប្រជាជនដោយមិនរើសមុខ និងដោយឥតគិតថ្លៃ។ ព្រះសង្ឃខ្លះពូកែខាងស្រោចទឹកព្យាបាលជំងឺផ្លូវចិត្តជាដើម។ យើងអាចនិយាយបានថា វត្តអារាមជាមន្ទីរពេទ្យសម្រាប់ព្យាបាលជំងឺផ្លូវចិត្តរបស់ប្រជាពលរដ្ឋ។

-វត្តអារាមជាសួនកម្សាន្តសាធារណៈ

វត្តអារាមទុកដូចជាសួនច្បារមួយសម្រាប់ប្រជាពលរដ្ឋដែលនៅជុំវិញ។ កាលណាអផ្សុក ឬមិនសប្បាយចិត្តដោយហេតុផលណាមួយ ប្រជាពលរដ្ឋតែងចូលទៅកាន់វត្តអារាមដែលជាទីកន្លែងទូលំទូលាយ ជាទីរមណីយដ្ឋាន។ លុះបានដើរលំហែមួយស្របក់ ក៏ត្រឡប់ជាបានធូរស្រាលចិត្តឡើងវិញ។ យើងដឹងហើយថា ទីវត្តអារាមគឺជាកន្លែងស្អាត មានដើមឈើ មានស្រះទឹក មានសត្វបក្សាបក្សី។ល។ នេះហើយជាទីរមណីយដ្ឋានសម្រាប់សាធារណជន។ សព្វថ្ងៃនេះ ក្រសួងទេសចរណ៍ក៏បានយកទីតាំងវត្តអារាមមួយចំនួនជាគោលដៅទេសចរណ៍មួយផងដែរ។

**-វត្តអារាមជាកន្លែងសម្រាប់ធ្វើបុណ្យសព បញ្ចុះសព បូជាសព និងតម្កល់អដ្ឋិធាតុ**

ក្នុងពេលដែលមាតាបិតា ញាតិសន្តានព្រៀងលានទាំងប៉ុន្មានធ្វើមរណកាល ប្រជាពលរដ្ឋតែងយកសពនោះទៅធ្វើឈាបនកិច្ចនៅទីវត្ត។ ក្រោយធ្វើឈាបនកិច្ច គេនិយមរើសអដ្ឋិធាតុតម្កល់ក្នុងកោដ្ឋហើយផ្ញើទុកក្នុងវត្តទៀត។ ដល់ទីបំផុត គេធ្វើចេតិយក្នុងវត្តហើយបញ្ចុះអដ្ឋិធាតុនៅក្នុងចេតិយនោះតែម្តង។ សពខ្លះត្រូវបានបញ្ចុះនៅទីវត្ត។ រីឯគ្រួសារដែលមានទីលំនៅតូចចង្អៀតមិនអាចរៀបចំពិធីបុណ្យសពបាន ក៏ត្រូវពឹងពាក់ទៅលើវត្តអារាមផងដែរ។ នេះបញ្ជាក់ឱ្យឃើញថា ប្រជាពលរដ្ឋខ្មែរយើងទីពឹងលើវត្តអារាមតាំងពីនៅរស់ដរាបដល់ស្លាប់។

**-វត្តអារាមជាកន្លែងសម្រាប់ផ្តល់នូវបុណ្យកុសលគ្រប់យ៉ាង**

ប្រជាជនដែលកាន់ព្រះពុទ្ធសាសនា ពេលណាត្រូវការធ្វើបុណ្យទាន រក្សាសីល និងភាវនា រមែងចូលទៅក្នុងវត្តអារាមព្រោះមានភិក្ខុសង្ឃនៅទីនោះ។ ព្រះអង្គអាចពន្យល់ពីបុណ្យទាន ការរក្សាសីល និងភាវនា ដែលអាចឱ្យប្រជាជនយល់ដឹងនិងកើតសេចក្តីជ្រះថ្លា។ ការធ្វើបុណ្យទានផ្សេងៗនៅក្នុងវត្តអារាមមិនត្រឹមតែផ្តល់នូវភាពសប្បាយរីករាយប៉ុណ្ណោះទេ ថែមទាំងផ្តល់នូវកុសលគ្រប់បែបយ៉ាង ហើយបង្ហាញនូវសាមគ្គីភាព ភាតរភាព ក៏ដូចជាចូលរួមចំណែក កសាងសង្គម។ វត្តអារាមទុកដូចជាថ្នាល

សម្រាប់បណ្តុះពូជធារនៃបុណ្យកុសល គ្រប់យ៉ាងដែលនាំមកនូវសេចក្តីសុខ។

**-វត្តអារាមជាកន្លែងសង្គ្រោះ និង អភិរក្សសត្វ**

ដោយវត្តអារាមជាកន្លែងស្ងប់ស្ងាត់ យើងសង្កេតឃើញមានសត្វច្រើនប្រភេទជ្រកកោននៅទីនោះ។ សត្វដែលរស់នៅក្នុងវត្តឬបរិវេណជុំវិញវត្តគេមិនហ៊ានសម្លាប់វាទេ ព្រោះគេខ្លាចបាប។ ប្រជាជនខ្មែរមួយចំនួនជឿថា ប្រសិនបើសត្វចិញ្ចឹមរបស់គេដូចជាគោ ជ្រូក សេះ ជាដើម កើតមកខុសពីធម្មតា មានជើងបីជើងប្រាំ ឬភ្នែកបីៗល។ គេនឹងមានសំណាងអាក្រក់។ គេតែងយកសត្វទាំងនោះទៅទុកចោលក្នុងវត្តឱ្យព្រះសង្ឃចិញ្ចឹមវិញ។ ម្យ៉ាងទៀត ពពួកសត្វខ្លះដូចជាព្រាប លលក ក្អែក និងមច្ឆាផ្សេងៗ បានយកទីវត្តអារាមជាទ្រនំ ជាជម្រកដ៏កក់ក្តៅរបស់ខ្លួន។

**-វត្តអារាមជាបណ្ណាល័យ ជាឃ្លាំងផ្ទុកមត៌កវប្បធម៌ជាតិ**

វត្តអារាមជាកន្លែងតម្កល់នូវគម្ពីរក្បួនខ្នាត ព្រមទាំងឯកសារផ្សេងៗ។ វត្តភាគច្រើនលំអដោយចម្លាក់ គំនូររៀបរាប់អំពីពុទ្ធប្រវត្តិដែលអាចរក្សាទុកសម្រាប់ការសិក្សាស្រាវជ្រាវរាប់រយឆ្នាំ។ សម្ភារវប្បធម៌ផ្សេងៗដែលជាមត៌ករបស់ជាតិ ដែលបម្រើផលប្រយោជន៍ សាធារណៈ ក៏ត្រូវបានបុព្វបុរសយើងតម្កល់ទុកនៅក្នុងវត្តអារាមដែរ។

ក្រៅពីនេះ វត្តអារាមដើរតួនាទីជាកន្លែងដោះស្រាយទំនាស់ក្រៅប្រព័ន្ធតុលាការ ដោយសន្តិវិធី ជាប្រភពមូលនិធិសម្រាប់កសាងជាតិ កន្លែងគោរពបូជា កន្លែងប្រមូលផ្តុំនូវសាមគ្គីធម៌ និងជាទីតាំងដ៏រឹងមាំនៃព្រះពុទ្ធសាសនា។

សរុបសេចក្តីទៅឃើញថា វត្តអារាមព្រះពុទ្ធសាសនានៅប្រទេសកម្ពុជា យើងពិតជាមានប្រយោជន៍ធំធេងណាស់ ព្រមទាំងបាននិងកំពុងដើរតួនាទីយ៉ាងសំខាន់ក្នុងការបម្រើសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ។

ក្នុងនាមជាពុទ្ធសាសនិក យើងគប្បីរួមចំណែកអភិរក្ស និងអភិវឌ្ឍវត្តអារាមយើងឱ្យបានល្អប្រសើរ គង់វង្ស ជាអង្វែងតទៅ៕

## គន្ថនិទ្ទេស


១-ខ្ញូត ធីតា៖ ***ការស្វែងយល់អំពីការវិវត្តព្រះពុទ្ធសាសនានៅក្នុងសង្គមខ្មែរ*** គ. ស. ២០០៧

២-ឆយ យីហ៊ាង៖ ***ពុទ្ធសាសនានិងបញ្ហាអប់រំ*** បទន្ធពាគមន៍ក្នុងសិក្ខាសាលាជាតិស្ដីពី "***ស្ថានភាពសាសនានៅកម្ពុជានាពេលបច្ចុប្បន្ន***" រៀបចំដោយវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម នៃរាជបណ្ឌិត្យសភាកម្ពុជា ឆ្នាំ២០០២

៣-ជួន ណាត៖ ***វចនានុក្រមខ្មែរ*** ភ្នំពេញ ការផ្សាយរបស់វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ គ.ស.១៩៦៧

៤-ត្រឹង ង៉ា៖ ***អរិយធម៌ខ្មែរ*** ការផ្សាយរបស់អ្នកនិពន្ធ គ.ស.១៩៧៥

៥-ទាវ ឆៃសុក៖ ***វប្បធម៌អរិយធម៌ខ្មែរ-ឥណ្ឌា*** ភ្នំពេញ ការផ្សាយរបស់អ្នកនិពន្ធ ឆ្នាំ១៩៧១-៧២

៦-ធ សោះ៖ ***អក្សរសិល្ប៍ពុទ្ធនិយម*** ភ្នំពេញ ការផ្សាយរបស់អ្នកនិពន្ធ ឆ្នាំ១៩៩៤

៧-ប៉ាង ខាត់៖ ***ព្រះត្រៃបិដកជាភាសាខ្មែរ*** ភ្នំពេញ ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ ព.ស. ២៥៣៨ គ.ស. ១៩៩៥

៨-យូ នួន៖ ***ទស្សនគតិពុទ្ធសាសនា*** ភ្នំពេញ ការផ្សាយរបស់អ្នកនិពន្ធ ឆ្នាំ១៩៩៧

៩-រ៉ា យ៉ាវ៖ ***នមស្ការព្រះរតនត្រ័យ*** ការផ្សាយរបស់អង្គការសន្តិសេនា គ. ស. ២០១១

១០-សាកលវិទ្យាល័យបៀលប្រាយ៖ ***សិល្បៈនៃការរស់នៅ*** ឯកសារប្រើប្រាស់ផ្ទៃក្នុង ឆ្នាំ ២០១៥

១១-អ៊ឹម ប៉ុក៖ ***គូលីកំនែន*** ភ្នំពេញ ការផ្សាយរបស់ក្រសួងអប់រំ យុវជននិងកីឡា ឆ្នាំ២០០២ ទំព័រទី៦

១២-K.Sri Dhammanada : ***What Buddhists Believe***, Expanded & revised edition edition, Taiwan 1993 p.88

# ទស្សនវិទូក្រិកបុរាណសម័យ( សូក្រាត ប្លាតុង អារីស្តូត)

*បណ្ឌិត* **ហែម ឡាច** *ប្រធានស្តីទីនាយកដ្ឋាននីតិសាស្ត្រ*
*វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសង្គមនៃ*
*រាជបណ្ឌិត្យសភាកម្ពុជា*

**១-សូក្រាត** )Socrates : ៤៦៩-៣៩៩ មុន គ.ស.)

**១.១-ប្រវត្តិរបស់សូក្រាត**

កាលបរិច្ឆេទពិតប្រាកដនៃកំណើតរបស់សូក្រាតមិនទាន់ត្រូវបានគេដឹងនៅឡើយមុនគ ទេ។ គេជឿថាគាត់បានកើតនៅឆ្នាំ៤៦៩ .ស. នៅទីក្រុងអាថែន )Athens។ ឪពុករបស់( លោកជាជាងចម្លាក់ ហើយម្តាយជាឆ្មប។

ក្រៅពីចំណង់ចំណូលចិត្តខាងវិទ្យាសាស្ត្រនិងទស្សនវិជ្ជា សូក្រាតបានចូលរួមយ៉ាងសកម្មក្នុងការការពារមាតុភូមិរបស់គាត់។ គាត់បានចូលរួមក្នុងយុទ្ធនាការយោធា៣ដងដែលបង្ហាញពីភាពក្លាហានដែលអាចជឿទុកចិត្តបាននៅសមរភូមិ។ មានករណីដែលគេដឹងនៅពេលគាត់ជួយសង្គ្រោះអាយុជីវិតរបស់មេបញ្ជាការរបស់គាត់។

សូក្រាតត្រូវបានរដ្ឋាភិបាលក្រុងអាថែនចោទប្រកាន់ថាគាត់មិនបានគោរពព្រះរបស់ទីក្រុងនាសម័យនោះហើយនិងបានផ្សព្វផ្សាយនូវដំណឹងអកុសលផ្សេងៗទៀត ហើយថែមទាំងបានបំផ្លាញដល់អនាគតរបស់យុវជន។ លោកត្រូវបានគេកាត់ទោសប្រហារជីវិតដោយបង្ខំឱ្យផឹកថ្នាំពុល។សូក្រាតបានស្លាប់នៅឆ្នាំ៣៩៩មុនគ.ស. ក្នុងអាយុប្រហែល៧០ឆ្នាំ[1]។

**១.២-វិធីបង្រៀនរបស់សូក្រាត**

សូក្រាតមានវិធីបង្រៀនពីរយ៉ាងគឺ សិល្បបង្កើតគំនិតនិងការចំអក។ សូក្រាតប្រើវិធីបង្កើតគំនិតចំពោះមនុស្សសាមញ្ញដែលមិនចេះអួតអាងហើយដឹងថាខ្លួនគ្មានចេះអ្វីសោះ។ សូក្រាតប្រើវិធីចំអកចំពោះពួកសូហ្វីស )ពួកទស្សនវិជ្ជាមួយក្រុមប្រឆាំងនឹងទស្សនវិជ្ជារបស់សូក្រាត ។( ពួកនេះអួតអាងនិងមានជំនឿថា ខ្លួនមានចំណេះជាសកល។ ឃ្លាចំបងរបស់សូក្រាតស្តីពីទស្សនវិជ្ជាគឺ ខ្ញុំដឹងតែមួយមុខគត់ គឺគ្មានចេះអ្វីសោះ។ លោកពោលថា៖

-ត្រូវយល់អំពីដំណើរប្រព្រឹត្តិទៅនៃធម្មជាតិ

-ត្រូវយល់នូវអ្វីដែលនៅជិតយើងមុននឹងយល់អ្វីដែលនៅឆ្ងាយពីយើង

-ត្រូវស្គាល់ខ្លួនឯងដោយខ្លួនឯង

-ត្រូវដុសខាត់ព្រលឹង( ចិត្ត )ឱ្យបានប្រសើរជាងដុសខាត់សរីរៈ

-ត្រូវនិយមប្រើពាក្យថា ខ្ញុំមិនចេះអ្វីសោះ

[1] រស់ ចន្ត្រាបុត្រ៖ *សូក្រាត* ភ្នំពេញ ការផ្សាយរបស់សារព័ត៌មានមហាជន ១៩៧២

-ត្រូវជជែកគ្នាដើម្បីរកការពិតព្រោះការជជែកជាវិធីបង្កើតគំនិត

-លទ្ធផលដែលល្អជាលទ្ធផលដែលបានទទួលការរិះគន់រួចហើយ។

## ១.៣-ទស្សនៈសំខាន់ៗរបស់សូក្រាត

-គតិបណ្ឌិតពិតប្រាកដគឺការដឹងថាខ្លួនមិនទាន់ចេះអស់

សូក្រាត ត្រូវបានជនជាតិក្រិចទាំងមូលប្រសិទ្ធនាមថាជាបិតាទស្សនវិជ្ជានិងជាបិតាវិទ្យាសាស្ត្រ នយោបាយផងដែរ។ លោកគឺជាបុគ្គលអស្ចារ្យមួយរូបដែលមានមូលដ្ឋានសច្ចភាពខ្ពស់ក្នុងការដឹកនាំនិងគ្រប់គ្រងជីវិតរបស់ខ្លួន។ សូក្រាតក៏ជាគ្រូបង្រៀនបណ្តុះគំនិតបង្កើតគំនិតយ៉ាងជំនាញមួយរូប តាមរយៈវិធីសាស្ត្រសួរ-ឆ្លើយ។ ទីបំផុតសូក្រាតលេចចេញជាទស្សនៈមួយឃ្លាចំពោះខ្លួនឯងគឺត្រូវនិយមប្រើពាក្យថា«ខ្ញុំមិនចេះអ្វីសោះ»។

វាពិតជាចម្លែកនៅពេលដែលកំពូលទស្សនវិទូមួយរូបនេះដែលមានភាពល្បីល្បាញទាំងគំនិតទាំង ប្រាជ្ញាទាំងកិត្តិសព្ទកិត្តិនាមថាជាកំពូលមនុស្សដែលមានសមត្ថភាពប្រកបដោយបញ្ញាញាណ។ ប៉ុន្តែសម្រាប់សូក្រាតបែរជាទម្លាក់ខ្លួនឯងជាមួយទ្រឹស្តីថា« ខ្ញុំមិនចេះអ្វីសោះ» ទៅវិញ ។

ជាការពិតណាស់សម្តីមួយឃ្លារបស់សូក្រាតនេះអាចមានការមិនយល់ស្របផ្នែកការយល់ឃើញលើ សមត្ថភាពរបស់លោក ។ ប៉ុន្តែនៅសម័យរបស់សូក្រាតមនុស្សសិក្សាពីអ្វីដែលមាននៅក្នុងចក្រវាល។ មានន័យថា នៅក្នុងចក្រវាលគឺមានរឿងរ៉ាវរាប់លានជំពូកដែលត្រូវសិក្សាស្រាវជ្រាវរែកញែកនិងស្វែងរកជារបកគំហើញថ្មីៗ ការបកស្រាយថ្មីបង្កើតទ្រឹស្តីថ្មី។ វាជាសម័យកាលមួយដែលជាបេសកកម្មរបស់អ្នកមានសមត្ថភាពខ្ពស់ផ្នែកខួរក្បាលដើម្បីទៅរុករក។ នៅពេលដែលទស្សនវិទូមួយរូបនេះលើកឡើងបែបនេះមានន័យថានៅពេលដែលលោកកាន់តែព្យាយាមមើលពីពិភពចក្រវាលនិងសិក្សាដើម្បីបង្កើតទ្រឹស្តីនានាធ្វើឱ្យលោកមានចម្ងល់កាន់តែច្រើនដែលមិនទាន់បានបកស្រាយ។ នេះអាចជាបុព្វហេតុដែលនាំឱ្យលោកហ៊ាន លើកឡើងបែបនេះ។ ក៏ប៉ុន្តែមិនមែនមានន័យថា លោកមិនយល់ មិនដឹងអ្វីសោះនោះទេ។ហើយនេះ ក៏មិនមែនជាសម្តីទម្លាក់តម្លៃរបស់លោកនោះដែរ។ ព្រោះថា ការដែលលើកឡើងបែបនេះក៏ព្រោះតែពេលខ្លះ រាល់អ្វីដែលលោកបានដឹងបានយល់បានគិតឃើញ មិនប្រាកដថា អ្នកដទៃយល់ស្របតាមគំនិតរបស់លោកនោះទេ។ អ្វីដែលលោកចេះ អ្វីដែលលោកចាំអាចនឹងមានការបកស្រាយថ្មីផ្សេងពីគំនិតរបស់លោក។ ហើយរាល់ចំណេះដឹងរបស់លោកនឹងក្លាយទៅជាប្រធានបទសម្រាប់អ្នកប្រាជ្ញជំនាន់ក្រោយយកទៅបកស្រាយទៅតាមឥរិយាបថនៃសង្គមរបស់បុគ្គលទាំងនោះ។ ពិតណាស់សូក្រាតគឺតែងតែស្វែងរកការពិតមានសុភវិនិច្ឆ័យសមហេតុផល មានសុជីវធម៌ សីលធម៌ដែលកត្តាទាំងនេះជាលក្ខណៈបញ្ជាក់ពីតម្លៃខ្លួនរបស់លោក។ លោកមានវិធីបង្រៀនយ៉ាងល្អដែលជាសិល្បៈបង្កើតគំនិតនិងការចំអកឱ្យបុគ្គលណាមួយដែលតាំងខ្លួនថាជាអ្នកចេះឬជាគតិវិញ្ញូឆ្ពោះទៅរកការទទួលស្គាល់ភាពពិតនៃ

ចំណេះដឹងរបស់ខ្លួនដែលជាសច្ចភាពជាក់ស្តែងនៃសមត្ថភាពរបស់បុគ្គលនោះ។

សូក្រាតប្រើវិធីបង្កើតគំនិតដែលមិនចេះអួតអាងហើយដឹងថាខ្លួនគ្មានចេះអ្វីសោះ។ លោកតែងចេញមុខប្រឆាំងនឹងពួកសូហ្វីសជាពួកពូកែអួតដែលចូលចិត្តយកពាក្យសំដីទៅប្រើផ្លូវខុសហើយធ្វើអាកប្បកិរិយាដូចជាអ្នកចេះដឹងច្រើន។

-ខ្ញុំអាចបង្រៀនមនុស្សនូវអ្វីៗគ្រប់យ៉ាង ដោយគ្រាន់តែបង្រៀនឱ្យពួកគេចេះគិតប៉ុណ្ណោះ

ជាការពិតណាស់មនុស្សម្នាក់ៗមិនអាចតម្រូវឬក៏ចង់ឱ្យនរណាម្នាក់ធ្វើតាមការគិតឬក៏គំនិតរបស់ខ្លួននោះទេ ព្រោះមនុស្សម្នាក់ៗតែមានចំណុចល្អ និងចំណុចអាក្រក់រៀងៗខ្លួន។ នៅក្នុងការបង្រៀន ការណែនាំការប្រៀនប្រដៅ ក្នុងទីផ្សារឬក៏សាលារៀនក្តីក្នុងសង្គមក្តី ទស្សនៈរបស់មនុស្សម្នាក់គ្រាន់តែជាគតិយល់ឃើញមួយប៉ុណ្ណោះ មិនអាចទៅបញ្ជាចិត្តមនុស្សគ្រប់គ្នាឱ្យយល់ស្របតាមបានទាំងអស់នោះទេ។

-មនុស្សខ្លាំងនិយាយពីគំនិត មនុស្សសាមញ្ញធម្មតានិយាយពីព្រឹត្តិការណ៍ មនុស្សចោលម្សៀតនិយាយដើមគេ

ទស្សនៈនេះបង្ហាញថា មនុស្សដែលមានចំណេះដឹង មានគតិបណ្ឌិតមិនចំណាយពេលវេលាឥតប្រយោជន៍នោះទេ។ ពួកគេចូលចិត្តលើកឡើង និយាយអំពីគំនិត បញ្ចេញគំនិត ទស្សនៈ និងរៀនសូត្រអំពីគំនិតរបស់អ្នកដទៃដើម្បីភាពរីកចម្រើន។ប៉ុន្តែ មនុស្សសាមញ្ញធម្មតាចូលចិត្តចំណាយពេលទៅលើព្រឹត្តិការណ៍ រឿងនេះរឿងនោះ ដែលមិនសូវមានប្រយោជន៍។ មនុស្សប្រភេទនេះចំណាយពេលតាមដានព្រឹត្តិការណ៍ ហើយជ្រួលជ្រើមតាមព្រឹត្តិការណ៍ដោយមិនបានគិតពិចារណា។ ពេលខ្លះពួកនេះជាមនុស្សតែស្តារ ដោយមិនបានថ្លឹងថ្លែងថាជារឿងមានប្រយោជន៍ឬអត់នោះទេ ដោយភាគច្រើនឃើញគេថា ថាតាមគេទាំងមិនដឹងអ្វីសោះក៏មាន។

ចំណែកមនុស្សគំនិតអន់ថយ ចូលចិត្តនិយាយដើមអ្នកដទៃ។ មនុស្សទាំងនេះរឿងនរណាក៏គាត់ដឹងដែរ ហើយពេលគាត់ដឹងហើយមាត់គាត់មិនមានគម្របនោះទេ។ ហើយមនុស្សសណ្តាននេះដឹងហើយគាត់ចូលចិត្តនិយាយចាក់ពីក្រោយខ្នង អ្នកនេះអីចេះអីចុះនិយាយពន្លើស ឬតែងរកវិធីក្នុងការនិយាយបង្ខូចឈ្មោះនរណាម្នាក់។ ពួកនេះមិនសូវនិយាយអំពីគំនិត ចែករំលែកគំនិតនោះទេ មនុស្សប្រភេទនេះតែងតែនាំអ្នកទៅរកភាពអវិជ្ជមាន។ ប្រសិនបើនៅជិតមនុស្សប្រភេទនេះពួកនេះចូលចិត្តយករឿងអ្នកដទៃមកនិយាយដោយគេដឹងរឿងគ្រប់យ៉ាង។ មួយថ្ងៃៗគឺនាំរឿងមកដល់អ្នក មិនសូវបានជាប្រយោជន៍ប៉ុន្មានទេ។កុំចំណាយពេលនឹងរឿងឥតប្រយោជន៍ ហើយកុំពូកែសន្សំរឿងរបស់អ្នកដទៃពេក តែត្រូវរៀនចែករំលែកគំនិត ស្វែងរកដំណោះស្រាយ រៀនសូត្រពីគ្នាទៅវិញទៅមក។ រៀនបើកចិត្ត បើកគំនិត រៀនសូត្របន្ថែម។

-ការពូកែឆ្ងល់គឺជាពន្លកនៃគតិបណ្ឌិត

បង្កើតទម្លាប់សួរនាំដើម្បីចង់ចេះ និងចង់ដឹងឱ្យបានច្រើននិងច្បាស់លាស់ និងគិតមុនគូរ។ ការចេះសួរនាំដើម្បីបានព័ត៌មាន

បន្ថែម ឬព័ត៌មានថ្មីៗ គឺធ្វើឱ្យយើងបានចេះដឹងកាន់តែច្រើន និងជ្រៅជ្រះ ឬយល់ដឹងពីហេតុការអ្វីមួយបានច្បាស់លាស់។ មុននឹងធ្វើអ្វីមួយ គឺយើងត្រូវគិតថាតើត្រូវធ្វើវាយ៉ាងដូចម្តេច? ធ្វើពេលណា? ធ្វើជាមួយអ្នកណា? តើវាមានផលប៉ះពាល់អ្វីខ្លះ? ហានិភ័យអ្វីខ្លះ? អាចបានផលអ្វីខ្លះជាដើម ជៀសវាងនឹកឃើញអ្វីក៏ចាប់ផ្តើមធ្វើតាមតែចិត្តចង់ តាមតែកំហឹង ឬអារម្មណ៍ជាដើម ។ យើងអាចនិយាយម្យ៉ាងទៀតថា រាល់អ្វីដែលយើងបានគិតមិនដែល" ត្រូវតែធ្វើសកម្មភាពនោះទេ តែរាល់សកម្មភាព។ បើ "ដែលយើងធ្វើយើងត្រូវតែគិតគូរជាមុន យើងអាចធ្វើបានដូចនេះ វានឹងអាចជួយឱ្យយើងមានការគិតពិចារណាបានស៊ីជម្រៅ ហើយមនុស្សដែលមានភាពនឹងធឹងមិនតក់ស្លុតច្រើន ច្រើនតែជាមនុស្សដែលមានបញ្ញាខ្ពស់ និងមានការសម្រេចបានត្រឹមត្រូវច្រើន។

-ខួរក្បាលគឺជាអ្វីៗទាំងអស់ អ្នកគិតអ្វីអ្នកនឹងទទួលបានផលនោះ

ការគិតពិតមានឥទ្ធិពលក្នុងជីវិតរបស់យើងម្នាក់ៗព្រោះការគិតគឺជាហេតុនៃទង្វើ។ អត្តចរិតនិងការប្រព្រឹត្តិគឺសុទ្ធតែសម្តែងឱ្យយើងដឹងពីចិត្តគំនិតរបស់បុគ្គលម្នាក់ៗ។ គ្មានអ្វីដែលថាមនុស្សធ្វើទៅដោយគ្មានការគិតនោះទេ។ មនុស្សធ្វើទៅដោយគិតល្អនឹងទទួលបានផលល្អ ចំណែកមនុស្សធ្វើដោយការគិតអវិជ្ជមាននឹងទទួលបានមកវិញនូវផលអវិជ្ជមានដូចគ្នា។ ការគិតមានឥទ្ធិពលលើទង្វើរបស់មនុស្ស។

-ខ្ញុំរើសយកចំណេះដឹងជាជាងទ្រព្យសម្បត្តិ ពីព្រោះទ្រព្យសម្បត្តិមិនស្ថិតស្ថេរនោះទេ

គាត់ជឿជាក់ថា វិធីដ៏ល្អបំផុតសម្រាប់ការរស់នៅ គឺត្រូវផ្តោតលើការអភិវឌ្ឍខ្លួនឯងជាជាងការខិតខំស្វែងរកទ្រព្យសម្បត្តិនិយម។ សូក្រាតបានសង្កត់ធ្ងន់ថាគឺជា "គុណធម៌" ទ្រព្យសម្បត្តិដ៏មានតម្លៃបំផុតក្នុងចំណោមទ្រព្យសម្បត្តិនានា។ លោកជាអ្នកដែលគោរពច្បាប់។ លោកចង់ឱ្យមនុស្សក្លាយជាចៅក្រមនៃខ្លួនឯង។ អាថ៌កំបាំងនៃសុភមង្គលមិនមែនកើតឡើងដោយសារតែការស្វែងរកទ្រព្យសម្បត្តិឱ្យច្រើនទេ ប៉ុន្តែ កើតឡើងដោយសារតែការចេះដាក់កំហិតខ្លួនឯងឱ្យរីករាយនឹងរបស់ដែល ខ្លួនមាន។ សូក្រាតពោលថា «ពុំមានអ្នកណាម្នាក់កាចដោយចេតនាទេ។ មនុស្សម្នាក់ៗសុទ្ធតែមានបំណងល្អ តែបើប្រែជាអាក្រក់វិញ គឺពិតជាមានបុព្វហេតុ ដូចជាបុព្វហេតុផ្ទាល់ខ្លួនឬក្រៅខ្លួន»។ ចំពោះប្លាតុងវិញយល់ថា «មនុស្សកើតមកមានអាកប្បកិរិយាខុសៗគ្នា ខ្លះល្អ ខ្លះអាក្រក់ ខ្លះស្លូត ខ្លះកាចតាមនិស្ស័យពីធម្មជាតិ»។ក្នុងតម្លៃសីលធម៌ សូក្រាត ចេញមុខប្រឆាំងនឹងពួកសូហ្វីស ជាពួកពូកែអួត ដែលចូលចិត្តយកពាក្យសំដីទៅប្រើផ្លូវខុស ហើយធ្វើអាកប្បកិរិយាដូចជាអ្នកចេះដឹងច្រើន ។

-មនុស្សដែលចង់ផ្លាស់ប្តូរពិភពលោក គួរតែផ្លាស់ប្តូរខ្លួនគេជាមុនសិន

មានមនុស្សជាច្រើនកំពុងតែគិតថា ពិភពលោកដែលពួកគេកំពុងរស់នៅសព្វថ្ងៃគឺមិនមានលក្ខណៈល្អប្រសើរឡើយហើយតែង

តែទាមទារចង់បាននូវការប្លាស់ប្ដូរប៉ុន្តែពុំសូវមាននរណាម្នាក់ចង់ប្លាស់ប្ដូរខ្លួនឯងសោះ។ បើបែបនេះតើអាចប្លាស់ប្ដូរពិភពលោកនេះបានដោយរបៀបណាបើមនុស្សម្នាក់ៗមិនសូវសូម្បីតែប្ដូរការគិតនិងទម្លាប់មិនល្អរបស់ខ្លួនផងនោះ។ ហេតុដូចនេះដើម្បីអាចប្លាស់ប្ដូរអ្វីៗគ្រប់យ៉ាងបានគឺសុទ្ធតែរផ្ដើមចេញពីការប្លាស់ប្ដូរខ្លួនឯងបន្តិចម្ដងៗដើម្បីឈានទៅរកការប្លាស់ប្ដូរពិភពលោកឱ្យមានភាពល្អប្រសើរឡើង។

-ស្គាល់ខ្លួនឯង ដោយខ្លួនឯង

ការស្គាល់ខ្លួនឯង មិនមែនជាការងាយស្រួលទេពីព្រោះថាមនុស្សម្នាក់ៗជឿទាំងខុសថាខ្លួនឯងស្គាល់ខ្លួនឯងប្រាកដណាស់។ ជំនឿនេះមិនត្រឹមត្រូវទេ ដោយសារមនុស្សម្នាក់ៗពិបាកនឹងស្គាល់ខ្លួនឯងច្បាស់លាស់ណាស់ ហើយបើចង់ស្គាល់ខ្លួនឯងឱ្យច្បាស់ ត្រូវដាក់រាងកាយខ្លួនឯងភ្ជាប់ទៅនឹងអ្នកដទៃ ពោលគឺលោកអ្នកត្រូវស្គាល់ពីតួនាទី ស្គាល់ភារកិច្ចស្គាល់កាតព្វកិច្ចរបស់ខ្លួនឯង ដែលនឹងត្រូវប្រព្រឹត្តចំពោះអ្នកដទៃ ។

-លទ្ធផលល្អ គឺត្រូវបានរិះគន់រួចហើយ

ការធ្វើអ្វីមួយដោយមិនបានឆ្លងកាត់គំនិតស្ថាបនារបស់អ្នកដទៃ ពុំសូវទទួលបានលទ្ធផលល្អនោះទេ។ ដូច្នេះលោកអ្នកគួរតែរៀនបើកចិត្តឱ្យទូលាយ ដើម្បីទទួលយកនូវគំនិតរបស់អ្នកដទៃមកពិចារណាដើម្បីឱ្យលទ្ធផលនៃការងាររបស់លោកអ្នកកាន់តែប្រសើរ។ យើងមិនត្រូវចាត់ទុកថាការរិះគន់ដើម្បីស្ថាបនាជាការបន្ទុចបង្អាក់នូវគំនិតរបស់យើងនោះទេ។

-ជីវិតគ្មានភាពឈឺចាប់ គ្មានភាពលំបាក មិនមែនជាជីវិតទេ

មានបុគ្គលជោគជ័យច្រើនណាស់នៅលើពិភពលោកនេះ ដែលសុទ្ធសឹងតែធ្លាប់ជួបប្រទះនូវភាពឈឺចាប់ និងភាពក្រលំបាក ហើយវាជាកត្តាដែលរុញច្រានឱ្យពួកគេក្លាយជាបុគ្គលជោគជ័យ។ ប្រសិនបើជីវិតរបស់ពួកគេមិនធ្លាប់បានជួបនូវរឿងរ៉ាវលំបាកៗក្នុងជីវិតនោះទេ ពួកគេក៏មិនអាចស្គាល់ច្បាស់ពីរសជាតិជីវិត និងមិនអាចស្វែងរកសុភមង្គលបានឡើយ។

-ធម្មជាតិបានផ្ដល់ឱ្យយើងនូវត្រចៀកពីរ ភ្នែកពីរ ប៉ុន្តែមានអណ្ដាតតែមួយ

យើងគួរតែស្ដាប់និងមើលឱ្យច្រើនជាងនិយាយ។ និយាយតិចហើយស្ដាប់ច្រើន។ ពិភពលោកមានសំឡេងខ្លាំងជាមួយនឹងប្រព័ន្ធផ្សព្វផ្សាយសង្គមគ្មានទីបញ្ចប់និងការញៀនទូរសព្ទនិងបច្ចេកវិទ្យា។ចំណាយពេលរីករាយក្នុងការសន្ទនាពិតប្រាកដជាមួយមនុស្សដែលអ្នកស្រលាញ់និងសូម្បីតែមនុស្សចម្លែកដែលអ្នកបានជួប។

-ចូរយឺតក្នុងការបង្កើតទំនាក់ទំនងមិត្តភាពតែចូររក្សាចំណងមិត្តភាពឱ្យរឹងមាំនិងស្ថិតស្ថេរ

នៅពេលដែលអ្នករកឃើញនរណាម្នាក់ដែលអ្នកអាចទាក់ទងនិងចែករំលែកគោលដៅជាមួយ អ្នកត្រូវប្រាកដថាអ្នកនឹងរក្សានូវចំណងមិត្តភាពនេះ។ មិត្តភាពយូរអង្វែងគឺជារឿងមួយដែលល្អបំផុតក្នុងជីវិត។ ចូរខិតខំធ្វើជាមិត្តល្អដែលចេះស្ដាប់ ចេះស្រឡាញ់ និងចេះជួយមនុស្សដែលមានន័យបំផុតចំពោះអ្នក។រស់នៅក្នុងជីវិតរបស់អ្នកឱ្យ

បានពេញលេញជារៀងរាល់ថ្ងៃដូច្នេះនៅពេលការស្លាប់បានមកដល់ មិនមែនជាអ្វី ដែលគួរឱ្យខ្លាចនោះទេ។ ចេញទៅគ្រប់ផ្នែកនៃជីវិតរបស់អ្នក។ ទោះម្នាក់ឯងប្រថុយ រីករាយ ឬលំបាកយ៉ាងណាអ្នកត្រូវហ៊ានពុះពារ។ ចូរកុំខ្លាចអ្វីដែលអ្នកជៀសមិនរួច។ រស់នៅក្នុងជីវិតដែលពិតចំពោះអ្នកហើយនឹងធ្វើឱ្យអ្នកសប្បាយចិត្តជាងពេលមុនៗ។

-សូមផ្តល់ឱ្យខ្ញុំនូវភាពស្រស់ស្អាតនៃព្រលឹងខាងក្នុង

សូមឱ្យព្រលឹងខាងក្នុងនិងព្រលឹងខាងក្រៅក្លាយជាព្រលឹងតែមួយ។ ចំណាយពេលផ្តោតអារម្មណ៍ លើខ្លួនឯង។ សុភមង្គលចាប់ផ្តើមនៅខាងក្នុង។ ប្រសិនបើអ្នកវេទនាអំពីអារម្មណ៍របស់អ្នកចំពោះខ្លួនអ្នកវានឹងស្តែងចេញឱ្យអ្នកដទៃបានដឹង។ បង្កើតអាកប្បកិរិយាប្រកបដោយសេចក្តីស្រឡាញ់ចំពោះខ្លួនអ្នកនិងមានមោទនភាពចំពោះអ្វីដែលអ្នកកំពុងធ្វើ។ កុំភ្លេចថាអ្នកខ្លាំងប៉ុណ្ណា ហើយបញ្ជាក់ប្រាប់ខ្លួនអ្នកថាអ្នកសំខាន់។ មនុស្សគ្រប់គ្នាកំពុងប្រឈមមុខនឹងការប្រយុទ្ធផ្ទាល់ខ្លួននៅខាងក្នុងសូម្បីតែមនុស្សដែលទទួលបានជោគជ័យបំផុតនៅលើពិភពលោកក្តី។

-ត្រូវចាំថាលក្ខខណ្ឌនៃមនុស្សគឺមិនអចិន្ត្រៃយ៍

ដូចនេះអ្នកមិនត្រូវរីករាយខ្លាំងនឹងសំណាងល្អ ហើយមើលងាយសំណាងអាក្រក់ឡើយ។ អ្វីៗទាំងអស់នៅក្នុងជីវិតគឺមានលក្ខណៈបណ្តោះអាសន្នទាំងល្អនិងអាក្រក់។ ចងចាំថានៅពេលមានរឿងអាក្រក់អ្នកតែងតែអាចរកផ្លូវចេញនិងសម្រេចគោលដៅរបស់អ្នក។ នៅពេលដែលអ្វីៗល្អសូមកុំភ្លេចខ្លួន មាន អំណួតរហូតភ្លេចការងារកាលពីជំហានទីមួយ ព្រោះជំហានទីមួយជាជំហាននាំអ្នកឱ្យមកដល់ចំណុចនេះ។

-មនុស្សឆ្លាតរៀនពីរឿងគ្រប់យ៉ាង និងមនុស្សគ្រប់គ្នា

មនុស្សធម្មតាតែងរៀនពីបទពិសោធន៍របស់ពួកគេ ហើយមនុស្សល្ងីល្ងើតែងដឹងចម្លើយទាំងអស់។ការរៀនសូត្រគឺជាគន្លឹះឆ្ពោះទៅរកភាពជោគជ័យក្នុងជីវិត។ កុំបោះបង់ការសិក្សាព្រោះការសិក្សាធ្វើឱ្យអ្នកមានផាសុកភាពក្នុងជីវិត។ អភិវឌ្ឍទម្លាប់ឱ្យក្លាយជាអ្នកចូលចិត្តរៀនហើយជីវិតរបស់អ្នកនឹងទទួលបានអត្ថន័យថ្មី។ រក្សាការចង់ដឹងចង់ឃើញឱ្យដូចកាលពីកុមារភាពរបស់អ្នក ហើយអ្នកនឹងទទួលបានរង្វាន់នៅគ្រប់ទិដ្ឋភាពក្នុងជីវិតរបស់អ្នក។

-ខ្ញុំគ្រាន់តែដឹងថាខ្ញុំមិនដឹងអ្វីទាំងអស់

តាមរយៈនេះគាត់ចង់មានន័យថាភាពល្ងង់ខ្លៅរបស់យើងអំពីពិភពលោកនិងអំពីខ្លួនយើងគឺធំជាងអ្វីដែលយើងដឹងហើយវាសំខាន់ណាស់ដែលត្រូវស្គាល់ភាពល្ងង់ខ្លៅរបស់យើងដើម្បីចាប់ផ្តើមរៀន។

សូក្រាតក៏បានជឿជាក់ផងដែរថាចំណេះដឹងសេចក្តីស្រឡាញ់នៃចំណេះដឹងនាំឱ្យមានជីវិតត្រឹមត្រូវនិងល្អខណៈដែលភាពល្ងង់ខ្លៅនាំមកនូវអាកប្បកិរិយាអាក្រក់។

-គុណធម៌គឺជាចំណេះដឹង ចំណែកឯគុណវិបត្តិគឺជាភាពល្ងង់ខ្លៅ

សូក្រាតពោលថា មិនមានអ្នកណាម្នាក់កាចដោយចេតនានោះទេ។ មនុស្សម្នាក់ៗសុទ្ធតែមានបំណងល្អ តែបើប្រែជាអាក្រក់វិញគឺពិតជាមានបុព្វហេតុ ដូចជាបុព្វហេតុផ្ទាល់ខ្លួនឬក្រៅខ្លួន តែចំពោះប្លាតុងវិញយល់ថាមនុស្សកើតមកមានអាកប្បកិរិយាខុសគ្នា ខ្លះល្អខ្លះអាក្រក់ ខ្លះស្លូតខ្លះកាចតាមនិស្ស័យពីធម្មជាតិ។ ក្នុងតម្លៃសីលធម៌សូក្រាត ចេញមុខប្រឆាំងនឹងពួកសូហ្វីសជាពួកពូកែអួត ដែលចូលចិត្តយកពាក្យសម្តីទៅប្រើផ្លូវខុស ហើយធ្វើអាកប្បកិរិយាដូចជាអ្នកចេះដឹងច្រើន។ សូក្រាតជាមនុស្សថ្មី ចំឡែកដែលបានក្លាយជាទស្សនវិទូគំរូមួយរូប សម្រាប់មនុស្សជំនាន់ក្រោយ ។ គេតែនិយាយថា សូក្រាត ជាមនុស្សនៃទីក្រុងអាតែន ដែលមានរូបអាក្រក់ ហើយល្អជាងគេបំផុត។

សូក្រាតនិយាយទៅកាន់ប្រជារាស្ត្រក្រុងអាថែនទាំងឡាយថាខ្ញុំពេញចិត្ត ហើយខ្ញុំ ប្រសិនបើខ្ញុំស្លាប់ គឺ !ស្រឡាញ់អ្នកណាស់ ព្រលឹងរបស់ខ្ញុំពិតជាមិនស្លាប់ឡើយ។ ព្រលឹងនិងចិត្តរបស់ខ្ញុំនៅតែតាមថែរក្សាអ្នក ពន្យល់អ្នក ប្រដៅទូន្មានអ្នក។ ជាពិសេសព្រលឹងខ្ញុំនៅតែក្រើនរំលឹកដល់អ្នកនូវ មេរៀនទស្សនវិជ្ជាដែលខ្ញុំធ្លាប់និយាយបង្ហាត់អ្នក។ សូមអ្នកទាំងអស់កុំតក់ស្លុតនឹងសេចក្តីស្លាប់របស់ខ្ញុំឱ្យសោះ ។ ខ្ញុំស្លាប់តែរូបទេ ចំណែកព្រលឹង ចិត្ត និងកេរ្តិ៍ឈ្មោះរបស់ខ្ញុំ មិនបានស្លាប់ឡើយ គឺខ្ញុំស្លាប់ទាំងញញឹម។ ជាពិសេសបើខ្ញុំស្លាប់ទៅ សូមអ្នករាល់គ្នាខិតខំហាត់ពត់ចិត្តឱ្យមានយុត្តិធម៌ ឱ្យមានសីលធម៌ និងឱ្យមានមនុស្សធម៌គ្រប់វេលា ដើម្បីបម្រើទស្សនៈរបស់លោកសូក្រាត ចំណោះដែលសំខាន់ជាងគេ គឺការស្គាល់ពីខ្លួនឯង។ ការស្គាល់ខ្លួនឯង ការត្រិះរិះពិចារណា ការចេះចោទសួរលើគ្រប់បញ្ហា ធ្វើឱ្យមនុស្សចេះទាញហេតុនិងផលដោយខ្លួនឯង។ កុំចេះតែជឿតាមគេ កុំជឿងប់ងល់ទៅលើការបង្រៀនរបស់សាសនា ឬការបង្គាប់បញ្ជារបស់អជ្ញាធរ។ សូក្រាតខ្លួនឯងផ្ទាល់ធ្លាប់បានបដិសេធមិនធ្វើតាមបញ្ជារបស់អាជ្ញាធរក្រុងអាថែន ដែលនេះជាទម្រង់មួយនៃអំពើបះបោរដោយអហិង្សា។ ក៏ប៉ុន្តែ ក្នុងពេលជាមួយគ្នា ទាក់ទងនឹងបញ្ហានេះ គេក៏ហាក់ដូចជាឃើញចំណុចផ្ទុយគ្នាមួយផងដែរក្នុងជីវិតរបស់លោកសូក្រាត ពីព្រោះថានៅពេលដែលលោកត្រូវបានគេកាត់ទោសប្រហារជីវិត សូក្រាតបានបដិសេធមិនរត់គេចខ្លួន ហើយដាក់ចិត្តដាក់កាយទទួលយកសេចក្តីស្លាប់ បើទោះបីជាដឹងថា ការកាត់ទោសលើរូបលោកនេះគឺជារឿងអយុត្តិធម៌ក៏ដោយ។

សូក្រាតនិយាយថា៖

-លើលោកនេះរបស់ល្អបំផុតគឺចំណេះដឹងហើយរបស់ដែលអាក្រក់បំផុតនោះគឺអវិជ្ជា។

-មានប្រពន្ធល្អអ្នកនឹងសប្បាយចិត្តតែប្រសិនបើមានប្រពន្ធមិនកើតវិញអ្នកនឹងក្លាយជាទស្សនវិទូ។

-ការយល់សំណួរគឺស្មើនឹងការដឹងចម្លើយពាក់កណ្តាលរួចទៅហើយ។

-អាថ៌កំបាំងនៃការប្លាស់ប្តូរគឺត្រូវផ្តល់ថាមពលទាំងអស់របស់អ្នកទៅលើការបង្កើតអ្វីដែលថ្មីមិនមែនទៅជំទាស់នឹងរបស់ចាស់ដែលមានស្រាប់ទេ។

ប្រទេសរបស់អ្នកទៅថ្ងៃមុខ៉ី។ បើស្រឡាញ់ខ្ញុំ សូមអ្នកស្តាប់ពាក្យខ្ញុំឱ្យច្បាស់ហើយបើស្តាប់... ច្បាស់ហើយត្រូវធ្វើតាមប្រសិនបើអ្នកអាច...។

**២-ប្លាតុង**( Platon : ៤២៨-៣៤៧ មុន គ.ស. )

**២.១-ប្រវត្តិរបស់ប្លាតុង**

លោក ប្លាតុង កើតនៅឆ្នាំ៤២៨ និង ស្លាប់ទៅវិញនៅឆ្នាំ៣៤៧ មុន គ្រិស្តសករាជ។

ប្លាតុង កើតនៅក្នុងបុរីអាថែន និងស្លាប់ទៅវិញក៏ទីនោះដែរ។ ឈ្មោះដើមរបស់លោកគឺ អារីស្តូក្លេស ( Aristocles) ប៉ុន្តែដោយសារលោកមានមាឌធំ ទើបគេហៅថា ប្លាតុង ដែលតាមភាសាក្រិក មានន័យថា ធំសម្បើម។ លោកសិក្សានៅអាថែន តាំងតែនៅពីតូចម្ល៉េះ លុះអាយុបាន២០ឆ្នាំ លោកក៏បានក្លាយជាសិស្សរបស់ សូក្រាត។

ឪពុករបស់លោក ប្លាតុង ឈ្មោះអារីស្តូន ( Ariston) ជាម្ចាស់ទាសករនៅអេហ្សីន ( Agean) ដែលមានកំណើតក្នុងរាជវង្សកូដ (Codre)ដែលត្រូវជារាជវង្សចុងក្រោយនៅអាថែន។ ម្តាយរបស់លោក ឈ្មោះ ពៀរីហ្សូន (Peritione)កើតក្នុងត្រកូលអ្នកបង្កើតច្បាប់។

ក្រោយគ្រូរបស់ខ្លួន គឺលោក សូក្រាត ត្រូវគេកាត់ទោសប្រហារជីវិតទៅ ប្លាតុង បាននិរទេសខ្លួនចាញពីអាថែន ទៅរស់នៅក្រុងមេហ្គា ក្នុងតំបន់ភាគខាងត្បូង នៃប្រទេសអ៊ីតាលីក្នុងឆ្នាំ៣៨៨ មុនគ្រិស្តសករាជ។ នៅទីនោះ ប្លាតុង ត្រូវបានព្រះអង្គដេនីសទី១ និងឱយ៉ុងដែលត្រូវជាបងថ្លៃរបស់ព្រះអង្គដេនីស ចាប់ខ្លួនយកទៅឃុំ ដោយចោទប្រកាន់ថា ប្លាតុងបង្កឱ្យមានឥទ្ធិពលអាក្រក់ដល់នយោបាយពួកគេ។

ក្នុងរង្វង់ឆ្នាំ៣៨៧ មុនគ្រិស្តសករាជ គឺពេលដែលលោកប្លាតុង មានអាយុ៤០ឆ្នាំ លោកបានវិល

ត្រឡប់មកដល់ក្រុងអាថែនវិញ និងបង្កើតសាកលវិទ្យាល័យទស្សនវិជ្ជា នៅក្រៅទីក្រុង ហើយ

សាកលវិទ្យាល័យនោះប្រមូលផ្តុំទៅដោយក្រុមអ្នកខ្លាំងរបស់ក្រិកប្រហែល១០នាក់ ឈ្មោះថា Acedmus។ ពេលធ្វើការក្នុងសាកលវិទ្យាល័យដែលស្ថិតនៅកណ្តាលវាលនេះ ប្លាតុងបង្រៀនសិស្សជាច្រើន ដែលជាពួកមកពីពិភពក្រិកទាំងមូល( ក្នុងនោះក៏មានសិស្សប្រហែល១០នាក់ទៀត មកពីប្រទេសផ្សេង )។

មានការកត់ត្រាភាគច្រើននៃសំណេររបស់ប្លាតុង ជាពិសេសសំណេរឈ្មោះ Later dialogues ត្រូវបានយកទៅធ្វើជាឯកសារក្នុងការបង្រៀនសិស្សមុនគេ។ សាកលវិទ្យាល័យរបស់ប្លាតុង បានរកឃើញរបកគំហើយថ្មីៗច្រើនជាងការបង្រៀនរបស់លោកសូក្រាតដែលជាគ្រូរបស់ប្លាតុងទៅទៀត។ នេះក៏ព្រោះតែសូក្រាតមិនដែលបង្កើតសាលាហើយក៏មិនដែលរៀបចំការបង្រៀនល្អដូចនៅសាកលវិទ្យាល័យ របស់

ប្លាតុងដែរ។

ប្លាតុងក៏ជាអ្នកនយោបាយម្នាក់ដែរក្នុងចំណោមអ្នកយោបាយទាំងឡាយ។ចំណង់ចំណូលចិត្តរបស់គាត់គឺផ្តោតទៅលើរដ្ឋនយោបាយនិងច្បាប់ ដែលធាតុទាំងនេះ ជាកត្តាជុំរុញឱ្យគាត់ចាប់អារម្មណ៍ទៅលើប្រជា

ជន ចង់ឱ្យប្រជាជនមានភាពប្រសើរសម្បូរសប្បាយនិងសុភមង្គលព្រមទាំង ធ្វើឱ្យសង្គមទាំងមូលស្ថិតក្នុងស្ថេរភាពទាំងផ្នែកសេដ្ឋកិច្ចទាំងផ្នែកនយោបាយ។ល។ ប្លាតុងព្យាយាមដោះស្រាយរាល់បញ្ហាទាំងឡាយដែលគេតែងតែជួបប្រទះក្នុងរដ្ឋ ក្នុងសង្គម ក៏ដូចជាក្នុងជីវភាពរស់នៅផងដែរដោយប្រើវិធីមួយ គឺបង្កើតរដ្ឋគំរូ ដែលមានមេដឹកនាំប្រកបដោយគំនិតស្នេហាជាតិមានសុភវិនិច្ឆ័យ។ រដ្ឋគំរូនោះលោកប្លាតុងបានធ្វើការប្រៀបធៀបរវាងទម្រង់គ្រប់គ្រងនយោបាយ ដែលមានលក្ខណៈមិនគ្រប់គ្រាន់ជាច្រើន ដូចជាទម្រង់សក្តិភូមិ ( Timocracy)អណាធិបតេយ្យ ( Oligarchy)និងប្រជាធិបតេយ្យ (Democracy)។

ទម្រង់ទាំង៣នេះ គាត់ឱ្យឈ្មោះថាជាទម្រង់អាក្រក់ គ្មានស្ថេរភាពហើយទីបំផុតក្លាយទៅជា

ទុជនាធិបតេយ្យ(Tyranny)។ អត្ថន័យរដ្ឋគំរូរបស់លោកប្លាតុង បានបង្ហាញឱ្យឃើញនូវភាពយុត្តិធម៌ ក្នុងការដឹកនាំដោយជ្រើសរើសយកទស្សនវិទូដ៏វៃឆ្លាតពីព្រោះចំណេះដឹងពិតប្រាកដនិងចិត្តសាងកុសលចំពោះអ្នកដទៃមានតែនៅក្នុងជំពូកមនុស្សប្រភេទនេះទេដែលបានធ្វើសម្បទាន។ តួអង្គដែលតំណាងឱ្យរដ្ឋគំរូរបស់លោកប្លាតុង គឺអ្នកធ្វើការក្នុង Polis(ក្រុងក្រិចបុរាណ)[2]។

### ២.២-របៀបដឹកនាំ៥ប្រភេទនិងមេរៀនជីវិត៣យ៉ាងរបស់ប្លាតុង

**-អភិជនាធិបតេយ្យ**(Aristoceacy)

របបនេះគឺការគ្រប់គ្រងមួយដែលដឹកនាំដោយមនុស្សដែលមានការអប់រំល្អដែលមានការគិតពិចារណាដោយប្រើប្រាស់ហេតុផលត្រឹមត្រូវ។ ក្នុងទ្រឹស្តីរបស់ប្លាតុង មនុស្សក្នុងវណ្ណៈអភិជនមានសមតុលរវាងចំណង់ភាពតក្ក និងផ្លូវសាសនា។ សង្គមមួយនេះជាទូទៅដឹកនាំដោយមនុស្សដែលមានទស្សនវិជ្ជាខ្ពង់ខ្ពស់ ដែលចូលចិត្តចំណេះដឹង មានភាពឆ្លាតវៃ និងចង់រស់នៅប្រកបដោយជីវិតសាមញ្ញ។

**-របបសក្តិភូមិ**(Timocracy)

សង្គមមួយនេះកាត់បន្ថយគុណតម្លៃនៃភាពតក្ក ហើយផ្តោតទៅលើសារៈសំខាន់នៃចំណង់អំណាច និងជឿលើសាសនា។ ជាទូទៅមនុស្សដែលមានចំណេះដឹង គុណធម៌មិនត្រូវគេឱ្យតម្លៃ ហើយមនុស្ស
ម្នាក់ៗខិតខំដើម្បីតែអំណាចខ្លួនឯងដោយពួកគេមានលក្ខណៈកាចសាហាវ ចូលចិត្តធ្វើសង្គ្រាម។ ក្នុងសង្គមមួយនេះ ពលរដ្ឋម្នាក់ៗផ្តោតសំខាន់ទៅលើមាសប្រាក់ ការកម្សាន្ត ជាជាងការអប់រំ។

**-គណាធិបតេយ្យ**(Oligarchy)

ក្នុងសង្គមមួយនេះ ទ្រព្យសម្បត្តិត្រូវគេចាត់ទុកថាជាគ្រឿងជំរុញចិត្តដ៏សំខាន់បំផុតដោយពួកគេឱ្យតម្លៃទៅលើអ្នកមានទ្រព្យសម្បត្តិ និងខ្ពើមរអើមអ្នកក្រីក្រ។ បើទោះបីជាសង្គមមួយនេះមានការខំប្រឹងប្រែងធ្វើការងារប៉ុន្តែពួកគេមានភាពអាត្មានិយម ដោយគ្រប់សកម្មភាពរបស់ពួកគេគឺដើម្បីតែប្រយោជន៍

[2]https://bookmemoryblog.files.wordpress.com/2014/07/259-e19e95e19f92e19e9be19eb6e19e8fe19ebc1.pdf

ផ្ទាល់ខ្លួន។ ការឱ្យតម្លៃទៅលើទ្រព្យសម្បត្តិកាន់តែច្រើន ធ្វើឱ្យមនុស្សបាត់បង់គុណធម៌។

**-ប្រជាធិបតេយ្យ**( Democracy )

លោកប្លាតុងមានជំនឿថារបបគ្រប់គ្រងគឺផ្តោតសំខាន់ទៅលើសេរីភាព។ លោកមានជំនឿថាតួនាទីរបស់អជ្ញាធរ និងច្បាប់ទាំងអស់គឺដើម្បីបម្រើសង្គម។ មនុស្សមានសិទ្ធិសេរីភាពក្នុងការធ្វើអ្វីដែលខ្លួនចង់ធ្វើដោយមិនចាំបាច់ឱនលំទោនចំពោះនរណាម្នាក់ឡើយ។ក្នុងសង្គមមួយនេះ ប្រជាធិបតេយ្យគឺផ្តល់សេរីភាព
ទៅដល់មនុស្សគ្រប់ៗ គ្នាស្មើៗគ្នាដោយមិនរើសអើង។

**-របបផ្តាច់ការ/ទុជនាធិតេយ្យ**

( Tyranny )

បើយោងតាមទស្សនរបស់ប្លាតុង របបនេះបែងចែកជាបំណែកតូចៗដោយមានអ្នកគ្រប់គ្រងដោយជនផ្តាច់ការ ចូលចិត្តប្រើអំពើហិង្សា គ្មានតម្លាភាព។ សង្គមមួយនេះគឺបែងចែកហើយរបបគ្រប់គ្រងមួយនេះគឺចង់បានសេរីភាពប៉ុន្តែខ្វះច្បាប់គ្រប់គ្រង។ របបមួយនេះគឺគ្មានសីលធម៌ អាត្មានិយម និងគ្មាន
យុត្តិធម៌។

អ្នកអាចប្រៀបធៀបរបបគ្រប់គ្រងទាំងនេះទៅនឹងបរិយាកាសនយោបាយសព្វថ្ងៃនេះ។ អ្នកប្រាកដជាគិតថាការគ្រប់គ្រងបែបប្រជាធិបតេយ្យជាទម្រង់ដែលល្អជាងគេ។

មនុស្សម្នាក់ៗចង់បានទ្រព្យសម្បត្តិ ប៉ុន្តែអ្នកត្រូវសួរខ្លួនរបស់អ្នកថាវាមិនមែនជាអ្វីដែលសំខាន់បំផុតសម្រាប់ជីវិតរបស់អ្នកនោះទេ។ អ្នកត្រូវទុកចន្លោះសម្រាប់រឿងផ្សេងៗក្នុងជីវិតរបស់អ្នក ពេញចិត្តនឹងពិភពលោកដែលនៅជុំវិញអ្នក។ អ្នកអាចរៀននូវមេរៀនដ៏មានតម្លៃ៣យ៉ាងរបស់ប្លាតុងៈ

**-រៀនផ្តល់អាទិភាពដល់រឿងត្រឹមត្រូវ**

មេរៀនដែលសំខាន់ដែលអ្នកត្រូវរៀននោះគឺអ្នកត្រូវស្វែងរកតុល្យភាពនូវរឿងដែលសំខាន់សម្រាប់អ្នក។ អ្នកអាចនឹងផុងខ្លួនទៅនឹងសកម្មភាពរាល់ថ្ងៃរបស់អ្នក និងមហិច្ឆតារបស់អ្នក។ អ្នកត្រូវប្រឹងធ្វើការដើម្បីរកប្រាក់ ប៉ុន្តែអ្នកត្រូវចាំថាលុយកាក់តែមួយមុខមិនមែនជារឿងចាំបាច់បំផុតនោះទេសម្រាប់អ្នក។ ដូចនេះ អ្នកត្រូវចេះឱ្យតម្លៃ និងផ្តល់អាទិភាពទៅរឿងដែលត្រឹមត្រូវសម្រាប់ជីវិតរបស់អ្នកផ្សេងៗទៀត។

**-ចំណេះដឹងគឺសំខាន់**

កុំឈប់រៀន ត្រូវស្វែងរកចំណេះដឹង។ មិនមែនអ្នកឈប់រៀននៅសាលា នោះអ្នកថាអ្នកនឹងមិនបន្តស្វែងរកចំណេះដឹងផ្សេងទៀតនោះទេ ហើយក៏មិនមែនជាការបញ្ចប់ការសិក្សារៀនសូត្ររបស់អ្នកនោះ
ដែរ។ អ្នកត្រូវរៀនជំនាញថ្មី រៀនភាសា និងរៀនអំពីអ្វីគ្រប់យ៉ាងដែលអ្នកជួបរៀងរាល់ថ្ងៃ។

**-ភ្ជាប់ខ្លួនអ្នកទៅកាន់អ្វីៗដែលនៅជុំវិញអ្នក**

អ្នកអាចភ្ជាប់ព្រលឹងរបស់អ្នកទៅកាន់ពិភពជុំវិញខ្លួនអ្នកដោយការនៅស្ងៀមស្ងាត់ម្នាក់ឯង ធ្វើលំហាត់ប្រាណ និងចំណាយពេលជាមួយធម្មជាតិ។

**២.៣-ទស្សនៈសំខាន់ៗរបស់ប្លាតុង**

ប្លាតុងបានបន្សល់ទុកនូវស្នាដៃជាសំណេរគិតជាសរុបចំនួន៣៦ ដោយក្នុងនោះ រួមមានទាំង

សំណេរជាសៀវភៅ និងជាសំបុត្រ។ សៀវភៅភាគច្រើនលើសលុបរបស់ប្លាតុង គឺសរសេរក្នុងទម្រង់ជាកិច្ចសន្ទនា ហើយក្នុងកិច្ចសន្ទនាភាគច្រើន គឺមានសូក្រាតជាតួអង្គសំខាន់។

ជាទូទៅ សំណេរជាកិច្ចសន្ទនារបស់ប្លាតុងត្រូវបានគេបែងចែកចេញជាច្រើនក្រុម អាស្រ័យទៅតាមប្រធានបទ រួមមាន កិច្ចសន្ទនាដែលផ្តោតសំខាន់ទៅលើគោលគំនិតរបស់សូក្រាត កិច្ចសន្ទនាដែលផ្តោតទៅលើគោលគំនិតផ្ទាល់ខ្លួនរបស់ប្លាតុង ទាក់ទងទៅនឹងប្រធានបទដែលសូក្រាតធ្លាប់បង្រៀន ព្រមទាំងកិច្ចសន្ទនាទៅលើប្រធានបទផ្សេងៗជាច្រើនទៀត ដែលរាប់ចាប់តាំងពីការត្រិះរិះពិចារណា ស្តីពីទស្សនទាននៃ "សេចក្តីស្នេហា" អំពី "សុភមង្គល" អំពី "ព្រលឹងវិញ្ញាណ" រហូតទៅដល់ការជជែកពីទ្រឹស្តី
ធរណីមាត្ររបស់ពីតាហ្គ័រ ជាដើម។

នៅក្នុងចំណោមស្នាដៃអស់ទាំងនេះ ស្នាដៃដែលត្រូវបានគេស្គាល់ច្រើនជាងគេ ហើយដែលត្រូវបានគេលើកមកបង្រៀននៅតាមបណ្តាប្រទេសជាច្រើនរហូតមកទល់នឹងពេលបច្ចុប្បន្ននេះ គឺសៀវភៅដែលមានចំណងជើងជាភាសាបារាំងថា « La République » ហើយដែលអ្នកខ្លះបកប្រែជាភាសាខ្មែរថា "សាធារណរដ្ឋ" ក៏ប៉ុន្តែ តាមការពិតគួរតែត្រូវបកប្រែថា "ស្តីអំពីការគ្រប់គ្រងរដ្ឋ" ទើបត្រូវទៅតាម
អត្ថន័យ។ សៀវភៅ "ស្តីអំពីការគ្រប់គ្រងរដ្ឋ" នេះត្រូវបានគេចាត់ទុកថាជាស្នាដៃដំបូងបង្អស់នៅក្នុងប្រវត្តិនៃទស្សនវិជ្ជានយោបាយ។

តាមទស្សនៈរបស់ប្លាតុង ដូចដែលមានសរសេរនៅក្នុងសៀវភៅ "ស្តីអំពីការគ្រប់គ្រងរដ្ឋ" រដ្ឋមួយអាចគ្រប់គ្រងបានល្អ ឬមិនល្អ វាអាស្រ័យលើលក្ខណសម្បត្តិរបស់មេដឹកនាំ ជាជាងលើទម្រង់នៃរបប
នយោបាយ។ ឬអាចនិយាយបានម្យ៉ាងទៀតថា រដ្ឋដែលគ្រប់គ្រងដោយរបបផ្តាច់ការ តែមានមេដឹកនាំប្រកបដោយគតិបណ្ឌិត វាប្រសើរជាងរដ្ឋដែលគ្រប់គ្រងដោយរបបប្រជាធិបតេយ្យតែមានមេដឹកនាំ
អសមត្ថភាព។

ប្លាតុងបានធ្វើការត្រិះរិះពិចារណាដោយប្រៀបធៀបគ្នា រវាងព្រលឹងរបស់ជាតិ និង បុគ្គល ដោយលោកធ្វើការបែងចែកជាឋានានុក្រមជាបីថ្នាក់ពីលើមកក្រោម គឺបុគ្គលមានក្បាលតំណាងឱ្យ
វិចារណញ្ញាណ បេះដូងដែលតំណាងឱ្យមនោសញ្ចេតនា ឬអារម្មណ៍ (កំហឹង ក្តីស្រឡាញ់ មោទនភាព និងភាពក្លាហាន...) និងក្រពះដែលតំណាងឱ្យចំណង់ផ្លូវកាយឬតណ្ហា។ ដូចគ្នាដែរ រដ្ឋ មានប្រមុខដឹកនាំជាក្បាល កងទ័ពជាបេះដូង និងរាស្ត្រជាក្រពះ។ យោងតាមប្លាតុង បុគ្គលត្រូវយកវិចារណញ្ញាណធ្វើជាធំ គឺធំលើសមនោសញ្ចេតនា និងតណ្ហា ហើយដូចគ្នាដែរ ប្រមុខដឹកនាំរដ្ឋត្រូវមានអំណាចធំជាងគេគ្រួតត្រាលើមន្ត្រី និងរាស្ត្រ ក៏ប៉ុន្តែ បុគ្គលដែលជាប្រមុខដឹកនាំរដ្ឋនេះត្រូវមានលក្ខណៈសម្បត្តិដ៏ចាំបាច់មួយ គឺត្រូវតែជាបុគ្គលដែលយកវិចារណញ្ញាណជាធំ និងជាមេដឹកនាំប្រកបដោយគតិបណ្ឌិត។

នៅក្នុងសៀវភៅ "ស្តីអំពីការគ្រប់គ្រងរដ្ឋ" ប្លាតុងសរសេរថា រដ្ឋដែលល្អបំផុត គឺរដ្ឋដែលមាន
មេដឹកនាំជាទស្សនវិទូ ឬ "ស្តេចទស្សនវិទូ" ពោលគឺ គេមានជម្រើសពីរ ឬមួយ ត្រូវឱ្យទស្សនវិទូឡើងធ្វើជាមេដឹកនាំ ឬមួយត្រូវឱ្យអ្នកត្រូវធ្វើជាមេដឹកនាំខិតខំស្វែងរកចំណេះដឹងជាទស្សនវិទូ។
គោលគំនិតបែបនេះរបស់ប្លាតុង គឺវាផ្សារភ្ជាប់ទៅនឹងបទពិសោធន៍នៅក្នុងជីវិតផ្ទាល់ខ្លួនរបស់លោក។ ស្ទើរតែពេញក្នុងមួយជីវិតរបស់លោក ប្លាតុងបានកើត ធំដឹងក្តី និងរស់នៅ ក្នុងពេលដែលក្រិកកំពុងឆ្លងកាត់នូវកលយុគនយោបាយដ៏ធ្ងន់ធ្ងរ ទាំងនៅក្នុងអំឡុងសង្គ្រាម រវាងអាថែន និងស្ប៉ាត (សង្គ្រាមប៉េឡូប៉ូនែស) និងវិបត្តិនយោបាយនៅក្រោយសង្គ្រាម រហូតក្រោយមកនាំទៅរកការដួលរលំនៃអាណាចក្រក្រិកទាំងមូល។ នៅក្នុងអំឡុងពេលនោះ ប្លាតុងបានសង្កេតឃើញ និងឆ្លងកាត់នូវរឿងរ៉ាវជាច្រើន ដែលធ្វើឱ្យលោកមានការខកចិត្តចំពោះរបបដឹកនាំតាមបែបប្រជាធិបតេយ្យ។ គេមិនត្រូវភ្លេចទេថា នៅពេលនោះ អាថែនគ្រប់គ្រងដោយរបបប្រជាធិបតេយ្យដោយផ្ទាល់ ពោលគឺ ប្រជាជនដែលគ្រប់អាយុជានីតិជនចូលរួមដោយផ្ទាល់នៅក្នុងនយោបាយ តាមរយៈសភាអាថែន។ សភាប្រជាធិបតេយ្យនេះហើយ ដែលសម្រេចដាក់ទោសប្រហារជីវិតសូក្រាត ហើយដែលប្លាតុងយល់ថាជារឿងដ៏អយុត្តិធម៌បំផុត។

លើសពីនេះទៅទៀត ប្លាតុងដែលជាកូនចៅនៃត្រកូលអ្នកមានវណ្ណៈខ្ពង់ខ្ពស់ មានខ្សែបណ្តាញ និងស្គាល់អ្នកនយោបាយច្រើន ក៏បានសង្កេតឃើញផងដែរថា អ្នកនយោបាយអាថែនស្ទើរតែទាំងអស់នៅពេលនោះ ធ្វើអ្វីៗដើម្បីប្រយោជន៍ផ្ទាល់ខ្លួន និងប្រយោជន៍បក្សពួកច្រើនជាងប្រយោជន៍ប្រជាជន ហើយនយោបាយដែលពួកគេដាក់ចេញ គឺភាគច្រើនមានគោលដៅបន្តរក្សាអំណាច ជាជាងបម្រើផលប្រយោជន៍ពលរដ្ឋដែលជាម្ចាស់អំណាច។

បើយោងតាមប្លាតុង ឫសគល់នៃបញ្ហារបស់អាថែននេះ គឺរបបប្រជាធិបតេយ្យដោយផ្ទាល់ ដែល
ផ្តល់អំណាចទៅដល់ពលរដ្ឋគ្រប់រូប គ្រប់មជ្ឈដ្ឋាន ទាំងអ្នកចេះដឹងច្រើន អ្នកចេះដឹងតិច និងអ្នកគ្មានចំណេះដឹង ហើយអ្នកដែលគ្មានចំណេះដឹង ឬមានចំណេះដែរតែមិនត្រូវជំនាញនយោបាយ គឺងាយនឹងជឿទៅតាមការឃោសនាប្រជាភិថុតនៃមន្ត្រីរដ្ឋាភិបាល និងពួកអ្នកមានវណ្ណៈខ្ពង់ខ្ពស់។

តាមគោលគំនិតរបស់ប្លាតុង សង្គមមួយ ឬរដ្ឋមួយ គួរតែត្រូវធ្វើការបែងចែកមុខងារគ្នា ទៅតាមជំនាញ។ អ្នកពូកែខាងកាត់ខោអាវត្រូវធ្វើជាជាងកាត់ដេរ។ អ្នកចេះព្យាបាលជំងឺត្រូវធ្វើជាគ្រូពេទ្យ។ អ្នកពូកែច្បាំង ត្រូវធ្វើជាទាហាន។ល។ និង។ល។ នៅពីលើកំពូលបំផុត តួនាទីជាមេដឹកនាំរដ្ឋ ត្រូវប្រគល់ទៅឱ្យទស្សនវិទូ។

ប្លាតុងយល់ឃើញថា ទស្សនវិទូជាមេដឹកនាំល្អ ពីព្រោះ ទស្សនវិទូជាអ្នកដែលមានគតិបណ្ឌិត ហើយជាពិសេស គឺជាអ្នកដែលមិនស្រឡាញ់អំណាច។ ដូច្នេះ នៅពេលដែលទស្សនវិទូកាន់អំណាច គេយកអំណាចនេះទៅ

ប្រើ ដើម្បីធ្វើអ្វីៗដែលជាប្រយោជន៍របស់ប្រជាជន ជាជាងប្រើអំណាចដើម្បីបន្តរក្សាអំណាច។ក៏ប៉ុន្តែ ប្លាតុងក៏យល់ឃើញផងដែរថា តាមធម្មជាតិពីកំណើតមក មនុស្សមិនប្រាកដថាមានគំនិតគិតគូរពីផលប្រយោជន៍រួមច្រើនជាងប្រយោជន៍ផ្ទាល់ខ្លួននោះទេ។ ដូច្នេះ ដើម្បីសម្រិតសម្រាំងមនុស្ស (ទោះជាពលរដ្ឋធម្មតា ឬក៏អនាគតមេដឹកនាំប្រទេស)ឱ្យទៅជាមនុស្សល្អ ចេះគិតគូរដល់ផលប្រយោជន៍រួម គេត្រូវការជាចាំបាច់នូវវិធានការធំៗពីរ។ ទីមួយ គឺការអប់រំ ដើម្បីផ្តល់នូវចំណេះដឹង តម្រែតម្រង់មនុស្សឱ្យស្គាល់ពីផ្លូវល្អ។ ទីពីរ គឺច្បាប់ ដើម្បីចែងកំណត់ពីបម្រាម និងការដាក់ទោសដល់អ្នកដែលប្រព្រឹត្តអំពើអាក្រក់។ នៅក្នុងន័យនេះហើយ ដែលប្លាតុងបានចំណាយពេលមួយផ្នែកធំ នៅក្នុងសៀវភៅ "អំពីការគ្រប់គ្រងរដ្ឋ"(La République) និងសៀវភៅមួយទៀតដែលមានចំណងជើងថា "ច្បាប់" (ជាភាសាបារាំងថា« Les lois ») ជជែកអំពីការអប់រំ ដើម្បីហ្វឹកហ្វឺនអនាគតមេដឹកនាំឱ្យក្លាយទៅជាទស្សនវិទូ។ នៅក្នុងការអនុវត្តជាក់ស្តែងវិញ ប្លាតុងក៏បានចំណាយពេលច្រើនទៅលើការអប់រំនេះដែរ ជាពិសេស តាមរយៈការបង្កើតបណ្ឌិត្យសភា។

## ៣-អារីស្តូត )Aristote : ៣៨៤-៣២២ មុន គ.ស.)

### ៣.១-ប្រវត្តិរបស់អារីស្តូត

អារីស្តូត កើតនៅឆ្នាំ៣៨៤មុនគ .ស. នៅប៉ែកខាងជើងប្រទេសក្រិក។ ខុសពីសូក្រាត និងប្លាតុង អារីស្តូតមិនមែនជាពលរដ្ឋរបស់អាថែននោះទេ។ ផ្ទុយទៅវិញ អារីស្តូតមានទំនាក់ទំនងច្រើនជាមួយនឹងនគរម៉ាសេដ្វាន់ ដោយឪពុករបស់អារីស្តូត គឺជាគ្រូពេទ្យប្រចាំរាជវាំងម៉ាសេដ្វាន់ នៅក្នុងរជ្ជកាលនៃជីតារបស់អធិរាជអាឡិចសង់ឡឺក្រង់។នៅក្នុងរយៈពេលរាប់សតវត្សរ៍ គោលគំនិតរបស់អារីស្តូតត្រូវបានគេយកមកធ្វើជាមូលដ្ឋានគ្រឹះនៅក្នុងការសិក្សា នៅស្ទើរតែគ្រប់វិស័យ រាប់ចាប់តាំងពីទស្សនវិជ្ជា រហូតទៅដល់ផ្នែកតារាសាស្ត្រ តក្កវិទ្យា និងវិទ្យាសាស្ត្រទូទៅ។ អារីស្តូតធំដឹងក្តីឡើងជាកូនកំព្រា ដោយទាំងឪពុក និងទាំងម្តាយ បានស្លាប់ចោលតាំងពីអារីស្តូតនៅក្មេងនៅឡើយ។ នៅពេលមានអាយុ១៧ឆ្នាំ អារីស្តូតបានចាកចេញពីស្រុកកំណើត ហើយធ្វើដំណើរទៅកាន់ទីក្រុងអាថែន ដើម្បីចូលរៀននៅបណ្ឌិត្យសភាដែលបង្កើតឡើងដោយប្លាតុង[3]។

អារីស្តូតបានចំណាយពេលប្រមាណជាង២០ឆ្នាំ នៅបណ្ឌិត្យសភារបស់ប្លាតុង តាំងពីជាកូនសិស្ស រហូតក្លាយជាគ្រូ។ នៅពេលនោះ អារីស្តូតត្រូវបានគេស្គាល់ថាជាសិស្សដ៏ឆ្នើមម្នាក់ ដែលមានទាំងការគោរពស្រឡាញ់ប្លាតុងដែលជាគ្រូ ហើយក្នុងពេលជាមួយគ្នា ក៏បានធ្វើការរិះគន់ច្រើនដែរ ទៅលើគោលគំនិតមួយចំនួនរបស់ប្លាតុង ដោយមិនមែនចេះតែរៀនតាម និងជឿងប់ងល់ទៅតាមរាល់សេចក្តីបង្រៀនរបស់គ្រូនោះទេ។

នៅឆ្នាំ៣៤៧មុនគ.ស. ប្លាតុងបានទទួលមរណភាព។ ផ្ទុយពីការរំពឹងទុកជាទូទៅ តំណែងជានាយកគ្រប់គ្រងបណ្ឌិត្យសភារបស់

[3] -https://www.rfi.fr/km/ប្រវត្តិសាស្ត្រដំណើរ-ទស្សនវិជ្ជា-អារីស្តូត-ជីវិត-2018

ប្លាតុងមិនត្រូវបានផ្ទេរទៅឱ្យអារីស្តូតនោះទេ តែបែរជាត្រូវបានទៅក្មួយរបស់ប្លាតុងទៅវិញ។ គេមិនដឹងច្បាស់នោះទេ ពីហេតុផលដែលប្លាតុងមិនផ្ទេរការគ្រប់គ្រងបណ្ឌិត្យសភាទៅឱ្យអារីស្តូត ក៏ប៉ុន្តែគេគិតថា នេះប្រហែលជាមកពីអារីស្តូតមានទស្សនវិជ្ជាផ្ទុយពីប្លាតុង។

អារីស្តូតក៏បានចាកចេញពីអាថែនដោយប្រហែលជាមកពីមានការខកចិត្តនឹងការសម្រេចចិត្តរបស់ប្លាតុង ឬក៏ប្រហែលជាដោយសារតែហេតុផលមួយទៀត គឺការរីកដុះដាលនៃចលនាប្រឆាំងនឹងម៉ាសេដ្វាន់ពីសំណាក់ពលរដ្ឋអាថែន ហើយគ្រួសាររបស់អារីស្តូត គឺជាអ្នកស្និទ្ធនឹងរាជវាំងម៉ាសេដ្វាន់។ អារីស្តូតបានទៅរស់នៅលើកោះមួយនៅជាប់នឹងព្រំដែនជាមួយនឹងប្រទេសតួកគីបច្ចុប្បន្នដោយនៅទីនោះ អារីស្តូតបានរៀបការ ហើយបានចំណាយពេលយ៉ាងច្រើនធ្វើការសិក្សាយ៉ាងលម្អិតទៅលើសត្វសមុទ្រ (ជីវសាស្ត្រសមុទ្រ) រហូតដល់ឆ្នាំ៣៤២មុនគ.ស. ទើបអារីស្តូតធ្វើដំណើរទៅកាន់នគរម៉ាសេដ្វាន់ ទៅតាមការកោះហៅរបស់ព្រះចៅហ្វីលីពទី២ ដើម្បីទៅបង្រៀនអាឡិចសង់ដែលជារាជបុត្រនិងជាអនាគតអធិរាជ។

ចាប់តាំងពីមានសង្គ្រាមហែកហួរគ្នាឯង ក្រិកដែលធ្លាប់តែជាមហាអំណាចដ៏ធំមួយក៏ត្រូវធ្លាក់ចុះទន់ខ្សោយ ហើយបុរីរដ្ឋរបស់ក្រិកត្រូវដួលរលំម្តងមួយៗ ដោយត្រូវធ្លាក់ក្រោមការកាន់កាប់របស់មហាអំណាចថ្មីមួយទៀត គឺម៉ាសេដ្វាន់។ អាថែនត្រូវធ្លាក់ក្រោមការកាន់កាប់របស់ម៉ាសេដ្វាន់នៅឆ្នាំ៣៣៨មុន គ.ស. ហើយ២ឆ្នាំក្រោយមក អាឡិចសង់ឡឺក្រង់បានឡើងគ្រងរាជ្យនៅម៉ាសេដ្វាន់ជំនួសព្រះចៅហ្វីលីព ទី២ជាបិតាដែលត្រូវគេលបធ្វើឃាត។ មួយឆ្នាំក្រោយការឡើងគ្រងរាជ្យរបស់អាឡិចសង់ឡឺក្រង់ នៅឆ្នាំ៣៣៥មុនគ.ស. អារីស្តូតបានធ្វើដំណើរត្រឡប់ទៅកាន់អាថែនវិញ ដោយបានបង្កើតសាលារៀនថ្មីមួយទៀតប្រជែងជាមួយនឹងបណ្ឌិត្យសភារបស់ប្លាតុង ។ សាលារៀនដែលអារីស្តូតទើបនឹងបង្កើតថ្មីនេះមានកេរ្តិ៍ឈ្មោះល្បីល្បាញមិនចាញ់សាលារៀនរបស់ប្លាតុងនោះទេ ហើយសាលារៀនទាំងពីរនេះបានទាក់ទាញកូនសិស្សយ៉ាងច្រើនមកពីគ្រប់ទិសទី។ នៅទីបំផុតទៅ អាថែន ថ្វីដ្បិតតែត្រូវរលំរលាយខាងនយោបាយ និងខាងយោធា ក៏ប៉ុន្តែ នៅតែមានកេរ្តិ៍ឈ្មោះជាមជ្ឈមណ្ឌលនៃចំណេះដឹងដូចពីមុនដដែល។ សូម្បីតែម៉ាសេដ្វាន់ ដែលក្លាយជាអ្នកត្រួតត្រាអាថែន ប៉ុន្តែ ត្រូវស្ថិតក្រោមឥទ្ធិពលនៃវប្បធម៌របស់អាថែន ជាពិសេស គឺឥទ្ធិពលនៃទស្សនវិជ្ជាក្រិក ទៅលើអធិរាជអាឡិចសង់ឡឺក្រង់ តាមរយៈអារីស្តូតដែលជាគ្រូ។ នៅក្នុងចន្លោះពីឆ្នាំ៣៣៦មុនគ.ស. រហូតដល់ឆ្នាំ៣២៣មុនគ.ស. អធិរាជអាឡិចសង់ឡឺក្រង់បានធ្វើសង្គ្រាមវាតទីពង្រីកទឹកដីអាណាចក្រម៉ាសេដ្វាន់ ចាប់តាំងពីក្រិកឆ្លងកាត់តាមអាណាចក្រ ពែរ្ស និង មេសូប៉ូតាមី រហូតទៅដល់ឥណ្ឌា ហើយអាណាចក្ររបស់អាឡិចសង់ឡឺក្រង់រីកសាយភាយទៅដល់ទីណា វប្បធម៌ក្រិកក៏រីកសាយភាយទៅដល់ទីនោះដែរ។

នៅឆ្នាំ៣២៣មុនគ.ស. អធិរាជអាឡិចសង់ឡឺក្រង់ចូលទិវង្គត ហើយអំណាចរបស់ម៉ាសេដ្វាន់ក៏ចាប់ផ្តើមរង្គោះរង្គើ។ នៅអាថែន

វិញ ចលនាប្រឆាំងនឹងម៉ាសេដ្វាន់ក៏ចាប់ផ្តើមកក្រើកឡើងវិញ ហើយអារីស្តូតដែលតាំងពីដើមមកត្រូវគេចាត់ទុកថាជាអ្នកស្និទ្ធនឹងអាឡិចសង់ឡឺក្រង់ ក៏ត្រូវក្លាយជាចំណុចស៊ីបនៃការធ្វើទុក្ខបុកម្នេញពីសំណាក់ពួកអាថែន។ មិនយូរប៉ុន្មានក្រោយការចូលទិវង្គតរបស់អធិរាជអាឡិចសង់ឡឺក្រង់ អារីស្តូតក៏ត្រូវបានអាជ្ញាធរអាថែនធ្វើការចោទប្រកាន់ពីបទប្រមាថសាសនា ហើយអារីស្តូតក៏ត្រូវប្រឈមមុខនឹងជោគវាសនាដូចជាសូក្រាតដែរ។ ក៏ប៉ុន្តែខុសពីសូក្រាត អារីស្តូតបានរត់គេចខ្លួនដោយមិនសុខចិត្តរង់ចាំទទួលយកការជំនុំជម្រះនិងទោសប្រហារជីវិត ពីអាជ្ញាធរអាថែននោះទេ។ ចំពោះសូក្រាត ការណ៍ដែលលោកមិនរត់គេចខ្លួន គឺដោយសារតែលោកប្រកាន់ខ្ជាប់តាមទស្សនវិជ្ជារបស់លោកដែលថាពលរដ្ឋនៃរដ្ឋមួយមានករណីយកិច្ចគោរពតាមច្បាប់របស់រដ្ឋនោះ បើទោះបីជាច្បាប់នោះមានភាពអយុត្តិធម៌យ៉ាងណាក៏ដោយ។ បើគេគិតតាមគោលការណ៍នេះ ការរត់គេចខ្លួនរបស់អារីស្តូតមិនមែនជា ទង្វើផ្ទុយនឹងទស្សនវិជ្ជារបស់សូក្រាតនោះទេ ពីព្រោះថា អារីស្តូត ថ្វីដ្បិតតែបានចំណាយពេលភាគច្រើនក្នុងជីវិត រស់នៅរៀនសូត្រ និងបង្រៀន នៅអាថែន តែអារីស្តូតមិនមែនជាពលរដ្ឋអាថែននោះទេ ហើយអ្នកស្រុកអាថែនក៏មិនទទួលយកអារីស្តូតថាជាជនរួមជាតិរបស់ពួកគេនោះដែរ។ ដូច្នេះ គេអាចនិយាយបានថា អារីស្តូតមិនមានកាតព្វកិច្ចដាច់ខាតត្រូវគោរពតាមច្បាប់និងការសម្រេចរបស់សភាអាថែន ដូចសូក្រាតនោះទេ។

អារីស្តូតបានអះអាងថា ការណ៍ដែលលោករត់គេចខ្លួនពីការកាត់ទោស គឺ "ដើម្បីបញ្ចៀសកុំឱ្យអ្នកស្រុកអាថែនប្រព្រឹត្តបាបកម្មផ្ទួនៗគ្នាប្រឆាំងនឹងទស្សនវិជ្ជា" ដោយលោកចង់សំដៅលើ "បាបកម្ម" ដែលពួកគេធ្វើទៅលើសូក្រាតម្តងរួចទៅហើយកាលពីលើកមុន។ អារីស្តូតបានទទួលមរណភាពនៅឆ្នាំ៣២២មុនគ.ស. ដោយជំងឺ ដោយនៅពេលនោះអារីស្តូតមានវ័យ៦២ឆ្នាំ។

**៣.២-ទស្សនៈរបស់អារីស្តូតពាក់ព័ន្ធនឹងនយោបាយ**

លោកអារីស្តូតមានការចាប់អារម្មណ៍យ៉ាងខ្លាំងទៅលើបញ្ហានយោបាយដោយលោកបានពោលថា "វិទ្យាសាស្ត្រនយោបាយ គឺជាកិច្ចការរបស់រដ្ឋឬសង្គម។ តាមគំនិត "អារីស្តូតរដ្ឋគឺជាសង្គម។ ហើយរដ្ឋកើតឡើងដោយសារតែពលរដ្ឋរួមផ្តុំគ្នាជាច្រើន។ តាមគំនិតអារីស្តូតម "នុស្សលោក គឺជាសត្វចេះធ្វើនយោបាយពីធម្មជាតិមក ដែលជាលក្ខណៈវិសេសរបស់មនុស្ស ហើយលក្ខណៈវិសេសមួយទៀត គឺមនុស្សព្យាយាមរស់នៅក្នុងសង្គមរួមទាំងអស់គ្នា ពោលគឺរស់នៅក្នុងរដ្ឋតែមួយតាមទស្ស ។ "

នៈរបស់អារីស្តូតរដ្ឋកើតឡើងដោយ " សារតែហេតុផលចាំបាច់ គឺធ្វើយ៉ាងណាឱ្យជីវិតរស់នៅរបស់ពលរដ្ឋមានភាពប្រសើរជាងមុន។ មានតែនៅមជ្ឈមណ្ឌលខាងក្នុងរដ្ឋទេដែលបង្កលក្ខខណ្ឌល្អៗឱ្យមនុស្សរស់នៅក្នុងភាពសុខដមរមនានិងសុភមង្គល ពីព្រោះភាពយុត្តិធម៌និងសិទ្ធិដែលបានបម្រើផលប្រយោជន៍ឱ្យប្រជាពលរដ្ឋគ្រប់រូប មានតែនៅក្នុងរដ្ឋប៉ុណ្ណោះ ។ "

លោកអារីស្តូត ជាសិស្សម្នាក់ ក្នុងចំណោមសិស្សជាច្រើនរបស់ប្លាតុង។ ភាពខុសគ្នារបស់អារីស្តូត ទៅនឹងលោកគ្រូរបស់ខ្លួន គឺមកពីប្រភពមូលដ្ឋាននៃទស្សនវិជ្ជាផ្សេងៗគ្នា ដែលជាមូលហេតុធ្វើឱ្យគំនិតនយោបាយរបស់មហាទស្សនវិទូទាំងពីរនេះក៏មិនដូចគ្នាដែរ។

អារីស្តូត បានបង្ហាញនូវរបបនយោបាយ និងទម្រង់គ្រប់គ្រងរដ្ឋ ដែលស្ថិតនៅក្នុងការកំណត់ និងការបែងចែកប្រភេទទាំងពីរផ្សេងពីគ្នានៃរចនាសម្ព័ន្ធរដ្ឋគំរូ ។

រដ្ឋគំរូទី១ អារីស្តូត ចាប់អារម្មណ៍ទៅនឹងរដ្ឋគំរូ ដែលមានលក្ខណៈខុសពីគេទាំងអស់ ។ រដ្ឋគំរូ បានផ្តល់ការបំពេញជូនសង្គមនូវស្ថេភាពយូរអង្វែងជាអតិបរមា រដ្ឋបែបនេះសម្រាប់អារីស្តូត ជារដ្ឋគំរូនៅក្នុងការអនុវត្តនយោបាយ។ អារីស្តូតបានគិតថា "Polity ជារបបនយោបាយគំរូព្រោះនៅក្នុងរបបនេះ អំណាចស្ថិតនៅក្នុងការគ្រប់គ្រងដោយវណ្ណៈកណ្តាល"។ តាមទស្សនៈរបស់អារីស្តូត Polity គឺចំពោះរដ្ឋណាដែលដឹកនាំប្រកបដោយគតិវិញ្ញូ និងភាពទទួលខុសត្រូវចំពោះសកម្មភាពរបស់ខ្លួនហើយអំណាចស្ថិតនៅក្រោមការគ្រប់គ្រងរបស់មនុស្សភាគច្រើន។

រដ្ឋគំរូទី២ អារីស្តូត បានឱ្យតម្លៃដោយគិតថាប្រសើរបំផុត ចំពោះទស្សនៈប្រកបដោយសីលធម៌ នៅក្នុងរបបដែលនៅទីនោះប្រជាពលរដ្ឋ ប្រឹងប្រែងដើម្បីបានទទួលនូវកិត្តិយសនិងគុណធម៌នៅក្នុងជីវិត។ រចនាសម្ព័ន្ធរដ្ឋដែលល្អបំផុតគឺជាអង្គការមួយដែលផ្តល់នូវលទ្ធភាពដល់មនុស្សដើម្បីរស់ក្នុងភាពរុងរឿង និងសុភមង្គល។ រដ្ឋគំរូអារីស្តូត បានចាប់អារម្មណ៍ជាខ្លាំងចំពោះស្ថានភាពខាងក្រៅនៃអត្ថិភាពរបស់រដ្ឋ ជាបឋមគឺចំនួនប្រជាពលរដ្ឋ ស្ថានភាពរស់នៅជាមួយនឹងការឧបត្ថម្ភគ្រប់បែបយ៉ាង និងស្ថានភាពទឹកដី ដើម្បីការពារនិងទប់ទល់សត្រូវឈ្លានពាន។ តាមទស្សនៈរបស់អារីស្តូត ដែលបានចារនៅក្នុងរបបនយោបាយបានឱ្យយើងដឹងថាក្នុងចំណោមប្រជាជនត្រូវបានបែងចែកចេញពួកសិប្បករ និងឈ្មួញព្រោះក្នុងកិច្ចការជីវិតរបស់គេមិនឆ្លើយតបទៅនឹងគុណធម៌ទេ ដើម្បីមានតួនាទីជាពលរដ្ឋចំតួ គឺមានតែពួកកសិករទេ ។ ប្រជាពលរដ្ឋទាំងអស់ត្រូវតែចូលរួមជួយគ្នាទៅវិញទៅមកក្នុងសកម្មភាពនិងគ្រប់មធ្យោបាយទាំងអស់ ដែលជាកិច្ចការកសិកម្ម ក្នុងសង្គម ។ អារីស្តូតបានគិតថា នៅក្នុងរដ្ឋគ "ំរូត្រូវតែបែងចែកដីធ្លី ជាសម្បត្តិរួម និងជាសម្បត្តិឯកជន" ។ ចំពោះដីរួម អារីស្តូតបានគិតថា ត្រូវតែបែង "ចែកជាពីរផ្នែក។ ប្រាក់ចំណូលដែលបានមកពីចំណែកមួយក្នុងចំណោមនេះ ត្រូវគេប្រើសម្រាប់សេចក្តីត្រូវការនៅក្នុងសាសនា រីឯចំណែកទីពីរ គឺសម្រាប់មូលនិធិសង្គម។"

ដូច្នេះ ភាពខុសគ្នាជាមូលដ្ឋាននៃទស្សនៈទាននយោបាយរបស់អារីស្តូត និងប្លាតុង ស្ថិតនៅត្រង់ថា អារីស្តូតមានទស្សនៈផ្ទុយនឹងលោកគ្រូរបស់ខ្លួនត្រង់កន្លែងតថភាពនិងលក្ខណៈជាគំរូដែលបានកំណត់តម្លៃនិងទិសដៅជាក្រឹត្យក្រមចំពោះការស្រាវជ្រាវបញ្ហាននយោបាយ។ រដ្ឋគំរូរបស់អារីស្តូត អាចកើតឡើងបានអាស្រ័យកត្តាពីរយ៉ាង កត្តាទីមួយ គឺស្ថេរភាព និងកត្តាទីពីរ គឺក្រមសីលធម៌។ ដូច្នេះសម្រាប់អារីស្តូត មានរចនាសម្ព័ន្ធរដ្ឋគំរូពីរយ៉ា

ង។ ម្យ៉ាង គឺរដ្ឋដែលគិតគូរដល់ប្រយោជន៍រួម នៃវណ្ណៈកណ្តាលជាអតិបរមា ម្យ៉ាងទៀត គឺ រចនាសម្ព័ន្ធសំដៅទៅលើគោលការណ៍បុគ្គលិក ភាព ដែលជាមនុស្សប្រកាន់ខ្ជាប់នូវគុណធម៌ ដែលជាទិសដៅនយោបាយសង្គមដ៏សំខាន់ បំផុត ជាពិសេសគឺនយោបាយទំនាក់ទំនងគ្នា របស់ប្រជាជន ដែលរស់នៅក្នុងរដ្ឋ។ និយាយ អំពីរដ្ឋ អារីស្តូតបានបង្ហាញថា គឺជា មនុស្ស " សត្វចេះធ្វើនយោបាយពី
ធម្មជាតិ ហើយដឹកនាំខ្លួន ការប្រឹងប្រែងជាស ភាវគតិ ដើម្បីរស់នៅជាមួយគ្នា រីឯការរីក ចម្រើនសង្គម គឺចេញពីគ្រួសារ ទៅជាសង្គម និងសង្គមទៅជារដ្ឋ ។ "

បើតាមទស្សនៈរបស់អារីស ្ត ូត ដែលបាននិយាយនៅក្នុងស្នាដៃនៃនយោបាយ គឺរដ្ឋបើតាមលក្ខណៈធម្មជាតិរបស់ខ្លួននាំមុខ បុគ្គលពីព្រោះលក្ខណៈធម្មជាតិរបស់រដ្ឋមានទី តាំងនៅមុនលក្ខណៈធម្មជាតិរបស់គ្រួសារ និង បុគ្គល ។ កត្តាចាំបាច់ ដើម្បីឱ្យរដ្ឋនាំមុខបុគ្គល តាមអារីស្តូតថា "រដ្ឋ ត្រូវបង្កលក្ខណៈល្អ ប្រសើរ សម្រាប់ជីវិតពលរដ្ឋ។មានតែនៅក្នុងរដ្ឋ ទេទើបមនុស្សអាចមានការជឿនលឿនពីព្រោះ រដ្ឋនាំមកនូវយុត្តិធម៌ និងសីលធម៌ ដែលបម្រើ ផលប្រយោជន៍រួមរបស់ប្រជាជន ។ ត្រង់នេះ " អារីស្តូត បាននិយាយអំពីរដ្ឋ ដូចជាការចុះកិច្ច ព្រមព្រៀងសង្គមរបស់ប្រជាពលរដ្ឋដែលជា ទស្សនទាន នៃការកកើតសង្គមពលរដ្ឋ និងនីតិ រដ្ឋ។ ថ្វីបើអារីស្តូត ពុំបានបែងចែក ឱ្យដាច់រវាង រដ្ឋ និងសង្គមពលរដ្ឋយ៉ាងណាក៏ដោយ ក៏អារី ស្តូត បាននិយាយថារដ្ឋត្រូវតែឆ្លុះបញ្ចាំងនូវ " "ផលប្រយោជន៍របស់ប្រជាពលរដ្ឋ។ នៅក្នុង ទ្រឹស្តីរបស់អារីស្តូត ក៏ដូចជានៅក្នុងទ្រឹស្តីរបស់ ប្លាតុងដែរ មានបង្កប់នូវលក្ខណៈផ្តាច់ការនិយ ម។ មនុស្សគឺជាផ្នែកមួយរបស់រដ្ឋ ផល ប្រយោជន៍បុគ្គល មិនត្រូវធ្វើឱ្យប៉ះពាល់ដល់ ផលប្រយោជន៍រួម ។ នៅក្នុងការវាយតម្លៃរបស់ អារីស្តូត ពលរដ្ឋ គឺជាផ្នែកមួយនៃនយោបាយរួ ម។ អារីស្តូតបានហៅពាក្យថា ពលរដ្ឋ គឺជា មនុស្សដែលមានសេរីភាព ប៉ុន្តែសេរីភាពមាន អត្ថន័យត្រឹមតែពាក្យផ្ទុយនឹងទាសភាពប្រជា ពលរដ្ឋ មិនមែនជាទាសករទេ គ្មាននរណា ដឹកនាំគេទេ ។ ពលរដ្ឋធ្វើការងារ តែជាយោធា និងការងារទាក់ទង នឹងតុលាការ រីឯការងារធ្វើ ស្រែចម្ការ និងផលិតកម្ម គឺជាការងារទាសករ ។ អារីស្តូត បានកំណត់គោលការណ៍របស់អភិ ជនាធិបតេយ្យ គឺគុណធម៌ ។ គោលដៅរបស់ អភិជនាធិបតេយ្យ គឺទ្រព្យសម្បត្តិ ។ គោលដៅ របស់ប្រជាធិបតេយ្យ គឺសេរីភាព ។ គឺមានតែ Polity ទេ ដែលចាត់ទុកដូចជាទម្រង់គ្រប់គ្រង រដ្ឋគំរូ មានអំណោយផលល្អ ហើយរបប នយោបាយគំរូ ដ៏ល្អបង្ហំទៅដោយសារជាតុបី យ៉ាងខាងលើនេះ។របបនយោបាយអភិ ជនាធិបតេយ្យត្រឹមត្រូវពិតប្រាកដ គឺនៅពេល ណាមានការដឹកនាំល្អ បានបង្រួបបង្រួម ប្រយោជន៍ទាំងអ្នកមាន ទាំងអ្នកក្រ។ វណ្ណៈ កណ្តាល ដែលកំណត់មុខមាត់របស់Polity គឺ ស្ថិតនៅចន្លោះរវាងអ្នកមាននិងអ្នកក្រ ហើយ ថែមទាំងជួយថែរក្សាសង្គម ឱ្យមានស្ថេរភាព និងគ្មានព្រឹត្តិការណ៍បដិវត្តន៍ ដូច្នេះហើយរបប នេះ គឺជារបបដ៏ល្អ រក្សាមិនឱ្យមានចលាចល អស្ថេរភាព ដែលអារីស្តូតបានចាត់ទុកថា ជា

ទម្រង់គ្រប់គ្រងរដ្ឋគំរូ ត្រឹមត្រូវសម្រាប់ជម្រើសរបស់អ្នកដឹកនាំ។

អារីស្តូត បានបន្សល់ទុកនូវស្នាដៃ ជាសំណេររហូតដល់ទៅប្រមាណជា២០០ ហើយស្នាដៃអស់ទាំងនេះ ត្រូវបានរក្សាទុកនៅក្នុងបណ្ណាល័យនៃសាលារៀនរបស់អារីស្តូតដែលត្រូវបានគេចាត់ទុកថាជា បណ្ណាល័យដ៏ធំជាងគេបង្អស់នៅលើពិភពលោក នៅក្នុងសម័យកាលនោះ។ នៅក្នុងចំណោមស្នាដៃរបស់អារីស្តូតទាំង២០០នេះ មានតែប្រមាណ៣១ប៉ុណ្ណោះដែលសេសសល់ មកទល់នឹងសម័យកាលបច្ចុប្បន្ន ហើយក្នុងចំណោមនោះ ភាគច្រើនលើសលុបគឺជាកំណត់ត្រាផ្ទាល់ខ្លួនដែលអារីស្តូត តាក់តែងឡើងសម្រាប់ការបង្រៀននៅសាលាជាជាងជាសៀវភៅឬឯកសារសម្រាប់ផ្សព្វផ្សាយជាសាធារណៈ។

អារីស្តូត បានធ្វើការបែងចែកចំណេះដឹងទៅតាមផ្នែកផ្សេងៗគ្នា រួមមានចំណេះដឹងខាងផ្នែក សីលធម៌ នយោបាយ គណិតវិទ្យា ជីវវិទ្យា។ល។និង។ល។ ហើយទ្រឹស្តីរបស់អារីស្តូត ក៏មានលក្ខណៈទូលំទូលាយគ្របដណ្តប់ទៅលើស្ទើរតែគ្រប់ផ្នែកផងដែរ ចាប់តាំងពីទស្សនវិជ្ជា នយោបាយ សីលធម៌ សិល្បៈ និកំណាព្យ រហូតដល់ខាងផ្នែករដ្ឋសាស្ត្រ ជីវវិទ្យា តក្កវិទ្យា និងវិទ្យាសាស្ត្រទូទៅគឺគណិតវិទ្យានិងរូបវិទ្យា។

ទាក់ទងនឹងទស្សនវិជ្ជានយោបាយគេអាចរកឃើញនូវគោលគំនិតសំខាន់ៗរបស់ អារីស្តូត នៅក្នុងសៀវភៅដែលមានចំណងជើងថា ″នយោបាយ‶ (ឬជាភាសាបារាំង La Politique)។ ជាទូទៅគេសង្កេតឃើញមានសម្តីមួយឃ្លារបស់អារីស្តូតដែលមាននៅក្នុងសៀវភៅនេះហើយដែលត្រូវបានគេលើកយកមកនិយាយញឹកញាប់ជាងគេ រហូតមកទល់នឹងពេលបច្ចុប្បន្ន គឺឃ្លាជាភាសាបារាំងថា «L'homme est un animal politique» ដែលមានន័យជារួមថាធម្មជាតិរបស់មនុស្សគឺ ត្រូវផ្សារភ្ជាប់ដោយមិនអាចកាត់ផ្តាច់បានពីនយោបាយ ហើយនៅត្រង់កន្លែង″នយោបាយ‶ នេះគឺ សំដៅលើនយោបាយក្នុងន័យទូលាយ ពោលគឺ សំដៅទៅលើជីវិតជាសហគមន៍ឬរដ្ឋ។

យោងតាម អារីស្តូត មនុស្សមិនអាចរស់នៅតែម្នាក់ឯងបាននោះទេ។ ផ្ទុយទៅវិញ មនុស្សគ្រប់រូបសុទ្ធតែត្រូវការគ្នាទៅវិញទៅមក ហើយមនុស្សចាំបាច់ត្រូវតែរស់នៅក្នុង ទម្រង់ជាសមូហភាព ឬសហគមន៍ ហើយ ទម្រង់ដើមបំផុតនៃសហគមន៍នេះគឺគ្រួសារ។ គ្រួសារប្រមូលផ្តុំគ្នា បង្កើតទៅជាភូមិហើយភូមិប្រមូលផ្តុំគ្នាបង្កើតទៅជាបុរី ឬរដ្ឋ។ សម្រាប់អារីស្តូត ការប្រមូលផ្តុំគ្នារបស់មនុស្សក្នុងទម្រង់ជាគ្រួសារមោលក្ខណៈជាធម្មជាតិយ៉ាងណា ការប្រមូលផ្តុំគ្នារបស់មនុស្សក្នុងទម្រង់ជាបុរី ឬរដ្ឋ ក៏មានលក្ខណៈធម្មជាតិ យ៉ាងនោះដែរ។ ដូច្នេះ និយាយជារួមមកវិញ ការរៀបចំរចនាសម្ព័ន្ធជារដ្ឋដែលមានប្រព័ន្ធគ្រប់គ្រងនយោបាយ មានច្បាប់ មានរដ្ឋាភិបាល និងមានមេដឹកនាំ គឺជាធម្មជាតិរបស់មនុស្ស។ដោយសារតែមនុស្សមានធម្មជាតិផ្សារភ្ជាប់ដោយមិនអាចកាត់ផ្តាច់បានពីនយោបាយ ដូច្នេះ អារីស្តូតយល់ឃើញថា វិទ្យាសាស្ត្រនយោបាយ គឺ ជាចំណេះដឹងដ៏សំខាន់ជាងគេបង្អស់ ដែលប្រជាជនគ្រប់រូបត្រូវតែរៀន។

ទាក់ទងនឹងរបៀបគ្រប់គ្រងរដ្ឋវិញ អារីស្តូតក៏មិនខុសពីសូក្រាតនិងប្លាតុងដែរ សុទ្ធតែមានគោលគំនិតប្រឆាំងនឹងរបបប្រជាធិបតេយ្យ គឺប្រជាធិបតេយ្យដោយផ្ទាល់ តាមបែបអាថែននៅក្នុងសម័យនោះ។ ទស្សនវិទូសំខាន់ៗទាំងបីរូបនេះសុទ្ធតែមានការយល់ឃើញដូចគ្នាថារបបប្រជាធិបតេយ្យដោយផ្ទាល់ដែលពលរដ្ឋគ្រប់រូបមានអំណាចដោយផ្ទាល់នៅក្នុងសភាបែបនោះវាបង្កើតឱ្យទៅជាអនាធិបតេយ្យទៅវិញ។

អារីស្តូត មានការយល់ឃើញដូចប្លាតុងថារបបនយោបាយដ៏ប្រសើរជាងគេបង្អស់គឺរបបនយោបាយដែលអំណាចទាំងអស់ប្រមូលផ្តុំនៅក្នុងដៃមនុស្សតែម្នាក់ ហើយមេដឹកនាំនេះគឺជាទស្សនវិទូដែលនៅក្នុងសៀវភៅ ស្តីពីការ" ) "គ្រប់គ្រងរដ្ឋLa République) ប្លាតុងបានហៅថា ។ ″ទស្សនវិទូ-ស្តេច"បើនិយាយឱ្យងាយស្តាប់គេអាចហៅរបបដឹកនាំបែបនេះបានម្យ៉ាងទៀតថាជារបបរាជានិយមដែលមានស្តេចប្រកបដោយទសពិធរាជធម៌។ ក៏ប៉ុន្តែ ខុសពីប្លាតុង អារីស្តូតយល់ឃើញថា របបនយោបាយបែបនេះ គឺមានតែនៅលើក្រដាសឬមានតែនៅក្នុងការស្រមើស្រមៃតែប៉ុណ្ណោះ។ រីឯនៅក្នុងការអនុវត្ត ជាក់ស្តែងវិញ គេកម្រនឹងរកបានណាស់ ដោយទស្សនវិទូមិន ″ទស្សនវិទូ-ស្តេច" បានឡើងធ្វើស្តេចរីឯអ្នកបានធ្វើស្តេចមិនមែនជាទស្សនវិទូ។

ជាងនេះទៅទៀត អារីស្តូត យល់ឃើញថា របបនយោបាយតាមបែប ទស្សន-ស្តេច" របស់ ″វិទូប្លាតុងនេះ គឺជារបបនយោបាយមួយ ដែលមានហានិភ័យខ្ពស់ ពីព្រោះថានៅពេលដែលអំណាចត្រូវប្រមូលផ្តុំនៅក្នុងដៃបុគ្គលតែម្នាក់ ហើយបុគ្គលនោះមិនមែនជាអ្នកដឹកនាំប្រកបដោយគតិបណ្ឌិត វាងាយនឹងត្រូវប្រែក្លាយទៅជារបបផ្តាច់ការឃោរឃៅដែលមេដឹកនាំយកអំណាចទៅប្រើប្រាស់ដើម្បីតែប្រយោជន៍ផ្ទាល់ខ្លួន ហើយជិះជាន់អ្នកទន់ខ្សោយ។ នៅពេលនោះរបបនយោបាយ -ស្តេច" ដែលជារបបដឹកនាំដ៏ល្អបំផុ ″ទស្សនវិទូតនោះត្រូវប្រែក្លាយទៅជារបបផ្តាច់ការឃោរឃៅដែលជារបបដឹកនាំដ៏អាក្រក់បំផុតទៅវិញ។

ហេតុដូច្នេះហើយ បានជាអារីស្តូតយល់ថារវាងរបបនយោបាយមួយដែលពោរពេញដោយភាពអនាធិបតេយ្យប្រជាធិបតេ) និងរបបនយោបាយមួយ( យ្យដោយផ្ទាល់ទៀតដែលល្អឥតខ្ចោះតែមិនអាច យកទៅអនុវត្តជាក់ស្តែងគ ("ទស្សនវិទូ-ស្តេច")ៈអាចមានជម្រើសកណ្តាលមួយគឺការដឹកនាំដោយមនុស្សមួយក្រុមតូច ដោយមនុស្សមួយក្រុមតូចនេះ ទទួលបាននូវការព្រមព្រៀងនិងការប្រគល់សិទ្ធិអំណាច ពីប្រជាជនទូទៅ ហើយអ្វីៗត្រូវប្រព្រឹត្តទៅនៅក្នុងក្របខណ្ឌនៃច្បាប់កំពូលមួយដែលមានចែងកំណត់ទាំងអំពីសិទ្ធិអំណាចនិងការទទួលខុសត្រូវរបស់មេដឹកនាំនិងទាំងអំពីសិទ្ធិនិងកាតព្វកិច្ចរបស់ប្រជាពលរដ្ឋ។ គោលគំនិតនេះគឺជាចំណុចចាប់ផ្តើមមួយដែលក្រោយមកបានវិវឌ្ឍទៅជារបបប្រជាធិបតេយ្យ តាមរយៈតំណាងដូចដែលគេយកមកអនុវត្តជាទូទៅនៅក្នុងសម័យកាលបច្ចុប្បន្នដោយច្បាប់កំពូ"លដែល អារីស្តូត បានលើក ″ឡើងនោៈគឺ។″រដ្ឋធម្មនុញ្ញ"

**៣.៣-ទស្សនៈសំខាន់ៗរបស់អារីស្តូត**

-អ្នកគឺជាអ្វីដែលអ្នកធ្វើជាប្រចាំថ្ងៃ។ ភាពល្អឥតខ្ចោះមិនមែនជាសកម្មភាពទេ តែវាជាទម្លាប់។

-សេចក្តីស្រលាញ់កើតចេញពីដួងព្រលឹងតែមួយដែលស្ថិតក្នុងរូបកាយពីរ។

-ភាពរីករាយគឺស្ថិតនៅលើអ្នក។

-អ្នកដែលដឹងធ្វើ ចំណែកអ្នកដែលយល់បង្រៀន។

-មនុស្សម្នាក់ៗអាចខឹងក្រោធបាន វាជារឿងងាយស្រួលនោះទេ។ ប៉ុន្តែ ការខឹងជាមួយមនុស្សត្រឹមត្រូវ នៅពេលត្រឹមត្រូវ ក្នុងគោលបំណងត្រឹមត្រូវ និងក្នុងវិធីត្រឹមត្រូវ មិនងាយស្រួលនោះឡើយ។

-អំណាចនៃខួរក្បាលគឺជាភាពចាំបាច់សម្រាប់ជីវិត។

-ឫសគល់នៃការអប់រំគឺល្វីងជូរចត់ ប៉ុន្តែផ្លែរបស់វាគឺផ្អែមត្រជាក់។

-មនុស្សមានលក្ខណៈល្អប្រពៃជាងសត្វណាៗទាំងអស់ ប៉ុន្តែបើមិនមានច្បាប់និងយុត្តិធម៌នោះទេ មនុស្សគឺមានភាពអាក្រក់ ឃោរឃៅ ព្រៃផ្សៃជួរជាតិជាងសត្វណាៗទាំងអស់។

-តាមធម្មជាតិ មនុស្សគ្រប់រូបសុទ្ធតែចង់បានចំណេះដឹង។

-ការស្គាល់ខ្លួនឯងគឺជាពន្លកនៃគតិបណ្ឌិត។

-ការអប់រំតែខួរក្បាលដោយមិនអប់រំបេះដូងគឺមិនមែនជាការអប់រំឡើយ។

-នៅពេលអ្នកកាន់តែចេះ នោះអ្នកនឹងកាន់តែដឹងថាអ្នកមិនចេះ។

**គន្ថនិទ្ទេស**


១-កាន អ៊ីនហ្គីន និងក្រុមអ្នកប្រែសម្រួល៖ *វចនានុក្រមទស្សនវិជ្ជាអក្សរហ្វីដ* ភ្នំពេញ ការផ្សាយរបស់វិទ្យាស្ថានMagga, ភ្នំពេញ ២០២០

២-ជួន ណាត៖ *វចនានុក្រមខ្មែរ* ភ្នំពេញ ការផ្សាយរបស់វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ

៣-រស់ ចន្ត្រាបុត្រ៖ *សូក្រាត* ភ្នំពេញ ការផ្សាយរបស់សារព័ត៌មានមហាជន ១៩៧២

៤-សុខ សុគ្គាល៖ *មហាទស្សនវិទូ និងទស្សនវិជ្ជាក្នុងលោក* ឆ្នាំ១៩៧១

៥-https://bookmemoryblog.files.wordpress.com/2014/07/259-e19e95e19f92e19e9be19eb6e19e8fe19ebc1.pdf

៦-https://en.wikipedia.org/wiki/Aristotle

៧-https://www.rfi.fr/km/ប្រវត្តិសាស្ត្រអារីស្តូត-ដំណើរជីវិត-ទស្សនវិជ្ជា--2018

# ទស្សនវិជ្ជាខ្មែរអំពី អាបោធាតុ

( WATER in Khmer Philosophy )

ដោយៈ **បណ្ឌិត ប៉ាន់ ខុន្ថា**
ប្រធានស្តីទីនាយកដ្ឋានទស្សនវិជ្ជានិងសង្គមវិជ្ជា
នៃវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម
រាជបណ្ឌិត្យសភាកម្ពុជា

## សេចក្តីផ្តើម

ព្រះពុទ្ធបានបរិយាយអំពីលោកធាតុ៤ គឺ បឋវីធាតុ (ធាតុដី) អាបោធាតុ (ធាតុទឹក) តេជោធាតុ (ធាតុភ្លើង) វាយោធាតុ (ធាតុខ្យល់) ជាលោកធាតុដំបូង ដែលទ្រទ្រង់ការកកើតនៃភាវៈទាំងអស់នៅលើលោកយើងនេះ មានដូចជា មនុស្ស សត្វ រុក្ខជាតិ និង វត្ថុអវិញ្ញាណកៈ ទាំងអស់។ ចំណែកឯទស្សនវិទូក្រិកៈ តាលេស (Thales) អះអាងថាៈ អ្វីៗទាំងអស់ គឺជាទឹក។ ទឹក ជាប្រភពនៃការកកើតវត្ថុ មនុស្ស សត្វ រុក្ខជាតិ ហើយអ្វីៗទាំងអស់រលាយក្លាយជា ទឹកវិញ។ អាណាស៊ីមែន (Anaximenes) អះអាងថា ៖ ខ្យល់ ជាធាតុដើមគេបង្អស់។ អ្វីៗទាំងអស់ ក្នុងលោកកកើតពី ខ្យល់ កក ពរ ក្តៅត្រជាក់។ ហេរ៉ាគ្លីត (Heraclitus) អះអាងថាៈ ភ្លើង ជាបិតានៃអ្វីៗទាំងអស់។ អារីស្តូត (Aristotle) អះអាងថាៈ អ្វីៗទាំងអស់ក្នុងលោកកកើតពី ទឹក ដី ភ្លើង ខ្យល់ ដូចទស្សនៈរបស់ព្រះពុទ្ធដែរ។

បញ្ញត្តិ ទឹក ដី ភ្លើង ខ្យល់ នៅក្នុងទស្សនវិជ្ជាខ្មែរ មិនគ្រាន់តែមានអត្ថន័យត្រឹមតែជាលោកធាតុវិទ្យាដូចក្នុងទស្សនវិជ្ជាបស្ចិមប្រទេសទេ តែវាមានអត្ថន័យបន្ថែមជាច្រើនអនេកក្នុងអស្តិរូបវិជ្ជាឬបរមត្ថវិជ្ជាទាក់ទងនឹងជំនឿសាសនាផងដែរ ទាំងក្នុងជំនឿជីវចលនិយម ទាំងក្នុងព្រហ្មញ្ញសាសនា ទាំងក្នុងពុទ្ធសាសនា ដែលអត្ថិភាពក្នុងសង្គមខ្មែរ និងជាព្រលឹងរបស់ខ្មែរ។ ប៉ុន្តែនៅក្នុងអត្ថបទដែលត្រូវធ្វើអភិប្រាយនេះ ខ្ញុំសូមលើកយកតែអាបោធាតុ (ទឹក) តែមួយទេ យកមកធ្វើជាបទឧទ្ទេសរឹងលោកធាតុ ផុ

*សេងៗទៀតនឹងសិក្សាស្រាវជ្រាវនៅពេលក្រោយ។*

## **អត្ថន័យ អាបោធាតុ (ទឹក) ក្នុងទស្សនវិជ្ជាខ្មែរ**

**អាបោធាតុ (ទឹក)** *ជាលោកជាតុសម្រាប់ទ្រទ្រង់ជីវិតមនុស្ស សត្វ រុក្ខជាតិ។* **ទឹក** *ក្រៅពីត្រូវបានគេប្រើសម្រាប់ ផឹក ដាំស្ល ងូត លុបលាងបោកគក់ ទ្រទ្រង់កសិកម្ម វារីអគ្គិសនី មធ្យោបាយគមនាគមន៍... វាផ្ទុកនូវអត្ថន័យជំនឿសាសនា និងទស្សនវិជ្ជាយ៉ាងច្រើន និងជ្រាលជ្រៅជាទីបំផុត។*

*នៅក្នុងការប្រត្តិបត្តិជំនឿនិងសាសនាទាំងក្នុងជំនឿជីវចលនិយម ទាំងក្នុងព្រហ្មញ្ញសាសនា ទាំងក្នុងពុទ្ធសាសនា នៅក្នុងសង្គមខ្មែរ* **ទឹក** *ដើរតួនាទីសំខាន់ណាស់។ មុនទទួលឥទ្ធិពលឥណ្ឌា ខ្មែរជឿលើកំលាំងអធិជម្មជាតិ និងចាត់ទុក* **ទឹក** *ជា* ***អ្នកតា គឺ អ្នកតាទឹក អ្នកតាម្ចាស់ទឹក*** *។*

*ចាប់តាំងពីទទួលកាន់ជឿនិងការសំយោគជំនឿជីវចលខ្មែរនិងសាសនាហិណ្ឌូ-ព្រហ្មញ្ញសាសនាមក ប្រជាជនខ្មែរក៏បានចាត់ទុក* ***ទឹក ជាវត្ថុពិសិដ្ឋ ជាអាទិទេព (ព្រះម៉ែគង្គា)*** *ជាអ្នកបង្កើត ជាអ្នកចិញ្ចឹមជាអ្នកសម្រាប់ភាវៈមានជីវិតទាំងអស់។*

**ទឹក** *ដក់ជាប់ក្នុងផ្នត់គំនិតខ្មែរ ដោយប្រជាពលរដ្ឋខ្មែរយកទឹកធ្វើជាគ្រឿងសំអាងក្នុងជំនឿផ្សេងៗ ដូចជា ៖ ធ្វើជា* ***ទឹកអម្រឹត ទឹកសម្បថ ទឹកមន្ត ទឹកអង្គបំពង់ខ្ចី ទឹកដោះម្តាយថ្ងៃ ទឹកសំបួរ ទឹកស័ង្ខ ជាវត្ថុលាងជម្រះ*** *។ល។*



*ទឹកនៅភ្នំគូលេន*

***១- ទឹកអម្រឹត*** *ក្នុងពិធិសិរៈរាត្រីនៅឥណ្ឌា គេបានដងទឹកទន្លេគង្គាទៅស្រោចស្រពលើសិវៈលិង្គដែលគេដាក់តម្កល់នៅលើយោនីនាងឧមា រួចគេត្រងយកទឹកដែលហូរចុះតាមប្រឡាយយោនីនាងឧមាយកទៅផឹក ស្រោចស្រពក្បាល មុខមាត់ ដើម្បីឱ្យមានសិរីសួស្តី ជ័យជំនះ បំបាត់ឧបទ្រពចង្រៃគ្រប់បែបយ៉ាង។ ទឹកដែលយកទៅស្រោចលើសិវៈលិង្គ និងយោនីនាងឧមា គឺ*

ជាទឹកត្រជាក់ត្រជុំ នាំមកនូវសិរីសួស្តី សម្រាប់មនុស្សផងទាំងពួង។ អ្នកណាបាន ចូលរួមពិធីលាងបាបនេះ នឹងបានសេចក្តី សុខគ្រប់ប្រការ។ ការប្រើទឹកក្នុងពិធីព្រហ្មញ្ញសាសនា គឺជាគោលគំនិតមួយទាក់ទងទៅ នឹងការជម្រះឱ្យមានភាពស្អាតទាំងផ្នែករូបរាងកាយ ទាំងផ្នែកផ្លូវសតិអារម្មណ៍។

ដោយការទទួលឥទ្ធិពលសាសនាហិណ្ឌូ-ព្រហ្មញ្ញសាសនា ព្រះបាទជ័យវរ្ម័នទី២ បានសន្មតយកភ្នំគូលែន ដែលព្រះអង្គយល់ថា ជាមេទឹក ជាកន្លែងនៃទឹកអម្រឹត ទឹកមន្តនៃភាពមិនស្លាប់ឬទឹកមន្តអមតៈ ដែលធ្លាក់ចុះមកផែនដីក្នុងអំឡុងពេលកូរសមុទ្ទទឹកដោះនៅឋានសួគ៌ ហើយហូរទៅកាន់ផ្ទៃប្រទេស តាម ព្រែក ស្ទឹង នានាដែលមានប្រភពហូរចេញពីភ្នំគូលែន។ ប្រទេសខ្មែរ ទាំងមុនសម័យអង្គរ ទាំងសម័យអង្គរ មានការគោរពធ្វើពិធីសិវៈរាត្រីដែរ ដោយគេបានសន្មតយកស្ទឹងសៀមរាបធ្វើជាទន្លេគង្គា ព្រោះស្ទឹងនេះមានប្រភពមកពីភ្នំគូលែនដែលត្រូវខ្មែរសន្មតថាជាភ្នំកៃលាស ជាទីស្នាក់អាស្រ័យរបស់ព្រះអាទិទេព។ នៅក្បាលស្ទឹងសៀមរាប ត្រង់អន្លង់អាចម៍ផ្កាយ និងនៅក្បាលស្ពាន គេបានកសាងលិង្គរាប់ពាន់ យកទៅតម្រៀបនៅបាតស្ទឹង (ជាយោនីនាងឧមា) ឱ្យទឹកហូរកាត់ពីលើលិង្គ និងយោនីនោះ ដើម្បីឱ្យមនុស្សនៅសៀមរាបឬនៅតាមបណ្តោយស្ទឹង ចុះធ្វើពិធីសិវៈរាត្រី ឬចុះមុជ ឬផឹក តាមចំណង់ចំណូលចិត្ត គ្រប់ទីកន្លែង និងគ្រប់ពេលវេលា។



លិង្គនៅភ្នំគូលេន

ចំពោះអ្នកនៅតំបន់ផ្សេងៗឆ្ងាយពីសៀមរាបគេបានយកទន្លេ និងស្ទឹងនានា មកសន្មតថាជាទន្លេគង្គា។ ចំពោះអ្នកនៅតំបន់ផ្សេងៗទៀតដែលគ្មាន ស្ទឹង អូរ ទន្លេ គេបានជីកជា បារាយ ស្រះ គូទឹក ហើយសន្មតថាជាទន្លេគង្គាសម្រាប់ប្រារពធ្វើពិធីសិវៈរាត្រី សម្រាប់យកទឹកធ្វើពិធីលាងបាបដែរ។ អាស្រ័យហេតុនេះ បានជារហូតមកដល់សព្វថ្ងៃនេះ មានកន្លែងជាច្រើននៅលើទឹកដីកម្ពុជាយើងមាន ទួលអង្គ ទួលក្រាំង

ដែលជាទីទួលខ្ពស់ ហើយមានបឹង ឬស្រះព័ទ្ធជុំវិញ យ៉ាងហោចណាស់ ក៏មានស្រែមានជម្រៅជ្រៅព័ទ្ធជុំវិញ ឬមានស្រះនៅពីមុខដែរ (ទួលអង្គ មានស្រះនៅពីមុខ គេហៅថា រហាល់)។ គេក៏ចាត់ទុកទឹកដែលស្ថិតនៅជុំវិញប្រាសាទឬទួលអង្គឬរហាល់នេះ ថាជា សមុទ្ទ ដែលគេកូរយកទឹកអម្រឹតដែលទាក់ទងនឹងរឿងកូរសមុទ្ទទឹកដោះ។



រូបភាពកូរសមុទ្រទឹកដោះ តាមរយៈផ្តែរនៅប្រាសាទធម្មនន្ទ ក្នុងតំបន់អង្គរ ខេត្តសៀមរាប

ការកូរសមុទ្ទទឹកដោះ ជានិម្មិតរូបនៃភាពតស៊ូស្វិតស្វាញ សាមគ្គីភាព ភាតរភាពដែលជាប្រពៃណីដ៏ល្អផូរផង់របស់ប្រជាជនខ្មែរតាំងពីបុរាណ ក្នុងការកសាងប្រទេសជាតិ ការការពារទឹកដី ការបង្កបង្កើនផល ។ល។ ដើម្បីឱ្យសមិទ្ធិផលទាំងអស់នេះទទួលបានជោគជ័យ គឺវាទាមទារឱ្យមនុស្សម្នាក់ៗចេះពួតដៃរួបរួមគ្នា និងជំនះរាល់ឧបសគ្គតូចធំទាំងពួងនៅគ្រប់កាលៈទេសៈទាំងអស់។ ជាក់ស្តែង យើងមើលពួកទេវៈនិងពួកអសុរៈ ដែលជាសត្រូវនឹងគ្នាស៊ីសាច់ហុតឈាម តែបែរជាផ្អាកសង្គ្រាម ហើយមករួបរួមគ្នាកូរសមុទ្ទទឹកដោះដើម្បីយកទឹកអម្រឹតចែកគ្នា។ រីឯទឹកអម្រឹត ដែលបានមកពីការកូរសមុទ្ទទឹកដោះនោះ គឺតំណាងជីវិត និងភាពត្រជាក់ត្រជុំ ដែលបានមកពីការរួបរួមគ្នា សាមគ្គីគ្នា នៃប្រជាជនគ្រប់ស្រទាប់វណ្ណៈ គ្រប់និន្នាការ។ ទង្វើនេះវាសរបញ្ជាក់ឱ្យឃើញថា នៅក្នុងប្រទេសមួយទោះបីជាមានក្រុមបក្សជាច្រើន ដែលមាននិន្នាការនយោបាយផ្សេងៗគ្នា ហើយតែងប្រឆាំងពាក្យសម្តីគ្នាយ៉ាងណាក៏ដោយ លុះដល់ពេលស្រុកទេស ជួបគ្រោះធម្មជាតិ មានបញ្ហាជាមួយបរទេស ដែលធ្វើឱ្យប្រជាពលរដ្ឋរងទុក្ខវេទនា ជួបគ្រោះទុរ្ភិក្ស មានជំងឺរាតត្បាត នោះបក្សទាំងអស់ត្រូវតែរួបរួមគ្នាសិន ហើយទុកប្រយោជន៍ផ្ទាល់ខ្លួន ទុកប្រយោជន៍បក្ស ដោយឡែកមួយអន្លើ មួយរយៈ ដើម្បីងាកមកដោះស្រាយប្រយោជន៍រួម រួមគ្នាក្នុងទិសដៅតែមួយ គឺរក្សាឱ្យបាននូវអធិបតេយ្យភាព បូរណភាពទឹកដី ជូនជាតិ មាតុភូមិ ព្រម

ទាំងនាំមកនូវសុខសន្តិភាព និងអភិវឌ្ឍនភាពដ៏បរិបូណ៌ជូនប្រជារាស្ត្រ។ នេះជាគំនិតទស្សនវិជ្ជាដ៏វិសេសវិសាលដែលបុព្វបុរសខ្មែរបានផ្ញើកន្ទងមក ហើយកូនខ្មែរជំនាន់នេះ ត្រូវតែដើរតាមមគ្គុទេសក៍នេះ។

**២- ទឹកសម្បថ** ជាទឹកដែលប្រជាពលរដ្ឋខ្មែរយកមកធ្វើជានិមិត្តរូបក្នុងការតាំងសច្ចាប្រណិធាន។ ខ្មែរយើងតែងមានជំនឿយ៉ាងខ្លាំងទៅលើទឹកមន្តនេះ។ ទឹកសម្បថ បានក្លាយជាធាតុដ៏សំខាន់ដែលមិនអាចខ្វះបាននៅក្នុងជំនឿរបស់ខ្មែរ ពីព្រោះ វាជាវត្ថុមួយដែលគេយកមកប្រើដើម្បីបញ្ជាក់ពីភាពស្មោះត្រង់ ភក្តីភាព និងជាឧបករណ៍ពិសោធន៍ផ្នែកចិត្តវិទ្យា។ ការឱ្យផឹកទឹកសម្បថ វាហាក់ដូចជា ការដាស់តឿនក្រើនរំលឹកដល់អ្នកស្បថទាំងអស់ឱ្យចងចាំនូវសម្តីរបស់ខ្លួនក្នុងការធ្វើអ្វីៗ ត្រូវធ្វើទៅតាមការធ្វើសច្ចាប្រណិធានរបស់ខ្លួន។

**៣- ទឹកមន្ត** ជាទឹកមង្គល ដែលព្រះសង្ឃសូត្រចម្រើនពុទ្ធមន្ត ឬទឹកដែលអ្នកចេះមន្តអាគមសូត្រផ្លុំ កូរសម្រាប់ស្រោចឬផ្ងូតបង្ការខ្លួន លុបលាងមុខ ផឹកព្យាបាលជំងឺ ដោះអំពើអំពាន់ផ្សេងៗ ឬចង្រៃតាមទម្លាប់អ្នកជឿ។ រាល់ពិធីបុណ្យទានផ្សេងៗ ក្នុងការសូត្រមន្ត គេតែងឱ្យព្រះសង្ឃរលាស់ប្រោះទឹកមកលើខ្លួន ក្នុងគោលបំណងសុំសេចក្តីសុខចម្រើន រំដោះគ្រោះឆ្នាំចាស់លើករាសីឆ្នាំថ្មីឱ្យមានសិរីសួស្តី។ ពេលចូលឆ្នាំ គេបានប្រមូលផ្តុំចាស់ៗក្នុងភូមិ នៅវត្តដើម្បីស្រោចទឹកជម្រះកាយ គេហៅថាពិធីស្រង់ព្រះ។ បុណ្យស្រង់ព្រះសុគន្ធវារី គេជឿថាអំណាចនៃព្រះសុគន្ធវារី (ទឹកក្រអូបដោយផ្កាភ្ញី)នឹងជួយឱ្យមនុស្សមានអាយុវែង និងរួចចាកកម្មពៀរវេរាទាំងពួង។

ក្នុងពិធីឡើងផ្ទះថ្មី ដើម្បីឱ្យផ្ទះថ្មីដែលគេឡើងទៅរស់នៅ ប្រកបដោយសេចក្តីសុខត្រជាក់ត្រជុំ សុខដុមរម្យនា មានជោគមានជ័យ សិរីមង្គលគ្រប់ប្រការ គេប្រើទឹកមន្តប្រោះព្រំ និងមានបទឧបកិច្ចដូចតទៅ៖ គេរកស្ត្រីដែលជាទីស្រលាញ់រាប់អានចំនួន៦នាក់ ហើយឧបកិច្ចឱ្យឈ្មោះថា នាងស្រីតំណាងសិរី និងភ័ព្វព្រេងសំណាង ជាអ្នកកាន់ផ្តិលឬក្អម។ ផ្តិលទឹកនោះបើបានធ្វើពីសំរិទ្ធទៀត រឹតតែល្អប្រពៃ ព្រោះសំរិទ្ធមានធាតុត្រជាក់ បានសេចក្តីថា តំណាងភាពត្រជាក់ត្រជុំ។ នាងរតន៍ តំណាងត្បូងគ្រប់

ប្រភេទឬកែវពេជ្រ ជាវត្ថុញុាំងចិត្តមនុស្ស ឱ្យត្រេកអរសប្បាយរីករាយ និងសេចក្តីល្អប្រសើរ ជាអ្នកកាន់ហិបម្លូស្លា។ ហិបម្លូស្លា ជាត្រីមុខ ឬជាប្រធាននាំមុខ ក្នុងការចចារ រាក់ទាក់ ទទួលភ្ញៀវដែលឡើងមកលើផ្ទះ។ នាងសួស្តី តំណាងសិរីសួស្តី និងមានសេចក្តីសុខស្រួល ជាអ្នកកាន់ជើងពានទ្រសំពត់អាវ។ នាងកែវ តំណាងទ្រព្យសម្បត្តិ មានមាសប្រាក់កែវកង ជាដើម ជាអ្នកកាន់ជើងពានដាក់គ្រឿងអលង្ការ។ នាងគង់ តំណាងភាពគង់វង្ស គឺគង់ទាំងទ្រព្យសម្បត្តិ និងជីវិតស្ថិតស្ថេរ ជាអ្នកកាន់កន្ទេលខ្នើយ។ នាងជ័យ តំណាងជោគជ័យ ជាអ្នកកាន់ខ្លាយឬក្អុក ព្រមទាំងមានគ្រឿងប្រដាប់ជាច្រើនទៀតសម្រាប់ធ្វើពិធីឡើងផ្ទះ។ បន្ទាប់មកទើបគេសែនព្រេនជូនតាជំនាងផ្ទះ ព្រះភូមិ ហើយព្រះសង្ឃសូត្រមន្តនិងប្រោះព្រំទឹកមន្តប្រសិទ្ធិពរជ័យ ។

**៨- ទឹកអង្គបំពង់ខ្ទី** គឺជាទឹកដែលគេដងស្រោចលើលិង្គហើយគេបុករុកលិង្គ ដែលតម្កល់លើយោនីនាងឧមា ហើយគេត្រងទឹកដែលហូរចេញតាមប្រឡាយយោនីនាងឧមា គេក៏សន្មតថា ជាទឹកអង្គបំពង់ខ្ទី។ ប្រជាជនខ្មែរនាំគ្នាត្រងទឹកអង្គបំពង់ខ្ទី យកមកផឹក លុបលាងមុខ ងូត ដោយគេមានជំនឿច្បាស់ថា នឹងបានសេចក្តីសុខ បានចម្រើន អាយុយឺនយូរ រកស៊ីមានបាន កើតកាលវាលគុម្ព ត្រជាក់ត្រជុំណាស់។ ទំនឹមទំនៀមក្នុងការឱ្យពរក្នុងពិធីអាពាហ៍ពិពាហ៍ អាចារ្យតែងឱ្យពរថា៖ សូមឱ្យកូនទាំង២ រស់នៅជួបជុំគ្នារហូតដល់ខាំបេករបូត ខាំពោតរបេះ ខ្មោចទាល់តម្រិះធ្វើមិនត្រូវ។ សូមឱ្យរស់នៅនិងរកស៊ីជាមួយគ្នា បានត្រជាក់ត្រជុំដូចទឹកអង្គបំពង់ខ្ទី។ អង្គ គឺលិង្គព្រះឥសូរ ចំណែកបំពង់ខ្ទី គឺយោនីនាងឧមា ។

**៩- ទឹកដោះម្តាយថ្លៃ** ជាពាក្យទំនឹមទំនៀមដែលបង្កប់ន័យថា៖ បើទឹកដោះម្តាយពិតជាថ្លៃ សូមឱ្យកូនគេចរួចផុតពីគ្រោះថ្នាក់នេះឬគ្រោះថ្នាក់នោះ។ ដោយសារទឹកដោះម្តាយថ្លៃ ទើបឈាមកូនអណ្តែត ជាដើម។ ខ្មែរឧទានពាក្យនេះ នៅពេលគេជួបឧបសគ្គភ័យអាសន្ន ឬគ្រោះថ្នាក់ផ្សេងៗ ដែលមានន័យថា ជានិមិត្តរូបនៃរបបមាតាបតេយ្យ ដែលម្តាយមានភារៈសំខាន់ក្នុងការចិញ្ចឹមបីបាច់ ការពារកូនទាំងនៅជិត ទាំងនៅ

ធ្លាយ ទោះតាមអារម្មណ៍ក៏ដោយ។ ទឹកដោះម្ដាយថ្ងៃ ជានិមិត្តរូបនៃព្រហ្មវិហារធម៌របស់ម្ដាយចំពោះកូន។

**៦- ទឹកក្ងស់ ឬ ទឹកស័ង្ខ** គឺជាទឹកមង្គលដែលស្រោចពីលើព្រះសិរ (ក្បាល) ព្រះរាជាក្នុងការអភិសេកឱ្យពេញទីជាក្សត្រ។

**៧- ទឹកជាស្ពានចម្លង** (ជាមធ្យោបាយសម្រាប់ផ្ញើរដំណឹងឬផ្ញើររបស់របរ) ក្នុងការឧទ្ទិសមគ្គផលទៅឱ្យបុព្វការីបុគ្គលដែលបានចែកឋានទៅហើយ ពេលសូត្រវេរអ្វីៗទៅដល់បុព្វការីបុគ្គលដែលបានចែកឋានទៅហើយ គេតែងច្រូចទឹក។

**៨- ទឹក ជា វត្ថុសម្រាប់លាងជម្រះ និងប្រភពនៃសិរីសួរស្តី៖** សិរីសួរស្តីពេលព្រឹកកើតមាន កាលបានយកទឹកមកលុបលាងមុខក្រោយពេលភ្ញាក់ពីដេក។ សិរីសួរស្តីពេលថ្ងៃកើតមាន កាលបានយកទឹកមកលាបសំឡាបដើមទ្រូង។ សិរីសួរស្តីពេលល្ងាច-យប់ កើតមានកាលបានយកទឹកមកលាងជើងមុនពេលចូលគេង។

ក្នុងពិធីអាពាហ៍ពិពាហ៍ខ្មែរ គេយកទឹកមកលាងជើង គឺមានន័យថា កាលពីមិនទាន់រៀបការ កូនប្រុស កូនស្រី អាចនឹងមានការជំពាក់វាក់វិនជាមួយអ្នកផ្សេង ជាសង្សារ គូរកំណាន់ ឯណានិមួយៗក្តីសូមឱ្យលះបង់ឱ្យស្អាតទាំងពីរនាក់ ហើយចាប់ដៃគ្នាកសាងមង្គលលើទ្រនំថ្មី កុំបីមានអ្វីល្អក់កករឡើយ។ រឿងរ៉ាវឧបទ្រពទាំងអម្បាលម៉ាណ ឱ្យវារលាយសាបសូន្យហូរទៅតាមទឹក។

ក្នុងផ្នត់គំនិតខ្មែរ ចាត់ទុកទឹក ជាប្រភពនៃជីវិត ទឹកជាប្រភពនៃអំណាច។ គ្រប់ពីធីសាសនា គេប្រើទឹកប្រោះព្រំដើម្បីបណ្តេញឧបទ្រពចង្រៃ។

ខ្មែរមានជំនឿថា ទឹក ជាវត្ថុស្អាតស្អំសម្រាប់លាងជម្រះបាបកម្ម។ កាលណាមនុស្សស្លាប់ទៅ គេយកសពមកលាងសម្អាតនឹងទឹក (ចម្អាសទឹក) ឱ្យស្អាត ដើម្បីឱ្យទៅចាប់ជាតិជាថ្មី បានស្អាតបរិសុទ្ធ គ្មានកម្មពៀរវេរា។

**៩- ទឹក ប្រើក្នុងតម្រាព្រហ្មគតិ៖** ឆ្នាំជូត (កណ្តុរ) ឆ្នាំកុរ (ជ្រូក) មានធាតុ ទឹក ជាធាតុត្រជាក់ត្រជុំ ជាធាតុពន្លត់ភ្លើង។

**សន្និដ្ឋាន**

សរុបសេចក្តីមកយើងឃើញថា ជំនឿរបស់ជនជាតិខ្មែរ ទាំងនៅពេលកើត ទាំងក្នុងជីវភាពរស់នៅ ទាំងពេលរៀបការ ទាំងពេលស្លាប់ និងទាំងការប្រតិបត្តិជំនឿសុទ្ធតែផ្សារភ្ជាប់ទៅនឹងអាបោ (ទឹក) ដោយចាត់ទុក ទឹក ជាប្រភពនៃជីវិត ជាប្រភពនៃអំណាចឬឥទ្ធិពល។ គំនិតទស្សនវិជ្ជាដែលឆ្លុះបញ្ចាំងតាមរយៈការប្រតិបត្តិ ការប្រោះព្រំទឹកមន្តដោយសំយោគលក្ខណៈជាព្រាហ្មសាសនានិយម និងលក្ខណៈជាពុទ្ធសាសនានិយម និងជីវចលនិយម រមែងជួយប្រជាជនខ្មែរឱ្យជៀសផុតពីឧបទ្រពចង្រៃនានា។ គំនិតទស្សនវិជ្ជានេះជាជំនួយក្នុងការឃុំគ្រងចិត្តគំនិត និងការរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋក្នុងសង្គមខ្មែរ ហើយវានៅតែមានអត្ថិភាពជានិរន្តន៍តាំងពីបុរាណកាលរហូតមកដល់សព្វថ្ងៃនេះ ហើយប្រសិនបើវានៅតែមានប្រយោជន៍ យើងត្រូវតែអភិរក្ស និងអភិវឌ្ឍន៍វា។

**ឯកសារពិគ្រោះ**


១- កែវ ណារុំ៖ តន្ត្រីនិងជីវិតខ្មែរ ឆ្នាំ ១៩៩៥។

២- គង់ សុខហេង៖ ឈ្វេងយល់អំពីទឹកក្នុងអរិយធម៌ខ្មែរ ភ្នំពេញ រោងពុម្ពពេជ្រ ណៃត បោះពុម្ពលើកទី១ ឆ្នាំ២០១០។

៣- ជួនណាត(សម្ដេចសង្ឃរាជ)៖ វចនានុក្រមខ្មែរ (ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ ភាគ ១ និងភាគ២) បោះពុម្ពនៅរោងពុម្ពកម្ពុជា បោះពុម្ពលើកទី៥ ព.ស.២៥១១/គ.ស. ១៩៦៧។

៤- ធ សោះ ព្រហ្មញ្ញសាសនា និងសង្គមខ្មែរ ភ្នំពេញ ឆ្នាំ១៩៩៤។

៥- លី សុវីរ៖ អរិយធម៌ខ្មែរទាក់ទងនឹង អក្សរសិល្ប៍ ភ្នំពេញ ២០០៧។

៦- ពុទ្ធសាសនបណ្ឌិត្យ៖ ប្រជុំរឿងព្រេងខ្មែរភាគ១ដល់ភាគ៩ បោះពុម្ពក្រសួងអប់រំ ឆ្នាំ ២០០៣ រឿងនិទានទាក់ទងនឹងបុណ្យចូលឆ្នាំខ្មែរ ។

៧- Gunner SkirbbeK ang Nils Gilje : A History of Western Thought (from ancient Greece to the twentieth century), New York, London, Routledge, English translation, first published, 2001.

# ទស្សនវិជ្ជាខ្មែរអំពីលំហ (ទេសភាពឬទីកន្លែង)

(Khmer Philosophy of Space)

*ដោយៈ លោកបណ្ឌិត* **ប៉ាន់ ទុន្លា**

*ប្រធានស្តីទីនាយកដ្ឋានទស្សនវិជ្ជានិងសង្គមវិជ្ជា*

*នៃវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម*

*រាជបណ្ឌិត្យសភាកម្ពុជា*

## សេចក្តីផ្តើម

*ស្វ័យភាពនៃគំនិត ដែលយើងបានរកឃើញឬយល់ដឹងតាមរយៈការផ្តោតអារម្មណ៍ ការគិតទៅលើទេសភាពឬទីកន្លែងមួយ គឺជាការបង្ហាញឱ្យឃើញពីចំណង់ចំណូលចិត្ត ការស្រលាញ់ តម្រូវការ និងការឱ្យតម្លៃចំពោះទីកន្លែង(លំហខាងក្នុង) ហើយទីកន្លែងក៏បង្ហាញរូបរាង និងឥទ្ធិពលដោយខ្លួនឯងទៅលើស្មារតីអារម្មណ៍ ការយល់ដឹង និងគំនិតរបស់មនុស្សវិញដែរ (លំហខាងក្រៅ) ។*

*តាមរយៈវត្ថុវិស័យភាពក្នុងទេសភាពមួយ (វត្ថុរូបវន្តក្នុងលំហ) គេអាចវិភាគ បកស្រាយពីលក្ខណៈនិមិត្តរូបរួម ធាតុបង្កុំក្នុងរចនាសម្ព័ន្ធ ដូចជា សមាសធាតុ ទំហំ រូបរាង ប្រភេទសណ្ឋានខាងក្នុង-ក្រៅ និងគុណតម្លៃនៃលំហ ទាក់ទងទៅនឹងចេតនាក្នុងគំនិត (លំហគំនិត) របស់មនុស្ស។*

**ទស្សនវិជ្ជាខ្មែរអំពីលំហ (ទេសភាពឬទីកន្លែង)** *បានសបញ្ជាក់ឱ្យឃើញថា ទឹកដីភូមិដ្ឋានរស់នៅរបស់ប្រជាជនខ្មែរ បានឆ្លុះបញ្ចាំងអំពីការប្រើគំនិត ចំណេះដឹង ប្រាជ្ញា គោលបំណងផ្សេងៗ សមត្ថភាពខាងបច្ចេកទេស សកម្មភាពអនុវត្តក្នុងជីវភាពប្រចាំថ្ងៃ ទំនាក់ទំនងរបស់មនុស្សចំពោះភាពសំខាន់របស់ទេសភាពឬទីកន្លែងក្នុងបរិបទ ជំនឿ សាសនា ទំនៀមទម្លាប់ ប្រពៃណី អក្សរសិល្ប៍ ប្រវត្តិសាស្ត្រ វប្បធម៌ សេដ្ឋកិច្ច ច្បាប់ នយោបាយ សង្គមកិច្ច... ហើយមានការវិវត្តទៅតាមសម័យកាលផងដែរ។*

### នេះជាទស្សនៈវិជ្ជាខ្មែរមួយចំនួនទាក់ទងទៅនឹងលំហ (ទេសភាពឬទីកន្លែង)៖

*១ - ការតាំងភូមិដ្ឋាន ការសង់លំនៅដ្ឋាននៅក្នុងកន្លែងណាមួយ បុព្វបុរសខ្មែរ មិនមែនធ្វើតាមតែនឹកឃើញនោះទេ គឺគេជ្រើសរើស*

ផ្អែកលើបទពិសោធន៍អព្ភន្តរញាណ និងវិចារញ្ញាណពុទ្ធិ រួមផ្សំនឹងការគុណគូរក្បួនហោរាសាស្ត្រផងដែរ។ មុនពេលសាងសង់ផ្ទះ គេជឿលើក្បួនហោរា គេទៅឱ្យហោរាឬលោកអាចារ្យគន់គូរមើល ទឹកដីព្រះភូមិ និងរកថ្ងៃមានពេលាល្អដើម្បីសាងសង់ និងឡើងរស់នៅលើផ្ទះនោះ។ ក្នុងទស្សនៈរបស់ខ្មែរ ទីតាំងមួយដែលមានដើមអំពិលពីខាងត្បូង អណ្ដូងពីខាងលិច គេមិនជ្រើសរើសជាកន្លែងសង់ផ្ទះទេ ព្រោះស្ថិតក្នុងវិថីព្រាយបិសាចឆ្លងកាត់ ដែលធ្វើឱ្យម្ចាស់ផ្ទះរស់នៅមិនបានសុខទេ។

២- ខ្មែរប្រើប្រាស់ទេសភាពឬទីកន្លែង ជាទីស្បថ បញ្ជាក់សីលធម៌ ភាពស្មោះត្រង់ សច្ចភាព និងជាទីផ្សងព្យាករណ៍ហេតុភេទ ផ្សេងៗដែលអាចនឹងកើតមានឡើងក្នុងអនាគត។ លើសពីនេះទៅទៀត មានកាប់អ្វីចំណាំនៅកន្លែងណាមួយជាសាក្សីផងដែរ។ ឧទាហរណ៍ អញកាប់ថ្មចំណាំកន្លែងហ្នឹង ចាប់ពីថ្ងៃនេះតទៅ... ជាដើម។ ពេល មានរឿងវិវាទត្រូវស្បថ គេទៅស្បថនៅវត្តឬនៅកន្លែងសក្តិសិទ្ធ ដូចជា នៅកន្លែង ព្រះអង្គជង់កើ អង្គរវត្ត ជាដើម។

៣- ការរៀបចំក្បួនរីតី ក៏គេត្រូវជ្រើសរើសទីកន្លែង ដែរ ដូចជា ព្រះបាទជ័យវរ្ម័នទី២ ជ្រើសរើសយកភ្នំគូលែន ធ្វើពិធីទេវរាជ។ រាជបុរោហិតរៀបចំពិធីផ្សងនៅលើភ្នំបាយង់កោ។ ក្នុងពិធីអកអំបុក និងសំពះព្រះខែ គេរៀបចំពិធីផ្សងនៅព្រះបរមរាជវាំង។

៤- ទីកន្លែងក៏មានទាក់ទងនឹងការបង្កើតរឿង និទានអក្សរសិល្ប៍ ទាក់ទងនឹងស្ថាននាម តួអង្គអធិធម្មជាតិ និងអ្នកតាអ្នកដូន ផងដែរ។ អក្សរសិល្ប៍ប្រជាប្រិយខ្មែរបង្កប់លក្ខណអត្តសញ្ញាណជាតិខ្មែរដូចជា៖ អត្តសញ្ញាណជាគ្រឿងសម្គាល់លក្ខណជាតិ មានដូចជា ភូមិសាស្ត្រ ឈ្មោះទីកន្លែង ប្រវត្តិសាស្ត្រ ការគ្រប់គ្រង វប្បធម៌ មនុស្ស សត្វ និងរុក្ខជាតិ ដែលប្រជាជនខ្មែរនិយមប្រើប្រាស់ក្នុងការរស់នៅ។ ឧទាហរណ៍ ដូចជា រឿងភ្នំប្រុសភ្នំស្រី រឿងភ្នំដូនពេញ រឿងភូមិតិរច្ឆាន ជាដើម។

៥- ក្នុងទស្សនវិជ្ជាខ្មែរ ទីកន្លែង មានភេទភាវៈជា ស្រី។ គំនិតមួយក្នុងការប្រើពាក្យមាតុភូមិ ជាទស្សនវិជ្ជាដែលកំណត់ភេទភាវៈជាស្រី ជាម្ចាស់កម្មសិទ្ធិទឹកដី ជាអត្តសញ្ញាណមាតាធិបតេយ្យ។ សំណង់ស្ថាបត្យកម្មខ្មែរបុរាណក្រុងអង្គរ គឺ តំណាងភេទប្រុស ដែលមានគូរទឹកព័ទ្ធជុំវិញតំណាងភេទស្រី ។ តួប្រាសាទជាលិង្គ(ដីឬប្រុស) កសិណទឹកជា

យោនីនាងឧមា(ទឹកឬស្រី) ទឹកអម្រឹតក្នុងគូទឹក (សូមមើលរូបក្នុងឧបសម្ព័ន្ធ)។

៦-ខ្មែរពីបុព្វកាលមានការធ្វើឋានីយកម្មធម្មជាតិ និងវប្បធម៌ ដោយការរៀបចំភូមិជារាងមូល(ភូមិមូល)។ការប្រែក្លាយ ទេសភាពធម្មជាតិមកជា ទេសភាពវប្បធម៌ មិនមែនជាការចៃដន្យទេ តែវាជាចេតនាគំនិត ដែលឆ្លុះបញ្ចាំងពីគំនិតទស្សនវិជ្ជា ៖ មូល តំណាង វដ្តជីវិត ដែលបុព្វបុរសខ្មែរយល់ថា ដើមនិងចុង ហើយ កើតនិងស្លាប់ នៅជាប់គ្នា។ ផ្ចិតរង្វង់មូលជាមជ្ឈមណ្ឌលរដ្ឋបាលទៅសព្វទិសទីមានចំងាយស្មើគ្នាក្នុងដែនរង្វង់ ងាយស្រួលគ្រប់គ្រង ការពារសន្តិសុខ និងផ្តល់-ទទួលព័ត៌មាន។

៧- ទស្សនៈលោកធាតុនិយមខ្មែរ ជាទស្សនវិជ្ជាមួយ ជាប់ទាក់ទងលោកទស្សនៈអស្តិរូបវិជ្ជាក្នុងព្រហ្មញ្ញសាសនា និងពុទ្ធសាសនា៖ ក្នុងលោកធាតុវិទ្យានៃលទ្ធិព្រហ្មញ្ញ សាសនាបានចែងថា ពិភពលោកយើងនេះមានរាងជាបួនជ្រុងសំប៉ែតស្មើ ដែលនៅចំកណ្តាលមានទ្វីបមួយយ៉ាងធំឈ្មោះ ថា ជម្ពូទ្វីប។ ជម្ពូទ្វីប មានទ្វីបតូចចំនួនប្រាំមួយទៀត ព្រមទាំងមហាសមុទ្រដែលហ៊ុមព័ទ្ធជុំវិញដោយជួរភ្នំជាកំពែង។ នៅចំកណ្តាលជម្ពូទ្វីប គេឃើញមានភ្នំមួយខ្ពស់ជាងគេ គឺភ្នំសុមេរុជាចន្ទល់ ឬជាស្នូលនៃចក្រវាឡ។ នៅលើកំពូលភ្នំសុមេរុ គឺជាឋានទេវលោក ឬឋានរបស់ព្រះអាទិទេព។ ម្យ៉ាងវិញទៀតទេវឋាននេះមានទិសប្រាំបី ដែលទ្រទ្រង់បីបាច់ថែរក្សា ដោយទេពបន្ទាប់បន្សំទាំងប្រាំបីអង្គ ដែលជាឆ្មាំប្រកបដោយជ័យចេស្តាដ៏ខ្លាំងពូកែអស្ចារ្យ។ ក្នុងសម័យអង្គរ នគរូបនីយកម្មប្តូរពី ភូមិមូល មក ភូមិ៤ជ្រុង ការកសាងប្រាសាទភ្នំ មានគូរទឹកព័ទ្ធជុំវិញរាង៤ជ្រុង ដែលបង្ហាញនូវនិមិត្តរូបទំនាក់ទំនង ទឹក ដី ភ្លើង ខ្យល់។ ក្នុងគោលការណ៍សោភណវិជ្ជា សិល្បករខ្មែរសម្តែងនូវគំនិតឬទស្សនៈផ្សារភ្ជាប់លោកិយនិងបរលោក ផ្សារភ្ជាប់អាត្ម័ននិងព្រហ្ម័ន (សេចក្តីប្រាថ្នាធំធេងគឺទាញទេវលោកមកនៅជាមួយមនុស្សលោក ឬទាញមនុស្សលោកឱ្យនៅប្រប និងទេវលោក) ដែលមានអត្ថន័យ និងអត្ថប្រយោជន៍ទូលំទូលាយវែងឆ្ងាយ ហើយប្រកបដោយឧត្តមគតិខ្ពស់។ លោកធាតុវិជ្ជាខ្មែរក៏ដូចលោកធាតុវិជ្ជាឥណ្ឌាដែរ គឺត្រូវធ្វើឱ្យមានភាពចុះសម្រុងដោយសម្បមាណឥតខ្ចោះរវាងឋានក្រោម និងឋានលើ ហើយទាល់តែមានការគោរពមិនធ្លាំធ្លង សម្បូងសម្រួងដោយពិធីបូជាទើបជានាស្ថេរភាព និងវិបុលភាពដល់សង្គម។

និមិត្តរូបនៃទីក្រុងខ្មែរគឺ ៖ ទឹកដី = ស្រីប្រុស=មេបា= លិង្គយោនី = ចក្រវាឡ => សង្គម/ក្រុង/នគរ។ ទីក្រុងខ្មែរត្រូវតែនៅខាងត្បូងនៃភ្នំសក្ការៈ ដែលព្រះអាទិទេពគង់នៅបែរមុខទៅ

ទិសខាងកើត ហើយជាមួយគ្នានោះដែរ នៅលើប្រសព្វគ្នានៃទន្លេ ដែលនាគញី ឈ្មោល អាចជួបគ្នាបាន ហើយទ្រទ្រង់នូវជំនឿទាំងអស់អំពីទឹក។ រាជធានីអង្គរបានគោរពរៀងៗមកនូវគំរូនេះ ដោយប្រើប្រាស់ទិន្នន័យធម្មជាតិ ទួល និងព្រែក។ ប្រសាទភ្នំ និងបារាយណ៍ដែលចញ្ចឹមដោយព្រែក គឺគ្មានអ្វីក្រៅពីភ្នំសក្ការៈ និងទន្លេប្រសព្វសិប្បនិម្មិតទេ។ គំរូនេះ នៅតែបន្តដល់ការកសាងទីក្រុងក្រោយសម័យអង្គរ ដូចជា ក្នុងការជ្រើសរើសទីតាំងកសាងទីក្រុងភ្នំពេញ (ដូចគ្នាដែរ ទីក្រុងលង្វែក ទីក្រុងឧត្តុង្គ) ក៏បានធ្លុះបញ្ចាំងលក្ខណៈនេះដែរ។ ទួលភ្នំខាងជើងលើកឡើងឱ្យខ្ពស់ សម្រាប់ជាទីសក្ការៈវត្ត និងវាំង ត្រូវរៀបចំ តាមពិធីឱ្យនៅខាងត្បូង ហើយបែរមុខទៅខាងកើត លើកន្លែងជួបគ្នានៃទន្លេទាំង៤។

៨- យោងតាមទ្រឹស្តីទស្សនវិជ្ជានាមនិយមអះអាងថា ៖ បញ្ញត្តិ សំខាន់ជាង វត្ថុជាក់ស្តែង។ វត្ថុជាក់ស្តែង ស្លាប់ឬបាត់បង់ទៅវិញ តែ នាមបញ្ញត្តិ រស់អមតៈ។ ការដាក់ស្ថាននាមក្នុងទស្សនៈខ្មែរផ្អែកលើ៖ ស្ថានភាពភូមិសាស្ត្រ នាមរុក្ខជាតិ នាមតាមសត្វ នាមតាមឈ្មោះនិងភេទមនុស្ស នាមតាមព្រឹត្តិការណ៍ប្រវត្តិសាស្ត្រ។ល។ ការកំណត់ស្ថាននាមទេសភាពឬទីកន្លែង ដូចជា កំពង់ ក្រាំង គោក ទួល ទំនប់ អង្គ អង្គរ កោះ តាំង... គឺធ្លុះបញ្ចាំងពីគំនិតខ្មែរដើម្បីរក្សាប្រវត្តិដើម មូលហេតុ វិធីកំណត់ឈ្មោះ រំលេចចេញនូវតឹកតាង ឈ្មោះអ្នកបង្កើត និងអ្នកធ្វើសកម្មភាពទៅលើទេសភាពក្នុងអតីតកាល។ ឧទាហរណ៍ ដូចជា ភូមិភ្លើងឆេះរទេះ ភូមិទួលពង្រ អង្គតាសោម ក្រុងដូនកែវ ក្រុងភ្នំពេញ អូរឈើទាល បឹងស្នោ ក្រាំងពង្រ តាំងគោក ស្រះស្រង់ ភូមិតិរច្ឆាន ជាដើម។ ជាងនេះទៅទៀត ស្ថាននាមធ្លុះបញ្ចាំងពីគុណតម្លៃនៃគំនិត មនោគមន៍វិជ្ជា ប្រវត្តិរឿងរ៉ាវក្នុងភូមិដ្ឋាន និងលក្ខណៈពិសេសផ្សេងៗដែលមាននៅក្នុងទីកើតហេតុ។ ស្ថាននាមអាចបញ្ជាក់ពីអត្តសញ្ញាណទីកន្លែង បន្សល់ជាមរតកវប្បធម៌ ប្រពៃណីតំបន់ រក្សាអត្តសញ្ញាណជាតិ កសាងប្រវត្តិសាស្ត្រជាតិ និងស្ថាននាមរដ្ឋបាល ដល់អ្នកជំនាន់ក្រោយ។ ស្ថាននាមគឺជាមត៌កជាតិមួយដ៏ថ្លៃថ្លាសម្រាប់សម្គាល់អត្តសញ្ញាណជាតិខ្មែរនិងភូមិសាស្ត្រវប្បធម៌ និងឫសគល់ ប្រវត្តិសាស្ត្រផងដែរ។

## សេចក្តីសន្និដ្ឋាន

សរុបសេចក្តីមក យើងអាចសន្និដ្ឋានថា វត្តមាន **លំហ** (**ទេសភាព ឬ អាកាស ឬ ទីកន្លែង**) មានពាក់ព័ន្ធគ្រប់ផ្នែក គ្រប់វិស័យ គ្រប់សកម្មភាព និងមានសារៈសំខាន់ក្នុងជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាជនខ្មែរ។ គ្រប់វិស័យទាំងអស់នៅក្នុងសង្គមខ្មែរ ដូចជា នយោបាយ

សេដ្ឋកិច្ច កសិកម្ម សិប្បកម្ម ឧស្សាហកម្ម ពាណិជ្ជកម្ម ការអប់រំ វប្បធម៌ ទំនៀមទម្លាប់ ប្រពៃណី ជំនឿ សាសនា ច្បាប់ សង្គមកិច្ច សុខាភិបាល រដ្ឋបាល ការចងក្រងប្រវត្តិសាស្ត្រ ការដាក់ស្ថាននាម ការរៀបចំនគរូបនីយកម្ម ការរៀបចំទីទួលភូមិឋាន ការសាងសង់សំណង់លំនៅដ្ឋាន ការសាងសង់សំណង់ប្រាសាទ ទីសក្ការៈ និងការប្រារព្ធពិធីក្បួនរីតី ការរៀបចំកន្លែងកប់សព ការរៀបចំទីកសិកម្ម ជីវដ្ឋាន ជលដ្ឋាន ប្រព័ន្ធគមនាគមន៍ ប្រព័ន្ធធារាសាស្ត្រ ការរៀបចំទីក្រុង ។បេ។ និង ។បេ។ សុទ្ធតែត្រូវបានបង្កើតចេញពីអានុភាពគំនិតទស្សនវិជ្ជាស្ដីអំពី **លំហ** (**ទេសភាព ឬ ទីកន្លែង**) ទាំងអស់ ហើយវាក៏ផ្ទុះបញ្ចាំងពីផ្នត់គំនិត អត្តចរិត អាកប្បកិរិយា របៀបរស់នៅ អន្តរទំនាក់ទំនងរវាងមនុស្សជាមួយទេវ អន្តរទំនាក់ទំនងរវាងមនុស្សជាមួយអមនុស្ស និងជោគជតារាសីក្នុងការរស់នៅរបស់ប្រជាជនខ្មែរផងដែរ។

## ឯកសារពិគ្រោះ


១- ឈឹម សុខាន់ដារ៉ា ៖ *ទេសភាពវប្បធម៌នៅស្ថានីយ៍កណ្ដាក* (និក្ខេបបទបណ្ឌិត) ភ្នំពេញ ឆ្នាំ២០១៤។

២ - នុត ណារ៉ាំង ៖ *ទីក្រុងទឹកអង្គរជំហរអារ្យធម៌ខ្មែរ* ភ្នំពេញ រោងពុម្ពពន្លឺពេជ្រ បោះពុម្ពឆ្នាំ ២០០៣។

## ឧបសម្ព័ន្ធ



*រូបភាពលិង្គ និង យោនី សង់នៅលើភ្នំគូលេន*




*រូបភាពពីលើអាកាសនៃប្រាសាទអង្គរវត្តដែលឃើញតួប្រាសាទ និង គូទឹក (ប្រភព៖* Google Earth)

# ទស្សនៈមូលដ្ឋាននៃប្រជាសាស្ត្រ

## Basic Concept of Demography

*ដោយៈ* **លោក ហៃ សុគន្ធា**
*ប្រធានស្តីទីនាយកដ្ឋានភូមិវិទ្យានិងនគរូបនីយកម្ម*
*នៃវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម*

## សេចក្តីផ្តើម

*បើនិយាយអំពីប្រជាសាស្ត្រ គឺគេនឹកឃើញភ្លាមអំពីប្រជាជន។ ជាការពិត ប្រជាសាស្ត្រ គឺជាការសិក្សាអំពីប្រជាជន ហើយពិសេសអំពីភាពបង្កើតកូន រៀបការ ការស្លាប់ និងបំលាស់លំនៅ និងទំនាក់ទំនងនៃការសិក្សាបែបវិទ្យាសាស្ត្រអំពីទំហំ របាយភូមិសាស្ត្រ និងសមាសភាពប្រជាជន និងការប្រែប្រួលគ្រប់ពេលវេលា។ បើតាមន័យសំខាន់នៃប្រជាសាស្ត្រ គឺផ្តោតការសិក្សាសំខាន់អំពី "ស្ថានភាពនិងចលនានៃមនុស្ស" ហើយការសិក្សាដែលច្បាស់ជាងនេះទៀត គឺការពង្រីកសញ្ញាណនៃពាក្យ "ស្ថានភាព" និង "ចលនា"។[1] ម្យ៉ាងទៀត ពាក្យប្រជាសាស្ត្រនេះ ត្រូវបានកំណត់និយមន័យដោយស្ថាប័នផ្សេងៗ ដូចជាៈ*

*តាមនិយមន័យ របស់អង្គការសហប្រជាជាតិនៅឆ្នាំ១៩៥៨ បានពន្យល់ថា "ប្រជាសាស្ត្រ គឺជាការសិក្សាអំពីប្រជាជនតាមបែបវិទ្យាសាស្ត្រ ជាបឋម ដោយគោរពតាមចំនួនរបស់វា ទម្រង់របស់វា និងការអភិវឌ្ឍរបស់វា។ ប្រជាសាស្ត្រ គឺជាការសិក្សាអំពីទំហំ របាយដែនដី និងសមាសភាពរបស់ប្រជាជន ការប្រែប្រួលក្នុងរឿងប្រជាជន និងសមាសភាគនៃការប្រែប្រួល ដែលអាចធ្វើអត្តសញ្ញាណបាន ដូចជា ជាតិប្រមាណ មរណប្រមាណ ចលនាដែនដី (បម្លាស់លំនៅ) និងចល័តភាពសង្គម (ការផ្លាស់ប្តូរស្ថានភាព)។*

*និយមន័យខ្លះកំណត់ថា ប្រជាសាស្ត្រ គឺជាការសិក្សាតាមបែបស្ថិតិ និងគណិតវិទ្យារបស់ទំហំ សមាសភាព និងរបាយក្នុងទំហំរបស់ប្រជាជន ជាមួយនឹងបម្រែបម្រួលតាមពេលវេលាជាក់ស្តែងក្នុងទិដ្ឋភាពមួយ ដោយឆ្លងតាមការអនុវត្តនៃដំណើរការទាំង៥ របស់ភាពបង្កើតកូន មរណប្រមាណ អាពាហ៍ពិពាហ៍ បម្លាស់លំនៅ និងចល័តភាពសង្គម។ ទោះបីជាវានៅរក្សាការវិភាគតាមបែបប្រៀបធៀបនិងរៀបរាប់បន្តរបស់ទំនោរ*

---

*[1] មជ្ឈមណ្ឌលសិក្សាស្រាវជ្រាវអំពីប្រជាជន សាកលវិទ្យាល័យភូមិន្ទភ្នំពេញៈ ឯកសារប្រើប្រាស់ផ្ទៃក្នុង "សញ្ញាណទូទៅ និងបញ្ញតិមូលដ្ឋាន" ២០០៩ ទំព័រទី១*

ក្នុងដំណើរនីមួយៗនិងក្នុងលទ្ធផលពិតរបស់វាក៏ដោយ ក៏គោលបំណងយូរអង្វែងរបស់វាគឺអភិវឌ្ឍអង្គទ្រឹស្ដីដើម្បីពន្យល់ព្រឹត្តិការណ៍ ដោយធ្វើជាក្រាហ្វ។

ជារួមប្រជាសាស្ត្រ គឺជាការសិក្សាអំពីប្រជាជនដោយយកចិត្តទុកដាក់ ជាពិសេសទៅលើភាពបង្កើតកូន (កើត) មរណប្រមាណ (ស្លាប់)និងការផ្លាស់ទីលំនៅ(ចលនាដែនដី)។ ដោយ សារអថេរនៃសមាសភាគទាំងបីនេះហើយដែលជាកត្តាធ្វើឱ្យមានការប្រែប្រួលចំនួនប្រជាជន។ ការប្រែប្រួលនៃចំនួនប្រជាជន ត្រូវបានវាស់ដោយអត្រាកើត អត្រាស្លាប់ និងអត្រាផ្លាស់ទីលំនៅ ពោលគឺសមាសភាគទាំងបីនេះ ជាកត្តាកំណត់ចំនួនប្រជាជន ដោយសមាសភាពតាមអាយុរបស់វា និងល្បឿននៃការកើនឡើង និងថយចុះរបស់វា។

លំនាំជាច្រើននាសម័យបុរាណ ដូចជាអជ្ញាបញ្ហាសាសនា បញ្ហាទីក្រុង សង្គ្រាម បាននាំឱ្យមានការយកចិត្តទុកដាក់យ៉ាងខ្លាំង ទៅលើបញ្ហាប្រជាជន ក្នុងបំណងប្រមូលទាសករ កេណ្ឌកងទ័ព និងការយកពន្ធដារ ជាដើម។ ការរាប់ចំនួនមនុស្ស អាចនិយាយបានថា ជាមុខងារប្រវត្តិសាស្ត្រឬជាសារពើពន្ធ ដូចជា នៅចុងសតវត្សរ៍ទី១៧ សេដ្ឋកិច្ចនិងវិទ្យាសាស្ត្រមានការរីកចម្រើនជាលំដាប់ ហើយនាំទៅដល់ការធ្វើស្ថិតិមនុស្ស ដែលមានមុខងារនិងតួនាទី ពណ៌នាអំពីស្ថានភាពរបស់ប្រជាជន។

ដោយឡែក សង្គ្រាមនៅទ្វីបអឺរ៉ុប បានអនុគ្រោះដល់ប្រទេសកំណើតនិយម ពិសេសនៅក្រោយឆ្នាំ១៨៧០។ ប្រទេសបារាំង និងប្រទេសអាណានិគមកិច្ចផ្សេងទៀត គឺជាលំនាំមូលដ្ឋានសំខាន់ ដែលផ្ដល់ផលប្រយោជន៍ដល់បញ្ហាប្រជាសាស្ត្រ ដូចជា ការបរាជ័យនៅឆ្នាំ១៨៧០ និងក្រោយសង្គ្រាមលោកលើកទី១ ពោលគឺប្រជាសាស្ត្រ ត្រូវបានចាត់ទុកជាបញ្ហាសំខាន់ ចំពោះប្រទេសនីមួយៗ ដែលមានតម្រូវការមនុស្សប្រកបដោយសុខភាពល្អ ដើម្បីបង្កើតបានជាកម្លាំងទ័ពជាតិ (កម្លាំងស្នូលសង្គម)។

## ១. ការវិវត្តប្រជាសាស្ត្រ

មុខវិជ្ជាប្រជាសាស្ត្រ បានជួយឱ្យអ្នកសិក្សាឱ្យយល់ដឹងអំពីមនុស្ស និងសកម្មនានាដែលមានប្រយោជន៍របស់រដ្ឋាភិបាល។ ការរីកចម្រើនផ្នែកប្រជាសាស្ត្រ ត្រូវបានធ្វើឡើងក្នុងក្របខណ្ឌនៃបណ្ដាប្រទេស ដែលផ្នែករដ្ឋបាលមានការរៀបចំបានប្រសើរ ហើយវាក៏ជាកិច្ចការសំខាន់សម្រាប់បង្កើតទិន្នន័យមូលដ្ឋាន ក្នុងប្រទេស។ ការបង្ហាញច្បាស់លាស់ តាមរយៈទិន្នន័យប្រជាសាស្ត្រ គឺជាលក្ខខណ្ឌមូលដ្ឋានពិតប្រាកដមួយដើម្បីយល់ដឹងអំពីស្ថានភាពប្រជាសាស្ត្រនៃប្រទេសនោះ។

ប្រជាសាស្ត្រ ជានិច្ចកាលច្រើនតែសិក្សាហួសពីបាតុភូតសាមញ្ញរបស់មនុស្ស ពោលគឺវាបានសិក្សាអំពីមូលហេតុនិងផលវិបាកនៃចលនាទាំងនោះផងដែរ។ ប្រជាសាស្ត្រ បានយកចិត្តទុកដាក់ផងដែរ ទៅលើកត្តាសរីរៈ អាកាសធាតុ

សង្គមសាស្ត្រ ចិត្តសាស្ត្រ ដែលមានឥទ្ធិពលទៅលើប្រជាជន។

ប្រទេសអាណានិគមជាច្រើន មានសិទ្ធិត្រួតពិនិត្យភោគទ្រព្យ នៃបណ្តាប្រទេសក្រោមអាណានិគមរបស់ខ្លួនមិនតែប៉ុណ្ណោះពួកគេបានត្រួតពិនិត្យលើប្រជាជនថែមទៀតផង ដូចជាការប្រើប្រាស់កម្លាំងពលកម្ម នៃប្រទេសទាំងនោះផងដែរ។ សម្រង់ស្ថិតិប្រជាជន ដែលស្ថិតនៅក្រោមអាណានិគម ត្រូវបានធ្វើឡើងក្នុងគោលដៅសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (ការប្រមូលពន្ធដារនិងការកត់សម្គាល់នូវមនុស្ស ដែលមានលទ្ធភាពបម្រើការក្នុងរោងច្រក សហគ្រាសនានា)។

## ២. ទិន្នន័យប្រជាជន ( Data of People )

បច្ចុប្បន្ននេះ ប្រជាសាស្ត្រត្រូវបានគេរកឃើញថាជាអន្តរមុខវិជ្ជា ព្រោះវាមានទំនាក់ទំនងជាមួយនឹងមុខវិជ្ជាផ្សេងៗទៀត រួមមាន មុខវិជ្ជាគណិតវិទ្យា ស្ថិតិវិទ្យា ជីវៈវិទ្យា វេជ្ជសាស្ត្រ ភូមិវិទ្យា សង្គមវិទ្យា និងសេដ្ឋកិច្ចវិទ្យា ជាដើម។ នៅពេលដែលមុខវិជ្ជានីមួយៗ បានធ្វើការសិក្សាទាក់ទងទៅនឹងអត្រារបស់ប្រជាជន មានន័យថាមុខវិជ្ជានោះ បានសិក្សាពាក់ព័ន្ធទៅនឹងទិន្នន័យប្រជាជនជាក្រុម មិនមែនជាលក្ខណៈជាបុគ្គលឡើយ។ ទិន្នន័យប្រជាជន មានប្រភពសំខាន់ៗចំនួនបួន គឺ ជំរឿន អង្កេតគំរូ ប្រព័ន្ធកត់ត្រានិងស្ថិតិរដ្ឋបាល និងទិន្នន័យតាមបែបគុណភាព។

### ក. ជំរឿនប្រជាជន (Census)

ពាក្យ "ជំរឿន" មានន័យថា ជាការរាប់ ឬរាប់ដែលជានិច្ចកាល ទាក់ទងទៅនឹងការយកពន្ធដារ ហើយពាក្យនេះ ចេញមកពីពាក្យ ឡាតាំង "សេនសើរ-Sensere" ដែលមានន័យថា ការប៉ាន់តម្លៃឬការយកពន្ធ។ មតិដទៃទៀតចំពោះការធ្វើជំរឿន គឺជាសេវារបស់កងទ័ព ដើម្បីផ្គត់ផ្គង់អាហារ ព្រោះជនជាតិក្រិកបុរាណ រាប់ចំនួនបុរសពេញវ័យក្នុងពេលធ្វើសង្គ្រាម និងរាប់ប្រជាជនទូទៅនៅពេលណា ដែលអាហារសម្រាប់ផ្គត់ផ្គង់មានរយៈពេលខ្លី។

បច្ចុប្បន្ន ជំរឿនប្រជាជន គឺមានការរាប់ជាផ្លូវការនៃចំនួនប្រជាជនទាំងអស់ ដែលធម្មតាមានជាព័ត៌មានលម្អិតផ្សេងៗ អំពីលក្ខណៈសម្គាល់ប្រជាសាស្ត្រ សង្គម និងសេដ្ឋកិច្ច។ ការរីកចម្រើន និងជឿនលឿនទៅមុខ បានធ្វើឱ្យមានការចាប់អារម្មណ៍ទៅលើជំរឿន ដែលអាចឆ្លុះបញ្ចាំងបានតាមការពិនិត្យមើល លើរដ្ឋធម្មនុញ្ញរបស់ប្រទេសជឿនលឿនមួយចំនួន ដូចជា សហរដ្ឋអាម៉េរិក ដែលតម្រូវឱ្យធ្វើជំរឿនក្នុងរយៈពេលដប់ឆ្នាំម្តង។ គួរកត់សម្គាល់ថា ព័ត៌មានជំរឿន គឺជាការសម្ងាត់ មានន័យថាទិន្នន័យរបស់បុគ្គលម្នាក់ៗ មិនផ្សព្វផ្សាយបានតាមការនឹកឃើញទេ។ ដោយសារជំរឿន ត្រូវគ្របដណ្តប់គ្រប់មនុស្សទាំងអស់ (ម្នាក់ៗ) វាត្រូវការចាំបាច់នូវថវិកាច្រើនក្នុងការទទួលបានព័ត៌មានទាំងនោះ។ ដូចនេះមានតែសំណួរមូលដ្ឋានខ្លះៗប៉ុណ្ណោះ ដែលត្រូវបាន

រៀបចំឡើងដូចជា អាយុ ភេទ ស្ថានភាពរៀបការ កន្លែងកើត កន្លែងរស់នៅ ការអប់រំ និងមុខរបរជាដើម ដើម្បីសួរនៅពេលធ្វើជំរឿន។

បទដ្ឋានស្ថិតិ ត្រូវបានកែលម្អយ៉ាងប្រសើរពាសពេញសាកលលោក ហើយទិន្នន័យជំរឿនដែលល្អ គឺមានសារសំខាន់ណាស់ សម្រាប់អ្នកដែលធ្វើផែនការសេដ្ឋកិច្ច អប់រំ សុខភាព និងវិស័យដទៃទៀត។ ដូចគ្នាផងដែរ នៅក្នុងប្រទេសដែលទើបតែទទួលបាននូវឯករាជ្យថ្មីៗ ភាពជាក់លាក់នៃរបាយការណ៍លម្អិតអំពីប្រជាជន គឺមានលក្ខណៈចាំបាច់ណាស់ ក្នុងកិច្ចការនយោបាយ ដូចជាការរៀបចំការបោះឆ្នោតជាដើម។

***ខ. អង្កេតគំរូ* (Survey)**

ការធ្វើអង្កេតគំរូទាមទារការចំណាយថវិកាតិចជាងការធ្វើជំរឿន ព្រោះវាទាក់ទងទៅនឹងការជ្រើសរើសក្រុមមនុស្ស សម្រាប់តាងឱ្យប្រជាជនទាំងមូល ឬតែផ្នែកណាមួយរបស់ប្រជាជននោះប៉ុណ្ណោះ(គំរូតាង)។ ជាទូទៅការធ្វើគំរូតំណាងតែងជួបប្រទះនូវបញ្ហាពីរគឺៈ

**ទី១ៈ** លំនាំនៃការជ្រើសរើសគំរូតាងមួយតែងតែបង្កើតឱ្យមានភាពលម្អៀង ព្រោះគំរូតាងមួយ ពិតជាពុំអាចតំណាងឱ្យប្រជាជនទាំងមូលបានមួយរយភាគរយឡើយ។

**ទី២ៈ** គំរូតាងរបស់ប្រជាជនមួយ មានចំនួនរាប់តិច ដូច្នេះមិនអាចធ្វើការវិភាគទិន្នន័យបានលម្អិតអំពីតំបន់តូចៗរបស់ប្រទេសមួយបានឡើយ។

ការរាប់ចំនួនតាមរយៈការអង្កេតគំរូតាង ក៏មានគុណសម្បត្តិច្រើនដែរ ព្រោះវាអាចផ្តល់ទិន្នន័យពេញលេញសំបូរបែប និងប្រកបដោយគុណភាពបាន ដោយសារមានពេលវេលាច្រើន និងការខិតខំប្រឹងប្រែង ដែលត្រូវចំណាយទៅលើការសម្ភាសន៍នីមួយៗ ដូចជាព័ត៌មានដែលទាក់ទងទៅនឹងការសិក្សាស្រាវជ្រាវ អំពីចំណេះដឹង ឥរិយាបថ និងការអនុវត្តផែនការគ្រួសារ។

***គ. កំណត់ត្រាអត្រានុកូលដ្ឋានឬស្ថិតិរដ្ឋបាល***

ជំរឿននិងអង្កេត រៀបរាប់អំពីសកម្មភាពរបស់ប្រជាជននៅពេលកំណត់មួយ។ ចំណែកស្ថិតិអត្រានុកូលដ្ឋាន គឺជាប្រភពសំខាន់របស់ទិន្នន័យ ដើម្បីសិក្សាស្រាវជ្រាវពីការប្រែប្រួលរបស់ប្រជាជន ព្រោះវាបានប្រមូលព័ត៌មានមូលដ្ឋាននៃពេលជាបន្តបន្ទាប់។ បច្ចុប្បន្ន កំណត់ត្រាអត្រានុកូលដ្ឋានឬស្ថិតិរដ្ឋបាល គឺជាការកត់ត្រារក្សាទុកនូវព្រឹត្តិការណ៍សំខាន់ នៃប្រទេសមួយដូចជា ចំនួនមនុស្សស្លាប់ ចំនួនមនុស្សកើត និងចំនួនអ្នករៀបអាពាហ៍ពិពាហ៍ជាដើម។ នៅក្នុងប្រទេសជាច្រើន សំបុត្រកំណើត ជាតម្រូវការមូលដ្ឋានសម្រាប់ចុះឈ្មោះចូលរៀន និងចូលបម្រើការងារនៅក្នុងស្ថាប័នផ្សេងៗទៀត។ តាមប្រវត្តិសាស្ត្រ កំណត់ត្រាក្នុងកំបន់ ឬបញ្ជីកំណត់ត្រាក្នុងតំបន់ ឬបញ្ជីកត់ត្រាអ្នកចំណុះព្រះវិហារសាសនា ត្រូវបានរក្សាទុក ដោយព្រះវិហារសាសនាមួយចំនួន ដូចជា នៅទ្វីបអឺរ៉ុបនាសតវត្សរ៍ទី១៤ និងក្រោយៗមកទៀត រហូតដល់ដើមសតវត្សរ៍ទី២០ សូម្បីតែ

ប្រព័ន្ធកត់ត្រារបស់រដ្ឋ ឬកំណត់ត្រាស៊ីវិល ក៏មិនទាន់មានការរីកចម្រើនដែរ។ នៅឆ្នាំ១៩៩០ ប្រវត្តិប្រជាវិទូជាច្រើន បានប្រើប្រាស់បញ្ជីកត់ត្រាអ្នកចំណុះព្រះវិហាររបស់ជនជាតិបារាំង ដើម្បីអភិវឌ្ឍបច្ចេកទេសក្នុងន័យបង្កើតពត៌មានអំពីសង្គមគ្រួសារឡើងវិញ ហើយបច្ចេកទេសនេះចាប់ផ្តើមដោយការកត់ត្រាអំពីអាពាហ៍ពិពាហ៍ និងបន្តបន្ទាប់មកបានភ្ជាប់កំណត់ត្រាទាំងនេះទៅកំណត់ត្រាផ្សេងៗទៀតដែលបង្ហាញអំពីកាលបរិច្ឆេទកំណើត និងការស្លាប់របស់ប្តីប្រពន្ធនិងកូនរបស់ពួកគេ។

បច្ចេកទេសកុំព្យូទ័រទំនើបរបស់ចំណងកត់ត្រា ត្រូវបានកំពុងប្រើប្រាស់នាពេលបច្ចុប្បន្ននេះ ជាពិសេសនៅអ៊ឺរ៉ុប និងអាមេរិកខាងជើង ហើយប្រព័ន្ធកត់ត្រាអត្រានុកូលដ្ឋាន មានទម្រង់ច្រើនសណ្ឋានដែលយើងអាចសង្ខេបដូចខាងក្រោម៖

- បញ្ជីប្រជាជន
- សេវាស្ថិតិ
- ស្ថិតិបម្លាស់លំនៅអន្តរជាតិ

### ឃ. ទិន្នន័យគុណភាព

ទិន្នន័យគុណភាព អាចត្រូវបានប្រមូលផងដែរ អំពីការប្រជុំជាក្រុម ដែលមានអ្នកចូលរួមក្នុងចំនួនតិច តែមានស្ថានភាពមួយប្រហាក់ប្រហែលគ្នា។ ជាមួយគ្នានេះ អ្នកស្រាវជ្រាវរៀបចំជាក្រុមតូចៗ ដើម្បីពិភាក្សាអំពីប្រធានបទពិសេសដោយឡែក ហើយកត់ត្រាអន្តរកម្មរបស់ក្រុម។ ឧទាហរណ៍ ការពិភាក្សាអំពីទំហំគ្រួសារ ដោយបែងចែកដាច់ដោយឡែកពីគ្នា ដូចជាបុរសក្មេងៗ ស្ត្រីក្មេងៗ បុរសចាស់ៗ និងស្ត្រីចាស់ៗ ជាដើម។

ជានិច្ចកាលប្រទេសអភិវឌ្ឍ អាចរៀបចំប្រមូលទិន្នន័យបានល្អ ព្រោះគេមានអង្គការចាត់តាំងស្ថិតិមានប្រសិទ្ធិភាពខ្ពស់ មានគមនាគមន៍ល្អ និងធនធានច្រើន ហើយប្រជាជននៃប្រទេសទាំងនោះភាគច្រើនជាមនុស្សចេះអក្សរ និងចេះលេខផងដែរ ដែលមូលដ្ឋានធ្វើឱ្យមានចម្លើយត្រឹមត្រូវដល់សំណួរដែលបានសួរ។ ជាក់ស្តែង នៅក្នុងប្រទេសអូស្ត្រាលី ប្រជាជនស្ទើរតែទាំងអស់ មានសំបុត្រកំណើតហើយស្គាល់អំពីអាយុពិតប្រាកដរបស់ខ្លួន។ រីឯប្រទេសកំពុងអភិវឌ្ឍន៍មួយចំនួនវិញ មានប្រជាជនខ្លះក្នុងចំណោមមនុស្សចាស់ៗ និងអ្នកមិនចេះអក្សរ មិនដឹងអំពីអាយុពិតប្រាកដរបស់ខ្លួនឡើយ ពោលគឺការ ផ្តល់ចម្លើយទៅដល់សំណួរ គឺធ្វើឡើងតាមរយៈការប៉ាន់ស្មានតែប៉ុណ្ណោះ។

### ៣. មរណប្រមាណ ( Mortality )

មរណប្រមាណ គឺជាលំនាំប្រជាសាស្ត្រមួយដែលសំដៅទៅលើចំនួនមនុស្សស្លាប់ (មរណភាព) នៅក្នុងប្រជាជនណាមួយ។ មរណប្រមាណមានលក្ខណៈខុសៗគ្នា អាស្រ័យទៅលើកត្តាសង្គមនិងកត្តាជីវសាស្ត្រ(លក្ខណៈនៃហ្សែនតំណរពូជពីឪពុកម្តាយ) ក៏ប៉ុន្តែ កត្តាសង្គមច្រើនមានឥទ្ធិពលលើមរណប្រមាណធំជេងជាងកត្តាជីវសាស្ត្រ។ រង្វាស់មួយដែលគេបានប្រើប្រាស់ញឹកញាប់ក្នុងប្រជាសាស្ត្រគឺ "អត្រា" ហើយការសិក្សាអំពីមរណ

ប្រមាណ គឺចាប់ផ្ដើមទៅលើបាតុភូតប្រជាសាស្ត្រ (មរណប្រមាណ ជាតិប្រមាណ ភាពបង្កើតកូន ប៉ុន្តែសិក្សាផងដែរ អំពីចំនួនអាពាហ៍ពិពាហ៍និង ចំនួនលែងលះ...)ដែលបញ្ជាក់លក្ខណៈរបស់ ព្រឹត្តិការណ៍ ស្លាប់ កើត រៀបការ និងលែងលះ ជាដើម។ ជាទូទៅ មរណប្រមាណមានសមាសភាព ពីរ គឺ៖

- ***ទីឃាយុកាល*** (Lifespan)៖ *ទីឃាយុកាល សំដៅទៅលើអាយុវែងបំផុតរបស់មនុស្ស ដែលអាចរស់នៅបាន ពោលគឺជាបាតុភូតជីវសាស្ត្រសុទ្ធសាធ ហើយពីមួយថ្ងៃទៅមួយថ្ងៃអាចប្រែប្រួលជានិច្ច ដោយមិនអាចទស្សន៍ទាយបាន។ ការទទួលស្គាល់អាយុកាល ដែលវែងជាងគេបំផុតរបស់មនុស្សបានរស់ គឺ អាយុ១២២ឆ្នាំនិង១៦៤ថ្ងៃ របស់ស្ត្រីជនជាតិបារាំងឈ្មោះ* Jeanne Louise Calment *ដែលបានស្លាប់នៅក្នុងឆ្នាំ១៩៩៧ ដោយគេដឹងថា គាត់បានកើតនៅថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ១៨៧៥*[2]

- ***ទីឃាយុភាព*** (Longevity)៖ *ទីឃាយុភាព សំដៅទៅលើលទ្ធភាព ដែលអាចរស់ពីមួយឆ្នាំទៅមួយឆ្នាំ ពោលគឺជាសមត្ថភាពទប់ទល់ទៅនឹងការស្លាប់ ត្រូវបានវាស់វែងដោយអាយុសង្ឃឹមរស់ ដែលជារយៈពេលមធ្យមស្ថិតិនៃជីវិត ឬហៅថាអាយុមធ្យមនៅពេលស្លាប់ មានន័យថាវាបាននូវឥទ្ធិពលនៃកត្តាជីវសាស្ត្រផង និងកត្តាសង្គមផងដែរ។*

### ៤. លទ្ធភាពបង្កើតកូន (Fertility)

*លទ្ធភាពបង្កើតកូន សំដៅទៅលើចំនួនកំណើតរស់ដែលស្ត្រីជាម្ដាយម្នាក់មាន។ លទ្ធភាពបង្កើតកូនខុសពីលទ្ធភាពបង្កកំណើត ដែលសំដៅចំពោះសមត្ថភាពសរីរៈវិទ្យារបស់ស្ត្រី ក្នុងការបន្តពូជតែប៉ុណ្ណោះ។ ដើម្បីសិក្សាពីលទ្ធភាពបង្កើតកូន ជាចាំបាច់គេត្រូវមានទិន្នន័យគ្រប់គ្រាន់អំពីថ្ងៃខែឆ្នាំកំណើតរបស់កូន និងអាយុកាលរបស់ ម្តាយនៅពេលសម្រាលកូន។ លទ្ធភាពបង្កើតកូនក៏ដូចជាមរណប្រមាណដែរ មានសមាសភាគពីរយ៉ាងគឺ៖ កត្តាសង្គមនិងកត្តាជីវសាស្ត្រ។ ម៉្យាងទៀត កត្តាសង្គមវប្បធម៌និងសេដ្ឋកិច្ច ក៏មានឥទ្ធិពលទៅលើលទ្ធភាពបង្កើតកូនផងដែរ។ ដូចនេះ បញ្ហាទ្រឹស្ដីកំណត់ភាពបង្កើតកូននៅតែមានបញ្ហាចោទនៅឡើយ ព្រោះក្រៅពីកត្តាប្រជាសាស្ត្រ នៅមានកត្តាជីវសាស្ត្រ សង្គមវប្បធម៌ និងសេដ្ឋកិច្ច ក៏ជួយធ្វើអន្តរាគមន៍នៅគ្រប់អថេរទាំងអស់ ដែលបានសន្មត់នៅក្នុងសង្គមនានាពោរពេញទៅដោយភាពអន្តរកាល។*

### ៥. បម្លាស់លំនៅ (Migration)

*បម្លាស់លំនៅ ត្រូវបានគេឱ្យនិយមន័យច្រើនសណ្ឋានទៅតាមបរិបទ នៃការសិក្សារបស់វា។ ដោយឡែក ក្រុមប្រឹក្សាជាតិភាសាខ្មែរ បានកំណត់និយមន័យ ដូចតទៅ៖ "បម្លាស់លំនៅ" គឺជាដំណើរផ្លាស់ទីរបស់ក្រុមមនុស្ស ហ្វូងសត្វ ឬ*

[2] https://anson.ucdavis.edu/~wang/calment.html

ក្រុមរុក្ខជាតិ ពីតំបន់មួយទៅកាន់តំបន់ផ្សេងដើម្បីនៅជាបណ្ដោះអាសន្នឬស្ថាពរ។[3] បម្លាស់លំនៅកើតមាននៅគ្រប់ទីកន្លែង ក្នុងតំបន់មួយ ក្នុងប្រទេសមួយ និងទូទាំងសាកលលោក ដោយផ្ទុះបញ្ឆាំង ពីការឆ្លើយតបរបស់មនុស្សទៅនឹងកត្តាជាច្រើន ដូចជា អតុល្យភាពសេដ្ឋកិច្ច គុណវិបត្តិសង្គម និងភាពមិនពេញចិត្តនឹងរូបភាពជាច្រើននៃការរស់នៅរបស់ពួកគាត់។ បម្លាស់លំនៅគឺជាលទ្ធផលដែលមានប្រភព មកពីបញ្ហាជាច្រើន ដូចជា ភាពខ្វះខាតនៅតាមតំបន់ជនបទ កំណើនលើសលប់នៅទីក្រុង និងបញ្ហាលំបាកនៃសង្គម និងសេដ្ឋកិច្ច ដែលមានឥទ្ធិពលដល់ការប្រែប្រួលសង្គម។

ជាក់ស្ដែង មនុស្សបានធ្វើការផ្លាស់ទីរវាងសហគមន៍ទីប្រជុំជននិងទីប្រជុំជនជនបទ និងសហគមន៍ជនបទនិងជនបទ។ បម្លាស់លំនៅចេញពីទីប្រជុំជន គឺមានសារៈសំខាន់ណាស់នៅក្នុងប្រទេសអភិវឌ្ឍ ប៉ុន្តែវាជាដំណើរការមានសារប្រយោជន៍ផងដែរ សម្រាប់អ្នករដ្ឋការសាធារណៈ និងអ្នកធ្វើការងារដោយវិជ្ជាជីវៈ នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍។ បម្លាស់លំនៅ រវាងសហគមន៍ជនបទ ត្រូវដំណើរការចម្បងក្នុងសករាជបុរេឧស្សាហកម្ម ពោលគឺនៅពេលដែលមនុស្សគ្រាន់តែធ្វើដំណើរជិតៗ ហើយជារឿយៗ គឺគ្រាន់តែជ្រើសរើសដៃគូរៀបការជាមួយគ្រួសារជិតខាងឬភូមិស្រុកជិតគ្នាតែប៉ុណ្ណោះ។ នៅក្នុងសង្គមអភិវឌ្ឍជឿនលឿន បែបបទនេះមានសារៈសំខាន់តិចតួចប៉ុណ្ណោះនាបច្ចុប្បន្ននេះ ប៉ុន្តែវានៅតែមាននៅក្នុងប្រទេសកំពុងអភិវឌ្ឍ ជាពិសេស សម្រាប់ស្ត្រីជនបទដែលមានការអប់រំតិចតួច ហើយមានការពេញចិត្តតិចតួចក្នុងការចាកចេញពីតំបន់ជនបទដើម្បីស្វែងរកការងារធ្វើនៅតំបន់ទីប្រជុំជន និងទីក្រុង។

### ក. អ្នកណាផ្លាស់ទី? ហេតុអ្វីបានផ្លាស់ទី?

ទិន្នន័យជំរឿន អាចផ្ដល់ព័ត៌មានជាក់ច្បាស់ អំពីលក្ខណៈសង្គមសេដ្ឋកិច្ចរបស់មនុស្សដែលស្ថិតនៅក្នុងប្រភេទខុសៗគ្នា នៃបម្លាស់នៅក្នុងស្រុក ដូចជា អ្នកចូលរួមនៅក្នុងបម្លាស់លំនៅជនបទទៅទីប្រជុំជននៅក្នុងប្រទេសខ្លះ ភាគច្រើនមានវ័យក្មេង និងមានការអបរំប្រសើរ ហើយពួកគេជានិច្ចកាលជាបុរស។ អ្នកផ្លាស់ទីពីទីប្រជុំជនទៅជនបទ មានក្រុមចំរុះ ដូចជា អ្នក មានប្រាក់ច្រើនស្វែងរកទីកន្លែងរស់នៅ ហើយអាចចំណាយប្រាក់ទាំងនោះ ទៅលើការធ្វើដំណើរទៅមក និងអ្នកចូលនិវត្តន៍ដែលស្វែងរកសហគមន៍យ៉ាងប្រញាប់ប្រញាល់ ដើម្បីចាកឆ្ងាយអំពីជីវិតទីក្រុងជាដើម។ ភាគច្រើននៃអ្នកផ្លាស់ទីរវាងក្រុមមនុស្សទាំងនោះ គឺដើម្បីរកវិជ្ជាជីវៈ ដែលជារឿយៗធ្វើការសម្រាប់ក្រុមហ៊ុនធំៗដែលមានបុគ្គលិកច្រើន ហើយមនុស្សមួយចំនួនទៀត នៅតែជាអ្នកតាំងទី

---

[3] ក្រុមប្រឹក្សាជាតិភាសាខ្មែរៈ សទ្ទានុក្រមបច្ចេកសព្ទភូមិវិទ្យា និងប្រវត្តិវិទ្យា ឆ្នាំ២០១៨ ទំព័រទី៣០

នៅជនបទដដែល សម្រាប់អ្នកដែលមានគំនិតអភិរក្សខ្លាំង ហើយភាគច្រើនមានវ័យចំណាស់។ លក្ខណៈសង្គមកិច្ច ដូចដែលលើកមកខាងលើបានបង្ហាញថា ការជម្រុញផ្នែកសេដ្ឋកិច្ចធ្វើឱ្យប្រសើរឡើង នូវការអប់រំ ឬទទួលបាននូវការងារដែលមានប្រយោជន៍ ជាមួយការបង្កើតឱ្យមានក្តីសង្ឃឹមដែលអាចនឹងមានឡើង។ ការសិក្សាជាច្រើន បានបង្ហាញឱ្យដឹងថា មនុស្សធ្វើការផ្លាស់ទីលំនៅសម្រាប់អ្វីផ្សេងទៀត ទាក់ទងនឹងមូលហេតុផ្សេងៗ ហើយមូលហេតុនេះ អាចមានភាពចាំបាច់ដោយឡែក នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ផងដែរ។ ការសិក្សាទាំងនេះ បានបង្ហាញថា ដំណើរការបម្លាស់លំនៅ គឺមានកើនឡើងច្រើន ជាពិសេសនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍។

## ខ. កត្តាជម្រុញនិងកត្តាទាក់ទាញ

ការទាញយកសារៈសំខាន់ នៃកំណត់សម្គាល់សម្រាប់បម្លាស់លំនៅ គឺជាការទ្រទ្រង់ក្នុងការពន្យល់ថា ហេតុអ្វីមានអ្នកខ្លះជាអ្នកផ្លាស់ទី និងអ្នកខ្លះទៀតមិនផ្លាស់ទី រាប់បញ្ចូលទាំងលក្ខណៈជាបុគ្គល ជាក្រុមធំ និងជាក្រុមតូចៗ។ មនុស្ស គឺមិនធ្វើការផ្លាស់ទីទៅរកទីកន្លែងណា ដែលគ្មានសារៈសំខាន់ចំពោះគេនោះទេ ប៉ុន្តែ គឺត្រូវធ្វើឡើងនៅក្នុងបរិស្ថានរួមមួយ គឺៈ

- សមាសភាគសេដ្ឋកិច្ច ដូចជាការទាក់ទងនឹងទ្រព្យសម្បត្តិ (ឬភាពក្រីក្រ) ឬឱកាសការងារ

- សមាសភាគសង្គមដូចជាកម្រិតនៃការអនុវត្តការរារាំងពីការចាកចេញពីផ្ទះ ឬក៏មូលហេតុផ្សេងទៀត ដែលបង្ខំឱ្យពួកគាត់បែបនេះ

- កត្តានយោបាយ ដូចជាការគាំទ្រផ្លូវច្បាប់នៃការផ្លាស់ទីរបស់ប្រជាជនរវាង ការតាំងទីជាក់លាក់ ឬមិនកំណត់។

បម្លាស់លំនៅអន្តរជាតិ គឺជាដំណើរផ្លាស់ទីរបស់មនុស្សឬសត្វ ជាបណ្តោះអាសន្នឬស្ថាពរ ពីប្រទេសមួយឬតំបន់មួយទៅកាន់ប្រទេសមួយឬតំបន់មួយផ្សេង។[4] អង្គការសហប្រជាជាតិ បានផ្តល់អនុសាសន៍ រយៈពេលមួយឆ្នាំឬច្រើនជាងសម្រាប់ការផ្លាស់ទី ត្រូវបានចាត់ទុកជាការផ្លាស់ទីរយៈពេលវែង ហើយជារឿយៗបម្លាស់លំនៅអន្តរជាតិ មានវិវាទច្រើនជាងបម្លាស់លំនៅក្នុងស្រុក។ ភាពជាប់ទាក់ទងទៅនឹងសង្គម សេដ្ឋកិច្ច និងនយោបាយ បានបង្កើតឱ្យមានបញ្ហាជាច្រើន រួមមានទាំងអវិជ្ជមាននិងវិជ្ជមាន ទោះបីជា ការផ្លាស់ទីក្នុងស្រុកមានទ្រង់ទ្រាយធំជាងការផ្លាស់ទីអន្តរជាតិក៏ដោយ។ ពេលខ្លះអន្តោប្រវេសន៍ប្រើប្រាស់ភាសាដូចគ្នា ហើយមានវប្បធម៌ស្រដៀងគ្នានៅក្នុងសហគមន៍ ដែលទទួលជនបម្លាស់លំនៅ អាចប្រែប្រួលគួរឱ្យចាប់អារម្មណ៍ ជាពិសេសនៅក្នុងពេលដែលសេដ្ឋកិច្ចជួបនឹងបញ្ហា និងអស្ថេរភាពនយោបាយនៅក្នុងប្រទេសកំណើតរបស់ខ្លួន។ ប៉ុន្តែ ពេលខ្លះទៀត ទោះបីភាពខុសគ្នា

[4] ក្រុមប្រឹក្សាជាតិភាសាខ្មែរៈ សទ្ទានុក្រមបច្ចេកសព្ទភូមិវិទ្យា និងប្រវត្តិវិទ្យា ឆ្នាំ២០១៨ ទំព័រទី៣១

ក៏ដោយ ក៏ជនអន្តោប្រវេសន៍និងទាយាទបន្តបន្ទាប់របស់ពួកគេ ងាយស្រួលឬរស់នៅលាយឡំជាមួយគ្នា ក្នុងសហគមន៍ទទួលជនបម្លាស់លំនៅ។

ការផ្លាស់ទីដ៏ច្រើន ជានិច្ចកាលកើតឡើងក្នុងការឆ្លើយតបទៅនឹងការកំណត់ដ៏ល្អ នៃកត្តាសង្គមនិងសេដ្ឋកិច្ច ដែលអាចមានប្រភេទផ្សេងៗគ្នាដូចជាសង្គ្រាម ការឈ្លានពាន អាណានិគម ការបញ្ជូនប្រជាជនដោយបង្ខំ និងការផ្លាស់ទីរបស់ជនភៀសខ្លួនជាដើម។

ទស្សនៈមូលដ្ឋានប្រជាសាស្ត្រ គឺជាវិធីសាស្ត្រមូលដ្ឋាន ដើម្បីសិក្សាអំពីប្រជាជន ដែលផ្តោតជាពិសេសទៅលើ កំណើនឆាប់រហ័សនៃចំនួនប្រជាជនសាកលលោក អាចជាមូលហេតុចម្បងនៃភាពក្រីក្រ។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ក៏ជាទូទៅវាមិនប្រាកដទេថា តើកំណើនប្រជាជននឹងបង្កើនចំនួនមនុស្ស ទៅក្នុងភាពក្រីក្របន្ថែមទៀត ឬបង្កើនភាគរយនៃចំនួនប្រជាជនរស់នៅក្នុងភាពក្រីក្រ ឬធ្វើឱ្យភាពក្រីក្រកាន់តែធ្ងន់ធ្ងរឡើង។ ទស្សនៈមួយទៀត នៃការសិក្សាប្រជាសាស្ត្របង្ហាញថា កត្តាសេដ្ឋកិច្ចជាមូលហេតុចម្បងនៃភាពក្រីក្រ ដោយមានកត្តាកំណើនប្រជាជនបន្ថែមជាកត្តាចម្បង ដែលមានឥទ្ធិពលលើភាពក្រីក្រ។ តាមការសិក្សាបែបសេដ្ឋកិច្ចនៅប្រទេសជាច្រើន បានរកឃើញឥទ្ធិពលអវិជ្ជមានរបស់កំណើនប្រជាជន មកលើភាពប្រែប្រួលដែលពាក់នឹងភាពក្រីក្រ ដូចជាប្រាក់ចំណូល ការអប់រំ និងសុខភាព ប៉ុន្តែមានភស្តុតាងតិចតួចណាស់ដែលបញ្ជាក់អំពីឥទ្ធិពលផ្ទាល់របស់វាមកលើភាពក្រីក្រ។

ភាពក្រីក្រ កើតមាននៅក្នុងពេលដែលមនុស្សម្នាក់ឬច្រើន ប្រើប្រាស់ទំនិញនិងសេវាកម្មក្នុងកម្រិតមួយទាបជាងកម្រិតប្រើប្រាស់ កម្រិតអប្បរមាយ៉ាងសមរម្យមួយ ផ្អែកទៅលើការយល់ឃើញជាក់ស្តែង ឬផ្អែកលើកម្រិតស្តង់ដាររបស់សង្គមមួយ។ ប៉ុន្តែ ការសិក្សាប្រជាសាស្ត្រ អំពីភាពក្រីក្រ មិនគ្រាន់តែការរៀបរៀងជាសំណួរអំពីប្រាក់ចំណូលមិនគ្រប់គ្រាន់ប៉ុណ្ណោះទេ ប៉ុន្តែ ក៏អាចនឹងមានសំណួរពាក់ព័ន្ធជាមួយនឹង ការអប់រំ ស្ថានភាពសុខភាព និងបរិយាកាសជុំវិញ។

របាយការណ៍ ឆ្នាំ២០០៩ នៃមជ្ឈមណ្ឌលស្រាវជ្រាវអំពីប្រជាជន នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ បង្ហាញថា មនុស្សជាង១០០០លាននាក់ ស្មើនឹងមួយភាគបីនៃប្រទេសកំពុងអភិវឌ្ឍន៍ រស់នៅក្រោមបន្ទាត់នៃភាពក្រីក្រ (៣៧០ដុល្លារសម្រាប់មនុស្សម្នាក់ក្នុងមួយឆ្នាំ)។ ក្នុងចំណោមមនុស្ស១១១៦លាននាក់ ដែលជាអ្នកក្រីក្រ មានមនុស្ស៦៣០លាននាក់ រស់នៅក្នុងភាពក្រីក្របំផុត បើគិតលើការចំណាយប្រចាំឆ្នាំទាបជាង២៧៥ដុល្លារ។ សម្រាប់ប្រទេសកំពុងអភិវឌ្ឍទាំងអស់មាន១៨% នៃប្រជាជនទាំងនោះ គឺក្រីក្របំផុត ចំណែកតំបន់អាហ្វ្រិកសាហារ៉ា មាន៣០% និងអាស៊ីខាងត្បូងមាន២៩%។ ភាពក្រីក្រនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ គឺមិនរាលដាលខ្លាំងទេ ប៉ុន្តែស្មើរតែពាក់កណ្តាលនៃប្រជាជនអាហ្វ្រិក

សាហារ៉ា និងអាស៊ីខាងត្បូងរស់នៅក្នុងភាពក្រីក្រ បើប្រៀបធៀបទៅប្រមាណជា២០% ក្នុងប្រទេសអាស៊ីខាងកើត ហើយមាន ១០%ក្នុងអ៊ឺរ៉ុបខាងកើត[5]

ជាការពិត មូលហេតុចម្បងនៃភាពក្រីក្រ គឺពាក់ព័ន្ធជាមួយនឹងប្រាក់ខែទាប កង្វះទុនមនុស្ស ដូចជា ការអប់រំនិសុខភាព កង្វះធនធានដែលអាចផ្តល់ជាប្រាក់ចំណូល វិសមភាពនៃប្រាក់ចំណូលជាមួយនឹងកំណើនសេដ្ឋកិច្ច ទំហំគ្រួសារធំ យេនឌ័រ និងជាតិពន្ធុជាដើម។ ប្រភពចម្បងនៃប្រាក់ចំណូលរបស់អ្នកក្រ គឺការរកបានពីកម្លាំងពលកម្ម ជាពិសេសនោះ គឺកម្លាំងពលកម្មគ្មានជំនាញ។ ជាការពិតកំណើនប្រជាជនបានធ្វើឱ្យប៉ះពាល់ទៅដល់ភាពក្រីក្រ ព្រោះវាអាចកើតមានដោយសារឥទ្ធិពលរបស់វាផ្ទាល់ ឬប្រយោលមកលើសម្ព័ន្ធនៃភាពក្រីក្រ ដែលអាចនិយាយបានថា កំណើនប្រជាជនប្រហែលជាមានឥទ្ធិពលមកលើកំណើនសេដ្ឋកិច្ច របាយប្រាក់ចំណូល តម្លៃនៃការរកបាន និងទ្រព្យធនដទៃទៀត ដោយប៉ះពាល់មកលើការបែងចែកសេវាកម្ម ការអប់រំ និងសុខភាព ឬតាមរយៈទំហំនិងរចនាសម្ព័ន្ធគ្រួសារ។

## សេចក្តីសន្និដ្ឋាន

ទស្សនមូលដ្ឋានប្រជាសាស្ត្រ គឺពិតជាជាប់ពាក់ព័ន្ធជាមួយនឹងភាពក្រីក្រ ដោយសារលទ្ធផលនៃការសិក្សាជាច្រើនដូចជាការផ្លាស់ទីរបស់ប្រជាជន ការស្លាប់ ការកើត ការរៀបការ រួមទាំងកំណើនប្រជាជន និងភាពក្រីក្រផងដែរ។

ពិតណាស់ ការសិក្សាមូលដ្ឋានប្រជាសាស្ត្របានឆ្លុះបញ្ចាំងអំពីភាពក្រីក្រ ដែលបណ្តាលមកអំពីស្ថានភាពនិងកត្តាបរិយាកាសផ្សេងៗ នៃប្រទេសនីមួយៗ ពិសេសប្រទេសកំពុងអភិវឌ្ឍន៍។ ការស្វែងរកការងារ ដើម្បីធ្វើឱ្យប្រសើរឡើងនូវស្ថានភាពសេដ្ឋកិច្ចរបស់អ្នកក្រីក្រ រដ្ឋាភិបាលគួតែប្រើប្រាស់ វិធានការណ៍គោលនយោបាយប្រជាជន ដែលសំដៅបង្កើនលទ្ធភាពដល់អ្នកក្រ ឱ្យទទួលបានដីធ្លី ឥណទាន ហេដ្ឋារចនាសម្ព័ន្ធ សេវាសាធារណៈ ជាពិសេស ការអប់រំ និងការគាំពារសុខភាព ជាដើម។ ម្យ៉ាងទៀត រដ្ឋាភិបាល បានអនុវត្តន៍យុទ្ធសាស្ត្រកំណែទម្រង់ដីធ្លី ការយកចិត្តទុកដាក់លើវិស័យកសិកម្ម ការអភិវឌ្ឍវិស័យមិនមែនកសិកម្មនៅតាមជនបទ និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ហើយមិនត្រឹមតែគាំទ្រលើកំណើននៃវិស័យទាំងនោះទេ ក៏ប៉ុន្តែថែមទាំងជួយជម្រុញឱ្យមានរបាយប្រាក់ចំណូលស្មើគ្នាផងដែរ។ ប្រទេសនៅអាស៊ីបូព៌ាមួយចំនួន មានលទ្ធភាពកាត់បន្ថយភាពក្រីក្រ ដោយសារការជម្រុញឱ្យមានកំណើន ទាំងផ្នែកកសិកម្ម និងផ្នែកផ្សេងទៀតក្រៅពីវិស័យកសិកម្ម។

[5] មជ្ឈមណ្ឌលស្រាវជ្រាវប្រជាជនៈ សញ្ញាណទូទៅ និងបញ្ញតិមូលដ្ឋាន សាកលវិទ្យាល័យភូមិន្ទភ្នំពេញ ទំព័រ៣៧

ផែនការគ្រួសារ គឺជាយុទ្ធសាស្ត្រមួយនៃលទ្ធផលរបស់ការសិក្សាប្រជាសាស្ត្រ ត្រូវបានលើកទឹកចិត្តឱ្យមានការអនុវត្ត ព្រោះវាជាអាចជួយកាត់បន្ថយភាពក្រីក្របានមួយកម្រិត ក៏ប៉ុន្តែឥទ្ធិពលនេះអាចមានតិចតួច ហើយត្រូវការពេលវេលាយូទៀតផង។ តាមរយៈការផ្លាស់ប្តូរគោលនយោបាយរបស់រដ្ឋាភិបាល ចំពោះការចំណាយទៅលើបញ្ហាសុខភាព និងការអប់រំសម្រាប់ក្មេងៗច្រើនជាងផែនការគ្រួសារដែរ។ កម្មវិធីផែនការគ្រួសារ ដែលផ្តោតលើសេវាសុខភាពដល់អ្នកក្រីក្រ គឺជាមធ្យោបាយល្អប្រសើរ ដោយហេតុផលថា វាបានបែងចែកនូវធនធានសុខាភិបាលដល់អ្នកក្រីក្រ។ កម្មវិធីផែនការគ្រួសារនានា នៅតែជាការបំពេញបន្ថែមយ៉ាងសំខាន់ដល់គោលនយោបាយផ្ទាល់ទាំងនោះ។

ទោះបីជាការសិក្សា ទស្សនមូលដ្ឋានប្រជាសាស្ត្រ មិនបានបង្ហាញច្បាស់លាស់ ថាតើកំណើនប្រជាជនបណ្តាលឱ្យមានភាពក្រីក្រនាពេលយូអង្វែងឬអត់ក៏ដោយ ក៏ប៉ុន្តែ វាបានបង្ហាញឱ្យឃើញយ៉ាងច្បាស់ថា ភាពបង្កើតកូនខ្ពស់ គឺបាននាំឱ្យមានកំណើនប្រជាជនយ៉ាងឆាប់រហ័ស ដែលអាចនឹងបង្កើនចំនួនប្រជាជនក្រីក្រក្នុងពេលភ្លាមៗ ហើយពេលខ្លះទៀត វាក៏បានធ្វើឱ្យមានការលំបាក ដើម្បីគេចឱ្យផុតពីភាពក្រីក្រ។

ជារួម ការសិក្សាប្រជាសាស្ត្រជាមូលដ្ឋានមានសារៈសំខាន់ណាស់ ចំពោះការពន្យល់នានាទាក់ទងទៅនឹងស្ថិតិប្រជាជន ជាពិសេសការធ្វើជំរឿនប្រជាជន។ អ្នកវិទ្យាសាស្ត្រ បានប្រើប្រាស់ស្ថិតិទាំងនេះ ដើម្បីទាក់ទាញឱ្យមានការយកចិត្តទុកដាក់ទៅលើ ស្ថិតិនៃការស្លាប់ ស្ថិតិនៃការផ្តល់កំណើត ស្ថិតិនៃការស្វែងរកការងារ ស្ថិតិនៃមនុស្ស ដែលបានផ្លាស់ទីពីទីក្រុងទៅជនបទ និងពីជនបទមកទីក្រុង ជាដើម។ លំនាំនៃបុព្វហេតុទាំងនេះ រាប់បញ្ចូលទាំងទំនាក់ទំនងអាពាហ៍ពិពាហ៍ផងដែរ គឺជាមូលដ្ឋានដើម្បីគណនាបែបវិទ្យាសាស្ត្រ ក្នុងការរៀបចំផែនការអភិវឌ្ឍន៍នានារបស់ប្រទេស រាប់បញ្ចូលទាំងវិស័យសេដ្ឋកិច្ច វិស័យសុខាភិបាល វិស័យអប់រំ និងវិស័យផ្សេងៗទៀត។

# គន្ថនិទ្ទេស


- ក្រុមប្រឹក្សាជាតិភាសាខ្មែរ: សទ្ទានុក្រមបច្ចេកសព្ទភូមិវិទ្យា និងប្រវត្តិវិទ្យា ឆ្នាំ២០១៨
- រាជរដ្ឋាភិបាលកម្ពុជា: "កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជាសម្រាប់នីតិកាលទី៤ នៃរដ្ឋសភា" ឆ្នាំ២០០៩
- កម្មវិធីអភិវឌ្ឍសហប្រជាជាតិ (UNDP) "របាយការណ៍សង្ខេបស្តីពីការអភិវឌ្ឍមនុស្សឆ្នាំ ២០០៥ ២០០៦"
- កម្មវិធីអភិវឌ្ឍសហប្រជាជាតិ(UNDP)«វេទិកាសេដ្ឋកិច្ចកម្ពុជា» របាយការណ៍ ឆ្នាំ២០០៦
- មជ្ឈមណ្ឌលសិក្សាស្រាវជ្រាវអំពីប្រជាជនសាកលវិទ្យាល័យភូមិន្ទភ្នំពេញ៖ ឯកសារប្រើប្រាស់ផ្ទៃក្នុង "សញ្ញាណទូទៅ និងបញ្ញតិមូលដ្ឋាន "ភ្នំពេញ ២០០៩
- សន្និសីទជាតិស្តីពី "អត្រានុកូលដ្ឋាននៅប្រទេសកម្ពុជា" របាយការណ៍ ឆ្នាំ២០០៥
- សាកលវិទ្យាល័យភូមិន្ទកសិកម្ម: ឯកសារប្រើប្រាស់ផ្ទៃក្នុង "អភិវឌ្ឍជនបទ" ២០០៨
- RGC, Cambodia National Poverty Reduction Strategy, 2009
- RGC, Cambodia Millennium Goals Report, 2009
- CDRI, Rural Development Research, 2008
- https://anson.ucdavis.edu/~wang/calment.html

# មូលដ្ឋាននៃចិត្តវិទ្យាព្រះពុទ្ធសាសនា

*ដោយៈ* **បណ្ឌិត សូ សុធីរ**
*មន្ត្រីស្រាវជ្រាវនាយកដ្ឋានវិទ្យាសាស្ត្រអប់រំ*
*នៃវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម*
*រាជបណ្ឌិត្យសភាកម្ពុជា*

*ទោះបីជាមុខវិជ្ជាចិត្តវិទ្យា ត្រូវបានគេអភិវឌ្ឍបានល្អប្រសើរជាវិទ្យាសាស្ត្របែបសង្កេតពិសោធ នៅក្នុងប្រទេសលោកខាងលិចនាពេលបច្ចុប្បន្នក៏ដោយ ក៏ចិត្តវិទូតិចតួចបំផុតបានសិក្សាដោយសង្ខេបផ្នែកទស្សនវិជ្ជា និងសាសនាពួកលោកខាងកើត។ រហូតមកដល់ពេលនេះ ការវិភាគបាតុភូតចិត្ត តាមវចនៈ* (Discourses)*របស់ព្រះពុទ្ធ ផ្តល់ការយល់ដឹងប្រកបដោយអត្ថន័យនូវធម្មជាតិរបស់ញាណ* (Consciousness) *និងចិត្តវិទ្យានៃអាកប្បកិរិយាមនុស្ស។ តាមពិតទៅ* Robert H. Thouless *ចិត្តវិទូនៅសាកលវិទ្យាល័យ* Cambridge *បានអធិប្បាយតាមបែបដោយឡែកទៅលើភាពពាក់ព័ន្ធនៃការឆ្លុះបញ្ចាំង តាមចិត្តសាស្ត្រ ទៅលើព្រះពុទ្ធថា ជាង២៥ស.វ.មកហើយ នៅតាមឈូងសមុទ្រ យើងហាក់ដូចជាឮសំឡេងព្រះពុទ្ធ ដែលជាការបញ្ជាក់បង្ហាញនូវចិត្តសម័យទំនើបដ៏សំខាន់*[1]*។*

*ទោះបីជាវចនៈរបស់ព្រះពុទ្ធ មានពោរពេញទៅដោយការប្រើប្រាស់វាក្យសព្ទចិត្តវិទ្យា* (Psychological terminology) *ព្រមទាំងការវិភាគបែបចិត្តសាស្ត្រក៏ដោយ ក៏ទិដ្ឋភាពនៃលទ្ធិនេះមិនសូវមានគេយកចិត្តទុកដាក់ទេ លើកលែងតែស្នាដៃដែលបានត្រួសត្រាយដោយ* Mrs. C. R. S. Rhys Davis[2]*។ ក្នុងពេលថ្មីៗនេះចិត្តវិទូលោកខាងលិចម្នាក់ ដែលបានសិក្សាចិត្តវិទ្យាបរិនិព្វាន បាននិយាយថា៖*

*អ្នកណាម្នាក់ ដែលមានចំណេះដឹងច្រើនខាងចិត្តវិទ្យា និងប្រវត្តិរបស់វា ហើយបានចេះអានភាសាបាលី ប្រាកដជាបានរកឃើញការពិត ដែលថា វាក្យសព្ទចិត្តវិទ្យា ដែលសម្បូរនៅក្នុងផ្នែកនេះ មានច្រើនជាងអក្សរសាស្ត្រសម័យបុរាណនៃសាសនាដទៃ និងទទួលបាន*

---

[1] Robert H. Thouless, *Riddel Memorial Lectures*, Oxford, 1940, p. 47

[2] Mrs. C. A. F. Rhys Davids, *Buddhist Psychology*. London, 1914

ចំណេះដឹងផ្សេងទៀត ដើម្បីវិភាគ និងពន្យល់ច្រើនជាងសាសនាផ្សេងទៀត[3]។

ដោយឡែកពីអត្ថន័យដ៏សំខាន់ នាសម័យទំនើបនៃការវិភាគចិត្ត នៅក្នុងព្រះពុទ្ធសាសនានោះ ការយល់ដឹងគ្រប់ផ្នែកនៃលទ្ធិពុទ្ធសាសនាទាំងមូល មិនអាចសម្រេចបានទេ បើសិនជាគ្មានការសិក្សាដ៏ទូលំទូលាយនៃបញ្ញត្តិចិត្ត (Mind) ពុទ្ធិ (Cognition) ចិត្តចលករ (Motivation) និងធម្មជាតិនៃចិត្តរំភើប (Emotion) និងបុគ្គលិកលក្ខណៈ ក្នុងពុទ្ធសាសនា។ គេក៏បានមើលឃើញផងដែរថា ទិដ្ឋភាពចិត្តសាស្ត្រនៃព្រះពុទ្ធសាសនា ត្រូវបានវេញបញ្ចូលគ្នាជាមួយគ្នានូវទិដ្ឋភាពខាងទស្សនវិជ្ជា និងសីលវិទ្យា។ ដោយហេតុផលនេះហើយវាគួរតែមានតម្លៃ ដើម្បីសង្ខេបទិដ្ឋភាពចិត្តនៃលទ្ធិនេះ ធ្វើវាឱ្យមានលក្ខណៈជាប្រព័ន្ធបង្ហាញរបកគំហើញក្នុងក្របខ័ណ្ឌមួយ និងតាមសំនួនវោហារសព្ទដែលផ្តល់ប្រយោជន៍ ដល់ចិត្តវិទ្យាសម័យបច្ចុប្បន្ន។ ទោះជាយ៉ាងណាក៏ដោយមុនពេលយើងសិក្សាដោយផ្ទាល់ ទៅលើខ្លឹមសារនៃវចនៈរបស់ព្រះពុទ្ធ ដែលផ្សារភ្ជាប់គ្នាទៅនឹងការវិភាគបែបចិត្តសាស្ត្រនោះ វាជារឿងចាំបាច់ដើម្បីស្វែងរកឱ្យឃើញនូវមាគ៌ាអ្វី ដែលចិត្តវិទ្យាព្រះពុទ្ធសាសនាមានការពាក់ព័ន្ធគ្នាទៅនឹងផ្នែកផ្សេងៗទៀតនៃលទ្ធិ។

ការសិក្សាដ៏ជិតដល់មួយនៃវចនៈរបស់ព្រះពុទ្ធ[4] នឹងលាតត្រដាងថា ការវិភាគបែបចិត្តសាស្ត្រ បានរកឃើញថា មានការផ្សារភ្ជាប់គ្នារវាងទិដ្ឋភាពទស្សនវិជ្ជាជាទូទៅនៃលទ្ធិ។ ទិដ្ឋភាពជាមូលដ្ឋាននៃទស្សនវិជ្ជាព្រះពុទ្ធសាសនាសម័យដើម នឹងត្រូវគេបែងចែកឱ្យទៅជាវិស័យទាំងឡាយដូចជា ទ្រឹស្តីនៃចំណេះដឹង សីលវិទ្យា ទ្រឹស្តីនៃសង្គម និងទ្រឹស្តីនៃតថភាព។ នៅពេលដែលខ្លឹមសារពាក់ព័ន្ធទៅនឹងចិត្តវិទ្យានៃពុទ្ធិ និងអាកប្បកិរិយា អាចត្រូវបានផ្តាច់ចេញ សម្រាប់ គោលបំណងសិក្សានោះ គុណភាពដោយឡែករបស់វា ត្រូវបានគេយល់ដឹងថា មានទំនាក់ទំនងទៅនឹងទិដ្ឋភាពផ្សេងទៀតនៃលទ្ធិ។

នៅពេលមួយដែលចិត្តវិទ្យាកំពុងប្រយុទ្ធតស៊ូ ដើម្បីបង្ហាញខ្លួន ជាមុខវិជ្ជាស្វ័យភាព (Autonomous discipline) ដោយសម្តែងចេញការផ្សារភ្ជាប់ទំនាក់ទំនងចាស់ និងទស្សនវិជ្ជានោះ ការប៉ុនប៉ងរបស់យើង ដើម្បីចូលទៅក្នុងទិសដៅបញ្ច្រាសគ្នា អាចជាជំហានមួយមានការជាក់ថយក្រោយ។ ទោះជាយ៉ាងនេះក្តី សព្វថ្ងៃនេះ មានចលនាដ៏សំខាន់ ដែលមានន័យសមភាព ជាមួយនឹងវិទ្យាសាស្ត្រអាកប្បកិរិយា ដើម្បីជំនះរបាំងការត្រួតត្រាខាងសាសនា (Parochial fences) និងស្វែងរករូបភាពដ៏ទូលំទូលាយថែមទៀតនៃមនុស្ស និងធម្ម

[3] Rune Johannson, *The psychology of Nirvana* London, 1965, p. 11

[4] The material pertaining to psychology of Buddhism is basically drawn from the *sutta pitaka*.

ជាតិមនុស្ស។ ជាឧទាហរណ៍ នៅក្នុងវិស័យចិត្តវិទ្យារបស់ Carl Rogers បានសង្កត់ធ្ងន់ទៅលើភាពចាំបាច់ដើម្បីអភិវឌ្ឍវិធីសាស្ត្រមួយនៅពេលដែលប្រព្រឹត្តតាមភាពជាក់លាក់ និងភាពថ្លៃថ្នូរជាផ្លូវការនៃវិទ្យាសាស្ត្រអាកប្បកិរិយានោះ នឹងយកចិត្តទុកដាក់ដល់បទពិសោធជាអត្តនោម័តនៃបុគ្គលទាំងឡាយ[5]។ ទស្សនវិទូទាំងឡាយ បានគូសបញ្ជាក់ផងដែរថា ការប៉ុនប៉ង នាំមកការវិភាគបញ្ញត្តិផ្លូវចិត្ត និងសីលវិទ្យារួមគ្នា នឹងនាំទៅដល់ការធ្វើឱ្យមានទៅវិញទៅមកនៃវិស័យទាំងពីរ[6]។

## **១-សីលវិទ្យា និងចិត្តវិទ្យា** ( Ethics and Psychology )

លទ្ធិព្រះពុទ្ធសាសនា ពិតជាបានតម្រូវចិត្តនូវការផ្សំបញ្ចូលគ្នា រវាងទិដ្ឋភាពនៃអាកប្បកិរិយាខាងសីលវិទ្យា និងចិត្តវិទ្យា។ ដោយផ្សារភ្ជាប់គ្នាយ៉ាងជិតស្និទ្ធ ទៅនឹងប្រវត្តិសីលវិទ្យាលោកខាងលិច គួរតែជាសីលវិទ្យារបស់លោកអារីស្តូត។ ការអភិវឌ្ឍគុណធម៌ គឺមិនគ្រាន់តែជាអ្នកកាន់សាសនាដ៏ងងឹតងងល់ ចំពោះក្បួនច្បាប់ប៉ុណ្ណោះទេ ប៉ុន្តែ ថែមទាំងការអភិវឌ្ឍប្រភេទនៃបំណិនដ៏ពិត។ គុណធម៌ ត្រូវបានគេអភិវឌ្ឍ តាមការបណ្តុះទម្លាប់ល្អ និងស្វ័យវិភាគ ជាបន្តបន្ទាប់។

សីលវិទ្យាព្រះពុទ្ធសាសនាមិនគ្រាន់តែត្រូវបានគេកំណត់ដែន ចំពោះការវិភាគបញ្ញត្តិ និងទ្រឹស្តីខាងសីលវិទ្យា ប៉ុន្តែ ថែមទាំងផ្តល់អនុសាសន៍នូវមាគ៌ានៃជីវិត និងគំរូនៃអាកប្បកិរិយា។ ការតម្រង់ទិសជាក់ស្តែងក្នុងធម្មសាស្ត្រព្រះពុទ្ធសាសនានេះ មានមូលដ្ឋានច្បាស់លាស់ នៅក្នុងការយល់ដឹងនៃកត្តាចិត្តសាស្ត្រ ដែលរារាំង ព្រមទាំងលើកកម្ពស់ជីវភាពរស់នៅប្រកបដោយគុណធម៌ សីលវិទ្យាព្រះពុទ្ធសាសនា ត្រូវបានសង្ខេបទៅជាពាក្យទាំងឡាយ ដូចជាកុំប្រព្រឹត្តអំពើអាក្រក់ ចូរបណ្តុះកុសល និងចូរធ្វើឱ្យចិត្តបរិសុទ្ធ(Not do any evil, to cultivate the good and to purify one's mind...)។ ការបណ្តុះកុសល និងការធ្វើឱ្យចិត្តបរិសុទ្ធ ត្រូវធ្វើទន្ទឹមគ្នា។ ការសិក្សាសីលវិទ្យាព្រះពុទ្ធសាសនាដ៏ជិតដល់មួយ បង្ហាញថាវាមានការផ្សារភ្ជាប់នឹងខ្លឹមសារចិត្តវិទ្យា។

នៅផ្នែកផ្សេងទៀតនៃចិត្តវិទ្យាព្រះពុទ្ធសាសនា យើងនឹងយល់ដឹងប្រយោជន៍នៃវាក្យសព្ទខាងចិត្តវិទ្យា ដែលមានភាពលំ អៀង ទៅរកន័យធៀបផ្នែកសីលវិទ្យា។ ជាឧទា ហរណ៍ យោងទៅតាមចិត្តវិទ្យាព្រះពុទ្ធសាសនា មានឫសគល់អំពីចិត្តចលករចំនួន៦គឺសេចក្តីលោភ (Greed) សេចក្តីស្អប់ (Hatred) គំនិតមាយាការ (Delusion) និងពាក្យផ្ទុយរបស់វា គឺភាពសប្បុរស

---

[5] Carl R. Rogers, "Some Thoughts Regarding The Current Philosophy of the Behavioral Sciences", *Journal of Humanistic Psychology*, autumn, 1965.

[6] Stuart Hampshire (ed.), Philosophy of Mind, London, 1966.

(Libe- rality) ភាពចិត្តល្អ (Kindness) និងគតិបណ្ឌិត (Wisdom)។ ឫសគល់៣ ដំបូងនៃចិត្តចលករ និយាយយោងទៅដល់វាក្យសព្ទអកុសល (Akusala) និង៣ផ្សេងទៀត គឺកុសល (Kusala)។ ពាក្យទាំងពីរនេះ គឺកុសល និងអកុសល ជួនកាល ត្រូវបានផ្តល់ឱ្យដោយវាក្យសព្ទសីលវិទ្យាបរិសុទ្ធ គឺល្អនិងអាក្រក់ ឬតាមបច្ចេកសព្ទ ដែលបានតម្រង់ទិសតាមចិត្តវិទ្យា ដែលមានន័យថា ដែលមានសុខភាពល្អ និងមិនល្អ ឬ ដែលមានបំណិន និងដែលគ្មានបំណិន។ ក្នុងន័យជាទូទៅ ដោយឡែកពីន័យធៀបតាមបែបសីលវិទ្យានៃវាក្យសព្ទខាងចិត្តវិទ្យា ដែលជាប្រភេទនៃបាតុភូតចិត្ត (Psychological phenomena) ដែលត្រូវបានជ្រើសរើស ដោយព្រះពុទ្ធ សម្រាប់ការពិភាក្សា និងការវិភាគយ៉ាងយូរ ដែលមានការពាក់ព័ន្ធទៅដល់សំណួរខាងស្មារតី និងខាងសីលវិទ្យាក្នុងលទ្ធិ។ អនុសាសន៍របស់ព្រះពុទ្ធ អំពីអ្វីដែលគួរឱ្យគេចង់បាន អាស្រ័យទៅលើការយល់ដឹងព្រឹត្តិការណ៍នូវអ្វីដែលជាការពិតដែលប្រាថ្នាចង់បានដោយមនុស្ស។ ហេតុដូច្នេះហើយ អនុសាសន៍ដែលទាក់ទងនឹងការព្យាបាលរបស់ព្រះពុទ្ធ ដែលទាក់ ទិនដល់អ្វីដែលគួរប្រាថ្នាចង់បាន គឺពឹងផ្អែកទៅលើការយល់ដឹងដ៏ជ្រាលជ្រៅនៃអ្វី ដែលមនុស្សធាប់ប្រាថ្នាចង់បាន ដែលជាវិថីពីកំណើត និងសក្តានុពលភាព សម្រាប់ការផ្លាស់ប្តូរ និងការដឹកនាំអាកប្បកិរិយារបស់គេឆ្ពោះទៅរកឧត្តមគតិដែលគួរឱ្យចង់បាន តាមលក្ខណៈបែបនេះ បញ្ហាសីលវិទ្យាក្នុងគម្ពីរព្រះត្រៃបិដក ព្រះពុទ្ធសាសនា មិនអាចមានលក្ខណៈ ឬសភាពអាក្រក់ពីមូលដ្ឋានគ្រឹះបែបចិត្តសាស្ត្រនោះទេ។

## ២-សីលវិទ្យាសង្គម និងធម្មជាតិមនុស្ស

នៅពេលដែលប្រភេទនៃសហគមន៍មនុស្ស ដែលព្រះពុទ្ធបានចាត់ទុកថា ជាឧត្តមគតិ ដែលត្រូវបានពឹងផ្អែក ទៅលើអនុសាសន៍សីលវិទ្យានោះ ការវិភាគអាកប្បកិរិយាសង្គម គឺត្រូវបានផ្សារភ្ជាប់ទៅនឹងចិត្តវិទ្យាព្រះពុទ្ធសាសនា។ នៅក្នុងការវិភាគទៅលើមូលដ្ឋានគ្រឹះនៃការចុះសម្រុងគ្នាក្នុងសង្គម (Foundations of social harmony) និងឫសគល់នៃទំនាស់នោះ ទឹកទ្វេងដ៏សំខាន់ គឺត្រូវបានផ្តល់ឱ្យចំពោះការបង្កើតឡើងនូវចិត្តសាស្ត្របុគ្គល។ ក្នុងនាមជាវិធីដោះស្រាយទំនាស់ដំបូងគេ ព្រះពុទ្ធទាមទារថា មនុស្សប្រតិបត្តិស្វ័យវិភាគប្រកប ដោយការយកចិត្តទុកដាក់ជាខ្លាំង និងស្រាវជ្រាវរកឫសគល់នៃការមិនចុះស ម្រុងនឹងខ្លួនគេ ព្រោះនេះ ជាមាគ៌ាដ៏បរិសុទ្ធបំផុតនៃការធ្វើឱ្យមានភាពតានតឹងក្នុងសង្គមថយចុះជាអប្បបរមា។

មូលដ្ឋានគ្រឹះចិត្តវិទ្យានៃសុខុមាលភាពសង្គម បានរៀបរាប់ដោយវាងវៃថា៖

យោងទៅតាមព្រះពុទ្ធ លក្ខខណ្ឌ ដែលមនុស្សម្នាក់ក្នុងនាមជាសត្វរស់នៅក្នុងសង្គម ដែលគួរតែគោរពនោះ គឺមានលក្ខណៈចិត្តសាស្ត្រយ៉ាងទូលំទូលាយ។ ក្នុងករណីជាច្រើន ពួកគេមិន

គ្រាន់តែមានរូបរាងកាយ និងទាក់ទងនឹងបរិស្ថានប៉ុណ្ណោះទេ ប៉ុន្តែ ព្រះអង្គបានចាត់ ទុកខ្លួនឯងវត្តមាននៃលក្ខ ខណ្ឌដ៏គួរឱ្យពេញចិត្តសម្រាប់ជីវិតផ្នែករាងកាយថា ជាការជូនពរដ៏ធំធេងមួយ។

វាជារឿងចាំបាច់មួយផងដែរ ដើម្បីសង្កត់ធ្ងន់ថា គោលបំណងរបស់ព្រះពុទ្ធ ដើម្បីយល់ដឹងដំណើរការចិត្តរបស់មនុស្ស គឺមិនគ្រាន់តែយល់ដឹងចិត្តបុគ្គលម្នាក់នោះទេ ប៉ុន្តែថែមទាំងតាមរយៈការយល់ដឹងគោលការណ៍ជាមូលដ្ឋាន ដើម្បីពន្យល់គំរូអន្តរកម្មសង្គម។ សីលវិទ្យាសង្គមនៃព្រះពុទ្ធសាសនា គឺពឹងផ្អែកទៅលើវិសាលភាពចិត្តវិទ្យាអាកប្បកិរិយាមនុស្សទូលំទូលាយជាងនេះទៀត។ សេចក្តីលោភលន់ សេចក្តីស្អប់ និងគំនិតមាយាការដែលជាឫសគល់នៃស កម្មភាពអកុសលនោះមាននៅក្នុងវិសាលភាពសង្គម។ ឥទ្ធិពលអាក្រក់នៃសេចក្តីលោភលន់ និងសេចក្តីស្អប់មិនមានដែនកំណត់ ចំពោះករណីទាំងឡាយដែលមនុស្សបានក្លាយជាជនរងគ្រោះ តាមបែបអកម្មនៃពលវេគទាំងនេះ។ ជាងនេះទៀត ពួកគេបង្កើតបរិយាកាស ដែលផ្តល់នូវបុគ្គ លិកលក្ខណៈដែលគួរចង់តែបាន (Raga carita) និងបុគ្គលិកលក្ខណៈដែលប្រកប ដោយកំហឹង (Dosa carita, ចរិតទោសៈ)។ ប្រសិន បើយើងត្រូវបានគ្របសង្កត់ដោយចំណង់ខ្លាំង ដែលត្រូវបានប្រ មូលផ្តុំ គរលាក់ទុកនិងយកជាកម្មសិទ្ធិនូវវត្ថុទាំងនោះ យើង បានបង្កើតឱ្យមានទំនោរដូចគ្នានឹងអ្នកដទៃ និងសរសើរដោយឥតបានដឹងនូវប្រភេទបុគ្គលិកលក្ខណៈ ដែលជានិមិត្តសញ្ញាស ង្គម ដែលប្រកបទៅ ដោយការចម្លងគ្នាច្រើនបំផុត។ គំនិតអាក្រក់កើតឡើងដោយមនុស្ស ដែលមានអារម្មណ៍ លោភលន់ (Greedy dispositions) ត្រូវបានរៀប រាប់យ៉ាងច្បាស់លាស់ នៅក្នុងគម្ពីរព្រះពុទ្ធ (Buddhist scriptures) ដែលនាំទៅដល់ត ណ្ហា (Passion) សេចក្តីកំណាញ់ (Avarice) ភាពកំណាច (Wickedness) ជម្លោះ (Quarrelling) និងសេចក្តីព្យាយាម (Strife)។

ចិត្តរំភើបដូចជា ការលោភលន់ ច្រណែន(Envy) ប្រចណ្ឌ(Jealousy) មោទនភាព (Pride) និងសេចក្តីភ័យខ្លាច(Fear) ទាំងអស់មកពីផ្នែកសំខាន់នៃបរិបទអន្តរបុគ្គល ហើយប្រសិនបើយើង មិនចង់ឱ្យមានការរាលដាលគ្រាប់ពូជនៃសេចក្តីមិនស្រុះស្រួលគ្នា (Discord) ទេនោះ យើងត្រូវតែចាប់ផ្តើមជាមួយខ្លួនយើង ហើយបន្ទាប់មក ព្យាយាមជំរុញស្មារតីតែមួយជាមួយអ្នកផ្សេងទៀត។ វាអាស្រ័យទៅលើមូលដ្ឋានគ្រឹះនៃតម្លៃសីលវិទ្យាប្រកបទៅដោយសុខភាព ដែលរចនាសម្ព័ន្ធសង្គមដ៏មានន័យ អាចត្រូវបានស្ថាបនាឡើង នៅពេលនោះ។ ហេតុដូច្នេះហើយ គេអាចនិយាយបានថា នៅពេលដែលមានវត្តមានមូលដ្ឋានគ្រឹះ ចិត្តវិទ្យាចាំបាច់សម្រាប់កសាងសង្គមមួយប្រកបដោយសុខភាពនោះ ព្រះពុទ្ធ បានកាត់បន្ថយផ្លូវបែកជាពីរដែលមានលក្ខណៈ ពន្ធ៌សគ្នាបន្តិច រវាងបុគ្គល និងសង្គម។ គេនិយាយថា ចូរការពារខ្លួន

ឯង ដូចដែលការពារអ្នកដទៃ ហើយចូរការពារអ្នកដទៃ ដូចខ្លួនឯងវិញ។

នៅពេលពលវេគ ប្រឆាំងនឹងសង្គមពិតប្រាកដ ដែលបាននាំដល់ការធ្វើឱ្យសីលធម៌សង្គមថោកទាប (Moral degradation of society) គួរតែត្រូវលុបបំបាត់ចោលនោះ ព្រះពុទ្ធបានផ្តល់ដំបូន្មានឱ្យមានការអភិវឌ្ឍនៃគុណសម្បត្តិស្វ័យគ្រប់គ្រង តាមបែបចិត្តសាស្ត្រដ៏គួរមានតម្លៃ នៅក្នុងសង្គម ការស្ងប់ចិត្ត (Mental calm) និងសេចក្តីអត់ធ្មត់ (Restraint)។ នៅក្នុងបរិបទផ្សេងទៀត នៅកន្លែងណា ដែលព្រះពុទ្ធបានពិភាក្សាកត្តាទាំងឡាយដែលជះឥទ្ធិពលដល់សង្គមនោះ ព្រះអង្គមានពុទ្ធដីកាថា កត្តាក្រខ្សត់ខាងសេដ្ឋកិច្ច (The economic factor of poverty) ទំនោរខាងរាងកាយទៅរកកើតជំងឺ (The bodily prodivity to sickness) និងកត្តាចំណង់ផ្នែកចិត្តសាស្ត្រ (The psycho-logical factor of craving) ទាំងអស់នេះ ត្រូវតែពិចារណាឱ្យបានជិតដល់។

ជាទូទៅ គេបានសន្និដ្ឋានថា សីលវិទ្យាសង្គមរបស់ព្រះពុទ្ធ មាននិយាយទាំងចំណុចវិជ្ជមាន និងអវិជ្ជមាន។ នៅផ្នែកចំណុចអវិជ្ជមាន ការគ្រប់គ្រងកត្តាបុគ្គលិកលក្ខណៈ និងការប្រតិបត្តិ នៃគោលការណ៍សីលវិទ្យា ដែលនឹងបន្ថយទំនាស់សង្គម ហើយនៅផ្នែកវិជ្ជមាន ការអភិវឌ្ឍប្រភេទបុគ្គលិកលក្ខណៈប្រកបដោយសុខភាព និងគោលការណ៍នៃជីវិតរស់នៅ ដែលនឹងលើកកម្ពស់ដល់ការស្ថាបនាសង្គមមួយដ៏ល្អប្រសើរ។ ចក្ខុវិស័យនៃសង្គមបែបនេះ ត្រូវបានគាំទ្រ ដោយបញ្ញត្តិធម្មជាតិមនុស្ស ដែលមិនចេះស្រពោន និងប្រកបដោយឧត្តមគតិដ៏ពិតប្រាកដ។ ព្រះពុទ្ធ បានប្រៀបប្រដូចចិត្តទៅនឹងដុំមាស ដែលត្រូវបានធ្វើឱ្យខូចគុណភាព ជាបណ្តោះអាសន្នដោយ សារដែក (Iron) សំណប៉ាហាំង (Tin) ប្រាក់ (Silver) និងសំណ (Lead)។ រឿងនេះ មិនមានន័យថា ទស្សនៈរបស់ព្រះពុទ្ធស្តីពីមនុស្ស គឺជាទស្សនៈមួយប្រកបដោយឧត្តមគតិនោះទេ។ ព្រះពុទ្ធបានផ្តល់ឱ្យនូវរូបភាពប្រកបដោយតថភាពនៃធម្មជាតិមនុស្ស ដោយទទួលស្គាល់ថា មនុស្សមានសមត្ថភាព ទាំងល្អ និងអាក្រក់។

## ៣-ទ្រឹស្តីនៃចំណេះដឹង

ការបង្កើតទំនាស់ កើតមានចេញពីទ្រឹស្តីបែបបរមត្ថវិទ្យារហូតដល់សម័យកាល នៃព្រះពុទ្ធ និងក្នុងអំឡុងរជ្ជកាលជីវិតព្រះអង្គទៀតនោះ បានលើកឡើងនូវចម្ងល់ ចំពោះមូលដ្ឋាននៃសច្ចភាព។ ឈ្មោះមួយ ដែលត្រូវបានផ្តល់ទៅឱ្យមែកធាងនៃទស្សនវិជ្ជា ដែលស្រាវជ្រាវបញ្ញត្តិនៃចំណេះដឹង សច្ចភាព និងអត្ថន័យ គឺទ្រឹស្តីនៃចំណេះដឹង ដែលជាមុខវិជ្ជារងក្នុងទស្សនវិជ្ជា ដែលជាទូទៅមានការពេញចិត្តនឹងសុភវិនិច្ឆ័យនៃស្វ័យភាព និងកំណត់ដោយជាក់លាក់នូវស្ថានភាព និងដែនកំណត់របស់វា។ រឿងនេះ ហាក់ដូចជាករណីដែលមានការពាក់ព័ន្ធដល់ទស្សនវិជ្ជាព្រះពុទ្ធសាសនាផងដែរ។

ប៉ុន្តែ មានចំណុចគួរឱ្យគេចាប់អារម្មណ៍តិចតួចផ្សេងទៀត ក្នុងទំនាក់ទំនងទៅនឹងព្រះពុទ្ធសាសនា។ ធនធាននៃចំណេះដឹង អាចបែងចែកយ៉ាងទូលំទូលាយ ទៅជាប្រភេទពីរនៃហេតុផល និងបទពិសោធ ហើយបទពិសោធនោះ ត្រូវបានបែងចែកជាផ្នែករងទៅ ជាបទពិសោធ ដែលទទួលបានតាមរយៈសរីរាង្គវិញ្ញាណ និងបទពិសោធតាមអព្ភន្តរញាណ កម្រិតខ្ពស់ជាងនេះ[7]។ ប្រយោជន៍នៃហេតុផល និងបទពិសោធតាមរយៈសរីរាង្គឥន្ទ្រិយ គឺជាទូទៅ ស្ថិតក្នុងវិសាលភាពនៃសត្វលោកកម្រិតមធ្យម ប៉ុន្តែ មានតែមនុស្សដែលបានអភិវឌ្ឍបំណិនអព្ភន្តរញាណរបស់គេតែប៉ុណ្ណោះ ដែលអាចប្រើប្រាស់មាគ៌ា នៃចំណេះដឹងនោះ។ ការផុសចេញប្រភេទបំណិននេះ គឺមិនមែនជារឿងអាថ៌កំបាំងនៅក្នុងព្រះពុទ្ធឡើយ វាគឺជាផលិតផល នៃប្រភេទការបណ្ដុះបណ្ដាលមនុស្សម្នាក់ ដែលបានទទួលរង។ ព្រះពុទ្ធបានស្ថាបនាមាគ៌ាដែលមនុស្សគួរតែអនុវត្តតាម គឺការប្រែប្រួលខាងស្មារតី និងចិត្តសាស្ត្រ ដែលចាំបាច់សម្រាប់ការបង្កើតចំណេះដឹងខាងអព្ភន្តរញាណ។ តាមពិតទៅ វាក្យសព្ទមួយ ដែលប្រសើរជាងចំណេះដឹង ដើម្បីរៀបរាប់ការបង្ហាញការយល់ដឹងបែបនេះ គួរតែជាការយល់ដឹង (Realization)។ នេះជាបញ្ញត្តិបែបពុទ្ធិវិទ្យា ដែលប្លែកគ្នាបន្តិច ទៅនឹងការគិតបច្ចុប្បន្នក្នុងលោកខាងលិច។

វាក៏មានការវិភាគផងដែរពីទម្រង់សុភវិនិច្ឆ័យ (Forms of sensibility) និងវចនាសម្ពន្ធបញ្ញត្តិរបស់យើង ដែលស្ដាប់ទៅហាក់ដូចជាទិដ្ឋភាពមួយនៃអ្វីមួយ ដែលត្រូវបានគេហៅថាពុទ្ធិវិទ្យា ដែលទាក់ទងទៅនឹងសែននាពេលសព្វថ្ងៃនេះ។ ការពេញចិត្ត និងការបង្ខិតបង្ខំ (Predilection and bondage) របស់មនុស្សម្នាក់ដែលទាក់ទង ទៅនឹងពិភពលោក ចំពោះបញ្ញត្តិពិត កំ ណត់បទពិសោធ និងទម្រង់នៃបទពិសោធកម្រិតខ្ពស់ក្នុងព្រះពុទ្ធសាសនា មានហួសពីបញ្ញត្តិ និងវិចាររវើរវាយ។ ដែនកំណត់តាមប្រភេទ ដែលយើងស្វែងរកចំណេះដឹងនោះ គឺជាត្រូវបានដិតស្នាម ចំពោះកម្រិតចំណង់ និងភាពល្ងង់ខ្លៅ។ ទិដ្ឋភាពនៃព្រះពុទ្ធសា សនាបែបនេះមិនអាចត្រូវបានគេធ្វេសប្រហែសបានឡើយ។ ហេតុ ដូច្នេះហើយ ក្នុងការវិភាគបញ្ញត្តិបែបនេះ ព្រះពុទ្ធសា សនា មិនត្រូវបញ្ឈប់ត្រឹមកម្រិតបែបតក្កវិទ្យា ឬភាសាវិទ្យាទេ តែស្វែងរកឱ្យបានជ្រាលជ្រៅជាងនេះទៀត នៅក្នុងហេតុផលចម្បងផ្នែកចិត្តសាស្ត្រ។ ទិដ្ឋភាពពុទ្ធសាសនាទាំងនេះ ដែលមិនទាក់ទងដល់បំណែងចែក នៃការសិក្សាស្រាវជ្រាវបែបទស្សនវិជ្ជា ដែលបានបង្កើត

[7] The Sangatava Sutta refers three groups of thinkers: (1) Traditionalists, (2) Rationalists and Metaphysicians, (3) Experientialists who had personal experience of a higher knowledge.

ឡើង អាចផ្តល់ផលដល់ព្រឹត្តិការណ៍គួរឱ្យចាប់អារម្មណ៍ ចំពោះជនដែលស្រាវជ្រាវគំរូថ្មីនៃពុទ្ធិវិទ្យា[8]។ បញ្ហាខាងវិធីសាស្ត្រ ដែលត្រូវបានពិភាក្សា ក្នុងជំពូកនេះ ក៏ទាក់ទងផងដែរដល់វិស័យនៃពុទ្ធិវិទ្យា។

## ៤-ទ្រឹស្តីនៃតថភាព

ធម្មជាតិនៃបាតុភូតចិត្ត មិនអាចត្រូវបានគេញែកឱ្យដាច់ទាំងស្រុង ចេញពីបញ្ញត្តិជាមូលដ្ឋាន នៃតថភាពក្នុងព្រះពុទ្ធសាស នាទេ។ បញ្ហាទាំងឡាយដែលជាប់ទាក់ទងនឹងរចនាសម្ព័ន្ធនៃចក្រវាឡ និងធម្មជាតិនៃមនុស្ស បង្កើតឡើងនូវបញ្ហាដ៏សំខាន់ ដែលទាក់ទងទៅនឹងបាតុភូតខាងរាងកាយ និងសីលធម៌ ព្រមទាំងផ្នែកចិត្តសាស្ត្រ។ ទោះជាយ៉ាងនេះក្តី ព្រះពុទ្ធសាសនា បានបែងចែកភាពខុសគ្នា នូវវិស័យជាច្រើននៃច្បាប់ ឬនិយាមចក្រវាឡ ដែលកំពុងប្រព្រឹត្តទៅមានដូចជា ច្បាប់ ឬនិយាមខាងរាងកាយ និយាមខាងជីវសាស្ត្រ និយាមខាងចិត្តសាស្ត្រ និយាមខាងសីលធម៌ និងនិយាមដែលទាក់ ទងទៅនឹងស្មារតី។ នៅពេលដែលនិយាមទាំងអស់ (លើកលែងតែនិយាមចុងក្រោយ) ដំណើរការជា មួយវិស័យដោយឡែកៗ ជាបន្តបន្ទាប់នោះ វិស័យចុងក្រោយ មិនជាប់ទាក់ទងទៅនឹងវិស័យទាំងអស់នោះទេ។ ព្រោះហេតុដូច្នោះហើយ វិស័យបាតុភូតចិត្ត គឺជាវិស័យសិក្សាដោយឡែកមួយ ប៉ុន្តែ នៅពេលចាំបាច់ វាត្រូវបានគេដាក់ជាមួយវិស័យទូលំទូលាយជាងនេះ តាមគោលការណ៍សហេតុធម៌ដូចនេះឯង។ គំរូព្រឹត្តិការណ៍ទាំងនេះ អាចទាំងបច្ច័យនិយម និងអបច្ច័យនិយម តែងបានបង្ហាញខ្លួនឯងថា ជាទំនោរដែលទំនងនឹងកើតឡើងជាជាងផល ដែលមិនអាចចៀសវាងបាន។

ទោះបីជាសកម្មភាពរបស់មនុស្ស អាចត្រូវបានកំណត់លក្ខខណ្ឌ តាមច្បាប់ទាំងនេះមួយចំនួនក៏ដោយក៏គេមិនត្រូវបាន កំណត់តាមច្បាប់ណាមួយនៃច្បាប់ទាំងនេះដែរ។ ជាទូទៅ ព្រះពុទ្ធ បានប្រឆាំងទៅនឹងទម្រង់ទាំងអស់ នៃបច្ច័យនិយម (Deter- minism) ថា តើបច្ច័យនិយមតាមបែបធម្មជាតិ (Natural determinism) បច្ច័យនិយម តាមទេវនិយម (Theistic determinism) បច្ច័យនិយមតាមកម្ម (Karmic determinism) ឬទស្សនវិជ្ជាណាមួយផ្សេងទៀត ដែលទិដ្ឋភាពទាំងនេះ ត្រូវបានគេរួមផ្សំបញ្ចូល។

ជាទូទៅ ទ្រឹស្តីហេតុផលរបស់ព្រះពុទ្ធផ្តល់នូវការផ្សាយព័ត៌មាន តាមកម្រិតកំពូលនៃបច្ច័យនិយម និងអបច្ច័យនិយម។ យោងទៅតាមបច្ច័យនិយមដ៏តឹងរ៉ឹងនោះ បច្ចុប្បន្ន និងអតីតកាល មិនអាចផ្លាស់ប្តូរបានឡើយ ប៉ុន្តែ

[8] For an analysis of the Buddhist theory of knowledge, see K. N. Jayatilleke, *Early Buddhist Theory of Knowledge* (London, 1963).

ព្រះពុទ្ធ បានប្រព្រឹត្តតាមឆន្ទៈសេរី (Free will) ដោយយោងទៅតាមបុគ្គលណាមួយដែលអាច ចំពោះវិសាលភាពដ៏ពិត គ្រប់គ្រងកម្លាំងដ៏មាន ថាមពលនៃអតីតកាលនិងបច្ចុប្បន្ន ព្រមទាំង ទិសដៅនាពេលអនាគតផងដែរ។ មនុស្សមាន ឆន្ទៈសេរីនិងការខិតខំប្រឹងប្រែងជាបុគ្គល (Personal endeavour: Purisa kara) ហើយមាន លទ្ធភាពផ្លាស់ប្តូរទាំងខ្លួនឯង និងបរិស្ថាន។ បញ្ញត្តិនៃលទ្ធភាព សម្រាប់សកម្មភាពបែបនេះ ចងភ្ជាប់សកម្មភាពមនុស្សជាពិសេស នៅក្នុង វិស័យអាកប្បកិរិយាផ្នែកសីលធម៌ ស្មារតី ចិត្ត ផងដែរ ដែលជារូបភាពមួយនៃមនុស្ស ដែល ក្រោកឈរ ប្រឆាំងនឹងប្រវត្តិអតីតកាលនៃការ វិភាគចិត្តរបស់យើង (The background of our psychological analysis) ក្នុងស្នាដៃនេះ។

សិស្សរបស់ព្រះពុទ្ធណាម្នាក់ ដែល មានភាពវៃឆ្លាត ដើម្បីតាមស្វែងរកទ្រឹស្តីតថភាព នៃព្រះពុទ្ធសាសនា នឹងរកឃើញនូវ ប្រភពខ្លឹមសារដ៏សម្បូរបែបក្នុងព្រះសូត្រ ដែល ព្រះពុទ្ធបានវិភាគត្រឹមត្រូវនៃវចនាសម្ព័ន្ធ និង ការប្រកាសសច្ចភាពផ្សេងៗ នៅក្នុងទ្រឹស្តីបែប បរមត្ថវិទ្យា ដែលបានកើតឡើងនៅក្នុងពេល នោះ។ តាមពិតទៅ មានអ្នកផ្តើមគំនិត៦នាក់ ដែលព្រះពុទ្ធ បានពិភាក្សាជាមួយគឺ Makkhali Gosala ដែលជាវេទនិយម និងបានប្រព្រឹត្ត តាម ទស្សនៈដែលថា ពិភពលោក ត្រូវបានបង្កើត និងនាំផ្លូវដោយឆន្ទៈព្រះ។ Ajita Kesa- kambali ដែលជាសម្ភារវិទូនិយម បានអះអាងថា មនុស្ស ត្រូវបានសាបសូន្យ នៅពេលស្លាប់ ហើយគ្មាន មូលដ្ឋានណាមួយ សម្រាប់អតិវឌ្ឍជីវិត ប្រកបដោយគុណធម៌នោះទេ។ Sanjaya Belatthiputta ដែលជាមនុស្សម្នាក់មិនជឿទៅ លើសាសនា បានអះអាងថា សញ្ញាណ មូលដ្ឋានពិតប្រាកដដូចជា ជំនឿនៅក្នុងជាតិក្រោយ (After-life) និងការទទួលខុសត្រូវផ្នែកសីលធម៌ (Moral responsibility) មិនអាចបកស្រាយឬផ្ទៀងផ្ទាត់ប្រកបដោយវិចារណញ្ញាណ។ Purana Kassapa បច្ច័យវិទូនិយមតាមបែបធម្មជាតិ (Natural determinist) មិនអាចមើលឃើញអត្ថន័យ ណាមួយ នៅក្នុងការបែងចែកភាពខុសគ្នារវាងអំពើល្អ និងអាក្រក់។ Pakutha Kac- cayana ដែលបានប៉ុនប៉ងពន្យល់ធម្មជាតិនៃតថភាព តាមវាក្យសព្ទដាច់ដោយឡែកពីគ្នា ហើយគាត់ត្រូវបានគេប្រសិទ្ធនាម ថាជាប្រភេទវិទូនិយម (Categoralist) ហើយនៅចុងបញ្ចប់ Nigantha Nataputa ដែលជាសាពេក្ខភាពវិទូនិយម (Relativist) បានមើលឃើញសច្ចភាពមួយចំនួន ក្នុងគ្រប់ចំណុចនៃទស្សនៈ។

ការវាយតម្លៃល្អិតល្អន់នៃទ្រឹស្តីបែបនេះ ស្ថិតនៅក្នុងមែកធាងនៃទស្សនវិជ្ជាពីរ ដែលត្រូវ បានគេនិយាយយោងទៅដល់ពុទ្ធិវិទ្យា និង បរមត្ថវិទ្យា (ឬត្រូវបានហៅតាមវាក្យសព្ទ ដែល ប្រសើរជាងនេះថា ទ្រឹស្តីនៃតថភាព)។ ប៉ុន្តែ ទ្រឹស្តីផ្សេងៗ ដែលត្រូវបានគេពិនិត្យមើល ក្នុង ការពិភាក្សាបែបនេះ គឺមានការជាប់ទាក់ទង ទៅនឹងក្របខ័ណ្ឌ ដែលក្នុងនោះ ការសិក្សាអំពី

បាតុភូតធម្មសាស្ត្រ ឬចិត្តសាស្ត្រ គឺត្រូវបានគេស្វែងរកបន្ទាប់មកទៀត។ ឧទាហរណ៍ បញ្ញត្តិនៃឆន្ទៈសេរី មានសារៈសំខាន់ចាំបាច់ ចំពោះសីលវិទ្យា ឋានៈ និងធម្មជាតិនៃច្បាប់ ហេតុផល គឺមានភាពទាក់ទងដ៏ធំធេងក្នុងការយល់ដឹងបាតុភូតចិត្ត។

ដោយឡែកអំពីការសិក្សាច្បាប់ហេតុផល លទ្ធិជាមូលដ្ឋាន ដូចជាអនិច្ចៈ (Impermanence: anicca) ទុក្ខៈ (Suffering: dukkha) និងអនត្តៈ (Egolessness: anatta) មានភាពលំអៀងទៅរកការពិភាក្សានៃសភាពចិត្តក្នុងព្រះពុទ្ធសាសនា។ តាមពិតទៅ លទ្ធិអនត្តៈ គឺជាគន្លឹះដល់ការយល់ដឹង ចំពោះការវិភាគចិត្តវិទ្យាព្រះពុទ្ធសាសនា។ តាមគំនិតលោកខាងលិចនាពេលបច្ចុប្បន្ន ការសិក្សាទាំងឡាយ មានការជាប់ពាក់ព័ន្ធទៅនឹងក្របខ័ណ្ឌ ដែលក្នុងនោះបញ្ញត្តិចិត្ត ត្រូវបានកើតចេញថ្មីៗពីទស្សនវិជ្ជា ដែលត្រូវបានគេស្គាល់ថា ជាចិត្តវិទ្យាបែបទស្សនវិជ្ជាហើយចិត្តវិទ្យាបែបសង្កេតពិសោធអាច ផ្តួចផ្តើមចេញពីមុខវិជ្ជាផ្សេងៗ ផ្សេងទៀតនៃការអង្កេត ដែលនឹងត្រូវបានគេហៅថា ចិត្តវិទ្យាអភិវឌ្ឍ។ នៅក្នុងមុខវិជ្ជា ដែលទាក់ទងទៅនឹងបញ្ហាការព្យាបាលរោគចិត្ត ត្រូវបានគេលើកឡើង អំពីរូបភាព និងទ្រឹស្តីមនុស្ស ដែលពឹងផ្អែកទៅលើប្រព័ន្ធព្យាបាលរោគ។ ចិត្តវិទ្យាព្រះពុទ្ធសាសនាផងដែរ គឺពឹងផ្អែកយ៉ាងច្បាស់លាស់ទៅលើទ្រឹស្តីមនុស្ស និងចក្រវាឡ។

## ៥-មូលដ្ឋាននៃការព្យាបាលរោគនៃចិត្តវិទ្យាព្រះពុទ្ធសាសនា

ចិត្តវិទ្យាព្រះពុទ្ធសាសនា មានការខុសប្លែកអំពីវិស័យមួយចំនួន ដែលការសិក្សាស្រាវជ្រាវបែបចិត្តវិទ្យា ត្រូវបានគេស្វែងរកផលប្រយោជន៍ផ្ទាល់ខ្លួន ពីព្រោះ ព្រះពុទ្ធ បានស្វែងរកបញ្ហាបែបទ្រឹស្តី តែនៅពេលណាដែលវាមានជាប់ទាក់ទងទៅនឹងស្ថានភាពដ៏លំបាកនៃសេចក្តីទុក្ខវេទនារបស់មនុស្ស។ ចិត្តវិទ្យាព្រះពុទ្ធសាសនា ត្រូវបានរៀបចំជាលើកដំបូង ដើម្បីឆ្លើយទៅនឹងសំណួរៈ

1-អ្វីជាមូលហេតុនៃសេចក្តីទុក្ខ?

2-អ្វីជាមធ្យោបាយ រំដោះរួចផុតអំពីវា?

មូលដ្ឋានព្យាបាលរោគនៃចិត្តវិទ្យាព្រះពុទ្ធសាសនាផ្តល់នូវសទិសភាពដ៏សំខាន់ និងគួរឱ្យចាប់អារម្មណ៍នៃទស្សនវិទ្យាព្រះពុទ្ធសាសនា។

នៅពេលដែល Wittgenstein បានប៉ុនប៉ងនូវការវិភាគរោគអប្រក្រតីភាពបែបតក្កវិទ្យាដ៏ជាក់លាក់នោះ គាត់បានបន្សល់ទុកឬសគល់ចិត្តសាស្ត្រ ថាជាការនៅខាងក្រៅការរៀបរាប់ដ៏តឹងរ៉ឹងនៃបញ្ហា ដោយយោងទៅតាមវិធីសាស្ត្ររបស់គាត់។ នៅពេលដែលការវិភាគរបស់ព្រះពុទ្ធនៃរចនាសម្ព័ន្ធតាមបែបតក្កវិទ្យានៃចម្ងល់ដ៏មានភាពវាងវៃ អាចបំបែករឿងនេះ ចេញពីឬសគល់បែបចិត្តសាស្ត្រនោះ ទិដ្ឋភាព២ ពិតជាអាចបំពេញគ្នាឱ្យទៅជាភាពទាំងមូល។ នៅពេលដែលព្រះពុទ្ធ ត្រូវបានប្រឈមមុខនឹងគំនិតផ្សេងៗគ្នា មិនល្អនៃទ្រឹស្តី និងមនោគម

វិជ្ជាទាំងឡាយនោះ ព្រះអង្គ មិនគ្រាន់តែធ្វើការវិភាគដោយម៉ត់ចត់ តាមពន្លឺលក្ខណៈវិនិច្ឆ័យប្រកបដោយតក្កភាព និងទិន្នន័យតាមបែបពិសោធនោះទេ ប៉ុន្តែ ថែមទាំងបានបំពេញបន្ថែមនូវការសិក្សា តាមការចង្អុលទៅដល់ឫសគល់ចិត្តសាស្ត្រ ដែលផ្តល់ទ្រឹស្តី ដែលត្រូវបានប្រឌិតខុស ដោយកត់សម្គាល់ឃើញថា ចំណង់បង្កើតឱ្យមានទ្រឹស្តីបែបបរមត្ថវិទ្យា បង្កើតឱ្យមានចំណង់ទាំងឡាយ។

តាមគំនិតនេះ នៅពេលដែលព្រះពុទ្ធ ពិនិត្យមើលលទ្ធិនៃអមតភាពរបស់បុគ្គលនោះ ព្រះអង្គពិនិត្យឃើញឫសគល់បែបភាសាវិទ្យា និងតក្កវិទ្យា ព្រមទាំងឫសគល់នៃចិត្តរំភើប នៃទស្សនអនន្តនិយម។ យ៉ាងហោចណាស់ ក៏មានហេតុផលល្អចំនួន២ សម្រាប់ធ្វើកិច្ចការនេះ គឺប្រសិនបើយើងព្រមទទួលយកនូវអត្តដ៏ពិតជាអចិន្ត្រៃយ៍ធ្វើជាឧទាហរណ៍នោះ វាអាចធ្វើទៅបាន ដើម្បីបកស្រាយបដិបក្ខភាពខាងក្នុងដ៏ពិតប្រាកដ ហើយរហូតមកដល់ពេលនេះ ក្នុងតថភាពជីវិត ទោះបីជាមានជំនឿស៊ប់ដោយវាងវៃក៏ដោយ គេមិនអាចកំចាត់ចោលមន្តអាគម ដែលបញ្ញត្តិមួយបែបនេះ នឹងបន្តប្រើប្រាស់នោះទេ។

ព្រះពុទ្ធ ក៏បានបង្ហាញផងដែរនូវអសារភាពនៃការពិភាក្សាដ៏វាងវៃ ហួសពីចំណុចដ៏ពិតទាំងនេះ។ តម្លាភាពបែបតក្កវិទ្យា គឺមានប្រយោជន៍គ្រាន់តែជាជំហានដំបូង ព្រោះមានទស្សនៈដ៏ពិតទាំងឡាយ ដែលអាចមានរូបរាងនៃសនិទានភាព និងនៅតែមានភាពក្លែងក្លាយ។ បន្ទាប់ពីមានលំនាំនៃតម្លាភាពបែបតក្កវិទ្យាមកនោះ គេគួរតែអភិវឌ្ឍថាមពលនៃស្វ័យវិភាគ ការយកចិត្តទុកដាក់ និងការយល់ដឹងទាំងឡាយ។ ការយល់ដឹងអំពីមូលដ្ឋានចិត្តសាស្ត្រនៃទស្សនៈខុសឆ្គង ឈានទៅដល់មធ្យោបាយមួយ ដែលនឹងជួយដល់មនុស្សម្នាក់ ដើម្បីគ្រប់គ្រងនូវចំណង់របស់ខ្លួន បំបាត់នូវភាពលំអៀង និងអភិវឌ្ឍមូលដ្ឋានគ្រឹះនៃការយល់ដឹង។ នៅដំណាក់កាលនេះហើយ ដែលគាត់នឹងមើលឃើញពិភពលោក តាមរបៀបថ្មី និងឆ្លងកាត់ការផ្លាស់ប្តូរប្រែប្រួលនៃទស្សនវិស័យ។

វាជារឿងចាំបាច់ណាស់ ដើម្បីសង្កត់ធ្ងន់ជាថ្មីម្តងទៀតថា ព្រះពុទ្ធ មិនបានស្វែងរកបញ្ហាបែបតក្កវិទ្យា បរមត្ថវិទ្យា ឬចិត្តវិទ្យា សម្រាប់ប្រយោជន៍ព្រះអង្គផ្ទាល់ខ្លួននោះទេ។ នៅក្នុងគម្ពីរសុត្តន្តបិតក Cula-Malunkya ព្រះពុទ្ធ បានប្រៀបធៀបបរមត្ថវិទូ ទៅនឹងមនុស្សម្នាក់ ដែលត្រូវបានរងរបួសដោយព្រួញ ហើយសួរសំណួរថា តើអ្នកណាតម្រង់ព្រួញ? តើគេស្ថិតក្នុងវណ្ណៈអ្វី? តើគេខ្ពស់ ឬទាប ស ឬខ្មៅ? តើធ្នូនោះ គឺប្រភេទណា?។ល។ ប្រសិនបើគាត់ បន្តលើកឡើងនូវសំណួរប្រភេទនោះ ដោយមិនបានយកចិត្តទុកដាក់ដល់ជំងឺ របស់គាត់ទេនោះ គាត់នឹងស្លាប់ ហើយមនុស្សដែលចង់កំចាត់ការឈឺចាប់ គឺប្រៀបប្រដូចទៅនឹងមនុស្សម្នាក់ ដែលត្រូវតែព្យាបាលជំងឺរបស់គាត់។

នៅក្នុងគម្ពីរសុត្តន្តបិដកទេវទហៈ (Devadaha sutta)ផងដែរ ព្រះពុទ្ធ គឺប្រៀបប្រដូចទៅនឹងគ្រូពេទ្យម្នាក់។ ប៉ុន្តែ តាំងតែពីទស្សនវិជ្ជា និងចិត្តវិទ្យាព្រះពុទ្ធសាសនា ត្រូវបានគេតម្រង់ទិសលើការព្យាបាល (Therapy oriented)នោះ សមានលក្ខណ៍រវាងព្រះពុទ្ធ និងគ្រូពេទ្យ មិនបានបញ្ចប់ នៅទីនោះទេ។ នៅពេលដែលទស្សនវិជ្ជា ផ្តល់នូវមធ្យោបាយសម្រាប់ដោះស្រាយប ញ្ហាដោយវាងវៃនោះ ក៏ចិត្តវិទ្យាផ្តល់នូវការព្យាបាលសម្រាប់ការរំខានផ្លូវអារម្មណ៍។

នៅក្នុងបរិបទនៃចិត្តវិទ្យាទំនើប ពាក្យព្យាបាលត្រូវបានគេប្រើជាញឹកញាប់ក្នុងន័យរឹតបន្តឹងនៃបច្ចេកទេស សម្រាប់ការព្យាបាលជំងឺផ្លូវចិត្ត។ ប៉ុន្តែ នៅក្នុងអំឡុងពេល២ ឬ៣ទស វត្សរ៍ចុងក្រោយនេះ ក្របខ័ណ្ឌនៃការព្យាបាលរោគ ត្រូវបានបើកទូលាយ គឺចន្លោះភាពចង្អៀត រវាងជំងឺផ្លូវចិត្ត និងសុខភាព ត្រូវបានគេលើកជាសំណួរឡើង។ សង្គមទាំងមូលមានជំងឺ ហើយចិត្តវិទូ ដូចជា Fromm បាននិយាយយោងទៅដល់រោគសាស្រ្ត ដែលមានភាពធម្មតា (Pathology of normalcy) ហើយបង្កើនចំនួនទទួលរងគ្រោះ តាមទម្រង់អប្រក្រតីភាពខាងអាកប្បកិរិយាទាបជាង។

បញ្ញត្តិនៃការព្យាបាល ដែលកំពុងពង្រីកន័យទាំងនេះ និងចំណុចនៃការទាក់ ទងជាមួយសាសនាទាំងឡាយ នៅអាស៊ី ត្រូវបានលេចឮឡើង នៅក្នុងសម្ដីដូចជាសាសនា ហ្សេន[9] និងចិត្តវិភាគព្រមទាំងចិត្តវិទ្យាលោកហ្វ្រីត (Freudian psychology) និងព្រះពុទ្ធសាសនា។

Fromm និយាយថា សូម្បីតែស្នាដៃរបស់ Freud ក៏មិនជាការព្យាបាលរោគចិត្តទាំងស្រុងដែរ ប៉ុន្តែ មានការយកចិត្តទុក ដាក់ ទៅនឹងសេរីភាពនៃមនុស្សពីអកុលតានិងការបង្ខិតបង្ខំបែបអវិចារណញ្ញាណ។ វាក៏មានការប្រែប្រួលផ្លាស់ប្តូរ ដ៏សំខាន់នៃប្រ យោជន៍ ក្នុងប្រភេទរបស់អ្នកជំងឺផងដែរ។ ព្រោះ Fromm បាននិយាយថា ចិត្តវិភាគ បានធ្វើឱ្យមានការ ប្រែប្រួលការសង្កត់ធ្ងន់ថែមទៀត ពីការព្យាបាលរោគសញ្ញាវិកលចរិត (Neurotic symptoms) ទៅដល់ការព្យាបាល បញ្ហាការលំបាកក្នុងជីវភាពរស់នៅដែលមានឫសគល់ នៅក្នុងអត្តចរិតវិកលចរិត។

ចិត្តវិទូសម័យបច្ចុប្បន្ន មានការចាប់អារម្មណ៍ ទៅលើបញ្ហាការកែតម្រូវទូលំទូលាយជាង និងគំរូនៃរោគសាស្រ្តសង្គម (Social pathology)។ ការពិតដែលថា មនុស្សក្នុងសង្គមឧស្សាហកម្មជឿនលឿន នៅក្នុងប្រទេសសម្បូរធនធាន ត្រូវបានលងបន្លាចដោយភាពទទេនៅផ្នែកខាងក្នុង និងការគិតឃើញត្រឹមត្រូវនៃ

[9] Zen is the Japanese form of Buddhism that stresses the importance of meditation more than the reading of religious writings.

ភាពមិនស្និទ្ធ និងការខ្វះទិសដៅនៅក្នុងជីវិតដដែលៗ ត្រូវបានហៅថា ការពង្រីកបញ្ញត្តិ និងគោលដៅនៃការព្យាបាលរោគចិត្ត។ ក្នុងពន្លឺនៃតម្រូវការទាំងនេះ និងចក្ខុវិស័យ ដែលកំពុងមានការផ្លាស់ប្តូរនៃជំងឺ និងសុខភាពនោះបញ្ញត្តិព្រះពុទ្ធនៃការព្យាបាលរោគ សមនឹងមានការពិចារណាដ៏ម៉ត់ចត់។

ព្រះពុទ្ធមានពុទ្ធដីកាថា មនុស្សរស់នៅរួមគ្នា ដោយលក្ខខណ្ឌរបស់គេបង្កើតបានទៅជាទំនាស់ទោមនស្ស (Discontent) និងអកុលតា និងឫសគល់ដ៏រឹងមាំនៃភាពលោភលន់ សេចក្តីស្អប់ និងគំនិតមាយាការ (Delusion) ដែលទ្រទ្រង់ភាពជាប់ថប់អារម្មណ៍របស់មនុស្ស នឹងគ្រាន់តែត្រូវបានធ្វើឱ្យស្ងប់ទាំងស្រុង និងបំបាត់ចោល នៅពេលដែលចូលនិព្វាន ទោះបីជាមនុស្សអាចទទួលរងការឈឺចាប់ពីជំងឺខាងផ្លូវកាយជាបន្តបន្ទាប់ក៏ដោយ ក៏ជំងឺផ្លូវចិត្តនឹងទទួលបាននូវជ័យជំនះ ដរាបណាឫសគល់នៃតណ្ហា (The roots of passion) ពិរោធន៍ (Animosity) និងអវិជ្ជា ត្រូវបានគេលុបបំបាត់ចោលទាំងស្រុង។ រូបមន្តព្រះពុទ្ធ សម្រាប់ជួយរំដោះមនុស្សឱ្យរួចផុតពីការធុញថប់ក្នុងអារម្មណ៍នៅក្នុងខ្លួន អាចត្រូវបានបកស្រាយតាមកម្រិត ២គឺ៖

1-ឯកវាសី (Recluse) ដែលលះបង់ (Renounce) ពិភពលោក នឹងស្វែងរកគោលដៅកម្រិតនៃភាពស្ងប់ស្ងាត់ និងសន្តិភាពទាំងស្រុង (Utter quietude and peace)។

2-មេផ្ទះ ដែលបង្កើតនូវការចេះសម្របសម្រួលជាមួយជីវភាពរស់នៅ ចេះស្វែងរកជីវិតមួយនៃការលះបង់ចោល (Renunciation) មិនអាចធ្វើទៅបាន ឬលំបាក នឹងស្វែងរកឧត្តមគតិនៃជីវិតដ៏ត្រឹមត្រូវ និងការចេះសម្របសម្រួលជាផ្លូវមួយ (សម្មាចរិយា និងធម្មចរិយា: Samacariya, Dhammacariya)។

## ៦-បញ្ហាចម្បងៗនៅក្នុងចិត្តវិទ្យាព្រះពុទ្ធសាសនា

ប្រសិនបើយើងពិនិត្យមើលមួយក្រឡេក ទៅលើចិត្តវិទូ ដែលគេបានស្គាល់ និងដែលបានផ្តើមគំនិតមួយចំនួន នៅក្នុងប្រទេសលោកខាងលិចនោះ គេនឹងយល់ឃើញថា បញ្ហាក្នុងវិស័យមួយចំនួនដ៏ពិត ជាមជ្ឈមណ្ឌលនៃការសិក្សា និងការស្រាវជ្រាវ គឺចិត្តវិទ្យាកេស្តាល់ Gestalt[10] បានចាប់អារម្មណ៍ជាចម្បងទៅលើប្រត្យក្សារម្មណ៍ ចិត្តវិភាគរបស់Freud បានចាប់អារម្មណ៍ទៅលើចិត្តចលករ(Motivation) និងបុគ្គលិកលក្ខណៈ ព្រមទាំងអាកប្បកិរិយានិយម នៅក្នុងការសិក្សា។

[10] Gestalt ជាភាសាអាល្លឺម៉ង់ មានន័យថា ទម្រង់ ឬរូបរាង។

ចាប់តាំងតែពីមានការយកចិត្តទុកដាក់ខ្លាំង ទៅលើចិត្តវិទ្យាព្រះពុទ្ធសាសនា គឺជាតម្រូវការ ដើម្បីស្វែងរកឫសគល់នៃសេចក្តីទុក្ខវេទនារបស់មនុស្ស និងបានបង្ហាញផ្លូវ ដើម្បីគេចចេញពីសេចក្តីទុក្ខវេទនានោះ ការសិក្សាពីចិត្តវិទ្យានៃចិត្តចលករ និងចិត្តរំភើប ជាមជ្ឈមណ្ឌលនៃការផ្តោតអារម្មណ៍ ទៅលើការវិភាគនៃលទ្ធិនេះ។ តាមពិតទៅ ការពិភាក្សា ពីបាតុភូតចិត្តក្នុងស្នាដៃនេះ នឹងជាមជ្ឈមណ្ឌលដ៏ចម្បង ស្តីអំពីត្រីលក្ខណៈនៃចិត្តចលករ ចិត្តរំភើបនិងបុគ្គលិកលក្ខណៈ។ យើងនឹងពិនិត្យមើលដោយពិស្តារនូវទ្រឹស្តីនៃចិត្តចលករចំណង់ជាមូលដ្ឋាន (Basic drives) និងសភាវគតិ (Instincts) ធម្មជាតិនៃកត្តាចិត្តចលករអញ្ញាណ (The nature of unconscious motives) និងជាទូទៅវិសាលភាពនៃអាកប្បកិរិយានៃទំនោរ និងក្តីស្រឡាញ់។ ចិត្តវិទ្យាពុទ្ធិ នឹងត្រូវបានគេចាប់ផ្តើមជាការសិក្សាចិត្តចលករ។

សូម្បីតែនៅក្នុងស្នាដៃ ដែលបានត្រួសត្រាយដោយ Mrs Rhys Davis ការនិយាយយោងទៅដល់ គឺត្រូវបានបង្កើតឡើង ចំពោះការសិក្សាដោយកម្រទៅលើការវិភាគនៃចិត្តរំភើប និងសភាវគតិក្នុងព្រះពុទ្ធសាសនា និងការសិក្សានៃបុគ្គលិកលក្ខណៈ គឺជាវិស័យមួយ ដែលមិនយកចិត្តទុកដាក់ឱ្យបានស្មើគ្នា។ ទោះជាយ៉ាងណាក៏ដោយ មានបញ្ហាលំបាកមួយចំនួន ក្នុងការពិភាក្សាចិត្តវិទ្យាបុគ្គលិកលក្ខណៈនៅក្នុងលទ្ធិមួយ។ ហេតុផលដ៏សំខាន់មួយ សម្រាប់រឿងនេះ គឺថានៅក្នុងព្រះពុទ្ធសាសនា ខ្លឹមសារ ដែលទាក់ទងទៅនឹងទស្សនវិជ្ជានៃមនុស្ស និងចិត្តវិទ្យាបុគ្គលិកលក្ខណៈ គឺត្រូវបានវេញបញ្ចូលគ្នា។ ប្រហែលជារឿងនេះដោយសារតែមជ្ឈមណ្ឌលនៃលទ្ធិអនត្តៈ (Egolessness: Anatta) និងការផ្សារភ្ជាប់ទាំងចិត្តវិទ្យាបុគ្គលិកលក្ខណៈ ទាំងការវិភាគផ្នែកទស្សនវិជ្ជានៃបញ្ញត្តិមនុស្ស។ បញ្ហាមួយ ត្រូវបានគេលើកឡើងថាតើប្រព័ន្ធទស្សនវិជ្ជា ដែលបដិសេធអត្តជាអចិន្ត្រៃយ៍នោះ បង្កើតសំណើការសិក្សានៃបុគ្គលិកលក្ខណៈ។ នៅពេលដែលការពិភាក្សានៃបញ្ញត្តិខាងព្រះពុទ្ធសាសនា នៃបុគ្គលិលក្ខណៈ ផ្តល់នូវមធ្យោបាយណាមួយដើម្បីធ្វើឱ្យរឿងនេះ កាន់តែច្បាស់លាស់នោះ វាអាចត្រូវបានគេលើកឡើងថា ចិត្តវិទ្យាប្រកបដោយថាមភាពមួយ ដូចជាព្រះពុទ្ធសាសនា អាចផ្តល់នូវមូលដ្ឋាន គួរជាទីចូលចិត្ត សម្រាប់ការសិក្សាបែបនេះ។

មជ្ឈមណ្ឌលសិក្សា ដែលទាក់ទងទៅនឹងចិត្តចលករ ចិត្តរំភើប និងបុគ្គលិកលក្ខណៈ នឹងត្រូវបានគេសន្និដ្ឋាន តាមការបង្ហាញរចនាសម្ព័ន្ធផ្នែកពេគ នៃចិត្តវិទ្យាព្រះពុទ្ធសាសនា ក្នុងទស្សនវិស័យ ដែលមានការប្រៀបធៀប។ នៅទីនេះ លក្ខណៈពិសេសខាងចិត្តសាស្ត្រ នៃការព្យាបាលខាងពុទ្ធសាសនា ត្រូវបានបង្ហាញតាមវាក្យសព្ទនៃប្រព័ន្ធគឺចិត្ត វិភាគរបស់ Freud ចិត្តវិទ្យាមនុស្សនិយមរបស់ Rogers and Maslow

ការព្យាបាលរោគតាមបែបអត្ថិភាព និងការព្យាបាលរោគតាមបែបអាកប្បកិរិយានិយម។

### ៧-ប្រភពនាំចេញ សម្រាប់ការសិក្សាចិត្តវិទ្យាព្រះពុទ្ធសាសនា

ការសិក្សារបស់យើង មានការពាក់ព័ន្ធជាចម្បងទៅនឹងប្រព័ន្ធកម្ម និងការបកស្រាយនៃការអង្កេត តាមបែបចិត្តសាស្ត្រ នៃព្រះពុទ្ធសាស នាសម័យដើម។ ពាក្យសម្ដីដើមរបស់ព្រះពុទ្ធ ដែលជាភាសាបាលី ត្រូវបានចែកចេញជា២ផ្នែកគឺ៖

១-ការប្រៀនប្រដៅដ៏ចម្បងរបស់ព្រះពុទ្ធ ដែលមាននៅក្នុងសុត្តន្តបិដក។

២-ក្បួនច្បាប់វិន័យ សម្រាប់ព្រះសង្ឃ ដែលត្រូវបាននិយាយយោងដល់វិន័យបិដក។

៣-ការពន្យល់ជាប្រព័ន្ធនៃសុត្តន្តបិដក ដែលត្រូវបានគេនិយាយយោង ទៅដល់អភិធម្មបិដក ដែលជាស្នាដៃនៃអ្នកផ្ដើមគំនិតជាប្រព័ន្ធនាពេលក្រោយ ហើយទោះបីជាការកត់សម្គាល់ ដ៏មានតម្លៃ សម្រាប់ការវិភាគខាងចិត្តសាស្ត្រក៏ដោយ ក៏ជួនកាល ហួសពីសម្ដីដើមរបស់ព្រះពុទ្ធ។

អភិធម្ម ដែលជាការប៉ុនប៉ងជាបឋម ដើម្បីប្រមូលផ្ដុំចងក្រងខ្លឹមសារ ដែលទាក់ទងដល់ការវិភាគផ្នែកចិត្តសាស្ត្រ ក្នុងពន្លឺនៃសម្ដីដើមរបស់ព្រះពុទ្ធនោះ គួរតែទាក់ទាញនិស្សិតផ្នែកចិត្តវិទ្យា ប៉ុន្តែ វាជារឿងសំខាន់ សម្រាប់និស្សិតជាលើកដំបូង ដើម្បីធ្វើការសិក្សា ដោយម្ចាស់ការនៃសម្ដីរបស់ព្រះពុទ្ធ ដែលមានផ្ទុកក្នុងសុត្តន្តបិដក។ តាមពិតទៅ មនុស្សណាម្នាក់ ដែលពេញចិត្តនឹងការសិក្សាសម្ដីដើមរបស់ព្រះពុទ្ធ ត្រូវបានផ្ដល់ដំបូន្មានឱ្យសិក្សា សុត្តន្តបិដកជាមុនសិន។ ភាគច្រើននៃផ្នែកនេះ ត្រូវបានគេបកប្រែជាភាសាអង់គ្លេស ហើយខ្លឹមសារក្នុងស្នាដៃនេះ ត្រូវបានទាក់ទាញជាលើកដំបូងពីសុត្តន្តបិដក។

សុត្តន្តបិដក អាចត្រូវបានគេបែងចែកទៅជា៥ ផ្នែកគឺ:

1-The Dialogues of the Buddha (The Digha Nikaya) ទីឃនិកាយ

2-The Middle Length Sayings (The Majjhima Nikaya)មជ្ឈិមនិកាយ

3-Kindred Sayings (The Samyutta Nikaya) សំយុត្តនិកាយ

4-Gradual Sayings (The Anguttra Nikaya) អង្គុត្តរនិកាយ

5-Division of Small Works (The Khuddaka Nikaya) ខុទ្ទកនិកាយ

គេបានប៉ុនប៉ង ដើម្បីបង្ហាញខ្លឹមសារតាមរបៀបងាយស្រួល និងច្បាស់លាស់ អាចធ្វើបាន។ វាត្រូវបានគេរៀបចំផងដែរ តាមរបៀបមួយដែលនិស្សិត មិនមានចំណេះដឹងខាងភាសាបាលី នឹងមានលទ្ធភាព បន្ទុជ្ឈភាពណាមួយនៃចិត្តវិទ្យាព្រះពុទ្ធសាសនា ដោយមានជំនួយអំពីការបកប្រែភាសាអង់គ្លេស។ និស្សិតទាំងនេះ អាចសិក្សាការពិចារណា ដើម្បីសិក្សា

ភាសាបាលីបាន ប្រសិនបើគាត់មានចាប់អារម្មណ៍ សិក្សាឱ្យបានដិតដល់ ពីប្រភពទាំងឡាយជាមួយគំនិតរបស់ព្រះពុទ្ធ។ ទោះបីជាកម្រិតនៃភាពស្មុគស្មាញ អំពីលទ្ធិព្រះពុទ្ធសាសនា អាចជាប្រយោជន៍ដំបូង នៅក្នុងប្រធានបទចម្បង ដែលបានបង្ហាញនៅទីនេះក៏ដោយ ក៏និស្សិត ដែលមានចំណេះដឹងបឋមនៃព្រះពុទ្ធសាសនា គួរតែមានលទ្ធភាពបង្កើតមាគ៌ារបស់ខ្លួនតាមរយៈជំពូកចុងក្រោយៗ គេក៏រំពឹងដែរថា សំនួនវោហារសព្ទ និងក្របខ័ណ្ឌ ដែលក្នុងនោះខ្លឹមសារត្រូវបានបង្ហាញនោះ នឹងជួយសម្រួលដល់ទំនាក់ទំនងនៃគំនិតទាំងនេះដល់និស្សិតចិត្តវិទ្យា ដែលបានចាប់អារម្មណ៍ ដល់ការឆ្លុះបញ្ចាំងខាងចិត្តវិទ្យារបស់ព្រះពុទ្ធ។

## ៨-បញ្ហាវិធីសាស្រ្តមួយចំនួន

សារៈសំខាន់នៃប្រព័ន្ធមួយរបស់ចិត្តវិទ្យា គឺមិនគ្រាន់តែវាយតម្លៃតាមវាក្យសព្ទនៃបញ្ហា ដែលវាបានពិភាក្សាប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងតាមវាក្យសព្ទនៃវិធីសាស្រ្ត ដែលវាគាំទ្រ ដើម្បីផ្ទៀងផ្ទាត់អំណះអំណាង សម្មតិកម្ម និងទ្រឹស្តីដែលវាបានបង្ហាញ។ តាមទស្សនៈធម្មជាតិនៃប្រភពខ្លឹមសារ ដែលគេបានផ្តល់នូវចំណុចសំខាន់ៗនោះ អ្វីជាបច្ចេកទេស ដែលព្រះពុទ្ធបានទ្រទ្រង់ សម្រាប់ការវិភាគ និងការធ្វើតេស្តទ្រឹស្តី និងអំណះអំណាង ដែលទាក់ទងទៅនឹងបាតុភូតចិត្ត នៅក្នុងព្រះគម្ពីរព្រះពុទ្ធសាសនា នាសម័យដើម?

នៅក្នុងគម្ពីរSangarava Sutta មានការនិយាយយោងទៅដល់អ្នកផ្តើមគំនិត៣ក្រុមៈ

1-អ្នកប្រពៃណីនិយម(The traditionalists)

2-អ្នកវិចារណញ្ញាណនិយម និងបរមត្ថវិទូនិយម (The rationalists and metaphy- sicians)

3-អ្នកពិសោធនិយម (The experiential-lists) ដែលមានបទពិសោធចំណេះដឹងខ្ពស់ ពីមនុស្ស។

ព្រះពុទ្ធក៏មានពុទ្ធដីកាថា ព្រះអង្គ ស្ថិតនៅក្នុងក្រុមទី៣។ លក្ខណៈវិនិច្ឆ័យនៃការវិនិច្ឆ័យសច្ចភាពនៃទ្រឹស្តីមួយមិនស្ថិតនៅលើតែប្រពៃណីប្រយោជន៍នៃហេតុផលបែបតក្កភាព ឬប៉ាន់ស្មានជាមុនទេ។ វាត្រូវបានគេធ្វើតេស្ត តាមបទពិសោធ។ បទពិសោធនៃទិសដៅកំណត់ គឺមិនមែនជាបទពិសោធ ដែលគិតឃើញត្រឹមត្រូវប៉ុណ្ណោះទេ ប៉ុន្តែ ក៏ជាបទពិសោធផ្នែកអព្ភន្តរញាណ និងការយល់ដឹង។ ទម្ងន់នៃប្រពៃណីប្រយោជន៍នៃតក្កភាព និងវិចារ មានដែនកំណត់ និងសំណើដ៏រឹងមាំ ដល់បទពិសោធ គឺជារឿងចាំបាច់។

នៅពេលដែលប្រយោជន៍នៃវិចារ គឺជាកំណែប្រែដ៏ត្រឹមត្រូវ ចំពោះរឿងរ៉ាវ ដែលអាចទទួលយកបាន ស្តីពីពាក្យចចាមអារាម ឬឥទ្ធិពលនោះ វិចារដែលពឹងផ្អែកទៅលើតក្កភាព គឺមិនមែនជាលក្ខណៈវិនិច្ឆ័យគ្រប់គ្រាន់ សម្រាប់ធ្វើតេស្តទៅលើជំនឿមួយបានទេ។ ប៉ុន្តែ នៅ

ពេលដែលយើងនិយាយថា ព្រះពុទ្ធ បង្កើតនូវសំណើដ៏រឹងមាំ ដល់បទពិសោធនោះ វាត្រូវបានគេអះអាងយ៉ាងច្បាស់លាស់នូវអ្វីដែលព្រះពុទ្ធ មានពុទ្ធដីកាតាមវាក្យសព្ទបទពិសោធ។ ដោយឡែកពីព័ត៌មាន ដែលទទួលបានដោយសរីរាង្គឥន្ទ្រិយទាំង៥ ដែលមានភ្នែក ត្រចៀក ច្រមុះ អណ្តាត និងការប៉ះផ្ទាល់ខាងរាងកាយនោះ ព្រះពុទ្ធ ក៏បានពិចារណាអត្តាពិគ្រោះ គឺជាបច្ចេកទេសមួយដ៏មានតម្លៃបំផុត សម្រាប់ទទួលបានចំ ណេះដឹង និងអភិវឌ្ឍការយល់ដឹង។ អត្តាពិគ្រោះគឺជាវិសាលភាពទាំងមូលនៃបទពិសោធពីការពិចារណា ចិត្តខ្លួនឯងផ្ទាល់ទៅដល់ការយល់ដឹងថែមទៀត ដែលពន្លេចកម្រិតផ្សេងៗគ្នានៃការអភិវឌ្ឍខាងស្មារតី។ ព្រោះហេតុដូច្នេះហើយ គេបានសង្កត់ធ្ងន់ថា ការទទួលយកបច្ចេកទេសមួយដូច្នេះពីវិធីសាស្ត្រអាកប្បកិរិយានិយម ដែលបដិសេធនូវអត្តាពិគ្រោះ។ ប៉ុន្តែ សូម្បីតែចិត្តវិទ្យាលោកខាងលិចដែលទទួលយកអត្តាពិគ្រោះ ថាជាវិធីដែលអាចសម្រេចបាននោះ នឹងមិនមែនជាបច្ចេកទេសនៃអត្តាពិគ្រោះ ដែលឡើងដល់កម្រិតកំពូល ក្នុងការយល់ដឹងខាងស្មារតីទេ។ ទោះជាយ៉ាងនេះក្តី ប្រយោជន៍នៃអត្តាពិគ្រោះនៅកម្រិតលោកិយមួយថែមទៀត នឹងជារឿងសាមញ្ញ ចំពោះទាំងព្រះពុទ្ធសា សនា និងសមភាគីលោកខាងលិច។

ប្រយោជន៍នៃស្វ័យវិភាគ សម្រាប់ទស្សនៈចង្អៀត និងមិនលំអៀងនៃការបង្កើតឡើងនូវចិត្តរំភើបផ្ទាល់ខ្លួន គឺត្រូវបានគេផ្តល់យោបល់ក្នុងព្រះពុទ្ធសាសនា។ តម្លៃនៃអត្តាពិគ្រោះ គឺត្រូវបានពិភាក្សាក្នុងព្រះគម្ពីរមួយដែលត្រូវ បានគេហៅថា Anumana sutta។ នៅក្នុងសុត្តន្តបិដកនេះ មានការនិយាយយោងទៅដល់មនុស្សម្នាក់ ដែលចិត្តរបស់គាត់ពិបាកប្រដៅ ពិបាកបង្រៀន និងមិនអាចស្តាប់អ្នកផ្សេងនិយាយ។ មនុស្សម្នាក់បែបនេះ គឺស្ថិតនៅក្នុងសេវគតិភាពនៃចំណង់ដ៏អាក្រក់ អ្នកស្វែងរកកំហុស ពោរពេញដោយកំហឹង (Wrathful) ស្តីបន្ទោសអ្នកផ្សេង(Reproves others) បង្អាប់អ្នកផ្សេង (Disparages others)។ល។ នៅក្នុងបរិបទនេះ ការឆ្លុះបញ្ចាំងជាបន្តបន្ទាប់ អំពីគុណសម្បត្តិផ្ទាល់របស់ខ្លួន ត្រូវផ្តល់ជំបូន្មាននះ

មនុស្សម្នាក់ ដែលមានចំណង់អាក្រក់ និងដែលស្ថិតក្នុងសេវគតិភាពនៃចំណង់ដ៏អា ក្រក់នេះ មនុស្សម្នាក់នោះ គឺកំពុងតែខឹងមួរម៉ៅ និងមិនយល់ស្របនឹងខ្ញុំ ហើយដូចគ្នានេះដែរ ប្រសិន បើខ្ញុំមានចំណង់អាក្រក់ និងស្ថិតក្នុងសេវគតិភាពនៃចំណង់អាក្រក់នោះ ខ្ញុំនឹងមានការខឹងមួរម៉ៅនិងអរមណីយ (Disagreeable) ចំពោះអ្នកផ្សេង។

បច្ចេកទេសនេះ ត្រូវបាននិយាយយោងដល់ថាជាវិធីមួយដែល អត្តគួរតែត្រូវបានឆ្លុះបញ្ចាំងដោយអត្ត (Self ought to be reflected by self) ហើយអត្តគួរតែត្រូវបានវាស់វែង ដោយទល់នឹងអត្ត (Self ought to be measured against self)។

ប្រសិនបើមនុស្សម្នាក់ ដែលស្ថិតនៅក្នុងជីវភាពដ៏សំខាន់ និងពេញចិត្តនឹងគ្រឿង តុបតែងសញ្ញឹងគិតខ្លាំង ទៅលើការផ្ដោតកញ្ចក់ដ៏ស្អាតនោះ នៅខណៈពេលនោះ គាត់មើលឃើញកំទេចធូលីមួយ គាត់នឹងជូតសំអាតវាចេញ។ មនុស្សដែលប្រើប្រាស់អត្តាពិ គ្រោះ ដើម្បីលុបបំបាត់សភាពចិត្តដ៏អាក្រក់ នឹងកំចាត់វាចេញយ៉ាងឆាប់រហ័ស។

ពាក្យប្រៀបទៅនឹងកញ្ចក់ ដើម្បីរៀបរាប់ប្រយោជន៍នៃអត្តាពិគ្រោះ ត្រូវបានរកឃើញ នៅក្នុងដំបូន្មាន របស់ពហុលផងដែរ។ បញ្ញត្តិនៃការពិនិត្យមើលខ្លួនឯង តាមការផ្ដោតបញ្ចាំងទៅលើសភាពចិត្ត គឺជាវិធីមួយ ដែលជាញឹកញាប់គាំទ្រដល់ការទទួលបានរូប ភាពពិតមួយអំពីខ្លួនឯង។ អត្តាពិគ្រោះ គឺជាវិធីដ៏សំខាន់ សម្រាប់ព្រះពុទ្ធ ពីព្រោះស្វ័យចំណេះដឹង គឺជាការយកចិត្តទុក ដាក់ជាដំបូងនៃចិត្តវិទ្យាព្រះពុទ្ធសាសនា។ អត្តាពិគ្រោះ អាចត្រូវបានគេប្រើប្រាស់ដើម្បីទទួលបានសច្ចភាពអរូបីថែមទៀត គឺគេអាចពិចារណាក្នុងចិត្ត ដូចជាក្នុងឧទាហរណ៍ David Hume បានធ្វើដែរនោះ និងបានរកឃើញតែលំដាប់នៃការចាប់អារម្មណ៍ គំនិត និងសញ្ចេតនា ជាជាងអត្តអចិន្ត្រៃយ៍ណាមួយ។

ក្នុងអត្តាពិគ្រោះ ចិត្តវិទ្យាលោកខាងលិច ជាញឹកញាប់ ត្រូវបានគេចាត់ទុកជាបច្ចេកទេស មិនគួរឱ្យទុកចិត្ត សម្រាប់ការសិក្សាបាតុភូតចិត្ត ពីព្រោះបទពិសោធផ្ទាល់ខ្លួនរបស់យើង មិនអាចត្រូវបានត្រួតពិនិត្យមើលដោយអ្នកផ្សេងទេ។ ដោយយោងទៅតាមព្រះពុទ្ធ អត្តាពិគ្រោះ អាចត្រូវបានបណ្ដុះតាមវិធីសាស្ត្រនោះ ភាពលំអៀង អាចត្រូវបានគេលុបចោល និងឥទ្ធិពលនៃការផ្ដោតបញ្ចាំងរបស់យើង ត្រូវបានចម្រាញ់ឱ្យបានល្អ។ នៅពេលដែលការអភិវឌ្ឍចិត្ត ត្រូវបានបន្តតាមវិធីមួយនោះ វាជារឿងអាចធ្វើទៅបាន ដើម្បីសម្រេចបានឥទ្ធិពលតាមសរីរផ្គឥន្ទ្រិយ ពិសេសដូចជាទូរវេទន៍ និងប្រាជ្ញាញាណ។ ការអភិវឌ្ឍអត្តាពិគ្រោះនូវកម្រិតការតាំងភាវនា ត្រូវបានគេចាត់ទុកថា ជាកម្មវិស័យភាព (Objectivity)៖

នៅពេលដែលមនុស្សម្នាក់ គួរសង្កេតមនុស្សម្នាក់ផ្សេងទៀត ជាកម្មវត្ថុនោះ មនុស្សម្នាក់ ដែលកំពុងតែឈរនោះ គួរសង្កេតមនុស្សម្នាក់ដែលបានអង្គុយ ឬមនុស្សម្នាក់ដែលបានអង្គុយ ឬកំពុងតែដេក។ ដោយហេតុដូច្នេះ កម្មវត្ថុនៃអត្តាពិគ្រោះ គួរត្រូវបានគេយល់យ៉ាងច្បាស់លាស់ ផ្ដោតបញ្ចាំងយ៉ាងច្បាស់លាស់ សម្លឹងមើលយ៉ាងច្បាស់លាស់ និងជ្រួតជ្រាបបានយ៉ាងច្បាស់លាស់ ជាមួយចំណេះដឹងរបស់របស់គេ។

ពិតហើយ អត្តាពិគ្រោះ ជាបច្ចេកទេសដំបូងនៃការព្យាបាលរោគ និងមានការតាំងភាវនា (Meditation) ២ប្រភេទ ដែលត្រូវបានផ្ដល់ដំបូន្មានដោយព្រះពុទ្ធ គឺការតាំងភាវនា ឱ្យស្ងប់អារម្មណ៍ (Tranquillity meditation: Samatha) និងការតាំងភាវនា ដើម្បីយល់ដឹង ឬវិបស្សនា

(Insight meditation: Vipassana)។ *ការតាំងការនា ដើម្បីយល់ដឹង ជាបច្ចេកទេសមូលដ្ឋាន ដែលអភិវឌ្ឍការយល់ដឹងអត្តាពិគ្រោះ។ មានការពិភាក្សាដ៏សំខាន់ពីរឿងនេះ នៅក្នុងគម្ពីរអង្គុតរនិកាយ* (Angutara Nikaya)៖

*ប្រសិនជាត្រូវបានអប់រំមែនតើប្រយោជន៍បែបណាដែលការស្ងប់អារម្មណ៍ទទួលបាន? ចិត្តត្រូវបានអប់រំហើយ។ តើប្រយោជន៍បែបណា ទទួលបានពីចិត្ត ដែលត្រូវបានគេអប់រំ? កាមមុច្ឆា*(Lust) *ទាំងអស់ត្រូវបានគេលះបង់ចោល។ ប្រសិនបើអត្តាពិគ្រោះ ត្រូវបានគេអប់រំបណ្តុះបណ្តាល តើគេទទួលបានប្រយោជន៍អ្វី? ការយល់ដឹង ត្រូវបានគេអប់រំបណ្តុះប ណ្តាល។ ប្រសិនបើការយល់ដឹងត្រូវបានគេអប់រំបណ្តុះបណ្តាល តើគេទទួលបានប្រយោជន៍អ្វី? អវិជ្ជា ទាំងអស់ត្រូវបានគេលះបង់ចោល។ ចិត្តដែលត្រូវបានប្រមាថដោយកាមមុច្ឆា មិនមានសេរីភាពទេ ទាំងការយល់ដឹង មិនអាចប្រមាថដោយអវិជ្ជា ត្រូវបានបណ្តុះបណ្តាលឡើង។ តាមការពិតទៅ ការបញ្ចប់នៃកាមមុច្ឆានេះ គឺការដោបញ្ចប់ចិត្តនៅក្នុងបេះដូង ការបញ្ចប់អវិជ្ជានេះ គឺជាការរំដោះតាមការយល់ដឹង។*

*ទោះបីជាអត្តាពិគ្រោះ គឺជាបច្ចេកទេសដ៏សំខាន់ នៅក្នុងចិត្តវិទ្យាព្រះពុទ្ធសាសនាក៏ដោយ ក៏មានការសុំឱ្យធ្វើតេស្តទៅលើអាកប្បកិរិយាផងដែរ។ នៅក្នុងរជ្ជកាលព្រះពុទ្ធ មិនមានបច្ចេកទេសមន្ទីរពិសោធដែលបានអភិវឌ្ឍទេ ប៉ុន្តែ តម្លៃនៃបទពិសោធបុគ្គល នៅក្នុងសភាព នៃស្ថានភាពតេស្ត គឺអាចទទួលយកបានដោយព្រះអង្គ។ មានការនិយាយយោងដល់មជ្ឈោ បាយ៤យ៉ាងនៃការយល់ដឹងអត្តចរិតរបស់មនុស្សគឺ៖*

*1-តាមការរស់នៅរួមគ្នាជាមួយមនុស្សម្នាក់ ដែលគេអាចរកឃើញ ថាតើមនុស្សម្នាក់ស្របទៅតាមសកម្មភាពរបស់ខ្លួន។*

*2-ហើយប្រសិនបើដូច្នេះមែន ថាតើគាត់ជាមនុស្សមានគុណធម៌ទេ។*

*3-តាមរបៀបដូចគ្នានេះ ភាពសុចរិត* (Integrity) *របស់មនុស្សម្នាក់ អាចត្រូវបានគេ ធ្វើតេស្តតាមការដោះស្រាយបញ្ហាជាមួយគាត់។*

*4-ភាពអត់ធ្មត់* (Fortitude) *របស់មនុស្សម្នាក់ អាចត្រូវបានគេធ្វើតេស្ត តាមស្ថានភាពមានវិបត្តិនិងគតិបណ្ឌិតរបស់គាត់នៅក្នុងការសន្ទនា។*

*របៀបដែលមនុស្សម្នាក់ប្រព្រឹត្ត ក្នុងស្ថានភាពដ៏ពិសេសមួយ ឬស្ថានភាពដូចគ្នានេះ មួយចំនួន ក្នុងអំឡុងពេលវេលាមួយពិតប្រាកដ ផ្តល់ឱ្យយើងនូវការចង្អុលបង្ហាញពីអត្តចរិត របស់មនុស្សម្នាក់។ គេក៏បាននិយាយផងដែរ ពីព្រះពុទ្ធដែលធម្មទេសនា និងសកម្មភាព របស់ព្រះអង្គ មានភាពកើតឡើងស្របគ្នា។*

### ៩-បញ្ញត្តិនៃចិត្ត

គេបានប៉ុនប៉ងរួចមកហើយ ដើម្បីធ្វើទំនាក់ទំនងចិត្តវិទ្យាព្រះពុទ្ធសាសនា ទៅនឹងទស្ស នវិជ្ជាព្រះពុទ្ធសាសនា និងកិច្ចការជាបឋមនៃការវិភាគរោគ និងការជួយសម្រាលទុក្ខវេទ នារបស់មនុស្ស។ គេក៏បាននិយាយយោងទៅដល់វិស័យបញ្ហាចម្បង នៃចិត្តវិទ្យាព្រះពុទ្ធសាសនា និងធម្មជាតិនៃប្រកពខ្លឹមសារ ដែលត្រូវបានគេប្រើប្រាស់នៅក្នុងការពិភាក្សា បញ្ញត្តិចិត្តវិទ្យាព្រះពុទ្ធសាស នា ព្រមទាំងរៀបរាប់ដោយសង្ខេបវិធីមួយចំនួននៃការវិភាគ តាមចិត្តវិទ្យា។ គេនឹងសន្និដ្ឋានជំពូកនេះ តាមការសរុបដោយសង្ខេបនៃបញ្ញត្តិចិត្តរបស់ព្រះពុទ្ធ បញ្ញត្តិមួយ ដែលនឹងស្ថិតនៅជាប្រវត្តិដើមនៃការសិក្សាចិត្តវិទ្យាព្រះពុទ្ធសាសនា។

ព្រះពុទ្ធបានបដិសេធអត្ថិភាពនៃអង្គជាអចិន្ត្រៃយ៍ ថាតើគេចាត់ទុកវាជាចិត្ត ឬ ញាណទេ។ អ្វីដែលគេនិយាយយោងទៅដល់ថាជាចិត្ត គឺពិតជាអង្គមានទំនាក់ទំនងរវាងចិត្ត និងរាងកាយ (Nama-Rupa)។

Nama ត្រូវបានគេនិយាយយោងទៅដល់ក្រុម ដែលមិនមែនជាវត្ថុ ឬខន្ធ(Khandhas) ចំនួន៤គឺ៖

1-វេទនា (Vedana: Feeling)

2-សញ្ញា (Sanna: Sense-impressions, images, ideas, concepts)

3-សង្ខារ (Sankhara: Conative activity, dispositions)

4-និងវិញ្ញាណ(Vinnana: Consciousness)

ពាក្យ រូប និយាយយោងដល់ធាតុទាំបាច់ចំនួន៤គឺ:

-ការលូតលាស់ (Extension)

-ភាពជាប់ទាក់ទងខាងសាច់ញាតិ (Cohesion)

-កម្តៅ (Heat)

-រូបរាងជាសម្ភារ: (The material shape) ដែលកើតចេញពីធាតុទាំងនោះ។

ការផ្សំខាងរាងកាយ និងចិត្ត បង្កើតបានជាអង្គមួយ ហើយចិត្តមានការពឹងពាក់គ្នាទៅវិញទៅមកលើរាងកាយ និងរាងកាយ ក៏មានការពឹងពាក់គ្នាទៅលើចិត្ត។

បាតុភូតចិត្តទាំងអស់ ត្រូវបានយល់ដឹងតាមពន្លឺនៃច្បាប់ហេតុផល ពីព្រោះវាមានលក្ខខណ្ឌទៅតាមហេតុផល។ ច្បាប់នៃប្រកព ដែលមានការពឹងពាក់គ្នា ឬបដិច្ចសមុប្បាទ (The law of depen- dent origination: Paticcasamuppada) បង្ហាញលក្ខខណ្ឌនៃបាតុភូតចិត្ត និងរាងកាយទាំងអស់។

ទ្រឹស្តីបដិច្ចសមុប្បាទ ជាសកម្មភាពភ្ជាប់ហេតុទៅនឹងផល។ទ្រឹស្តីនេះបានបញ្ជាក់ថា៖

-បើមាននេះ គឺមាននោះ

-បើគ្មាននេះ គឺគ្មាននោះ

-បើនេះរលត់ នោះក៏រលត់។ល។

តាមទ្រឹស្តីនេះ គ្មានភាវៈណាមួយ កើតឡើងតែឯង ដោយគ្មានទំនាក់ទំនងនឹងភាវៈផ្សេងទៀតទេ ហើយក៏គ្មានភាវៈណាសំខាន់ដែរ (គ្មានភាវៈដើម"ព្រហ្មន"ដូចសាសនា

ព្រាហ្មណ៍ឡើយ) ចំពោះការវិលកើតវិលស្លាប់របស់មនុស្ស ទ្រឹស្តីបដិច្ចសមុប្បាទ បានលើកយកទំនាក់ទំនងវាងបុព្វហេតុទាំង១២ ដូចខាងក្រោម៖

1-អវិជ្ជា ( Ignorance ) នាំឱ្យកើតសង្ខារ

2-សង្ខារ ( Formation; Impression ) នាំឱ្យកើតវិញ្ញាណ

3-វិញ្ញាណ ( Conscience ) នាំឱ្យកើតនាមរូប

4-នាមរូប ( Mentalite et physique; Name and form ) នាំឱ្យកើតអាយតនៈ

5-អាយតនៈ ( Sens; Sense organs)នាំឱ្យកើតផស្សៈ

6-ផស្សៈ ( Contact sensoriel; Feeling ) នាំឱ្យកើតវេទនា

7-វេទនា ( Sensation; Pain )នាំឱ្យកើតណ្ហា

8-តណ្ហា (Desir; soif; Sense enjoyment ) នាំឱ្យឧបាទាន

9-ឧបាទាន ( Attachement ) នាំឱ្យកើតភព

1០-ភព ( Existence ) នាំឱ្យកើតជាតិ

11-ជាតិ ( Naissance; Rebirth and stratification ) នាំឱ្យជរា

12-ជរា ( Vieillesse; Old age )នាំឱ្យកើតមរណៈ ( Mort; Death )

បើហេតុណាមួយកើតឡើង ហេតុឯទៀតឡើងបន្តបន្ទាប់គ្នា។

**ឧទាហរណ៍៖** បើមានអវិជ្ជា សង្ខារ វិញ្ញាណ និងហេតុផ្សេងៗ កើតមានឡើងបន្តៗគ្នារហូតដល់ជរា និងមរណា ផ្ទុយទៅវិញបើគ្មានអវិជ្ជា អ្វីៗទាំងអស់ក៏រលត់ទាំងអស់ដែលហៅថា និរោធ។

នៅពេលដែលទ្រឹស្តីបដិច្ចសមុប្បាទបង្ហាញថា បាតុភូតចិត្តទាំងអស់ មានលក្ខខណ្ឌជាហេតុនោះ លទ្ធិអនត្តភាព ចង្អុលបង្ហាញការពិត ដែលថា មិនមានទាំងបាតុភូតចិត្ត និងរាងកាយទាំងក្នុង និងក្រៅ ដែលជាសារធាតុ ដែលស្ថិតនៅ ជាមួយគ្នាជានិច្ចកាលទេ។

លទ្ធិទាំងពីរនេះ ផ្តល់នូវមូលដ្ឋានគ្រឹះសម្រាប់ការយល់ដឹងបញ្ញត្តិនៃចិត្ត នៅក្នុងចិត្តវិទ្យាព្រះពុទ្ធសាសនា៖

បដិច្ចសមុប្បាទ ជាលទ្ធិនៃភាពដែលមានលក្ខខណ្ឌនៃបាតុភូតចិត្ត និងរាងកាយ ដែលជាលទ្ធិមួយផ្សំគ្នា ជាមួយអបុគ្គលិកលក្ខណៈ (Impersonality: Anatta)នោះ បង្កើតលក្ខខណ្ឌដែលមានសារៈសំខាន់ចាំបាច់បំផុត សម្រាប់ការយល់ដឹងតថភាព នៃការប្រៀនប្រដៅរបស់ព្រះពុទ្ធ។

ក្នុងការពន្យល់បាតុភូតទី១ ចូរអ្នកពិចារ ណាទៅលើគោលវិធីសំយោគ (Synthetic approach)និងទី២ គោលវិធីវិភាគ (Analy- tic approach) គឺការវិភាគទ្រឹស្តីបដិច្ច សមុប្បាទ បង្ហាញភាពពឹងពាក់គ្នា និងភាពឯករាជ្យ នៃបាតុភូត ពីព្រោះក្នុងការវិភាគផ្សេងទៀត ជាផ្នែកនៃបុគ្គលិកលក្ខណៈដូចជា សញ្ចេតនា គំនិត ចំណាប់អារម្មណ៍ តាមរយៈសរីរាង្គឥន្ទ្រិយញាណ ឆន្ទៈ។ល។ ត្រូវបានលាតត្រដាង នៅក្នុងលក្ខណៈ ពិសេសខុសៗគ្នា។

យោងទៅតាមចិត្តវិទ្យាពុទ្ធសាសនា ចិត្តមានកម្រិតខុសគ្នាទៅតាមថាមភាព ដែលមានវិសា លភាព ទៅតាមកំណើតមួយចំនួនដែលមិនអាចរាប់បាន។ ចិត្ត អាចជាញាណនិងអញ្ញាណ។ ចិត្តអញ្ញាណ មានផ្ទុកទៅដោយលំនឹក ដែលទទួលខុសត្រូវផ្នែកលំនឹក ដែលមានវិសាលភាពហួសពីមួយជីវិតបុគ្គល។ បញ្ហាថាតើមានរឿងរ៉ាវទាំងឡាយដូចជា លំនឹក ដែលមានហួសពីវ័យកុមារភាព ទៅដល់ជីវិតអតីតកាលផ្សេងទៀត ពិតហើយស្ថិតនៅក្រោមការអង្កេតពិសោធនាពេលបច្ចុប្បន្ន។ នេះជាទិដ្ឋភាពដ៏សំខាន់នៃចិត្តវិទ្យា ព្រះពុទ្ធសាសនាដែលមិនត្រូវបានគេទទួលយក ដោយអ្នកផ្តើមគំនិតចិត្តវិទ្យាលោកខាងលិច ដែលមានការទទួលស្គាល់។ វាអាចជាចំណាប់អារម្មណ៍ ដែលបានបង្ហាញឱ្យឃើញយ៉ាងពិតប្រាកដ ដោយ Freud តាមវាក្យសព្ទ មត៌ករបស់មនុស្សហួសសម័យ (Archaic heritage of man) និងតាមវាក្យសព្ទ អញ្ញាណតាមបែបប្រមូលផ្តុំ (Collective unconscious)។

ធម្មជាតិនៃចិត្តក្នុងកម្រិតផ្សេងៗគ្នា ត្រូវបានពន្យល់នៅក្នុងសុត្តន្តបិដកដោយមានជំនួយ ពីសទិសភាព និងពាក្យប្រៀបមួយចំនួន។ ដូន កាលវាត្រូវបាននិយាយយោងទៅដល់ថាជាចរន្តនៃញាណ ដូនកាលវាត្រូវបានគេប្រៀប ប្រដូចទៅនឹងចលនានៃសត្វស្វាមួយក្បាល ដែលកំពុងធ្វើចល នាពីមែកឈើមួយទៅមែកឈើមួយទៀត ដោយមិនបានព្រលែងកណ្តាប់ដៃពីមែកឈើមួយទៀត។ វាក៏ត្រូវបានគេប្រៀបប្រដូច ទៅនឹងព្រះអគ្គី ដែលនឹងស្ថិតនៅតែនៅពេលណាដែលមានប្រេង។ល។

## ១០-ទិដ្ឋភាព៤យ៉ាងនៃបញ្ញត្តិអំពីចិត្ត

ក្រុមមិនមែនសម្ភារ៤យ៉ាងត្រូវការបញ្ជាក់ច្បាស់មួយចំនួន ព្រោះបញ្ញត្តិទាំងនេះនឹងត្រូវបានគេនិយាយយោងទៅដល់ជាថ្មីម្តងទៀត នៅពេលដែលមានការពិភាក្សាទិដ្ឋភាពបន្ថែមទៀត នៃចិត្តវិទ្យាព្រះពុទ្ធសាសនា នៅក្នុងជំពូកជាបន្ត បន្ទាប់។ អត្ថន័យនៃពាក្យវិញ្ញាណ សង្ខារ វេទនា និងសញ្ញា ជាញឹកញាប់ត្រូវបានគេលំអៀងដោយការប្តូរទិសនៃបរិបទនិងការសង្កត់ធ្ងន់ទៅលើន័យវា។ ដូច្នោះ វានឹងមានប្រយោជន៍ ដើម្បីរើសចេញនូវរបុំអត្ថន័យនូវចំណុចនេះ។ ជាងនេះទៀត បញ្ញត្តិទាំង៤នេះ ត្រូវបានគេមើលឃើញថាជាគន្លឹះ ដល់ការយល់ដឹងធម្មជាតិនៃបាតុភូតចិត្តក្នុងពុទ្ធសាសនា។ តាមពិតទៅ មានអ្នកប្រាជ្ញមួយចំនួន ដែលបានធ្វើការប្រៀបធៀបការវិភាគពុទ្ធសាសនាទៅនឹងបំណែងចែកចិត្តជា៣ផ្នែកគឺពុទ្ធិ ទំនោរ និងសេចក្តីស្រឡាញ់ ជាបញ្ញត្តិមួយ ជាចរន្តទស្សនវិជ្ជា លោកខាងលិច តាំងតែពីក្នុងរជ្ជកាលលោកAristotle។ វាជាការពិតដែលថា ចិត្តវិទូសម័យទំនើប ក្នុងប្រទេសលោកខាងលិច ពិចារណារឿងនេះ ថាជារូបភាពងាយស្រួលកម្រិតខ្ពស់ ដែលមិនបានធ្វើឱ្យសមនឹងភាពស្មុគស្មាញ នៃបាតុភូតចិត្ត។ ប៉ុន្តែអ្នកផ្សេង

ទៀត ដូចជា J. C. Flugel មានអារម្មណ៍ថា វាត្រូវបានគេប្រើប្រាស់ ដោយមានការប្រុងប្រយ័ត្ន ឬការព្រមានមួយចំនួន សម្រាប់រៀបចំធម្មជាតិដ៏ពេញលេញនៃបទពិសោធរបស់យើង។

អ្នកប្រាជ្ញទាំងឡាយ ដែលបានរកឃើញមុខងារទាំង៣ ដ៏មានប្រយោជន៍ក្នុងការយល់ដឹងបញ្ញត្តិចិត្តខាងពុទ្ធសាសនា ចាត់ទុកវេទនា ជាជាវិសាលភាពនៃបទពិសោធដ៏មានឥទ្ធិពល អជ្ឈាស័យ និងឆន្ទៈ(Sankhara) ជាជាវិសាលភាពទំនោរ និងប្រត្យក្សារម្មណ៍ (Sanna) និងវិញ្ញាណ(Vinnana) ជាជាទិដ្ឋភាពពុទ្ធិ។ នៅពេលដែលរឿងនេះអាចជាមធ្យោបាយមានប្រយោជន៍នៃការធ្វើផែនការប្រកប ដោយវិសាលភាពនៃបទពិសោធ និង អាកប្បកិរិយានោះ វាមិនសូវមានប្រសិទ្ធភាព ដើម្បីដាក់សេចក្ដីទុកចិត្តទៅលើវាទាំងស្រុង។ នៅក្នុងអត្ថន័យជ្រាលជ្រៅជាងនេះទៀត ខន្ធទាំង៤ ដែលមានទំនាក់ទំនងនឹងផ្លូវចិត្ត មានវត្តមានក្នុងគ្រប់សភាពនៃញាណ និងបទពិសោធ។ ដូច្នេះ ហើយកត្តាចិត្ត ដូចជាឆន្ទៈ គឺមិនគ្រាន់តែជាអង្គដោយឡែកប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងផ្សារភ្ជាប់គ្នាយ៉ាងជិតស្និទ្ធ ជាមួយកត្តាផ្សេងទៀត។ តាមរបៀបបែបនេះ វិសាលភាពបទពិសោធទាំង៣ ជាផលនៃការវិភាគបែបអរូបី ផ្ទុយទៅវិញទិដ្ឋភាពទាំង៣ ត្រូវបានគេរកឃើញក្នុងសភាពនៃញាណ និងអាកប្បកិរិយាទាំងអស់។

វេទនា ដែលជាធាតុផ្សំអារម្មណ៍នៃបទពិសោធរបស់យើង ត្រូវបានគេចាត់ទុកថាជាប្រភេទទាំង៣ នៃភាពរីករាយ ភាពឈឺចាប់ និងភាពធម្មតាជាកណ្ដាល។ សញ្ចេតនា ត្រូវបានគេធ្វើចំណាត់ថ្នាក់ទៅជាសញ្ចេតនាខាងរាងកាយ និងខាងផ្លូវចិត្ត (Bodily and mental feelings) ហើយវាមានទំនាក់ទំនងទៅផងដែរនឹងសរីរាង្គឥន្ទ្រិយ។ អារម្មណ៍រីករាយ ដាស់អារម្មណ៍ជំពាក់ចិត្ត (ឧបាទាន Attach- ment) របស់មនុស្ស ទៅនឹងវត្ថុទាំងឡាយ និងដាស់ភាពលោភលន់ផ្នែកសរីរាង្គឥន្ទ្រិយដែលមិនទាន់បង្ហាញឱ្យឃើញ។ អារម្មណ៍ឈឺចាប់ ដាស់កំហឹង និងសេចក្ដីស្អប់ដែល មិនទាន់បង្ហាញឱ្យឃើញ។ មនុស្សដូចជាព្រះ ដែលចង់ធ្វើ ជាម្ចាស់លើតណ្ហានោះ ត្រូវតែលុបបំបាត់លក្ខណៈពិសេស ដែលមានការពាក់ព័ន្ធទៅនឹងអារម្មណ៍ទាំងបីនេះគឺ៖

1-ទំនោរចំពោះឧបាទាន ក្នុងអារម្មណ៍រីករាយ។

2-ទំនោរចំពោះការស្អប់ខ្ពើមក្នុងការឈឺចាប់។

3-ទំនោរធ្វើមិនដឹងឮ ក្នុងអារម្មណ៍អព្យាក្រឹត ឬធម្មតា។

មានវិសាលភាពសីលវិទ្យាគួរឱ្យចាប់អារម្មណ៍ផងដែរ ដែលពិនិត្យមើលការវិភាគអារ ម្មណ៍។ បញ្ហាត្រូវបានគេលើកឡើង ថាតើមានសភាពគួរឱ្យរីករាយ ដែលគ្មានសោះ នៅក្នុងឧបាទាន។ នៅដំណាក់កាលនេះ ភាពខុសគ្នា ត្រូវបានបង្កើតឡើងរវាងភាពរីករាយ ដែលកើតមានឡើងក្នុងជីវភាពក្នុងគ្រួសារ (The

pleasures of domestic life) និងភាពរីករាយដែលកើតឡើងពីការលះបង់ (The pleasures of renunciation) ដែលជាភាពរីករាយនៃការគិតឃើញត្រឹមត្រូវ និងអស្សាទ ដែលកើតចេញអំពីសភាពតាំងភាវនា។ល។ ប៉ុន្តែ សញ្ចេតនាដែលជាផ្នែកមួយនៃខណ្ឌបញ្ចឧបាទាន (Panca Upadana-Khandhas) នោះមិនអាចត្រូវបានកាត់ផ្ដាច់ចេញពីការប៉ាន់ស្មានទុកជាមុននៃអត្ត (Ego)។ សញ្ចេតនា កើតចេញពីការចូលរួមដោយការភ្ញោចតាមសរីរាង្គឥន្ទ្រិយ និងសកម្មភាពចិត្តទទួលបានតាមប្រត្យក្សារម្មណ៍។

ដូចដែលបាននិយាយរួចមកហើយ សញ្ញាជាក្រុមមួយនៃក្រុមដែលមិនមែនជាសម្ភារៈទាំង៤ ជាញឹកញាប់ ត្រូវបានគេធ្វើឱ្យទៅជាប្រត្យក្សារម្មណ៍។ នៅពេលដែលក្រុមផ្សេងទៀតធ្វើឱ្យវាជាសម្មភាពបែបប្រត្យក្សារម្មណ៍នោះ វាទំនងជាថា ការបកស្រាយនៃវាក្យសព្ទមួយ ដើម្បីឱ្យសមនឹងបរិបទទាំងអស់ និងការបញ្ចេញឱ្យឃើញរបស់វាទាំងអស់ គឺមិនអាចធ្វើទៅបានទេ។ ពាក្យសញ្ញា ត្រូវបានគេបែងចែកទៅជា Patigha-sanna និង Adivacana-sanna គឺសញ្ញាដែលកើតចេញពីទំនាក់ទំនងរវាងសរីរាង្គឥន្ទ្រិយ ត្រូវបានគេ ចាត់ទុកថាជា Patigha-sanna។ អាទិវចនៈ (Adivacana) មានលក្ខណៈធម្មតា និងរាប់បញ្ចូលរូបភាព និងបញ្ញត្តិទទួលបានតាមរយៈសរីរាង្គឥន្ទ្រិយ។ ប្រត្យក្សារម្មណ៍អាចមាន៦ប្រភេទ គឺទម្រង់ ចក្ខុ សោតៈ ជីវ្ហា ឃានៈ និងឥន្ទ្រិយារម្មណ៍តាមរាងកាយ និងរូបភាពទាំងឡាយ។

អារម្មណ៍ និងប្រត្យក្សារម្មណ៍ កើតឡើងតែក្នុងទំនាក់ទំនងទៅនឹងឥន្ទ្រិយទាំងឡាយ (Indriya) និងទាំងនេះ កើតមានតែតាមរាងកាយ (The physical body)។ បញ្ញត្តិ២ផ្សេងទៀត សង្ខារ និងវិញ្ញាណ ដែលជាឫសគល់ដ៏ជ្រាលជ្រៅ តាមដំណើរការប្រែប្រួលនៃភាវៈ (Bhava) និងភាពបន្តនៃសង្សារៈ (Samsaric continuity) និងវាស្ថិតនៅក្នុងសរីរាង្គឥន្ទ្រិយណាមួយ ដែលជាបុព្វហេតុសម្រាប់ភាពបន្តនោះ។ ព្រោះហេតុដូច្នេះហើយ ពាក្យសព្ទ២កើតឡើង ទាំងជាមួយការនិយាយយោងទៅដល់ខន្ធទាំង៥ ព្រមទាំងតាមទំនាក់ទំនងទៅនឹងបដិច្ចសមុប្បាទ។ សង្ខារ និងវិញ្ញាណ កើតឡើងតាមការវិភាគខន្ធដែលជាឧបា ទានទាំង៥ តាមន័យចង្អៀត (Narrow sense) នៃអារម្មណ៍ទាំងនោះ និងតាមសកម្មភាពនៃញាណ ដែលសម្ដែងឱ្យឃើញដោយខ្លួនឯងតែម្យ៉ាង ដើម្បីឱ្យរាងកាយ និងចិត្តស្ថិតនៅជាមួយគ្នា។ ប៉ុន្តែ វាមានខ្លឹមសារៈសំខាន់ជ្រាលជ្រៅផងដែរ ដែលជាទំនាក់ទំនងទៅនឹងរូបមន្តនៃបដិច្ចសមុប្បាទ។ ក្នុងការវិភាគធម្មជាតិនៃញាណក្នុងជំពូកជាបន្តបន្ទាប់គេនឹងនិយាយទៅដល់តួនាទីនៃវិញ្ញាណ ទាំងក្នុងទំនាក់ទំនងទៅនឹងអារម្មណ៍ថាជាផ្នែកមួយនៃខន្ធទាំង៥ ព្រមទាំងក្នុងតួនាទីជាការផ្សារភ្ជាប់ទៅនឹងដំណើរនៃបដិច្ចសមុប្បាទ។

តាមបរិបទនៃប្រត្យក្សារម្មណ៍ដែល ទទួល បានតាមរយៈសរីរាង្គឥន្ទ្រិយនោះ មាន ការនិ យាយយោងទៅដល់ប្រភេទនៃញាណ ទាំង៦គឺៈ

-ចក្ខុវិញ្ញាណ (Visual consciousness) ដែលទទួលបានមកពីភ្នែក និងទ្រង់ទ្រាយវត្ថុ (Material shapes)

-សោតវិញ្ញាណមកពីត្រចៀក (Auditary consiousness) និងសំឡេង

-ឃានវិញ្ញាណ មកអំពីច្រមុះ (Olfactory consciousness) និងក្លិន

-ជីវ្ហាវិញ្ញាណ (Gustatory consiousness) មកពីអណ្តាត និងរសជាតិ

-កាយវិញ្ញាណ (Bodily consciousness) មកពីរាងកាយ និងការប៉ះស្ទាប

-មនោវិញ្ញាណ (Mental consciousness) មកពីចិត្ត និងសភាពចិត្ត។

វិញ្ញាណក្នុងបរិបទទាំងនេះ អាចត្រូវ បានគេផ្តល់នូវពុទ្ធិញាណ (Cognitive consciousness) ក្នុងទំនាក់ទំនងទៅនឹងដំណើរនៃ បដិច្ចសមុប្បាទ វិញ្ញាណត្រូវបានគេមើល ឃើញថា ជាចរន្តមិនអាចបំបែកបាន ដែលត្រូវ ដឹកនាំតាមកំណើតថ្មី បង្កើតឡើងដោយកម្ម (Kamma)។ នៅទីនេះ វិញ្ញាណ គឺជាញាណ ទាំងស្រុង ដែលរាប់បញ្ចូលទាំងញាណ ព្រម ទាំងព្រឹត្តិការណ៍ចិត្ត ដែលជាសំណល់នៃ បុគ្គលម្នាក់ៗ។

ពាក្យសង្ខារ ក៏ត្រូវបានគេប្រើផងដែរ ក្នុងទំនាក់ទំនងទៅនឹងខន្ធ៥ ព្រមទាំងដំណើរ បដិច្ចសមុប្បាទ។ ទោះបីជាវាមិនមានភាពវាងវៃ ដើម្បីកំណត់អត្តសញ្ញាណអត្ថន័យអំពីសង្ខារ ជាមួយការប្រើប្រាស់ជាក់លាក់ណាមួយក៏ ដោយក៏យើងអាចយល់ដឹងដ៏ទូលំទូលាយនូវ ប្រភេទ បរិបទពិតប្រាកដដែលវាកើតឡើង។ ក្នុងនាមជាផ្នែកមួយអ្នកប្រាជ្ញទាំងឡាយ មាន អារម្មណ៍ថា បញ្ញត្តិនៃធន្ធៈ គឺជាមជ្ឈមណ្ឌល នៃអត្ថន័យរបស់វា ហើយក្នុងនាម ជាអ្នកផ្សារ ភ្ជាប់គ្នាក្នុងដំណើរនៃបដិច្ច សមុប្បាទ ជាញឹក ញាប់ វាត្រូវបានគេផ្សារភ្ជាប់ ទៅនឹងការបង្កើត កម្ម។

តាមសកម្មភាពនៃធន្ធៈ សង្ខារ និង វិញ្ញាណ អាចជាញាណ និងអញាណ ហើយ គេអាចរាប់បញ្ចូលវេទ្ធិចនិងអារម្មណ៍ទាំងអស់។ ប្រភេទទាំង៣នេះគឺៈ

-កាយ (Kaya) ដែលជាវេទ្ធិចខាងរាងកាយ

-វាចា ដែលជាវេទ្ធិច និងអារម្មណ៍ខាង ពាក្យសម្តី

-មនោ (Mano) ដែលជាវេទ្ធិចខាងគំនិត និងអារម្មណ៍។

ដោយឡែកពីការប្រើប្រាស់ទាំងនេះ សង្ខារ ក៏ត្រូវបានគេប្រើ ដើម្បីបង្ហាញពីគំនិត ដែលអ្វីមួយត្រូវបានគេដាក់លក្ខខណ្ឌថា គ្រប់ អត្ថិភាព បាតុភូត គឺត្រូវមានលក្ខខណ្ឌ។ អត្ថ ន័យនេះ ត្រូវបានគេរកឃើញ នៅក្នុងពាក្យ ចាស់មួយថា កំណើតទាំងអស់ គឺអនិច្ចៈ។

ដូចដែលបាននិយាយរួចមកហើយ ពាក្យសង្ខារ មិនអាចត្រូវបានបកស្រាយដោយវាក្យសព្ទតែមួយ ដែលនឹងគ្របដណ្តប់ទៅលើការប្រើប្រាស់ទាំងអស់បានទេ។ ទោះជាយ៉ាងនេះក្តី បញ្ញត្តិឆន្ទៈ បង្កើតរបុំដ៏សំខាន់ក្នុងអត្ថន័យនេះ ហើយនៅក្នុងសុត្តន្តបិដក ពាក្យចេតនា (Cetana) និងសង្ខារ ត្រូវបានគេប្រើជាវេវចនសព្ទ។ លក្ខណៈពិសេសនៃបញ្ញត្តិមួយផ្សេងមួយទៀតនៃសង្ខារ គឺថាវាផ្សំគ្នានូវសញ្ញាណការគិតទុកមុន ដែលជាទម្លាប់កើតមានក្នុងពេលជាមួយគ្នា។ ក្នុងនាមជាផ្នែកមួយនៃខន្ធនោះ បរិបទមួយចំនួន សង្កត់ធ្ងន់ទៅលើការគិតទុកមុន និងឆន្ទៈនោះ ផ្ទុយទៅវិញ ការប្រើប្រាស់របស់វាក្នុងនាម ជាការផ្សារភ្ជាប់ក្នុងដំណើរនៃបដិច្ចសមុប្បាទ សង្កត់ធ្ងន់ទៅលើកត្តាថាមភាព ទម្លាប់ និងអារម្មណ៍។ ជាចុងបញ្ចប់ វាត្រូវបានគេលើកយកមកនិយាយម្តងទៀតថា ទាំងវិញ្ញាណ និងសង្ខារ មានការប្រើប្រាស់បរិបទផ្សេងគ្នា។ គេមិនអាចកាត់បន្ថយវាទៅដល់កម្រិតន័យតែមួយទេ ហើយមានការផ្សារគួរឱ្យចាប់អារម្មណ៍មួយចំនួនប៉ុណ្ណោះ ដែលត្រូវបានបង្កើតដោយបញ្ញត្តិទាំងនោះ គឺកំពុងត្រូវបានគេស្រាវជ្រាវនៅទីនេះផងដែរ។

## ឯកសារយោង

-Dr. W. F. Jayasuriya, *The psychology & philosophy of Buddhism, an introduction to the Abhidhamma,* Bhudhist Misionary Society, 1988

-Brooke Noel Moore & Kenneth Bruder, *Philosophy, The Power of Ideas,* McGraw Hill, 2002.

-John W. Santrock, *Psychology*, McGraw Hill, 2005

-Padmasiri de Silva, *An Introduction to Budhist Psychology,* Library of Philosophy and Religion, 1978

-Robert H. Thouless, *Riddel Memorial Lectures,* Oxford, 1940.

-Mrs. C. A. F. Rhys Davids, *Buddhist Psychology*. London, 1914.

-Rune Johannson, *The psychology of Nirvana* London, 1965.

-Carl R. Rogers, *"Some Thoughts Regarding the Current Philosophy of the Behavioral Sciences", Journal of Humanistic Psychology,* Autumn, 1965.

-Stuart Hampshire (ed.), Philosophy of Mind, London, 1966.

-K. N. Jayatilleke, *Early Buddhist Theory of Knowledge*, London, 1963.

# ប្រសិទ្ធភាពនៃការសិក្សារបស់សិស្ស

*ដោយៈ* **បណ្ឌិត សូ សុធីរ**
*មន្ត្រីស្រាវជ្រាវនាយកដ្ឋានវិទ្យាសាស្ត្រអប់រំ*
*នៃវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម*
*រាជបណ្ឌិត្យសភាកម្ពុជា*

## ១-ការសិក្សា និងលំនឹក

*តើអាកាសធាតុ មានលក្ខណៈយ៉ាងដូចម្តេច នៅថ្ងៃទី៤ ខែមីនាកាលពីឆ្នាំទៅ? អ្នកដឹងតែម្តងគត់ៗ ចិត្តវិទូ នៅតែមិនទាន់ប្រាកដនៅឡើយទេថា តើយើងចងចាំដូចម្តេច និងហេតុអ្វីបានជាយើងភ្លេចៗ ប៉ុន្តែ គេនៅតែជឿថា លំនាំនៃការចងចាំ ពាក់ព័ន្ធនឹងព័ត៌មាន ឆ្លងកាត់ពីលំនឹកខ្លីរបស់យើង ទៅជាលំនឹកវែងៗ ព័ត៌មានអាចត្រូវបានរក្សាទុកក្នុងលំនឹកខ្លី តែពីរ ឬបីវិនាទីប៉ុណ្ណោះៗ លំនឹកវែង អាចរក្សាទុកព័ត៌មានរហូតដល់មួយជីវិត ប៉ុន្តែ ស្ទើរតែគ្រប់អ្វីៗទាំងអស់ ដែលបានឆ្លងកាត់ខួរក្បាលយើង ត្រូវភ្លេចភ្លាមៗដែរៗ*

### ក-លំនឹករយៈពេលខ្លី

**លំនឹករយៈពេលខ្លី**

*ជាលំនឹកដែលព័ត៌មាន ត្រូវបានគេរក្សាទុកយូរដល់ទៅ៣០វិនាទី ប្រសិនបើព័ត៌មានមិនត្រូវបានគេប្រតិបត្តិទេនោះ ក្នុងករណីនេះ វាមិនអាចរក្សាទុកបានយូរជាងនេះទេៗ*

*បើប្រៀបធៀបទៅនឹងលំនឹកតាមសរីរាង្គឥន្ទ្រិយនោះ លំនឹកខ្លី មានដែនកំណត់ខាងសមត្ថភាព ប៉ុន្តែ មានរយៈពេលយូរជាបង្គួរ រហូតដល់៣០វិនាទីៗ ការផ្តុំព័ត៌មាន ជួយពង្រីកលំនឹកខ្លី និងការថែរក្សាការប្រតិបត្តិ អាចជួយរក្សាព័ត៌មានក្នុងលំនឹកខ្លីឱ្យបានយូរជាងនេះៗ ក្នុងគំរូមួយនៃលំនឹកខ្លី ប្រព័ន្ធប្រតិបត្តិបន្ថែមឱ្យការបម្រើ២ គឺជុំសូរវិទ្យា(ដែលមានផ្ទុកព័ត៌មាន ពាក្យសម្តី) និងកូនសៀវភៅចក្ខុលំហ (ដែលមានផ្ទុករូបភាពផ្លូវចិត្ត) មានការពាក់ព័ន្ធៗ*

*បុរសអភ័ព្វម្នាក់ បានបាត់បង់លំនឹកខ្លីរបស់គាត់ បណ្តាលមកពីរបួសក្បាល ដោយគ្រោះថ្នាក់រថយន្ត នៅតែអាចប្រាប់វេជ្ជបណ្ឌិតរបស់គាត់យ៉ាងពិស្តារនូវអ្វីដែលគាត់បានធ្វើក្នុងសង្គ្រាមៗ ប៉ុន្តែ ពេលដែលគេសួរគាត់ថា តើគេបានដាក់កាហ្វេគាត់ នៅកន្លែងណានោះ គាត់សួរថា កាហ្វេអ្វី? គ្រោះថ្នាក់បានធ្វើឱ្យគាត់ខូចលំនឹកខ្លីៗ*

*លំនឹកខ្លីរបស់យើង រក្សាទុកនូវអ្វី ដែលយើងកំពុងគិត នៅពេលមួយជាមួយនឹងព័ត៌មានដែលទទួលបានពីភ្នែក ត្រចៀក...របស់យើងៗ ក្រោយពេលរក្សាទុក និងដំណើរការ*

ព័ត៌មានអស់រយៈពេល២ ឬ៣នាទីមកលំនឹកនេះ ស្ទើរតែបានភ្លេចបាត់បង់ទៅវិញទាំងអស់។ ឧទាហរណ៍៖ ប្រសិនបើអ្នកណាម្នាក់ បានអានលេខទូរសព្ទចំនួន៦ខ្ទង់ ជាបន្តបន្ទាប់គ្នា គេអាចចងចាំលេខទូរសព្ទចុងក្រោយគេ ប៉ុន្តែ គេប្រហែលជាភ្លេចលេខទូរសព្ទមុនៗ។

ខ្លឹមសារលំនឹករយៈពេលខ្លី ស្ថិតស្ថេរក្នុងរយៈពេលខ្លី និងងាយជំនួសដោយព័ត៌មានថ្មីៗ។ ល្បះចុងក្រោយនេះ ជាផលដ៏សំខាន់សម្រាប់ជាមធ្យោបាយ ដែលគ្រូគួរតែរៀបចំមេរៀន និងវគ្គសិក្សារបស់គាត់។

ពិតហើយ ជួនកាល ខ្លឹមសារនៃលំនឹកខ្លី ត្រូវបានបន្តទៅដល់លំនឹករយៈពេលវែង។ខ្លឹមសារលំនឹកខ្លី ត្រូវបានរៀបចំជារចនាសម្ព័ន្ធ។ ប្រសិនបើអ្នកព្យាយាមចងចាំពីរបៀបធ្វើលេខចែកច្រើនខ្ទង់ អ្នកត្រូវការលំនឹកពាក់ព័ន្ធតិចតួចដែលទាក់ទិននឹងជំនាញផ្សេងទៀត ដែលអ្នកបានសិក្សានៅពេលមួយ។ លំនឹកវែង គឺប្រៀបបាននឹងបន្ទប់ផ្ទុកឯកសារដ៏មានប្រសិទ្ធភាពបំផុត ដោយរក្សាបាននូវព័ត៌មាន សម្រាប់ប្រើ នាពេលអនាគត។ ដើម្បីឆ្លងកាត់ទៅដល់លំនឹកវែងមួយបាន ព័ត៌មានត្រូវតែដំណើរការ និងរៀបចំឱ្យបាន ត្រឹមត្រូវជាមុននៅក្នុងលំនឹកខ្លី ដើម្បីធ្វើឱ្យវាមានន័យដល់សិស្ស។ លំនាំនៃការរៀបចំព័ត៌មាន ត្រូវការពេលវេលាមួយដ៏សមស្រប ព្រោះសិស្សស្ទើរតែមិនអាចចងចាំបាននូវអ្វីមួយដែលពួកគេមិនទាន់យល់បានត្រឹមត្រូវ។ ប្រសិនបើគេផ្តល់ព័ត៌មាន ទៅឱ្យសិស្សម្នាក់រហ័សពេកនោះ គាត់នឹងមិនមានពេលវេលារៀបចំព័ត៌មាននោះ បានត្រឹមត្រូវក្នុងលំនឹកខ្លីទេ ដូច្នេះ ព័ត៌មាន នឹងមិនត្រូវគេរក្សាទុកបានទេ។ ការពិសោធ បានឱ្យដឹងថា ប្រសិនបើគេព្យាយាមកាត់បន្ថយអត្រានៃការនិយាយឱ្យបានកាន់តែយឺត ដល់សិស្សដែលរៀនខ្សោយខ្លាំងនោះ គេឃើញថា ការរក្សាទុកព័ត៌មានរបស់សិស្សទទួលបានកាន់តែ បានច្រើន

លំនាំនៃការរៀបចំ ឬផ្តល់អត្ថន័យ ចំពោះព័ត៌មានថ្មីដ៏សំខាន់នេះ គឺទាមទារនូវការប្រើប្រាស់ ពេលវេលាមួយសមរម្យ។ សកម្មភាពសិក្សា ដែលពាក់ព័ន្ធដល់សិស្សក្នុងការប្រើប្រាស់គំនិតថ្មីៗនឹងជួយផ្តល់តម្លាភាពផងដែរ។

**ខ-លំនឹករយៈពេលវែង**

**លំនឹករយៈពេលវែង** ជាប្រភេទនៃលំនឹកដែលស្ថិតនៅជាអចិន្ត្រៃយ៍បន្តរ ដែលផ្ទុកបរិមាណនៃផ្ទុកព័ត៌មានបានច្រើន សម្រាប់រយៈពេលដ៏យូរ។

នៅក្នុងការសិក្សាមួយ មនុស្ស អាចចាំឈ្មោះ និងមុខមិត្តរួមថ្នាក់ នៅមធ្យមសិក្សាពិតប្រាកដ បានយ៉ាងច្រើនបំផុតក៏២៥ឆ្នាំដែរ។

នៅពេលដែលលំនឹកខ្លី បានបង្កើតន័យនៃព័ត៌មាន វាបានក្លាយទៅជាលំនឹកវែង ដែលប្រសិនបើវាមិនត្រូវបានប្រើ ឬរំលឹក ជាញឹកញាប់

តាមរបៀបណាមួយទេ វានឹងត្រូវភ្លេចឡើងវិញជារឿងធម្មតា។

ឧទាហរណ៍៖ អ្នកបានចងចាំអ្វីខ្លះ ពីមេរៀន នៅមធ្យមសិក្សា?

អ្វីដែលគេហៅថា ការភ្លេច គឺជាបច្ចេកទេសខាងក្នុងខួរក្បាល សម្រាប់ធានាថា វាមិនមានសំណាយជាមួយនឹងចំណេះដឹងឥតប្រយោជន៍។ គោលបំណងរបស់វាគឺគ្មានចងចាំអ្វីក្រៅពីព័ត៌មាន មានប្រយោជន៍ឡើយ។ ទោះជាយ៉ាងនេះក្ដី វាមានបំណងពិចារណានូវគំនិតដ៏មានប្រយោជន៍ នៅក្នុងលក្ខខណ្ឌវែងតែម្យ៉ាងប្រសិនបើវាបានឆ្លងកាត់យ៉ាងទៀងទាត់។

ការភ្លេច និងការចងចាំ គឺមិនស្ថិតក្រោមការត្រួតពិនិត្យដោយផ្ទាល់ពីញាណឡើយ។ វាមានលក្ខណៈស្វ័យប្រវត្តិ។ វាមានតែរបៀបតែម្យ៉ាងគត់ ដើម្បីធានាថា អ្វីមួយ ត្រូវបានចងចាំនោះ គឺការរំលឹកឡើងវិញដដែលៗ។ ជាគ្រូបង្រៀន យើងត្រូវតែមានភាពជឿជាក់ថា ចំណេះដឹងណាមួយដែលយើង ចង់ឱ្យសិស្សចងចាំគឺត្រូវរំលឹកឡើងវិញ និងប្រើប្រាស់ជាញឹកញាប់។

វាមានការលើកលែង ចំពោះក្បួនច្បាប់នេះដែរ។ ជួនកាល បទពិសោធតែម្ដងគត់ ត្រូវបានចងចាំអស់រយៈពេលមួយជីវិត ដូចជាព្រឹត្តិការណ៍មួយដ៏សែនរំភើបបំផុត។ ប៉ុន្តែ ពាក់ព័ន្ធដល់ការបង្រៀន គេ ត្រូវតែមានចិត្តមេត្តាដល់យន្តការស្វ័យប្រវត្តិរបស់ខួរក្បាលនិងសារៈសំខាន់នៃការរំលឹកឡើងវិញ។

ក្រោយពេលសិក្សា គំនិតធម្មតាមួយភ្លាម ឬការសាឡើងវិញនូវការសិក្សានោះ ការនឹកឃើញឡើងវិញបាន១០០%។ បន្ទាប់មកយើងបានភ្លេចនូវអ្វី ដែលយើងបានសិក្សា។ យ៉ាងណាក៏ដោយ ការសាឡើងវិញ កំណត់នូវការសិក្សានោះ បានរឹងមាំ ជាងក្នុងលំនឹកវែង។ ជាលទ្ធផល វាត្រូវការពេលច្រើនជាងសម្រាប់ការសិក្សានោះ ត្រូវភ្លេច បន្ទាប់ពីការសាឡើង វិញនីមួយៗ។

ជាលទ្ធផលនៃយន្តការភ្លេចនេះ យើងគ្រាន់តែចងចាំនូវគំនិតដែល៖

-ត្រូវបានសាឡើងវិញជាញឹកញាប់

-ត្រូវបានពន្យាពេលថ្មីៗ។

J. B. Watson ជាបិតានៃសាលារៀនចិត្តវិទ្យាអាកប្បកិរិយានិយម ដែលត្រូវបានអភិវឌ្ឍដោយ B. F. Skinner និយាយថា ការចងចាំ វាអាស្រ័យដោយភាពញឹកញាប់ និងភាពកើតឡើងថ្មីៗ។

តាមរយៈចំណេះដឹងរបស់យើងអំពីលំនឹកខ្លី និងលំនឹកវែង វាបានផ្ដល់ដំបូន្មានគរុកោសល្យ ដូចតទៅ៖

-បង្ហាញសម្ភារៈ និងខ្លឹមសារថ្មីបានច្បាស់លាស់។ បើសិនជាអ្នកចង់និយាយរហ័ស ចូរព្យា យាម និយាយឱ្យបានយឺតៗ។ ចូរស្ងាត់មួយរយៈ ក្រោយពេលមានល្បះសំខាន់ៗ ដើម្បីទុកពេលឱ្យល្បះនោះ ជិតជាប់ក្នុងអារម្មណ៍។

-សិស្សត្រូវការសកម្មភាព ដើម្បីលើកទឹកចិត្តគេចាប់យកខ្លឹមសារថ្មី។ សកម្មភាព ដែលបង្ខំឱ្យសិស្សប្រើប្រាស់ និងអភិវឌ្ឍបុគ្គលឡើងវិញគឺគំនិតដែលអ្នកកំពុងព្យាយាមបង្រៀនពួកគេ ដើម្បី ធ្វើឱ្យគេ សិក្សាមានប្រសិទ្ធភាពជាងសកម្មភាពអកម្ម ដូចជាការស្តាប់។

-ចំពោះព័ត៌មាន ដែលត្រូវរក្សាទុកក្នុងលំនឹកវែង វាត្រូវតែប្រើប្រាស់ និងសាឡើងវិជាញឹកញាប់ គ្រូម្នាក់ មិនអាចរំពឹងទុកថា បង្រៀនខ្លឹមសារមួយ នៅខែកញ្ញា ដោយមិនបានរំលឹកឡើងវិញ ហើយធ្វើឱ្យសិស្សចងចាំបាន នៅខែមិថុនាបានទេ។

## ២-ទ្រឹស្តីនៃការសិក្សា៣ប្រភេទ

មានទ្រឹស្តីចិត្តវិទ្យាចំនួន៣ប្រភេទ ដែលបានរួមចំណែកដល់ទ្រឹស្តីនៃការសិក្សា។ ទ្រឹស្តីនីមួយៗ មានទស្សនៈពីការសិក្សាផ្សេងៗគ្នា។ វាមានគំនិតបន្ថែមឱ្យគ្នា ជាជាងគំនិតផ្ទុយគ្នា ហើយជាញឹកញាប់ មានគំនិតប្រតិបត្តិត្រួតលើគ្នា។

-ទ្រឹស្តីពុទ្ធិនិយម សិក្សាពីលំនាំការគិត ដែលទាក់ទិនដល់ពេលដែលយើងសិក្សា

-ទ្រឹស្តីអាកប្បកិរិយានិយម បែរជាមិនអើ ពើដល់រឿងនេះ ហើយសិក្សាពីអាកប្បកិរិ យាគ្រូនិងកត្តាផ្ទៃក្នុងផ្សេងទៀត ដែលជះឥទ្ធិពលដល់ការសិក្សាយ៉ាងដូចម្តេច។

-ទ្រឹស្តីមនុស្សនិយម មានចំណូលចិត្តលើការអប់រំ ដែលជាមធ្យោបាយឆ្លើយតប នឹងតម្រូវការចិត្តរំភើប និងការអភិវឌ្ឍ។ ចូរយើងសិក្សាទ្រឹស្តីនីមួយៗ ដោយពិស្តារៈ

### ក-ទ្រឹស្តីពុទ្ធិនិយមៈ ការសិក្សាជាលំនាំមួយសកម្ម និងបង្កើតអត្ថន័យ

**ពុទ្ធិនិយម** គឺជាទ្រឹស្តីសិក្សា ដែលផ្តោតលើរបៀបដែលព័ត៌មានត្រូវបានទទួល រៀបចំរក្សាទុក និងរំលឹកឡើងវិញដោយចិត្ត។ មនុស្សភាគច្រើន ដែលមិនមែនជាគ្រូបង្រៀន ជឿជាក់ថា ការបង្រៀន ជាការប្រាប់សិស្សនូវរឿងអ្វីមួយ ហើយការសិក្សា កើតមានឡើង ប្រសិនបើសិស្សចងចាំបាន។

ការពិត រឿងនេះ មានភាពស្មុគស្មាញជាងនេះ។ សិស្សមិនគ្រាន់តែចងចាំនូវអ្វីដែលគ្រូ បានប្រាប់គេទេ។ ពួកគេ បានបង្កើតនូវបំណកស្រាយថ្មីៗផ្ទាល់ខ្លួន ពីពុទ្ធិដែលគ្រូបានផ្តល់ឱ្យ។

ឧទាហរណ៍ៈ អ្នកបានអានប្រលោមលោកមួយរឿង នាពេលថ្មីៗនេះ។ តើអ្នកចងចាំពីអ្វីខ្លះ?

ការសិក្សា ដែលទទួលបានជោគជ័យកើតឡើងដោយលំនាំនៃការបង្កើតសម្មតិកម្ម ដោយផ្ទាល់ខ្លួន។ ទ្រឹស្តីនៃការសិក្សាតាមបែបពុទ្ធិនិយមនេះ ជួនកាលត្រូវបានគេហៅថា អ្នកស្ថាបនានិយម ពីព្រោះ វាបានពិពណ៌នាពីរបៀប ដែលសិស្សកសាងចំណេះដឹងរបស់ពួកគេ។ តើអ្នកអាចជួយសិស្ស របស់អ្នកយ៉ាងដូចម្តេច ដើម្បីឱ្យគេក

សាងអត្ថន័យនៃពុទ្ធិផ្ទាល់ខ្លួន ដែលអ្នកបានបង្ហាញគេ? ពួកគេ ត្រូវការគិតពិភាក្សា និងប្រើគំនិត ដើម្បីរៀបចំវាឡើងវិញ ឱ្យទៅជាអត្ថន័យផ្ទាល់ខ្លួន។ ពួកគេត្រូវការគំនិតផ្ទាល់ខ្លួន ដែលគេអាចសិក្សាបាន។

ចិត្តវិទូពុទ្ធិនិយម ជឿជាក់ថា លំនាំនៃការសិក្សាតាមបែបស្ថាបនានិយមនេះ ពាក់ព័ន្ធនឹងគំរូ ពុទ្ធិ។ ទាំងនេះ ជាសម្មតិកម្ម ដែលជាគំរូនៃ តថភាព ជាជាងផែនទីខួរក្បាល ដែលអ្នកមានពីគំរូតថភាពទីក្រុងរបស់អ្នក។ ផែនទីខួរក្បាលរបស់អ្នក មានកំហុស និងការភ្លេច ឯការសិក្សាវិញ ក៏ដូច្នេះដែរ។ សិស្សរបស់អ្នក នឹងរៀនបានប្រសើរបំផុត ប្រសិនបើពួកគេ ប្រើគំនិត បំណិន និងពុទ្ធិ ដែលអ្នកព្យាយាម បង្រៀនពួកគេ។ គេនឹងសិក្សាបានប្រសើរបំផុត តាមការអនុវត្ត មិនមែនតាមការស្តាប់ទេ។

## យើងសិក្សាបានប្រសើរបំផុតតាមរយៈការអនុវត្ត

គេប្រាប់ខ្ញុំ ខ្ញុំភ្លេច ខ្ញុំឃើញ ខ្ញុំចាំ ខ្ញុំធ្វើ ខ្ញុំយល់។ សុភាសិតនេះ ជារបស់ចិន ដែលមានរយៈ ពេលជាង២០០០ឆ្នាំមកហើយ។ វាជារឿងពិត ស ម្រាប់បំណិនបញ្ញា និងប្រតិបត្តិ។ យ៉ាងណាដោយ វាត្រូវបានភ្លេចជាញឹកញាប់ ទៅតាមពូជសាសន៍ ដែលមិនរាប់បញ្ចូលគំនិត ដែលប្រើពេលកាន់តែតិច កាន់តែប្រសើរ។

ឧទាហរណ៍៖ ស្ត្រីម្នាក់ភ័យខ្លាច មិនហ៊ានបើករថយន្តដោយខ្លាចបែកកង់។

## យើងសិក្សាតាមរយៈការអនុវត្តប្រសើរជាងការមើល ឬការស្តាប់

ការពោលបែបនេះ ហាក់ដូចជាមិនសមហេតុផល ព្រោះរហូតដល់ពេលនេះ គ្រូភាគច្រើនបំផុត បានចំណាយពេលជាង៦០% និយាយទៅកាន់សិស្សខ្លួន។

ចិត្តវិទូពុទ្ធិនិយម យកចិត្តទុកដាក់ជាខ្លាំងទៅលើសិស្ស ដែលគិតពីរឿងរ៉ាវទាំងឡាយ ដោយ ខ្លួនឯង ជាជាងគ្រាន់តែចងចាំអ្វីដែលគេបានប្រាប់។ គេចូលចិត្ដសំណួរ បង្កើតឱ្យមានការគិត ជាជាង ភាពពិតធម្មតា។ ចូរប្រៀបធៀបសំណួរទាំងពីរនេះ៖

តើថតទាំង៤នៃបេះដូង ឈ្មោះអ្វី?

តើនឹងមានអ្វីកើតឡើង ចំពោះបេះដូងប្រ សិនបើសរសៃឈាមក្រហម មានបញ្ហា?

ប្រសិនបើគេមិនទាន់ប្រាប់ចម្លើយសំណួរទី២ដល់សិស្ស នោះសំណួរទី២ ពិតជាគួរឱ្យចាប់អារម្មណ៍ជាងសំណួរទី១ ហើយវាតម្រូវឱ្យសិស្ស មានគំរូចិត្តផ្ទាល់ខ្លួនដើម្បីឆ្លើយ។

ចូរប្រើគំនិតពុទ្ធិនិយមក្នុងការប្រតិបត្តិជាមួយយុទ្ធសាស្ត្រដូចតទៅ៖

-ការបង្រៀនដោយសួរសំណួរប្រសើរជាងការរៀបរាប់ប្រាប់។ ជំនួសឱ្យការរៀបរាប់សិស្សពីរបៀប ដែលបេះដូងធ្វើចលនា គ្រូអាចផ្តល់ឱ្យ សិស្ស នូវរូបបេះដូង ហើយសួរថា «តើអ្នកគិតថា បេះដូងនេះ ធ្វើ

ចលនាយ៉ាងដូចម្តេច?»។ ពិតហើយ គេនឹងត្រូវការជំនួយ ដើម្បីឈានទៅរកចម្លើយត្រឹមត្រូវបាន ប៉ុន្តែ ការធ្វើបែបនេះ គេនឹងអាចរៀនវិនិច្ឆ័យផង និងរកឃើញអត្ថន័យដោយខ្លួនឯងផង។ ល្បិចនេះ គេហៅថា"ការរកឃើញចម្លើយដោយមានការណែនាំ"។

-ការសួរសំណួរ ត្រូវប្រើសំណួរកម្រិតខ្ពស់ សំណួរខ្លះ ត្រូវការការរំឭកឡើងវិញ ឬការយល់ តាមបែបធម្មតា។ ចូរព្យាយាមសួរសំណួរ ដែលទាមទារឱ្យសិស្សចេះវិនិច្ឆ័យ។ ឧទាហរណ៍ ដូចជា ចូរសួរសំណួរ "តើមានអ្វីកើតឡើងប្រសិនបើ...?" ឬសួរសិស្សឱ្យវាយតម្លៃពីភាពខុសគ្នា ឬពីផលល្អ និងអាក្រក់នៃអ្វីមួយ។

-ចូរដាក់បញ្ហា ឬកិច្ចការ ដែលពាក់ព័ន្ធនឹងការគិតដោយប្រឌិតញាណ។ ចូរនាំឱ្យសិស្សចេះ ដោះស្រាយបញ្ហា ធ្វើការសម្រេចចិត្ត បង្កើតគំនិត ឬការផលិតច្នៃប្រឌិត។

## ខ-ទ្រឹស្តីអាកប្បកិរិយានិយម៖ ការជួនរង្វាន់ និងចលករសិក្សា

**អាកប្បកិរិយានិយម** គឺជាផ្នែកមួយនៃចិត្តវិទ្យា ដែលផ្តោតលើរបៀបដែលមនុស្សរៀនតាមរយៈអន្តរកម្មរបស់ពួកគេជាមួយបរិស្ថាន។ វាត្រូវបានផ្អែកលើគំនិត ដែលថា អាកប្បកិរិ យាទាំងអស់ ត្រូវបានទទួល តាមរយៈលក្ខខណ្ឌដែលជាដំណើរការនៃការពង្រឹងលើកទឹកចិត្ត និងការដាក់ទណ្ឌកម្ម។

ចិត្តវិទូអាកប្បកិរិយានិយម បានសិក្សាទៅលើសត្វ ដោយបង្ហាត់វានូវកិច្ចការសាមញ្ញ។ E. L. Thorndike(១៨៧៤-១៩៤៩)បានដាក់សត្វឆ្មានៅក្នុងទ្រុង"ល្បងប្រាជ្ញា" ដែលអាចមើលឃើញអាហារ។ សត្វឆ្មា ចេះទាញខ្សែគន្លឹះដើម្បីចេញពីប្រអប់ ទៅរកស៊ីអាហារ។ លោក Skinner បានបង្ហាត់សត្វព្រាប ឆ្កែ កណ្តុរ និងសត្វផ្សេងៗទៀត ដោយប្រើប្រអប់Skinner។ ក្នុងប្រអប់នេះ មានគន្លឹះដែលពេលគេចុចគន្លឹះ វាចេញអាហារសម្រាប់សត្វស៊ី។ បច្ចេកទេសដូចគ្នានេះដែរ ត្រូវបានប្រើប្រាស់ ដោយអ្នកពិសោធ ដើម្បីបង្ហាត់កណ្តុរឱ្យស្វែងរកផ្លូវកាត់តាមក្នុងទីខ្វាត់ខ្វែងនាំឱ្យវង្វេងផ្លូវ។

ក្នុងករណីនីមួយៗ សត្វ ត្រូវបានគេបង្ហាត់ ដោយផ្តល់រង្វាន់ឱ្យវា ជាមួយអាហារពេលដែលវា សម្តែងបានល្អ។ ការធ្វើរបៀបនេះដូចគ្នាច្រើន ទៅនឹងវិធីដែលគេប្រើដើម្បីសត្វចិញ្ចឹម ឬសត្វដែលសម្រាប់លេងសៀក។ ការរកឃើញមួយចំនួន ត្រូវបានគេយកទៅអនុវត្តដោយភ្ញាក់ផ្អើល ចំពោះការសិក្សារបស់មនុស្ស ទោះបីជាគេស្ទើរតែមិនអាចប្រាប់សាច់រឿងទាំងមូលបានក៏ដោយ។ នេះ ជាការសង្ខេប ដោយសាមញ្ញ ពីរបកគំហើញការស្រាវជ្រាវ តាមបែបអាកប្បកិរិយានិយម ដែលមានប្រយោជន៍ជាពិសេស ចំពោះគ្រូ។

## សិស្សត្រូវការរង្វាន់ខ្លះៗ ឬការលើកទឹកចិត្ត ដើម្បីសិក្សា

ប្រសិនបើគេដាក់ឆ្មា ដែលទើបស៊ីឆ្អែត ភ្លាមក្នុងប្រអប់ល្បងប្រាជ្ញា វានឹងទៅដេក។ មានតែសត្វឆ្មាដែលឃ្លាន ទើបវាស្វែងរករបៀបគេចខ្លួន។ សិស្សក៏ដូច្នេះដែរ គឺត្រូវជំរុញចិត្តដោយសង្ឃឹមថានឹងបានទទួលរង្វាន់ខ្លះៗ ដូចជាការសរសើរ ឬការចង់ចេះចង់ដឹងដោយការពេញចិត្ដ។ ការសិក្សានឹងមិន អាចទទួលលទ្ធផលបានទេ បើសិនជាគ្មានលក្ខណៈខាងលើនេះ។

គ្រូដែលមានសមត្ថភាព ត្រូវសង្កត់ធ្ងន់លើការផ្ដល់រង្វាន់ឱ្យសិស្ស ដោយសរសើរ ការយកចិត្ដទុកដាក់ និងការលើកទឹកចិត្តផ្សេងៗទៀត។ គាត់ដាក់កិច្ចការ ដែលសង្ឃឹមថា នឹងទទួលបានផល សម្រាប់សិស្សទាំងអស់គ្នា និងបែងចែកកិច្ចការវែងៗ ទៅជាកិច្ចការខ្លីៗ។ រឿងនេះ ទុកឱ្យសិស្សស្វែងរកបទពិសោធ បញ្ចប់ដោយជោគជ័យភ្លាមៗ។ មុខវិជ្ជាសិក្សាជារឿយៗ ត្រូវបែងចែកជាមេរៀន ដើម្បីបង្កើនការផ្ដល់រង្វាន់ ឱ្យបានញឹកញាប់។

## ការលើកទឹកចិត្ត គួរតែធ្វើទៅតាមអាកប្បកិរិយា តាមសេចក្ដីប្រាថ្នាកាន់តែឆាប់កាន់តែល្អ

ប្រសិនបើកណ្ដុរចេះរុញគន្លឹះ ហើយអាហារធ្លាក់ភ្លាមៗទៅក្នុងទ្រុងវា ដូច្នេះវាចេះចុចគន្លឹះ ដើម្បីស៊ីអាហារភ្លាមៗ។ ប្រសិនបើការលើកទឹកចិត្ត ត្រូវបានពន្យាពេល នោះការរៀនចុចគន្លឹះ ត្រូវការពេលវេលាច្រើនជាងនេះ។

លទ្ធផលស្រដៀងគ្នានេះ ត្រូវបានគេរកឃើញ ចំពោះការសិក្សារបស់មនុស្ស។ សិស្សម្នាក់ ដែលកិច្ចការរបស់ខ្លួន ជាទូទៅបានទទួលពិន្ទុភ្លាមនោះ មានទឹកចិត្តចង់រៀនសូត្រជាងសិស្ស ដែលត្រូវរង់ចាំពេលរាប់សប្ដាហ៍ ដើម្បីបានទទួលកិច្ចការជាការលើកទឹកចិត្ត ដោយសរសើរ ឬទទួលបាន ភាពជោគជ័យខាងពុទ្ធិ។

គ្រូបង្រៀនដែលមានសមត្ថភាព ត្រូវផ្ដល់រង្វាន់ និងលើកទឹកចិត្តសិស្សជាបន្តបន្ទាប់ ពេល ដែលសិស្សកំពុងសិក្សា ដូច្នេះការលើកទឹកចិត្ត ត្រូវតែធ្វើឡើងភ្លាមៗដែរ។

ការសិក្សាត្រូវបន្តធ្វើបន្តិចម្ដងៗ ជាជាងសិក្សារួមទាំងអស់ភ្លាមៗ ហើយត្រូវបានពង្រឹង ដោយ ភាពជោគជ័យម្ដងហើយម្ដងទៀត

សត្វឆ្មាជាធម្មតា ត្រូវការពេលវេលា ដើម្បីគេចចេញពីប្រអប់ល្បងប្រាជ្ញា ប៉ុន្តែពេលវេលា ត្រូវការបន្ថយជាទៀងទាត់ក្នុងការប្រតិបត្តិ។ ការសិក្សារបស់មនុស្ស ក៏មានលក្ខណៈដូចគ្នានេះដែរ គឺគេ ត្រូវពេលវេលា ហើយនិងជោគជ័យ នាពេលអតីតកាល ផ្ដល់ចលករសិក្សា នាពេលបច្ចុប្បន្ន។ ប្រសិនបើសិស្សមិនដែលទទួលជោគជ័យក្នុងមេ

រៀនខ្លួននោះទេ គេនឹងបោះបង់ការសិក្សាភ្លាមៗ។

**សិស្សចងចាំអ្វីដែលគេបានឆ្លងកាត់ជាញឹកញាប់ និងថ្មីៗ**

ប្រសិនបើអ្នកបង្រៀនមេរៀនមួយ នៅខែកញ្ញា ហើយមិនដែលបានបង្រៀនមេរៀននោះទេ វា នឹងភ្លេចភ្លាមៗដែរ ។

គ្រូបង្រៀនដែលមានសមត្ថភាព ត្រូវស ង្កត់ធ្ងន់លើចំណុចគន្លឹះ ហើយសង្ខេបវានៅពេលចាប់ ផ្តើមរៀនមេរៀន និងពេលបញ្ចប់ម៉ោងសិក្សា។ គេទាញយកប្រយោជន៍ ពីពុទ្ធិសិក្សាក្នុងមេរៀនចាស់ ទៅអភិ វឌ្ឍពុទ្ធិសិក្សាក្នុងមេរៀនថ្មី។

គួរឱ្យបារម្ភណាស់ ការបង្រៀនភាគច្រើននៅក្នុងសាលារៀន បានរំលោភលើរបកគំហើញរបស់អ្នកអាកប្បកិរិយានិយមនេះ។ សិស្សខ្សោយមួយចំនួន ត្រូវបានគេដាក់កិច្ចការលំបាកខ្លាំងពេក រហូតដល់គេមិនដែលបានទទួលជោគជ័យទេ។ ជាលទ្ធផលមួយផ្នែកណានោះ សិស្សមួយចំនួនកម្រ ឬមិនដែលទទួលការសរសើរ ឬការលើកទឹកចិត្តទេ។ ការសិក្សាមិនអាចទទួលបានពិន្ទុភ្លាមៗទេ ហើយពុទ្ធិ និងបំណិនជារឿយៗត្រូវបានគេបង្រៀន ហើយបន្ទាប់មក មិនត្រូវបានគេរំលឹកសាឡើងវិញ អស់រយៈពេលជាច្រើនខែ។ ជាលទ្ធផល សិស្សបោះបង់ការសិក្សាជាធម្មតា។

**គ-ទ្រឹស្តីមនុស្សនិយម៖ ការឆ្លើយតបនឹងតម្រូវការចិត្តរំភើបសិស្ស**

មនុស្សនិយម គឺជាវិធីសាស្ត្រនៃជីវិតដោយផ្អែកលើហេតុផល និងមនុស្សជាតិទូទៅរបស់យើង ដោយទទួលស្គាល់ថាតម្លៃសីលធម៌ ត្រូវបានបង្កើតឡើងយ៉ាងត្រឹមត្រូវលើធម្មជាតិ និងបទពិសោធរបស់មនុស្ស។

ក្នុងសៀវភៅមួយដែលមានចំណងជើងថា របៀបសិស្សរៀនមិនចេះ(១៩៦៤)John Holt បានប្រកាសថា ប្រព័ន្ធសាលារៀនអាចបំផ្លាញទឹកចិត្ត និងចិត្តរំភើបរបស់កុមារ។ ការរិះគន់យ៉ាងខ្លាំងរបស់គាត់ គឺបានចោទសាលារៀនពីកាធ្វើឱ្យសិស្សភ័យខ្លាច ភាពអាម៉ាស់ ការចំអក ការបន្ទាបតម្លៃ។ ចិត្តវិទូមនុស្សនិយម ជឿជាក់ថា ការភ័យខ្លាចពីភាពបរាជ័យ ការលែងរាប់អានបានធ្វើឱ្យមានការមិន ចុះសម្រុងនឹងគ្នា។

គ្រូបង្រៀនភាគច្រើន បានដឹងថា ការសិ ក្សាផ្ទាល់ខ្លួនរបស់គេ គឺជាលំនាំមួយមិនស្មុគស្មាញងាយស្រួល។ ទោះបីជាអ្នកបានដឹងច្បាស់ថា ការសិក្សាមានការលំបាកខ្លះៗ អ្នកប្រាកដជាសិស្ស ដែលទទួលបានជោគជ័យក្នុងមុខវិជ្ជាផ្សេងៗដើម្បីទទួលបានសញ្ញាបត្រ ដែលតម្រូវឱ្យក្លាយជាគ្រូ។ ទោះជាយ៉ាងនេះក្តី សម្រាប់មនុស្សភាគច្រើន ការសិក្សាជាលំនាំមួយ ដែលពោរពេញដោយការឈឺចាប់ ការខឹងសំបារ និងបរាជ័យ។ មនុស្សភាគច្រើន បានបោះបង់ការសិក្សា នៅមធ្យមសិក្សា មនុស្សមួយ

ចំនួនទៀត ជាអនក្ខរជន។ ការសិក្សា ជារឿងងាយស្រួលសម្រាប់អ្នក តែវាជាការលំបាកសម្រាប់មនុស្សគ្រប់ រូប។

ទ្រឹស្តីមនុស្សនិយម ជឿជាក់ថា កត្តាចិត្តរំភើប និងការលូតសាល់ និងអភិវឌ្ឍបុគ្គល មានតម្លៃបំផុត ព្រមទាំងបានអះអាងថា ផ្នែកទាំងអស់ខាងលើនេះ ត្រូវបានគេមិនយកចិត្តទុក ដាក់ទេនៅក្នុងសង្គម។ ចិត្តវិទូតាមបែបមនុស្សនិយម ជឿជាក់ថា សង្គម សាលារៀន កើតមាន ដើម្បីឆ្លើយតបនឹងតម្រូវការសិស្សម្នាក់ៗ។ ពួកគេជឿជាក់ថា សិស្សគួរតែត្រូវបានអនុញ្ញាត ឱ្យបន្តចំណូលចិត្ត និងកោសល្យផ្ទាល់ខ្លួនរបស់គេ ដើម្បីអភិវឌ្ឍខ្លួនគេឱ្យបានពេញលេញ តាមដែលអាចធ្វើទៅបាន ទៅតាមគោលដៅតែមួយរបស់គេ។

គោលការណ៍ចម្បងៗ ដែលបានផ្តល់យោបល់ដោយចិត្តវិទូបែបមនុស្សនិយម មានសក្តានុពលជាខ្លាំង ជាពិសេសការអប់រំ និងការបណ្តុះបណ្តាលមនុស្សចាស់ និងការអប់រំផ្សេងៗទៀត។

## សិស្សគួរតែមានស្វ័យដឹកនាំ

គ្រូបង្រៀន ត្រូវចេះជួយលើកទឹកចិត្តសិស្សម្នាក់ៗ ឱ្យចេះជ្រើសរើសនូវពុទ្ធិ និងបំណិនណា ដែលគេចង់សិក្សា។ ខ្លឹមសារមេរៀន សម្ភារៈវិធីបង្រៀន និងតម្លៃនៃការសិក្សា ត្រូវតែប្តូរដើ ម្បីឆ្លើយតប ទៅតាមតម្រូវការនៃបុគ្គល។

ការជ្រើសរើសរបស់សិស្ស ត្រូវតែមានការពាក់ព័ន្ធផ្ទាល់ខ្លួននឹងកិច្ចការសិក្សា ហើយសិស្សនឹងត្រូវលើកទឹកចិត្តជាខ្លាំង ទៅតាមចំណូលចិត្ត និងញាណិច្ឆតាផ្ទាល់ខ្លួនគេ។

ប្រសិនបើគ្រូ មិនអាចទុកឱ្យសិស្សស្វ័យដឹកនាំនូវការសិក្សារបស់ពួកគេយ៉ាងហោចណាស់ ជាញឹកញាប់ គ្រូ ត្រូវផ្តល់ឱ្យសិស្សនូវវិធានការជ្រើសរើសមួយចំនួន ក្នុងកិច្ចការឬកិច្ចការស្រាវ ជ្រាវដោយ ជួយឱ្យគេធ្វើតាមចំណូលចិត្ត។ គ្រូក៏អាចដាក់កិច្ចការស្រាវជ្រាវ ដែលផ្តល់កម្រិតច្នៃប្រឌិត និងញាណិច្ឆតា ជំនួសឱ្យកិច្ចការ ដែលគ្រាន់តែបានរៀបរាប់ឡើងវិញនូវព្រឹត្តិការណ៍ផ្សេងៗ។

## សិស្ស គួរតែទទួលខុសត្រូវចំពោះការសិក្សាផ្ទាល់ខ្លួន

ដោយជ្រើសរើសខ្លឹមសារនិងរចនាបថនៃការសិក្សាផ្ទាល់ខ្លួន គេត្រូវលើកទឹកចិត្តសិស្ស ឱ្យចេះទទួលខុសត្រូវ ចំពោះប្រសិទ្ធភាពរបស់វា។ សិស្សត្រូវបានគេលើកទឹកចិត្តឱ្យមានភាពសកម្មជាងភាព អកម្មក្នុងឥរិយាបថ ចំពោះការសិក្សា ហើយការជួយជ្រោមជ្រែងពីគ្រូ ធ្វើឱ្យសិស្សមិនមានទឹកចិត្តសិក្សា ព្រោះគេគិតថា ដើម្បីធ្វើឱ្យសិស្សមានភាពម្ចាស់ការ។

## ស្វ័យវាយតម្លៃ គឺគួរឱ្យចូលចិត្តជាងការវាយតម្លៃពីគ្រូ

ស្វ័យវាយតម្លៃ លើកទឹកចិត្តឱ្យមានស្វ័យជឿជាក់ និងស្វ័យដឹកនាំ ដែលទ្រឹស្តីវិទូ

បែបមនុស្សនិយម ឱ្យតម្លៃទៅលើ។ ស្វ័យវាយតម្លៃ គឺជាបំណិនចាំបាច់ សម្រាប់ការងារ និងការសិក្សា។ វាលើកទឹកចិត្តសិស្សឱ្យទទួលខុសត្រូវ ចំពោះកំណែលំអផ្ទាល់ខ្លួន ហើយនិងជាវិធីដើម្បីឧត្តមភាពក្នុងវិស័យណាមួយ។ គេបានពោលអាងថា ការធ្វើតេស្តរបស់គ្រូ លើកទឹកចិត្តដល់ការទន្ទេញចាំមាត់ និងការសិក្សា ដើម្បីពិន្ទុ ជាជាងការសិក្សាពិតប្រាកដ និងការអភិវឌ្ឍបុគ្គល។ ការវាយតម្លៃរបស់គ្រូ ក៏អាចបង្កើតនូវការភ័យខ្លាច និងភាពអាម៉ាស់ ហើយអាចបន្ទាបការឱ្យតម្លៃលើខ្លួនឯងរបស់សិស្ស។ សិស្សនឹងមិនទទួលខុសត្រូវចំពោះការកែលំអផ្ទាល់ខ្លួនគេឡើយ រហូតដល់គេសិក្សា ដើម្បីរិះគន់ដោយស្ថាបនា ពីការសិក្សាផ្ទាល់ខ្លួនគេ។

ជាញឹកញាប់គ្រូបង្រៀនសួរសិស្ស ឱ្យវាយតម្លៃកិច្ចការផ្ទាល់ខ្លួនគេឬការសិក្សាមួយផ្នែករបស់គេ ដោយផ្តល់នូវការវាយតម្លៃពីគ្រូម្នាក់តែប៉ុណ្ណោះ បើសិនជាការវាយតម្លៃពីខ្លួនឯង មិនគួរជាទីពេញចិត្ត។

### ការសិក្សា ងាយស្រួល មានអត្ថន័យ និង មានប្រសិទ្ធភាពបំផុត នៅពេលវាកើតឡើង នៅក្នុងស្ថានភាពមួយមិនគំរាមកំហែង

សិស្សគួរតែត្រូវបានជំរុញទឹកចិត្ត តាមចំ ណាង់ ដើម្បីរុករក អភិវឌ្ឍ និងកែលំអ មិនមែនតាមការភ័យខ្លាចការបរាជ័យនោះទេ។ វា មិនគួរមានគោលនយោបាយ"ស្តីបន្ទោស" ចំពោះកំហុសទេ។ សិស្ស គួរត្រូវបានអនុញ្ញាតឱ្យបង្ហាញខ្លួនគេចំពោះ ការវាយតម្លៃ ពេលដែលគេបានត្រៀមជាស្រេច ជាជាងនៅ ពេលមុនការសម្រេចចិត្ត និងគេគួរតែទុកពេលឱ្យសិស្សកែលំអការសិក្សារបស់គេ បើសិន ជាគេមិនទាន់ បានធ្វើយការវាយតម្លៃតាមកម្រិតស្តង់ដានោះទេ។


**ឯកសារយោង**

Santrock ( John W. ), *Psychology*, Brown & Benchmark, 1997.

Santrock ( John W. ), *Psychology*, Mc Graw Hill, 2005.

Kosslyn ( Stephen M. ) & Rosenberg ( Robin S. ), *Psychology,* Pearson, 2004.

Killen ( Roy ), *Effective Teaching Strategies, Lessons from Research and Practice*, Social Science Press, Australia, 2003.

# សេចក្ដីផ្ដើមនៃចិត្តវិទ្យាព្រះពុទ្ធសាសនា

*ដោយៈ* **បណ្ឌិត សូ សុធីរ**

*មន្ត្រីស្រាវជ្រាវនាយកដ្ឋានវិទ្យាសាស្ត្រអប់រំ*

*នៃវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម*

*រាជបណ្ឌិត្យសភាកម្ពុជា*

**នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស។**

**Pali:** Namo Tassa Bhagavato Arahato Samma Sambuddhasa[1].

Honour to the Exalted One! The Arahant, the Supremely Awakened One!

*ប្រែថាៈរីកិរិយានមស្ការថ្វាយបង្គំនៃយើងខ្ញុំព្រះករុណាចូរមានដល់ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គ ជាព្រះអរហន្តដ៏ប្រសើរទ្រង់ត្រាស់ដឹងនូវញេយ្យធម៌ទាំងពួង ដោយប្រពៃចំពោះព្រះអង្គឥតមានគ្រូអាចារ្យណាប្រដៅព្រះអង្គឡើយ*[2]*។*

*កំណើតនមោៈ*

*អ្នកពោលបទ នមោតស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្សជាដំបូង មានឈ្មោះដូចតទៅនេះៈ*

*1-នមោសាតាគីរីយក្ស ពោលនមស្ការ*

*2-តស្ស អសុរិន្ទរាហូ ពោលនមស្ការ*

*3-ភគវតោ ស្ដេចចាតុមហារាជ ពោលនមស្ការ*

*4-អរហតោ សម្ដេចទេវរាជ ពោលនមស្ការ។*

*5-សម្មាសម្ពុទ្ធស្ស មហាព្រហ្មពោល នមស្ការ*

*ទេវតាទាំង៥ព្រះអង្គនេះ ជាអ្នកបានពោលនមស្ការមួយអង្គមួយបទៗរៀងខ្លួន*[3]*។*

*ព្រះពុទ្ធសាសនា ក្នុងនាមជាសាសនាមួយ ឬជាវិទ្យាសាស្ត្រមួយ គឺមានភាពល្អឯកក្នុងការផ្សារភ្ជាប់ទៅនឹងការសិក្សាស្រាវជ្រាវបែបទស្សនវិជ្ជា និងបរមត្ថវិទ្យា។ ព្រោះហេតុដូច្នោះហើយ វាត្រូវបានគេចាត់ទុកថា ជាប្រព័ន្ធទស្សនវិជ្ជាដែលមានភាពជឿនលឿន បំផុតនៃប្រទេសឥណ្ឌា។ ទោះជាយ៉ាងនេះក្ដី វាត្រូវបានគេជំទាស់ជាខ្លាំង ក្នុងចំណុចយ៉ាងច្រើន ដើម្បីឱ្យវាមានភាពសមរម្យជាងក្នុងការចាត់ទុកថាជាអង្គដោយឡែក ដែលផ្នែកមួយ អាចជាវិទ្យាសាស្ត្រនៃចិត្ត។ សីលវិទ្យា វិទ្យាសាស្ត្រ*

[1] Dr. W. F. Jayasuriya: *The Psychology & Philosophy of Buddhism, an introduction to the Abhidhamma*, Buddhist Missionary Society, 1988, p.1.

[2] *បណ្ឌិត ឈឹម ទូច គិហិប្បតិបត្តិពិស្ដារ បណ្ណាគារត្រៃ រតន៍ ភ្នំពេញ ឆ្នាំ១៩៩៦ ទំព័រ២*

[3] *បណ្ឌិត ឈឹម ទូច -ដ- ទំព័រ៩៣*

និងទស្សនវិជ្ជា ត្រូវបានគេវេញចូលគ្នា យ៉ាងប្រណិតទៅជាប្រព័ន្ធ មួយ ដែលគ្មាន អាទិទេព និងគ្មានព្រលឹង (Godless and Soulless) និងដែលបានប៉ុនប៉ង បំបែកអាថ៌កំបាំងនៃជីវិត (Mystery of life)។ គ្មានទិដ្ឋភាពណាមួយ ដែលព្រះធម៌របស់ព្រះពុទ្ធ(Buddha-Dham ma)ឬការប្រៀនប្រដៅរបស់ព្រះពុទ្ធ មិនមាន មែកធាងចេញពីមូលដ្ឋានគ្រឹះ នៃទស្សនវិជ្ជា ប្រកបដោយតក្កវិទ្យា និងវិចារណញ្ញាណនោះទេ។ វាឆ្លើយតបទៅនឹងការទាមទារមនុស្ស ដែលមានប្រាជ្ញា និងមានការគិតល្អិតល្អន់ ដែលអត្តចរិត និងតម្លៃខាងសាសនា គួរត្រូវ បានគេកំណត់ មិនមែនតាមចិត្តរំភើប ដែល បានកើតឡើងនោះតែតាមរយៈខ្លឹមសាររបស់វា។ យ៉ាងណាក៏ដោយ វាមិនហួសហេតុពេកទេ ដើម្បីប្រកាសថា ក្នុងសម័យវិទ្យាសាស្ត្រ នេះ ចំណេះដឹងស្តីពីចិត្តវិទ្យាពុទ្ធសាសនា និង ទស្សនវិជ្ជាមានសារៈសំខាន់យ៉ាងខ្លាំងដល់ ពុទ្ធសាសនិកជន។ តាមពិតទៅវាត្រូវបាន គេនិយាយ ក្នុងបទអត្ថាធិប្បាយមួយ ដែល គេដឹងថាជាអភិធម្ម (Abhidhamma) ឬពុទ្ធ សាសនា កម្រិតខ្ពស់ គឺជាសមាសធាតុនៃព្រះ ធម៌។

## I-ពុទ្ធប្បវត្តិសង្ខេប

មុននឹងសិក្សាអំពីជីវប្រវត្តិរបស់ព្រះពុទ្ធ គេគួរតែយល់ដឹងជាមុនថា ការសរសេរអំពីរឿងនេះ មានខ្លឹមសារពីរផ្សេងគ្នា គឺមួយសរសេរតាមបែបអច្ឆរិយៈ និងមួយទៀតសរ សេរ តាមជីវិតក្នុងជីវភាពសាមញ្ញផងដែរ។

### ១-កំណើត

ព្រះពុទ្ធទ្រង់ប្រសូត នៅនគរកបិលពស្តុ ឬកបិលវត្ថុ (The King- dom of Kapilavastu) ក្នុងសួនលុម្ពិនី (Lumbini Park) ត្រង់ព្រំប្រទល់នគរកបិល ពស្តុ និងនគរទេវទហៈ (Devadaha) នាថ្ងៃ សុក្រ ទី១៥កើត ខែពិសាខ ឆ្នាំច ត្រូវនឹងថ្ងៃ ទី១៥ ខែឧសភា ឆ្នាំ៦២៣មុនគ.ស.[4] នៅក្នុង ត្រកូល គោតម (Gautama)។ ព្រះមាតានាម សិរិមហាមាយា (Sri Mahamaya) ជាបុត្រី មហាក្សត្រនៃបក្សសម្ព័ន្ធ កោឌ្យ (Kaudya Clan) និងបិតានាម សុទ្ធោទន៍ (Suddho- dana) ជារាជានៃបក្ស សម្ព័ន្ធសាក្យៈ (Sha- kya Clan)។

ព្រះពុទ្ធព្រះនាម សិទ្ធាថ៌ (Siddhar- tha: Realization of all aims; every wish fulfiled) ព្រះអគ្គមហេសីនាមពិម្ពា យសោធារា (Yashodhara) ជាបុត្រីស្តេចសុប្បពុទ្ធ (Suppabuddha) ព្រះរាជបុត្រនាម រាហុល កុមារ (Rahula: a ring or cycle)។

## ២-ការត្រាស់ដឹង ( Enlightenment )

### ក-រាជាភិសេក

[4] សូមមើល *ពុទ្ធប្បវត្តិអមដោយរូបភាព* ឆ្នាំ២០២១ ទំព័រ៥

ព្រះជន្ម១៦វស្សា ព្រះអង្គ បានរាជាភិសេកជាមួយព្រះនាង ពិម្ពាសោធារា។

**ខ-ទេពនិមិត្តទាំង៤យ៉ាង**

ដោយទ្រង់អផ្សុកនឹងគង់ក្នុងប្រាសាទ ពេក ព្រះអង្គ ក៏យាងទៅក្រសាលសួនឧទ្យាន ដែលនៅ ពេលនោះ ព្រះអង្គទតឃើញទេពនិមិត្ត៤យ៉ាងគឺះ

លើកទី១ ឃើញមនុស្សជរា

លើកទី២ ឃើញមនុស្សឈឺ

លើកទី៣ ឃើញមនុស្សស្លាប់

លើកទី៤ ឃើញមនុស្សបួស

ទេពនិមិត្តទាំង៤លើកនេះ ធ្វើឱ្យព្រះអង្គកើតក្ដីសង្វេគ ហើយទ្រង់ពិចារណាឃើញច្បាស់ អំពីបញ្ហា ជីវិតរបស់មនុស្សលោក។ ទេពនិមិត្តទាំង៤ នាំឱ្យព្រះអង្គចង់សាងផ្នួស។

**គ-ការសាងផ្នួស**

នៅក្នុងព្រះជន្ម២៩វស្សា ព្រះអង្គទ្រង់បានយាងសាងផ្នួសទាំងកណ្ដាលអាធ្រាត្រ ដោយមានព្រាហ្មណ៍កោណ្ឌញ្ញ និងកូន៤នាក់តាមបម្រើផងដែរ ហៅថា "បញ្ចវគ្គីយ៍"។

**ឃ-ការត្រាស់ដឹង** ( Enlightenment )

ក្រោយពីធ្វើទុក្ករកិច្ច (Asceticism) អស់រយៈពេល៦វស្សា ព្រះអង្គទ្រង់យាងចេញពីរាជគ្រឹះ "រាជធានីនៃមគធរដ្ឋ" ទៅកាន់ស្រុកពោធិគយាក្នុងរដ្ឋដដែល។ ព្រះអង្គទ្រង់តាំងសមាធិ នៅក្រោមដើមពោធិព្រឹក្ស (Bodhi tree) ក្បែរស្ទឹងនេរញ្ជរា (Nairanjara)។

-ព្រះអង្គ ទ្រង់តាំងសីលហើយបានផ្ចាញ់មារ (Phantoms)។

-ព្រះអង្គបានត្រាស់ដឹង ជាព្រះពុទ្ធនៅមុនថ្ងៃរះនាថ្ងៃពុធ ទី១ កើតពេញបូណ៌មី ខែពិសាខ (The full moon day of Visakha month) ឆ្នាំរកា ក្នុងជន្មាយុ៣៥វស្សា។

**ង-ធម្មទេសនាប្រោសសត្វលោក**

បន្ទាប់ពីបានត្រាស់ដឹងនូវសម្មាសម្ពោធិញ្ញាណហើយ ព្រះពុទ្ធទ្រង់ត្រាស់ធម្មទេសនាទូន្មានសត្វលោក ដោយពុំប្រកាន់វណ្ណៈឡើយ។ អស់រយៈពេល៤៥ឆ្នាំ ព្រះអង្គ តែងបំពេញពុទ្ធកិច្ច៥ប្រការ ជានិច្ចគឺះ

-ពេលព្រឹក ទ្រង់និមន្តបិណ្ឌបាត្រ

-ពេលរសៀល ទ្រង់សម្ដែងធម្មទេសនា សម្រាប់សាធារណជន

-ពេលព្រលប់ ទ្រង់ប្រទានឱវាទដល់ភិក្ខុសង្ឃ

-នៅកណ្ដាលអាធ្រាត្រ ទ្រង់ដោះស្រាយប្រស្នានៃពួកទេវតា

-នៅពេលជិតភ្លឺ ទ្រង់ប្រមើលទតភ័ព្វសំណាងសត្វលោក។

**ច-បរិនិព្វាន** ( Mahaparinirvana: Nibbana )

ថ្ងៃ១៥កើត ខែមាឃ "វស្សាទី៤៥" ព្រះអង្គបានដាក់អាយុសង្ខារ ដោយប្រកាស

ប្រាប់មារថា ៣ខែទៀត ព្រះអង្គនឹងចូលបរិនិព្វាន។

ព្រះអង្គ ចូលបរិនិព្វាន នៅថ្ងៃអង្គារ ១៥កើត ថ្ងៃពេញបូណ៌មី ខែពិសាខ ឆ្នាំម្សាញ់ "៥៤៣មុនគ.ស." ក្នុងព្រះជន្ម៨០វស្សា[5]។

## ៣-គោលដៅ និងមាគ៌ា

ព្រះពុទ្ធសាសនា អាចត្រូវបានគេកំណត់ថាជាមាគ៌ាមួយនៃជីវិត ដែលអាចត្រូវបានគេហៅថា អដ្ឋង្គិកមគ្គ (The Noble Eightfold Path) ដែលនាំគោលដៅទៅដល់ និព្វាន។

អដ្ឋង្គិកមគ្គ គឺះ

-សម្មាទិដ្ឋិ (Right view)ការយល់ឃើញត្រូវ

-សម្មាសង្កប្ប (Right aim) ការត្រិះរិះត្រូវ

-សម្មាវាចា (Right speech) វាចាត្រឹមត្រូវវៀរចាកវចីទុច្ចរិត៤ះ

.មុសាវាទ និយាយកុហក

.បិសុនាវាទ និយាយចាក់ដោតញុះញង់

.ផរុសវាទ ជេរប្រទេចតិះដៀល

.សម្ផប្បលាវាទ ពាក្យឡេះឡោះ លេងសើចឥតប្រយោជន៍

-សម្មាកម្មន្ត (Right action) ការងារត្រឹមត្រូវ វៀរចាកកាយទុច្ចរិត៣យ៉ាងះ

.បាណា មិនសម្លាប់សត្វមានជីវិត

.អទិន្នា មិនលួចទ្រព្យអ្នកដទៃ

.កាមេ មិនលួចកូនប្រពន្ធ ឬប្តីគេ "ផ្លូវកាមតណ្ហា"

-សម្មាអាជីវ (Right living) រកស៊ីចិញ្ចឹមជីវិតត្រឹមត្រូវ

-សម្មាវាយាម (Right effort) ការព្យាយាមអំណត់អត់ធន់ សន្សំកុសលផលបុណ្យ

-សម្មាសតិ (Right mindfulness) ការដឹងខ្លួនជានិច្ច មិនធ្វេសប្រហែស

-សម្មាសមាធិ (Right contempla- tion) ការធ្វើសមាធិត្រឹមត្រូវ តម្កល់ចិត្តឱ្យនឹង[6]។

គោលដៅនេះជាកុសលកំពូលពីព្រោះវារួចចាកផុតពីអនិបុណភាព និងអចិន្ត្រៃយ៍ភាព សន្តិភាព ភាពបរិសុទ្ធ និងសុភមង្គលកម្រិតខ្ពស់បំផុត ដែលចិត្តរបស់យើងអាចប្រឌិតបាន។ រហូតមកដល់ពេលនេះ វាជារឿងមួយដែលមិនអាចត្រូវបានគេប្រគល់ជូនដល់អ្នកណាម្នាក់ឡើយ ទោះជាយ៉ាងនេះក្តី គេអាចជាជនដ៏ប្រសើរផងដែរ ប៉ុន្តែគេអាចទទួលបានជោគជ័យដោយការខិតខំប្រឹងប្រែងគេអាចទទួលបានជោគជ័យ តាមការធ្វើឱ្យរួច ចាកផុតពីធម៌វិបល្លាសទាំងអស់

[5] ត្រឹង ង៉ា *អរិយធម៌ខ្មែរ* ការផ្សាយរបស់អ្នកនិពន្ធ ឆ្នាំ ១៩៧៤ ទំព័រ៤៩-៦៤

[6] Cf. Brooke Noel Moore & Kenneth Bruder, *Philosophy, The Power of Ideas*, MacGraw Hill, 2002, pp.464-66.

(All illu- sions: Vipallasa Dhamma)។ ដើម្បីស ម្រេច បានសមិទ្ធផលទាំងនេះ រឿងបីមានភាព ចាំបាច់បំផុត គឺការសិក្សា ការប្រតិបត្តិ និង ការយល់ដឹង។ ការសិក្សា ឬការអង្កេត មាន សារៈសំខាន់ជាបឋម។ មិនមានពេលវេលា ត្រូវ តាមឱកាស ដើម្បីសង្កត់ធ្ងន់ទៅលើតម្លៃ ជាងនៅពេល ដែលព្រះពុទ្ធកំពុងចាក់ពុម្ព អំពីមាគ៌ាដ៏ប្រសើរបំផុត កាលពីជាង២៥៥០ ឆ្នាំមុន។

## ៤-គម្ពីរព្រះត្រៃបិដក និងចំណែកចែក

ឥឡូវនេះ ផ្នែកនៃការសិក្សានេះ គឺការ ធ្វើអង្កេតដ៏មានសារៈសំខាន់មួយ នៅក្នុងភាព ស្មុគស្មាញនៃសមាសធាតុទាំង៣នៃការប្រៀន ប្រដៅដែលត្រូវបានគេស្គាល់ថាជា វិន័យបិដក (The Vinaya Pitaka) សុត្តន្តបិដក (Sutta Pitaka) និងអភិធម្មបិដក (Abhidhamma Pitaka)។ ជាតុផ្សំ ទាំង៣នេះ ត្រូវបានគេហៅ ថា ព្រះត្រៃបិដក (The three baskets of the Buddhist doctrine)។

ព្រះត្រៃបិដក (តាមទស្សនៈព្រះពុទ្ធ សាសនា) ជាឃ្លាំងផ្ទុកពុទ្ធវចនៈ គឺវចនៈនៃ អង្គ ព្រះសម្មាសម្ពុទ្ធ ដែលទ្រង់ទេសនាអប់រំ ទូន្មានក្នុងរវាង៤៥វស្សា ចាប់តាំងពីទ្រង់បាន ត្រាស់ ដឹងព្រះសម្មាសម្ពោធិញ្ញាណ រហូត ដល់ទ្រង់ចូលបរិនិព្វាន។

តាមប្រវត្តិព្រះត្រៃបិដក ដែលចារឹក លើតួអក្សរ និងជាភាសាបាលីលើកដំបូងប ង្អស់ ធ្វើនៅប្រទេសស្រីលង្កា (Sri Lanka) ក្នុងរវាងព.ស.៤៣៣ ដោយចារលើស្លឹករឹត។

ចំពោះប្រទេសខ្មែរយើង ព្រះត្រៃបិដក បានចាប់កំណើតឡើង លើសាស្ត្រាស្លឹករឹត ជាយូរមកហើយ ដោយសរសេរជាអក្សរខ្មែរ បុរាណអានជាបាលី។ លុះមកដល់ថ្ងៃទី២៥ ខែ មករា ឆ្នាំ១៩៣០ (ព.ស.២៤៧៣) ក្រុមជំនុំ ប្រែព្រះត្រៃបិដកនៃវិជ្ជាស្ថានពុទ្ធសាសនា បណ្ឌិត្យ បានចាប់ផ្តើមផ្ទៀងផ្ទាត់ ឱ្យបានត្រឹម ត្រូវ និងប្រែពីភាសាបាលីមក ជាភាសាខ្មែរ នៅក្នុងព្រះរាជបណ្ណាល័យកម្ពុជាក្រុងភ្នំពេញ ការកសាងព្រះត្រៃបិដកនេះ នៅក្រោមព្រះរា ជូបត្ថម្ភកៈនៃព្រះបាទសម្តេចព្រះស៊ីសុវត្ថិ មុនី វង្ស ព្រះចៅក្រុងកម្ពុជាធិបតី ដែលបានបង្កើត ក្រុមជំនុំប្រែព្រះត្រៃបិដក នៅថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ១៩២៩។ តាមរាជបញ្ញត្តិថ្ងៃទី១៦ ខែធ្នូ ១៩៣០ ព្រះអង្គ បានរៀបចំនូវការសិក្សាភា សាបាលី និងពុទ្ធលទ្ធិក្នុងខេត្តទាំងឡាយ នៃ ព្រះរាជាណាចក្រកម្ពុជា និងមានការបង្កើត សាលាអនុវត្ត សម្រាប់ព្រះសង្ឃ ដែលនៅទី នោះ ព្រះសង្ឃ-គ្រូ បានទៅសិក្សាវិធីបង្រៀន តាមសាលាទំនើប[7]។

[7] ត្រឹង ងា ប្រវត្តិសាស្ត្រខ្មែរ សម្រាប់មធ្យមសិក្សា និង ឧត្តមសិក្សា ភាគ២ ក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ ២០០១(ឯកសារដើមឆ្នាំ១៩៧៣) ទំព័រ២៧៤

ព្រះតៃបិដកខ្មែរ មានចំនួន១១០ ក្បាល ចែកជាវិន័យបិដកមាន១៣ក្បាល សុត្ត ន្តបិដក មាន៦៤ក្បាលនិងអភិធម្មបិដក មាន៣៣ ក្បាល។

**ក-វិន័យបិដក** ( The Vinaya Pitaka )

គម្ពីរកម្រងធម៌វិន័យសិក្ខាបទសម្រាប់ភិក្ខុសង្ឃនិងភិក្ខុនីសង្ឃ។ គម្ពីរនេះ មាន ២១០០០ធម្មក្ខន្ធ។

**1-មហាវិភង្គ ឬភិក្ខុវិភង្គ:** និយាយពី សិក្ខាបទ (Precept) ២២៧ ក្នុងបាដិមោក្ខ ផ្នែកភិក្ខុសង្ឃ(ភាគទី១ ដល់ភាគទី២)។

**2-ភិក្ខុនីវិភង្គ:** និយាយពីសិក្ខាបទ ៣១១ក្នុងបាដិមោក្ខ ផ្នែកភិក្ខុនីសង្ឃ (ភាគ ៥)

**3-មហាវគ្គ:** និយាយពីពុទ្ធប្បវត្តិ ពីដំបូងៗ សិក្ខាបទក្រៅបាដិមោក្ខ និងពិធីកម្មខាងព្រះវិន័យ។ មហាវគ្គនេះ ចែកចេញជាខន្ធក: (ក្រុម) ចំនួន១០ ខន្ធក: (ភាគ ៦-៨)។

**4-ចុល្លវគ្គ:** និយាយពីពិធីកម្មខាងព្រះវិន័យ ប្រវត្តិកំណើតនាងភិក្ខុនី និងប្រវត្តិការធ្វើសង្គាយនា ចុល្លវគ្គ ចែកចេញជា១២ខន្ធ ក: (ភាគ ៩-១១)។

**5-បរិវារ:** និយាយពីវត្តប្រតិបត្តិបន្ទាប់បន្សំ ការសួរ-ឆ្លើយ ដើម្បីផ្ទៀងផ្ទាត់ការចេះដឹងខាងវិន័យ គម្ពីរនេះ ចែកចេញជាផ្នែកសំខាន់ៗ ចំនួន២១បំណុច ឬវារ: (ភាគ១២-១៣)។

ជារួមមក វិន័យបិដក (The Book of Discipline) ជាពិសេស សង្កត់ធ្ងន់ទៅលើព្រះសង្ឃ ផ្តល់ឱ្យព្រះអង្គ នូវគោលការណ៍ប្រតិបត្តិមួយសម្រាប់មាគ៌ានៃជីវិតដែលប្រាសចាកនូវកិលេស។ វា ជាការបរិយាយវិន័យ និងភាពប្រិតប្រៀននៃការរស់នៅ ចាំបាច់ដល់ការសម្រេចបាននូវសីលធម៌បរិសុទ្ធមួយ (A purity of morals) ដែលត្រូវបាននាំផ្លូវដោយ ក្បួនច្បាប់និងសិក្ខាបទ(Precept)។ យ៉ាង ណាក៏ដោយវា ត្រូវបានគេហៅថា ការប្រៀនប្រដៅតាមសិក្ខាបទ។ ទិដ្ឋភាពទាំង២នេះត្រូវបានសរសេរ តាមទម្រង់សំនួនវោហារ ន័យជៀប និងន័យត្រង់ ឬជាភាសាសន្ទនា (Vohara Vacana)ដូចជា មនុស្ស សត្វ រាងកាយ និងចិត្ត ដែលងាយស្រួលយល់ដឹង។ នៅពេលដែលមាន ការយល់ដឹងដ៏ជ្រាល ជ្រៅនោះគ្មានត្រង់ណា ដែលមិនមានអត្ថន័យល្អិតល្អន់នោះទេ។

**ខ-សុត្តន្តបិដក ឬព្រះសូត្រ**

(Sutta Pitaka) (៦៤ក្បាល)

ជាគម្ពីរដែលប្រមូលផ្តុំកត់ត្រាព្រះធម្មទេសនា ការអធិប្បាយធម៌និងរឿងរ៉ាវផ្សេងៗ ដែលទាក់ ទងនឹងបុគ្គល ឬឱកាសផ្សេងៗ។ គម្ពីរនេះ មាន២,១០០០ធម្មក្ខន្ធ។ ព្រះសូត្រ ចែកចេញជា៥និកាយ (ប្រជុំ ជំនុំ)៖

**1-ទីឃនិកាយ:** ប្រជុំសូត្រ ដែលមានខ្នាតវែង មានទាំងអស់ចំនួន៣៤សូត្រ ចែកចេញជា៣វគ្គ គឺសីលវគ្គ មហាវគ្គ បាដិកវគ្គ (ភាគ១៤-១៩)។

**2-មជ្ឈិមនិកាយ:** ប្រជុំសូត្រ ដែលមានខ្នាតវែងជាមធ្យម មានទាំងអស់ចំនួន ១

៥២សូត្រ ចែកចេញជា៣ បណ្ណាសកៈ (ក្រុម ៥០)៖ មូលបណ្ណាសកៈ មជ្ឈិមបណ្ណា សកៈ ឧបរិបណ្ណាសកៈ (ភាគ ២០-២៨)។

**3-សំយុត្តនិកាយ:** គម្ពីរដែលប្រមូលធម៌ ឬរឿងរ៉ាវជាពួកៗ ហៅថា សំយុត្ត ដូចជារឿងព្រះកស្សប ហៅកស្សបសំយុត្ត រឿងរ៉ាវដែលមាន នៅក្នុងរដ្ឋកោសល ហៅកោសលសំយុត្ត។ គម្ពីរសំយុត្តនិកាយ មានទាំងអស់ចំនួន ៧៧៦២សូត្រ ឬ៥៦សំយុត្ត។ សំយុត្តនេះ ចែកចេញជា៥វគ្គ (ភាគ២៩-៣៩)។

**4-អង្គុត្តរនិកាយ:** គម្ពីរដែលមានព្រះសូត្រចាត់ជាពួកៗ ហៅថានិបាត។ គម្ពីរនេះ មានទាំងអស់ចំនួន១១និបាត គឺតាំងពីនិបាតទី១(ឯកនិបាត)ដល់និបាតទី១១ (ឯកាទសនិបាត)រួមទាំងអស់ មានចំនួន៩ ៥៥៧សូត្រ (ភាគ៤០-៥១)។

**5-ខុទ្ទកនិកាយ:** គម្ពីរដែលប្រជុំព្រះសូត្រធម៌ ពាក្យអធិប្បាយ និងរឿងរ៉ាវតូចតាចដែលរួមទាំងភាសិតរបស់ព្រះសាវ័ក ប្រវត្តិនិងជាតកជាដើម។ ខុទ្ទកនិកាយ មានទាំងអស់ចំនួន១៥គម្ពីរ (ភាគ៥២-៧៧)។

ជារួមមក សុត្តន្តបិដក (The Book of Discourses) មានច្រើននៅក្នុងការប្រៀនប្រដៅរបស់ព្រះពុទ្ធ ដើម្បីដឹកនាំជីវិតប្រកបដោយកុសល តាមការលាងជម្រះគំនិតរបស់ខ្លួនតាមទម្រង់នៃរឿងនិទាន។ វាជាការប ង្រៀនជាទូទៅ ដែលមានភាពសមរម្យទៅ នឹងប្រភេទអត្តចរិតផ្សេងៗ ដើម្បីរំដោះគំនិតខ្លួនចេញពីលក្ខណៈនៃការខុសឆ្គង ឬក្លែងក្លាយ (False Views)។ វាជាមូលដ្ឋាននៃធម្មសាស្ត្រខាងពុទ្ធសាសនា។

**គ-អភិធម្មបិដក** ( Abhidhamma Pitaka )

ជាគម្ពីរទី៣របស់ពុទ្ធសាសនា ដែលនិយាយពីគោលធម៌សុទ្ធ មិនទាក់ទងដល់បុគ្គល ហេតុការណ៍ និងរឿងរ៉ាវផ្សេងៗឡើយ ជាវិជ្ជាសុទ្ធៗ។ គម្ពីរនេះ មាន៤,២០០០ ធម្មក្ខន្ធ[8]។ ព្រះអភិធម្ម ចែកចេញជា៧គម្ពីរធំៗ៖

**1-ធម្មសង្គណី:** ពោលពីការរួមក្រុមធម៌ គឺការចាត់ឱ្យមានរបៀបនៃធម៌ ដែលអាចរាយប៉ាយ ច្រើនកន្លែងឱ្យមកនៅជាក្រុម ពួកមានឈ្មោះក្បាលធម៌ខ្លីៗ។ ធម្មសង្គណី ចែកជា៥ក្រុមធំៗ គឺមាតិកា ចិត្តុប្បាទកណ្ឌ រូបកណ្ឌ និក្ខេបកណ្ឌ អត្ថុទ្ធារកណ្ឌ (ភាគ ៧៨-៧៩)។

**2-វិភង្គ:** គម្ពីរនេះ និយាយពីការចែក (វិភង្គ) គឺញែកក្រុមធម៌ផ្សេងៗ ឱ្យឃើញពិស្តារល្អិតល្អន់ ដូចជា ខន្ធ៥ អាយតនៈ១២ និងបែងចែកឱ្យល្អិតឱ្យឃើញមានអ្វីខ្លះ។ វិភង្គញែក ពួកធម៌ ចេញជា១៨ក្រុម (ភាគ ៨០-៨២)។

[8]ក្រសួងទេសចរណ៍ មគ្គុទេសក៍ទេសចរណ៍ពិសេសតំបន់សៀមរាប នាយកដ្ឋានទេសចរណ៍ នៃអគ្គនាយកដ្ឋានទេសចរណ៍ ឆ្នាំ២០០៤ ទំព័រ១០៨

**3-ធាតុកថា:** និយាយពីធាតុពោល គឺនាំយកមាតិកាក្នុងធម្មសង្គណី និងបទក្នុងវិភង្គចំនួន១២៥យ៉ាង ព្រមទាំងមេបទក្នុងធម្មសង្គណីមកសង្គ្រោះ ជាមួយធម៌៣យ៉ាង គឺខន្ធ អាយតនៈ និងធាតុ ថាតើចូលគ្នាបាន ឬមិនបានយ៉ាងណា។ ធាតុកថា មានទាំងអស់ចំនួន១៤មេ (ភាគ៨៣)។

**4-បុគ្គលបញ្ញត្តិ:** និយាយពីការបញ្ញត្តបុគ្គល ដោយពោលដល់គុណធម៌ខ្ពស់ ទាបរបស់បុគ្គល។ បុគ្គលប្បញ្ញត្តិ មានទាំងអស់ចំនួន៦យ៉ាង គឺតាំងពីខន្ធបញ្ញត្តិ រហូតដល់បុគ្គលប្បញ្ញត្តិ (ភាគ៨៣)។

**5-កថាវត្ថុ:** ជាគម្ពីរមួយ ដែលអដ្ឋក ថាពោលថា ព្រះមានព្រះភាគ ទ្រង់បានស ម្ដែងជា មេបទតែបន្តិចបន្តួចទេ ក្រៅពីនោះ ព្រះមោគ្គលិបុត្តតិស្សថេរៈ បានរៀបរៀងឡើងក្នុងសង្គាយនាលើកទី៣។ កថាវត្ថុ មានពាក្យសួរ ឆ្លើយទាំងអស់២១៩កថា (ភាគ ៨៤-៨៦)។

**6-យមក:** គម្ពីរដែលពោលពីធម៌ជាគូមានទាំងអស់១០គូគឺតាំងពីមូលយមកៈរហូតដល់ ឥន្ទ្រិយមកៈ (ភាគ៨៧-៩៣)។

**7-មហាបដ្ឋាន:** គម្ពីរដែលពោលពីទីតាំងគឺបច្ច័យ២៤ ដោយសម្ដែងថាអ្វីជាបច្ច័យរបស់អ្វី ខាងផ្នែកធម៌ មានចាប់តាំងអំពីហេតុបច្ច័យរហូតដល់អវិគតបច្ច័យ (ភាគ៩៤-១១០)[9]។

ជារួមមក អភិធម្មបិដក ឬសៀវភៅនៃការប្រៀនប្រដៅកម្រិតខ្ពស់ (The Books of the Higher Teaching) ដែលមានផ្ទុកការប្រៀនប្រដៅស្ដីអំពីវិទ្យាសាស្ត្រ និងទស្សនវិជ្ជា ត្រូវបាននិពន្ធជាសំនួនវោហារសាស្ត្រ ដែលមានភាពស្មុគស្មាញ ប៉ិនប្រសប់ និងពោរពេញ ទៅដោយភាសាបែបបច្ចេកទេស និងវិទ្យាសាស្ត្រ (Paramattha Vacana) ដូចជា ធាតុ វគ្គ ឬផ្នែកលំអិត និងទំនាក់ទំនង ប៉ុន្តែ វាសមស្របទៅនឹងកម្មវត្ថុមុខវិជ្ជា នៃការអង្កេត ពោលគឺធម្មជាតិវត្ថុដោយខ្លួនឯង និង ហេតុអ្វីបានជាវត្ថុទាំងនោះ កើតមានឡើង។ ពាក្យអភិធម្មមានន័យថា ការប្រៀនប្រដៅពិសេសពេញលេញកម្រិតខ្ពស់ ដែលស្ថិតក្នុងតថភាពនៃវត្ថុទាំងឡាយ។ ដូច្នេះ នៅក្នុង អភិធម្ម គេមិននិយាយអំពីមនុស្ស សត្វ ឬ លំនៅដ្ឋានទេ ប៉ុន្តែគេនិយាយអំពីធាតុទាំងឡាយ ដែលមានតែមួយ ឬជាបន្សំរួមគ្នា បង្កើតបានជា បាតុភូតនៃព្រឹត្តិការណ៍ ខាងផ្លូវចិត្ត និងរាងកាយ ដ៏ស្មុគស្មាញនេះ និងនិយាយពីម៉ាសវិស័យញាណ សតិ សច្ចភាព។ ដូច្នេះ វាបង្ហាញ

---

[9] សូ មុយឃៀង et al. *អរិយធម៌ខ្មែរ វប្បធម៌ និងសង្គមធម៌សម្រាប់ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន សាកលវិទ្យាល័យជាតិគ្រប់គ្រង* ឆ្នាំ២០០៤ ទំព័រ៩២-៩៤។

តាមទ្រឹស្តី ដែលជាមូលហេតុ មិនសមរម្យ ដើម្បីដាស់ការប្រមាថនៃកាមមុច្ឆា(Lust)។ល។ នៅពេលដែលមិនមានអត្ថភាព ឬមនុស្ស ប៉ុន្តែជាម៉ាសមួយនៃធាតុទាំងឡាយ។ ដូចគ្នានេះដែរ គីមីវិទូ មិននិយាយពី អំបិល នៅក្នុងការអង្កេតរបស់គាត់ទេ ប៉ុន្តែ និយាយ អំពីសូដ្យូម និងអាតូមក្លូរ (Sodium and chlorine atoms) ឬ ចុណ្ណភាគដើម ច្រើនជាង ដែលរួមបញ្ចូលគ្នានូវអាតូម ទាំងនេះ។ អ្វីដែលលើសពីនេះទៀតនោះ ក៏ដូចគ្នា នឹងអ្នកវិទ្យាសាស្ត្រផងដែរ អ្នកប្រាជ្ញខាងអភិធម្ម មិនគ្រាន់តែចូលរួមវិភាគបាតុភូតប៉ុណ្ណោះទេ ប៉ុន្តែ ថែមទាំងបានចូលរួមក្នុងការយល់ ដឹងពីការបង្កើតសម្មតិកម្មនៃគំនិត និងអាតូម ផ្សេងៗទៀតផង។

**៥-ប្រភេទនៃធាតុទាំង ៤** ( The Four Categories of Elements )

ទាំងនេះ ផ្តល់ឱ្យយើងនូវការយល់ដឹងជ្រាលជ្រៅថែមទៀត និងការយល់ដឹងបញ្ញាថែមទៀតនូវធម្មជាតិនៃវត្ថុនិងមនុស្ស។ ដើម្បីសម្រេចបានរឿងនេះ មុខវិជ្ជា ដែលប្រៀនប្រដៅកម្រិតខ្ពស់ទាំងអស់ ជាបឋមត្រូវបានអធិប្បាយនូវប្រភេទទាំង៤ ការទទួលបានពុទ្ធិ (Cognition) កត្តាខាងផ្លូវចិត្ត (Mental factors) រូបធាតុ (Matter) និងនិញ្វាន។ ក្រុមនៃធាតុទាំង៤នេះ គឺជាតថភាពក្នុងបាតុភូត ពីព្រោះវាមានអត្ថិភាព និងមានមុខងារពិសេស។ ក្រុម៣ ដំបូងគេ មានការពាក់ព័ន្ធ នឹងលោកិយ គឺកើតឡើង ដោយសារបុព្វហេតុ និងមានរយៈពេលខ្លី (Momentary dura- tion)។ ប៉ុន្តែ ក្រុមចុងក្រោយ មានលក្ខណៈហួសពីលោកិយ (supra-mundane) ដែល កើតឡើងដោយគ្មានបុព្វហេតុ និងមានលក្ខណៈអនន្ត។

**II-អ្វីជាអភិធម្ម** ? ( What is Abhidhamma? )

**១-ក្នុងនាមជាវិទ្យាសាស្ត្រចិត្តវិទ្យា** ( As Science, Psychology )

ពីព្រោះអភិធម្ម គឺជាអភិប្រាយបែបវិទ្យាសាស្ត្រ និងអំណោះអំណាងបែបបរមត្ថវិទ្យានោះ ជាបឋម គេបានលើកឡើង ដើម្បីពិភាក្សាអភិធម្មក្នុងនាមជាប្រព័ន្ធវិទ្យាសាស្ត្រមួយ។ និយាយជាសង្ខេប វិទ្យាសាស្ត្រពុទ្ធសាសនា ជាការសិក្សាពីសមាសភាព នៃសត្វលោក ដែលមានជីវិត និងដំណើរការ ខាងសរីរវិទ្យារបស់វា។ ការរួមបញ្ចូលគ្នានៃសត្វលោក ដែលមានជីវិត និយាយយោងទៅដល់ម៉ាសនៃធាតុទាំងឡាយ ដែលបង្កើតឡើង នូវចិត្ត និងរាងកាយរបស់មនុស្សម្នាក់។ ក្នុងការសិក្សាតាមបែបវិភាគបែបនេះ ប្រភេទនៃសំណួរ ត្រូវបានអង្កេតដោយព្រះពុទ្ធ គឺអ្វីជាធម្មជាតិនៃធាតុ ដែលរួមបញ្ចូលគ្នា? តើវាផ្សំបញ្ចូលគ្នា ដើម្បីបង្កើតផ្នែកលំអិត

ផ្សេងៗនៃចិត្ត និងរូបធាតុយ៉ាងដូចម្ដេច? តើផលបែបណា ដែលធាតុទាំងនេះ មាននៅក្នុងការផ្សំបញ្ចូលគ្នា? អ្វីជាលក្ខខណ្ឌទាំងឡាយដែលនៅក្រោមផ្ទៃកលម្អិតទាំងនេះ មានវត្តមាននិងអវត្តមាន? តើយើងអាចធ្វើចំណាត់ថ្នាក់ពួកវា បានដែរឬទេ? និងចុងក្រោយ អ្វីជាគោលការណ៍ឬច្បាប់តាមធម្មជាតិ គ្រប់គ្រងទៅលើដំណើរការនៃធាតុទាំងនោះ? ម្យ៉ាងវិញទៀត ការសិក្សាពីដំណើរការសរីរាង្គ គឺជាការសិក្សាពីលំនាំខាងរាងកាយ និងផ្លូវចិត្តដែលដំណើរការ ដើម្បីគោលដៅ ឬគោលបំណងរួមៗ ការពាក់ព័ន្ធនេះ មិនសូវមានការវិភាគច្រើនទេ ប៉ុន្តែ មានលក្ខណៈជាប្រព័ន្ធ ដែលក្នុងនោះសំណួរជ្រួតជ្រាបទាំងឡាយ មិនគ្រាន់តែជាអ្វីប៉ុណ្ណោះទេ ប៉ុន្តែ ថែមទាំងហេតុអ្វី និងដូចម្ដេចៗ ដូច្នេះការអង្កេត មិនគ្រាន់តែអ្វីជាកំណើត និងមរណភាពប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងហេតុអ្វីបានជាសត្វលោក មានជីវិតឡើង និងវាខុសប្លែកពីជីវិតផ្សេងៗយ៉ាងដូចម្ដេច នៅជុំវិញខ្លួនព្រះអង្គ និងលំដាប់លំដោយនៃព្រឹត្តិការណ៍ៗ

វិទ្យាសាស្ត្រសម័យទំនើប ក៏ដូច្នេះដែរ បានយល់ព្រមធ្វើតាមកម្មវិធីអង្កេតស្រដៀងគ្នានេះ ជាពិសេស នៅក្នុងភាពខុសគ្នារវាងសំណួរ អ្វី ហេតុអ្វី និងដូចម្ដេចៗ រហូតមកដល់ពេលនេះ ភាពខុសគ្នាដ៏សំខាន់ ស្ថិតនៅលើគោលបំណងទាំងឡាយ ដែលត្រូវបានសិក្សាស្រាវជ្រាវការអង្កេតបែបផ្សេងៗគ្នាៗ

លើសពីនេះទៀត ការសិក្សាពីអភិធម្មត្រូវបានគេ តម្រង់ទិស ដើម្បីយល់ដឹងពីផល ដែលមានការប៉ះពាល់ ឬមានប្រយោជន៍ ចំពោះគេ និងដើម្បីទទួលបាននិព្វានដែលជាប្រយោជន៍កំពូលបំផុត ដែលគេមានបំណងប្រាថ្នា ទៅដល់ៗ

ព្រះពុទ្ធ ក្នុងនាមជាអ្នកសង្កេតមួយអង្គ មិនបានរួមបញ្ចូលការពិសោធ តាមវិធីសង្កេតពិសោធទេ ពីព្រោះវាជាប់ពាក់ព័ន្ធនឹងវិទ្យាសាស្ត្រទំនើបៗ វិធីរបស់ព្រះអង្គ គឺមានលក្ខណៈប្រកបដោយតក្កភាព និងប្រាជ្ញាវាងវៃ ដោយមានវិញ្ញាណ ឬចិត្តទី៦ (The sixth sense or mind)ៗ តាមរបៀបដូច្នេះ រឿងចុងក្រោយនេះ អាចត្រូវគេទទួលយកបានដោយវិទ្យាសាស្ត្រសម័យទំនើប ជាពិសេស ប្រសិនបើគេទទួលស្គាល់ស្នាដៃថ្មីៗនេះ របស់សាកលវិទ្យាល័យ Dr. Rhine of Duke ស្ដីអំពីចិត្តវិទ្យាវិសាមញ្ញ ឬប្រត្យក្សារម្មណ៍ ដោយប្រើសរីរាង្គឥន្ទ្រិយវិសាមញ្ញ (Para-Psycho- logy or Extra-Sensory Perception = ESP)ៗ

ប្រត្យក្សារម្មណ៍ដោយប្រើសរីរាង្គឥន្ទ្រិយពិសេស គឺជាប្រត្យក្សារម្មណ៍ ដែលកើតឡើងដោយមិនមានការប្រើប្រាស់លំនាំសរីរាង្គឥន្ទ្រិយណាមួយ ដែលគេបានស្គាល់នោះទេៗ

ប្រត្យក្សារម្មណ៍នេះ មានទម្រង់សំខាន់៣គឺ:

1-**ទូរចេឆន៍** (Telepathy)

គឺជាការផ្ទេរគំនិត តាមរយៈសរីរាង្គឥន្ទ្រិយវិសាមញ្ញ ពីមនុស្សម្នាក់ ទៅមនុស្សម្នាក់ ផ្សេងទៀត។

ឧទាហរណ៍: បំណិននេះ មានចំពោះមនុស្សទាំងឡាយ ដែលអាចមើលចិត្តមនុស្សផ្សេងទៀតយល់។ ប្រសិនបើមនុស្សពីរនាក់កំពុងលេងបៀ ហើយមនុស្សម្នាក់ អាចប្រាប់សន្លឹកបៀណា ដែលមនុស្សម្នាក់ទៀត បានជ្រើសរើស នៅពេលនោះ ទូរវេទន៍នឹងកើតមានឡើង។

**2-ការយល់ដឹងហេតុការណ៍ជាមុន** (Precognition)

ឧទាហរណ៍: គ្រូទាយម្នាក់ ប្រកាស ថា គេអាចមើលឃើញព្រឹត្តិការណ៍ នាពេលអនាគត និងអាចប្រាប់អ្នកថា នឹងមានអ្វី កើតឡើង ចំពោះអ្នកក្នុងឆ្នាំខាងមុខ ឬហោរម្នាក់ អាចទស្សន៍ទាយថា នឹងមានបាតុភូតរញ្ជួយដីកើតមានឡើងនៅតំបន់ណាមួយ នៅកន្លែងណាមួយ។

ព្រះពុទ្ធ បានប្រកាសប្រាប់មារ នៅថ្ងៃទី១៥កើត ខែមាឃ ថា៣ខែទៀត ព្រះអង្គនឹងចូលបរិញ្ញន។

**3-ប្រាជ្ញាញាណ** (Clairvoyance)

គឺជាសមត្ថភាពយល់ដឹងព្រឹត្តិការណ៍ពីចម្ងាយ ដែលគេមើលមិនឃើញផ្ទាល់។

ឧទាហរណ៍: មនុស្សម្នាក់នៅក្នុងពេងភាពយន្ត មានអារម្មណ៍ ដឹងថា ចោរកំពុងគាស់ផ្ទះចូលលួចឥវ៉ាន់ នៅពេលបច្ចុប្បន្ន[10]។

ក្រៅពីនេះ ក៏មានផ្នែកមួយទៀត ក៏មានការពាក់ព័ន្ធនឹងប្រត្យក្សារម្មណ៍ ដោយប្រើសរីរាង្គឥន្ទ្រិយពិសេសនេះផងដែរ គឺបាតុភូតចិត្តបញ្ញា (Psychokinesis) ដើម្បីរំកិល វត្ថុដោយមិនបានចាប់កាន់ ឬប៉ះវត្ថុទាំងនោះ ទេ ដូចជាការប្រើចិត្ត ដើម្បីលើកកៅអីឱ្យផុតពីកម្រាលឥដ្ឋឬសម្លឹងមើលស៊ុតមួយឱ្យបែក។

ដោយកើតមានស្របគ្នា ជាមួយការប្រកាសនៃចិត្តវិទូវិសាមញ្ញនោះ គឺថាចិត្តរបស់ព្រះពុទ្ធ បានហ្វឹកហាត់ និងអភិវឌ្ឍបានល្អខ្លាំងពេករហូតដល់វាមានភាពរួស និងដល់កម្រិត កំពូលថែមទៀត ទៅដល់មុខងារនៃសរីរាង្គឥន្ទ្រិយផ្សេងទៀត។ វាគឺតាមដំណើររឿងនេះឯង ដែលព្រះពុទ្ធបានប្រកាសដោយព្រះអង្គ និងសាវ័កព្រះអង្គមួយចំនួននូវថាមពលដើម្បីសម្លឹងមើលត្រឡប់ទៅរកអតីតកាល និងទៅក្នុងអនាគតដ៏វែងឆ្ងាយ។ ទោះបីជាយ៉ាងណាក៏ដោយ ក៏ទម្រង់ការរបស់ព្រះពុទ្ធមានភាពខុសគ្នាពី Galileo, Newton or Einstein ដែលវាជាព្រឹត្តិការណ៍គួរឱ្យកត់សម្គាល់នោះ គឺថាវាបានកើតមុន ការមកដល់ នៃសម័យវិទ្យាសាស្ត្រសម័យទំនើបនោះ ព្រះ ពុទ្ធ អាចជាប្រផ្នូលនៃការរកឃើញសម័យបច្ចុប្បន្ននេះ។

---

[10] Cf. John W. Santrock, Psychology, McGraw Hill, 2000, pp.108-109.

## ២-ផ្លូវនាមជាទស្សនវិជ្ជា

ដោយចាប់ផ្តើមនឹងការសិក្សាអំពីព្រឹត្តិការណ៍នៃជីវិតនោះ ព្រះពុទ្ធ បានបន្តទៅដល់ទស្សនវិជ្ជា ទៅលើកស្តុតាងទាំងនោះ។ វាមិនមែនជាទស្សនវិជ្ជា ដែលគ្រាន់តែជាការស្មាន ឬមិនប្រាកដនោះទេ។ អភិធម្ម ដែលជាអំអំណាងបែបបរមត្ថវិទ្យានោះមានផ្នែកជាច្រើនដែលក្នុងនោះ ត្រូវបានគេហៅថាទស្សនវិជ្ជាដែលមានលក្ខណៈវិទ្យាសាស្ត្រ (Scienti- fic philosophy)។ រឿងនេះ មានការជាប់ ពាក់ ព័ន្ធ អំពីលក្ខណៈគួរឱ្យកត់សម្គាល់ ដែល ជាលក្ខណៈពិសេសនូវបាតុភូតដែលមាន លក្ខ ខណ្ឌ ឬព្រឹត្តិការណ៍ ដែលត្រូវបានគេនាំយកមកដោយបុព្វហេតុ និងលក្ខណៈពិសេសរបស់បុគ្គលនីមួយៗ ត្រូវបានគេចាត់ទុកថា វានៅក្រោមវិទ្យាសាស្ត្រព្រះពុទ្ធ (Buddhist Science)។ ឥឡូវនេះ សញ្ញាណបាតុភូត ដែលមានលក្ខខណ្ឌ រក្សាតំណែង ដែលមានលក្ខណៈកំណត់នៃអ្នកវិទ្យាសាស្ត្រ សម័យទំនើបបំផុត ដែលគ្មានហេតុការណ៍ណា មិនមានបុព្វហេតុនោះទេ ហើយប្រសិនបើយើងមិន ជឿជាក់លើសហេតុធម៌ទេនោះ នឹងមិនមានវិទ្យាសាស្ត្រ ឬព្រះពុទ្ធសាសនាទេ។ ដូចជាព្រះពុទ្ធ មានពុទ្ធដីកាថា ការកើតឡើងនៃព្រឹត្តិការណ៍មួយគឺកើតឡើងពីអនេកគុណ នៃបុព្វហេតុទាំងឡាយ ដែលជាទំនាក់ទំនងហេតុផលនោះ ផ្នែកខ្លះៗ គឺស្ថិតនៅផ្នែកខាងក្នុងឬជាអត្តនោម័តិ មានក្នុងខ្លួនអ្នកផ្ទាល់ និងផ្នែកផ្សេងទៀត ស្ថិតនៅផ្នែកខាងក្រៅ។ នោះគឺថា មានព្រឹត្តិការណ៍ជាច្រើន ដែលកើតមានជាមួយព្រឹត្តិការណ៍ ឬបាតុភូតផ្សេងៗទៀត។ តាមពិតទៅ វាជាសមិទ្ធផលតែមួយគត់របស់ព្រះពុទ្ធ ដើម្បីយល់ដឹងសច្ចភាពនេះ កាលពីជាង២៦០០ឆ្នាំកន្លងទៅហើយ។ប៉ុន្តែព្រះពុទ្ធបានប្រកាសជា បន្ថែមថា មានធាតុដែលមិនមានហេតុផល ពោលគឺនិព្វាន ដែលកើតមានឡើងដោយខ្លួនឯងតែម្យ៉ាងគត់នៅពេលយើងបានយល់ដឹងលក្ខខណ្ឌទាំងឡាយ។

ក្នុងការយល់ដឹងទម្រង់ទាំង៣ នៃទស្សនវិជ្ជា ចំពោះបាតុភូតពោលគឺ មនោនិយម សម្ភារនិយម តថនិយមផងដែរ។ ព្រះពុទ្ធសាសនា ត្រូវបានចាត់ចូលក្នុងចំណាត់ថ្នាក់មួយ ដែលត្រូវបានគេហៅថា តថនិយម។

## ៣-ត្រីលក្ខណៈ (Tilakkhana, The Three Marks)

នៅទីនេះ វាជាប់ទាក់ទងនឹងការពិចារណាថា តើអ្វីជាលក្ខណៈពិសេសជាទូទៅ នៃលក្ខណៈសាមញ្ញ ឬបាតុភូត ដែលមានលក្ខខណ្ឌ។ ក្នុងចំណោមនេះ មានលក្ខណៈសំខាន់បីយ៉ាងគឺ៖

1-ដំបូងគេ មានលក្ខណៈជាបណ្តោះអាសន្ន (Mark of Impermanence)។ រឿងនេះ

ចង្អុលបង្ហាញឱ្យឃើញថា វត្ថុទាំងឡាយ ស្ថិតនៅក្នុងសភាពប្រែប្រួល ឬមិនស្ថិតស្ថេរ។

2-លក្ខណៈទី២ គឺជាប់ពាក់ព័ន្ធនឹងភាពមិនសប្បាយចិត្ត(Infelicity)ដែលចង្អុលបង្ហាញ ទៅដល់ធម្មជាតិ នៃការមិនពេញចិត្ត នៃវត្ថុ ដែលមានភាពជាបណ្ដោះអាសន្ន ពីព្រោះ សេចក្ដីភ័យខ្លាច កើតមានឡើង ដោយការផ្លាស់ប្ដូរនៃវត្ថុទាំងឡាយ។ លក្ខណៈបែបនេះ មានភាពជាក់ស្ដែងជាខ្លាំងក្នុងការផ្លាស់ប្ដូរទៅរកវ័យជរា (Old age) ដែលអាចកើតមានទូវជំងឺ និងគ្រោះថ្នាក់ មរណភាព និងសេចក្ដីទុក្ខព្រួយ។

3-លក្ខណៈទី៣ គឺថា អបុគ្គលិកលក្ខណៈ ឬភាពមិនស្និទ្ធស្នាល ដែលជាសញ្ញានៃអវត្តមាននៃភាពស្ថិតនៅទីណាមួយ ឬសារជាតិណាមួយ ដែលមានឥទ្ធិពល ដូចជាអត្ត ឬព្រលឹង ដោយសារតែភាព ជាបណ្ដោះអា សន្ននិងភាពមិនរីកពាយ នៅក្នុងវត្ថុដែលមានលក្ខខណ្ឌ ទាំងអស់នោះ។ ក្នុងការប្រៀនប្រដៅរបស់ព្រះពុទ្ធ ដែលគេនិយាយយោង ទៅដល់នោះ គឺមានលក្ខណៈទាំង៣ នេះ ដូចជា អនិច្ចៈ(Anicca) ទុក្ខៈ(Dukkha) ព្រមទាំង អនត្តៈ (Anatta)ផងដែរ។

## ៤-ដង់ស៊ីតេ និងមាយាការ ( The Densities and the Illusions )

នៅក្នុងជីវភាពនៅក្នុងលោកយើងនេះ យើងមិនអាចមើលឃើញលក្ខណៈទាំងឡាយនៃវត្ថុឡើយ ពីព្រោះចក្ខុវិញ្ញាណច្បាស់លាស់របស់យើង ត្រូវបានរាំងស្កាត់ដោយដង់ស៊ីតេនៃភាពបន្ត(Continuity) ភាពទាំងមូល (Whole) មុខងារ(Function) និងវត្ថុ (Object)។ រឿងនេះ បង្កើតឱ្យមានមាយាការ ឬកំហុស (Vipallasa) តាមមុខងារ៣នៃចិត្ត គឺថា តាមការយល់ដឹង តាមការសង្កេតកត់ចំណាំ និងតាមការបង្កើតគំនិត ដើម្បីបង្កើតសញ្ញាណក្លែងក្លាយ៤នៃ អចិន្ត្រៃយ៍ភាព (Per- manence, Nicca Sanna) ភាពពេញលេញ ឬការធ្វើឱ្យមានសុខភាព (Whole some, Subha Sanna) សុភមង្គល (Hapi ness, Sukha Sanna) និងអត្ត (Self, Attha Sanna) ក្នុងអ្វីដែលមានភាពមិនអចិន្ត្រៃយ៍ (Impermanent) ភាពមិនត្រឹមត្រូវ (Unwholesome) ភាពមិនពេញចិត្ត (Unsatisfactory) និងអនត្តៈ (Without Self)។

ព្រោះហេតុដូច្នោះហើយ មាយាការតាមរយៈកែវភ្នែកទាំងនេះ មិនមែនជាកំហុសតែមួយ ដែលកើតមាន នៅក្នុងចិត្តនោះទេ។

## ៥-ចតុរារិយសច្ចៈ ( The Four Noble Truths = Catu-Ariya-Sacca )

នៅលើមូលដ្ឋានដែលមានលក្ខណៈទាំង៣ បញ្ញត្តិសកល និងសំណើ អំពីបាតភូតដែលមានលក្ខខណ្ឌ និងការប្រៀនប្រដៅ ចំពោះកំហុសនោះ គោលការណ៍ ឬទូទៅកម្ម១ចំនួន ស្ដីពីជីវិត ត្រូវបានទាញផលពីវិចារណកិច្ច។ ទាំងនេះ ត្រូវបានគេស្គាល់ថាជាចតុរ

រិយសច្ចៈ ហើយទាក់ទងនឹងទុក្ខអរិយសច្ចៈ (Suffering) សមុទយអរិយសច្ចៈ (The cause of suffering) និរោធអរិយសច្ចៈ (The cessation of suffering) និងមគ្គអរិយសច្ច (The way to the cessation of suffering)។

ទាំងនេះបង្កើតបានជាការប្រៀនប្រដៅរបស់ព្រះពុទ្ធ ដែលមានលក្ខណៈជាកណ្តាល ឬមានសារៈសំខាន់បំផុត(Pivotal)។

**ក-ទុក្ខអរិយសច្ចៈ**

សេចក្តីទុក្ខជាការពិតរបស់មនុស្សសត្វគ្រប់រូប ទោះតិច ឬច្រើនគ្មានអ្នកណាគេចផុត ឬគេអាចនិយាយថា ជីវិតដែលបង្កើតឡើងដោយធាតុ ដែលមានលក្ខខណ្ឌទាំងឡាយ ជារឿងមិនគួរឱ្យពេញចិត្ត ឬតែងតែមានជំងឺ។ ទុក្ខធំៗមាន៖

-ជាតិទុក្ខ ទុក្ខព្រោះមានកើត"មានរូបមានទុក្ខ"

-ព្យាធិទុក្ខ ទុក្ខដោយសារមានជំងឺបៀតបៀន

-ជរាទុក្ខ ទុក្ខព្រោះចាស់ជរាទ្រុឌទ្រោម

-មរណទុក្ខ ទុក្ខព្រោះសេចក្តីស្លាប់ "ឈឺចុកចាប់ ពិបាកខ្លួនមុនស្លាប់"។

**ខ-សមុទយអរិយសច្ចៈ**

មូលហេតុនៃទុក្ខ ជាការពិត"ទុក្ខ មានមូលហេតុ"។ ហេតុដែលនាំឱ្យមានទុក្ខ មានពីរយ៉ាង៖

-អវិជ្ជា (Ignorance) គឺភាពល្ងង់ខ្លៅ

-តណ្ហា (Cravings) អវិជ្ជាបង្កើតឱ្យមានតណ្ហា។ តណ្ហា គឺការស្រេកឃ្លាន សេចក្តីប្រាថ្នា លោភលន់ ចង់បានមិនចេះឆ្អែតឆ្អន់។

**គ-និរោធអរិយសច្ចៈ**

ការរំលត់ទុក្ខជាការពិត។ ដើម្បីរំលត់ទុក្ខ ត្រូវបំបាត់អវិជ្ជា រំលត់តណ្ហា។ ផ្នែកនេះស្ថិតនៅក្នុងសភាពនៃការរួចចាកផុតពីទុក្ខវេទនា និងស្ថិតក្នុងកុសលកម្រិតកំពូល។

**ឃ-មគ្គអរិយសច្ចៈ**

មធ្យោបាយរំលត់ទុក្ខគឺសេចក្តីពិតដើម្បីរំលត់ទុក្ខឈានដល់ស្ថាននិព្វានត្រូវប្រកាន់យកផ្លូវកណ្តាល ហើយប្រតិបត្តិផ្លូវ៨យ៉ាងគឺ "អដ្ឋង្គិកមគ្គ"(The Noble Eightfold Path)

## ៦-ការសិក្សាអភិធម្ម នាំទៅដល់គោលដៅយ៉ាងដូចម្តេច?

(How the Study of Abhidham- ma leads to the Goal?)

កំហុស មាយាការ ជំនឿខុស ជំនឿឆ្វេងជាឈ្មោះផ្សេងទៀតនៃអវិជ្ជា(Ignorance, Avijja)។ ដោយសារតែពួកវាទាំងនេះឯងដែលមនុស្សមិនបានរីកចម្រើន។ មធ្យោបាយដើម្បីបំបាត់អវិជ្ជាចោល គឺត្រូវបានគេហៅថា គតិបណ្ឌិត(Wisdom, Panna)។ គតិបណ្ឌិតទាំងនេះ មិនគ្រាន់តែគតិបណ្ឌិត នៃតក្កវិជ្ជា និងវិចារ ដែលត្រូវបានសិក្សាតាមទម្រង់២ ដូចជាវិទ្យាសាស្ត្រ និងទស្សនវិជ្ជាប៉ុណ្ណោះទេ ប៉ុន្តែ ថែមទាំងគតិបណ្ឌិតប្រកបដោយការយល់ដឹង (Insight wisdom)ដែលពឹងផ្អែក ទៅ

លើនោះផងដែរ ហើយនិងមានកំណើតពីការតាំងការនោផង។ ការប្រៀនប្រដៅ តាមអភិធម្មតាមការវិភាគជីវិតសត្វលោក ជាបឋមមានចិត្តនិងរាងកាយ និងបន្ទាប់មកមានធាតុទាំងឡាយនោះ ជួយរំដោះមនុស្សឱ្យរួចផុត ពីមាយាការ ដែលបាំងមនុស្សមិនឱ្យមើលឃើញសច្ចភាព។ ព្រោះហេតុដូច្នោះ បុគ្គលម្នាក់គួរតែចូល រួមក្នុងការប្រតិបត្តិ និងនាំទៅដល់មាគ៌ាជីវិតរបស់ព្រះពុទ្ធ ដែលទទួលបានចំ ណេះដឹង តាមការប្រៀនប្រដៅ ស្ថិតក្នុងសច្ចភាព។

ព្រះពុទ្ធសាសនា ជាមាគ៌ា ដែលបានកំណត់ដោយព្រះពុទ្ធ កើតចេញពីគតិបណ្ឌិតរបស់ព្រះអង្គនិងមេត្តាធម៌ (Compassion) សម្រាប់ជាប្រយោជន៍ជីវិតសត្វលោកទាំងអស់។ វាជាមាគ៌ានៃព្រះពុទ្ធ សម្មាសតិ និងសម្មាកម្មន្ត (Right action or conduct)។ វាជាមាគ៌ា រំដោះចេញពីកំហុស និងភាពឥតខ្ចោះហើយដែលគេធ្វើការគ្រប់ពេលវេលាគ្រប់ទីកន្លែង ជាប្រយោជន៍ និងសុខុមាលភាព នៃជីវិតសត្វលោក។ ការចាប់ប្រើមាគ៌ានេះ ទាមទារឱ្យ មានទំនុកចិត្ត និងការជឿជាក់ទៅ លើសមត្ថភាពរបស់ព្រះពុទ្ធក្នុងនាមជាអ្នកប្រដៅសាសនាម្នាក់។ ប៉ុន្តែ ព្រះពុទ្ធ ក៏បានទាមទារឱ្យអ្នកទាំងឡាយ ដែលមានបំណង ដើរតាមព្រះអង្គឱ្យទទួលយកព្រះអង្គ មិនគ្រាន់តែជាជំនឿខាងផ្លូវចិត្តឆាប់រហ័ស (Credulence) ប៉ុណ្ណោះទេ ប៉ុន្តែ ថែមទាំងមានជំនឿស៊ប់ (Conviction)ឬការទទួលយក ដោយមានអំណះអំណាង (Confirmation)។ ការបដិសេធនៃលទ្ធិ និងអំណាច មានន័យថា យើង ត្រូវតែធ្វើតេស្តការប្រៀនប្រដៅតាមហេតុផល និងបទពិសោធ ព្រមទាំងចំណេះដឹង ដែល មានការកើនឡើង ទាមទារ ចំពោះយើងតាម បែបវិទ្យាសាស្រ្ត ទំនើប (Modern science) ព្រោះសម្រាប់ព្រះពុទ្ធសាសនា ក៏ជាវិទ្យាសាស្រ្តមួយផងដែរនោះ ហើយនិងមិនមានទំនាស់ ជាមួយហេតុការណ៍ ដែលបានកើត ឡើងនោះទេ។

# ឯកសារយោង


*-បណ្ឌិត ឈឹម ទូច: គិហិប្បតិបត្តិពិស្តារ បណ្ណាគារត្រៃរតន៍ ភ្នំពេញ ឆ្នាំ១៩៩៦*

*-ត្រឹង ង៉ា: ប្រវត្តិសាស្ត្រខ្មែរ សម្រាប់មធ្យមសិក្សា និងឧត្តមសិក្សា ភាគ២ ក្រសួង អប់រំ យុវជន និង កីឡា ឆ្នាំ២០០១ (ឯកសារដើម ឆ្នាំ១៩៧៣)*

*៤-ក្រសួងទេសចរណ៍: មគ្គុទ្ទេសក៍ទេសចរណ៍ពិសេសតំបន់អង្គរ នាយកដ្ឋានទេសចរណ៍ ឆ្នាំ ២០០៤*

*-សូ មុយឃឿង* et al. *អរិយធម៌ខ្មែរ: វប្បធម៌ និងសង្គមធម៌ សម្រាប់ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន សាកលវិទ្យាល័យជាតិគ្រប់គ្រង ឆ្នាំ ២០០៥*

-Dr. W. F. Jayasuriya, The psychology & philosophy of Buddhism, an introd- uction to the Abhidhamma, Bhudhist Misionary Society, 1988

-Brooke Noel Moore & Kenneth Bruder, Philosophy, The Power of Ideas, McGraw Hill, 2002.

-John W. Santrock, Psychology, McGraw Hill, 2005

-Padmasiri de Silva, An Introduction to Budhist Psychology, Library of Philosophy and Religion, 1978

# កត្តាចម្បងនៃការបោះបង់ការសិក្សា
# របស់ជនជាតិដើមភាគតិចថ្មូនក្នុងខេត្តមណ្ឌលគិរី

Main Factors of Dropout of Thmoun Ethnic Minority Students in Mondulkiri Province

*ដោយៈ លោក***ប៉ាន់ សំណាង** *មន្ត្រីនាយកដ្ឋានវិទ្យាសាស្ត្រអប់រំ*
*វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម*
*នៃរាជបណ្ឌិត្យសភាកម្ពុជា*

## ១.សេចក្តីផ្តើម

*ការបោះបង់ការសិក្សា តែងតែកើតមានឡើងនៅគ្រប់បណ្តាប្រទេសទាំងអស់នៅលើសាកលលោក មិនថានៅក្នុងប្រទេសអភិវឌ្ឍ ឬប្រទេសកំពុងអភិវឌ្ឍនោះឡើយ។ រដ្ឋាភិបាលរបស់ប្រទេសនីមួយៗ បានយកចិត្តទុកដាក់លើបញ្ហានេះ ដោយបានដាក់ចេញជាគោលនយោបាយ យុទ្ធសាស្ត្រ កម្មវិធី និងការគាំទ្រផ្សេងៗ ដើម្បីកាត់បន្ថយអត្រាបោះបង់ការសិក្សា តាមលទ្ធភាពដែលអាចធ្វើបាន។ សកម្មភាពជាច្រើនត្រូវបានដាក់ចេញ ដើម្បីទប់ស្កាត់ការបោះបង់ការសិក្សារបស់សិស្សានុសិស្ស អាស្រ័យទៅតាមស្ថានភាពជាក់ស្តែងដែលជាមូលហេតុនៅពីក្រោយការបោះបង់ រួមមានស្ថានភាពផ្ទាល់ខ្លួនរបស់សិស្ស បរិយាកាស សង្គម ការគាំទ្រពីអាជ្ញាធរ ភាពក្រីក្រ យេនឌ័រ លទ្ធផលនៃការសិក្សាធ្លាក់ចុះ។*

*ការបោះបង់ចោលការសិក្សាបានក្លាយជាបញ្ហាអាទិភាពជាអន្តរជាតិ ដែលបានទទួលការយកចិត្តទុកដាក់នៅក្នុងគ្រប់បណ្តាប្រទេសទាំងអស់លើសាកលលោក ទាំងប្រទេសអភិវឌ្ឍ និងប្រទេសកំពុងអភិវឌ្ឍ។ បណ្តាប្រទេសទាំងអស់ បានប្តេជ្ញាចិត្តដើម្បីធ្វើយ៉ាងណាឱ្យការអប់រំទទួលបានជោគជ័យមានន័យថាធ្វើយ៉ាងណាឱ្យអត្រាបោះបង់ការសិក្សានៅទាបបំផុត និងអត្រាឆ្លងភូមិសិក្សា ព្រមទាំងបញ្ចប់ភូមិសិក្សាឱ្យមានកម្រិតខ្ពស់បំផុត ទៅតាមលទ្ធភាព និងធនធានដែលខ្លួនមាន។*

*ម្យ៉ាងទៀត ដើម្បីធ្វើឱ្យប្រជាពលរដ្ឋមានជីវភាព កាន់តែប្រសើរ ហើយនិងធ្វើយ៉ាងណា*

ឱ្យប្រទេសរបស់ខ្លួនមានកម្លាំងគ្រប់គ្រាន់ដើម្បីប្រកួតប្រជែងខាងផ្នែកសេដ្ឋកិច្ច និងវិស័យផ្សេងៗទៀតជាមួយប្រទេសដទៃ។

កម្ពុជា ជាប្រទេសមួយដែលទាមទារយ៉ាងណាសម្រេចឱ្យបាននូវគោលនយោបាយអប់រំរបស់ខ្លួនក្នុងការកាត់បន្ថយអត្រានៃការបោះបង់ការសិក្សារបស់សិស្សានុសិស្ស។ ទាក់ទងនឹងចំណុចនេះ ក្រសួងអប់រំ យុវជន និងកីឡា បានដាក់ចេញនូវផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៤-២០១៨ និងរៀបចំជាយុទ្ធសាស្ត្រសម្រាប់កាត់បន្ថយអត្រាបោះបង់ការសិក្សានៅមធ្យមសិក្សាបឋមភូមិឲ្យថយចុះពីជាង ២០% មកត្រឹម៣% ក្នុងរយៈពេល៥ឆ្នាំខាងមុខ ដោយផ្តល់ជាតុចូលមានគណនេយ្យភាព និងគាំទ្របច្ចេកទេសដល់សាលារៀនស្របតាមស្តង់ដារ។[1]

ពិតណាស់ហើយថា មូលហេតុនៃការបោះបង់ការសិក្សា គឺមានការប្រែប្រួលពីតំបន់មួយទៅតំបន់មួយ ពីខេត្តមួយទៅខេត្តមួយ។ ខេត្តមណ្ឌលគិរី ជាខេត្តភាគឦសានរបស់ប្រទេសកម្ពុជា ដែលសម្បូរទៅដោយជនជាតិដើមភាគតិចរស់នៅច្រើនអម្បូរ មានដូចជាពួងរអ្នង គ្រោលថ្នូន ចារ៉ាយនិងស្ទៀងជាដើម។ ក្រុមជនជាតិដើមភាគតិចទាំងនេះ មានបែបផែនប្រពៃណី ការរស់នៅនិងទំនៀមទម្លាប់ខុសៗគ្នាបន្តិចៗ ជាពិសេសគឺភាសានិយាយ។[2] បច្ចុប្បន្ន ជនជាតិដើមភាគតិចទាំងនោះ បាននិងកំពុងសិក្សាភាសា អក្សរសាស្ត្រខ្មែរនៅតាមសាលានានាក្នុងតំបន់របស់ខ្លួន។ ក៏ប៉ុន្តែអ្វីដែលយើងកត់សម្គាល់នោះ យើងឃើញថាពួកគាត់មិនសូវបានបន្តការសិក្សាដល់ឧត្តមសិក្សាប៉ុន្មានទេ ជាពិសេសបងប្អូនជនជាតិដើមថ្នូន។ ការរស់នៅបច្ចុប្បន្នរបស់ជនជាតិដើមភាគតិចឬខ្មែរលើ«ថ្នូន»ដែលធ្វើការស្រាវជ្រាវពីមន្ទីរវប្បធម៌និងវិចិត្រសិល្បៈខេត្តមណ្ឌលគិរី ក្រោមការចង្អុលបង្ហាញពីលោក **សី ទូច** ប្រធានមន្ទីរនោះថា ជនជាតិថ្នូននេះបានបាត់បង់ទំនៀមទម្លាប់ប្រពៃណី ស្ទើរតែទាំងស្រុង ក្រោយរបបកម្ពុជាប្រជាធិបតេយ្យ។ ក្នុងទិដ្ឋភាពបែបនេះ យើងមានការចាប់អារម្មណ៍ខ្លាំងលើការបាត់បង់នេះ ក៏ដូចជាការ

---

[1] ក្រសួងអប់រំ ការស្រាវជ្រាវស្តីពីការបោះបង់ការសិក្សារបស់សិស្សនៅមធ្យមសិក្សាបឋមភូមិ(ថ្នាក់ទី៧ដល់ថ្នាក់ទី៩) ឆ្នាំ២០១៦.

[2] ស្រង់ពីគេហទំព័រ៖https://ams.com.kh

សិក្សាអប់រំរបស់បងប្អូនជនជាតិដើមថ្នូននេះផងដែរ ពីព្រោះអត្រាឆ្លងចូលភូមិសិក្សានីមួយៗរបស់ជនជាតិដើមមានកម្រិតមួយគួរឲ្យព្រួយបារម្ភ។ ពេលយើងមកដល់ទីតាំងបងប្អូនជនជាតិដើមថ្នូន វារឹតតែធ្វើឱ្យយើងក្តុកក្តួល ពីព្រោះតាមការសង្កេតជាទូទៅស្ថានភាពរបស់ពួកគាត់ខុសពីការគិតពេលដែលយើងមិនទាន់មកដល់ភូមិស្រុករបស់ពួកគាត់ ហើយក្មេងៗ យុវជនជាតិថ្នូនមិនបានបន្តការសិក្សាដូចជនជាតិដទៃឡើយ។ ដោយយល់ឃើញថា ថ្នូនជាជនជាតិដើមមួយដែលប្រឈមនឹងការបាត់បង់វប្បធម៌ ប្រពៃណីទំនៀមទម្លាប់បែបនេះ យើងខ្ញុំក៏ធ្វើការស្រាវជ្រាវស្តីពីការសិក្សាអប់រំរបស់ពួកគេដោយការអានឯកសារនានា ការអង្កេត ពិនិត្យការសម្ភាស និងចុះផ្ទាល់សួរនាំប្អូនៗជាតិថ្នូន។

យើងខ្ញុំសង្ឃឹមថា អត្ថបទស្រាវជ្រាវខ្ទីនេះនឹងក្លាយជាឯកសារជំនួយស្មារតីមួយសម្រាប់អ្នកអាន ក៏ដូចជាអ្នកស្រាវជ្រាវទាំងឡាយ។

## ២.និយមន័យ

កន្សោមពាក្យ«**បោះបង់ការសិក្សា**»មានការឱ្យនិយមន័យផ្សេងៗគ្នា។ខាងក្រោមជាការយល់ឃើញផ្សេងៗគ្នា៖

យោងតាមវចនានុក្រមមួយពាក្យ «Dropout» មានន័យថាបុគ្គលដែលបោះបង់ការសិក្សា ឬអ្នកដែលបដិសេធសង្គមធម្មតាដើម្បីបន្តរបៀបរស់នៅជំនួស។ (a person who has abandoned a course of study or who has rejected conventional society to pursue an alternative lifestyle ) ។ ចំពោះពាក្យ «Drop out» ដែលមានការដកឃ្លា មានន័យថា កុំធ្វើអ្វីមួយដែលអ្នកនឹងធ្វើ ឬឈប់ធ្វើអ្វីមួយមុនពេលអ្នកបានបញ្ចប់ទាំងស្រុង។ ឧ. បើគេឈប់រៀន ពួកគេឈប់ចូលថ្នាក់រៀន មុនពេលពួកគេបញ្ចប់វគ្គសិក្សា។( not do something that you were going to do, or to stop doing something before you have completely finished: If a student drops out, they stop going to classes before they have finished their course.)[3]

បើតាមវចនានុក្រមខ្មែរសម្តេច **ជួន ណាត** បានសរសេរថា «បោះបង់» មានន័យថា

[3] ស្រង់ពីគេហទំព័រ៖https://dictionary.cambridge.org

លះបង់ ចោលបង់ មិននឹកនា មិនថែទាំ ហើយសិក្សាវចនានុក្រមខ្មែរដដែលបាន សរសេរថា សិក្សា នាមសព្ទ (សំ. តិក្សា; បា. សិក្ខា) សិក្ខា គឺការរៀន, ការរៀនទន្ទេញ, ការសូត្ររៀន; ការហ្វឹក, ការហ្វឹកហាត់; ការប្រុងប្រយ័ត្នរក្សាមារយាទឲ្យល្អ; ខប្រតិបត្តិ; វិជ្ជា; ការស្ទាត់ជំនាញ, ...។ ខ្មែរច្រើនប្រើជា កិ. "រៀន, រៀនទន្ទេញ, សូត្ររៀន" : មាតាបិតាទំនុកបម្រុងបុត្រឲ្យសិក្សា។ សិក្សាការ ឬ–ការ្យ ការសិក្សា។ សិក្សាចតុរង្គ (–ចៈតុរ៉ង់) អង្គ៤ នៃការសិក្សាគឺ សុ. ចិ. បុ. លិ. (ម. ព. នេះ)។ សិក្សាត្រ័យ ប្រជុំ ៣ នៃខប្រតិបត្តិគឺសីល, សមាធិ, បញ្ញា (ហៅ ត្រ័យសិក្ខា ក៏បាន; ព. ពុ.)។ សិក្សាធិការ (សំ. តិក្សា + អធិការ) ការគ្រប់គ្រងឬត្រួតត្រាលើការសិក្សា : ក្រសួងសិក្សាធិការ។ល។ ជារួមមក យើងអាចនិយាយបានថា បោះបង់សិក្សា សម្ដៅលើ «លះបង់ឬចោលបង់ការសូត្ររៀន។

ចំពោះនិយមន័យនៃការបោះបង់ ការសិក្សាមួយចំនួនបានកំណត់ ផ្សេងៗគ្នា ទៅតាមបរិបទនៃប្រទេសនីមួយៗ។ យោងតាម UNESCO (1984) បានកំណត់និយមន័យសិស្សបោះបង់ថា ជាកុមារដែលបានចុះឈ្មោះចូលរៀននៅសាលារៀន ប៉ុន្តែមិនបានបញ្ចប់ការសិក្សានៅកូមិសិក្សានោះទេ។ មានន័យថា សិស្សបោះបង់ការសិក្សានៅមធ្យមសិក្សាបឋមភូមិជាសិស្សដែលចុះឈ្មោះចូលរៀននៅថ្នាក់ទី ៧ ប៉ុន្តែមិនបានបញ្ចប់ការសិក្សាថ្នាក់ទី៩ ទេ។ យោងតាម OECD, (2002) បានកំណត់ថា សិស្សបោះបង់ គឺជាសិស្សដែលចាក ចេញពីកម្រិតជាក់លាក់នៃប្រព័ន្ធអប់រំដោយមិនបានសម្រេចនូវគុណវុឌ្ឍិដំបូង។[4]

## ៣. កត្តាឆ្ពោះនៃការបោះបង់ការសិក្សា

បោះបង់ការសិក្សា គឺជាបាតុភូតដែលសិស្សឈប់ចូលរៀន ហើយត្រូវទុកចោលប្រព័ន្ធអប់រំដោយមិនបានទទួលសញ្ញាបត្រផ្នែកអប់រំ។ បើតាមការស្រាវជ្រាវស្ដីពីការបោះបង់ការសិក្សារបស់សិស្សនៅមធ្យមសិក្សាបឋមភូមិរបស់ក្រសួងអប់រំ នៅឆ្នាំ២០១៦ បានបង្ហាញថា៖ ក្នុងបរិបទរបស់កម្ពុជាឯណោះវិញ តាមទិន្នន័យរបស់នាយកដ្ឋានគ្រប់គ្រងប្រព័ន្ធ

[4] ក្រសួងអប់រំ ការស្រាវជ្រាវស្ដីពីការបោះបង់ការសិក្សារបស់សិស្សនៅមធ្យមសិក្សាបឋមភូមិ(ថ្នាក់ទី៧ដល់ថ្នាក់ទី៩) ឆ្នាំ២០១៦។

ព័ត៌មានអប់រំ បង្ហាញថា ការបោះបង់ការសិក្សា នៅគ្រប់កម្រិតថ្នាក់គឺនៅមានកម្រិតខ្ពស់នៅឡើយរហូតមកទល់ឆ្នាំសិក្សា ២០១៤-២០១៥ ដែលក្នុងនោះ ការបោះបង់របស់សិស្សនៅបឋមសិក្សាមានចំនួន ៨.៣%! នៅមធ្យមសិក្សាបឋមភូមិមាន២១% និង ចំនួន ២៣.៤% នៅមធ្យមសិក្សាទុតិយភូមិ។ ដោយមើលឃើញពីបញ្ហាប្រឈមដូចនេះ ក៏ដូចជាចង់កំណត់ ឲ្យបានច្បាស់លាស់នូវយន្តការមួយក្នុងការកាត់បន្ថយការបោះបង់ជាពិសេសការបោះបង់ការសិក្សារបស់សិស្សនៅមធ្យមសិក្សាបឋមភូមិ ដែលមានកម្រិតខ្ពស់ជាងគេនោះ ថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡា បានស្នើឲ្យមានការសិក្សាស្រាវជ្រាវនេះឡើង។ ការសិក្សា ស្រាវជ្រាវនេះ មានវត្ថុបំណងធំពីរគឺ ១). កំណត់អំពីកត្តាចម្បងៗនានា ដែលធ្វើឲ្យសិស្សបោះបង់ការសិក្សា និង២)កំណត់នូវយន្តការដែលមានប្រសិទ្ធភាព ដើម្បីចូលរួមកាត់បន្ថយ ការបោះការសិក្សារបស់សិស្សនៅមធ្យមសិស្សបឋមភូមិ។

កត្តាចម្បងដែលនាំឲ្យសិស្សបោះបង់ការសិក្សាមាន៨[5]៖

**១. កត្តាសិស្សខ្លួនឯង៖** សិស្សលែងមានទឹកចិត្តក្នុងការរៀនសូត្រ និងលែងឱ្យតម្លៃលើសាលារៀន និងភាពជោគជ័យនៃការរៀនសូត្ររបស់ខ្លួន។ ការជះឥទ្ធិពលទៅវិញទៅមករវាងកង្វះចំណាប់អារម្មណ៍ និងបញ្ហាជួបប្រទះក្នុងការសិក្សា។ កង្វះចំណាប់អារម្មណ៍ និងកង្វះឆន្ទៈ ធ្វើឱ្យបញ្ហាពាក់ព័ន្ធនឹងការសិក្សាកើនឡើងជាលំដាប់ពីមួយថ្ងៃទៅមួយថ្ងៃ ហើយបញ្ហានេះបានជះឥទ្ធិពលអវិជ្ជមានទៅលើចំណាប់អារម្មណ៍ និងឆន្ទៈក្នុងការសិក្សារបស់សិស្ស។

**២. កត្តាគ្រួសារ៖** ជីវភាពគ្រួសារក្រីក្រក៏ជាបញ្ហាប្រឈមមួយធ្ងន់ធ្ងរដែរ ដែលបណ្ដាលឱ្យសិស្សបោះបង់ការសិក្សា។ កុមារកើតមក និងរស់នៅជាមួយគ្រួសារតាំងពីតូច ហើយគ្រួសារបានក្លាយជាការសម្រេចចិត្តលើអនាគតរបស់ពួកគេរួមទាំងការសិក្សាផងដែរ។ គ្រួសារក្រីក្រមួយចំនួនតែងតែផ្លាស់ប្ដូរទីលំនៅនិងនាំ កូនរបស់គេទៅជាមួយ ដើម្បីជួយធ្វើការតាមដែលអាចធ្វើទៅបាន ដូចជាការធ្វើស្រែចម្ការឬការរកលុយដើម្បីចិញ្ចឹមជីវិត។

[5] ស្រង់ពីគេហទំព័រ៖https://education.ams.com.kh

ហេតុនេះបានរារាំងកូនចៅមិនឱ្យចេញពីផ្ទះទៅសាលារៀន។

**៣. កត្តាសាលារៀន៖** សាលារៀនជាកត្តាដែលគួរឱ្យកត់សម្គាល់និងពិចារណាលើបញ្ហាដែលបណ្តាលឱ្យសិស្សបោះបង់ការសិក្សាផងដែរ។ គំរូទ្រឹស្តីពន្យល់ពីការបោះបង់ការសិក្សាបានបង្ហាញថា កុមារនិងបរិស្ថាននៃថ្នាក់រៀនរបស់ពួកគេ ព្រមទាំងទំនាក់ទំនងរបស់ពួកគេនៅសាលារៀនជាកត្តាសំខាន់បំផុតក្នុងការព្យាករណ៍ពីភាពជោគជ័យ និងការបោះបង់ការសិក្សា។ តាមការស្រាវជ្រាវរបស់ Khan, Azhar and Shah នៅឆ្នាំ២០១១ បានបង្ហាញថា បញ្ហានៅក្នុងសាលារៀនដែលជះឥទ្ធិពលអវិជ្ជមានដល់សិស្សមានជាដូចជា សមត្ថភាពគ្រូកម្រិតនៃកម្មវិធីសិក្សាលំបាកខ្លាំង និងវិធីសាស្ត្របង្រៀនមិនមានភាពទាក់ទាញជាដើម។

**៤. កត្តាសហគមន៍និងអាជ្ញាធរ៖** សហគមន៍ក៏ជាកត្តាមួយដែលទាក់ទងដល់ការសម្រេចចិត្តបោះបង់ការសិក្សារបស់សិស្សផងដែរ។ សិស្សអាចបន្តការសិក្សានៅសាលារៀនបានយូរអង្វែងអាស្រ័យលើការលើកទឹកចិត្តពីខ្លួនគេផ្ទាល់ និងមនុស្សនៅជុំវិញ។ តាមការស្រាវជ្រាវរបស់ Natriello ក្នុងឆ្នាំ២០១២ បានបញ្ជាក់ថា ទីណាដែលមានការគាំទ្រទាបពីសំណាក់សហគមន៍ទីនោះមានការបោះបង់ការសិក្សាច្រើន។

គួរបញ្ជាក់ថា ដើម្បីទប់ស្កាត់ និងកាត់បន្ថយការបោះបង់ការសិក្សាដែលនៅមានកម្រិតខ្ពស់នៅឡើយនោះ អាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធបានយកចិត្តទុកដាក់ និងខិតខំប្រឹងប្រែងទប់ស្កាត់ការបោះបង់ការសិក្សាដោយបានដាក់ចេញជាវិធានការនានានៅតាមសហគមន៍ ជាពិសេសនៅតាមសាលារៀនដែលប្រឈមនឹងការបោះបង់ការសិក្សាខ្ពស់។ អត្រាបោះបង់ការសិក្សារបស់សិស្សនៅមធ្យមសិក្សាបឋមភូមិ មិនមែនមានតែនៅកម្ពុជានោះទេ នៅបណ្តាប្រទេសផ្សេងៗក៏មានដែរ ខណៈរូបភាពនៃការបោះបង់ការសិក្សាកើតឡើងប្រហាក់ប្រហែលគ្នា។

## ៤.កត្តាចម្បងនៃការបោះបង់ការសិក្សារបស់ជនជាតិដើមភាគតិចថ្នូនក្នុងស្រុកកោះញែក

### ក.ភូមិសាស្ត្រនៃជនជាតិថ្នូន

តាមរយៈការផ្តល់ដំណឹងពីឈ្មោះ **ចើត ក្លួល** និងឈ្មោះ **ខាំ លាញ់**[6] បានអះអាងថា ការនិយាយតៗគ្នាជាច្រើនជំនាន់ពីដូនតា អំពីស្ថានភាពភូមិសាស្ត្រ មានទីតាំងមួយកន្លែងស្ថិតក្នុងស្រុកកោះញែកប៉ែកខាងលិចពីភូមិភាគឥសាន មានព្រៃស្តុកធំមួយ មានជនជាតិភាគតិច១ក្រុម រស់នៅក្នុងព្រៃនោះប្រហែល ៥០គ្រួសារ។ពួកគេ បានបង្កបង្កើតកូនចៅ និងរស់នៅជាពួក ពឹងពាក់លើធម្មជាតិ និងបានហៅខ្លួនឯងថា ជនជាតិ«ថ្នូន»។[7] ហើយតាមការចុះស្រាវជ្រាវផ្ទាល់ យើងបានទៅដល់ភូមិឋានរបស់ជនជាតិដើមថ្នូននេះ គឺពួកគាត់រស់នៅភូមិមេមុំ ឃុំរយ៉ ស្រុកកោះញែក ខេត្តមណ្ឌលគិរី(រូបទី១)។



រូបទី១៖ឈ្មោះ ថេល សោយ អាយុ៥០ឆ្នាំ ជាតិថ្នូន នៅភូមិមេមុំ ឃុំរយ៉ ស្រុកកោះញែក

**ខ.ការសិក្សានៃសិស្សានុសិស្សជាតិថ្នូន**

នៅសតវត្សថ្មីនេះ កុមារជនជាតិថ្នូន មិនមានការសិក្សាសាលាជនជាតិដើមខ្លួនទេ

[6] ស្រង់ពីគេហទំព័រ៖https://ams.com.kh

[7] ស្រង់ពីគេហទំព័រ៖https://ams.com.kh

ដោយពួកគេសិក្សានៅសាលាសាធារណៈរបស់រដ្ឋ។ពួកគេ រៀនតាមកម្មវិធីក្រសួងអប់រំកម្ពុជា។

ពេលដែលកុមារជ្ជូនដល់អាយុចូលរៀន ឪពុកម្ដាយក្នុងភូមិមេមុំ បានបញ្ជូនកូនៗរបស់ពួកគេមកសិក្សារៀនសូត្រនៅសាលាក្នុងភូមិ។ កុមារៗ មិនបានចូលរៀនថ្នាក់មត្តេយ្យនោះទេ ពោលគឺពួកគេចូលរៀនបឋមសិក្សាតែម្ដង។ សាលាបឋមសិក្សាដែលកុមារៗជាតិជ្ជូន រៀន គឺសាលាបឋមសិក្សាថុមប៉ុង។ បន្ទាប់ពីបញ្ចប់ការសិក្សានៅបឋមសិក្សា ពួកគេត្រូវបន្តការសិក្សានៅអនុវិទ្យាល័យបន្តទៀត។

ក្នុងការសិក្សានៅអនុវិទ្យាល័យកុមារជាតិជ្ជូនក្នុងភូមិមេមុំ ត្រូវទៅសិក្សានៅអនុវិទ្យាល័យហ៊ុនសែនកោះញែកទាំងអស់។ ជាក់ស្ដែង កុមារីជាតិជ្ជូនឈ្មោះ ដុម កាយ៉ា អាយុ ១៣ឆ្នាំ នៅភូមិមេមុំ រៀនថ្នាក់ទី៧ នៅអនុវិទ្យាល័យហ៊ុន សែន កោះញែកបានផ្ដល់បទសម្ភាសន៍ថា នាងរៀនជាភាសាខ្មែរ និងរៀនភាសាអង់គ្លេសផងដែរនៅឯសាលា(រូបទី២)។




*រូបទី២៖កុមារីឈ្មោះ **ដុម កាយ៉ា** អាយុ១៣ឆ្នាំ រៀនថ្នាក់ទី៧នៅភូមិមេមុំ ឃុំរយ៉ ស្រុកកោះញែក*

កុមារី**កាយ៉ា**បានបន្ថែមទៀតថា ក្នុងចំណោមមុខវិជ្ជាទាំងអស់ នាងរៀនពូកែ លើមុខវិជ្ជាភាសាខ្មែរជាងគេ។ ក្រៅពីកាយ៉ា ប្អូនប្រុសនាងឈ្មោះ ដុម ផល្វា (រូបទី៣) អាយុ១២ឆ្នាំ រៀនថ្នាក់ទី៦ នៅសាលាបឋមសិក្សាថុមប៉ុង ក៏បាននិយាយថា ក្មេងៗក្នុងភូមិគាត់រៀននៅសាលាជាមួយគាត់ទាំងអស់ ហើយពេលរៀនចប់គឺពួកគេបន្តការសិក្សានៅសាលាអនុវិទ្យាល័យហ៊ុនសែន កោះញែកដូចយ៉ាយ៉ា[8]ដែរ។



រូបទី៣៖ កុមារីឈ្មោះ **ដុម កាយ៉ា** និងប្អូនប្រុសឈ្មោះ **ដុម ផល្វា** ជនជាតិថ្នូន និងអ្នកស្រាវជ្រាវ

### គ.កត្តាចម្បងនៃការបោះបង់ការសិក្សារបស់សិស្សានុសិស្សជាតិថ្នូន

ការបោះបង់ចោលសាលារៀន គឺជាក់ស្តែងជាពិសេសនៅក្នុងប្រទេសអភិវឌ្ឍនិងកំពុងអភិវឌ្ឍន៍ដែលបាតុភូតនេះត្រូវបានគេសង្កេតឃើញនៅចន្លោះឆ្នាំចុងក្រោយនៃបឋមសិក្សានិងអនុវិទ្យាល័យ។ នៅក្នុងប្រទេសឧស្សាហកម្ម ការបោះបង់ការសិក្សាកើតឡើងនៅក្នុងការអប់រំឧត្តមសិក្សាឬការសិក្សានៅសាកលវិទ្យាល័យ។យោងតាមមូលនិធិកុមាររបស់អង្គការសហប្រជាជាតិ (យូនីសេហ្វ) ការបោះបង់ចោលសាលារៀនមានបុព្វហេតុចម្បងមួយ

---

[8] ប្អូនផល្វា ហៅកាយ៉ា ថា យ៉ាយ៉ា

*ចំនួនដូចជា៖ កុមារខ្វះអាហារូបត្ថម្ភ ឬអ្នកដែលត្រូវបានបង្ខំឱ្យទៅធ្វើការដោយសារបរិយាកាសក្រីក្រ ការបដិសេធសង្គមឬសាលារៀនដែលមានសមត្ថភាពថយចុះ។*[9]

*ចំពោះជនជាតិដើមថ្នូន មានលក្ខណៈពិសេសដោយឡែក ពីព្រោះប្រពៃណីទំនៀមទម្លាប់ស្ទើរតែបាត់បង់ សូម្បីតែក្មេងៗជាតិថ្នូនក៏មិនចេះនិយាយភាសាថ្នូនផង។ គឺមានតែចាស់ៗនិងមនុស្សវ័យជិត៥០ឆ្នាំ ឬលើស បានចេះភាសាថ្នូន។រីឯការសិក្សាវិញ សិស្សានុសិស្សថ្នូនរៀនបានត្រឹមអនុវិទ្យាល័យត្រឹមកម្រិតថ្នាក់ទី៩ប៉ុណ្ណោះ(រូបទី៤)។ បើតាមក្មេងស្រីជាតិថ្នូនម្នាក់ បាននិយាយថា នាងឈប់រៀនត្រឹមអនុវិទ្យាល័យទេ ហើយបងប្អូននាងក៏ឈប់រៀនត្រឹមហ្នឹងដែរ(រូបទី៥)។*



*រូបទី៤៖កុមារី* ***ដុម កាយ៉ា*** *កុមារា* ***ដុម ផល្លានិងឪពុកម្តាយ***

[9] *ស្រង់ពីគេហទំព័រ៖*https://education.ams.com.kh

ក្រៅពីនេះ យើងក៏បានសួរនាំជីតា ឪពុក ម្តាយរបស់កុមារជាតិថ្នូន ដោយពួកគាត់អះអាងថា បានជាកូនចៅរបស់ពួកគាត់ឈប់រៀនត្រឹមកម្រិតថ្នាក់ទី៩ ព្រោះដោយសារតែគ្មានលទ្ធភាពបន្តការសិក្សានៅទីក្រុង។ កត្តាសំខាន់ គឺបញ្ហាជីវភាពតែម្តងដែលកុមារៗក្នុងភូមិមិនអាចបន្តការសិក្សាទៀតបាន។



រូបទី៥៖បងស្រីរបស់កុមារីឈ្មោះ **ដុម កាយ៉ា ឈប់រៀនត្រឹមអនុវិទ្យាល័យ**

## ៥.ការសន្និដ្ឋាន និងគតិសំខាន់ៗ

តាមលើកឡើងមកខាងលើ សម្រាប់សិស្សមួយចំនួន ការបោះបង់ការសិក្សា គឺកើតចេញពីការពូនផ្តុំបញ្ហាផ្សេងបន្តិចម្តងៗក្នុងការសិក្សា ក្នុងការសេពគប់ និងក្នុង ការដើរផ្លូវខុស ជាដើម។ សិស្សមួយចំនួនទៀត ការ

បោះបង់ការសិក្សា កើតចេញពីការប៉ះទង្គិចផ្លូវចិត្ត សម្ពាធជីវិត តម្រូវការក្នុងការជួយដល់គ្រួសាររបស់ពួកគេផ្នែកហិរញ្ញវត្ថុ ឬការទាមទារឲ្យពួកគេឈប់ ដើម្បីជួយមើលថែរក្សាបងប្អូន ជីដូនជីតា ជំនួសដៃជើងឪពុកម្តាយ ឬអាណាព្យាបាល។ ពេលខ្លះការបោះបង់ការសិក្សា កើតចេញពីការធុញទ្រាន់នឹងថ្នាក់រៀន សាលារៀន គ្រូបង្រៀន មិត្តរួមថ្នាក់ ឬក៏ការមើលឃើញពីភាពមិនស៊ីចង្វាក់គ្នារវាងការសិក្សា និងជីវិតពិត។ បើទោះបីជាហេតុផលនៃការបោះបង់ការសិក្សាមានលក្ខណៈខុសៗ គ្នាក៏ដោយចុះ តែផលប៉ះពាល់ដែលកើតចេញពីការសម្រេចចិត្តក្នុងការបោះបង់ការសិក្សា គឺមានលក្ខណៈស្រដៀងគ្នា។

ជាមួយគ្នានេះដែរ បាតុភូតនៃការបោះបង់ការសិក្សានេះ មានកត្តាជាច្រើនរួមផ្សំគ្នា ហើយស្របតាមភូមិសាស្ត្រ តាមតំបន់ តាមខេត្ត ឬតាមជនជាតិផ្សេងៗ។ចំពោះជនជាតិដើមភាគតិចថ្នូន មានកត្តាសំខាន់បំផុត គឺកត្តាជីវភាពដែលនាំឱ្យសិស្សានុសិស្សថ្នូន បោះបង់ការសិក្សាត្រឹមកម្រិតថ្នាក់ទី៩។

ដើម្បីរួមចំណែកកាត់បន្ថយការបោះបង់ រដ្ឋាភិបាលនៃប្រទេសនីមួយៗខិតខំរៀបចំគោលនយោបាយ ផែនការ យុទ្ធសាស្ត្រ សកម្មភាពនានា ។ជនជាតិទាំងអស់ក៏បានទទួល "វប្បធម៌សាកលភាវូបនីយកម្ម" ចេះស្លៀកពាក់តាមសម័យនិយម មានយានយន្តប្រើ មានអគ្គិសនីចូលដល់ ឯដីភូមិពួកគាត់ពីដូនតា ធ្លាប់តាំងនៅកណ្តាលព្រៃ ក៏មានផ្លូវលំពុះកាត់ ឯផ្ទះអណ្តើក ក្លាយជាផ្ទះឈើ ឬផ្ទះថ្ម។[10] ចំពោះជនជាតិភាគតិច គឺជាបញ្ហាអាទិភាពមួយ ពិសេសជនជាតិដើមថ្នូន ពីព្រោះវាជាបញ្ហាប្រឈមដែលឈានទៅរកការបាត់បង់នូវវប្បធម៌ជនជាតិ។ការបោះបង់ការសិក្សារបស់កុមារៗជាតិថ្នូននៅឃុំរយ៉ ជាការខានបង់ធនធានមនុស្សក្នុងសង្គមពហុវប្បធម៌មួយ។ ម្យ៉ាងវិញទៀត យើងគួរតែជួយគិតគូរដល់ពួកគេដោយអភិវឌ្ឍភាពជាអ្នកដឹកនាំការគ្រប់គ្រងសាលារៀន អ្នកពាក់ព័ន្ធ ផ្តល់អាហារូបករណ៍ ពិសេសផ្សព្វផ្សាយបញ្ជ្រាបយ៉ាងណាឱ្យពួកគេយល់ពីតម្លៃនៃការអប់រំ។

[10] https://norkorthom.com

## **ឯកសារយោង**


-ក្រសួងអប់រំ (២០១៦) *ការស្រាវជ្រាវស្តីពីការបោះបង់ការសិក្សារបស់សិស្សនៅមធ្យមសិក្សាបឋមភូមិ*

-ជួន ណាត (១៩៦៧) ***វចនានុក្រមខ្មែរ*** *ការផ្សាយដោយវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ*


## **គេហទំព័រ**

- https://ams.com.kh
- https://dictionary.cambridge.org
- https://education.ams.com.kh
- https://norkorthom.com

## **បទសម្ភាសន៍**

*-លោកពូ ថេល សោយ អាយុ៥០ឆ្នាំ ជនជាតិថ្នូន នៅភូមិមេមុំ ឃុំរយ៉ ស្រុកកោះញែក ខេត្តមណ្ឌលគិរី នៅថ្ងៃទី៧ ខែមេសា ឆ្នាំ២០២៣។*

*-ក្មួយស្រី ដុម កាយ៉ា អាយុ១៣ឆ្នាំ  ក្មួយប្រុស ដុម ផល្លា អាយុ១២ឆ្នាំនិងឪពុកម្តាយបងស្រីៗកាយ៉ា ជាតិថ្នូន នៅភូមិមេមុំ ឃុំរយ៉ ស្រុកកោះញែក ខេត្តមណ្ឌលគិរី នៅថ្ងៃទី៧ ខែមេសា ឆ្នាំ២០២៣។*

# អត្ថប្រយោជន៍នៃការអប់រំមត្តេយ្យសិក្សា ដល់កុមារតូច

The Benefits of Kindergarten Education for Small Infants

*ដោយ៖ លោក* **ប៉ាន់ សំណាង**

*មន្ត្រីនាយកដ្ឋានវិទ្យាសាស្ត្រអប់រំ*

*វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម*

*នៃរាជបណ្ឌិត្យសភាកម្ពុជា*

## ១. សេចក្តីផ្តើម

*មត្តេយ្យសិក្សា ជាគ្រឹះសំខាន់បំផុតរបស់កុមារក្នុងការប្រឈមនឹងពិភពខាងក្រៅបន្ទាប់ពីការអប់រំបង្ហាត់បង្រៀនរបស់ឪពុកម្តាយនៅតាមផ្ទះរបស់ពួកគេ។ មាតាបិតា ឬអ្នកអាណាព្យាបាលសិស្សានុសិស្ស មិនគួរមើលរំលងការសិក្សានៅមត្តេយ្យសិក្សានោះទេ ព្រោះថ្នាក់មត្តេយ្យ គឺជាកម្រិតដំបូងក្នុងជីវិតសិក្សារបស់មនុស្សយើងម្នាក់ៗ។ ពេលចម្រើនវ័យ ការអប់រំក៏ត្រូវឆ្លើយតបតាមអាយុកាលដែរ។កុមារតូចដែលកើតមកដល់អាយុក្រោម៦ឆ្នាំ តែងមានការអភិវឌ្ឍលើផ្នែករាងកាយនិងស្មារតីដែលជាតម្រូវការចាំបាច់សម្រាប់កុមារ។ការលូតលាស់ទាំងនេះ តែងមានឥទ្ធិពលគ្នាទៅវិញទៅមក។*[1]

*កម្មវិធីអប់រំកុមារតូច គឺជាកម្មវិធីសម្រាប់ការអភិវឌ្ឍគ្រប់ជ្រុងជ្រោយរបស់កុមារ ហើយកុមារទទួលបាននូវសមត្ថភាពពេញលេញទាំងរាងកាយ ផ្លូវចិត្ត ស្មារតីសាមគ្គីភាព ជាពិសេសសមត្ថភាពពិចារណាដោះស្រាយបញ្ហា ស្មារតីស្រឡាញ់បរិស្ថាន និងការចូលចិត្តរបស់កុមារ ពិសេសជាងនេះទៀត មូលដ្ឋានគ្រឹះ ធ្វើឱ្យពួកគេក្លាយជាពលរដ្ឋពេញលេញ និងជាពលរដ្ឋប្រកប ដោយការ*

[1] *ស្រង់ពីអត្ថបទបទ «តម្លៃនៃការអប់រំបរិយាបន្ន» របស់លោកប៉ាន់ សំណាង ផ្សាយដោយរាជបណ្ឌិត្យសភាកម្ពុជា ឆ្នាំ២០២២។*

*ទទួលខុសត្រូវខ្ពស់។*[2] *កុមារគ្រប់រូប មានសិទ្ធិទទួលបានការគាំទ្រពីឪពុកម្តាយ និងសហគមន៍របស់ពួកគេ ដើម្បីទទួលបានការរីកលូតលាស់រូបរាងកាយ ទទួលបានការសិក្សា និងមានការអភិវឌ្ឍបញ្ញាស្មារតីមុនដល់អាយុចូលសាលា ហើយពេលពួកគេដល់អាយុចូលរៀន ពួកគេត្រូវទទួលបានការសិក្សាតាមរយៈគ្រូបង្រៀន និងមិត្តរួមថ្នាក់។ ម្យ៉ាងទៀត កុមារគ្រប់រូបទទួលបានការលូតលាស់ទាំងផ្លូវកាយ ផ្លូវចិត្ត បញ្ញា និងស្មារតី ដោយគ្មានអំពើហិង្សាគ្រប់ទម្រង់ ដើម្បីឱ្យក្លាយជាធនធានមនុស្សសម្រាប់អភិវឌ្ឍន៍ប្រទេសប្រកបដោយចីរភាព។*[3]

*ដូចនេះ ការអប់រំចាប់ផ្តើមពីកុមារតូច ជាការអប់រំដែលមានសារៈសំខាន់បំផុតក្នុងការបណ្តុះស្មារតីជាមូលដ្ឋាននៃការបង្កើតចរិតលក្ខណៈមនុស្សពេញលេញ។*[4]

## ២.ប្រវត្តិមត្តេយ្យសិក្សា

### ក.និយមន័យ

*នៅក្នុងចំណុចនេះ យើងឃើញថា មត្តេយ្យសិក្សា គឺផ្សារភ្ជាប់នឹងកុមារតូចដែរ ។ដូចនេះ មុននឹងលើកពីនិយមន័យសាលាមត្តេយ្យឬមត្តេយ្យសិក្សា យើងត្រូវស្វែងយល់ពីន័យ«ការអប់រំកុមារតូច»ដែរ។* ***តើការអប់រំកុមារតូច ជាអ្វី?***

*ការអប់រំកុមារតូច គឺជាដំណាក់កាលដំបូងនៅក្នុងប្រព័ន្ធអប់រំ នេះត្រូវបានបន្តដោយការអប់រំបឋមសិក្សា និងមធ្យមសិក្សា។ ការអប់រំកុមារតូចរួមបញ្ចូលការបង្រៀនរបស់កុមារចាប់ពីអាយុ ០ ដល់ ៦ ឆ្នាំ និងមានបីប្រភេទនៃផ្នែកដែលខុសគ្នាយ៉ាងល្អ៖ ស្វ័យភាព ចំណេះដឹងអំពីបរិស្ថាន និងការអភិវឌ្ឍភាសាដ៏ល្អប្រសើរ។*

*ការអប់រំកុមារតូចនឹងចែកចេញជាពីរវដ្តៈ ទីមួយត្រូវបានបង្រៀននៅក្នុងសាលាមត្តេយ្យ និងមានគោលបំណងដល់កុមាររហូតដល់អាយុ៣ ឆ្នាំ។ វដ្តទីពីរត្រូវបានបង្រៀននៅសាលា ហើយមានគោលបំណងដល់កុមារអាយុពី៣ ទៅ ៦ ឆ្នាំ។ការងាររបស់អ្នកអប់រំគឺគ្មានអ្វីក្រៅពីការធានាថា កុមារអាចមានស្វ័យភាពនៅពេលនិយាយអំពីអនាម័យ ឬ*

---

[2] *ស្រង់ពីសៀវភៅកម្មវិធីសិក្សាលម្អិតសម្រាប់មត្តេយ្យសិក្សារដ្ឋ របស់ក្រសួងអប់រំ ឆ្នាំ២០១៨។*

[3] *ចក្ខុវិស័យរបស់គោលនយោបាយស្តីពីកិច្ចការពារកុមារនៅសាលារៀន របស់ក្រសួងអប់រំ ឆ្នាំ២០១៦។*

[4] *ស្រង់ពីសៀវភៅកម្មវិធីសិក្សាលម្អិតសម្រាប់មត្តេយ្យសិក្សារដ្ឋ ទំព័រ១ របស់ក្រសួងអប់រំ ឆ្នាំ២០១៨។*

ពេលទទួលទានអាហារ។ លើសពីនេះ វិជ្ជាជីវៈប៉ះពាល់ដល់ប្រភេទនៃការរៀនមួយចំនួន ដូចជាជំនាញភាសា ឬជំនាញចិត្តសាស្ត្រ។ ដើម្បីធ្វើការជាអ្នកអប់រំកុមារ គឺត្រូវឆ្លងកាត់សញ្ញាបត្រដែលទាក់ទងនឹងការអប់រំកុមារតូច និង បានទទួលការបណ្តុះបណ្តាលគ្រប់គ្រាន់ក្នុងការបង្រៀន និងអប់រំកុមារ។

ខាងក្រោម ជាន័យទាក់ទងនឹងមត្តេយ្យសិក្សា៖

**តេមត្តេយ្យសិក្សា ជាអ្វី?**

មត្តេយ្យសិក្សា ជាកន្លែងដែលទទួលកុមារមានអាយុពី៣ឆ្នាំទៅក្រោម៦ឆ្នាំឱ្យចូលរៀនប្រកបដោយសមធម៌។ ក្នុងន័យផ្សេងទៀត មត្តេយ្យ ជាស្ថាប័នសាធារណៈឬឯកជនដែលផ្តល់ការថែទាំ និងការស្តារនីតិសម្បទា ការអប់រំ និងការចិញ្ចឹមបីបាច់ថែរក្សាកុមារ។ មួយវិញទៀត មត្តេយ្យ គឺជាស្ថាប័នអប់រំសាធារណៈរបស់កុមារអាយុមត្តេយ្យសិក្សា ហើយសាលាមត្តេយ្យ ជាប្រភេទស្ថាប័នមួយមាននៅក្នុងប្រទេសភាគច្រើន ហើយជាធម្មតាគឺជាតំណភ្ជាប់ដំបូងបង្អស់នៅក្នុងប្រព័ន្ធអប់រំ។[5] បើតាមវចនានុក្រមអង់គ្លេស Collinsបានសរសេរ៖ សាលាមត្តេយ្យ ជាសាលាក្រៅផ្លូវការមួយប្រភេទសម្រាប់កុមារតូចៗ ហើយពួកគេសិក្សាតាមរយៈការលេងកំសាន្ត (A Kindergarten is an informal kind of school for very young children ,where they learn things by playing. )[6]។

តាមវចនានុក្រមសម្តេចសង្ឃរាជ **ជួន ណាត** យើងរកមិនឃើញពីន័យនៃកន្សោមពាក្យ «សាលាមត្តេយ្យ» ឬ «មត្តេយ្យសិក្សា»នោះទេ តែយើងឃើញមានពាក្យ «មត្តេយ្យកៈ» ឬ «មត្តេយ្យកា»វិញ ដែលមានន័យថា «ទ្រព្យសម្បត្តិឬកេរមរតកខាងមាតា»។ជាឧទាហរណ៍៖ ស្រែហ្នឹង ជាមត្តេយ្យកៈរបស់ខ្ញុំ ទាំងដីចម្ការក្បែរស្រែនុះ ក៏ជាមត្តេយ្យការបស់ខ្ញុំដែរ។ ដូច្នោះ តាមន័យនៃពាក្យក្នុងវចនានុក្រមខ្មែររបស់សម្តេច ជួន ណាត ដូចមិនជាប់ទាក់ទងនឹងការសិក្សារៀនសូត្រនោះទេ តែជាមរតកដែលម្តាយទុកឱ្យកូនទៅវិញ។[7]

---

[5] ស្រង់ពីគេហទំព័រhttps://hidenshell.ru

[6] ស្រង់ពីគេហទំព័រhttps://www.collinsdictionary.com

[7] វា ហាក់ដូចជាបដិរូបភាសាមួយស្របនឹងពាក្យស្លោកខ្មែរតែងតែដឹងលឺគ្រប់គ្នាថា«វិជ្ជា ជាទ្រព្យដ៏ប្រសើរ» ដែលមាតាបិតាសន្សំទុកឱ្យកូនតាមរយៈចំណេះដឹងដោយបញ្ជូនកូនទៅសាលា។

ទោះបីមានការលើកឡើងមានន័យផ្សេងៗគ្នាឬស្រដៀងគ្នាយ៉ាងណាក៏ដោយ ក៏ដំណូចន័យសំខាន់គឺ ផ្តោតលើការយកចិត្តទុកដាក់លើកុមារដែលត្រូវទទួលការថ្នាក់ថ្នម ការសិក្សា ការអប់រំ ដើម្បីឆ្លើយតបនឹងការលូតលាស់ឥតឈប់ឈររបស់ពួកគាត់ទាំងរាងកាយ និងបញ្ញាស្មារតី មុនចូលបឋមសិក្សា។

## ខ. ប្រវត្តមត្តេយ្យសិក្សា

នៅលើពិភពលោក យើងសង្កេតឃើញថា ប្រទេសធំៗច្រើនយកចិត្តទុកដាក់លើធនធានកុមារតាំងពីយូរយារមកហើយ ដោយមានមត្តេយ្យសិក្សាតាំងពីដើម។ ជាក់ស្តែង លោក ហ្វ្រេដរីក ហ្វ្រឺប៊ែល **(Friedrich Froebel)** ជនជាតិអាឡឺម៉ង់ បានបើកសាលាមត្តេយ្យដំបូងនៅប្លែងឃិនប៊ឹក (Blankenburg) ប្រទេសអាឡឺម៉ង់នៅឆ្នាំ១៨៣៧។ អំឡុងទសវត្សឆ្នាំ១៨៣០ និង១៨៤០ គាត់បានអភិវឌ្ឍនូវចក្ខុវិស័យរបស់គាត់សម្រាប់មត្តេយ្យសិក្សាដោយផ្អែកលើគតិបណ្ឌិតដែលជាគំនិតល្អៗរបស់ទស្សនវិទូបារាំងឈ្មោះ ហ្សង់ ហ្សាក់ រូស្សូ **(Jean-Jacques Rousseau)** ហើយក្រោយមកយកតាមអ្នកអប់រំជនជាតិស្វីសឈ្មោះ ចូហាន់ ហេនរីកណា ពេស្តាឡូហ្ស៊ី **(Johann Heinrich Pestalozzi)** ( Friedrich Froebel, a German educator, opened the first kindergarten in Blankenburg, Germany, in 1837. During the 1830s and 1840's he developed his vision for kindergarten based on the ideas of the French philosopher Jean-Jacques Rousseau and the later Swiss educator Johann Heinrich Pestalozzi.)[8]

នៅប្រទេសកម្ពុជា ការសិក្សាកើតមានឡើងតាំងពីសម័យព្រេងនាយ។ ប៉ុន្តែ កាលពីដើមឡើយ ការសិក្សានេះ មានតែត្រកូលស្តេចប៉ុណ្ណោះ។ ក្រោយមកទៀត ពិសេសនៅសតវត្សរ៍ទី១៩ ការសិក្សាចាប់ផ្តើមចម្រើនឡើង សាស្ត្រាច្បាប់ សាស្ត្រាល្បែង សាស្ត្រាទេសន៍ កើតឡើងច្រើន។នៅឆ្នាំ១៩១១ ព្រះមហាក្សត្របានចេញព្រះរាជប្រកាសមួយដោយតម្រូវឱ្យមាតាបិតា មានកាតព្វកិច្ចបញ្ជូនកូនចៅរបស់ខ្លួនដែលមានអាយុចាប់ពី៨ឆ្នាំឱ្យទៅសិក្សានៅតាមវត្តអារាម។[9] ក្រោយមក គេបានបែងចែកកម្រិតនិងថ្នាក់ ពិសេសនៅបឋមសិក្សាជាន់ដំបូង ចែកជា៣ថ្នាក់ គឺ

[8] ស្រង់ពី៖https://www.redleafpress.org

[9] ស្រង់ពីអត្ថបទ«ការអប់រំនិងការអភិវឌ្ឍនៅកម្ពុជា» របស់បណ្ឌិត កង់ ឌិម ការផ្សាយរបស់រាជបណ្ឌិត្យសភាកម្ពុជា ឆ្នាំ២០២០។

ថ្នាក់កុមារដ្ឋាន ថ្នាក់បរិវច្ឆណដ្ឋាន និងថ្នាក់អាទិកដ្ឋាន។តាមចំណុចនេះ យើងសង្កេតឃើញថា កម្ពុជា មិនទាន់លេចរូបរាងមត្តេយ្យសិក្សានោះទេ។ ដោយកម្ពុជា បានជួបប្រទះសង្គ្រាមជាច្រើនឆ្នាំ ការអប់រំ ការសិក្សាតាមសាលារៀន ក៏មានការរអាក់រអួលដែរ តែក្រោយមក ឆ្នាំ១៩៧៩ វិស័យសិក្សាធិការ ក៏បានដំណើរការឡើងវិញ។ មត្តេយសិក្សា ក៏លេចរូបរាងឡើងដែរ ពោលគឺមត្តេយ្យសិក្សានៅឆ្នាំ១៩៧៩- ១៩៨០ កើនពី៩៦ដល់១៨៩៥ នៅឆ្នាំ២០០៩-២០១០និងរហូតដល់៣១៨៤ នៅឆ្នាំ២០១៣-២០១៤។[10] ក្រៅពីកំណើននេះ ការបណ្តុះបណ្តុះគ្រូមត្តេយ្យ ក៏មានហូរហែរ មានទាំងវគ្គវែងវគ្គខ្លី ។ ជាក់ស្តែង នៅឆ្នាំ១៩៩៤ ក្រសួងអប់រំ បានបន្តផែនការបណ្តុះបណ្តាលក្នុង១ឆ្នាំ បណ្តុះបណ្តាលគ្រូបឋមសិក្សាចំនួន១ ០០០នាក់ ដោយក្នុងនោះមានគ្រូមត្តេយ្យសិក្សា៥០នាក់។[11]

ជាបន្តបន្ទាប់ មត្តេយ្យសិក្សានៅកម្ពុជា បានរីកចម្រើនគួរឱ្យកត់សម្គាល់ ពិសេសបច្ចុប្បន្ន សាលាមត្តេយ្យរីកព្រោងព្រាត មានទាំងសាលាមត្តេយ្យរដ្ឋ និងឯកជន។ មិនតែប៉ុណ្ណោះ មត្តេយ្យសិក្សា មានសេវាដូចជាមត្តេយ្យសិក្សាសហគមន៍ មត្តេយ្យសិក្សារដ្ឋ មត្តេយ្យសិក្សាឯកជន និងកម្មវិធីអប់រំកុមារតូចតាមផ្ទះ។

## ៣.កម្មវិធីសិក្សាមត្តេយ្យសិក្សា

កម្មវិធីសិក្សា ជាមុខវិជ្ជាសិក្សាទាំងឡាយដែលបានផ្តល់ឱ្យដោយស្ថាប័នអប់រំណាមួយ។ យោងតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ត្រង់មាត្រា៦៧ចែងៈ រដ្ឋនឹងអនុម័តកម្មវិធីអប់រំ «យោងតាមគោលការណ៍គរុកោសល្យទំនើបរួមទាំងបច្ចេកវិទ្យា និងភាសាបរទេស» ព្រមទាំងរដ្ឋគ្រប់គ្រងសាលារៀនសាធារណៈនិងឯកជន និងថ្នាក់រៀននៅគ្រប់កម្រិត។ទាក់ទិនចំណុចនេះ ក្រសួងអប់រំដែលជាសេនាធិការរបស់រាជរដ្ឋាភិបាល បានដាក់ចេញនូវគោលការណ៍ជាច្រើន រួមទាំងចងក្រងជាសៀវភៅជាច្រើនដើម្បីកំណត់ការអនុវត្ត អភិវឌ្ឍកម្មវិធីសិក្សា។

ការអភិវឌ្ឍកម្មវិធីសិក្សាលម្អិតសម្រាប់មត្តេយ្យសិក្សា គឺការចាំបាច់ ដើម្បីផ្តល់លទ្ធភាពឱ្យកុមារទទួលបានពេញលេញនូវសុខុមាលភាពរាងកាយ និងផ្លូវចិត្ត

10

11 សម្រួលសំណេរចេញពីសៀវភៅប្រវត្តិក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ១៩៩៤។

ស្មារតីសាមគ្គីភាព ភាពម្ចាស់ការ ការទទួលខុសត្រូវ សមត្ថភាពពិចារណា ការដោះស្រាយបញ្ហា បំណិនអន្តរបុគ្គល និងសង្គម ស្មារតីស្រឡាញ់បរិស្ថាន និងការចូលរួមរបស់កុមារ។[12]

កម្មវិធីសិក្សាមត្តេយ្យ មានលក្ខណៈ ផ្សេងៗគ្នាតាមសាលា ឬតាមបរិយាកាសសិក្សា។

## តើកម្មវិធីសិក្សាថ្នាក់មត្តេយ្យ ត្រូវបង្កើតឡើងយ៉ាងដូចម្តេច?

សាលាមត្តេយ្យភាគច្រើនមានគោលដៅ និងទស្សនវិជ្ជាដែលគ្រូបង្រៀនម្នាក់ៗត្រូវតែប្រកាន់ខ្ជាប់។ ក្នុងករណីមួយចំនួនគ្រូបង្រៀនធ្វើតាមការណែនាំទូទៅទាំងនោះដោយមិនផ្លូវការ។ ក្នុងករណីជាច្រើនទោះជាយ៉ាងណាគ្រូបង្រៀនត្រូវតែបំពេញផែនការមេរៀននិងការធ្វើចំណាត់ថ្នាក់សម្រាប់វាយតម្លៃការរីកចម្រើនរបស់សិស្ស។

សិក្ខាសាលាថ្នាក់មត្តេយ្យគិតអំពីរយៈពេលនៃថ្ងៃចូលរៀន។ សាលារៀនមត្តេយ្យជាច្រើនមានរយៈពេលតែពីរបីម៉ោងក្នុងមួយថ្ងៃខណៈពេលដែលកុមារដទៃទៀត (ជាពិសេសនៅក្នុងសាលារៀនសាធារណៈ) មានរយៈពេលយូរ។ មនុស្សខ្លះអាចរត់បានយូរជាងថ្ងៃធម្មតាដើម្បីគ្របដណ្តប់រាល់ម៉ោងធ្វើការរបស់មាតាឬបិតា។ ក្នុងកំឡុងពេលណាមួយដែលបានផ្តល់ឱ្យ, សាលាមត្តេយ្យទំនងជានឹងចូលរួមក្នុងៈ

- សកម្មភាពដាក់លាក់ដូចជាពេលវេលារង្វង់ម៉ោងបទចម្រៀងពេលវេលាប្រតិទិនពេលវេលាលេងល្បែងពេលវេលាពេលវេលារឿងសិប្បកម្មជាដើម។
- រយៈពេលអន្តរកាល ដែលមានរវាងសកម្មភាព (ការរៀនពីរបៀបដើរនៅក្នុងបន្ទាត់ជាមួយមិត្តភក្តិរៀនរបៀបសម្អាតប្រដាប់ប្រដាក្មេងលេងនិងសម្ភារៈជាដើម)
- សកម្មភាពពិសេសមិនចាំបាច់ត្រូវបង្រៀនដោយគ្រូថ្នាក់មត្តេយ្យបឋមទេប៉ុន្តែជាគ្រូបង្រៀនពិសេសដូចជាសិល្បៈតន្ត្រីតន្ត្រី និងបណ្តុះបណ្តាល
- កម្មវិធីសិក្សាថ្នាក់មត្តេយ្យអាចរួមបញ្ចូលកិច្ចការផ្ទះដែលផ្តល់ឱ្យកុមារដើម្បីពង្រឹង

ស្រង់ពីអត្ថបទ«ការអប់រំនិងការអភិវឌ្ឍនៅកម្ពុជា»របស់បណ្ឌិត កង ឱម ការផ្សាយរបស់រាជបណ្ឌិត្យសភាកម្ពុជា ឆ្នាំ២០២០

[12] ស្រង់ពីសៀវភៅកម្មវិធីសិក្សាលម្អិតសម្រាប់មត្តេយ្យសិក្សារដ្ឋរបស់ក្រសួងអប់រំ ឆ្នាំ២០១៨

នូវអ្វីដែលបានរៀននៅក្នុងថ្នាក់រៀនថ្នាក់មត្តេយ្យ

- ការធ្វើដំណើរតាមទីលានដែលត្រូវបានបង្កើតឡើងដើម្បីលើកកម្ពស់មេរៀន - ឧទាហរណ៍ការធ្វើដំណើរទៅកាន់ការិយាល័យប្រៃសណីយ៍ដើម្បីរៀនអំពីសំបុត្រឬការធ្វើដំណើរទៅកាន់ហាងលក់គ្រឿងទេសដើម្បីស្វែងយល់អំពីការជ្រើសរើសអាហារដែលមានសុខភាពល្អ។

- វាគ្មិនពិសេសដែលត្រូវបានគេយកទៅផ្តល់ព័ត៌មានលំអិតបន្ថែមលើមេរៀនមួយ (ឧទាហរណ៍៖ មន្ត្រីប៉ូលីសនិយាយអំពីសុវត្ថិភាពឬពេទ្យធ្មេញ ដើម្បីនិយាយអំពីការថែរក្សាធ្មេញ)

ការលេងគឺមានច្រើនជាងកុមារដែលសប្បាយ។ លេងជាពិសេសនៅពេលដែលវាទាក់ទងនឹងការប្រាស្រ័យទាក់ទងជាមួយកុមារដទៃទៀតបង្រៀនក្មេងៗអំពីរបៀប៖

- បង្កើតមិត្ត
- ផ្លាស់វេន
- រៀនពីរបៀបសហការ
- ព្យាយាមវិធីផ្សេងគ្នានៃការដោះស្រាយបញ្ហា
- ប្រើការស្រមើលស្រមៃរបស់ពួកគេ
- គិតច្នៃប្រឌិត

ប្រភេទផ្សេងៗគ្នានៃការលេងរួមទាំង រចនាសម្ព័ន្ធ និង មិនមានរចនាសម្ព័ន្ធ អនុញ្ញាតឱ្យកុមារអាចអនុវត្តជំនាញខុសៗគ្នាតាមរបៀបផ្សេងៗ (រូបទី១)។



***រូបទី១៖ សកម្មភាពនៃការលេងរបស់កុមារមត្តេយ្យ***

ក្នុងការរៀបចំកម្មវិធីសិក្សាថ្នាក់មត្តេយ្យបានធ្វើការកែសម្រួលសម្ភារៈ និងវិធីសាស្ត្រដើម្បីដាក់មូលដ្ឋានគ្រឹះនៃការអប់រំ លំនាំតាមការអប់រំលំដាប់ពិភពលោកជាមួយនឹងការអភិវឌ្ឍដែលគ្មានដែនកំណត់។ នៅដំណាក់កាលដំបូងនៃការអប់រំ សិស្សរៀនពី ប្រធានបទសំខាន់បី គឺ ការរាប់លេខ ការប្រៀបធៀបវត្ថុ និងការ

សរសេរលេខជាពាក្យ។ បន្ថែមនូវការសិក្សាភាសា គឺមានប្រធានបទទាក់ទងនឹងវិទ្យាសាស្ត្រ ពិភពលោក និង អប់រំកាយ។ សិស្សទទួលយកចំណេះដឹងនេះដោយសប្បាយរីករាយ តាមរយៈបទចម្រៀង ល្បែងកំសាន្ត និងសកម្មភាពដែលផ្តល់នូវតម្ងាភាព និងអនុវត្តសកម្មភាពដែលមានទំនាក់ទំនងជាមួយគោលដៅមេរៀន។ ដូច្នេះមិនត្រឹមតែសិស្សអាចចាប់យកចំណេះដឹងមូលដ្ឋាននោះទេ ពួកគេក៏បានភ្ជាប់ការសិក្សាជាមួយភាពសប្បាយរីករាយផងដែរ។

ចំពោះមត្តេយ្យសិក្សារដ្ឋ គឺកុមារដែលមានអាយុពី៣ឆ្នាំដល់ក្រោម៦ឆ្នាំ ហើយត្រូវបែងចែកជាកម្រិតថ្នាក់៖

- កុមារដែលមានអាយុ៣ឆ្នាំ៖ រៀនកម្រិតទាប
- កុមារដែលមានអាយុ៤ឆ្នាំ៖ រៀនកម្រិតមធ្យម
- កុមារដែលមានអាយុ៥ឆ្នាំ៖ រៀនកម្រិតខ្ពស់

រីឯមត្តេយ្យឯកជន គឺកម្រិតថ្នាក់អាស្រ័យលើគោលការណ៍ឬបែបបទសាលាផ្សេងៗគ្នា។

## ៤. សារសំខាន់នៃការសិក្សាថ្នាក់មត្តេយ្យ

មត្តេយ្យសិក្សា ត្រូវលើកទឹកចិត្តនិងផ្តល់តម្លៃទៅលើភាពស្មើចសរសើរនិងភាពរីករាយនៃសម្រស់ជីវិតតាមរយៈភាពកក់ក្តៅនិងសោភណភាពថ្នាក់រៀន សម្ភារៈលេង សិល្បៈ (រូបទី២) និងបរិស្ថានធម្មជាតិទាំងក្នុងនិងក្រៅថ្នាក់។



រូបទី២៖ ការរៀនរាំរបស់សិស្សមត្តេយ្យធនធានក្រុងតាខ្មៅ

បរិស្ថានដែលពោរពេញទៅដោយភាពកក់ក្ដៅនិងការស្វាគមន៍រួមជាមួយនឹងទម្លាប់ប្រចាំថ្ងៃនិងសប្ដាហ៍ដូចជា ការដុតនំ ការចម្អិនម្ហូប ការផាត់ពណ៌ ការងាររហត្ថកម្ម ការលេងទឹក និងការរុករក ការលេងល្បែង ការលេងនៅខាងក្រៅថ្នាក់ និងការសម្អាតជាកត្តាជម្រុញការលូតលាស់របស់ក្មេងៗទាំងផ្នែករាងកាយ និងប្រាជ្ញាស្មារតី។ តាមរយៈការលេងសកម្មភាពជួបជុំ និងការនិទានរឿងជាពីរភាសា កិច្ចការដែលមានគោលបំណងច្បាស់លាស់ និងការសហការ ក្មេងៗរៀនពីភាពផ្សេងៗគ្នានៃភាសា គណិតវិទ្យា ជំនាញសង្គម និងការអនុវត្តជាក់ស្ដែង។

## ជំនាញភាសា

- ស្ដាប់និងធ្វើតាមការណែនាំងាយៗ
- ស្ដាប់អ្នកដទៃនិងរង់ចាំវេនរបស់ខ្លួនក្នុងការនិយាយ
- រៀននិងអនុវត្តវាក្យសព្ទតាមរយៈសកម្មភាពប្រចាំថ្ងៃ
- សម្គាល់សម្លេងព្យញ្ជនៈតាមរយៈការស្ដាប់និងការនិយាយ
- ធ្វើត្រាប់តាមការបញ្ចេញសម្លេងនៃពាក្យទូទៅនៃភាសាខ្មែរនិងអង់គ្លេស
- បង្កើតឈ្មោះពេញលេញ
- សូត្រកំណាព្យ ច្រៀងចម្រៀង និងចូលរួមក្នុងការធ្វើចលនា
- ប្រាប់ពីគំនិតនិងតម្រូវការ

## ជំនាញគណិតវិទ្យា

- ស្គាល់និងយល់លេខនិងសារៈសំខាន់របស់វាក្នុងជីវិតប្រចាំថ្ងៃ
- រាប់លេខដើម្បីចូលរួមសកម្មភាពអនុវត្តជាក់ស្ដែង
- បែងចែកវត្ថុទៅតាមក្រុម
- សម្គាល់លេខសរសេរ
- ដឹងពីលំនាំនិងជំហានក្នុងការធ្វើកិច្ចការងាយៗ

## ជំនាញសង្គមនិងសតិអារម្មណ៍

- បង្ហាញការគោរព ចិត្តអាណិតអាសូរ និងការយកចិត្តទុកដាក់លើអ្នកដទៃ
- បង្ហាញភាពឯករាជ្យក្នុងទម្លាប់ប្រចាំថ្ងៃ
- សហការជាមួយអ្នកដទៃក្នុងការបំពេញការងារ
- យល់និងមានអាកប្បកិរិយាល្អ
- អនុវត្តការគ្រប់គ្រងខ្លួនឯង
- បង្ហាញការជឿជាក់លើខ្លួនឯងនិងមានសមត្ថភាពក្នុងការបំពេញកិច្ចការ
- បង្ហាញការអរគុណនិងការថែរក្សាបរិស្ថានថ្នាក់រៀន

**បំណិនជីវិតនិងកាយសម្បទា**

- ធ្វើតាមលំនាំនិងទម្លាប់ប្រចាំថ្ងៃរួមជាមួយនឹងការរៀបចំនិងការសម្អាត
- អនុវត្តការមានអនាម័យល្អ
- ជួយរៀបចំអាហារសម្រន់
- ជួយសម្អាតប្រចាំថ្ងៃ
- អភិវឌ្ឍការសហការរវាងភ្នែកនិងដៃតាមរយៈការងារហត្ថកម្មនិងសិប្បកម្មដែលមានភាពលម្អិត
- អភិវឌ្ឍការធ្វើការរួមគ្នានិងការរក្សាលំនឹងរាងកាយតាមរយៈការងារហត្ថកម្មនិងសិប្បកម្ម។

បើតាមគេហទំព័រខេអេកស៊ើចផ្សាយថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៨បានបង្ហាញថាការចូលរៀននៅមត្តេយ្យសិក្សាមានសារៈប្រយោជន៍ចំពោះកុមារដូចជា៖

- ធ្វើឱ្យកុមារមានភាពក្លាហានឈ្លាសវៃ
- ចេះស្តាប់ដំបូន្មានលោកគ្រូ អ្នកគ្រូដែលនិយាយពីការអប់រំ
- រស់នៅមានសុជីវធម៌
- ចេះបន្សាំខ្លួនជាមួយមិត្តភក្តិនិងលោកគ្រូ អ្នកគ្រូ
- ធ្វើឱ្យកុមារមិនងាយបោះបង់ចោលការសិក្សា[13](រូបទី៣)



រូបទី៣៖ កុមារមត្តេយ្យទទួលវិញ្ញាបនបត្របញ្ចាក់ការសិក្សាដោយស្នាមញញឹម

បន្ថែមពីនេះ យោងតាមប្រសាសន៍ **លោក រស់ សុវាចា** អ្នកនាំពាក្យក្រសួងអប់រំថ្លែងកន្លងមកថា ដំណើរការអប់រំកុមារតូចនៅតែផ្តោតសំខាន់លើការអភិវឌ្ឍផ្នែកទាំង៥ រួមមាន សុខភាពរាងកាយ ភាសា បញ្ញា ការគិតសង្គម អារម្មណ៍ ការអភិវឌ្ឍសីលធម៌និងវប្បធម៌ ដោយផ្អែកលើមុខវិជ្ជាចិត្តចលភាព វិទ្យាសាស្ត្រសិក្សាសង្គម បុរេគណិតវិទ្យា និង

[13] ស្រង់ពី៖https://www.khsearch.com

ភាសាខ្មែរ ដើម្បីសម្រេចបានលទ្ធផលសិក្សារបស់កុមារស្របតាមគោលបំណងនៃកម្មវិធីសិក្សាលម្អិតសម្រាប់មត្តេយ្យសិក្សាឈានឆ្ពោះទៅសម្រេចបានចំណុចដៅក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០១៩-២០២៣។[14]

## ៥.ភាពខុសគ្នារវាងអ្នកអត់បានរៀន និងអ្នកបានរៀនមត្តេយ្យសិក្សា

ការសិក្សាអ្វីក៏ដោយ សុទ្ធតែមានប្រយោជន៍របស់វា។ មាតាបិតាឬអ្នកអាណាព្យាបាលមួយចំនួន មើលរំលងការសិក្សានៅថ្នាក់មត្តេយ្យ ពីព្រោះពួកគាត់មិនបានបញ្ជូនកូនចៅទៅចូលរៀនមត្តេយ្យសិក្សាដោយឱ្យកូនចូលរៀនថ្នាក់ទី១តែម្តង។ទោះបី មត្តេយ្យសិក្សា មិនមែនជាភូមិសិក្សានិងប្រភេទសិក្សាដែលមានចែកក្នុងច្បាប់ស្តីពីការអប់រំក៏ដោយ ក៏មត្តេយ្យសិក្សានៅតែមានសារៈប្រយោជន៍ខ្លាំង ចំពោះប្អូនៗកុមារដែរ។

សិស្សដែលបានរៀនចប់ថ្នាក់មត្តេយ្យ គឺជាក្តីប្រាថ្នាចង់បានយកទៅបង្រៀនរបស់គ្រូដែលបង្រៀនថ្នាក់ទី១ ។[15]ការអប់រំកុមារតូចត្រូវបានរាជរដ្ឋាភិបាលកម្ពុជាទទួលស្គាល់ថាជាមធ្យោបាយចាំបាច់ក្នុងការបង្កើនការចូលរៀននៅថ្នាក់បឋមសិក្សា ហើយជាមធ្យោបាយក្នុងការកសាងមូលដ្ឋានអប់រំ ដែលនឹងជួយឱ្យលទ្ធផលសិក្សារបស់កុមារមានភាពប្រសើរឡើង ហើយកាត់បន្ថយការបោះបង់ការសិក្សា។[16]

ដូចនេះ កុមារដែលមិនបានចូលរៀននៅមត្តេយ្យសិក្សានិងកុមារដែលបានសិក្សានៅថ្នាក់មត្តេយ្យ មានភាពខុសគ្នា ដោយកុមារមិនបានសិក្សាថ្នាក់មត្តេយ្យ បាត់បង់នូវភាពស៊ាំនឹងមជ្ឈដ្ឋានអប់រំដែលជាពិភពខាងក្រៅបន្ទាប់ពីផ្ទះសម្បែងរបស់ពួកគេ។ការយល់ដឹងនានាសម្រាប់មត្តេយ្យសិក្សា ក៏ពួកគេមិនបានទទួលដូចក្មេងដែលចូលរៀនមត្តេយ្យដែរ។

## សន្និដ្ឋាន

ការធ្វើអ្វីក៏ដោយ ទាមទារឱ្យមានគ្រឹះរឹងមាំដែលជាមូលដ្ឋានត្រឹមត្រូវក្នុងការបង្កើតអ្វីៗផ្សេងទៀត។ការសង់ផ្ទះ ត្រូវគ្រឹះក្រោមរឹងមាំទើបផ្ទះនោះមានគុណភាពល្អនិងមាំទាំ។ ចំពោះការអប់រំ ក៏មិនខុសពីអ្វីដែលបានលើកឡើងមកនេះដែរ ពោលគឺមត្តេយ្យសិក្សាជាបឋមគ្រឹះនៃការអប់រំ។ បើកុមារតូចមិនបាន

[14] ស្រង់ពីគេហទំព័រកាសែតកម្ពុជាថ្មី ចុះផ្សាយថ្ងៃទី៦ មករា ឆ្នាំ២០២២។

[15] ស្រង់ពី៖https://www.worldbank.org

[16] ស្រង់ពី៖https://www.wvi.org

ទទួលការអប់រំថ្នាក់មត្តេយ្យ នោះពួកគេនឹងប្រឈមនឹងបញ្ហាច្រើនក្នុងការបន្តការសិក្សានៅកម្រិតបឋមសិក្សា ក៏ដូចជាភូមិសិក្សាផ្សេងទៀត។ តែបើពួកគេ បានសិក្សាមត្តេយ្យ កុមារតូចនឹងទទួលអត្ថប្រយោជន៍ស្របតាមកម្មវិធីអប់រំកុមារតូចដូចខាងក្រោម៖

1. កាត់បន្ថយយ៉ាងខ្លាំងគួរឲ្យកត់សម្គាល់នូវផលប៉ះពាល់ដែលអាចកើតមាននៃស្ថានភាពបាត់បង់នីតិសម្បទា និងជួយបង្កាការវិវឌ្ឍទៅមុខនៃស្ថានភាពបាត់បង់នីតិសម្បទានៅថ្នាក់វិទ្យាល័យ
2. បង្កើតអត្ថប្រយោជន៍ជាបន្តបន្ទាប់នៅក្នុងផ្នែកលូតលាស់នានាដូចជា៖ ផ្នែករាងកាយ ផ្នែកពុទ្ធិ ផ្នែកពាក្យសម្ដី និងភាសា ផ្នែកចិត្តសង្គម និងការជួយខ្លួនឯង
3. កាត់បន្ថយភាពតានតឹងក្នុងគ្រួសារ ការពឹងផ្អែកលើសង្គម និងការធ្វើស្ថាប័នភាវូបនីយកម្ម និងតម្រូវការសម្រាប់ការដាក់បញ្ចូលទៅក្នុងថ្នាក់ពិសេស នៅពេលកុមារណាម្នាក់គ្រប់អាយុចូលរៀន។

## គន្ថនិទ្ទេស


១. កង ឱម ការអប់រំនិងការអភិវឌ្ឍនៅកម្ពុជា ការផ្សាយរបស់រាជបណ្ឌិត្យសភាកម្ពុជា ២០២០

២. ក្រសួងអប់រំ  កម្មវិធីសិក្សាលម្អិតសម្រាប់មត្តេយ្យសិក្សារដ្ឋ ២០១៨

៣. ក្រសួងអប់រំ ប្រវត្តិក្រសួងអប់រំ  យុវជន និងកីឡា១៩៩៨

៤. ក្រសួងអប់រំ គោលនយោបាយស្តីពីកិច្ចការពារកុមារនៅសាលារៀន ២០១៦

៥. ច្បាប់ស្តីពីការអប់រំ  ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

៦. ជួន ណាត វចនានុក្រមខ្មែរ ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ ១៩៦៧

៧. ប៉ាន់ សំណាង តម្លៃនៃការអប់រំបរិយាបន្ន ការផ្សាយរបស់រាជបណ្ឌិត្យសភាកម្ពុជា ២០២២

៨.រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣


## ប្រភពគេហទំព័រ


- https://www.kampucheathmey.com

-https://www.wvi.org

-https://www.worldbank.org

-https://www.khsearch.com

-https://www.redleafpress.org

-https://hidenshell.ru

-https://www.collinsdictionary.com

-http://www.camlaw.com.kh

# ការអប់រំប្រកបដោយគុណតម្លៃព្រះពុទ្ធសាសនាដល់ព្រះសង្ឃ

*ដោយៈ លោក* **ប៉ាន់ សំណាង**

*មន្ត្រីនាយកដ្ឋានវិទ្យាសាស្ត្រអប់រំ*

*វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម*

*នៃរាជបណ្ឌិត្យសភាកម្ពុជា*

## ១. សេចក្តីផ្តើម

*តាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលជាច្បាប់កំពូលរបស់ជាតិ បានចែងថា ព្រះពុទ្ធសាសនា ជាសាសនារបស់រដ្ឋ។[1] ព្រះសង្ឃ ជាសាវ័ក[2]នៃសាសនាព្រះពុទ្ធដែលដឹកនាំ អប់រំ ប្រៀនប្រដៅពុទ្ធបរិស័ទតាមពុទ្ធបញ្ញត្តិ។ បើនិយាយពីពាក្យថា«សង្ឃ»គឺជាភាសាសំស្ក្រឹតដែលមានអត្ថន័យថា «សហគមន៍» ដែលត្រូវបានប្រើប្រាស់ជាចម្បងសម្តៅទៅរកសហគមន៍អ្នកបួសនៅក្នុងសាសនាព្រះពុទ្ធ ឬត្រូវបានគេហៅម្យ៉ាងទៀតថាជា ភិក្ខុឬភិក្ខុនី[3] ព្រះសង្ឃ និងដូនជីជាដើម។[4]*

*នៅក្នុងសង្គមខ្មែរ ជនជាតិខ្មែរបាន និងកំពុងគោរពព្រះពុទ្ធសាសនាយ៉ាងខ្ជាប់ខ្ជួន។ តាំងពីអតីតកាលក៏ដូចជាបច្ចុប្បន្ន ទាំងថ្នាក់ដឹកនាំ ទាំងប្រជាពលរដ្ឋ ពិសេសរាជវង្ស បានបូជានិងគោរពសក្ការដល់ព្រះត្រៃរតន៍ ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃតាមប្រពៃណីរហូតមក។ ទន្ទឹមនឹងនេះ ព្រះសង្ឃ គឺជាសាវ័កដ៏សំខាន់បំផុតក្នុងការប្រតិបត្តិនៅក្នុងសាសនា ហើយព្រះអង្គក៏ខំព្យាយាមសិក្សារៀនសូត្រ អប់រំហ្វឹកហាត់យ៉ាងហ្មត់ចត់តាមពុទ្ធឱវាទ ក៏ដូចជាវិន័យក្នុងព្រះពុទ្ធសាសនា។ អ្វីៗដែលភិក្ខុសាវ័កត្រូវបំពេញក្នុងការអប់រំផ្សព្វផ្សាយនូវគុណ*

---

[1] *ចែងនៅមាត្រា៤៣ ច្បាប់រដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ ១៩៩៣*

[2] *សាវ័ក ប្រែថា អ្នកស្តាប់ឱវាទ*

[3] *ពីដើម មានស្ត្រីបានបួសក្នុងសាសនាដែរ*

[4] *ដកស្រង់ពី៖*https://studybuddhism.com

តម្លៃនានានៃព្រះពុទ្ធសាសនា ត្រូវឆ្លើយតបនឹងសង្គមជាក់ស្តែងផងដែរ ទើបឧត្តមកិច្ចនោះ ទទួលបាននូវប្រសិទ្ធភាពនិងប្រសិទ្ធផលខ្ពង់ខ្ពស់។ចំណុចនេះ គឺទាមទារឱ្យព្រះសង្ឃអគ្គសាវ័កមួយក្នុងចំណោមសាវ័កទាំង៤ពួក ខិតខំសិក្សារៀនសូត្រពុទ្ធវិន័យ ចំណេះដឹងទូទៅ ឬពិចារណាពីតថភាព សច្ចភាពសង្គមទាំងឡាយ ។មិនតែប៉ុណ្ណោះ ព្រះអង្គ ក៏ទទួលបាននូវជំនាញអក្សរសាស្ត្រតាមរយៈព្រះផ្នួសដែរ ពីព្រោះព្រះពុទ្ធសាសនា ជាជម្រកដ៏ធំនៃអក្សរសាស្ត្រខ្មែរនៅសម័យដែលយើងមានគ្រោះថ្នាក់ធ្លាក់ដុនដាបក្នុងភ្លើងសង្គ្រាម ដោយសារវត្តអារាមនេះហើយ ជាទីកន្លែងតែមួយគត់ក្នុងការថែរក្សាខឿនវប្បធម៌ជាតិឱ្យបានគង់វង្ស។

នៅក្នុងអត្ថបទស្រាវជ្រាវខ្លីនេះ យើងចង់ឆ្លុះបញ្ចាំងឱ្យឃើញពីគុណតម្លៃនៃព្រះពុទ្ធសាសនាដែលព្រះសង្ឃខ្មែរទទួលបានដោយផ្សារភ្ជាប់ជីវភាពជាក់ស្តែងនៅក្នុងសង្គម។ព័ត៌មានក៏ដូចជាទិន្នន័យដែលយើងទទួលបាន គឺតាមរយៈការសម្ភាសផ្ទាល់ជាមួយព្រះសង្ឃ ពីការអង្កេត ពីគេហទំព័រនានា ហើយនិងពីឯកសារផ្សេងៗ ។

## ២. និយមន័យ

ទាក់ទិននឹងប្រធានបទនេះ ពាក្យគន្លឹះដែលគួរស្វែងយល់មានដូចខាងក្រោមៈ

### ក. អប់រំ

អប់រំ [5]: (កិ.) អប់ បង្អប់ ផ្សែង ឬ បង្អប់ចំហាយ ។ ព. ប្រ. ហាត់ ចិត្ត, បង្វឹក ចិត្ត; ដួសដុល ចំពោះវិជ្ជា ឬ កិរិយា មារយាទ, ហ្វឹកហាត់ឱ្យស្ទាត់ជំនាញជាងមុន, កែឲ្យបានល្អប្រពៃជាង មុនជាលំដាប់; ខំប្រឹងបំពេញ ឧបនិស្ស័យឱ្យ បរិបូណ៌, ខំកសាង សន្សំបុណ្យ កុសល រក្សា ទុកពុំឱ្យមានហ្មង, មិនឱ្យមានថ្នាំងថ្នាក់; បន្ទំ បារមី : ព្រះបរមពោធិសត្វបានអប់រំបន្ទុំបារមី អស់កាលយូរអង្វែង។ ន. ឈ្មោះក្រសួងរដ្ឋ មន្ត្រីកាន់កាប់មុខការផ្នែកខាងការអប់រំ, ការសិក្សា : ក្រសួងអប់រំជាតិ (ពីដើម ហៅ: ក្រសួង សិក្សាធិការ)។ ពាក្យ«អប់រំ»ក៏ត្រូវនឹងពាក្យអង់គ្លេស «Educate» ដែលមានន័យថាផ្តល់ការណែនាំខាងបញ្ញា សីលធម៌ និងសង្គមដល់ នរណាម្នាក់ ជាធម្មតានៅសាលា ឬសាកលវិទ្យាល័យ។"នាងបានទទួលការអប់រំ

[5] ស្រង់ពីវចនានុក្រមសម្តេចសង្ឃរាជ ជួន ណាត

នៅសាលាបឋមសិក្សា" ( give intellectual, moral, and social instruction to (someone), typically at a school or university." : she was educated at a boarding school")[6]។

**ខ. សង្ឃ**

ខាងក្រោមជាន័យរបស់ពាក្យ«សង្ឃ»និងកន្សោមពាក្យដទៃទៀតដែលមានពាក្យ«សង្ឃ» ជាធាតុបង្គោល(Main Element)៖

សង្ឃ[7]: សំ. បា.(ន.) (ប្រើជា សំឃ ក៏បាន (អ. ថ. ស័ង-ឃៈ) ពួក; ប្រជុំ; បន; ហ្វូង។ តាម លទ្ធិពុទ្ធសាសនា សំដៅចំពោះពួកភិក្ខុ តាំងពី ៤ រូបឡើងទៅ : ជំនុំសង្ឃ, របស់សង្ឃ, អាជ្ញាសង្ឃ, សង្ឃព្រមព្រៀងគ្នា។ បើរៀងភ្ជាប់ពីខាងដើមសព្ទដទៃ អ. ថ. សង់ឃៈ, ដូចជា : សង្ឃកតិកា (--កៈ--) ប្ដេជ្ញារបស់សង្ឃ ។ សង្ឃកម្ម ការរបស់សង្ឃដែលប្រជុំគ្នាធ្វើក្នុងសីមា។ សង្ឃករណីយកិច្ច កិច្ចដែលសង្ឃត្រូវធ្វើ (មានការជួសជុល សេនាសនៈជាដើម)។ សង្ឃការី (តាមទម្លាប់ អ. ថ. សង់ខ្រី) អ្នកធ្វើការសង្ឃ; ខ្មែរ ហៅក្រុមអ្នករាជការក្នុងព្រះរាជវាំងមួយក្រុមមានមុខការខាងចាត់ការសង្ឃដែលទាក់ទង ដោយកិច្ចមានព្រះរាជនិមន្ត ជាដើម។ សង្ឃកិច្ច កិច្ចការផ្សេងៗរបស់សង្ឃ។ សង្ឃគតទាន (សង់ឃៈគៈតៈ--) ទានដែលបង្អោនទៅ ចំពោះសង្ឃ គឺទានដែលទាយកប្រគេនចំពោះសង្ឃ(ព. ផ្ទ. បុគ្គលិកទាន)។ សង្ឃគារវតា (--រៈវៈ--) សេចក្ដីគោរពចំពោះសង្ឃ។ សង្ឃគុណ គុណព្រះសង្ឃ គឺវត្តប្រតិបត្តិ ឬសណ្ដាប់ធ្នាប់ល្អវិសេសរបស់ព្រះអរិយសង្ឃ។ សង្ឃដីកា ដីការបស់សង្ឃ; ដីការបស់ភិក្ខុដែលចេញជាផ្លូវរាជការ; សំបុត្រសម្រាប់សាមណេរ ក្នុងសម័យបច្ចុប្បន្ននេះ កាន់ជាសម្គាល់ខ្លួន ទុកដូចជា សំបុត្រឆាយាសម្រាប់ភិក្ខុ (ប្រើតាមសម័យនិយមរបស់ប្រទេស)។ សង្ឃត្ថេរ ឬ--រៈ ភិក្ខុ ដែលជាថេរៈក្នុងជំនុំសង្ឃ។ សង្ឃទាន ទានដែលទាយកប្រគេនចំពោះ សង្ឃ (ព. ផ្ទ. បុគ្គលិក ទាន)។ សង្ឃទាសៈ ឬ សង្ឃទាសី បុរស ឬ ស្ត្រី ដោយប្ដេជ្ញាប្រគល់ ខ្លួនជាអ្នកធ្វើការបម្រើសង្ឃ ហាក់ដូចជា ទាសៈ ឬទាសី។ សង្ឃទូត បម្រើរបស់សង្ឃ, តំណាងសង្ឃ។ សង្ឃនវក (--នៈវៈកៈ ឬ--នៈវក់) ភិក្ខុថ្មី ក្នុងសង្ឃ គឺភិក្ខុដែលទើបនឹងបួស ថ្មីក្នុងជំនុំសង្ឃមួយពួកៗ។ សង្ឃនាយក (--យក់) មហាថេរដែលជា អ្នកដឹកនាំសង្ឃ គឺ ព្រះថេរៈ

---

[6] ស្រង់ពីវចនានុក្រមOxford Language

[7] ស្រង់ពីវចនានុក្រមសម្ដេចសង្ឃរាជ ជួន ណាត

ធំដែលជាអ្នកត្រួតត្រាលើសង្ឃទូទៅក្នុងរដ្ឋមួយៗ។ សង្ឃបញ្ញា ពាក្យបង្គាប់ ឬ ពាក្យផ្ដាំផ្ញើរបស់សង្ឃ។ សង្ឃបរិនាយក (--ប៉ៈរ៉ិនាយក) ព្រះថេរៈ ដែលជាអ្នកត្រួតត្រាលើ សង្ឃមួយពួក ៗ។ សង្ឃបរិភោគ ការប្រើ ប្រាស់របស់ក្នុងអំណាចសង្ឃ (ព. ផ្ទ. បុគ្គល បរិភោគ)។ សង្ឃបាមោក្ខ (-ប៉ា-ម៉ោក) ព្រះ ថេរៈ ដែលជាប្រធានឬជាមេរបស់សង្ឃ, មេ ក្រុមក្នុងវត្តមួយៗ ឬមេគណក្នុងខេត្ត មួយៗ។ សង្ឃបិតា ព្រះមហាថេរដែលទុកដូចជា បិតារបស់សង្ឃ។ សង្ឃបូជា បូជាចំពោះសង្ឃ។ ព្រះសង្ឃប្រកាស ឬព្រះសង្ឃរាជប្រកាស សេចក្ដីប្រកាសរបស់សម្ដេចព្រះសង្ឃនាយក ឬសេចក្ដីប្រកាសរបស់សម្ដេចព្រះសង្ឃរាជ។ សង្ឃប្រណាមការ បង្អោន កាយ វាចា ចិត្ត ថ្វាយ បង្គំ ចំពោះសង្ឃគុណ។ សង្ឃភត្ត ភត្ត ដែលទាយកប្រគេនចំពោះសង្ឃ។ សង្ឃភេទ ការបំបែកសង្ឃ (ដោយពេញតាមលក្ខណៈវិន័យ)។ សង្ឃភេទកៈ ភិក្ខុអ្នកបំបែកសង្ឃ។ សង្ឃមណ្ឌល ជំនុំសង្ឃ; ភិក្ខុសង្ឃ ក្នុង ប្រទេស ឬដែនទីមួយៗ។ សង្ឃមាមកៈ អ្នករាប់អាន សង្ឃថា ជារបស់ខ្លួន (អ្នកប្ដេជ្ញាយកសង្ឃរតនៈ ជាសរណៈ); បើស្ត្រី ជាសង្ឃមាមិកា។ សង្ឃរតនៈ ឬសង្ឃរ័ត្នរតនៈគឺសង្ឃ, សង្ឃ ដែលទុកដូចជា រតនៈ។

សង្ឃរាជ ឬ សង្ឃ រាជា សម្ដេចសង្ឃ។ សង្ឃរាជីការ ប្រេះធា របស់សង្ឃ, ដំណើរមោះមៃរបស់សង្ឃ ។ សង្ឃ វង្ស វង្សរបស់សង្ឃ។ ខ្មែរប្រើពាក្យនេះ ជា សមណស័ក្តិ ទីបាឡាត់ខាងស្ដាំជា ឋានានុក្រម សម្រាប់សម្ដេចព្រះមហាសង្ឃរាជ : ព្រះ បាឡាត់សង្ឃ វង្ស ជាគូគ្នានឹងព្រះបាឡាត់ សង្ឃរក្ខ (បាឡាត់ខាងឆ្វេង)។ សង្ឃសម្មតិ (--ស័ម-ម៉ៈតិ) សន្មតិរបស់សង្ឃ។ សង្ឃសាមគ្គី សេចក្ដីព្រមព្រៀង ឬស្រុះស្រួលរបស់សង្ឃ; សេចក្ដីព្រមព្រៀងរបស់ពួក ក្រុម។ សង្ឃាណត្តិ (បា. សង្ឃ + អាណត្តិ) សេចក្ដីបង្គាប់ ឬ ពាក្យផ្ដាំផ្ញើរបស់សង្ឃ។ សង្ឃានុស្សតិ (បា. សង្ឃ + អនុស្សតិ) សេចក្ដីរឭកដល់សង្ឃគុណ។ សង្ឃុបដ្ឋាក (សង់-ឃុប៉ុត-ឋាក; បា. សង្ឃ + ឧបដ្ឋាក) អ្នកបម្រើ ឬទំនុកបម្រុងសង្ឃ; បើ ស្ត្រី ជាសង្ឃុបដ្ឋាយិកា (បា. សង្ឃ + ឧបដ្ឋាយិកា)។ល។ចំពោះភាសាអង់គ្លេស « សង្ឃ» ត្រូវនឹងពាក្យ «Monk» ដែលមានន័យថា«ជាសមាជិកនៃសហគមន៍សាសនានៃបុរសដែលរស់ដោយការសច្ចាចំពោះភាពខ្វះខាត សេចក្ដីបរិសុទ្ធដោយកាយ វាចា ចិត្ត និងឱវាទ ឬការស្ដាប់បង្គាប់។ ( a member of a religious

community of men typically living under vows of poverty, chastity, and obedience)[8]។

**គ. គុណតម្លៃ**

*ចំពោះពាក្យគុណតម្លៃនេះ យើងសង្កេតឃើញមានការលើកឡើងជាច្រើនដូចខាងក្រោម៖*

- ***គុណតម្លៃ*** *គឺជាជំនឿជាមូលដ្ឋាន និងជាគោលការណ៍សំខាន់ដែលដឹកនាំ ឬជំរុញអាកប្បកិរិយា ឬសកម្មភាព*[9]*។*
- ***គុណតម្លៃ*** *:ការបរិបូណ៌ដោយសេចក្ដីល្អ និងប្រយោជន៍ដែលមិនអាចកាត់*[10] *។*
- ***គុណតម្លៃ*** *គឺជាជំនឿឬឧត្តមគតិដែលមនុស្សវាយតម្លៃស្ថានភាព មនុស្សរឿង សកម្មភាព ឬព្រឹត្តិការណ៍ ផ្សេងៗ។ ពីការវាយតម្លៃនោះ វាត្រូវបានគេសម្រេចចិត្តថាតើមានអ្វីអាក្រក់ ឬល្អចង់បាន ឬមិនចង់បាន។ គុណតម្លៃ មានឥទ្ធិពលលើការសម្រេចចិត្ត និងអាកប្បកិរិយាដែលមនុស្សធ្វើពេញមួយជីវិតរបស់ពួកគេ។ ដូច្នេះពួកគេ ជាគោលការណ៍នៃសកម្មភាព។ ឧទាហរណ៍ប្រសិនបើមនុស្សម្នាក់ឱ្យតម្លៃលើ "មិត្តភាព" ដូច្នេះគាត់មានតម្លៃនៃមិត្តភាព គាត់នឹងសម្រេចចិត្តចំណាយពេលច្រើនជាមួយមិត្តរបស់គាត់ ហើយនឹងផ្ដល់សារៈសំខាន់ចំពោះវា បើប្រៀបធៀបទៅនឹងអ្វីផ្សេងទៀត*[11]*។*
- *បើពិនិត្យទៅលើពាក្យ«**គុណតម្លៃ**» កើតមកពីពាក្យ «គុណ» ដែលមានន័យថា ដំណើរធ្វើឲ្យចម្រើន សភាពបែបបទ សេចក្ដីចម្រើន និង «តម្លៃ» ដែលមានន័យថា អ្វីៗដែលថ្លៃ*[12]*។ តាមន័យនេះ យើងអាចសរុបបានថា គុណតម្លៃ បានដល់ដំណើរចម្រើននូវអ្វីៗដែលថ្លៃ។*

*ជារួមមក ទោះបីមានការយល់ឃើញផ្សេងៗគ្នាក៏ដោយ ក៏គុណតម្លៃមានអត្ថន័យវិជ្ជមាន ហើយមានជាតួរួមដូចគ្នាដែលសម្ដៅលើភាពលើសលប់ដោយការល្អលាស់ដែលជាសេចក្ដីល្អដែរ។*

---

[8] *ស្រង់ពីវចនានុក្រម*Oxford Language

[9] *ស្រង់ពី៖*https://thehrdaily.com.dream

[10] *ស្រង់ពី៖*https://www.sangapac.com

[11] *ស្រង់ពី៖*https://km.warbletoncouncil.org

[12] *ន័យក្នុងវចនានុក្រម ជួន ណាត*

ប្រសិនបើគេនិយាយថា នរណាម្នាក់"មានតម្លៃ" វាមានន័យថាពួកគេមានគុណតម្លៃ ដូចជាការគោរព សុភាពរាបសារ ភាពអត់ធ្មត់ ការតស៊ូ និងភាពស្មោះត្រង់ ឬគេចាត់ទុកថា មានលក្ខណៈវិជ្ជមានក្នុងសង្គម។

## ៣. ព្រះសង្ឃនៅក្នុងព្រះពុទ្ធសាសនា

សព្វថ្ងៃ នៅខណៈពេលដែលព្រះពុទ្ធសាសនា បានរីកសាយភាយទៅកាន់បច្ចិមលោក ពាក្យថាសង្ឃនេះ បានក្លាយទៅជាពាក្យដែលគេប្រើប្រាស់យ៉ាងទូលាយសម្រាប់សហគមន៍អ្នកបដិបត្តិព្រះពុទ្ធសាសនា ឬសូម្បីតែក្រុមអ្នកបដិបត្តិមួយក្រុមតូចនៅតាមមជ្ឈមណ្ឌលព្រះធម៌ ក៏គេរួមគ្នាបង្កើតសហគមន៍សង្ឃឡើងដែរ (រូបទី១)។



រូបទី១៖ សហគមន៍សង្ឃនិមន្តបិណ្ឌបាត

កម្ពុជាជាប្រទេសវ័យចំណាស់នៅតំបន់អាស៊ីអាគ្នេយ៍ ដែលគោរពប្រតិបត្តិព្រះពុទ្ធសាសនា។ ព្រះសង្ឃ បានដើរតួនាទីជាច្រើននៅក្នុងពុទ្ធចក្រ និង អាណាចក្រ។

### ក. សង្ឃប្រវត្តិ៖

បន្ទាប់ពីព្រះសម្មាសម្ពុទ្ធត្រាស់ដឹង ព្រះសូត្រនៃកង់ចក្រព្រះធម៌ ឬព្រះធម្មចក្រ បានពន្យល់ប្រាប់យើងថា ព្រះអង្គបានសម្តែងធម៌ដំបូងរបស់ព្រះអង្គ ពោលគឺអរិយសច្ចៈបួន ទៅកាន់ព្រះភិក្ខុប្រាំរូប។ ភិក្ខុទាំងប្រាំរូបនេះ បានក្លាយជាសាវ័ករបស់ព្រះអង្គ ហើយមួយព្រះអង្គក្នុងចំណោមទាំងប្រាំអង្គគឺ កោណ្ឌញ្ញៈព្រះអង្គបានសម្រេចព្រះអរហន្ត។ កន្លងទៅបានពីរបីថ្ងៃក្រោយមកទៀត ស្របពេលដែលព្រះអង្គសម្តែងអំពីសុញ្ញភាព ឬភាពសូន្យនៃអត្តភាព ឬអនត្តា បញ្ចវគ្គីភិក្ខុទាំងអស់បានសម្រេចនូវព្រះអរហន្ត។ ភិក្ខុទាំងប្រាំអង្គនេះ បានក្លាយជាសមាជិកសង្ឃដំបូងគេបំផុត។ បន្ទាប់មកព្រះពុទ្ធ បានចំណាយពេលវេលាដែលនៅសេសសល់ទាំងប៉ុន្មានរបស់ព្រះអង្គ ប្រហែលជាសែសិបប្រាំព្រះវស្សា ដើម្បីសម្តែងព្រះធម៌ដែលព្រះអង្គបានត្រាស់ ស្របពេលដែលសាវ័ករបស់ព្រះអង្គក៏បានធ្វើដំណើរនិមន្តទៅកាន់ភូមិឋាននានា នៅពាសពេញភាគខាងជើងនៃ

ប្រទេសឥណ្ឌា ដើម្បីផ្សព្វផ្សាយនូវព្រះធម៌របស់ព្រះអង្គ។ មិនយូរមិនឆាប់ ព្រះសម្មាសម្ពុទ្ធ បានទាក់ទាញនូវបរិស័ទជាច្រើនដែលមកពីគ្រប់ស្រទាប់វណ្ណៈទាំងអស់៖ មានទាំងគ្រូសាសនា ទាំងមហាក្សត្រ និងមហាក្សត្រិយានី កសិករ និងអ្នកសម្លាប់សត្វជាដើម ។ល។ តែភាគច្រើននៃសាវ័ករបស់ព្រះអង្គនៅសម័យនោះ ពួកគេមិនចង់បោះបង់ចោលនូវជីវិតលោកិយ៍របស់គេទេ តែបើគេប្រាថ្នាលាចាកជីវិតលោកិយ៍របស់គេ ដើម្បីចូលរួមជាមួយសហគមន៍សង្ឃនោះ នោះព្រះអង្គតែងទទួលស្វាគមន៍ពួកគេជានិច្ច។ ពុទ្ធបរិស័ទដែលបន្តរស់នៅ នៅក្នុងភេទជាគ្រហស្ថ ពួកគេជួយទំនុកបម្រុងជាអាហារ និងស្បង់ជីវរដល់សង្ឃ។

ពេលវេលាចេះតែកន្លងផុតទៅ មានមនុស្សជាច្រើនបានមកចូលរួមស្តាប់និងបដិបត្តិជាមួយព្រះអង្គ ប្រការនេះបានសេចក្តីថា វាគឺជារឿងចាំបាច់ដែលត្រូវបង្កើតវិន័យសម្រាប់សាវ័ក ដើម្បីធានាឱ្យបាននូវសហគមន៍សង្ឃដែលមានក្តីសុខុដុមរមនា។ វិន័យត្រូវបានបង្កើតឡើង ត្រូវបានគេយកមកប្រើប្រាស់នៅពេលចាំបាច់ ដើម្បីឆ្លើយតប់ទៅនឹងកំហុសឆ្គង ឬអធិករណ៍នានាដែលកើតឡើងនៅក្នុងសហគមន៍សង្ឃ។ មានវិន័យរាប់រយ «ខ» ត្រូវបានបង្កើតឡើង រហូតដល់ទីបញ្ចប់នៃជីវិតចុងក្រោយរបស់ព្រះសម្មាសម្ពុទ្ធ សម្រាប់ឱ្យអ្នកបួស និងដូនជីបដិបត្តិតាម។

កាលពីដំបូងឡើយ ព្រះសម្មាសម្ពុទ្ធព្រះអង្គទទួលតែបុរសតែប៉ុណ្ណោះឱ្យចូលបួសនៅក្នុងសហគមន៍សង្ឃ។ ប្រាំឆ្នាំក្រោយពីការបង្កើតនូវសហគមន៍សង្ឃ ម្តាយមីងរបស់ព្រះអង្គព្រះនាមថា មហាបជាបតី គោតមី បានស្នើសុំឱ្យព្រះពុទ្ធបំបួសរូបនាងជាភិក្ខុនី ប៉ុន្តែព្រះអង្គបានបដិសេធ។ ប៉ុន្តែព្រះនាងមហាបជាបតី គោតមី រួមទាំងស្ត្រីប្រាំរយនាក់ទៀត មិនរាថយ និងបានសម្រេចចិត្តថា កោរសក់និងស្លៀកពាក់ស្បង់ជីវរព័ណ៌លឿង និងធ្វើដំណើរតាមព្រះពុទ្ធ។ ព្រះនាងមហាបជាបតីបានធ្វើការស្នើសុំពីរលើកទៀតទៅកាន់ព្រះសម្មាសម្ពុទ្ធ តែព្រះពុទ្ធបានធ្វើការបដិសេធចំពោះនាងគ្រប់ពេលទាំងអស់។ លើកទីបួនជីដូនមួយរបស់ព្រះសម្មាសម្ពុទ្ធ គឺព្រះអានន្ទព្រះអង្គបានចូលបង្គំថ្វាយដល់ព្រះពុទ្ធជំនួសម្តាយមីងរបស់ព្រះអង្គ ព្រះអានន្ទបានសួរទៅកាន់ព្រះសម្មាសម្ពុទ្ធថា តើស្ត្រីគេមានសមត្ថភាពដូចបុរសដើម្បីបដិបត្តិលើមាគ៌ាផ្លូវចិត្តនេះ និងសម្រេចបាននូវការត្រាស់ដឹងដូច

បុរសឬទេ ព្រះសម្មាសម្ពុទ្ធព្រះអង្គទ្រង់យល់ព្រមនិងឆ្លើយតបទៅកាន់អានន្ទវិញ។ បន្ទាប់មកទៀត អានន្ទបានផ្តល់ជាយោបល់ថា វាគឺជារឿងល្អដែលស្ត្រីអាចក្លាយជាអ្នកបួសបាន ហើយព្រះសម្មាសម្ពុទ្ធទ្រង់ក៏អនុញ្ញាតឱ្យបំបួសស្ត្រីជាសាវ័ករបស់ព្រះអង្គ។

**ខ. សារៈសំខាន់របស់ព្រះសង្ឃ**

នៅក្នុងសាសនា ព្រះសង្ឃ ជាសាវ័កមួយនៃព្រះពុទ្ធដែលទូន្មានដល់ពុទ្ធបរិស័ទ ហើយនៅក្នុងសង្គមមនុស្ស ព្រះសង្ឃ គឺជាអ្នកអប់រំសីលធម៌សង្គម។

ព្រះសម្មាសម្ពុទ្ធចូលបរិនិព្វាន២៥០០ព្រះវស្សាកន្លងផុតទៅហើយ ព្រះអង្គបានបន្សល់ទុកនូវព្រះធម៌របស់ព្រះអង្គ ដើម្បីឱ្យយើងបដិបត្តិ នេះហើយគឺជាព្រះពុទ្ធសាសនា។ ប៉ុន្តែដើម្បីឱ្យយើងបដិបត្តិទៅដោយរលូន និងមានប្រសិទ្ធិភាពនោះ យើងចាំបាច់ត្រូវការនូវគំរូភាពដែលគួរអោយទុកចិត្តបាន ពោលគឺបុគ្គលដែលមានការចេះដឹង និងធ្វើការបដិបត្តិនូវព្រះធម៌ និងសម្រេចបាននូវគោលដៅខ្លះៗ ហើយ ដើម្បីឱ្យគេជួយណែនាំតម្រង់ផ្លូវដល់យើង។ សហគមន៍ដែលមានបុគ្គលបែបនោះ នោះគឺជាសហគមន៍សង្ឃនេះឯង។

សព្វថ្ងៃនេះ យើងតែងតែងាកទៅរកតារាល្បីៗនិងយកគេមកធ្វើជាគំរូរបស់យើង៖ តារាសម្តែងប្រុសស្រី តារាដើរម៉ូដ តារាចម្រៀង និងកីឡាករជាដើម។ ប៉ុន្តែមនុស្សទាំងអស់នេះគេមានបញ្ហារបស់គេរៀងៗខ្លួន។ យើងដឹងច្បាស់ណាស់ នៅក្នុងជីវិតឯកជនរបស់គេ គឺមានបញ្ហាស្មុគស្មាញខ្លាំងណាស់។ មិនត្រឹមតែប៉ុណ្ណោះទេ តែកាលណាយើងមានភាពជុំបជុំលជាមួយនឹងតារាល្បីៗ និងជុំបជុំលជាមួយនឹងជីវិតរបស់គេ វានាំយើងទៅរកតែការនិយាយដើមពីគេ និងនាំយើងទៅរកការជាប់ជំពាក់លើសម្ភារៈនិយមផ្សេងៗ។ សកម្មភាពទាំងអស់នេះ មិននាំមកនូវប្រយោជន៍ និងក្តីសុខដល់រូបយើងនិងដល់មនុស្សគ្រប់រូបឡើយ។ ម្យ៉ាងវិញទៀត សហគមន៍សង្ឃ គឺជាអ្នកដែលបានលុបបំបាត់បញ្ហារបស់ខ្លួនមួយចំនួនហើយ និងកំពុងតែបដិបត្តិដើម្បីកម្ចាត់បង់បញ្ហារបស់ព្រះអង្គដែលនៅសេសសល់ទាំងប៉ុន្មានៗ។ នេះ ជាគំរូភាពដែលគួរគោរព។

ដោយសារតែគុណបុណ្យដ៏ធំធេងរបស់ព្រះសង្ឃ ដែលសព្វថ្ងៃ នៅក្នុងពិភពលោកដ៏ទំនើបយើងនេះ យើងនៅមានព្រះធម៌ដែលបានរក្សាមកយ៉ាងល្អ ដែលបន្តឆ្លងកាត់ពីជំនាន់មួយទៅជំនាន់មួយទៀតមិនឈប់។

សហគមន៍សង្ឃបានបំផុសគំនិតយើង ឱ្យសំឡឹងមើល និងមើលឱ្យឃើញវែងឆ្ងាយជាងបញ្ហារបស់យើងទៅទៀត គឺមើលឃើញមាគ៌ាមួយដែលដឹកនាំយើងទៅរកការរួចចាកផុតពីសេចក្តីទុក្ខទាំងស្រុង។ សង្ឃ មិនត្រឹមតែបំផុសគំនិតយើងតែប៉ុណ្ណោះទេ ព្រះអង្គដឹកនាំ លើកកម្លាំងចិត្ត និងជួយគាំទ្រយើងរាល់គ្រប់ជំហានទាំងអស់នៅលើមាគ៌ានេះ។ ហេតុដូច្នេះហើយ បានជាពេលខ្លះគេពោលពាក្យថា បើគ្មានសង្ឃ គឺគ្មានពុទ្ធសាសនា។

**គ. វិន័យសង្ឃ**

វិន័យ (មកពីពាក្យបាលីសំស្រ្កឹត«វិនយ») មានន័យថា ការដឹកនាំទៅរកផ្លូវល្អ ច្បាប់ ...។ការីកចម្រើនលូតលាស់ទាំងឡាយ កើតឡើងពីការបដិបត្តវិន័យនេះឯង។

ព្រះសម្មាសម្ពុទ្ធ ជាអ្នកប្រាជ្ញ ជាទស្សនវិទូដ៏មហាអស្ចារ្យក្នុងលោក។គឺមានវិន័យរាប់រយ«ខ»ត្រូវបានបង្កើតឡើង រហូតដល់ទីបញ្ចប់នៃជីវិតចុងក្រោយរបស់ព្រះសម្មាសម្ពុទ្ធ សម្រាប់ឱ្យអ្នកបួស និងដូនជីបដិបត្តិតាម (រូបទី២)។



*រូបទី២៖ ព្រះសម្មាសម្ពុទ្ធ សមាធិក្រោមដើមពោធិ៍ និងវិនយបិដកសម្រាប់បព្វជិតបដិបត្តិ*

បើនិយាយពីវិន័យសង្ឃ គឺមានច្រើន«ខ» ណាស់ តែបើនិយាយរួម គម្ពីរព្រះវិន័យព្រះសម្មាសម្ពុទ្ធ ទ្រង់បានបញ្ញត្តិសិក្ខាបទដល់សាវ័កទាំងឡាយ ព្រោះអាស្រ័យអំណាចប្រយោជន៍កើតមានចំពោះសង្ឃគឺ[13]៖

១- ដើម្បីសេចក្តីល្អដល់សង្ឃ

២- ដើម្បីការរស់នៅសប្បាយដល់សង្ឃ

៣- ដើម្បីសង្កត់សង្កិននូវបុគ្គលទាំងឡាយដែលមិនអៀនខ្មាស

៤- ដើម្បីនៅជាសុខស្រួលដល់ភិក្ខុទាំងឡាយដែលមានសីលជាទីស្រឡាញ់

៥- ដើម្បីរារាំងអាសវធម៌ទាំងឡាយក្នុងបច្ចុប្បន្ន

[13] តាមការផ្សាយនៃគេហទំព័រកាសែតកោះសន្តិភាពនៅថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២១ ដោយដាក់ចំណងជើងមានអំណាចប្រយោជន៍១០យ៉ាង តែសរសេរឃើញតែ៩

៦- ដើម្បីញ៉ាំងបុគ្គលទាំងឡាយដែលមិនទាន់ជ្រះថ្លាឲ្យជ្រះថ្លាឡើង

៨- ដើម្បីញ៉ាំងបុគ្គលទាំងឡាយដែលជ្រះថ្លាហើយឱ្យរឹងរិតតែជ្រះថ្លាឡើងថែមទៀត

៩- ដើម្បីតម្កល់នៅមាំនៃព្រះសទ្ធម្ម

១០- ដើម្បីអនុគ្រោះដល់ព្រះវិន័យ។ វិន័យបញ្ញត្តិនេះ មានប្រយោជន៍ធំធេងណាស់ដល់អ្នកបួស រស់នៅក្នុងព្រះពុទ្ធសាសនា ដើម្បីទូលជ្រោងសាសនាឱ្យបានថ្កុំថ្កើងដរាបរៀងទៅ។

ក្រៅពីការលើកឡើងខាងលើ យើងឃើញថា វិន័យមានប្រយោជន៍១០យ៉ាងដែលព្រះបរមគ្រូទ្រង់បញ្ញត្តិមក ព្រោះទ្រង់យល់ប្រយោជន៍ចំពោះសង្ឃសាវ័កឬអ្នកបួស។ ប្រយោជន៍វិន័យ១០យ៉ាងនោះមានដូចតទៅនេះ៖

1. **សង្ឃសុដ្ឋុតាយ៖** ដើម្បីសេចក្តីល្អដល់សង្ឃ
2. **សង្ឃផាសុតាយ៖** ដើម្បីការស្រួលដល់សង្ឃ
3. **ទុម្មង្គូនំ ភិក្ខូនំ និគ្គហាយ៖** ដើម្បីញាំញីពួកភិក្ខុដែលទ្រុស្តសីល
4. **បេសលានំ ភិក្ខុនំផាសុវិហារាយ៖** ដើម្បីនៅជាសុខដល់ពួកភិក្ខុដែលមានសីលជាទីស្រឡាញ់
5. **ទិដ្ឋធម្មិកានំ អាសវានំ សំវរាយ៖** ដើម្បីឃាត់នូវអាសវធម៌ទាំងឡាយក្នុងបច្ចុប្បន្ន។
6. **សម្បរាយិកានំ អាសវានំ បដិឃាតាយ៖** ដើម្បីឃាត់នូវអាសវ[14]ធម៌ទាំងឡាយក្នុងបរលោក។
7. **អប្បសន្នានំ បសាទាយ៖** ដើម្បីញ៉ាំងពួកជនដែលមិនទាន់ជ្រះថ្លាឲ្យជ្រះថ្លា
8. **បសន្នានំ ភិយ្យោភាវាយ៖** ដើម្បីញ៉ាំងពួកជនដែលជ្រះថ្លាហើយ ឲ្យរឹតតែជ្រះថ្លាឡើង
9. **សទ្ធម្មដ្ឋិតិយា៖** ដើម្បីញ៉ាំងព្រះសទ្ធម្មឲ្យស្ថិតស្ថេរ
10. **វិនយានុគ្គហាយ៖** ដើម្បីអនុគ្រោះដល់ព្រះវិន័យ៤យ៉ាងមានសំវរវិន័យជាដើម។

## ៤. ការសិក្សាអប់រំប្រកបដោយគុណតម្លៃ

[14] អាសវៈ មានន័យថា សៅហ្មង ឧបទ្រព ចង្រៃ។

យើងសង្កេតឃើញថា មានមនុស្សតិចតួចណាស់ ដែលបានដឹងពីវិភាគទានរបស់ព្រះពុទ្ធសាសនាចំពោះការអប់រំ។ សូម្បីតែនៅក្នុងប្រទេសកាន់ពុទ្ធសាសនាទាំងឡាយ ដែលមានប្រពៃណីទទួលការអប់រំពីពុទ្ធសាសនាជាប់មិនដាច់ អស់កាលជាច្រើនសតវត្សហើយក៏ដោយ ក៏ប្រព័ន្ធអប់រំបច្ចុប្បន្ននៃប្រទេសនោះលែងទៅជាការវិវត្តដោយផ្ទាល់នៃប្រពៃណីអតីតកាលនោះទៀតហើយ ទាំងមិនបិតនៅក្នុងបែបបទណាមួយ ដែលជាប់ទាក់ទងជាមួយការអប់រំពុទ្ធសាសនាដែរ[15]។

វត្តអារាម បានដើរតួនាទីនាំមុខក្នុងសហគមន៍ ក្នុងឋានៈជាមណ្ឌលផ្សាយចេញនូវគំនិត និងបច្ចេកទេសថ្មីៗ។ លោកសង្ឃ មានទឹកព្រះទ័យមេត្តាធម៌ និងដឹកនាំប្រជាជនកសាងផ្លូវ មន្ទីរពេទ្យ សាលារៀន មណ្ឌលក្មេងកំព្រា និងបង្កើតភាពសប្បាយរីករាយដទៃទៀត ដែលប្រព្រឹត្តទៅក្នុងវត្តអារាមសម្រាប់សហគមន៍ (រូបទី៣)។



**រូបទី៣៖ ព្រះគ្រូ ជួន កក្កដា និងសមណសិស្សនៅវត្តប្រាសាទនាងខ្មៅកំពុងសិក្សា[16]**

លោកបានលើកស្ទួយករងារសហប្រតិបត្តិការក្នុងកសិកម្ម និងសំណង់ សម្រាប់បម្រើសាធារណជន និងឯកជន។ វត្តអារាម នៅតែបន្តតួនាទីជាកន្លែងជួបជុំប្រជាជន ដើម្បីចាត់តាំងសកម្មភាពអភិវឌ្ឍសហគមន៍ នៅក្នុងប្រទេសកាន់ពុទ្ធសាសនានានា។ លោកសង្ឃនៅតែបានតាំងខ្លួនជានិច្ច ជាអ្នកផ្ដើមគំនិតការងារ

[15] ផ្សាយរបស់ទស្សនាវដ្ដីកម្ពុជសុរិយា ថ្ងៃទី១ ខែមីនា ឆ្នាំ ១៩៩៦ អត្ថបទរបស់លោក ឈន អៀម។

[16] វត្តប្រាសាទនាងខ្មៅ កំពុងក្លាយជាទីកន្លែងផ្ដល់ការអប់រំដល់សាមណសិស្សជាង ៣៤៥អង្គ ព្រះជន្មចន្លោះពី៣ – ២០ព្រះវស្សាកំពុងទទួលបានការអប់រំ និងបណ្ដុះបណ្ដាលចំណេះដឹង អក្សរសាស្ត្រខ្មែរ ភាសាបាលី វិជ្ជានព្វន្ត និងការប្រតិបត្តិខ្លួនតាមគន្លងអប់រំសីលធម៌ព្រះពុទ្ធសាសនា (សាលាពុទ្ធិកបឋមសិក្សាវត្តប្រាសាទនាងខ្មៅ ស្ថិតនៅវត្តប្រាសាទនាងខ្មៅ មានទីតាំងស្ថិតនៅភូមិចារ ឃុំរវៀង ស្រុកសំរោង ខេត្តតាកែវ)។

ជាអ្នកនាំធ្វើការងារ និងជាអ្នកជំរុញរាល់ការងារ (រូបទី៤)។



**រូបទី៤៖ សម្ដេចព្រះមហាអរិយវង្ស បណ្ឌិត ឃី សុវណ្ណរតនា[17] អគ្គលេខាធិការថេរសភាពុទ្ធសាសនានៃព្រះរាជាណាចក្រកម្ពុជា និងជាសាកលវិទ្យាធិការពុទ្ធិសាកលវិទ្យាល័យព្រះសីហនុរាជ និងមន្ត្រីបរិស្ថាន និមន្តដាំនិងដាំកូនឈើ១៥០ដើមនៅសាលាតិចណូ (រូបភាពរបស់កាសែតរស្មីកម្ពុជា)**

ការរំដោះបញ្ហាខាងស្មារតីរបស់ពុទ្ធសាសនា គឺជាការលើកទឹកចិត្តដល់ការធ្វើឲ្យវិស័យអប់រំរីកចម្រើន ព្រោះកត្តាចម្បងមួយនៃអាកប្បកិរិយារបស់ពុទ្ធសាសនាចំពោះការរៀន ការបង្រៀន និងការស្រាវជ្រាវ គឺជាការលើកទឹកចិត្តឲ្យមានសេរីភាពរូបនីយកម្មខាងបញ្ញាស្មារតីដែលព្រះអង្គទ្រង់សម្ដែងទុកមក។ ទន្ទឹមនឹងការសិក្សាយល់ដឹងពីតម្លៃនៃពុទ្ធបញ្ញត្តិ ការអប់រំផ្លូវចិត្ត ព្រះសង្ឃក៏ទទួលបានចំណេះដឹងផ្នែកភាសា អក្សរសាស្ត្រ ដូចជាភាសាបាលី ភាសាសំស្ក្រឹត ជាដើម។ទុនភាសាបាលី សំស្ក្រឹត មាននៅក្នុងការសិក្សាព្រះធម៌តាំងពីមុនសាងផ្នួស ពីព្រោះមុនសាងផ្នួសត្រូវឆ្លងកាត់ការសិក្សាធម៌វិន័យ។ នៅកម្ពុជាបច្ចុប្បន្ន ការអប់រំនៅក្នុងព្រះពុទ្ធសាសនា មានលក្ខណៈទំនើបជាងមុនដោយមានការចងក្រងសៀវភៅច្រើន កម្មវិធីសិក្សាក៏ដូចជាវិធីសិក្សារៀនសូត្រក៏មានការវិវឌ្ឍដែរ ពីព្រោះកន្លងមកការរៀនភាសាបាលីនៅកម្ពុជា បានប្រព្រឹត្តទៅតាមការរៀនសូត្យចាំមាត់ ហើយដោយហេតុនេះត្រូវការយ៉ាងបន្ទាន់ឲ្យមានការផ្លាស់ប្ដូរក្នុងវិធីបង្រៀន[18](រូបទី២)។

---

[17] សព្វថ្ងៃនេះ សម្ដេចបានលាចាកសិក្ខាបទមកគ្រហស្ថដោយបម្រើការងាររាជការនៅក្រសួងការបរទេសក្នុងអាណត្តិទី៧នៃរាជរដ្ឋាភិបាលថ្មី ដឹកនាំដោយសម្ដេចធិបតីហ៊ុន ម៉ាណែត ជានាយករដ្ឋមន្ត្រីនៃកម្ពុជា។

[18] ស្រង់ពីសៀវភៅបែបរៀនភាសាបាលី ភាគ១ ប្រាក់ ឃុន ផ្សាយដោយពុទ្ធសាសនបណ្ឌិត្យ ១៩៩៧។



*រូបទី៤៖ ការបង្រៀននិងរៀននៅពុទ្ធិកវិទ្យាល័យ ប៊ុនរ៉ានីហ៊ុនសែនក្រពើហា ក្នុងក្រុងតាខ្មៅ*

*ព្រះពុទ្ធសាសនា កំពុងដើរតួនាទីយ៉ាងសំខាន់ នៅក្នុងការអភិវឌ្ឍប្រទេសកម្ពុជា នៅពេលបច្ចុប្បន្ននេះ យើងសង្កេតឃើញមានព្រះសង្ឃជាច្រើនអង្គ បាននិងកំពុងចូលរួមធ្វើសកម្មភាពជួយដល់ការអភិវឌ្ឍនៅក្នុងសង្គមកម្ពុជា តាមរយៈការចុះអប់រំផ្ទាល់នៅតាមសហគមន៍ និងបានទេសនាធម៌វិន័យ និងសីលធម៌តាមប្រព័ន្ធផ្សព្វផ្សាយ មានដូចជា វិទ្យុ ទូរទស្សន៍ បណ្ដាញសង្គម យូធូប ហ្វេសប៊ុក ជាដើម។ លើសពីនេះទៀតនោះ ការសិក្សារបស់សមណសិស្ស និស្សិតតាមពុទ្ធិកក៏ត្រូវការប្រឡងប្រជែងដូចសាលាសាធារណៈនានារបស់គ្រហស្ថដែរ ។ជាក់ស្ដែង កន្លងមកយើងឃើញមានសមណសិស្សនិមន្តមកប្រឡងនៅសាលាសិក្សា នៅក្រុងតាខ្មៅដោយមានការចូលរួមពី**សម្ដេចព្រះឧត្តមមុនី ជាសំអាង** មេគណខេត្តកណ្ដាលនិងលោកប៊ុនផេងអភិបាលរងខេត្តជាអធិបតី។ លោកអភិបាលរងមានប្រសាសន៍ថា សមណសិស្សទាំងអស់ ត្រូវគោរពវិន័យបទបញ្ជាផ្ទៃក្នុង នៃការប្រឡងអោយបានល្អ និងខិតខំបញ្ចេញឲ្យអស់ពីសមត្ថភាព លទ្ធភាពពល់ចំណេះដឹង ដែលមានដើម្បីទទួលបានលទ្ធផលល្អ ដែលជាការអភិវឌ្ឍធនធានបុព្វជិតឱ្យកាន់តែមានសុក្រិត្យភាព និងគុណភាពខ្ពស់ ពីព្រោះការប្រឡងនេះគឺជា កត្តាសំខាន់មួយសំរាប់អ្នកបួសបានរាស់ស្ទង់ចំណេះដឹងខាងផ្នែកព្រះពុទ្ធសាសនា ក៏ដូចជាចំណេះដឹងទូទៅសំរាប់ប្រតិបត្តិខ្លួនក្នុងនាមជាបុព្វជិត ស្របទៅនឹងគោលនយោបាយកំណែរទម្រង់ស៊ីជម្រៅរបស់រាជរដ្ឋាភិបាល(រូបទី៥)។[19] មិនត្រឹមតែពុទ្ធិកវិទ្យាល័យទេ កម្ពុជា ក៏មានពុទ្ធិកសាកលវិទ្យាល័យដែរក្នុងការបម្រើឲ្យវិស័យអប់រំសិក្សាធិការ។យ៉ាងណាមិញ នៅក្នុងរាជធានីភ្នំពេញមានពុទ្ធិកសាកលវិទ្យាល័យចំនួន២កន្លែង គឺពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ និងពុទ្ធិកសាកលវិទ្យាល័យព្រះសីហមុនីរាជា។ កម្មវិធីអប់រំសម្រាប់ពុទ្ធិកសាកលវិទ្យាល័យមានដូចជា៖ រដ្ឋបាលសាធារណៈនីតិសាស្ត្រ ភាសាអង់គ្លេស គ្រប់គ្រងទូទៅ អប់រំ*

[19] http://ckknews.link

ទស្សនវិជ្ជា អក្សរសាស្ត្រខ្មែរ និងព័ត៌មានវិទ្យា។ ដោយសារពុទ្ធិកសាកលវិទ្យាល័យទាំងពីរខាងលើ មានផ្តល់កម្មវិធីអាហារូបករណ៍ច្រើន ជួយដល់សមណនិស្សិត និងនិស្សិតទូទៅដែលពុំមានលទ្ធភាពគ្រប់គ្រាន់ សម្រាប់បង់ថ្លៃសិក្សានាំឱ្យមានចំនួនសមណនិស្សិត និងនិស្សិតទូទៅជាច្រើនរស់នៅតាមបណ្តាខេត្តនានា សំដៅមកសិក្សានៅពុទ្ធិកសាកលវិទ្យាល័យទាំងពីរនេះ។ នេះសរបញ្ជាក់ឲ្យឃើញថា កម្ពុជាបច្ចុប្បន្នការបណ្តុះបណ្តាលសង្ឃគឺមានយុទ្ធសាស្ត្រ មានកម្មវិធី មានផែនការ និងគោលនយោបាយអប់រំត្រឹមត្រូវព្រោះព្រះពុទ្ធសាសនា ជាសាសនារបស់រដ្ឋ។



***រូបទី៥៖ កាត់វិញ្ញាសាក្នុងការប្រឡងចូលរៀនពុទ្ធិកអនុវិទ្យាល័យទូទាំងខេត្តកណ្តាល នៅព្រឹកថ្ងៃទី៩ ខែមីនា ឆ្នាំ២០២៣***

## ៥. បញ្ញវន្តខ្មែរដែលទទួលបានការអប់រំខ្ពង់ខ្ពស់តាមរយៈព្រះពុទ្ធសាសនា

យើងដឹងមកហើយថា កម្ពុជាជាប្រទេសកាន់ព្រះពុទ្ធសាសនាតាំងពីយូរលង់ណាស់មកហើយ។ ភិក្ខុទាំងនោះ បានបង្កើតស្នាដៃអក្សរសាស្ត្រ សម្រាប់ការសិក្សាយ៉ាងច្រើនសន្ធឹកសន្ធាប់ ដែលនៅក្នុងនោះ លោកបានធ្វើការសិក្សា និងធ្វើវិភាគយ៉ាងល្អិតល្អន់ នូវពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ។ ស្នាដៃទាំងអស់នេះ មិនអាចកើតមានបាននៅក្នុងអំឡុងពេលខ្លីនៃពីរសតវត្សដំបូងបានទេ ប្រសិនបើមុខងារអប់រំរបស់ព្រះសង្ឃព្រះពុទ្ធសាសនិក មិនត្រូវបានចាត់តាំងយ៉ាងរឹងមាំ តាំងតែពីដើមទីនៃសកម្មភាពចាត់ឲ្យទៅបំពេញបេសកកម្មរបស់ព្រះពុទ្ធនោះ។

បណ្ឌិត អ្នកប្រាជ្ញ បញ្ញវន្ត បានប្រសូត្រចេញពីព្រះពុទ្ធសាសនាមានទាំងបព្វជិត ទាំងគ្រហស្ថ[20]។ អ្នកដែលមានចំណេះដឹងជ្រៅជ្រះទាំងនោះមានដូចខាងក្រោម៖

- **បព្វជិត៖** សម្តេចសង្ឃរាជ ជួនណាត សម្តេចសង្ឃរាជ ហួត តាត ព្រះភិក្ខុប៉ាងខាត់ សម្តេចអ៊ុម ស៊ុម (រូបទី៦)......។

[20] គ្រហស្ថទីនេះ សម្តៅដល់បញ្ញវន្តឬអន្ទិតដែលចាកសិក្ខាបទពីសង្ឃភេទ។



រូបទី៦៖ សម្តេច ជួន ណាត និងសម្តេច ហួតតាត

- គ្រូហស្ត៖ ក្រមង៉ុយ លោកញ៉ុក ថែម សុត្តន្តប្រីជាឥន្ទ(រូបទី៧)...។



រូបទី៧៖ កវីអ៊ុក អ៊ូ ហៅង៉ុយ និង ឧកញ៉ា សុត្តន្តប្រីជាឥន្ទ

## ៦. សន្និដ្ឋាន

ព្រះពុទ្ធសាសនា ផ្តល់ភាពរីកលូតលាស់យ៉ាងច្រើននៅក្នុងសង្គម ឲ្យតែមានការបដិបត្តិត្រឹមត្រូវ ច្បាស់លាស់ ប្រកបដោយចក្ខុវិស័យ។ ពីមុន ប្រពៃណីការអប់រំរបស់ព្រះពុទ្ធសាសនាត្រូវបានគេបោះបង់ចោលស្ទើរតែទាំងស្រុង ប៉ុន្តែនៅមានសេសសល់តែបន្តិចបន្តួច ដែលគេឃើញមានរក្សាទុកនៅក្នុងការចាត់តាំងរបស់វត្តអារាម សម្រាប់ការហ្វឹកហ្វឺនភិក្ខុ-សាមណេរ។ ចំណុចនេះហើយ វត្តអារាម បានក្លាយទៅជាស្ថាប័នសម្រាប់ការអប់រំជាប្រពៃណី ដែលត្រូវបានគេរក្សាទុករហូតមកដល់បច្ចុប្បន្ន សូម្បីវត្តអារាមមួយយ៉ាងតូច តាំងនៅកៀនកោះដាច់ស្រយាលមួយនៃប្រទេសកាន់ពុទ្ធសាសនា ក៏គង់បានទៅជាមណ្ឌលរៀនសូធ្យ[21]មួយដ៏សំខាន់ដែរ។ នៅក្នុងការរីកដុះដាលនៃប្រព័ន្ធអប់រំរបស់វត្ត កើតមានគោលការណ៍ដ៏មានអត្ថន័យមួយចំនួន ត្រូវបានគេយកមកអនុវត្ត។

ជាការបន្តមរតកអប់រំនៃព្រះពុទ្ធសាសនា សាលារៀន ពុទ្ធិកសិក្សា បានបង្កើតឡើងជា

[21] សូធ្យ មានន័យថាតាមរបៀបដែលទន្ទេញចាំមាត់៖សូត្រធម៌ សូត្របាលី។សូធ្យនិងសូត្រមានន័យដូចគ្នា។

បន្តបន្ទាប់ ដើម្បីបម្រើវិស័យសិក្សាធិការ។ វាជាការរួមចំណែកបន្ថែមលើការអប់រំខាងបញ្ញាស្មារតី និងសង្គមតាមរយៈពុទ្ធបញ្ញត្តិឬធម៌វិន័យ ដែលមានសារៈសំខាន់សម្រាប់ការអភិវឌ្ឍប្រទេសជាតិ និងសីលធម៌សង្គម។ ព្រះសង្ឃ បាននិងកំពុងរួមចំណែកយ៉ាងសន្ធឹកសន្ធាប់ក្នុងការអភិវឌ្ឍព្រះពុទ្ធសាសនា សង្គមកម្ពុជា ហើយអង្គខ្លះដែលលាចាកសិក្ខាបទក៏មានធនជានចំណោះដឹងបម្រើសង្គមជាតិដែរ។ ដូចនេះ យើងអាចនិយាយបានថា ព្រះពុទ្ធសាសនាអប់រំមនុស្សឱ្យមានសន្តិភាពនិងការអភិវឌ្ឍ។

**គន្ថនិទ្ទេស**


-កាសែតកោះសន្តិភាព ផ្សាយថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២១

-ជួន ណាត *វចនានុក្រមខ្មែរ ផ្សាយដោយពុទ្ធសាសនបណ្ឌិត្យ* ១៩៦៧

-ឈន អៀម *ការអប់រំរបស់ពុទ្ធសាសនា* ផ្សាយក្នុងទស្សនាវដ្ដីកម្ពុជសុរិយា ដោយពុទ្ធសាសនបណ្ឌិត្យ ១៩៩៦

-ប្រាក់ ឃុន *បែបនៃរៀនភាសាបាលី* ផ្សាយដោយពុទ្ធសាសនបណ្ឌិត្យណ១៩៩៧

-រដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា ១៩៩៣

- វចនានុក្រមOXFORD Language dictionary

-Facebook page: ពុទ្ធិកវិទ្យាល័យប៊ុនរ៉ានីហ៊ុនសែនក្រពើហា

- Facebook page: ពុទ្ធិកអនុវិទ្យាល័យវត្តសិត្បូ

-https://education.ams.com.kh

- http://ckknews.link

-https://km.warbletoncouncil.org

-https://studybuddhism.com

-https://thehrdaily.com.dream

-https://www.pailin.org.kh

-https://www.sangapac.com

# ទម្លាប់

(custom)

*បណ្ឌិត* **ភ្លាន់ ធុល**
*មន្ត្រីនាយកដ្ឋានទស្សនវិជ្ជានិងសង្គមវិជ្ជា,*
*វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសង្គម,*
*រាជបណ្ឌិត្យសភាកម្ពុជា*

## ១. សេចក្តីផ្តើម

*មនុស្សគ្រប់ជាតិសាសន៍នៅលើលោកនេះ សុទ្ធតែមានមាន ទម្លាប់របស់ខ្លួនគ្រប់ៗគ្នា។ វាអាចជា ទម្លាប់របស់បុគ្គល, ទម្លាប់របស់គ្រួសារ, ឬអាចជាទម្លាប់របស់ស្រុកទេស។ ទម្លាប់របស់បុគ្គលបង្កើតឱ្យមានទម្លាប់គ្រួសារ ដែលបុគ្គលនោះបានបង្កើតឡើង ហើយទម្លាប់គ្រួសាររួមផ្សំបង្កើតទៅជាទម្លាប់ស្រុកទេស ដោយអនុលោមទៅតាមគំនិតយល់ឃើញ និងកាលៈទេសៈ ឬបរិស្ថានដែលគេរស់នៅនៅក្នុងនោះ។ អ្នកស្រុកស្រែចុងកាត់មាត់ញកអាចមានទម្លាប់ខុសពីអ្នកស្រុកស្រែប្រជុំជន និងអាចខុសប្លែកពីអ្នកទីក្រុង។*

*ទម្លាប់របស់មនុស្សខុសពីទម្លាប់របស់សត្វ ដែលមានលក្ខណៈជាសភាវគតិ (ចំណេះដឹងពីកំណើត) គិតរាប់ចាប់តាំងពីការស៊ីស្មៅ, ផឹកទឹក, ចៀសវាង, ការដេក ដើរ ឈរ អង្គុយ, ការបង្កាត់ពូជ។ សត្វមិនចេះបង្កើតទម្លាប់ដោយខ្លួនវាទេ។ ទម្លាប់របស់វាកើតមានឡើងដោយសារមនុស្ស ឬបរិស្ថានដែលវារស់នៅនៅក្នុងនោះបង្រៀនវា ពីព្រោះ ទម្លាប់មានប្រភពដើមដំបូងមកពី បញ្ញា (វិចារណញ្ញាណ) ពោលគឺ មនុស្សធ្វើវាឡើងតាមការគិតពិចារណា និងការយល់ឃើញរបស់ខ្លួនម្នាក់ៗ មានន័យថា ពួកគេយល់ឃើញបែបណា ហើយក៏គិតថា ល្អសម្រាប់ការរស់នៅហើយ ពួកគេក៏ធ្វើ រឿងនោះម្តងជាពីរដង សារចុះសារឡើង ពីមួយថ្ងៃទៅមួយថ្ងៃ ពីមួយខែទៅមួយខែ និងពីមួយឆ្នាំទៅមួយឆ្នាំ ដដែលៗតកូនតចៅ។ ចំណែកឯសត្វមិនមានបញ្ញាស្វ័យប្រវត្តិដូចមនុស្សទេ លុះតែមនុស្សបង្រៀន ទើបទម្លាប់របស់វាកើតឡើង។*

*តើទម្លាប់ជាអ្វី? វាមានសារសំខាន់*

បែបណា ខ្វះសម្រាប់អភិវឌ្ឍន៍គំនិត និង ការរស់នៅរបស់យើងនៅក្នុងជីវភាព ប្រចាំថ្ងៃ?

## ២. និយមន័យទម្លាប់

ទម្លាប់ បើប្រើជាកិរិយាស័ព្ទសកម្ម (transitive verb) មានន័យថា ធ្វើឱ្យធ្លាប់, ឱ្យថ្នឹក ឧទាហរណ៍ ៖ ទម្លាប់ខ្លួន, ទម្លាប់ចិត្ត, ទម្លាប់ដៃ, ទម្លាប់មាត់[១]។ ទម្លាប់ បើតាមខ្លឹមនេះ ទម្លាប់គឺជាការធ្វើឱ្យមនុស្ស ឬសត្វណាមួយមានបទពិសោធន៍ញយៗ ច្រើនដង រហូតដល់បាត់ជាតុបញ្ញា ដែលជាធាតុអំពើរបស់គំនិត នៅសល់តែធាតុអំពើដោយកាយ និងវាចា ដែលអាចប្រើក្លាយទៅជានាមស័ព្ទថា *ការដែលធ្លាប់, លំអានដែលធ្លាប់តែមានមក*។ ឧទាហរណ៍ ទម្លាប់ចាស់បុរាណ; ធ្វើតាមទម្លាប់ពីមុនមក; មានទម្លាប់ពីនាយមក ជាដើម[២]។ នៅក្នុងខ្លឹមសារទម្លាប់នេះ ខ្មែរយើងច្រើនប្រើភ្ជាប់ជាមួយនឹងពាក្យ ទំនៀម ដែលមានន័យថា បវេណី, សណ្ដាប់ធ្នាប់, បែបបទ[៣] ដែលមានសទិសន័យជាមួយនឹងពាក្យទម្លាប់នេះដែរ គឺទៅជា ទំនៀមទម្លាប់ នេះឯង។

ទម្លាប់ ឬ**ទំនៀមទម្លាប់** (customs) ឬអាចហៅម្យ៉ាងទៀតថា **របៀបរស់នៅបែបប្រពៃណី** (folkways) សំដៅទៅលើ **របៀបទូទៅ** (common ways) ឬ **ទម្លាប់ជាតួយ៉ាង** (typical habits) និង **គំរូឥរិយាបថ** (behavioral patterns) ផ្សេងៗទៀតដែលគេបានទទួលយកនិងអនុវត្តតាមដដែលៗ ដោយ **មនុស្សមួយក្រុម** ឬដោយ **សហគមន៍មួយ**។ របៀបដូចបានរៀបរាប់មកនេះ **មានលក្ខណៈប្រពៃណី** ជារបៀបងាយស្រួល និងតស៊ូព្យាយាម ដែលត្រូវបានបង្ខំមកលើយើងដោយក្រុមរបស់យើងចាប់ ចាប់តាំងពីកើតមកម៉្លេះ[៤]។ ឯចំពោះ **ប្រពៃណី** (traditions) វិញគឺជា **ទំនៀមទម្លាប់** ដែលគេបានអភិរក្សរាប់ជំនាន់មកហើយ ហើយជារឿយៗវាតែងចាក់ឫសគល់ និងមានឥទ្ធិពលយ៉ាងជ្រៅទៅលើ **ការគិត** និង **របៀបរស់នៅ**របស់មនុស្ស។ ទាំង **ទំនៀមទម្លាប់** និង **ប្រពៃណី**

---

[១] ជួនណាត *វចនានុក្រមខ្មែរ* រក្សាសិទ្ធិដោយវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ, ២០០៨, ទំព័រ ទម្លាប់

[២] -ដ- ទំព័រ ទម្លាប់

[៣] -ដ- ទំព័រ ទនៀម

[៤] Venancio B. Ardales, *"Introductory text to philosophy,"* 2nd printing, New York, 1974, p 54

បានបន្តពីជំនាន់មួយទៅជំនាន់មួយ ដោយ **ការត្រាប់តាម** (imitation) និង **ការបង្រៀន** (instruction)។ ពួកវាមានទំនោរដាក់សម្ពាធទៅលើ **បុគ្គលម្នាក់ៗឱ្យគោរពតាម** ដូចជា**ការជំទាស់** (disapproval), **ការសើចចំអក** (ridicule) ឬ **ការបង្អាប់ឱ្យខ្មាសគេ** (embarrassment) មកលើអ្នកទាំងឡាយណាដែលមិនគោរពតាមវា[៥]។

## ៣. មូលហេតុនៃការបង្កើតទម្លាប់

ហេតុអ្វីបានជាគេត្រូវបង្កើតឱ្យមានទម្លាប់?

ដើម្បីបំពេញតម្រូវការនៅ ក្នុងក្រុមសង្គមដូចជា បុគ្គល, គ្រួសារ, សហគមន៍ជាដើម ហើយនិងដើម្បីឱ្យមានសណ្តាប់ធ្នាប់, ស្ថេរភាព និង សន្តិសុខ, សេចក្តីសង្ឃឹមនិងជំនឿជាក់លាក់, របៀបរៀបរយនិងអភិវឌ្ឍន៍នានា គេត្រូវតែបង្កើតទម្លាប់ឡើងសំដៅដាក់កម្រិតនិងគ្រប់គ្រងទៅលើ **ឥរិយាបថសមាជិក**ក្រុមសង្គមនោះ។ ប្រសិនបើគេមិនយកចិត្តទុកដាក់ ឬមិនគិតគូដល់ទម្លាប់ទេ នោះការរំពឹងទុកពីវិបុលភាពសង្គមនឹងត្រូវទទួលរងនូវការមើលស្រាល, គ្មានសណ្តាប់ធ្នាប់, ហើយនិងការធ្វើព្រងើយកន្តើយដោយសមាជិកក្រុមសង្គមជាមិនខាន។ ហេតុដូច្នេះ គេត្រូវតែបង្កើតទម្លាប់ឡើងចាប់តាំងពីកម្រិតបុគ្គលទៅដល់គ្រួសារ និងទៅដល់កម្រិតសង្គមដ៏ធំទូលាយ។

## ៤. ការផ្ទៀងផ្ទាត់សច្ចភាពនៃទម្លាប់

ទាក់ទងទៅនឹងការស្វែងរកសច្ចភាពនៅក្នុងទម្លាប់នេះ យើងអាចនឹងចោទសំណួរថា តើទម្លាប់មានសច្ចភាពអាចឱ្យគេទុកចិត្តបានដែរឬទេ?

បើតាមបទពិសោធន៍នៅក្នុងការស្រាវជ្រាវរបស់ទស្សនវិទូ, អ្នកវិទ្យាសាស្ត្រ ក៏ដូចជាអ្នកទំនៀមទម្លាប់វិទ្យាសាស្ត្រមុនៗបានចង្អុលបង្ហាញឱ្យឃើញថា មានទម្លាប់ជាច្រើន ដែលនៅពេលមួយគេមានជំនឿយ៉ាងមុតមាំថា ពិត (true) តែក្រោយមកវាបែរទៅជាខុសទៅវិញ។ រឿងនេះពិតជាត្រឹមត្រូវ មិនត្រឹមតែទៅលើទម្លាប់ទូទៅប្រចាំថ្ងៃប៉ុណ្ណោះទេ ប៉ុន្តែវាក៏ពិតជាត្រឹមត្រូវចំពោះទម្លាប់របស់អ្នកវិទ្យាសាស្ត្រផងដែរ សូម្បីតែទស្សនវិទូដែលគេដឹងគ្រប់គ្នាថា មានការស្រាវជ្រាវមានលក្ខណៈជាប្រព័ន្ធ និងដោយការរិះគន់

[៥] Venancio B. Ardales, *op.cit*, p 55

ទៅលើការសម្រេចបានសច្ចភាពនោះក៏ដូច្នេះដែរ។ ចំពោះអ្នកវិទ្យាសាស្ត្រ, ទស្សនវិទូ, និងអ្នកគិតហេតុផលដទៃៗទៀត **សច្ចភាព** (truth) មានសារៈសំខាន់បំផុតសម្រាប់ពួកគេ។ យើងត្រូវតែប្រាកដនៅក្នុងខ្លួនចំពោះអ្វីដែលយើងធ្វើជាប្រចាំនៅក្នុងជីវិតប្រចាំថ្ងៃរបស់យើង ពីព្រោះសកម្មភាពដែលកើតចេញមកពីទម្លាប់អាចត្រូវ និងអាចខុស។ ទម្លាប់ខុសកើតចេញមកពីគំនិតខុស រីឯទម្លាប់ត្រូវកើតចេញមកពីគំនិតត្រូវ។ ពេលខ្លះ អ្នកខ្លះប្រកាន់តាមទម្លាប់ខុស តែឥតដឹងខ្លួនថាខុសទេ នៅតែប្រកាន់ខ្ជាប់ថាត្រូវ។

តែទោះជាមានហេតុផលដូចបានរៀបរាប់មកខាងលើនេះក៏ដោយ ក៏គេមិនអាចទទួលយកនិងអនុវត្តតាមទម្លាប់ ដែលដូនតាបានបន្សល់ទុកឱ្យទាំងស្រុងនោះបានទេ ដោយហេតុថា ទម្លាប់ទាំងនោះមានសច្ចភាពមិនអាចឱ្យទុកចិត្តបាន ពីព្រោះថា ការបង្កើតទម្លាប់ដែលតម្រូវឱ្យប្រតិបត្តិតាមដោយមិនតម្រូវឱ្យសួរដេញដោលហេតុផលគឺជាកំហុស១ (ឧទាហរណ៍ វេទគឺជាពុទ្ធិពិសិដ្ឋ ជាពុទ្ធិដ៏ស័ក្តិសិទ្ធិដែលជាអំណោយរបស់អាទិទេព។ អាទិទេពបានប្រគល់គម្ពីរវេទដល់ពួកមនុ ដែលជាមនុស្សប្រម្បងបំផុតក្នុងលោក។ មនុនេះបានផ្សព្វផ្សាយគម្ពីរវេទដល់ពួកឥសី។ ពួកឥសីក៏បានបង្រៀនវេទមន្តអាគមមកឱ្យពួកព្រាហ្មណ៍តាមការរៀន ជាតាមយល់តាម សូត្រតាម ដោយពុំមានសិទ្ធិដេញដោល[៦] សួររកខុសត្រូវអ្វីឡើយ ពីព្រោះគម្ពីរជាអំណោយអាទិទេព ហើយមានលក្ខណៈសច្ចៈរួចស្រេចទៅហើយ។); ការផ្ទេរឬការបញ្ជូនទម្លាប់មកឱ្យមនុស្សជំនាន់ក្រោយរបស់ដូនតាខ្លះដោយមិនប្រាប់ ឬពន្យល់ហេតុផលឱ្យបានយល់ច្បាស់ គឺ ជាកំហុស ១ (ឧទាហរណ៍ ពិធីកម្មនៅក្នុងពិធីមង្គលការដែលបានរៀបចំឡើងដោយជីដូនជីតា, ឪពុកម្ដាយ និងជាពិសេសគឺលោកអាចារ្យ មិនសូវដែលឮការពន្យល់ពីហេតុដូចម្ដេចបានជាត្រូវរៀបចំពិធីហែជំនូន?, កាន់ផ្កាស្លា?, ការតម្រូវឱ្យកូនប្រុសកាន់ព្រះខ័ន្ធ, ពិធីបុកល័ក្តជាដើម ឱ្យកូនប្រុស -ស្រី និងភ្ញៀវកិត្តិយសបានស្ដាប់ ដើម្បីយល់ដឹងឡើយ); ការទទួលយករបស់មនុស្សជំនាន់ក្រោយ

---

[៦] ឥន្ទ ឱមសាម៉េង, “*ប្រវត្តិទស្សនៈ, សាសនា, សិល្បធម៌, នយោបាយ*”, សាកលវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, ២០០៥, ទំព័រ ២២

ៗ ដោយមិន សួរហេតុផល (មិនចេះឆ្ងល់) ជូនតា ហើយចេះតែទទួលយកតៗគ្នាតាមទម្លាប់ជាប្រពៃណី គឺជាកំហុស ១ (ករណីកាន់ព្រះពុទ្ធសាសនាតៗគ្នាពីជីដូនជីតា, មកដល់ឪពុកម្តាយ និងមកដល់កូនចៅជំនាន់ក្រោយៗតាមទម្លាប់ប្រពៃណីជាដើម)។ ប្រការទាំងបីចំណុចនេះរួមផ្សំបង្កើតឱ្យមានការយល់ និងការប្រតិបត្តិខុសនៅក្នុងទម្លាប់។

ហេតុនេះ **ទម្លាប់** បើទោះជាវាបម្រើឱ្យតម្រូវការពិតប្រាកដរបស់បុគ្គល, ក្រុមគ្រួសារ, និងក្រុមសង្គមក៏ដោយ ក៏វាមិនមែនជាការផ្ទៀងផ្ទាត់មានសុពលដែលយើងអាចទុកចិត្តបាននោះទេ។ គេត្រូវតែផ្ទៀងផ្ទាត់សច្ចភាព នៅពេលគេទទួលទម្លាប់ណាមួយពីអ្នកណាម្នាក់ ឬមុនពេលគេបង្កើតទម្លាប់ឱ្យខ្លួនគេដោយខ្លួនគេ ឬឱ្យគ្រួសារ ពីព្រោះថា ទម្លាប់តែបើវាកើតឡើងចំពោះអ្នកណាហើយ អ្នកនោះពិបាកកែណាស់។ វាប្រៀបដូចសន្ទឹកក្រដាស ឬសំលៀកបំពាក់ ដែលបត់ឬច្បត់ហើយ មិនងាយនឹងលាឱ្យស្មើស្អាតដូចដើមដូច្នោះដែរ។ តែបើគេអាចបង្កើតទម្លាប់ល្អឱ្យដល់ខ្លួនបាន គឺជារឿងប្រសើរបំផុត។ ជារួម គំនិតល្អបង្កើតទម្លាប់ល្អ គំនិតអាក្រក់បង្កើតទម្លាប់អាក្រក់។ គំនិតជាប្រភពនៃទម្លាប់។ គេត្រូវអភិវឌ្ឍគំនិតល្អ ដើម្បីឱ្យទម្លាប់ល្អមានវិបុលភាព។

## ៥. បំណែងចែកទម្លាប់

គេអាចបែងចែកទម្លាប់ទៅជាបីបែបគឺ

### ៥.១. ទម្លាប់អាក្រក់

ទម្លាប់អាក្រក់ គឺទម្លាប់ទាំងឡាយណា ដែលផ្តល់ផលអវិជ្ជមានដល់អ្នកបង្កើតវា។ ទម្លាប់អាក្រក់ហ្នឹងតែបើលូកកាលណាហិនកាលនោះ។ ទម្លាប់អាក្រក់មានច្រើនដូចខាងក្រោម៖

#### ៥.១.១. ទម្លាប់ជឿលើការសង់ផ្ទះ ឬព្រះវិហារបែរមុខទៅទិសខាងកើត

ខ្មែរមិនមែនតែព្រះវិហារទេ គឺមានរហូតដល់ការសាងសង់ផ្ទះទៅទៀតដែលពួកគេមានជំនឿថាល្អ មានសិរីសួស្តីក្នុងការសង់ព្រះវិហារ ឬផ្ទះបែរមុខទៅទិសខាងកើត។ នេះបើតាមអ្នកប្រកាន់បែបចាស់ ពីព្រោះមានគម្ពីរក្បួនមួយនិយាយថា បុគ្គលប្រុសស្រីណាធ្វើរោងទទឹងថ្ងៃពុំបានបុណ្យសោះឡើយហាង លុះត្រាតែធ្វើ

បណ្តាយថ្ងៃទើបបានបុណ្យ។ សង់ផ្ទះត្រូវតែបែរមុខ ទៅឯកើត ឱ្យព្រះអាទិត្យរះពីកើតទើបធ្វើបុណ្យបានបុណ្យមានសិរីសួស្តី។ ដល់ពេលទំនៀមនោះ វាកើតឡើងថ្កល់ជាតិធ្វើត្រង់ពីជើងទៅត្បូង រួចផ្ទះខ្លួននៅឯកើតថ្កល់ មិនធ្វើយកមុខមកឯលិចទេ ទយគួចផ្ទះមករកថ្កល់ ធ្វើទ្រុងជ្រូកមកក្បែរថ្កល់វិញ រួចមុខផ្ទះបែរទៅរកវាលស្រែ។ ចំណែកឯជនជាតិចិន ជាតិដទៃ ធ្វើផ្ទះបែរមុខមកឯលិចជិតគ្នាក្នុងភូមិជាមួយលក់ដូរដាច់ មានប្រាក់កាសចាយវាយ ចំណែកឯខ្មែរដែលមានជំនឿធ្វើផ្ទះបែរមុខទៅកើត ធ្វើស្រែចេះតែមិនសូវបានស្រូវ ក៏មិនដឹងខ្លួនថាខ្លួនហ្នឹងមានជំនឿមិនទាន់ត្រូវ។ រឿងហ្នឹងមកពីគម្ពីរកុហក គឺគម្ពីរដែលថា ធ្វើពេងទទឹងថ្ងៃមិនបានបុណ្យនោះ។

ទាក់ទងទៅនឹងជំនឿលើទិសនេះដែរ បើដំណេកក្បាលទៅលិចគេជឿថាដំណេកខ្មោច ៗគេកប់ក្បាលទៅលិច ម្យ៉ាងទៀតទិសខាងលិច យើងហៅឯលិចមកពីព្រះអាទិត្យលិចនៅទិសខាងលិច។ បើដំណេកក្បាលទៅឯ ជើងវាទាស់នឹងរាសីពីព្រោះខាងជើង គឺ ជើង។ ដំណេកដែលត្រឹមត្រូវ គឺត្រូវបង្វែរក្បាលទៅឯត្បូង គឺទិសខាងត្បូង ព្រោះត្បូង គឺក្បាល ហើយសណ្តូកជើងទៅទិសខាងជើង។ ទិសឯកើតព្រោះ ព្រះអាទិត្យរះមុននៅទិសឯកើតមានសិរីសួស្តី។ ជំនឿបែបនេះមិនមានសច្ចភាពទេ។ សម្តេចព្រសង្ឃរាជ ជួន ណាត មាន ព្រះរាជសង្ឃដីការថា "ព្រះអង្គសឹងមិនដែលគិតពីរឿងទិសនេះទេ ហើយដូចជាមិនដែលធ្វើទុក្ខអ្វីផង មិនដឹងថាទិសអ្វីទេ។ រឿងនេះគេហៅថាទម្លាប់នេះឯង។

សរុបសេចក្តីមក នៅស្ទើរគ្រប់វត្តពុទ្ធ សាសនាខ្មែរទាំងអស់ ច្រើនតែកសាងព្រះវិហារបែរមុខទៅទិសខាងកើត រឿងនេះមិនមែនមានតែខ្មែរទេ ថៃក៏មានដែរ។ បើលាវលង្កាភូមា ដែលជាអ្នកកាន់ព្រះពុទ្ធសាសនាដែរនោះ គឺស្រេចតែនឹងទិស បើព្រែកនៅពីលិច ព្រះវិហារបែរមុខមកឯលិច បែរទៅឥសាន បែរទៅឯជើង គឺស្រេចតែនឹងទិស ឬជ្រោយ។ ឯផ្ទះក៏ដូច្នេះដែរ។ ឯខ្មែរប្រកាន់ថាបែរមុខទៅឯកើតពីព្រោះដីវានៅទួលាយ រួចគេប្រកាន់ថាព្រះកាលដែលលោកពិចារណាអំពីបដិច្ចសមុប្បាទ ពិចារណាធម៌ដែលរាវរកឱ្យបានត្រាសជាព្រះពុទ្ធនោះ គឺលោកបែរព្រះភក្ត្រទៅឯកើត រួចម្ល៉ោះហើយក៏យកន័យ

ហ្នឹងមកដាក់ថាព្រះបែរតែព្រះភ័ក្ត្រទៅឯកើតៗ តាមពិត ព្រះលោកក៏ជាមនុស្សដែរ លោកមិនមែនជាសត្វ ហើយក៏មិនមែនជាគល់ឈើដែរៗ ហេតុនេះ ព្រះជន្ម៨០គត់ ព្រះអង្គយាងទៅគ្រប់ទិសទីសើម្បីសម្តែងធម៌ប្រោសសព្វសត្វ មិនមែនព្រះអង្គប្រកាន់យកតែទិសខាងកើតនោះទេៗ មិនគួរបង្កើតទម្លាប់ជឿខុសឡើយៗ

## ៥.១.២.ទម្លាប់ជឿខុសក្នុងការដាំឬស្សីស្រុក ឬដើមគរ

ចាស់សម័យមុន (កំឡុងពេលពី ព.ស.២៤២៧/គ.ស.១៨៨៣ និង ព.ស. ២៥១៣/គ.ស.១៩៦៩) មានជំនឿថា ក្មេងៗ សូម កុំដាំឬស្សីស្រុក ព្រោះតែឬស្សីស្រុកនោះធំល្មមធ្វើស្នែងខ្មោចបាន ក្មេងៗទាំងនោះនឹងស្លាប់ហើយ ក្មេងៗទាំងនោះក៏លែងហ៊ានដាំៗ

ចំណែកឯជំនឿលើការដាំដើមគរវិញ ក៏ពួកក្មេងៗមិនហ៊ានដាំដែរ ពីព្រោះគរតាមជំនឿតែកាលណាធំបានល្មមធ្វើសសរក្តោងយោងបាន ពួកក្មេងៗទាំងនោះនឹងត្រូវស្លាប់ជាមិនខាន ពួកគេក៏ខានដាំគរនិងឬស្សីទៅៗ ទម្លាប់ហ្នឹងមិនស្រួលទេ វាខាតជំណាស់ៗ ឬស្សីឥឡូវឡើងថ្លៃ ឬស្សីស្រុកស្រែមួយដើមថ្លៃ១៥ រៀល (ព.ស. ២៥១៣) លុះចាំដល់អាយុ ៧០ទើបអាចដាំបាន ឃើញថាវាខាតខ្លាំងណាស់ៗ ឯគេអ្នកដែលមិនប្រកាន់ជំនឿនេះ គេដាំលក់បានលុយ គេមិនឃើញទៅជាអ្វីផងៗ ទម្លាប់បែបនេះ គេហៅថាទម្លាប់មិនល្អទេៗ ដូចស្រុកខ្លះ ខេត្តខ្លះជឿតាមក្បួនមួយថា នៃ ដើមឈើកុំដាំឱ្យចាក់ឫសដល់សសរផ្ទះណា រឿងហ្នឹងវាធ្វើឱ្យស្លាប់កូនស្លាប់ចៅចង្រៃជំណាស់ៗ ឯអ្នកដែលយល់ឃើញត្រូវ គេគិតថា ការដាំដើមឈើនេះ កាលណាវាធំទៅ វាស្រូបយករស់ជាតិក្រខ្វក់ៗ វាឱ្យម្ចប់ វាជក់យករស់ជាតិពុលខ្លះៗ ខ្មែរដែលចងគោក្រោមផ្ទះ ជុះនោម ពពឹកពពរ វាអួរអាប់នៅទីនោះហេតុអ្វីបានជាវាមិនស្អុយអី វាចេះតែរស់ៗ នេះមកពីយើងធ្វើផ្ទះនៅបក្រាលក្តារមានប្រហោង ជញ្ជាំងស្ទឹក មានខ្យល់ចេញចូលបានល្អៗ បើជាផ្ទះថ្មវិញ បើបែបនេះពិតជាមិនសុខទេ ពីព្រោះជម្ងឺវាកើតឡើងពីភាពអួរអាប់ប៉ុន្តែផ្ទះយើងវាស្រួលមកពីវាមានខ្យល់បក់ទៅមកល្អៗរួចអ្នកមិនយល់ មិនហ៊ានដាំដើមឈើទេនៅក្នុងភូមិទេៗ ហេតុដូច្នេះហើយបានជាមានកន្លែងខ្លះឱ្យត្រង់ខ្លាំងត្រង់ថ្ងៃលកណ្តាលថ្ងៃ អត់ដាំដើមឈើទេៗ បើវត្តមិនជាអ្វីទេ វត្តមើលទៅទ្រុប តែឡូវហ្នឹងបាត់

ហើយ។ គំនិតហ្នឹងកាន់តែអន់ហើយ នៅតែតាៗទេ តាៗហ្នឹងនៅមិនប៉ុន្មានគាត់ទេ តាៗហ្នឹងនៅប្រកាន់មាំណាស់ តែរៀបដើរទៅឯណា គាត់យកដៃខ្ទប់ប្រមុះដកដង្ហើមមើល៍ ខាងឆ្វេងធូ ឬខាងស្ដាំធូ? បើខាងឆ្វេងធូជាងគាត់ឈានជើងឆ្វេងមុន ដល់ពេលរៀបទៅបួលដង្ហើមសិន ថាតើដង្ហើមរស់នៅឯណា នៅចំថ្ងៃណាមួយក្នុងចំណោមថ្ងៃទាំង៧។ ថ្ងៃនីមួយៗសុទ្ធតែត្រូវគ្នានឹងទិសមួយជាប្រាកដ...ឧទាហរណ៍ អាទិត្យឧត្តរ...សៅរ៍ទក្សិណ...អូ! ថ្ងៃនេះថ្ងៃសៅរ៍ទៅឯត្បូង! ផ្លូវទៅឯជើង ប៉ុន្តែ គាត់ទៅឯត្បូងសិន។ រួចដល់វាធ្លាប់ជឿទៅ បើមិនធ្វើអញ្ចឹងបេះតែរង្គាសចិត្ត។ រឿងហ្នឹងគេហៅថាអ្នកកាន់ក្បួនពេក។

ទាក់ទងទៅនឹងក្បួនភូមាមួយហៅភុក អំពីជំនឿក្នុងការធ្វើដំណើរ។ ក្បួននេះចែងថា សូមបួងសួងមហាលាភាឱ្យចរយាត្រាទៅណានឹងបានលាភគាប់ចិត្ត ជើងក្អែកកាកបាទបង្កើតអន្តរាយ ទោះទៅជិតឆ្ងាយ កុំបីឱ្យចរយាត្រា ដល់ពេលរៀបចំទៅ ឡានរៀបចេញហើយ ប៉ុន្តែ ដល់ពេលបើកទៅដូចជើងក្អែក ក៏ខានទៅតែម្ដងទៅ។ រឿងបង្កើតទម្លាប់ជំនឿខុសនេះគឺវាខាតអញ្ចឹង។ វាជាទម្លាប់មិនល្អទេ ទម្លាប់ហ្នឹងគ្មានទំនងទេ ប៉ុន្តែ យើងមិនហ៊ានថា តែហ៊ានថាគាត់ដែរ ប៉ុន្តែ គាត់មិនហ៊ានដែរនឹងមុខ គាត់ជេរក្រោយខ្នងថា មនុស្សចង្រៃអីអញ្ចឹង ខ្ជិនបេះដឹងអីជាងគេ?[៧]។

## ៥.១.៣. ទម្លាប់ជឿថ្ងៃ ខែ ឆ្នាំខុស

នៅក្នុងការទិញរបស់ទ្រព្យធំៗចូលផ្ទះដូចជារថយន្ត ឬក៏ធ្វើពិធីឡើងគេហដ្ឋានថ្មី រើសគូស្រករ ភ្ជាប់ពាក្យ ឬរៀបមង្គលការ កូនប្រុស-ស្រីជាដើម សុទ្ធតែត្រូវរកគ្រូគន់គូរមើលជោគជតារាសី ថាតើត្រូវយកថ្ងៃ ខែ ឆ្នាំណាល្អ។ តាមចំណាំថ្ងៃដែលល្អដែលអ្នកមានជំនឿនេះចង់បាន គឺថ្ងៃច័ន្ទដើមទ្រព្យ ថ្ងៃសុក្រ (= សុខ) ; តាមពិតសុក្រ និងសុខ នេះមិនមានន័យដូចគ្នាឡើយ) គឺសុខសប្បាយ។ កាលលពី១០០ឆ្នាំ មុន ការរើសរកថ្ងៃខែ ឆ្នាំល្អនេះ ប្រព្រឹត្តទៅដោយខានមិនបានឡើយ ពីព្រោះជាថ្ងៃមាន សិរីសួស្ដី ជ័យមង្គល រកស៊ីមានបានកូន ចៅប្រុសស្រីអាចរស់នៅជាមួយគ្នា

[៧] ខ្សែអាត់សម្លេង កិច្ចសម្ភាសអក្សរសាស្ត្រខ្មែរ ដោយសម្ដេចព្រះ មហាសុមេធាធិបតី ជោតញ្ញាណោ **ជួន ណាត** អំពីវិហារបែរមុខទៅកើត។

រហូតដល់ទៅខាំចេកបបូតខាំពោតល្បេះៗ តែមក ដល់សម័យសព្វថ្ងៃ ជំនឿនេះបានចុះថយឥទ្ធិពលហើយ ដោយសារតែសច្ចភាពនៅក្នុងជំនឿនោះមិនអាចឱ្យគេជឿទុកចិត្តបាននៅក្នុងជីវិតពិត (real life)ៗ នៅត្រង់ចំណុចនេះ **ភិរម្យ ង៉ុយ** ក៏បានបញ្ជាក់ផងដែរ នៅក្នុងល្បះទី៧៩នៃច្បាប់ល្បើកថ្មីរបស់លោកថា *"កូនអើយអ្នកចាំ កុំជឿខែឆ្នាំ កុំជឿតម្រា ពាក្យប្រួនតម្រាយ កើតពីមនុស្សព្រាវ ពីដូនពីតាចារតាមសម្គាល់"*[៥៥]ៗ

សរុបសេចក្តីមក គ្រប់ថ្ងៃទាំង៧ ខែទាំង១២ និងឆ្នាំទាំង១២ សុទ្ធតែល្អទាំងអស់ តែជីវិតពិតដែលល្អមិនអាចពឹងផ្អែកតែទៅលើថ្ងៃខែឆ្នាំនេះបានទេ ត្រូវយកចំណេះវិជ្ជា បទពិសោធន៍ការងារ ជំនាញវិជ្ជា ហើយនិងនិស្ស័យ (ចំណង់ចំណូលចិត្តរវាងកូននិងកូន) របស់កូនត្រូវគ្នា មានចិត្តស្រលាញ់គ្នា (ទម្លាប់ចាស់ទុំជំនាន់មុនមិនចូលចិត្តឱ្យកូនស្រលាញ់គ្នាមុនរៀបការនោះទេ ដូចសុភាសិតចាស់បុរាណពោលទុកមកថា បើក្រមុំឱ្យចូលដណ្តឹងម្តាយ បើមេម៉ាយឱ្យចូលដណ្តឹងចិត្តៗ) ចង់រស់នៅជាមួយគ្នាទើបល្អៗ និយាយជារួមកូនប្រុសស្រីត្រូវមានគុណសម្បត្តិសំខាន់៣ គឺ សមត្ថភាព, សុខភាព, និងគុណធម៌ៗ

## ៥.២. ទម្លាប់យ៉ាងកណ្តាល

ទម្លាប់នេះធ្វើក៏បាន មិនធ្វើក៏បាន ឧបមាថា យើងចង់ធ្វើក៏ធ្វើទៅ បើ មិនចង់ធ្វើក៏គ្មានខុសត្រង់អ្វីទេៗ

## ៥.៣. ទម្លាប់ល្អ

ទម្លាប់ល្អជាទម្លាប់ត្រូវច្បាប់ ទម្លាប់ត្រូវរបៀបល្អសមរម្យ ជាទម្លាប់ដែលឱ្យផលដល់អ្នកធ្វើនូវសេចក្តីសុខ និងសេចក្តីចម្រើនៗ ខាងក្រោមនេះគឺជាទម្លាប់រស់នៅល្អ១៥ចំណុចរបស់ជនជាតិជប៉ុនៈ

### ៥.៣.១. គោរពពេលវេលា

បើសិនជាអ្នកណាត់ជួបជនជាតិជប៉ុន អ្នកនឹងកម្រនឹងឃើញពួកគេមកយឺតម៉ោងណាស់ៗ នេះដោយសារតែជនជាតិជប៉ុនឱ្យតម្លៃទៅលើពេលវេលារបស់ខ្លួនឯង ហើយក៏ឱ្យតម្លៃទៅលើពេលវេលារបស់អ្នកដទៃដែរៗ កត្តាមួយទៀតដែលតម្រូវឱ្យជនជាតិជប៉ុន ត្រូវតែគោរពពេលវេលាតែម្តងនោះ គឺការធ្វើដំណើរនៅទី

---

[៥៥] យីង ហុកឌី "ក្រមង៉ុយ និង ស្នាដៃ" គ្រឹះស្ថានបោះពុម្ពផ្សាយអង្គរ ភ្នំពេញ, ២០០៨, ទំព័រ ៩៩

សាធារណៈ ដូចជាការជិះរថភ្លើង និងការជិះរថយន្តក្រុងជាដើម។ ប្រសិនបើពួកគេទៅយឺតតែ១នាទី រថភ្លើង ឬរថយន្តក្រុងអាចនឹងត្រូវ ចេញចោល ហើយពួកគេត្រូវរង់ចាំរហូតដល់៥នាទី ឬ១០នាទីក្រោយ ខ្លះដល់ទៅ១ម៉ោង ហើយរថភ្លើងខ្លះទៀតនោះ មួយថ្ងៃចេញតែពីរបីជើងទេ អញ្ចឹងពួកគេអាចរង់ចាំដល់ពេលល្ងាច ឬក៏ ថ្ងៃស្អែកក៏ថាបាន។ នេះគឺជាកត្តាជម្រុញមួយធ្វើឱ្យពួកគេឱ្យតម្លៃពេលវេលាមួយនាទី ៗខ្លាំងមែន ទែន។

## ៥.៣.២. សុជីវធម៌

នេះគឺជាចំណុចពិសេសមួយរបស់ជនជាតិជប៉ុន ដែលត្រូវបានមនុស្សទូ ទៅដឹងឮអំពីវា។ ជនជាតិជប៉ុនតែងតែមាន ការគួរសមជាមួយនឹងអ្នកដទៃជានិច្ច មិនថាពួកគេ ស្គាល់ ឬមិនស្គាល់គ្នានោះទេ។ បើពួកគេដើរបុកអ្នក ពួកគេនឹងសុំទោសអ្នក តែបើអ្នកដើរបុកពួក គេ ក៏ពួកគេសុំទោសអ្នកដូចគ្នាដែរ។ នេះគឺជា អត្តចរិកល្អមួយ ដែលជនជាតិជប៉ុនបានបំពាក់នៅជាប់នឹងខ្លួន។

## ៥.៣.៣.មិនបង្កការរំខានដល់អ្នកដទៃ

បើសិនជាអ្នកទាំងអស់គ្នាបានដើរជាមួយនឹងជនជាតិជប៉ុន អ្នកទាំងអស់គ្នានឹងឃើញថា ពួកគេព្យាយាមអត់ឱ្យតែខ្លួនឯងលួមបានហើយ ដោយមិនព្យាជៀតជ្រែកឱ្យទៅប៉ះដល់កន្ទែងអ្នកដទៃទេ ហើយប្រសិនបើពួកគេមានវ៉ាលីធំៗវិញ ពួកគេខិត ខំព្យាយាមដាក់វាឱ្យនៅក្បែរខ្លួន ដើម្បីកុំឱ្យវាទើសទៅដល់អ្នកដទៃ ហើយពួកគេក៏ មិនបង្កសម្លេង រំខានទៅដល់អ្នកដទៃផងដែរ។ ជនជាតិមួយនេះមានភាពឯករាជ្យនៅក្នុងខ្លួនច្រើន ពួកគេចូលចិត្ត ពឹងផ្អែកទៅលើខ្លួនឯងមុននឹងពួកគេពឹងផ្អែកទៅលើអ្នកដទៃ។ គេអាចសង្កេតឃើញជនជាតិជប៉ុន ចាស់ៗជាច្រើន អ្នកខ្លះកាន់ឈើច្រត់ អ្នកខ្លះទៀតអាចនឹងពិការត្រង់ណាមួយ ប៉ុន្តែពួកគេព្យាយាម ធ្វើដំណើរដោយខ្លួនឯងដោយមិនមានអ្នកណាមកជួយ ឬមកជូនដំណើរអ្វីនោះទេ។ អ្វីដែលពួកគាត់អាចធ្វើដោយខ្លួនឯងបាន ពួកគេខិតខំធ្វើដោយខ្លួនឯងតែម្តង។

## ៥.៣.៤. គិតគូពីមនុស្សនៅជុំវិញខ្លួន

ជនជាតិមួយនេះគិតចិត្តអ្នកដទៃណាស់។ ប្រសិនបើជា នៅក្នុងអាហារដ្ឋានមួយ ពួកគេកំពុងតែទទួលទានអាហារតាម

ធម្មតា ប៉ុន្តែនៅខណៈពេលនោះ មានភ្ញៀវជាច្រើនទៀតកំពុងឈរចាំ ដើម្បីបានកន្លែងអង្គុយ នោះពួកគេគេខិតខំញ៉ាំអាហារឱ្យបានលឿនបំផុត ដើម្បីធ្វើយ៉ាងណាសល់កន្លែងនេះអាចឱ្យអ្នកផ្សេងមកអង្គុយទទួលទានអាហារ ជាមួយគ្នាបានដែរ ហើយប្រសិនបើពួកគេក្រោកចេញពីតុកៅអីណាមួយ ពួកគេនឹងរៀបតុកៅអីនោះឱ្យបានស្អាត់ឡើងវិញ ទោះបីជាវាមិនមែនជាកតព្វកិច្ចរបស់ពួកគេក៏ដោយ ដោយសារតែពួក គេគិតថា ការធ្វើទង្វើបន្តិចបន្តួចនេះអាចជួយសម្រួលដល់អ្នកដែលគេរង់ចាំរៀបចំពីក្រោយយើង ហើយការនេះបង្ហាញពីការយកចិត្តទុកដាក់របស់ពួកគេទៅកាន់អ្នកដែលកាន់ការងារមួយនេះ ដែលអាចឱ្យអ្នកកាន់ការងារនោះមានអារម្មណ៍កក់ក្ដៅ និងសប្បាយចិត្តពេញមួយថ្ងៃបាន។

## ៥.៣.៥. ជួយចេញពីចិត្ត

បើអ្នកទាំងអស់គ្នាទៅដើរលេងនៅជប៉ុន ហើយអ្នកទាំងអស់គ្នា វង្វេងផ្លូវ ឱ្យតែអ្នកទាំងអស់គ្នារកឃើញជនជាតិជប៉ុនណាម្នាក់ នោះអ្នកទាំងអស់គ្នានឹងមានអារម្មណ៍កក់ក្ដៅ ពួកគេនឹងព្យាយាមប្រាប់អ្នកទាំងអស់គ្នា ថាអ្នកទាំងអស់គ្នាគួរទៅកន្លែងណា បើ សិនជាអាច ពួកគាត់អាចនឹងនាំអ្នកទាំងអស់គ្នាទៅដល់កន្លែងដែលអ្នកទាំងអស់គ្នាត្រូវទៅតែម្ដង។ នេះគឺជាការជួយមួយដែលចេញពីចិត្ត។ ជនជាតិខ្មែរយើងក៏មានលក្ខណៈបែបនេះដែរ គឺការជួយ ដោយសុទ្ធចិត្ត។

## ៥.៣.៦. មានវិន័យ

អ្នកកម្រនឹងឃើញជនជាតិជប៉ុនបោះចោលសម្រាមផ្ដេសផ្ដាស់ណាស់ ផ្ទុយមកវិញយើងមានតែឃើញពួកគេរើសសម្រាមដែលអ្នកដទៃបោះចោលទៅដាក់ក្នុងធុងសម្រាម វិញទៀត។ ពួកគេមានសណ្ដាប់ធ្នាប់ មិនបង្កភាពរញ៉េរញ៉ៃ មិនចោលសម្រាមផ្ដេសផ្ដាស ប្រសិន បើពួកគេទៅដល់កន្លែងណា ក៏មិនបង្កការរំខានទៅដល់អ្នកនៅជាមួយពួកគេដែរ។ ខ្ញុំធ្លាប់ឮគេនិ យាយថា ជនជាតិជប៉ុនចូលចិត្តតម្រង់ជួរ តាមពិតទៅ នេះគឺជាវិន័យរបស់ពួកគេ ប្រសិនបើពួកគេ ចូលក្នុងបន្ទប់ទឹក បើមានមនុស្សច្រើនត្រូវរង់ចាំពួកគេត្រូវឈរតម្រង់ជួរចាំចូលម្នាក់ម្ដងៗ ពុំមាន អ្នកណាប្រជ្រៀតដណ្ដើមចូលមុននោះទេ។

## ៥.៣.៧. មានការអត់ធ្មត់ខ្ពស់

មានសំណួរមួយ បើសិនអ្នកទាំងអស់គ្នាចង់ញ៉ាំអាហារនៅក្នុង ហាងមួយ ប៉ុន្តែហាងមួយនោះមានមនុស្សរង់ចាំច្រើនមែនទែន តើអ្នកគិតថា ត្រូវតែរង់ចាំដើម្បីអាច ដល់ពេលខ្លួនឯងបានចូលញ៉ាំនោះ ឬក៏យកពេកពេលហ្នឹងទៅរកកន្លែងផ្សេងដើម្បីញ៉ាំវិញ? មនុស្សដែលមិនសូវមានការអត់ធ្មត់ នឹងគិតថា ខ្ជិលចាំណាស់ ខ្ញុំទៅរកកន្លែងផ្សេងដើម្បីញ៉ាំវិញ ល្អជាងខុសត្រូវគ្នាបន្តិចបន្តួចមិនអីទេ។ ប៉ុន្តែសម្រាប់ជនជាតិជប៉ុនវិញ បើសិនពួកគេចង់ញ៉ាំនៅ កន្លែងហ្នឹងហើយ ពួកគេសុខចិត្តចំណាយពេលវេលាឈររង់ចាំនៅកន្លែងនោះ រហូតដល់ពួកគេ អាចចូលទៅញ៉ាំនៅកន្លែងហ្នឹងបាន។ តើជនជាតិជប៉ុនមិនឱ្យតម្លៃទៅលើពេលវេលាឬ?មិនមែនបែបនេះទេ តាមពិតទៅជនជាតិជប៉ុនឱ្យតម្លៃទៅលើពេលវេលាណាស់ ដូចដែលយើងបានជជែកគ្នានៅ ខាងលើរួចមកហើយ ប៉ុន្តែពួកគេគិតថា ការចំណាយពេលរង់ចាំរបស់ពួកគេមានប្រសិទ្ធិភាព ពួក គេនឹងទទួលបានលទ្ធផលមួយដែលគាប់ចិត្តរបស់ពួកគេ។ ការចំណាយពេលកន្លះម៉ោងមួយម៉ោង ឬពីរម៉ោងរបស់ពួកគេក្នុងការរង់ចាំនេះ អាចផ្តល់មកឱ្យពួកគេវិញនូវអាហារមួយដ៏ឆ្ងាញ់ពិសា។ ប៉ុន្តែ សម្រាប់អ្នកដែលមិនរង់ចាំវិញ គេនឹងអាចទទួលបាននូវអាហារមួយពេលដូចគ្នា ប៉ុន្តែមិនមែន ជាអាហារមួយពេលដែលឆ្ងាញ់ដូចអ្វីដែលពួកគេចង់បាននោះទេ ហើយបើពួកគេនៅឈ រង់ចាំនៅ ក្នុងការប្រើប្រាស់សេវាកម្មណាមួយយូរ ពួកគេមិនដែលរហូតរ៉ា ឬនិយាយអ្វីទេ។

## ៥.៣.៨. គោរពសិទ្ធិនិងតួនាទីរបស់អ្នកដទៃ

បើមានជនជាតិជប៉ុនចូលទៅកាន់ស្ថាប័នណា មួយ ហើយគេប្រាប់អំពីគោលការណ៍ស្ថាប័ននោះ ជនជាតិជប៉ុននឹងរីករាយទទួលយកគោលណ៍ ទាំងនោះ ហើយគោរពទៅតាមគោលការណ៍របស់គេទាំងអស់ បើពួកគេទទួលយកបានពួកគេនឹងធ្វើ តែបើពួកគេទទួលយកមិនបានទេ ពួកគេនឹងដើរចេញដោយសុជីវធម៌ ពួកគេមិនតវ៉ាឱ្យអ្នកដទៃ ផ្លាស់ប្តូរគោលណ៍របស់គេដើម្បីតែខ្លួនឯងនោះទេ គឺពួកគេយល់អំពីគោលការណ៍ នៅក្នុងស្ថាប័ន នីមួយៗ ហើយពួកគេគោរពទៅដល់ស្ថាប័ននោះ។ ចំពោះអ្នកដែលមិនគោរពតួនាទីការងាររបស់ អ្នកដទៃវិញ ពួកគេតែងតែតវ៉ាឱ្យអ្នក

ដទៃផ្លាស់ប្តូរអ្វីមួយសម្រាប់តែខ្លួនគេ ឬក៏ពួកគេរអ៊ូរទាំ ពៀបជ្រាយ និយាយឌឺដងបែបនេះ បែបនោះជាដើមៗ ទាំងនេះមិនមែនជាអាកប្បកិរិយាល្អនោះ ទេៗ

## ៥.៣.៩. ការរស់នៅស្អាត

ប្រហែលជាអ្នកទាំងអស់គ្នាយល់ដឹងដែរ អំពីការរស់នៅស្អាតរបស់ ជនជាតិជប៉ុនៗ ការរស់នៅស្អាត់នៅទីនេះ គឺចង់និយាយសំដៅទៅលើការមានសណ្តាប់ធ្នាប់ៗ ទីក្រុងរបស់គេស្អាត មិនមែនស្អាតតែនៅលើផ្លូវថ្នល់ ដើមឈើរបស់រដ្ឋាភិបាលនោះទេ គឺស្អាតទាំង ផ្ទះរបស់ប្រជាជននៅតាមផ្លូវថែមទៀតៗ ជនជាតិជប៉ុនមានទម្លាប់រស់នៅស្អាត មានអនាម័យតាំងពីដើមរៀងមកៗ ពួកគេជឿថា ការសំអាតស្អាតៗនេះ ធ្វើឱ្យពួកគេមានសុខភាពល្អមានអាយុវែង ហើយនិងនាំលាភសក្ការៈចូលមកក្នុងផ្ទះរបស់ពួកគេៗ ហេតុនេះគេអាចនឹងស្រមៃលមើល បើមាន ផ្លូវថ្នល់ស្អាត មានអំពូលភ្លើង មានការរៀបចំនៅខាងក្រៅស្អាត ប៉ុន្តែនៅតាមផ្ទះបែរជាគគ្រិច តើទី ក្រុងនោះអាចនឹងស្អាតបានទេ? គឺវាមិនអាចស្អាត់ទៅរួចទេៗ ពួកគេយល់ថា នៅតាមផ្លូវស្អាត ផ្ទះ ប្រជាជនស្អាត ស្អាតទាំងក្នុង ស្អាតទាំងក្រៅ នោះទីក្រុងរបស់ពួកគេនឹងស្រស់ស្អាតខ្លាំងជាមិនខានៗ

## ៥.៣.១០. ធ្វើការងារប្រកបដោយវិជ្ជាជីវៈ

លោកអ្នកប្រហែលជាធ្លាប់ជួបបទពិសោធន៍ថា ពេល យើងមានបញ្ហាមួយកើតឡើង ហើយយើងទៅរកស្ថាប័នណា មួយ ជួយ ដោះស្រាយៗ យើងខំនិយា យ អំពីបញ្ហា របស់ យើងប្រាប់បុគ្គលិក ក នេះរួចហើយ តែនៅពេលបុគ្គលិក ក នេះមិននៅ យើងជួប នឹងបុគ្គលិក ខ បុគ្គលិក ខ នេះមិនដឹងអ្វីទាល់តែសោះ ហើយ យើងមិនអាចរកអ្នកណាមកជួយដោះ ស្រាយបញ្ហាដែលយើងបានប្រាប់ទៅរួចមកហើយនោះៗ ពួកគេអាចរុញដាក់អ្នកនេះ រុញដាក់អ្នក នោះរុញចុះ រុញឡើង បញ្ហារបស់យើងមិនត្រូវបានដោះស្រាយ ទាល់តែសោះៗ តែសម្រាប់ជនជាតិ ជប៉ុនវិញ ប្រសិនបើការងារនេះគឺជាការងារដែលយើងបាននិយា យជាមួយ គេហើយ បើទោះបីជាបុគ្គលិក ក នេះមិននៅក៏ដោយ បុគ្គលិក ខ គ យដែលនៅទាំងអស់គ្នា ឱ្យតែពួកគេឋិតនៅក្នុងតួនាទី ដែល ទាក់ទងជាមួយអតិថិជន គឺពួកគេដឹងពីបញ្ហារបស់អ្នកទាំង

អស់។ ភាពខុសគ្នានោះគឺឋិតនៅ ត្រង់ការងារក្រុមរបស់ពួកគេ បើទោះជាបុគ្គលិកនេះមិននៅ ក៏គេផ្តែផ្តាំទៅកាន់បុគ្គលិកដែលពាក់ព័ន្ធ ដើម្បីផ្តល់សេវាកម្មមួយដ៏ល្អដល់អតិថិជនរបស់ពួកគេ។ ហេតុនេះ បើយើងទៅលើកក្រោយ គ្រាន់តែប្រាប់ពីឈ្មោះរបស់យើង គឺពួកគេដឹងថាបញ្ហារបស់យើងគឺជាអ្វីតែម្តង។

## ៥.៣.១១. ភាពរហ័សរហួន

កាលពីចំណុចមុន យើងបាននិយាយរួចម្តងមកហើយ អំពីការឱ្យតម្លៃពេលវេលារបស់ជនជាតិជប៉ុន។ ជនជាតិជប៉ុនតែងតែមានការគិតមួយថា ពេលវេលាគឺមានតម្លៃណាស់។ ហេតុនេះ ពេលវេលាមួយនាទីៗរបស់ពួកគេនោះ គឺពួកគេធ្វើយ៉ាងណា ប្រើប្រាស់ពេលវេលាឱ្យអស់ពីលទ្ធភាព។ បើគេបានឃើញស្ថានីយ៍រថភ្លើងជនជាតិជប៉ុន នោះគេនឹងឃើញថា ជន ជាតិជប៉ុនដើរលឿនៗណាស់ គឺសឹងតែរត់តែម្តង។ ភាពរហ័សរហួនបែបនេះ ធ្វើឱ្យពួកគេចំណេញ ពេលវេលាបានច្រើន។

## ៥.៣.១២. មានការយោគយល់ច្រើន

ប្រជាជនជប៉ុនទូទៅ តែងតែមានការយោគយល់ទៅលើ មនុស្សចាស់, ស្ត្រីមានផ្ទៃពោះ, ឬក៏ស្ត្រីដែលមានកូនតូចៗ ពួកគេផ្តល់អាទិភាពឱ្យអ្នកទាំងនោះបានដើរទៅមុន ឬក៏ទទួលបានសេវាកម្មមុនពួកគេ។ តែបើយើងជាភ្ញៀវទេសចរណ៍វិញ ដែលមិនចេះភាសាជប៉ុនទៅលេងនៅជប៉ុន ពួកគេខិតខំព្យាយាមពន្យល់យើងមួយៗឱ្យយើងយល់ មានការពន្យល់ ជារូបភាពផង ជាកាយវិការផង ឬក៏ប្រើហ្គូហ្គលបកប្រែ ដើម្បីជួយសម្រួលទៅដល់យើង ដែលធ្វើឱ្យ យើងមានអារម្មណ៍កក់ក្តៅ។

## ៥.៣.១៣. ហាត់ប្រាណជាប្រចាំ

ជាទៅ ជនជាតិជប៉ុនមានទម្លាប់ក្រោកហាត់ប្រាណពេលព្រឹក ក្រោមពន្លឺព្រះអាទិត្យ។ ពួកគេអាចហាត់ជាក្រុម ឬក៏ហាត់ម្នាក់ឯង។ តែបើពួកគេមិនបានក្រោកហាត់នៅពេលព្រឹកដោយខ្លួនឯងទេ ក៏ពួកគេតម្រូវឱ្យមានការហាត់ប្រាណមួយផ្សេងទៀតដែរ នោះគឺ ការធ្វើដុះណើរនេះឯង។ ថ្វីត្បិតតែជនជាតិជប៉ុន ជាទូទៅតែងតែប្រើសេវាសាធារណៈនៅក្នុងការធ្វើ ដំណើរពី

កន្លែងធ្វើការទៅផ្ទះ និងពីផ្ទះទៅកន្លែងធ្វើការ ឬក៏ទៅទីកន្លែងផ្សេងក៏ដោយ គឺពួកគេត្រូវតែ ដើរពីផ្ទះទៅស្ថានីយ៍។ ស្ថានីយ៍រថភ្លើងរបស់ពួកគេមានទំហំធំៗណាស់ ហេតុដូចនេះ ពួកគេត្រូវតែចំណាយពេលដើរឱ្យស្រែកគីឡូ។ ហេតុដូចនេះហើយបានជាគេតែងសង្កេតឃើញជនជាតិជប៉ុនមាន រាងសមសួន និងមានសុខភាពល្អ។

## ៤.៣.១៤. បរិភោគអាហារល្អៗ

នៅតាមសាលារៀនជាពិសេសតែម្តង គឺពួកគេតែងតែមានឈុត អាហារសម្រាប់សិស្សានុសិស្សរបស់គេជារៀងរាល់ថ្ងៃ។ ឈុតអាហារទាំងនោះមានដូចជា បាយ, បន្លែ, ស៊ុត, សាច់, ពោលគឺមានគ្រប់ជីវជាតិទាំងអស់ដើម្បីផ្តល់ទៅឱ្យសិស្ស។ អ្នករៀបចំអាហារបាន គិតទៅដល់ថាតើក្នុងម្ហូបមួយមុខៗមានកាឡូរីប៉ុន្មាន មានជីវជាតិប៉ុន្មានដើម្បីឱ្យសិស្សទទួលទាន ទៅទទួលបានថាមពល មិនឈឺពោះ និងមិនមានបញ្ហាសុខភាពជាដើម។ ជនជាតិជប៉ុនមិនចូល ចិត្តញ៉ាំអាហារហិរៗពេកទេ ព្រោះវាប៉ះពាល់ទៅដល់សុខភាព។

## ៥.៣.១៥. ប្រើគោលការណ៍ខៃហ្សេន(Kaizen) នៅក្នុងការរស់នៅ

គោលការណ៍ខៃហ្សេននេះ គឺជាគោលការណ៍ផ្លាស់ប្តូរអ្វីមួយ ដែលចេញអំពីការបន្សាំបន្តិចម្តងៗទៅនឹងបច្ចុប្បន្នភាព។ ឧបមាថា ប្រសិន បើយើងនៅក្នុងភោជនីយដ្ឋានមួយ ជាដំបូងគេជួលមនុស្សឱ្យរត់តុ ធ្វើម្ហូប និងគិតលុយជាដើម ប៉ុន្តែគេចង់ធ្វើបច្ចុប្បន្នភាពវាការគិតលុយដោយម៉ាស៊ីនស្វ័យប្រវត្តិ ហើយមាន ម៉ាស៊ីនបញ្ជាម្ហូបស្វ័យប្រវត្តិ គេមិនផ្លាស់ប្តូរវាភ្លាមៗនៅក្នុងពេលតែមួយនោះទេ គឺគេដាក់ម៉ាស៊ីន ជាមួយនឹងមនុស្សម្នាក់ដើម្បីចាំជួយប្រាប់យើងថា តើត្រូវចុចម៉ាស៊ីននោះយ៉ាងមួយ។ ហេតុនេះ គេ ត្រូវបន្សាំយើងបន្តិចម្តងៗរហូតដល់ចេះចាំស្ទាត់ក្នុងការកម្ម៉ង់ម្ហូប ក្រោយមកទើបគេចាប់ផ្តើមដាក់ម៉ាស៊ីនមួយទៀត គឺម៉ាស៊ីនគិតលុយ ហេតុនេះ គេត្រូវមានមនុស្សម្នាក់ទៀត ដើម្បីបង្រៀនយើងពី របៀបគិតលុយយ៉ាងណាមួយ។ នៅពេលយើងស៊ាំនៅក្នុងការប្រើប្រាស់ម៉ាស៊ីនទាំងពីរនេះហើយ គេក៏ចាប់ផ្តើមដកមនុស្សចេញ ដើម្បីឱ្យយើងប្រើជាមួយនឹងម៉ាស៊ីនសុទ្ធតែម្តង។ ហេតុ

នេះ យើងអាចបន្សាំខ្លួនបានដោយមិនមានការលំបាកអ្វីឡើយ។ គោលការណ៍នេះក៏ប្រជាជនជប៉ុនប្រើដើម្បីអភិវឌ្ឍន៍ប្រទេសរបស់គេដែរ គឺគេបន្សាំប្រជាជនរបស់គេបន្តិចម្តងៗរហូតដល់ពួកគេអាចទទួលយកបានៗតាមពិតទៅ គោលការណ៍ខៃហ្សេននេះមិនត្រឹមតែប្រើប្រាស់នៅក្នុងប្រទេសជប៉ុនទេ គឺមាន ប្រើប្រាស់នៅក្នុងសហរដ្ឋអាមេរិក ក៏ដូចជាប្រទេសជាច្រើនទៀតនៅក្នុងពិភពលោកផងដែរ[៩]។

## សេចក្តីសន្និដ្ឋាន

ទម្លាប់ដើមដំបូងគឺចាប់ផ្តើមឡើងដោយបញ្ញា តែដល់វាវិវត្តទៅជាទម្លាប់ពេញលេញ វាលែងមានជាតុបញ្ញាទៀតហើយ។ ទម្លាប់ បើកើតឡើងដោយបញ្ញានៅក្នុងបរិបទវិចារណញ្ញាណ (សម្មាសង្កប្ប និងសម្មាទិដ្ឋិ) វាជាទម្លាប់ល្អ អាចឱ្យគេទុកចិត្តបាន ប៉ុន្តែ បើវាកើតឡើងដោយឥន្ទ្រិយពុទ្ធិ វាជាទម្លាប់អាក្រក់ មិនអាចឱ្យគេទុកចិត្តបានទេ។ ឧទាហរណ៍ ទម្លាប់កាន់ព្រះពុទ្ធសាសនាតៗគ្នាពីឪពុកម្តាយមកកូនតៗជំនាន់ ដែលមិនមែនជាការ ទទួលយកដោយយល់ ឬដោយរៀនសូត្រច្បាស់លាស់ជាដើម។ ទម្លាប់អាក្រក់ តែបើកាលណាវាកើតឡើងនៅចំពោះអ្នកណាហើយ អ្នកនោះមិនងាយនឹងលះបង់ចោលទេ ព្រោះទម្លាប់អាក្រក់កើតឡើងមកពីអវិជ្ជា គឺទម្លាប់ដែលកើតឡើងមកពីឥន្ទ្រិយពុទ្ធិនេះឯង។

ហេតុនេះ ចូរកុំគិតថា យើងធ្លាប់ធ្វើអ្វី សំខាន់យកបញ្ញាមកគិត បើយល់ថាត្រូវទទួលយក តែបើគិតថាខុសលះចោល។ គេអាចពិនិត្យផ្ទៀងផ្ទាត់ទម្លាប់ដើម្បីរកសច្ចភាពដែលអាចទុកចិត្តបានតាមយៈ *វិបាក* (consequence) របស់វា។ បើវិបាករបស់វាជាសុខ និងចម្រើនដល់ទាំងអ្នកប្រព្រឹត្ត និងអ្នកដទៃ ទម្លាប់នេះល្អ ប៉ុន្តែបើវាឱ្យវិបាកផ្ទុយពីនេះ វាជាទម្លាប់អាក្រក់។

ពួកស្តេចលេច្ឆវី បានលើកសំណួរសួរព្រះពុទ្ធថា មានវិធីសាស្ត្រដឹកនាំច្រើនណាស់ លោកគ្រូនេះថាបែបនេះ លោកគ្រូនោះថាបែបនោះ ចុះព្រះអង្គថាដូចម្តេចដែរ?

ព្រះពុទ្ធលោកត្រាស់ថា “ម្នាលលេច្ឆវីទាំងឡាយ អ្នកទាំងឡាយស្តាប់ក៏ស្តាប់ទៅ កុំបដិសេធ អី មានវិធីដឹកនាំ

[៩] ឈួន ច័ន្ទធីតា, *ទម្លាប់ល្អ១៥យ៉ាងរបស់ជនជាតិជប៉ុន*, YouTube

*ច្រើនណាស់ ប៉ុន្តែ អ្នកកុំបោះបង់ខួរក្បាលរបស់អ្នកចោល អ្នកត្រូវយកមកគិតពិចារណា ដោយល្អិតល្អន់ រាល់ពាក្យដែលគេផ្សព្វផ្សាយនោះ ប្រសិនបើវាមិនបាត់បង់ប្រយោជន៍ខ្លួនឯង និងអ្នកដទៃតែវាប្រព្រឹត្តទៅដើម្បីប្រយោជន៍ខ្លួនឯងនិងអ្នកដទៃ អ្នកត្រូវទទួលយកទៅកុំគិតថាពាក្យនោះចេញពីប្រភពណា ជាពាក្យរបស់តថាគតក៏ដោយ ជាពាក្យរបស់ឥសីក៏ដោយ ឬជា ពាក្យរបស់អ្នកណាមួយក៏ដោយ ឱ្យតែវាពិត និងមានប្រយោជន៍។ ក៏ប៉ុន្តែ ពាក្យណាក៏ដោយ ទោះបីវាមានតំណ១០០ឆ្នាំ ២០០ឆ្នាំ រាប់ម៉ឺនឆ្នាំក៏ដោយ បើអ្នកពិចារណាដោយល្អិតល្អន់ហើយវាអត់ ពិត ឥតមានប្រយោជន៍ អ្នកត្រូវតែលះបង់ចោល។*

*ដូចគ្នានេះដែរ ចិត្តមានជំពៅរបស់យើង បើទោះជាវានៅជាមួយរាងកាយយើងយូរប៉ុណ្ណាក៏ដោយ ធ្មេញដែលយើងស្រលាញ់ណាស់ តែបើវាត្រូវដង្កូវស៊ីអស់ហើយ គឺត្រូវតែដកចោល។ យើងមិនមែនក្បត់វាទេ តែវាក្បត់យើង ព្រោះវាធ្វើឱ្យយើងឈឺ។ យ៉ាងណាមិញ នៅក្នុងនាមធម៌នៅក្នុងចិត្តរបស់យើងដូចគ្នា បើវាបង្កើតទិដ្ឋិ បង្កើតទៅនាំឱ្យយើងវង្វេងផ្លូវកាន់តែច្រើនគឺត្រូវតែ លះបង់ចោល ដោយមិនគិតថាវាជារបស់ជីដូនជីតាផ្ដល់ឱ្យនោះទេ។*

## គន្ថនិទ្ទេស


### I- **ព្រឹត្តិប័ត្រ**, **ទស្សនាវដ្ដី**, **សារពត៌មាន និង** Internet

១- *ខ្សែអាត់សម្លេង កិច្ចសម្ភាសអក្សរ សាស្ត្រខ្មែរ ដោយសម្ដេចព្រះមហា សុមេធាធិបតី ជោតញ្ញាណោ* ***ជួន ណាត*** *អំពីវិហារបែរ មុខទៅកើត*

២- ឈួន ច័ន្ទធីតា, *ទម្លាប់ល្អ១៥យ៉ាងរបស់ ជនជាតិជប៉ុន*, YouTube

### II- **ស្នាដៃនិពន្ធជាភាសាខ្មែរ**

*១- យឹង ហុកឌី "ក្រមង៉ុយ និង ស្នាដៃ" គ្រឹស្ថានបោះពុម្ព ផ្សាយអង្គរ ភ្នំពេញ, ២០០៨*

*២- ជួនណាត វចនានុក្រមខ្មែរ រក្សាសិទ្ធិ ដោយវិទ្យា ស្ថានពុទ្ធសាសនបណ្ឌិត្យ, ២០០៨*

*៣- ឥន្ទ ឱមសាម៉េង, "ប្រវត្តិទស្សនៈ, សាសនា, សិលធម៌, នយោបាយ", សាកលវិទ្យាល័យនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច, ២០០៥*

### III- **ស្នាដៃនិពន្ធជាភាសាអង់គ្លេស**

1.Venancio B.Ardales, *"Introductory text to philosophy, "* 2nd printing,New York,1974,

# ការវិនិយោគនាំជោគជ័យដល់កម្ពុជា

ដោយៈ បណ្ឌិត **មិន ប្រុសបញ្ញារិទ្ធិ**
មន្ត្រីនាយកដ្ឋាននីតិសាស្ត្រ
នៃវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម
រាជបណ្ឌិត្យសភាកម្ពុជា
E-mail: prosepanharithmin@gmail.com

## សេចក្តីផ្តើម

*វិនិយោគ គឺជាវេវចនសព្ទ ជាមួយពាក្យការបណ្តាក់ទុន។ វិនិយោគ ជាការបណ្តាក់ទុនធ្វើអាជីវកម្មក្នុងការបង្កើតរោងចក្រ សហគ្រាស កសិដ្ឋាន ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ឬសេវាអ្វីមួយដើម្បីបានទទួលប្រាក់ចំណេញ។ ម្យ៉ាងទៀតវិនិយោគក៏ជាការប្រើប្រាស់ដើមទុន ដើម្បីបង្កើតផលិតផល ឬដើម្បីកែលម្អទិន្នផលនៃសហគ្រាសណាមួយ។*

*ដូច្នេះវិនិយោគ គឺជាការបណ្តាក់ទុនរយៈពេលយូរនៅក្នុងប្រទេស ឬក្រៅប្រទេស នៅក្នុងសហគ្រាសឧស្សាហកម្ម កសិកម្ម ការដឹកជញ្ជូនពាណិជ្ជកម្ម និងមែកធាងសេដ្ឋកិច្ចនានា ក្នុងបំណងដើម្បីជាការបង្កើតជាប្រាក់ចំណេញ។ ដើម្បីធ្វើវិនិយោគយើងត្រូវមានគម្រោងវិនិយោគ ដូចម្តេចដែលហៅថាគម្រោងវិនិយោគ? គម្រោងវិនិយោគ សំដៅដល់គម្រោងដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ គម្រោងពង្រីកនៃគម្រោងវិនិយោគមានលក្ខណៈគ្រប់គ្រាន់ និងគម្រោងវិនិយោគដែលទទួលបានត្រឹមតែការធានាលើការវិនិយោគ។*

*គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ (គ.ល.គ.) សំដៅដល់គម្រោងវិនិយោគដែលទទួលបានវិញ្ញាបនបត្រចុះបញ្ជីពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឬអនុគណៈកម្មាធិការវិនិយោគរាជធានីខេត្ត។ គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់បម្រើឱ្យការនាំចេញ សំដៅដល់ (គ.ល.គ.)ដែលបានលក់ ឬបានផ្ទេរសមាមាត្រណាមួយនៃផលិតផលរបស់ខ្លួនទៅឱ្យអ្នកទិញ ឬអ្នកទទួលនៅក្រៅព្រះរាជាណាចក្រកម្ពុជា។ គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែលជាប្រភេទឧស្សាហកម្មគាំទ្រ សំដៅដល់ (គ.ល.គ.) ដែលផលិតផលរបស់ខ្លួនក្នុងសមាមាត្រណាមួយត្រូវផ្គត់ផ្គង់ដល់ឧស្សាហកម្ម នាំចេញ។ គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់បម្រើទីផ្សារក្នុងស្រុក សំដៅដល់ (គ.ល.គ.)ដែលមិនបម្រើឱ្យការនាំចេញ។ គម្រោងពង្រីកនៃគម្រោងវិនិយោគមានលក្ខណៈ សម្បត្តិគ្រប់គ្រាន់ (គ.ព.គ.ល.គ.) សំដៅដល់ការពង្រីកនៃ គ.ល.គ. ដែលធ្វើឡើងតាមរូបភាពណាមួយ មានជាអាទិ៍ ការពង្រីកផលិតកម្មដែលមានស្រាប់ ការពង្រីក*

តាមរយៈការធ្វើពិពិធកម្មមុខសញ្ញាផលិតកម្ម ដែលស្ថិតក្នុងខ្សែស្រឡាយផលិតផលជាមួយគ្នា ការពង្រីកតាមរយៈការបំពាក់បច្ចេកវិទ្យាទំនើបថ្មីដែលលើកកម្ពស់ផលិតភាព ឬការពារបរិស្ថាន ការពង្រីកហេដ្ឋារចនាសម្ព័ន្ធបម្រើឱ្យសេវាទូរគមនាគមន៍មូលដ្ឋាន ឬ ការពង្រីកក្រោមរូបភាពផ្សេងទៀត ដែលនឹងត្រូវកំណត់ដោយអនុក្រឹត្យតាមច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា។

វិនិយោគគឺជាផ្នែកមួយនៃសេដ្ឋកិច្ចដែលជាប្រព័ន្ធសកម្មភាពរបស់មនុស្ស ជាសមូហភាពទាក់ទិនទៅនឹងផលិតកម្ម ការបែងចែក និង ការប្រើប្រាស់ធនធាន។ លំហូរវិនិយោគទាំងក្នុងប្រទេស និង មកពីក្រៅប្រទេស គឺ ជាកត្តាជំរុញចលនាសេដ្ឋកិច្ចឱ្យកាន់មានសន្ទុះខ្លាំងឡើងនិង មានកំណើនមួយកម្រិតថែមទៀត។ ការធ្វើសមាហរណកម្មកម្ពុជា ចូលទៅក្នុងសេដ្ឋកិច្ចតំបន់និងពិភពលោកគឺជាយុទ្ធសាស្ត្រ ដ៏សំខាន់សម្រាប់ជំរុញការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។ ប្រទេសកម្ពុជាបានចូលជាសមាជិកនៃសមាគមន៍ សេដ្ឋកិច្ចអាស៊ាន ដែលជាតំបន់ពាណិជ្ជកម្មសេរី មានប្រជាជនជាងប្រាំមួយរយលាននាក់ មានទីផ្សារធំទូលាយ។កម្ពុជា ជាភាគីហត្ថលេខីមួយនៃកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីរវាងអាស៊ាន និង ប្រទេស ឬ តំបន់ដៃគូ, ការបង្កើនការតភ្ជាប់ខាងផ្នែកហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និង អរូបវន្ត ជាមួយនឹងប្រទេសក្នុងតំបន់, ការកែលម្អជាលំដាប់នូវក្របខណ្ឌគតិយុត្ត និងស្ថាប័ន, និង ការធ្វើពិពិធកម្ម ទីផ្សារជាដើម។ ទាំងក្នុងក្របខណ្ឌទ្វេភាគី និង ក្របខណ្ឌអាស៊ានកម្ពុជា បានពង្រឹងទំនាក់ទំនងធុរកិច្ចយ៉ាងសកម្មតាមរយៈ ការចូលរួមក្នុងវេទិកាធុរកិច្ច ការតាំងពិព័ណ៌ និង ការចាប់ដៃគូអាជីវកម្មនានា។ ការប្រឹងប្រែងទាំងអស់នេះ បានផ្តល់ផលជាកំណើននៃសកម្មភាពសេដ្ឋកិច្ចពាណិជ្ជកម្ម និង ការវិនិយោគ ដែលបានបង្កើតការងារសម្រាប់ប្រជាជនរាប់ម៉ឺននាក់។

ក្របខណ្ឌពាណិជ្ជកម្មនៅក្រោមអង្គការពាណិជ្ជកម្មពិភពលោកនិងអាស៊ាននៅតែមានសារៈសំខាន់សម្រាប់កម្ពុជា។ កម្ពុជាមិនត្រឹមតែបន្តខិតខំរក្សាឱ្យបាននូវទីផ្សារនាំចេញ ដែលខ្លួនមានក្នុងពេលបច្ចុប្បន្នប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងត្រូវប្រឹងប្រែងបើកច្រកចូលទីផ្សារសម្រាប់ការនាំចេញឱ្យកាន់តែធំទូលាយថែមទៀត ដោយផ្អែកលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី ដែលមានលក្ខណៈអចិន្ត្រៃយ៍ដើម្បីទំហំនៃវិមាត្រសេដ្ឋកិច្ច ដែលជាចលករដ៏ចម្បងមួយសម្រាប់ជំរុញ លើកកម្ពស់ កំណើនប្រកបដោយចីរភាព។ រាជរដ្ឋាភិបាលនឹងផ្តោតលើ៖ (១)ការបន្តខិតខំបំពេញនូវកាតព្វកិច្ចសេសសល់នានា ក្នុងក្របខណ្ឌអង្គការពាណិជ្ជកម្មពិភពលោក សហគមន៍សេដ្ឋកិច្ចអាស៊ាន និង ក្របខណ្ឌទ្វេភាគីជាពិសេសការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និង អរូបវន្ត, ព្រមទាំងការកែលម្អក្របខណ្ឌ

គតិយុត្ត ក៏ដូចជាការកសាងសមត្ថភាពស្ថាប័ន និង មនុស្ស ដើម្បីទាញយកចំណេញឱ្យបាន ជាអតិបរមាពីសមាហរណកម្ម និង ពីការ លើកកម្ពស់លំហូរពាណិជ្ជកម្ម និង ការវិនិយោគ នៅក្នុងតំបន់ និង ពិភពលោក។ (២) ការជំរុញបង្កើតតំបន់ពាណិជ្ជកម្មសេរីទ្វេភាគីជាមួយដៃគូពាណិជ្ជកម្មសំខាន់ៗ និង បង្កើតតំបន់ពាណិជ្ជកម្មសេរីពហុភាគី ជាមួយនឹងតំបន់សំខាន់ដូចជាតំបន់ អឺរ៉ាស៊ី សហគមន៍អឺរ៉ុប ព្រមទាំងកិច្ចព្រមព្រៀងភាពដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយ (RCEP) និង កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី ផ្សេងៗទៀត។ (៣)ការបន្តពង្រឹងការតភ្ជាប់ផ្នែកធុរកិច្ច ដោយរៀបចំឱ្យមានវេទិកាដំណើរទស្សនកិច្ច ឬ ការតាំងបង្ហាញផលិតផល សំដៅលើកកម្ពស់ ការចាប់ដៃគូពាណិជ្ជកម្ម និង ការស្វែងយល់អំពីតម្រូវការទីផ្សារ ព្រមជាមួយនឹងការបន្តជំរុញ ពិពិធកម្មទីផ្សារនាំចេញ។ (៤)ការបន្តជំរុញការចូលរួមដោយសកម្មរបស់កម្ពុជា ក្នុងកិច្ចសហប្រតិបត្តិការ និង គំនិតផ្តួចផ្តើមក្នុងផ្នែកសមាហរណកម្មសេដ្ឋកិច្ច នៅកម្រិតអន្តរជាតិ តំបន់ និង ទ្វេភាគី។ (៥)ការជំរុញកិច្ចសហប្រតិបត្តិការ និងការសម្របសម្រួលរវាងក្រសួងស្ថាប័នរបស់រដ្ឋាភិបាល និង គ្រប់តួអង្គអភិវឌ្ឍផ្សេងៗទៀត ក្នុងគោលដៅពង្រឹងសមត្ថភាព និង ប្រព័ន្ធជាតិ ដើម្បីកែលម្អនូវការផ្តល់សេវានិង ពង្រឹងភាពប្រកួតប្រជែងរបស់កម្ពុជា។(៦) ការបន្តកសាងសមត្ថភាពសម្រាប់ការតាមដាននិន្នាការពាណិជ្ជកម្មនៅគ្រប់វិស័យ។

តើការវិនិយោគមានខ្លឹមសារ ទាក់ទងនឹង**ច្បាប់វិនិយោគ**, **តំបន់ពាណិជ្ជកម្មសេរី** និង**ទំហំទីផ្សារ**យ៉ាងដូចម្តេច?

## ១.ច្បាប់វិនិយោគនៅព្រះរាជាណាចក្រកម្ពុជា

### ១.១. គោលបំណង

ក្នុងគោលបំណងបង្កើតនូវក្របខណ្ឌគតិយុត្ត ដែលបើកចំហ,មានតម្លាភាព, អាចប៉ាន់ប្រមាណទុកជាមុនបាន ប្រកបដោយភាពអំណោយផលសម្រាប់ការវិនិយោគ ដើម្បីទាក់ទាញនិងលើកកម្ពស់ការវិនិយោគ ដោយបុគ្គលសញ្ជាតិខ្មែរ ឬ បរទេស ប្រកបដោយគុណភាព ប្រសិទ្ធភាពនិង ប្រសិទ្ធផល សំដៅអភិវឌ្ឍសង្គម-សេដ្ឋកិច្ច នៅក្នុងព្រះរាជាណាចក្រកម្ពុជា ច្បាប់នេះជំរុញ៖ (១)ការបង្កើនភាពប្រកួតប្រជែងរបស់កម្ពុជា ដើម្បីធ្វើឱ្យរចនាសម្ព័ន្ធសេដ្ឋកិច្ចអាចធ្វើពិពិធកម្មនិងធន់ទៅនឹងវិបត្តិក្នុងតំបន់ និង សកលលោក។ (២)ការធ្វើទំនើបកម្ម ការបង្កើនផលិតភាពនៃឧស្សាហកម្មក្នុងស្រុក ការពង្រឹងការតភ្ជាប់ទៅក្នុងខ្សែច្រវាក់ផ្គត់ផ្គង់ក្នុងតំបន់ និង សកលលោកតាមរយៈ ការជំរុញកំណើនលំហូរចូលមូលធន ការផ្ទេរបច្ចេកវិទ្យា ចំណេះដឹង និង ចំណេះធ្វើ។ (៣)ការបង្កើតរបបលើកទឹកចិត្តវិនិយោគមួយ ដែលមានតម្លាភាព ភាពអាចប៉ាន់

ប្រមាណទុកជាមុនបាន គ្មានការរើសអើង មានលក្ខណៈប្រកួតប្រជែង និង គាំទ្រគោលនយោបាយ សង្គម-សេដ្ឋកិច្ច។ (៤)ការផ្ដល់ការការពារសិទ្ធិ និង ផលប្រយោជន៍ស្របច្បាប់របស់វិនិយោគិននៅព្រះរាជាណាចក្រកម្ពុជា តាមរយៈការបង្កើតនូវក្របខណ្ឌគតិយុត្តដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ និង មានតុល្យភាពស្របទៅនឹងផលប្រយោជន៍ជាតិ[1]។

### ១.២.ស្ថាប័នក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាគឺជាស្ថាប័នប្រតិបត្តិបំពេញមុខងារជាសេនាធិការ និង ជាច្រកចេញចូលតែមួយរបស់រាជរដ្ឋាភិបាល លើបេសកកម្មដឹកនាំ និង គ្រប់គ្រងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ ការវិនិយោគឯកជន និង តំបន់សេដ្ឋកិច្ចពិសេស[2]។ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មាននាយករដ្ឋមន្ត្រីជាប្រធាន ព្រមទាំងមានអនុប្រធានមួយរូប ឬ ច្រើនរូប និង សមាជិកមួយចំនួន តាមការចាំបាច់។ អាស្រ័យដោយឆន្ទានុសិទ្ធិរបស់ខ្លួន នាយករដ្ឋមន្ត្រីអាចប្រគល់សិទ្ធិដល់តស្សរជនជាសមាជិកនៃរាជរដ្ឋាភិបាលឬជាថ្នាក់ដឹកនាំនៃ ក.អ.ក.[3] ដើម្បីដឹកនាំជំនួសក្នុងកម្រិតណាមួយ ឬ ក្នុងផ្នែកណាមួយនៃការងាររបស់ ក.អ.ក. ក្នុងគោលដៅធានាប្រសិទ្ធភាពនៃការបំពេញបេសកកម្ម ដែលមានកំណត់ក្នុងមាត្រា៤ នៃច្បាប់នេះ រួមបញ្ចូលនូវការគ្រប់គ្រង និង ការចាត់ចែងប្រើប្រាស់ថវិកា និងធនធានមនុស្សដោយអនុលោមតាមច្បាប់ និង លិខិតបទដ្ឋានគតិយុត្តជាធរមាន។



Source:https://en.khmerpostasia.com/images.app.goo.gl/Council for the Development of Cambodia (CDC)//

### ១.៣.យន្តការវិនិយោគរាជធានីខេត្ត

ដើម្បីបង្កើនប្រសិទ្ធភាពក្នុងការផ្ដល់សេវាជូនវិនិយោគិន ការពិនិត្យ និង សម្រេចលើការវិនិយោគឯកជន និងការដោះស្រាយវិវាទពាក់ព័ន្ធនឹងគម្រោងវិនិយោគត្រូវធ្វើប្រតិភូកម្មទៅឱ្យរដ្ឋបាលរាជធានី ខេត្ត ស្របតាមការសម្រេចរបស់រាជរដ្ឋាភិបាល តាមរយៈការបង្កើតអនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្ត ធ្វើជាសេនាធិការ ឱ្យរដ្ឋបាលរាជធានី ខេត្ត។ សិទ្ធិ អំណាច ទំហំនៃ

---

[1] រាជរដ្ឋាភិបាលកម្ពុជា៖ ***ច្បាប់ស្ដីពីវិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា*** ភ្នំពេញ ក្រុមប្រឹក្សាអ្នកច្បាប់ ឆ្នាំ ២០២១ ទំព័រ ៣។

[2] -ដ- ទំព័រ ៥។

[3] ក.អ.ក. មានន័យថា ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។

ការវិនិយោគ និង ការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈកម្មាធិការវិនិយោគ រាជធានីខេត្ត ត្រូវកំណត់ដោយអនុក្រឹត្យដោយឡែក[4] ។

### ១.៤.ការចុះបញ្ជីនិងការអនុវត្តគម្រោងវិនិយោគ

បុគ្គលដែលមានបំណងអនុវត្ត គ.ល.គ. ឬ គ.ព.គ.ល.គ. ឬ គ.ធ.វ. ត្រូវដាក់សំណើសុំចុះបញ្ជីជាលាយលក្ខណ៍អក្សរនៅ ក.អ.ក. ឬ អនុគណៈកម្មាធិការវិនិយោគរាជធានីខេត្ត។ សំណើសុំចុះបញ្ជីគម្រោងវិនិយោគខាងលើនេះ អាចធ្វើឡើងតាមរយៈថ្នាលបច្ចេកវិទ្យាព័ត៌មាន។ សំណើសុំចុះបញ្ជីគម្រោងវិនិយោគត្រូវភ្ជាប់ជាមួយនូវព័ត៌មានមួយចំនួន ដែលនឹងកំណត់នៅក្នុងអនុក្រឹត្យ។ នៅពេលទទួលបានសំណើសុំចុះបញ្ជីគម្រោងវិនិយោគ ក.អ.ក. ត្រូវពិនិត្យ និង សម្រេចលើសំណើនេះតាមយន្តការច្រកចេញ-ចូលតែមួយ។ យន្តការច្រកចេញ-ចូលតែមួយក្នុងការពិនិត្យសំណើសុំចុះបញ្ជីគម្រោង វិនិយោគគឺជាយន្តការពិនិត្យ និង សម្រេចក្នុងការចុះបញ្ជីគម្រោងវិនិយោគដោយតំណាងក្រសួង ស្ថាប័ន ពាក់ព័ន្ធដែលប្រចាំការនៅ ក.អ.ក. ទៅតាមការចាត់តាំង និង ប្រតិភូកម្មសិទ្ធិអំណាចពីប្រធានក្រសួង ស្ថាប័ន ក្រោមការសម្របសម្រួលរបស់ ក.អ.ក.។

ប្រសិនបើគម្រោងវិនិយោគដែលត្រូវបានស្នើសុំនេះ មិនស្ថិតក្នុងបញ្ជីអវិជ្ជមានដែលនឹងត្រូវកំណត់ដោយឡែកដោយក្នុងអនុក្រឹត្យ ក.អ.ក. ត្រូវចេញវិញ្ញាបនបត្រចុះបញ្ជីជូនអ្នកដាក់ពាក្យសុំក្នុងអំឡុងពេលមិនលើសពី ២០ (ម្ភៃ)ថ្ងៃនៃថ្ងៃធ្វើការ។ វិញ្ញាបនបត្រចុះបញ្ជីត្រូវមានភ្ជាប់នូវ បាកូដដែលមានលេខសម្គាល់ ឬ យូអរកូដ ឬ ប្រព័ន្ធបច្ចេកវិទ្យាដទៃទៀត ដែលផ្ទុកទិន្នន័យបឋមមួយចំនួនពាក់ព័ន្ធនឹងគម្រោងវិនិយោគ ដែលត្រូវបានចុះបញ្ជី ដើម្បីជាប្រយោជន៍ដល់ការចុះបញ្ជីពាក់ព័ន្ធនានា និង សម្រាប់ការអនុវត្តគម្រោងវិនិយោគ[5]។ ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធនឹងការចុះបញ្ជី ពាក់ព័ន្ធនឹងការពិនិត្យអនុលោមភាពនៃការ អនុវត្តគម្រោងវិនិយោគមិនអាចតម្រូវឱ្យអ្នកដាក់ពាក្យស្នើសុំ ឬអ្នកអនុវត្ត គម្រោងវិនិយោគផ្តល់នូវឯកសារនានា ដែលមានស្រាប់នៅក្នុងបាកូដដែលមានលេខសម្គាល់ ឬ យូអរកូដ ឬ ប្រព័ន្ធបច្ចេកវិទ្យាដទៃទៀតដែលជាប់នៅលើវិញ្ញាបនបត្រចុះបញ្ជីដែលចេញដោយ ក.អ.ក. បានទេ។ គម្រោងវិនិយោគ ដែលទទួលបានវិញ្ញាបនបត្រចុះបញ្ជីអាចចាប់ផ្តើមអនុវត្តបានដោយស្វ័យប្រវត្តិ។ ការទទួលបានវិញ្ញាបនបត្រចុះបញ្ជីមិនមែន

---

[4] រាជរដ្ឋាភិបាលកម្ពុជា៖ ***ច្បាប់ស្តីពីវិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា*** .ដ.៦.ម. ទំព័រ ៦។

[5] រាជរដ្ឋាភិបាលកម្ពុជា ៖ ***ច្បាប់ស្តីពីវិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា*** .ដ.៦.ម. ទំព័រ ៧។

ជាការលើកលែងឱ្យគម្រោងវិនិយោគរួចផុតពីការទទួលនូវលិខិតអនុញ្ញាតតាមការកំណត់ដោយច្បាប់ និងបទប្បញ្ញត្តិនានាឡើយ។ រាល់គម្រោងវិនិយោគត្រូវជាកម្មវត្ថុនៃការតាមដាន និង ត្រួតពិនិត្យតាមរយៈយន្តការច្រកចេញ-ចូលតែមួយ សម្របសម្រួលដោយ ក. អ. ក. ដើម្បីធានាបាននូវអនុលោមភាព គតិយុត្ត និង លក្ខខណ្ឌនានាដែលជាមូលហេតុនៃការទទួលបានវិញ្ញាបនបត្រចុះបញ្ជី[6]។

អ្នកអនុវត្តគម្រោងវិនិយោគត្រូវផ្តល់របាយការណ៍ ស្តីពីការអនុវត្តគម្រោងវិនិយោគ ទៅតាមកាលវិភាគជាក់លាក់ ដែលកំណត់ដោយ ក. អ. ក.។ ទម្រង់នឹងបែបបទលម្អិត នៃគំរូរបាយការណ៍ត្រូវកំណត់ដោយសេចក្តីណែនាំរបស់ ក. អ. ក.។ ការផ្តល់របាយការណ៍ស្តីពីការអនុវត្តគម្រោងវិនិយោគ ពុំមែនជាមូលដ្ឋាននៃការរួចផុត ពីការពិនិត្យអនុលោមភាពក្នុងការអនុវត្តគម្រោងនៅនឹងកន្លែងអនុវត្តគម្រោងទេ ប្រសិនបើ ក. អ. ក. សន្មតថាមានភាពចាំបាច់ ឬ ប្រសិនបើមានការតវ៉ាណាមួយពីបុគ្គលដែលអះអាងថាបានទទួលរងនូវផលប៉ះពាល់ពីការអនុវត្តគម្រោងវិនិយោគ។ នីតិវិធីនៃការចុះបញ្ជីគម្រោងវិនិយោគនៅអនុគណៈកម្មាធិការវិនិយោគ រាជធានី ខេត្ត ត្រូវកំណត់ដោយអនុក្រឹត្យដោយឡែក[7]។

## ១.៥.ការធានា និង ការការពារវិនិយោគ

វិនិយោគិន នឹងទទួលបាននូវប្រព្រឹត្តកម្មមិនរើសអើង ទាក់ទងនឹងបដិទាន សំណង ឬ ដំណោះស្រាយជាតម្លៃសេដ្ឋកិច្ចផ្សេងទៀត ក្នុងករណីការវិនិយោគរបស់ខ្លួនបានទទួលរងនូវការខូចខាត ដោយសារជម្លោះប្រដាប់អាវុធ ឬ កលិយុគស៊ីវិល ឬ ការដាក់ប្រទេសជាតិស្ថិតនៅក្នុងភាពអាសន្ន ប្រសិនបើមានច្បាប់ និង គោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការធ្វើបដិទានឬផ្តល់សំណងសមរម្យណាមួយនោះ។ វិនិយោគិនបរទេសមិនត្រូវជាកម្មវត្ថុនៃការរើសអើងដោយសារមូលហេតុសញ្ជាតិបរទេស លើកលែងតែកម្មសិទ្ធិលើដីធ្លីដូចដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាកម្ពុជា និង បទប្បញ្ញត្តិទាំងឡាយជាធរមាន។ រដ្ឋមិនត្រូវធ្វើជាតូបនីយកម្មដែលនាំឱ្យប៉ះពាល់ដល់ទ្រព្យសម្បត្តិរបស់វិនិយោគិនក្នុងព្រះរាជាណាចក្រកម្ពុជាឡើយ។ រដ្ឋមិនត្រូវធ្វើអស្សាមិករណ៍ដែលនាំឱ្យប៉ះពាល់ដល់គម្រោងវិនិយោគដែលបានទទួលការអនុម័តនោះឡើយ ទោះបីដោយផ្ទាល់ឬដោយប្រយោល ឬតាមរយៈវិធានការប្រហាក់

---

6 -ដ- ទំព័រ ៧-៨។

7 រាជរដ្ឋាភិបាលកម្ពុជា ៖ *ច្បាប់ស្តីពីវិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា* .ដ. ឯ. ម. ទំព័រ ៨។

ប្រហែលនឹងការធ្វើអស្សាមិករណ៍ក្តីលើកលែងតែក្នុង ករណីបម្រើប្រយោជន៍សាធារណៈ ដែលការធ្វើអស្សាមិករណ៍នេះត្រូវអនុវត្តតាមលក្ខខណ្ឌដូចតទៅៈ (១)ភាពមិនរើសអើង, (២)សំណងដោយសមរម្យនិងយុត្តិធម៌, (៣)អនុលោមតាមច្បាប់និងនីតិវិធីអស្សាមិករណ៍ជាធរមាន[8]។

រាជរដ្ឋាភិបាលមិនត្រូវកំណត់ថ្លៃផលិតផល ឬ ថ្លៃសេវានានាដែលបង្កើតដោយគម្រោងវិនិយោគនោះឡើយ។ ដោយអនុលោមទៅតាមច្បាប់ និង លិខិតបទដ្ឋានគតិយុត្តជាធរមាន វិនិយោគិនមានសិទ្ធិទិញរូបិយបណ្ណបរទេសដោយសេរី និង បង្វិលទៅបរទេសនូវរូបិយបណ្ណបរទេសទាំងអស់នោះដើម្បីទូទាត់កាតព្វកិច្ចខាងហិរញ្ញវត្ថុដែលពាក់ព័ន្ធនឹងការ វិនិយោគរបស់ខ្លួនតាមរយៈប្រព័ន្ធធនាគារដែលជាអន្តរការីប្រតិស្រុតិ។ ការផ្ទេរទាំងនេះរាប់បញ្ចូលទាំង៖ (១)វិភាគទានចំពោះមូលធនបឋម(២)ប្រាក់ចំណូលចំណេញមូលធនភាគលាភកម្រៃសួយសារកម្រៃអាជ្ញាបណ្ណកម្រៃនៃការគ្រប់គ្រង និង ជំនួយបច្ចេកទេស ការប្រាក់និង ប្រាក់ចំណូលដទៃទៀតដែលកើតពីការវិនិយោគ(៣)ផលដែលទទួលបានពីការលក់សរុប ឬ ការ លក់មួយផ្នែកឬការរំលាយក្រុមហ៊ុនដែលអនុវត្តគម្រោងវិនិយោគ, (៤)ការទូទាត់លើការនាំចូល និង ការបង្វិលទៅក្រៅប្រទេសទាំងប្រាក់ដើម និង ការប្រាក់នៃប្រាក់កម្ចី, (៥)ការទូទាត់ចំពោះសំណងក្នុងករណីមានកលិយុគស៊ីវិល ក្នុងករណីមានអស្សាមិករណ៍ឬការដកហូតដោយរដ្ឋ, (៦)ការទូទាត់កើតឡើងពីដំណោះស្រាយវិវាទដោយមធ្យោបាយណាមួយ រាប់បញ្ចូលទាំងសេចក្តីសម្រេចរបស់តុលាការ ឬ សេចក្តីសម្រេចរបស់មជ្ឈត្តការ និង (៧)ចំណូលនិងប្រាក់ឈ្នួលដទៃទៀតរបស់និយោជិត[9]។

កម្មសិទ្ធិបញ្ញារបស់វិនិយោគិនត្រូវបានការពារដោយអនុលោមតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងកម្មសិទ្ធិបញ្ញានៃព្រះរាជាណាចក្រកម្ពុជា។ កម្មសិទ្ធិលើដីធ្លីរបស់វិនិយោគិនសម្រាប់បម្រើឱ្យគោលដៅអនុវត្តគម្រោងវិនិយោគ ត្រូវបានអនុញ្ញាតចំពោះបុគ្គលដែលមានសញ្ជាតិខ្មែរស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។ វិនិយោគិនមានសិទ្ធិប្រើប្រាស់ដីធ្លីតាមរយៈជាអាទិ៍ សម្បទានដីសេដ្ឋកិច្ច ឬសិទ្ធិជួលអចិន្ត្រៃយ៍ និង ការជួលដែលមានអំឡុងពេលកំណត់ស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។ បុគ្គលដែលត្រូវបានចាត់ទុកជាវិនិយោគិនដោយផ្អែកទៅលើច្បាប់នេះ មានសិទ្ធិដូចតទៅៈ (១)សិទ្ធិជួលនិយោជិតបរទេសដើម្បីគ្រប់គ្រងឬប្រតិបត្តិការគម្រោងវិនិយោគក្នុងចំនួនមិនលើសពីចំនួន ដែលបានកំណត់ដោយច្បាប់

[8] -ដ- ទំព័រ ៨-៩។

[9] រាជរដ្ឋាភិបាលកម្ពុជាៈ *ច្បាប់ស្តីពីវិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា* .ដ. ឯ. ម. ទំព័រ ៩។

និង លិខិតបទដ្ឋានគតិយុត្តជាធរមាន ក្នុងករណីពុំអាចរកនិយោជិតខ្មែរ ដែលមានជំនាញដើម្បីគ្រប់គ្រងឬប្រតិបត្តិការគម្រោងវិនិយោគនោះ។ ការអនុញ្ញាតឱ្យជួលនិយោជិតបរទេសនេះគឺត្រូវពិនិត្យ ទៅតាមស្ថានភាពជាក់ស្តែង និង ពុំមានលក្ខណៈ អចិន្ត្រៃយ៍ ទេ។ (២)សិទ្ធិទទួលបានការអនុញ្ញាតស្នាក់នៅបណ្តោះអាសន្នរយៈពេលវែងសម្រាប់ខ្លួនឯងផ្ទាល់ សម្រាប់សហព័ទ្ធ និង កូនដែលជាអនីតិជន ក្នុងអំឡុងពេលដែលគម្រោងវិនិយោគរបស់ខ្លួនមានប្រតិបត្តិការ។ (៣)សិទ្ធិស្នើសុំការអនុញ្ញាតស្នាក់នៅបណ្តោះអាសន្នរយៈពេលវែងសម្រាប់និយោជិតបរទេស និង សម្រាប់សហព័ទ្ធនិងកូនដែលជាអនីតិជនរបស់និយោជិតបរទេសទាំងនេះ ក្នុងអំឡុងពេលដែលកិច្ចសន្យាការងារនៅមានសុពលភាព។ (៤)សិទ្ធិទទួលបានបណ្ណការងារ និង សៀវភៅការងារសម្រាប់ខ្លួនឯងផ្ទាល់និងសម្រាប់និយោជិតបរទេសរបស់ខ្លួន[10]។

ក. អ. ក. ឬអនុគណៈកម្មាធិការរាជធានី ខេត្ត ត្រូវចេញលិខិតបញ្ជាក់អំពីឋានៈជាវិនិយោគិនជូនបុគ្គលពាក់ព័ន្ធនឹងគម្រោងវិនិយោគទៅតាមការស្នើសុំរបស់វិនិយោគិនដើម្បីប្រើប្រាស់សម្រាប់ការស្នើសុំការអនុញ្ញាតស្នាក់នៅបណ្តោះអាសន្នរយៈពេលវែង បណ្ណការ និង សៀវភៅការងារនិងគោលបំណងចាំបាច់ដទៃទៀតស្របតាមនីតិវិធីជាធរមាន។ នីតិវិធីពិសេសសម្រាប់ការស្នើសុំបណ្ណការងារនិងសៀវភៅការងារ ដូចមានចែងនៅក្នុងមាត្រា២២ នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា នេះត្រូវកំណត់នៅក្នុងប្រកាសរួមរវាង ក. អ. ក. និង ក្រសួងទទួលបន្ទុកវិស័យការងារ។ បែបបទ និង នីតិវិធីពិសេសសម្រាប់ស្នើសុំការអនុញ្ញាតស្នាក់នៅបណ្តោះអាសន្នរយៈពេលវែង ដូចមានចែងនៅក្នុងមាត្រា២២ នេះត្រូវកំណត់ដោយអនុក្រឹត្យដោយឡែក។ វិនិយោគិនមានសិទ្ធិទទួលបាននូវសេវាថែទាំវិនិយោគចំពោះគម្រោង វិនិយោគដែលបានចុះបញ្ជីនៅ ក. អ. ក. ឬ អនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្ត។ លក្ខខណ្ឌ បែបបទ និង នីតិវិធីនៃការផ្តល់សេវាថែទាំវិនិយោគចំពោះគម្រោងវិនិយោគ ត្រូវកំណត់ដោយអនុក្រឹត្យ[11]។

### ១.៦.ការលើកទឹកចិត្តវិនិយោគ

វិស័យ និង សកម្មភាពវិនិយោគដូចខាងក្រោមត្រូវទទួលការលើកទឹកចិត្តៈ(១) ឧស្សាហកម្ម ដែលមានបច្ចេកវិទ្យាខ្ពស់ប្រកបដោយនវានុវត្តន៍ និង ការស្រាវជ្រាវនិងអភិវឌ្ឍ, (២)ឧស្សាហកម្ម និង កម្មន្តសាលថ្មីៗផ្តល់តម្លៃបន្ថែមខ្ពស់មាននវានុវត្តន៍ និង ភាពប្រកួតប្រជែងខ្ពស់, (៣)ឧស្សាហកម្មបម្រើឱ្យខ្សែប្រវាក់ផលិតកម្មតំបន់ និង

[10] រាជរដ្ឋាភិបាលកម្ពុជា៖ *ច្បាប់ស្តីពីវិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា*.ដ. ឯ. ម. ទំព័រ ១០។

[11] -ដ- ទំព័រ ១០-១១។

សកលលោក, (៤)ឧស្សាហកម្មគាំទ្រពាក់ព័ន្ធនឹងវិស័យ កសិកម្ម ទេសចរណ៍ កម្មន្តសាលឧស្សាហកម្មបម្រើឱ្យខ្សែច្រវាក់ផលិតកម្មតំបន់ និង សកលលោក និង ឧស្សាហកម្មតភ្ជាប់បណ្តាញផ្គត់ផ្គង់, (៥)ឧស្សាហកម្មគ្រឿងអគ្គិសនីនិងអេឡិចត្រូនិក, (៦)ឧស្សាហកម្មគ្រឿងបន្លាស់ បង្គុំនិងតម្លើង, (៧)ឧស្សាហកម្មមេកានិកនិងគ្រឿងម៉ាស៊ីន, (៨)កសិកម្ម កសិឧស្សាហកម្ម ឧស្សាហកម្មកែច្នៃ ផលិតផលកសិកម្ម និង ឧស្សាហកម្មកែច្នៃចំណីអាហារដែលបម្រើទីផ្សារក្នុងស្រុក ឬ ការនាំចេញ, (៩)សហគ្រាសធុនតូចនិងមធ្យមក្នុងវិស័យអាទិភាព និង ការអភិវឌ្ឍបណ្តុំសហគ្រាសធុនតូច និងមធ្យម សួនឧស្សាហកម្ម និង សួនវិទ្យាសាស្ត្រ បច្ចេកវិទ្យានិងនវានុវត្តន៍, (១០)ឧស្សាហកម្មទេសចរណ៍ និង សកម្មភាពពាក់ព័ន្ធនឹងទេសចរណ៍, (១១)ការអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេស, (១២)ឧស្សាហកម្មឌីជីថល, (១៣)ការវិនិយោគក្នុងវិស័យអប់រំ ការបណ្តុះបណ្តាលវិជ្ជាជីវៈ និង ជំរុញផលិតភាព, (១៤)ការវិនិយោគក្នុងវិស័យសុខាភិបាល, (១៥)ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត, (១៦)ការវិនិយោគក្នុងវិស័យឡូជីស្ទីក, (១៧)ការវិនិយោគក្នុងការគ្រប់គ្រង ការការពារបរិស្ថាននិងការអភិរក្សជីវៈចម្រុះ និង សេដ្ឋកិច្ចចក្រ, (១៨)ការវិនិយោគក្នុងវិស័យថាមពលបៃតង បច្ចេកវិទ្យា ដែលរួមដែលរួមចំណែកដល់ការបន្សាំ និង ការកាត់បន្ថយការប្រែប្រួលអាកាសធាតុ, (១៩)វិស័យ និង សកម្មភាពវិនិយោគផ្សេងៗទៀត ដែលមិនមានចែងក្នុងច្បាប់នេះក្នុងករណីដែលរាជរដ្ឋាភិបាល យល់ឃើញថា មានសក្តានុពលដល់ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច[12]។

វិស័យនិងសកម្មភាពវិនិយោគដែលចែងក្នុងមាត្រា២៤ នៃច្បាប់នេះដែលមិនស្ថិតនៅក្នុងបញ្ជីវត្តមាន ត្រូវទទួលបានការលើកទឹកចិត្តជាមូលដ្ឋានផ្នែកពន្ធដារ និង/ឬពន្ធគយទាំងស្រុងឬមួយផ្នែក ក្រោយទទួលបានវិញ្ញាបនបត្រចុះបញ្ជីបញ្ជាក់ឋានៈជា គ.ល. គ.។ វិស័យនិងសកម្មភាពវិនិយោគដែលមានចែងក្នុងមាត្រា២៤ នៃច្បាប់នេះដែលពុំទទួលបានការលើកទឹកចិត្តទាំងផ្នែកពន្ធដារ និងពន្ធគយ ត្រូវបានកំណត់ក្នុងបញ្ជីអវិជ្ជមានដែលនឹងចែងដោយអនុក្រឹត្យ។

១.៧.ការទិញ ការលក់ ឬការរួមបញ្ចូលគ្នានៃគម្រោងវិនិយោគសិទ្ធិ បុព្វសិទ្ធិ ឬសិទ្ធិដទៃទៀត គ.ល.គ. បានទទួលមិនផ្ទេរទៅតតិយជនណាមួយបានទេ លើកលែងតែការផ្ទេរតាមរយៈការទិញ ការលក់ និង ការរួមបញ្ចូលគ្នានៃគម្រោងវិនិយោគ។ គម្រោងវិនិយោគអាចត្រូវបាន ទិញ លក់ ឬ រួមបញ្ចូលគ្នាដោយមិនបាត់បង់ការលើកទឹកចិត្ត ការធានា លើការវិនិយោគ និង កាតព្វកិច្ចទាំងឡាយដែលត្រូវមានបន្ត ប្រសិនបើការ

[12] រាជរដ្ឋាភិបាលកម្ពុជា៖ *ច្បាប់ស្តីពីវិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា* .ដ.ឯ.ម. ទំព័រ ១១។

*វិញ ឬការលក់ ឬ ការរួមបញ្ចូលគ្នានោះ ស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ជាធរមាន ហើយត្រូវបានធ្វើឡើងតាមរយៈ ការស្នើសុំជាលាយលក្ខណ៍អក្សរទៅ ក. អ. ក. ស ឬ ទៅអនុគណៈកម្មាធិការរាជធានីខេត្ត ដែលមាននីតិវិធីលម្អិតត្រូវកំណត់ដោយអនុក្រឹត្យ[13]។*

## ១.៨.ការលុបគម្រោងវិនិយោគ

*គម្រោងវិនិយោគអាចត្រូវបានលុបក្នុងករណីណាមួយដូចតទៅនេះ៖ (១)អលទ្ធភាពក្នុងការអនុវត្ត គ. ល. គ. បន្តទៀត។ (២) នីតិបុគ្គលដែលអនុវត្តត្រូវបានរំលាយ។(៣) ការខកខានអនុវត្តកាតព្វកិច្ចដែលបានកំណត់ក្នុងច្បាប់ និង លិខិតបទដ្ឋានគតិយុត្តជាធរមាន។ (៤) តាមសំណើរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ លើគម្រោងដែលមានផលប៉ះពាល់ធ្ងន់ធ្ងរជាអាទិ៍ដល់បរិស្ថាន ឬ សន្តិសុខជាតិ ឬ ផលប្រយោជន៍សាធារណៈ ឬ សុខុមាលភាពប្រជាពលរដ្ឋ ឬ តាមសំណើរបស់វិនិយោគិន។*

*ក្នុងករណី មានការលុបដោយលក្ខខណ្ឌដូចមានចែងខាងលើ វិនិយោគិនត្រូវស្នើសុំដាក់ពាក្យដោយផ្ទាល់ ឬតាមរយៈអ្នកតំណាងដែលមានសិទ្ធិ ក. អ. ក. ឬ ទៅអនុគណៈកម្មាធិការ វិនិយោគរាជធានី ខេត្ត។ លិខិតស្នើសុំខាងលើនេះត្រូវចុះហត្ថលេខាដោយវិនិយោគិន ឬ អ្នកតំណាងដែលមានសិទ្ធិ ដោយត្រូវបញ្ជាក់អំពីមូលហេតុនៃអលទ្ធភាពនេះ និង ត្រូវភ្ជាប់មកជាមួយនូវឯកសារគាំទ្រផ្សេងៗ។ ក្នុងករណីការលុបដោយការរំលាយដូចមានចែងខាងលើនេះ ប្រសិនបើការរំលាយនេះ ធ្វើឡើងដោយការជម្រះបញ្ជី និង រំលាយក្រុមហ៊ុនដោយស្ម័គ្រចិត្ត នោះវិនិយោគិនត្រូវដាក់ពាក្យស្នើសុំលុបដោយផ្ទាល់ ឬតាមរយៈអ្នកតំណាងដែលមានសិទ្ធិ ទៅក. អ. ក. ឬទៅអនុគណៈកម្មាធិការវិនិយោគ រាជធានី ខេត្ត[14]។*

*ទោះបីជាគម្រោងវិនិយោគ ត្រូវបានលុបក៏ដោយ វិនិយោគិនមិនអាចរួចផុតពីកាតព្វកិច្ចសារពើពន្ធនិងកាតព្វកិច្ចដទៃផ្សេងៗទៀតឡើយ។ វិនិយោគិនអាចធ្វើការតវ៉ាចំពោះការលុបគម្រោងវិនិយោគបាន តាមរយៈការដាក់ពាក្យតវ៉ាជាលាយលក្ខណ៍អក្សរទៅ ក. អ. ក. ឬ ទៅអនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្ត ស្របតាមនីតិវិធីជាធរមាន។ ក្នុងករណីមានការតវ៉ា ក. អ. ក. ឬ អនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្ត ត្រូវធ្វើសេចក្តីសម្រេចចំពោះការតវ៉ាខាងលើ។ ក្នុងករណីមិនពេញចិត្តនឹងសេចក្តីសម្រេចចំពោះការតវ៉ាខាងលើវិនិយោគិនដែលបានតវ៉ា អាចដាក់ពាក្យបណ្តឹងទៅតុលាការមានសមត្ថកិច្ចនៃព្រះរាជាណាចក្រ*

[13] *រាជរដ្ឋាភិបាលកម្ពុជា៖ **ច្បាប់ស្តីពីវិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា**.ដ. ឯ. ម. ទំព័រ ១៤។*

[14] *-ដ- ទំព័រ ១៤-១៥។*

កម្ពុជា[15]។ ក្នុងករណីដែលគម្រោងវិនិយោគត្រូវបានលុប វិនិយោគិនអាចផ្ទេរទ្រព្យសម្បត្តិដែល សេសសល់ ទៅក្រៅប្រទេសឬប្រើនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ក្នុងករណីដែលគម្រោងវិនិយោគបានប្រើសម្ភារៈសាងសង់ បរិក្ខាសំណង់ សម្ភារៈបរិក្ខាផលិតកម្ម និង ធាតុចូលផលិតកម្មដែលបាននាំចូលដោយលើកលែងពន្ធគយអាករពិសេស និង អាករលើតម្លៃបន្ថែម ជាបន្ទុករបស់រដ្ឋ ក្នុងអំឡុងពេលតិចជាង៥ឆ្នាំ វិនិយោគិនមានកាតព្វកិច្ចបង់ពន្ធ លើសម្ភារៈសាងសង់ បរិក្ខាសំណង់ សម្ភារៈបរិក្ខាផលិតកម្ម និង ធាតុចូលផលិតកម្មផ្សេងៗទាំងនោះដែលត្រូវកំណត់ដោយអនុក្រឹត្យស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន[16]។

### ១.៩.ការវិវាទ និង ការដោះស្រាយវិវាទ

វិវាទរវាងវិនិយោគិននិងវិនិយោគិនពាក់ព័ន្ធទៅនឹងគម្រោងវិនិយោគអាចត្រូវបានដោះស្រាយតាមយន្តការសម្របសម្រួលដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឬ ដោយអនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្ត តាមនីតិវិធីជាធរមាន តាមការស្នើសុំជាលាយលក្ខណ៍អក្សរទៅក.អ.ក. ឬអនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្ត ដោយភាគីវិវាទណាមួយ។ ក្នុងរយៈពេល ៣០ (សាមសិប)ថ្ងៃ បន្ទាប់ពីទទួលបានសំណើសុំជាលាយលក្ខណ៍អក្សរ ដែលស្នើសុំសម្របសម្រួល ក. អ. ក. ឬអនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្ត ត្រូវចាត់ចែងរៀបចំការសម្របសម្រួលជាមួយវិនិយោគិន និងអង្គពាក់ព័ន្ធដទៃទៀត ទៅតាមការចាំបាច់សំដៅទទួលបានដំណោះស្រាយសមរម្យមួយ។ ប្រសិនបើការដោះស្រាយតាមយន្តការសម្របសម្រួល ខាងលើ ពុំទទួលបានជោគជ័យ វិវាទអាចត្រូវបានដោះស្រាយតាមរយៈ (១)មជ្ឈត្តការជាតិ ឬ មជ្ឈត្តការអន្តរជាតិ ដែលយល់ព្រមដោយគូវិវាទ, (២) តុលាការមានសមត្ថកិច្ចនៃព្រះរាជាណាចក្រកម្ពុជា[17]។

## ២.តំបន់ពាណិជ្ជកម្មសេរីអាស៊ាន

ក្នុងសម័យប្រជុំកំពូលអាស៊ានលើកទី៤ ដែលបានប្រារព្ធធ្វើនៅប្រទេស សិង្ហបុរីនាថ្ងៃទី២៧-២៨ មករា ឆ្នាំ ១៩៩២ ប្រមុខរដ្ឋ និង ប្រមុខរដ្ឋាភិបាលនៃប្រទេសអាស៊ានដោយទទួលបានការលើកទឹកចិត្តពីសមិទ្ធផលរបស់អាស៊ាន នៅក្នុងរយៈពេល ២៥ ឆ្នាំកន្លងមកនេះ និង ដោយមានជំនឿជឿជាក់ក្នុងចិត្តថាកិច្ចសហប្រតិបត្តិការអាស៊ាន នៅតែជាកត្តាសំខាន់បំផុត ចំពោះសុខមាលភាពនៃប្រជាពលរដ្ឋរបស់ខ្លួន។ ក្នុងបរិការណ៍នេះ ពួកគេបានលើកឡើងគោល

15 រាជរដ្ឋាភិបាលកម្ពុជា៖ ***ច្បាប់ស្តីពីវិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា***. ដ. ឯ. ម. ទំព័រ ១៥។
16 -ដ- ទំព័រ ១៥-១៦។

17 រាជរដ្ឋាភិបាលកម្ពុជា៖ ***ច្បាប់ស្តីពីវិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា*** .ដ. ឯ. ម. -ដ- ទំព័រ ១៦។

ការណ៍ យន្តកម្មផលិតផលនិងថេរវេលាសម្រាប់បង្កើតតំបន់ពាណិជ្ជកម្មសេរីអាស៊ាន AFTA[18]។

(ក)គោលដៅសេដ្ឋកិច្ចសំខាន់ៗ នៃតំបន់ពាណិជ្ជកម្មសេរីអាស៊ាន៖ តំបន់ពាណិជ្ជកម្មសេរីអាស៊ានមានគោលដៅសេដ្ឋកិច្ចសំខាន់ៗបី (១) បន្សាំអាស៊ានទៅនឹងការផ្លាស់ប្ដូរលក្ខខណ្ឌសេដ្ឋកិច្ចពិភពលោក ជាពិសេសគឺដំណើរការសាកលភាវូបនីយកម្ម និង ការបង្កើតឡើងនូវកិច្ចព្រមព្រៀងតំបន់ពាណិជ្ជកម្មបណ្ដាប្រទេសអភិវឌ្ឍ។ ប្រការនេះគោលបំណងសំខាន់គឺជានាភាពប្រជែងឈ្នះអាស៊ាននៅលើទីផ្សារអន្តរជាតិ ពោលគឺការប្រែក្លាយអាស៊ានឱ្យទៅជាមូលដ្ឋានផលិតកម្មសំខាន់មួយក្នុងផ្នែកឧស្សាហកម្មកម្មន្តសាល ឧស្សាហកម្មកែច្នៃកសិកម្ម និង កសិឧស្សាហកម្ម។ (២)សេរីភាវូបនីយកម្មពាណិជ្ជកម្មក្នុងអាស៊ានតាមរយៈការកាត់បន្ថយអត្រាពន្ធគយ និងការលុបបំបាត់របាំងមិនមែនពន្ធគយ (Non-tariff barriers)។ (៣)ទាក់ទាញវិនិយោគិនមកក្នុងតំបន់អាស៊ាន តាមរយៈការបង្កើនទំហំសេដ្ឋ និងការសម្របសម្រួលទីផ្សារក្នុងតំបន់ ។ ក្នុងប្រការទាំងអស់ខាងលើនេះ ដោយយោងលើទំហំទីផ្សារនិងសមត្ថភាពប្រណាំងប្រជែង សេដ្ឋកិច្ចអាស៊ាន គេអាចសន្និដ្ឋានបានថា គោលដៅទាក់ទាញការវិនិយោគជាគោលដៅសំខាន់ពិតប្រាកដរបស់តំបន់ពាណិជ្ជកម្មសេរី អាស៊ាន។

(ខ)យន្តការនៃតំបន់ពាណិជ្ជកម្មសេរីអាស៊ាន៖ តើយន្តការសម្រាប់ដាក់ឱ្យអនុវត្តនៅក្នុងតំបន់ពាណិជ្ជកម្មសេរីមានអ្វីខ្លះ? ដែលដាក់ឱ្យអនុវត្ត ដើម្បីសម្រេចគោលបំណងនេះ គឺកិច្ចព្រមព្រៀងស្ដីពីការអនុគ្រោះពន្ធគយរួម (Common Effective Preferential Tariff-CEPT) ដែលចុះហត្ថលេខាដោយរដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន នាខែ មករា ឆ្នាំ ១៩៩២ នៅសឹង្ហបុរី។ កិច្ចព្រមព្រៀងស្ដីពីការអនុគ្រោះពន្ធគយរួមនេះមានវិសាលភាពគ្របដណ្ដប់លើបណ្ដាមុខទំនិញ កម្មន្ត សាលដោយរាប់បញ្ចូលទាំងទំនិញមូលធនផលិតផលកសិកម្មកែច្នៃ និង ទំនិញមិនមែនកសិកម្មផ្សេងទៀត។ ទន្ទឹមនឹងនោះរបបនៃការអនុវត្តកិច្ចព្រមព្រៀងស្ដីពីការអនុគ្រោះពន្ធគយរួមមានការលើកលែងលើផលិតផលមួយចំនួន ដែលជាទូទៅគេចែកចេញជាពីរផ្នែក៖ (១)គឺការលើកលែងទូទៅដែលត្រូវបានអនុញ្ញាតសម្រាប់ប្រភេទផលិតផល ដែលប៉ះពាល់ដល់សន្តិសុខជាតិ សីលធម៌សាធារណៈ ជីវិតនិងសុខភាពរបស់មនុស្ស សត្វ និង រុក្ខជាតិ វប្បធម៌សិល្បៈ ប្រវត្តិសាស្ត្របុរាណវត្ថុ។ (២)គឺការលើកលែងបណ្ដោះអាសន្ន ដែលសំដៅទៅលើប្រភេទផលិតផល ដែលមានវេទយិតភាព (Sensitivity)

---

[18] AFTA: ASEAN Free Trade Area

សម្រាប់ផលិតកម្មនៅក្នុងស្រុក។ ប្រទេសជាសមាជិកត្រូវផ្ទេរផលិតផលដែលស្ថិតនៅក្នុងបញ្ជីលើកលែងបណ្តោះអាសន្នទៅក្នុងបញ្ជីសម្រាប់អនុវត្តជាដំណាក់ៗស្មើៗគ្នា ពីថ្ងៃទី១ ខែមករា ឆ្នាំ១៩៩៦ ដល់ថ្ងៃទី១ ខែមករា ឆ្នាំ ២០០០។

ជាមួយគ្នានោះសម្រាប់ផលិតផលកសិកម្ម មិនទាន់កែច្នៃការលើកលែងត្រូវបានចែកចេញជាពីរ៖ (១)ការលើកលែងបណ្តោះអាសន្ន ដែលត្រូវផ្ទេរចូលមកក្នុងបញ្ជីសម្រាប់អនុវត្តជាដំណាក់ៗស្មើៗគ្នា (២) បញ្ជីផលិតផលដែលមានវេទយិតភាពខ្ពស់ដែលត្រូវផ្ទេរចូលមកក្នុងបញ្ជីសម្រាប់អនុវត្តតាមរយៈកិច្ចព្រមព្រៀងដោយឡែក។ ទន្ទឹមនឹងនោះវិធាននៃកិច្ចព្រមព្រៀងស្តីពីការអនុគ្រោះពន្ធគយរួមក៏បានចែងច្បាស់ថា ប្រទេសសមាជិកអាស៊ាន អាចទទួលបាននូវអត្រាពន្ធគយអនុគ្រោះពីប្រទេសសមាជិកអាស៊ានផ្សេងទៀត សម្រាប់ផលិតផលរបស់ខ្លួនក្នុងករណីដែល៖ (ក)ផលិតផលនោះត្រូវមានប្រភពដើមមកពីអាស៊ាន៤០%, (ខ)ការអនុគ្រោះគប្បីត្រូវបានអនុវត្តទៅវិញទៅមកសម្រាប់ផលិតផលដែលមានក្នុងបញ្ជីសម្រាប់អនុវត្ត និងមានអត្រាពន្ធគយ២០% ឬ ទាបជាងនេះ។

(គ)ផលិតផលនោះ ត្រូវមានក្នុងកម្មវិធីកាត់បន្ថយពន្ធគយ ដែលអនុម័តដោយក្រុមប្រឹក្សាតំបន់ពាណិជ្ជកម្មសេរីអាស៊ានលើកលែងតែផលិតផល ដែលមានអត្រាពន្ធគយពី ០ ទៅ ៥% ស្រាប់។ ក្នុងប្រការទាំងអស់នេះគួរគូសបញ្ជាក់ថាមុខទំនិញ ដែលបានបញ្ចូលទៅក្នុងបញ្ជីនៃកិច្ចព្រមព្រៀងស្តីពីការអនុគ្រោះពន្ធគយរួម រួចហើយ ប្រទេសជាសមាជិកមិនអាច តម្លើងអត្រាពន្ធគយលើប្រភេទទំនិញនោះបានទេ។

**២. ១. គោលដៅសេដ្ឋកិច្ចសំខាន់ៗនៃតំបន់ពាណិជ្ជកម្មសេរីអាស៊ាន** (AFTA)

(១)បន្សាំអាស៊ានទៅនឹងការផ្លាស់ប្តូរលក្ខខណ្ឌសេដ្ឋកិច្ចពិភពលោក ជាពិសេសគឺដំណើរការសាកលភាវូបនីយកម្ម និង ការបង្កើតឡើងវិញនូវកិច្ចព្រមព្រៀងតំបន់ពាណិជ្ជកម្មបណ្តាប្រទេសអភិវឌ្ឍ។ក្នុងប្រការនេះគោលបំណងសំខាន់ គឺជានាភាពប្រជែងឈ្នះអាស៊ាននៅលើទីផ្សារអន្តរជាតិពោលគឺប្រែក្លាយអាស៊ានឱ្យទៅជាមូលដ្ឋានផលិតកម្មសំខាន់មួយ ក្នុងផ្នែកឧស្សាហកម្មកម្មន្តសាល ឧស្សាហកម្មកែច្នៃកសិកម្ម និង កសិឧស្សាហកម្ម។ (២)សេរីភាវូបនីយកម្មពាណិជ្ជកម្មក្នុងអាស៊ានតាមរយៈការកាត់បន្ថយអត្រាពន្ធគយនិងការលុបបំបាត់របាំងមិនមែនពន្ធគយ (Non-tariff barriers)។ (៣)ទាក់ទាញវិនិយោគិនមកក្នុងតំបន់អាស៊ានតាមរយៈការបង្កើនទំហំសេដ្ឋកិច្ច និងការសម្របសម្រួលទីផ្សារក្នុងតំបន់[19]។ ក្នុងប្រការទាំងអស់ខាងលើនេះ ដោយយោង

19 ហ៊ាន សាហ៊ីប៖ *គ្រប់គ្រងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ* ភ្នំពេញ ២០០៦ ទំព័រ ៥២៣-៥២៤។

លើទំហំទីផ្សារ និងសមត្ថភាពប្រណាំងប្រជែងសេដ្ឋកិច្ចអាស៊ាន គេអាចសន្និដ្ឋានបានថាគោលដៅទាក់ទាញការវិនិយោគ ជាគោលដៅសំខាន់ពិតប្រាកដរបស់តំបន់ពាណិជ្ជកម្មសេរីអាស៊ាន[20]។

## ២.២. យន្តការនៃតំបន់ពាណិជ្ជកម្មសេរីអាស៊ាន

តើយន្តការសម្រាប់ដាក់ឱ្យអនុវត្តនៅក្នុង តំបន់ពាណិជ្ជកម្មសេរីមានអ្វីខ្លះ? ដើម្បីសម្រេចគោលបំណងនេះ គឺ កិច្ចព្រមព្រៀងស្តីពីការអនុគ្រោះពន្ធគយរួម (Common Effective Preferential Tariff-CEPT) ដែលចុះហត្ថលេខាដោយរដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន នាខែមករា ឆ្នាំ១៩៩២ នៅសឹង្ហបុរី។ «កិច្ចព្រមព្រៀងស្តីពីការអនុគ្រោះពន្ធគយរួម» នេះ មានវិសាលភាព គ្របដណ្តប់លើបណ្តាមុខទំនិញកម្មន្តសាលដោយរាប់បញ្ចូលទាំងទំនិញមូលធន ផលិតផលកសិកម្មកែច្នៃ និង ទំនិញមិនមែនកសិកម្មផ្សេងទៀត។ ទន្ទឹមនឹងនោះរបបនៃការអនុវត្ត «កិច្ចព្រមព្រៀងស្តីពីការអនុគ្រោះពន្ធគយរួម» មានការលើកលែងលើផលិតផលមួយចំនួន ដែលជាទូទៅគេចែកចេញជាពីរផ្នែក ៖ (ទី១)ការលើកលែងទូទៅ ដែលត្រូវបានអនុញ្ញាតសម្រាប់ប្រភេទផលិតផល ដែលប៉ះពាល់ដល់សន្តិសុខជាតិ សីលធម៌សាធារណៈ ជីវិតនិងសុខភាព របស់មនុស្ស សត្វ និង រុក្ខជាតិ វប្បធម៌ សិល្បៈ ប្រវត្តិសាស្ត្រ បុរាណវត្ថុ។ (ទី២)ការលើកលែងបណ្តោះអាសន្ន ដែលសំដៅទៅលើប្រភេទផលិតផលដែលមានវេទយិតភាព (Sensitivity) សម្រាប់ផលិតកម្មនៅក្នុងស្រុក។ ប្រទេសជាសមាជិកត្រូវផ្ទេរផលិតផល ដែលស្ថិតនៅក្នុងបញ្ជីលើកលែងបណ្តោះអាសន្ន ទៅក្នុងបញ្ជីសម្រាប់អនុវត្តជាដំណាក់ៗស្មើៗគ្នាពីថ្ងៃទី១ ខែមករា ឆ្នាំ ១៩៩៦ ដល់ថ្ងៃទី១ ខែមករាឆ្នាំ២០០០[21]។

## ២.៣.ការលើកលែងផលិតផលកសិកម្មមិនទាន់កែច្នៃ

ជាមួយគ្នានេះសម្រាប់ផលិតផលកសិកម្មមិនទាន់កែច្នៃការលើកលែងត្រូវបានចែកចេញជាពីរគឺ៖ (១)ការលើកលែងបណ្តោះអាសន្ន ដែលត្រូវផ្ទេរចូលមកក្នុងបញ្ជីសម្រាប់អនុវត្តជាដំណាក់ៗ ស្មើៗគ្នា ហើយបញ្ចប់នៅឆ្នាំ ២០០៣, (២)បញ្ជីផលិតផលដែលមានវេទយិតភាពខ្ពស់ដែលត្រូវផ្ទេរចូលមកក្នុងបញ្ជីសម្រាប់អនុវត្តតាមរយៈកិច្ចព្រមព្រៀងដោយឡែកៗ ទន្ទឹមនឹងនោះវិធាននៃ«កិច្ចព្រមព្រៀងស្តីពីការអនុគ្រោះពន្ធគយរួម» ក៏បានចែងច្បាស់ថាប្រទេសសមាជិកអាស៊ានអាចទទួលបាននូវ

---

[20] មិន ប្រុសបញ្ញាវិទ្ធិ៖ *យន្តការសេវាសាធារណៈនៃការនាំចេញអង្ករពីប្រទេសកម្ពុជា(២០០៩-២០១២)* និក្ខេបបទបណ្ឌិត ភ្នំពេញ ឆ្នាំ២០១៣ ទំព័រ ១២៦។

[21] ហ៊ាន សាហ៊ីប៖ *គ្រប់គ្រងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ* ដ. ឯ. ម. ទំព័រ ៥២៤-៥២៥។

អត្រាពន្ធគយអនុគ្រោះពីប្រទេសសមាជិកអាស៊ានផ្សេងទៀត សម្រាប់ផលិតផលរបស់ខ្លួនក្នុងករណីដែលៈ (ក)ផលិតផលនោះត្រូវមាន ប្រភពដើមមកពីអាស៊ាន៤០% , (ខ) ការអនុគ្រោះគប្បីត្រូវបានអនុវត្តទៅវិញទៅមកសម្រាប់ផលិតផលដែលមានក្នុងបញ្ជីសម្រាប់អនុវត្តនិងមានអត្រាពន្ធគយ២០% ឬ ទាបជាងនេះ, (គ)ផលិតផលនោះត្រូវមានក្នុងកម្មវិធីកាត់បន្ថយពន្ធគយដែលអនុម័តដោយក្រុមប្រឹក្សាតំបន់ពាណិជ្ជកម្មសេរីអាស៊ានលើកលែងតែផលិតផលដែលមានអត្រាពន្ធគយពី០ ទៅ ៥% ស្រាប់ៗ ក្នុងប្រការទាំងអស់នេះគួរគូសបញ្ជាក់ថាមុខទំនិញដែលបានបញ្ចូលទៅក្នុងបញ្ជីនៃ «កិច្ចព្រមព្រៀងស្តីពីការអនុគ្រោះពន្ធគយរួម» រួចហើយប្រទេសជាសមាជិកមិនអាចដំឡើងអត្រាពន្ធគយលើប្រភេទទំនិញនោះបានទេៗ

ក្រៅពីបញ្ចុះរបាំងពន្ធគយ AFTA ទាមទារឱ្យប្រទេសជាសមាជិកបញ្ចុះនូវរបាំងមិនមែនសារពើពន្ធជាបណ្តើរៗក្នុងរយៈពេល៥ ឆ្នាំ បន្ទាប់ពីបានទទួលសិទ្ធិសម្បទានៗ ប្រទេសជាសមាជិកក៏ត្រូវបំបាត់ឱ្យអស់នូវការកម្រិតបរិមាណ ដូចជា ការកំណត់បរិមាណផលិតផលអាជ្ញាបណ្ណវិធានការរដ្ឋបាល និង ការទាមទារនានាៗប្រទេសជាសមាជិកមិនត្រូវអនុវត្តការរឹតត្បិតរូបិយបណ្ណបរទេសក្នុងការទូទាត់ចំពោះទំនិញដែលបានបញ្ចូលក្នុងតារាង CEPTៗ ប្រទេសជាសមាជិកត្រូវសហការគ្នាដើម្បីធ្វើឱ្យខ្នាតគំរូស៊ីចង្វាក់គ្នា ទទួលគ្នាទៅវិញទៅមកនូវតេស្ត និង វិញ្ញាបនបត្រនៃផលិតផល ការបញ្ចុះរបាំងដើម្បីទាក់ទាញវិនិយោគទុនបរទេស ការពិគ្រោះយោបល់ម៉ាក្រូសេដ្ឋកិច្ច វិធានស្តីពីការប្រណាំងប្រជែងដោយយុត្តិធម៌ និង លើកស្ទួយមូលធនចម្រុះៗ ក្រៅពីនោះក៏នៅមានការបង្កលក្ខណៈងាយស្រួលមួយចំនួនដូចជាប្រទេស ដែលមានការអនុគ្រោះបំផុត (Most Fevered Nations)ពន្ធគយអនុគ្រោះ ដែលមានប្រសិទ្ធភាពទូទៅ CEPT (Common Effective Preferential Tariff) សហគមន៍អឺរ៉ុបឱ្យនាំចូលអ្វីៗទាំងអស់ លើកលែងតែអាវុធ (EBA) ក្នុងនោះភាពជាប្រទេសក្រីក្រ LDC (Less Developed Country) ក៏មានការអនុគ្រោះពន្ធនាំចេញដែរៗ

## ៣.ចំនួនប្រជាជននៅក្នុងតំបន់នីមួយៗ

### ៣.១.សមាគមប្រជាជាតិអាស៊ីប៉ែក អាគ្នេយ៍ (ASEAN)

សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ ហៅកាត់ថាអាស៊ានត្រូវបានបង្កើតឡើងនៅថ្ងៃទី៨ ខែសីហា ឆ្នាំ១៩៦៧ នៅទីក្រុងបាងកកប្រទេសថៃ ដោយមានចុះហត្ថលេខាលើសេចក្តីថ្លែងការក្រុងបាងកកដោយប្រទេសជាសមាជិកដើមដំបូង៥ គឺប្រទេសឥណ្ឌូនេស៊ី ម៉ាឡេស៊ី សឹង្ហបុរី ហ្វីលីពីន និងប្រទេសថៃៗ បច្ចុប្បន្នអាស៊ានមានសមាជិក

១០ ប្រទេស ដែលក្នុងនោះប្រទេសព្រុយណេដារូសាឡឹម បានចូលជាសមាជិកនៅឆ្នាំ ១៩៨៤, ប្រទេសវៀតណាមនៅឆ្នាំ ១៩៩៦, ប្រទេសមីយ៉ាន់ម៉ា និង ឡាវ នៅឆ្នាំ ១៩៩៧។ រីឯប្រទេសកម្ពុជាបានចូលជាសមាជិកអាស៊ាននៅថ្ងៃទី៣០ ខែ មេសា ឆ្នាំ ១៩៩៩។ ប្រទេសទាំង១០ នៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ បានរួបរួមគ្នាបង្កើតបានជាក្រុមមនុស្សជាងប្រាំមួយរយលាននាក់ពោលគឺចំនួនពិតប្រាកដ**៦៨៦ ៩២៩ ៧៩៨** នាក់[22] ដោយមានផសស ជីឌីភី **៣,៣៥ ទ្រីលានដុល្លា** (3.35 trillion U.S dollars)[23]។ គោលដៅជា មូលដ្ឋានរបស់អាស៊ានគឺជំរុញឱ្យចម្រើនឡើងនូវពាណិជ្ជកម្មសេរីរវាងសមាជិកទាំងឡាយ ដើម្បីឱ្យសម្រេចនូវបំណងសហប្រតិបត្តិការនៅក្នុងគោលនយោបាយឧស្សាហកម្មរបស់អាស៊ាន។

សេចក្តីថ្លែងការណ៍ទីក្រុងបាងកក បានបង្រួបបង្រួមប្រទេសជាសមាជិកអាស៊ាន នៅក្នុងការប្រឹងប្រែងមួយដើម្បីជំរុញសហប្រតិបត្តិការខាងសេដ្ឋកិច្ច និង ដើម្បីសុខុមាលភាពរបស់ប្រជាពលរដ្ឋនៅក្នុងក្នុងតំបន់។ សេចក្តីថ្លែងការណ៍ទីក្រុងបាងកក បានដាក់ចេញនូវគោលមាគ៌ាសម្រាប់សកម្មភាពរបស់អាស៊ាន និង កំណត់ទិសដៅរបស់អង្គការនេះ។ ប្រទេសអាស៊ាន បានឯកភាពគ្នាប្រកាន់ខ្ជាប់នូវគោលដៅសំខាន់ៗ បីៈ (១)ជំរុញការអភិវឌ្ឍសេដ្ឋកិច្ចសង្គមនិងវប្បធម៌នៅក្នុងតំបន់តាមរយៈកម្មវិធីសហប្រតិបត្តិការ។ (២)ការពារស្ថេរភាពនយោបាយនិងសេដ្ឋកិច្ចនៅក្នុងតំបន់ទល់នឹងគូប្រជែងមហាអំណាចធំៗ។ (៣)បម្រើការជាវេទិកាមួយសម្រាប់ដោះស្រាយការខ្វែងយោបល់គ្នាក្នុងរង្វង់តំបន់។ ដូច្នេះក្នុងរង្វង់អាស៊ាន ប្រទេសកម្ពុជាគួរគប្បីពង្រឹងទំនាក់ទំនងបន្ថែមទៀតដើម្បីឱ្យច្បាប់វិនិយោគនៃប្រទេសនីមួយៗមានអំណោយផលទៅវិញទៅមកដែលជាកត្តាជំរុញឱ្យការវិនិយោគទ្វេភាគីក្នុងរង្វង់អាស៊ានកាន់តែកើនឡើងបន្ថែមទៀត។




**Source:**https://rencanamu.id/images.app.goo.gl/ASEAN MAP//

**៣.២. ទីផ្សារអាស៊ី** (Asian Market)

ទ្វីបអាស៊ីមានទីផ្សារធំទូលាយ ដែលក្នុងនោះប្រទេសចិនមានប្រជាជន១ ៤២៥ ៧៦៨ ០០៨ នាក់ (មួយពាន់បួនរយម្ភៃប្រាំពាន់លាន ប្រាំពីររយហុកសិបប្រាំបីពាន់

[22] http://w.w.w.en.m.wikipedia, the current population of South Eat Asian Nations, as of Thursday, March, 23, 2023, worldometers.info,//
[23] https://www.statista.com,statistics, the GDP of the ASEAN in 2023, dated on 4/4/2023//

សូន្យសូន្យប្រាំបីនាក់)[24]។ ប្រទេសជប៉ុន មានប្រជាជន១២៥ ៤២៦ ៨៨៧ នាក់ (មួយរយម្ភៃប្រាំលាន បួនរយម្ភៃប្រាំមួយពាន់ ប្រាំបីរយប៉ែតសិបប្រាំពីរនាក់)[25]។ ប្រទេសឥណ្ឌា មានប្រជាជន១ ៤២៥ ០៤៨ ៨៣៩ នាក់ (មួយពាន់បួនរយម្ភៃប្រាំពាន់លានសូន្យសែសិបប្រាំបីពាន់ ប្រាំបីរយសាមសិបប្រាំបួននាក់)[26]។ ប្រទេសអូស្ត្រាលីមានប្រជាជន ២៦ ៣០៣ ០២៨ នាក់ (ម្ភៃប្រាំមួយលាន បីរយបីពាន់សូន្យម្ភៃប្រាំបីនាក់)[27]។ ប្រទេសកូរ៉េខាងត្បូង មានប្រជាជន៥១ ៣៨៨ ៧២៥ នាក់ (ហាសិបមួយលាន បីរយប៉ែតសិបប្រាំបីពាន់ ប្រាំពីររយម្ភៃប្រាំនាក់)[28]។




**Source:**https://www.pinterest.co.uk/images.app.goo.gl/ASIA MAP//

## ៣. ៣. ទីផ្សារអាហ្វ្រិក (African Market)

ទ្វីបអាហ្វ្រិក ក៏ជាទ្វីបមួយ ដែលមានទំនាក់ទំនងសេដ្ឋកិច្ចជាមួយទ្វីបអាស៊ីដែរ។ ក្នុងនោះ ប្រទេសអាហ្វ្រិកខាងត្បូងមានប្រជាជន ៦១ ៣៣៨ ៦៨៣នាក់ (ហុកសិបមួយលាន បីរយសាមសិបប្រាំបីពាន់ ប្រាំមួយរយប៉ែតសិបបីនាក់)[29]។ ប្រជាជនអាហ្វ្រិកខាងត្បូង ៥១,១% ជាភេទស្រី និង ៤៨,៩% ភេទប្រុស។ ប្រជាជនប្រហែល ២៨,៣% មានអាយុក្រោម ១៥ ឆ្នាំ និង ប្រជាជនប្រហែល ៩,២% មានអាយុ ៦០ឆ្នាំ ឬ ក៏លើសពីនេះទៅទៀត។ ដូច្នេះប្រជាជនចំនួន ៦២,៥% ជាមនុស្សពេញកម្លាំងសម្រាប់ចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ច។ ប្រទេសអាហ្វ្រិកខាងត្បូងគឺជាប្រទេសមួយដែលមានផលិតផលមកពីស្ទើរតែគ្រប់ប្រទេសនៅទ្វីបអាហ្វ្រិក យកមកដាក់លក់នៅប្រទេសអាហ្វ្រិកខាងត្បូង។ ម្យ៉ាងទៀត ប្រទេសអាហ្វ្រិកខាងត្បូង ជាច្រកទីផ្សារអន្តរជាតិ ដ៏ធំទូលាយសម្រាប់ទ្វីបអាហ្វ្រិកទាំងមូល។

---

24 http://www.worldometers.info, the current population of China, 24/3/2023.//
25 http://www.worldometers.info, the current population of Japan, 24/3/2023.//
26 http://www.worldometers.info, the current population of India, 24/3/2023.//
27 http://www.worldometers.info, the current population of Australia, 24/3/2023.//
28 http://www.worldometers.info, the current population of South Korea, 24/3/2023.//
29 http://www.worldometers.info, the current population of South Africa, 24/3/2023.//




**Source:**https://www.researchgate.net /images.app.goo.gl/Map of Africa//

### ៣.៤. ទីផ្សារអឺរ៉ុប (EU) និងអង់គ្លេស (U.K)

សហភាពអឺរ៉ុបមានប្រជាជន៧៤៨ ៨៧២ ៣៩៧ នាក់ (ប្រាំពីររយសែសិបប្រាំបីលាន ប្រាំបីរយចិតសិបពីរពាន់បីរយកៅសិបប្រាំពីរនាក់)[30]។ ប្រទេសអង់គ្លេសមានប្រជាជន ៦៨ ៨៥៣ ៥៣៩ នាក់ (ហុកសិបប្រាំបីលាន ប្រាំបីរយហាសិបបីពាន់ ប្រាំរយសាមសិបប្រាំបួននាក់)[31]។ តើអ្វីជាគោលនយោបាយសំខាន់នៃការវិនិយោគរបស់សហភាពអឺរ៉ុប? គោលនយោបាយ តភ្ជាប់គឺជាគោលនយោបាយវិនិយោគសំខាន់របស់សហភាពអឺរ៉ុប។ គោលនយោបាយតភ្ជាប់មានគោលដៅតម្រង់ទៅគ្រប់តំបន់និងទីក្រុងនៅក្នុងសហភាពអឺរ៉ុបដើម្បីគាំទ្រ ដល់ការបង្កើតការងារ, ការប្រកួតប្រជែងធុរកិច្ច, កំណើនសេដ្ឋកិច្ច, ការអភិវឌ្ឍដោយចីរភាព, និង ពង្រឹងគុណភាពជីវិតរបស់ប្រជាពលរដ្ឋ។ ដើម្បីសម្រេចគោលដៅនេះ និង បញ្ជាក់ថាតម្រូវការនៃការអភិវឌ្ឍ ដាច់ដោយឡែកនៅក្នុងតំបន់សហភាពអឺរ៉ុបទាំងមូល មានទំហំទឹកប្រាក់៣៩២ ពាន់លានអឺរ៉ូ ស្មើរតែស្មើនឹងមួយភាគបីនៃថវិកាសរុបរបស់សហភាពអឺរ៉ុប ដែលបានដាក់ចេញជាផ្នែកមួយនៃគោលនយោបាយតភ្ជាប់សម្រាប់ឆ្នាំ ២០២១-២០២៧[32]។



**Source:**https://nordics.info/images.app.goo.gl/ Map of European Countries and UK//

### ៣. ៤. អាមេរិកខាងជើង (North America)

សហរដ្ឋអាមេរិក មានប្រជាជន ៣៣៩ ៤៩៩ ៥៩៩ នាក់ (បីរយសាមសិបប្រាំបួនលាន បួនរយកៅសិបប្រាំបួនពាន់ ប្រាំរយកៅសិបប្រាំបួននាក់)[33]។ ប្រទេសកា

---

[30] http://www.worldometers.info, the current population of European Union, 24/3/2023.//

[31] http://www.worldometers.info, the current population of United Kingdom (UK), 24/3/2023.//

[32] https://www.ec.europa.eu, the EU's main investment policy,4/4/2023//

[33] http://www.worldometers.info, the current population of United States of America, 24/3/2023.//

ណាដា មានប្រជាជន ៣៨៦៤០ ២៥១ នាក់ (សាមសិបប្រាំបីលាន ប្រាំមួយរយសែសិបពាន់ ពីររយហាសិបមួយនាក់)[34]។ សហរដ្ឋអាម៉េរិក និង ប្រទេសកាណាដា សប្បាយរីករាយនឹងទំនាក់ទំនងពាណិជ្ជកម្មពិភពលោកដ៏ធំជាងគេបង្អស់ និង ទំនាក់ទំនងពាណិជ្ជកម្មដ៏ទូលំទូលាយ ដែលជួយបង្កើតការបានរាប់លាននៅក្នុងប្រទេសនីមួយៗ និង បង្កើតពាណិជ្ជកម្មទ្វេភាគីដែលមានទំហំទឹកប្រាក់ ១,៧ ទ្រីលានដុល្លាអាម៉េរិក និង មានទំនាក់ទំនងក្នុងការធ្វើវិនិយោគ។ ជាទម្លាប់ កាណាដា គឺប្រទេសដែលជាទីផ្សារនាំចេញខ្ពស់បំផុតរបស់អាម៉េរិក ដែលមានទំហំទឹកប្រាក់ ១៧,៥ % នៃទំនិញនាំចេញរបស់អាម៉េរិកនៅក្នុងឆ្នាំ២០២១។ ប្រទេសកាណាដាបានក្លាយជាដៃគូពាណិជ្ជកម្មខ្ពស់បំផុត របស់អាម៉េរិក ធ្វើពាណិជ្ជកម្មប្រចាំថ្ងៃជាមួយគ្នាមានទឹកប្រាក់ជាង២ ពាន់លានដុល្លាអាម៉េរិក ក្នុងទំនិញ និង សេវាកម្ម។ ពាណិជ្ជកម្មទៅវិញទៅមកនៅក្នុងទំនិញ និង សេវាកម្ម សរុបជាទឹកប្រាក់មាន ៧៦២,៨ ពាន់លានដុល្លាអាម៉េរិក នៅក្នុងឆ្នាំ ២០២១ និង ការ វិនិយោគទំនិញសន្និធិទ្វេភាគីសរុបជាទឹកប្រាក់ ៩៣៤,៣ ពាន់លានដុល្លាអាម៉េរិក។

សហរដ្ឋអាម៉េរិកនាំទៅប្រទេសកាណាដាគឺជិតស្មើ ៣៦៥ ពាន់លានដុល្លាអាម៉េរិក នៅក្នុងឆ្នាំ២០២១។ សហរដ្ឋអាម៉េរិក បានដាក់ចំណាត់ថ្នាក់ឱ្យកាណាដាជាប់លេខ៣១ ដែលបាននាំចូលលើស បើប្រៀបធៀបទៅនឹងការនាំចេញរបស់សហរដ្ឋអាម៉េរិក ទៅកាន់ប្រទេសចិន ជប៉ុន និង ប្រទេសឥណ្ឌា បូកបញ្ចូលគ្នា ប្រសិនបើក្រុមហ៊ុនរបស់អ្នក ជាអ្នកនាំចេញជាលើកដំបូង ឬជាអ្នកនាំចេញតាមរដូវកាល ប្រទេសកាណាដា ជាប្រទេសដែលផ្តល់នូវធាតុគន្លឹះសម្រាប់ យុទ្ធសាស្រ្តកំណើន ការនាំចេញនៃក្រុមហ៊ុនរបស់អ្នក។ នៅក្នុង ២០២១ សហរដ្ឋអាម៉េរិកបាននាំទំនិញចេញទៅប្រទេសកាណាដាគិតជាទឹកប្រាក់ ៣០៨,៤ ពាន់លានដុល្លាអាម៉េរិក។ ប្រភេទទំនិញនាំចេញខ្ពស់បំផុត នៅក្នុងឆ្នាំ ២០២១ ទៅប្រទេសកាណាដា មានម៉ាស៊ីន៤៤ ពាន់លានដុល្លាអាម៉េរិក, យានយន្ត ៤៤ ពាន់លានដុល្លាអាម៉េរិក, គ្រឿងអេឡិចត្រូនិក២៤ ពាន់លានដុល្លាអាម៉េរិក ប្រេងឥន្ធនៈ២៣ ពាន់លានដុល្លាអាម៉េរិក និង ប្លាស្ទិក១៦ ពាន់លានដុល្លាអាម៉េរិក។ ការនាំចេញរបស់សហរដ្ឋអាម៉េរិកផ្នែកសេវាកម្មទៅកាន់ប្រទេសកាណាដា មានតម្លៃជាទឹកប្រាក់ ៥៦,១ ពាន់លានដុល្លាអាម៉េរិក នៅក្នុងឆ្នាំ ២០២១។ សេវាកម្មនាំមុខគេដែលនាំចេញពីសហរដ្ឋអាម៉េរិក ទៅប្រទេសកាណាដា មាន

[34] http://www.worldometers.info, the current population of Canada, 24/3/2023.//

សេវាកម្មមុខរបរ សេវាកម្មគ្រប់គ្រង និង ផ្នែកកម្មសិទ្ធិបញ្ញា[35]។




**Source:**https://www.pinterest.com/images.app.goo.gl/Map of Canada and USA//

## ៣. ៥. អាម៉េរិកឡាទីន (South American)

ប្រទេសប្រេស៊ីលមានប្រជាជន២១៦ ៦៥៩ ៥៦៦ នាក់ (ពីររយដប់ប្រាំមួយលានប្រាំមួយរយហាសិបប្រាំបួនពាន់ ប្រាំរយហុកសិបប្រាំមួយនាក់)[36]។ ប្រទេសអាសង់ទីន មានប្រជាជន ៤៦ ៣២១ ៣៦៧ នាក់ (សែសិបប្រាំមួយលាន បីរយម្ភៃមួយពាន់ បីរយហុកសិបប្រាំពីរនាក់)[37]។ នេះគឺជាមគ្គុទ្ទេសក៍របស់វិនិយោគិន ឆ្ពោះទៅអាម៉េរិកខាងត្បូងផ្តល់នូវ a one-stop shop សម្រាប់គេម្នាក់ៗយកចិត្តទុកដាក់ធ្វើនៅក្នុងប្រទេស Argentina (អាហ្សង់ទីន), Brazil (ប្រេស៊ីល), Bolivia (បូលីវី), Chile (ស៊ីលី), Colombia (កូឡុំប៊ី), Ecuador (អេក្វាទ័រ), Guyana (ហ្គីយ៉ាន), Paraguay (ប៉ារ៉ាហ្គាយ), Peru (ប៉េរូ), Suriname (សូរីណាម), Uruguay (អ៊ុយរូហ្គាយ), and Venezuela (វ៉េណេស៊ុយអេឡា)។ អាម៉េរិកខាងត្បូងមានតំបន់សេដ្ឋកិច្ចធំៗនៅតំបន់អាម៉េរិកឡាទីន និង តំបន់ការ៉ាប៊ីន។ ចំណុចខ្លាំងជារួមមាន៖ កសិកម្ម, ប្រេង, និង ទេសចរណ៍។ នៅក្នុងឆ្នាំ ២០២០ តំបន់អាម៉េរិកខាងត្បូងដែលមានការយកចិត្តទុកដាក់ច្រើនជាង៦០% នៃជីឌីភី សរុបរបស់តំបន់អាម៉េរិកឡាទីន, តំបន់ការីប៊ីននិង មានគម្រោងច្រើនជាង៥០% វិនិយោគផ្ទាល់ពីបរទេស។ ខណ:ពេលដែលមានសេដ្ឋកិច្ចជាច្រើននៅក្នុងតំបន់កំពុងរីកលូតលាស់សេដ្ឋកិច្ចទាំងនោះគ្មានការប្រកួតប្រជែងគ្នាទេ[38]។




[35]https://www. market overview, the United States and Canada trading, 8 March, 2023//
[36] http://www.worldometers.info, the current population of Brasilia, 24/3/2023.//
[37] http://www.worldometers.info, the current population of Argentina, 24/3/2023.//
[38]https://www.investmentmonitor, an investor's guide to South America, 5/April/2023.//

Source:https://www.pinterest.com/images.app.goo.gl/Map of South America//

## ៤.ផលប្រយោជន៍ទៅវិញទៅមក

ការធ្វើវិនិយោគលុះត្រាតែចំណេញទើបវិនិយោគិន យកចិត្តទុកដាក់ធ្វើ នេះជាសារជាតិអ្នកជំនួញ។ បរិយាកាសវិនិយោគកាន់តែល្អ នៅពេលដែលប្រទេសមួយមានសុខសន្តិភាព មានកម្លាំងពលកម្មគ្រប់គ្រាន់ កម្លាំងពលកម្មមានជំនាញច្រើនមុខ មានការបញ្ជាទិញផលិតផលទាំងក្នុង និង ក្រៅប្រទេសច្រើន និង មានទីផ្សារទូលំទូលាយប្រទេសនីមួយៗ មានទំនាក់ទំនងល្អទៅវិញទៅមកបង្កើនទំហំពាណិជ្ជកម្មទៅវិញទៅមកធ្វើយ៉ាងណាឱ្យមានផលចំណេញទៅវិញទៅមកទើបរក្សាការវិនិយោគបានយូរអង្វែង។ ព្រះរាជាណាចក្រកម្ពុជាបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគីរវាងប្រទេស កូរ៉េខាងត្បូង ចិន អារ៉ាប៊ីសាអូឌីត ....។ល។

## ៥.ចំណុចទាក់ទាញវិនិយោគិន

ដូចដែលខ្ញុំបានរៀបរាប់ខាងលើរួចហើយថាវិស័យ និង សកម្មភាពវិនិយោគដូចខាងក្រោមត្រូវទទួលការលើកទឹកចិត្ត៖(១) ឧស្សាហកម្ម ដែលមានបច្ចេកវិទ្យាខ្ពស់ប្រកបដោយនវានុវត្តន៍ និង ការស្រាវជ្រាវនិងអភិវឌ្ឍ, (២)ឧស្សាហកម្មនិងកម្មន្តសាលថ្មីៗផ្តល់តម្លៃបន្ថែមខ្ពស់មាន នវានុវត្តន៍ និង ភាពប្រកួតប្រជែងខ្ពស់, (៣)ឧស្សាហកម្មបម្រើឱ្យខ្សែច្រវាក់ផលិតកម្មតំបន់និងសកលលោក, (៤)ឧស្សាហកម្មគាំទ្រពាក់ព័ន្ធនឹងវិស័យកសិកម្ម ទេសចរណ៍ កម្មន្តសាល ឧស្សាហកម្មបម្រើឱ្យខ្សែច្រវាក់ផលិតកម្មតំបន់ និង សកលលោកនិងឧស្សាហកម្មតភ្ជាប់បណ្តាញផ្គត់ផ្គង់, (៥)ឧស្សាហកម្មគ្រឿងអគ្គិសនី និង អេឡិចត្រូនិក, (៦) ឧស្សាហកម្មគ្រឿងបន្លាស់ បង្គុំ និង តម្លើង, (៧)ឧស្សាហកម្មមេកានិក និង គ្រឿងម៉ាស៊ីន។ (៨)កសិកម្ម កសិឧស្សាហកម្ម ឧស្សាហកម្មកែច្នៃផលិតផលកសិកម្ម និង ឧស្សាហកម្មកែច្នៃចំណីអាហារដែលបម្រើទីផ្សារក្នុងស្រុកឬការនាំចេញ, (៩)សហគ្រាសធុនតូច និង មធ្យមក្នុងវិស័យអាទិភាព និង ការអភិវឌ្ឍបណ្តុំសហគ្រាសធុនតូច និង មធ្យមសួនឧស្សាហកម្ម និង សួនវិទ្យាសាស្ត្រ បច្ចេកវិទ្យា និង នវានុវត្តន៍, (១០)ឧស្សាហកម្មទេសចរណ៍ និង សកម្មភាពពាក់ព័ន្ធនឹងទេសចរណ៍, (១១)ការអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេស, (១២)ឧស្សាហកម្មឪជីថល,(១៣) ការវិនិយោគក្នុង វិស័យអប់រំ ការបណ្តុះបណ្តាលវិជ្ជាជីវៈនិងជំរុញផលិតភាព, (១៤) ការវិនិយោគក្នុងវិស័យសុខាភិបាល, (១៥) ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត (១៦)ការវិនិយោគក្នុងវិស័យឡូជីស្ទីក។ (១៧)ការ វិនិយោគក្នុងការគ្រប់គ្រង ការការពារបរិស្ថាន និង ការអភិរក្សជីវៈចម្រុះនិងសេដ្ឋកិច្ចចក្រ, (១៨)ការវិនិយោគក្នុងវិស័យថាមពលបៃតង បច្ចេកវិទ្យា ដែលរួមចំណែកដល់ការបន្សុាំ

និង ការកាត់បន្ថយការប្រែប្រួលអាកាសធាតុ , (១៩)វិស័យ និង សកម្មភាពវិនិយោគ ដែលមិនមានចែងក្នុងច្បាប់នេះក្នុងករណី ដែលរាជរដ្ឋាភិបាលយល់ឃើញថាមានស ក្តានុពលដល់ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច។ វិស័យនិងសកម្មភាពវិនិយោគដែលចែងក្នុង មាត្រា២៤ នៃច្បាប់នេះដែលមិនស្ថិតនៅក្នុង បញ្ជីវត្តមាន ត្រូវទទួលបានការលើកទឹកចិត្ត ជាមូលដ្ឋានផ្នែកពន្ធដារ និង/ឬ ពន្ធគយ ទាំងស្រុង ឬ មួយផ្នែកក្រោយទទួលបាន វិញ្ញាបនបត្រចុះបញ្ជីបញ្ជាក់ឋានៈជា គ. ល. គ.។ វិស័យនិងសកម្មភាពវិនិយោគ ដែល មានចែងក្នុងមាត្រា២៤ នៃច្បាប់នេះដែលពុំ ទទួលបានការលើកទឹកចិត្តទាំងផ្នែកពន្ធដារ និងពន្ធគយ ត្រូវបានកំណត់ក្នុងបញ្ជី អវិជ្ជមានដែលនឹងចែងដោយអនុក្រឹត្យ។

វិនិយោគិននឹងទទួលបាននូវប្រព្រឹត្ត កម្មមិនរើសអើងទាក់ទងនឹងបដិទានសំណង ឬ ដំណោះស្រាយជាតម្លៃសេដ្ឋកិច្ចផ្សេង ទៀត ក្នុងករណីការវិនិយោគរបស់ខ្លួនបាន ទទួលរងនូវការខូចខាត ដោយសារជម្លោះ ប្រដាប់អាវុធ ឬ កលិយុគស៊ីវិល ឬ ការ ដាក់ប្រទេសជាតិស្ថិតនៅក្នុងភាពអាសន្ន ប្រសិនបើមានច្បាប់ និង គោលនយោបាយ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការធ្វើ បដិទានឬផ្តល់សំណងសមរម្យណាមួយ នោះ។ វិនិយោគិនបរទេសមិនត្រូវជាកម្មវត្ថុ នៃការរើសអើង ដោយសារមូលហេតុ សញ្ជាតិបរទេស លើកលែងតែកម្មសិទ្ធិលើដី ធ្លី ដូចដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជានិងបទប្បញ្ញត្តិ ទាំងឡាយជាធរមាន។ រដ្ឋមិនត្រូវធ្វើជាតូបនីយកម្មដែលនាំឱ្យប៉ះពាល់ដល់ទ្រព្យសម្បត្តិ របស់វិនិយោគិន ក្នុងព្រះរាជាណាចក្រកម្ពុជាឡើយ។ រដ្ឋមិនត្រូវធ្វើអស្សាមិករណ៍ដែល នាំឱ្យប៉ះពាល់ដល់គម្រោងវិនិយោគ ដែល បានទទួលការអនុម័តនោះឡើយ ទោះបី ដោយផ្ទាល់ឬដោយប្រយោលឬតាមរយៈ វិធានការប្រហាក់ប្រហែលនឹងការធ្វើ អស្សាមិករណ៍ក្តី លើកលែងតែក្នុងករណី បម្រើប្រយោជន៍សាធារណៈ ដែលការធ្វើ អស្សាមិករណ៍នេះត្រូវអនុវត្តតាមលក្ខខណ្ឌ ដូចតទៅ៖ (១)ភាពមិនរើសអើង, (២) សំណងដោយសមរម្យនិងយុត្តិធម៌ (៣)អនុលោមតាមច្បាប់និងនីតិវិធីអស្សាមិករណ៍ជាធរមាន។

រាជរដ្ឋាភិបាលមិនត្រូវកំណត់ថ្លៃ ផលិតផល ឬ ថ្លៃសេវានានាដែលបង្កើត ដោយគម្រោងវិនិយោគនោះឡើយ។ ដោយ អនុលោមទៅតាមច្បាប់ និង លិខិតបទដ្ឋាន គតិយុត្តជាធរមាន វិនិយោគិនមានសិទ្ធិទិញ រូបិយបណ្ណបរទេសដោយសេរី និង បង្វិល ទៅបរទេសនូវរូបិយបណ្ណបរទេសទាំងអស់ នោះដើម្បីទូទាត់កាតព្វកិច្ចខាងហិរញ្ញវត្ថុ ដែលពាក់ព័ន្ធនឹងការវិនិយោគរបស់ខ្លួន តាមរយៈប្រព័ន្ធធនាគារដែលជា**អន្តរការី ប្រតិស្រុតិ**។ ការផ្ទេរទាំងនេះរាប់បញ្ចូលទាំង ៖ (១)វិភាគទានចំពោះមូលធនបឋម, (២)

ប្រាក់ចំណូល ចំណេញមូលធន ភាគលាភ កម្រៃសួយសារ កម្រៃអាជ្ញាបណ្ណ កម្រៃនៃការគ្រប់គ្រង និង ជំនួយបច្ចេកទេស ការប្រាក់ និង ប្រាក់ចំណូលដទៃទៀតដែលកើតពីការវិនិយោគ

(៣)ផលដែលទទួលបានពីការលក់សរុប ឬការលក់មួយផ្នែកឬការរំលាយក្រុមហ៊ុនដែល អនុវត្តគម្រោងវិនិយោគ, (៤)ការទូទាត់លើការនាំចូល និង ការបង្វិលទៅក្រៅប្រទេសទាំងប្រាក់ដើម និង ការប្រាក់នៃប្រាក់កម្ចី, (៥)ការទូទាត់ចំពោះសំណងក្នុងករណីមានកលិយុគស៊ីវិល ក្នុងករណីមានអស្សាមិករណ៍ឬការដកហូតដោយរដ្ឋ, (៦) ការទូទាត់កើតឡើងពីដំណោះស្រាយវិវាទដោយមធ្យោបាយណាមួយ រាប់បញ្ចូលទាំងសេចក្តីសម្រេចរបស់តុលាការ ឬ សេចក្តីសម្រេចរបស់មជ្ឈត្តការ និង (៧)ចំណូលនិងប្រាក់ឈ្នួលដទៃទៀតរបស់និយោជិត។

កម្មសិទ្ធិបញ្ញារបស់វិនិយោគិនត្រូវបានការពារដោយអនុលោមតាមច្បាប់ និង លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងកម្មសិទ្ធិបញ្ញានៃព្រះរាជាណាចក្រកម្ពុជា។ កម្មសិទ្ធិលើដីធ្លីរបស់វិនិយោគិនសម្រាប់បម្រើឱ្យគោលដៅអនុវត្តគម្រោងវិនិយោគ ត្រូវបានអនុញ្ញាតចំពោះបុគ្គលដែលមានសញ្ជាតិខ្មែរ ស្របតាមច្បាប់ និង លិខិតបទដ្ឋានគតិយុត្តជាធរមាន។ វិនិយោគិនមានសិទ្ធិប្រើប្រាស់ដីធ្លីតាមរយៈជាអាទិ៍ សម្បទានដីសេដ្ឋកិច្ច ឬ សិទ្ធិជួលអចិន្ត្រៃយ៍ និង ការជួលដែលមានអំឡុងពេលកំណត់ស្របតាមច្បាប់ និង លិខិតបទដ្ឋានគតិយុត្តជាធរមាន។ បុគ្គលដែលត្រូវបានចាត់ទុកជាវិនិយោគិនដោយផ្អែកទៅលើច្បាប់នេះ មានសិទ្ធិដូចតទៅះ (១)សិទ្ធិជួលនិយោជិតបរទេស ដើម្បីគ្រប់គ្រងឬប្រតិបត្តិការគម្រោងវិនិយោគ ក្នុងចំនួនមិនលើសពីចំនួន ដែលបានកំណត់ដោយច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ក្នុងករណីពុំអាចរកនិយោជិតខ្មែរដែលមានជំនាញដើម្បីគ្រប់គ្រងឬប្រតិបត្តិការគម្រោងវិនិយោគនោះ។ ការអនុញ្ញាតឱ្យជួលនិយោជិតបរទេសនេះគឺត្រូវពិនិត្យទៅតាមស្ថានភាពជាក់ស្តែង និងពុំមានលក្ខណៈអចិន្ត្រៃយ៍ទេ។ (២)សិទ្ធិទទួលបានការអនុញ្ញាតស្នាក់នៅបណ្តោះអាសន្នរយៈពេលវែងសម្រាប់ខ្លួនឯងផ្ទាល់ សម្រាប់សហព័ទ្ធ និង កូនដែលជាអនីតិជន ក្នុងអំឡុងពេលដែលគម្រោងវិនិយោគរបស់ខ្លួនមានប្រតិបត្តិការ។ (៣)សិទ្ធិស្នើសុំការអនុញ្ញាតស្នាក់នៅបណ្តោះអាសន្ន រយៈពេលវែងសម្រាប់និយោជិតបរទេស និង សម្រាប់សហព័ទ្ធនិងកូនដែលជាអនីតិជនរបស់និយោជិតបរទេសទាំងនេះ ក្នុងអំឡុងពេលដែលកិច្ចសន្យាការងារនៅមានសុពលភាព។ (៤)សិទ្ធិទទួលបានបណ្ណការងារ និង សៀវភៅការងារសម្រាប់ខ្លួនឯងផ្ទាល់ និង សម្រាប់និយោជិតបរទេសរបស់ខ្លួន។

ក. អ. ក. ឬអនុគណៈកម្មាធិការរាជធានី ខេត្ត ត្រូវចេញលិខិតបញ្ជាក់អំពីឋានៈ

*ជាវិនិយោគិនជូនបុគ្គលពាក់ព័ន្ធនឹងគម្រោងវិនិយោគទៅតាមការស្នើសុំរបស់វិនិយោគិន ដើម្បីប្រើប្រាស់សម្រាប់ការស្នើសុំការអនុញ្ញាតស្នាក់នៅបណ្ដោះអាសន្នរយៈពេលវែង បណ្ណការ និង សៀវភៅការងារ និងគោលបំណងចាំបាច់ដទៃទៀតស្របតាមនីតិវិធីជាធរមាន។ នីតិវិធីពិសេសសម្រាប់ការស្នើសុំបណ្ណការងារនិងសៀវភៅការងារ ដូចមានចែងនៅក្នុងមាត្រា២២ នៃច្បាប់ស្ដីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា នេះត្រូវកំណត់នៅក្នុងប្រកាសរួមរវាង ក. អ. ក. និង ក្រសួងទទួលបន្ទុកវិស័យការងារ។ បែបបទ និង នីតិវិធីពិសេសសម្រាប់ស្នើសុំការអនុញ្ញាតស្នាក់នៅបណ្ដោះអាសន្នរយៈពេលវែង ដូចមានចែងនៅក្នុងមាត្រា២២ នេះត្រូវកំណត់ដោយអនុក្រឹត្យដោយឡែក។*

*វិនិយោគិនមានសិទ្ធិទទួលបាននូវសេវាថៃទាំវិនិយោគចំពោះគម្រោងវិនិយោគដែលបានចុះបញ្ជីនៅ ក. អ. ក. ឬ អនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្ត។ លក្ខខណ្ឌ បែបបទ និង នីតិវិធីនៃការផ្ដល់សេវាថៃទាំវិនិយោគចំពោះគម្រោងវិនិយោគត្រូវកំណត់ដោយអនុក្រឹត្យ។*

## សេចក្តីសន្និដ្ឋាន

*សរុបសេចក្ដីមកការវិនិយោគដែលរៀបចំផែនការច្បាស់លាស់និងមានលក្ខណៈទូលំទូលាយគ្រប់ជ្រុងជ្រោយលើវិស័យសំខាន់ៗចាំបាច់ដូចជាការលើកកម្ពស់ធនធានមនុស្ស ហេដ្ឋារចនាសម្ព័ន្ធទឹក និង ភ្លើងអគ្គិសនី គឺជាប្រភពចំណេញទៅវិញទៅមកមិនចេះរីងស្ងួត ឆ្លើយតបទៅនឹងតម្រូវការជាក់ស្ដែងក្នុងក្របខណ្ឌ ទូទាំងប្រទេស និយាយជារួមនិងនិយាយដោយឡែក តាមខេត្តនីមួយៗបច្ចុប្បន្ននេះ មានតម្រូវការចាំបាច់ផ្សេងៗគ្នា* ***ក្នុងវិស័យកសិកម្ម*** *ដូចជា វិនិយោគទៅលើប្រព័ន្ធធារាសាស្ត្រ ពូជដំណាំ សំខាន់ៗដែលធននឹងបម្រែបម្រួលអាកាសធាតុ។ ការផលិតជីសរីរាង្គ ជីធម្មជាតិ ការដាំដំណាំ យុទ្ធសាស្ត្រសម្រាប់នាំចេញទៅលក់នៅក្រៅប្រទេសដូចជា គ្រាប់ស្វាយចន្ទី អង្ករក្រអូប ស្រាដំណើបខ្មៅ ដូងក្រអូប ស្ករអំពៅ ស្ករត្នោត។ល។ ជាមួយគ្នានេះដែរ ការវិនិយោគដែលទាក់ទងនឹងម្ហូបអាហារ ត្រីសាច់ ទាំងត្រីទឹកសាបនិង ត្រីទឹកប្រៃ ក៏បានទទួលផលចំណេញយ៉ាងគ្រាស់ក្រៃលផងដែរ ទាំងនេះគឺជាទីតាំងវិនិយោគដ៏ល្អសម្រាប់វិនិយោគិន។*

***ក្នុងវិស័យឧស្សាហកម្ម*** *ប្រទេសកម្ពុជាបាននិងកំពុង វិនិយោគលើវិស័យកាត់ដេរ សម្លៀកបំពាក់ និង វិស័យថាមពលវារីអគ្គិសនី ថាមពលពន្លឺព្រះអាទិត្យក៏ជាចំណុចវិនិយោគដែលវិនិយោគិន ទទួលផលចំណេញសម្រាប់ រយៈពេលវែង ឆ្លើយតបទៅនឹងតម្រូវការទាំងរដ្ឋ និង ឯកជន។ ក្នុងវិស័យឧស្សាហកម្មធុនធ្ងន់ រួមមាន ក្រុមហ៊ុនរថយន្តហ្វត* (Ford Company) *របស់សហរដ្ឋអាម៉េរិក ក្រុមហ៊ុន*

តូយ៉ូតា (Toyota Company) របស់ប្រទេសជប៉ុន ក្រុមហ៊ុន (Hyundai Company) របស់ប្រទេសកូរ៉េខាងត្បូង ក្រុមហ៊ុនមីនីបៀផលិតម៉ូទ័រ (Minebea Company) របស់ប្រទេសជប៉ុន ក្រុមហ៊ុនជីអេស៊ីម៉ូទ័រ (GAC Motor Company) របស់ប្រទេសចិន ក្រុមហ៊ុន Chevrolet (General Motors Company) របស់សហរដ្ឋអាមេរិក ក្រុមហ៊ុន Mercedes (Mercedes Company) របស់ប្រទេសអាល្លឺម៉ង់ ។ល។

លើសពីនេះទៀត **វិស័យសេវាកម្ម** ក៏បាននិងកំពុងរួមចំណែករកប្រាក់ចំណូលបានយ៉ាងក្រាស់ក្រែលផងដែរ។ នៅក្នុងប្រទេសប្រទេសដែលរីកលូតលាស់ខាងឧស្សាហកម្មក្នុងចំណោមវិស័យទាំងបីៈ កសិកម្ម ឧស្សាហកម្ម និង សេវាកម្ម គេសង្កេតឃើញថា វិស័យសេវាកម្ម មានភាគរយខ្ពស់ជាងគេ។ នៅព្រះរាជាណាចក្រកម្ពុជា បាននិងកំពុង វិនិយោគលើវិស័យ សេវាកម្មនេះផងដែរ ដូចជាការដឹកជញ្ជូនតាមយន្តហោះ រាជរដ្ឋាភិបាលអនុញ្ញាតឱ្យសាងសង់ព្រលានយន្តហោះខ្នាតអន្តរជាតិដែលយន្តហោះប៊ូអ៊ីងអាចចុះចតបាន ព្រលានយន្តហោះទាំងនោះមានដូចជា ព្រលានយន្តហោះភ្នំពេញ ក្រុងតាខ្មៅ វិនិយោគដោយលោកឧកញ៉ា **ពុង ខៀវសែ** ដែលជាវិនិយោគិនក្នុងស្រុក ព្រលានយន្តហោះខេត្តសៀមរាប ត្រូវបានវិនិយោគដោយវិនិយោគិនចិន នឹងបើកឱ្យដំណើរការនៅខែតុលា ឆ្នាំ២០២៣ នាពេលខាងមុខនេះ។ តាមផ្លូវគោក រាជរដ្ឋាភិបាលយកចិត្តទុកដាក់សាងសង់ហេដ្ឋារចនាសម្ព័ន្ធរឹងមាំទាំងផ្លូវថ្នល់ ដែលចែកចេញជាផ្លូវលំ និងផ្លូវជាតិ ក្នុងនោះរាជរដ្ឋាភិបាលជំរុញឱ្យមានផ្លូវល្បឿនផងដែរ។ រីឯផ្លូវដែករាជរដ្ឋាភិបាលក៏បានយកចិត្តទុកដាក់ជួលជុលផ្លូវដែកដែលមានស្រាប់ចំនួនពីរខ្សែ និង មានគម្រោងសាងសង់ផ្លូវដែកល្បឿនលឿននៅពេលឆាប់ៗខាងមុខនេះ។ លើសពីនេះទៅទៀត រាជរដ្ឋាភិបាលយកចិត្តទុកដាក់កែលម្អកំពង់ផែក្រុងព្រះសីហនុឱ្យទៅជាកំពង់ផែទឹកជ្រៅដែលអាចទទួលនាវាខ្នាតអន្តរជាតិបាន។ សេវាដឹកជញ្ជូនតាមផ្លូវទឹកទទួលផលចំណេញបានច្រើនណាស់ពីព្រោះវាមានតម្លៃថោក និង នាវាអាចផ្ទុកទំនិញបានច្រើនបើប្រៀបធៀប ទៅនឹងសេវាដឹកជញ្ជូនតាមផ្លូវគោក និង ផ្លូវអាកាស។

តាមការសិក្សាស្រាវជ្រាវ និង សរសេរតាមលំដាប់លំដោយខាងលើបញ្ជាក់យ៉ាងច្បាស់ថា ការវិនិយោគគឺពិតជាទាក់ទងយ៉ាងជិតស្និទ្ធទៅនឹង**ច្បាប់វិនិយោគ ច្បាប់ពាណិជ្ជកម្មសេរីទ្វេភាគី ច្បាប់ពាណិជ្ជកម្មសេរីពហុភាគី តំបន់ពាណិជ្ជកម្មសេរី** និង **ទំហំទីផ្សារ** សម្រាប់នាំចេញនាំចូលនូវផលិតផលដែលផលិតបានយកទៅលក់ដើម្បីបានប្រាក់ចំណេញ។ លើសពីនេះទៅទៀត **កត្តាសុខសន្តិភាព ស្ថេរភាព**

**នយោបាយ** ទីតាំងអំណោយផលក្នុងការផលិត ទំនិញ ថ្លៃឈ្នួលកម្លាំងពលកម្មថោកៗ វិនិយោគិនបរទេសអាចមានសិទ្ធិបោះទុន ១០០% តែឯងបានៗ វិនិយោគិននឹងទទួលបាននូវប្រព្រឹត្តកម្មមិនរើសអើង ទាក់ទងនឹងបដិទាន សំណង ឬ ដំណោះស្រាយជាតម្លៃសេដ្ឋកិច្ចផ្សេងៗទៀតៗ វិស័យ និងសកម្មភាពវិនិយោគមួយចំនួនធំ ត្រូវទទួលបានការលើកទឹកចិត្តពីរដ្ឋាភិបាលៗ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាគឺជាស្ថាប័នប្រតិបត្តិបំពេញមុខងារជាសេនាធិការនិងជាច្រកចេញចូលតែមួយរបស់រាជរដ្ឋាភិបាលលើបេសកកម្មដឹកនាំ និង គ្រប់គ្រងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ ការវិនិយោគឯកជន និងតំបន់សេដ្ឋកិច្ចពិសេសៗ ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា**ការវិនិយោគពិតជានាំជោគជល់កម្ពុជា** នឹងកើនឡើងបន្ថែមទៀត ទាំងវិស័យកសិកម្ម ឧស្សាហកម្ម និង សេវាកម្ម ដែលជាកម្លាំងចលករ ជួយជំរុញកំណើនសេដ្ឋកិច្ចនៃព្រះរាជាណាចក្រកម្ពុជា នាពេលបច្ចុប្បន្ន និង ទៅអនាគតបន្ថែមទៀត៕

# ឯកសារយោង


១.រាជរដ្ឋាភិបាលកម្ពុជា ៖ ***ច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា*** ភ្នំពេញ ក្រុមប្រឹក្សាអ្នកច្បាប់ ឆ្នាំ ២០២១។

២.ហ៊ាន សាហ៊ីប ៖ ***គ្រប់គ្រងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ*** ភ្នំពេញ ការផ្សាយរបស់អ្នកនិពន្ធ ឆ្នាំ ២០០៦។

៣.រាជរដ្ឋាភិបាលកម្ពុជា ៖ ***យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤*** ភ្នំពេញ ការផ្សាយរបស់រាជរដ្ឋាភិបាល នីតិកាលទី៦នៃរដ្ឋសភា ឆ្នាំ ២០១៨។

៤.ទីស្តីការគណៈរដ្ឋមន្ត្រី ៖ ***សទ្ទានុក្រមឈ្មោះប្រទេស, រាជធានី***, ក្រុមប្រឹក្សាជាតិភាសាខ្មែរ ភ្នំពេញ ឆ្នាំ ២០១៣។

៥.ទីស្តីការគណៈរដ្ឋមន្ត្រី ៖ ***សទ្ទានុក្រមពាក្យច្បាប់*** ភ្នំពេញ ការផ្សាយរបស់គណៈកម្មការបណ្ឌិត្យសភាទទួលបន្ទុកអនុម័តពាក្យច្បាប់ ឆ្នាំ ២០០៧។

៦.រាជរដ្ឋាភិបាលកម្ពុជា ៖ ***ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣*** ភ្នំពេញ ឆ្នាំ ២០១៩។

៧.http://w.w.w.en.m.wikipedia, the current population of South East Asian Nations, as of Thursday, March, 23, 2023, worldometers.info,//

៨.https://www.statista.com,statistics, the GDP of the ASEAN in 2023, dated on 4/4/2023//

៩.http://www.worldometers.info, the current population of China, 24/3/2023.//

១០. http://www.worldometers.info, the current population of Japan, 24/3/2023.//

១១.https://www.ec.europa.eu, the EU׳s main investment policy,4/4/2023//

១២. https://www. market overview, the United States and Canada trading, 8 March, 2023//

១៣.https://www.investmentmonitor, an investor׳s guide to South America, 5/April/2023.//

១៤.http://www.worldometers.info, the world population is the sum total of all living humans on earth. Thursday, march, 23,2023, based on the latest United Nations estimates.,...//

១៥.Royal Government of Cambodia, ***Small and Medium Enterprise*** Development Framework,Phnom Penh, July 22, 2005.

១៦.Royal Government of Cambodia, ***Cambodia Industrial Development Policy 2015-2025,***Phnom Penh, 6 March,2015.

១៧.World Trade Organization, ***Opening Markets for Trade in Services***, Countries and Sectors in Bilateral and WTO Negotiations, Cambridge, 2008.

# ឧបសម្ព័ន្ធ

## ១.តំបន់សេដ្ឋកិច្ចពិសេស របស់ប្រទេសកម្ពុជា



## ២. ផែនទីប្រទេសកាណាដា និង សហរដ្ឋអាមេរិក



# ការរៀបចំនិងប្រព្រឹត្តទៅនៃតួនាទី និងអំណាចរដ្ឋបាលឃុំ សង្កាត់


ដោយៈ **បណ្ឌិត ហ៊ឹម ញាណារិទ្ធ**

មន្ត្រីស្រាវជ្រាវនៃវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម

នៃរាជបណ្ឌិត្យសភាកម្ពុជា


## ១- សេចក្តីផ្តើម

ការគ្រប់គ្រងរដ្ឋបាលតាមបែបវិមជ្ឈការ គឺជាប្រព័ន្ធនៃការគ្រប់គ្រងរដ្ឋបាលដែលរដ្ឋបាលកណ្តាលផ្ទេរអំណាចទៅឱ្យរដ្ឋបាលមូលដ្ឋាន ដែលមានរដ្ឋបាលឃុំ សង្កាត់។ ការផ្ទេរអំណាចបែបនេះ ក្នុងគោលបំណងឱ្យរដ្ឋបាលមូលដ្ឋាន ទទួលខុសត្រូវលើកិច្ចការទាំងឡាយណាដែលជាប្រយោជន៍របស់ខ្លួនផងដែរ។

ការរៀបចំគ្រប់គ្រងរដ្ឋបាលថ្នាក់ឃុំ សង្កាត់តាមបែបវិមជ្ឈការបានចាប់ផ្តើមអនុវត្តតាំងពីឆ្នាំ២០០១ក្នុងរូបភាពផ្តល់ស្វ័យភាពដល់ថ្នាក់មូលដ្ឋានឃុំ សង្កាត់ តាមរយៈច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងច្បាប់ ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អនុម័តឆ្នាំ២០០១ ព្រមទាំងលិខិតបទដ្ឋានគតិយុត្តជាច្រើនទៀត។

បច្ចុប្បន្នការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់បានធ្វើឡើងចំនួនប្រាំលើកមកហើយ នៅក្នុងឆ្នាំ២០០២ ឆ្នាំ២០០៧ ឆ្នាំ២០១២ ឆ្នាំ២០១៧ និងឆ្នាំ២០២២ ប្រកបដោយជោគជ័យ។

ទោះបីការអនុវត្តក្របខណ្ឌច្បាប់ នៃកំណែទម្រង់វិមជ្ឈការ បានជឿនលឿនទៅមុខក្តី ក៏នៅមិនទាន់មានការត្រួតពិនិត្យជាប្រព័ន្ធអំពីជោគជ័យសំខាន់ៗ ដែលសម្រេចបានមកទល់បច្ចុប្បន្ននេះទេ។ ការសិក្សាពីមុនៗបានផ្តល់គំនិតខុសៗគ្នា អំពីការសម្រេចបាននិងអនាគតនៃកំណែទម្រង់។

ក្នុងការអនុវត្តនយោបាយវិមជ្ឈការនៅរដ្ឋបាលមូលដ្ឋានឃុំ សង្កាត់ មានការវិវត្តរីកចម្រើនគួរឱ្យកត់សម្គាល់។

## ២- ស្ថានភាពទូទៅនៃការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់

ប្រទេសកម្ពុជាបានឆ្លងផុតពីរបបដ៏ខ្មៅងងឹតកម្ពុជាប្រជាធិបតេយ្យ អស់រយៈកាល៣ឆ្នាំ៨ខែនិង២០ថ្ងៃ គឺចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី០៧ ខែមករា ឆ្នាំ១៩៧៩។ នៅពេលនោះ ហើយដែលរបបសាធារណរដ្ឋប្រជាមានិតកម្ពុជាបានបង្កើតឡើងនាថ្ងៃទី០៧ ខែមករា ឆ្នាំ១៩៧៩ ដោយមានការជួយឧបត្ថម្ភពីកងកម្លាំងវៀតណាម។ ហើយបានដូរឈ្មោះ

ពី កម្ពុជាប្រជាធិបតេយ្យ ទៅជាសាធារណៈរដ្ឋប្រជាមានិតកម្ពុជា។

ដែនដីនៃសាធារណរដ្ឋប្រជាមានិតកម្ពុជាត្រូវបែងចែកជា ខេត្ត និងក្រុង ចំណុះរដ្ឋអំណាចមជ្ឈិមផ្ទាល់។ ខេត្ត ត្រូវបែកចែកជាស្រុក។ ស្រុក ត្រូវបែកចែកជា ឃុំ។ ក្រុងចំណុះរដ្ឋអំណាចមជ្ឈិមផ្ទាល់ ត្រូវបែងចែកជាសង្កាត់[១]។

ការគ្រប់គ្រងរដ្ឋបាលតាមរយៈកែប្រែរដ្ឋធម្មនុញ្ញ នៅឆ្នាំ១៩៨៩ បានកែសម្រួល ការបែងចែកទឹកដី ដូចជា ដែនដីនៃរដ្ឋកម្ពុជា ត្រូវបែងចែកជា ខេត្ត និងក្រុង ចំណុះរដ្ឋអំណាចមជ្ឈិមផ្ទាល់។ ខេត្តត្រូវបែកចែកជាទីរួមខេត្ត និងស្រុក។ ទីរួមខេត្តត្រូវបែងចែកជាសង្កាត់។ ស្រុកត្រូវបែកចែកជាឃុំ។ ក្រុងចំណុះរដ្ឋអំណាចមជ្ឈិមផ្ទាល់ ត្រូវបែងចែកជាខណ្ឌ និងស្រុកជាយក្រុង។ ខណ្ឌត្រូវបែងចែកសង្កាត់។ ស្រុកជាយក្រុងត្រូវបែងចែកដូចស្រុកចំណុះខេត្ត[២]។ ការបែងចែកទឹកដី និងការគ្រប់គ្រងរដ្ឋបាលតាមការបែងចែកនោះ បានបន្តរហូតមកដល់ឆ្នាំ១៩៩៣[៣]។

ផ្អែកតាមសន្ធិសញ្ញាសន្តិភាព ទីក្រុងប៉ារីស ថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ ប្រទេសកម្ពុជាបានរៀបចំបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រលើកទីមួយ ដោយមានការគាំទ្រសំណាក់ពីអាជ្ញាធរបណ្ដោះអាសន្នរបស់អង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា(UNTAC) នៅថ្ងៃទី២៣ ខែឧសភា ឆ្នាំ១៩៩៣។ តាមរយៈការបោះឆ្នោតនេះ រដ្ឋធម្មនុញ្ញថ្មីមួយត្រូវបានបង្កើតឡើងថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ បានចែងអំពីអធិបតេយ្យ របបគ្រប់គ្រងប្រទេសតាមបែបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ របបគ្រប់គ្រងរដ្ឋបាល ជាដើម។

ទឹកដីនៃព្រះរាជាណាចក្រកម្ពុជាចែកជា រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់[៤]។ ខេត្តចែកជាក្រុង និងស្រុក។ ក្រុងចែកជា សង្កាត់ ហើយស្រុកចែកជា ឃុំ សង្កាត់។ រាជធានីភ្នំពេញចែកចេញជា ខណ្ឌ។ ខណ្ឌចែកជា សង្កាត់។ ដោយឡែកភូមិមិនមែនជាថ្នាក់របស់រដ្ឋបាល ឡើយ។

ព្រឹត្តិការណ៍សំខាន់ៗ ដែលទាក់ទងការបោះឆ្នោតឃុំ សង្កាត់ រួមមាន ៖

-ឆ្នាំ១៩០៨ ប្រទេសកម្ពុជាបោះឆ្នោតរើសមេឃុំលើកដំបូងរើសតែម្នាក់ គឺមេឃុំ

-ឆ្នាំ១៩២៥ បោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ (ប្រើដូចសព្វថ្ងៃគ្រាន់តែគ្មានសង្កាត់)

-ឆ្នាំ១៩៥៩ បោះឆ្នោតជ្រើសរើស ក្រុមប្រឹក្សាជំនុំឃុំ

[១] មាត្រា៧១ រដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា

[២] មាត្រា៧១ រដ្ឋធម្មនុញ្ញនៃរដ្ឋកម្ពុជា

[៣] សក់ សេដ្ឋា ៖ ប្រវត្តិនៃអភិបាលកិច្ចមូលដ្ឋាន វិមជ្ឈការ និងវិសហមជ្ឈការ និងក្របខណ្ឌច្បាប់សម្រាប់វិមជ្ឈការ និងវិសហមជ្ឈការនៅកម្ពុជា ភ្នំពេញ ២០០៨ ទំព័រ៥

[៤] មាត្រា១៤៥ថ្មី (មួយ) រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា បច្ចុប្បន្នភាព ខែតុលា ឆ្នាំ២០១៤

-ឆ្នាំ១៩៨២ បោះឆ្នោតជ្រើសរើស គណៈកម្មាធិការប្រជាជនបដិវត្តឃុំ

-ឆ្នាំ២០០២ ២០០៧ ២០១២ ២០១៧និង ២០២២ បោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់។

## ២.១- រចនាសម្ព័ន្ធរដ្ឋបាលឃុំ សង្កាត់

រដ្ឋបាលឃុំ សង្កាត់ត្រូវបានគ្រប់គ្រងដោយច្បាប់ ស្តីពី ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនាឆ្នាំ ២០០១។

ឃុំ សង្កាត់ ជានិតីបុគ្គល[៥]។ ដូច្នេះ ឃុំ សង្កាត់ត្រូវមានតំណាងរបស់ខ្លួនដើម្បីដឹកនាំ និងគ្រប់គ្រងកិច្ចការដែលស្ថិតនៅក្រោមដែនសមត្ថកិច្ចរបស់ឃុំ សង្កាត់ត្រូវបំពេញតួនាទីមុខងារនិងអំណាចរបស់ខ្លួន ស្របទៅតាមកំណត់របស់ច្បាប់។ ឃុំ សង្កាត់ ត្រូវតែមានហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិផ្ទាល់។ ប៉ុន្តែឃុំសង្កាត់ ត្រូវក្រោមអាណាព្យាបាលរបស់រដ្ឋ។

### ២.២.១- ក្រុមប្រឹក្សាឃុំ សង្កាត់

ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវបន្តអនុវត្តច្បាប់ ស្តីពី ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់និងលិខិតបទដ្ឋានពាន់ព័ន្ធនានា។ ប៉ុន្តែ លើកលែងតែគោការណ៍ដូចមានចែងក្នុងមាត្រា៨៨ នៃផ្នែកទី៦ផ្នែកទី៧ផ្នែកទី៨ផ្នែកទី៩ នៃជំពូកទី២ និងគោលការណ៍ នៃជំពូកទី៥នៃច្បាប់នេះ។

រដ្ឋបាលឃុំ សង្កាត់ ត្រូវគ្រប់គ្រងដោយក្រុមប្រឹក្សាឃុំ សង្កាត់។ ក្រុមប្រឹក្សាឃុំ សង្កាត់ តំណាងឱ្យអំណាចនិតីបញ្ញត្តិ ហើយក៍ជាអ្នកសម្រាប់រាល់កិច្ចការក្នុងឃុំ សង្កាត់ផងដែរ។ ក្រុមប្រឹក្សាឃុំ សង្កាត់មានអណត្តិប្រាំឆ្នាំ។ ក្រុមប្រឹក្សាឃុំ សង្កាត់ ជាអង្គតំណាងឱ្យប្រជាពលរដ្ឋក្នុងឃុំ សង្កាត់របស់ខ្លួន។ ហើយមានបេសកកម្មបម្រើផលប្រយោជន៍ទូទៅក្នុងឃុំ សង្កាត់របស់ខ្លួន។

ការរៀបចំក្រុមប្រឹក្សាឃុំ សង្កាត់ ភូមិជាច្រើនរួមគ្នាបង្កើតបានជាឃុំ ឬសង្កាត់មួយ។ ឃុំ សង្កាត់ «គឺជារដ្ឋបាលឃុំ សង្កាត់ដែលស្ថិតក្រោមដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ៗ»។

យោងតាមច្បាប់ ស្តីពី ការគ្រប់គ្រងរដ្ឋបាលឃុំសង្កាត់ «ឃុំ សង្កាត់ ជានីតិបុគ្គល»។ ឃុំ សង្កាត់នីមួយៗ មានក្រុមប្រឹក្សាមួយហៅថា «ក្រុមប្រឹក្សាឃុំ សង្កាត់» ក្រុមប្រឹក្សាឃុំសង្កាត់ត្រូវ បានជ្រើសរើសឡើងតាមការបោះឆ្នោតដោយប្រជាពលរដ្ឋក្នុងឃុំ សង្កាត់របស់ខ្លួនដែលមានអាណត្តិប្រាំឆ្នាំ ហើយត្រូវផុតកំណត់នៅពេលដែលមានក្រុមប្រឹក្សាឃុំ សង្កាត់ថ្មីចូលកាន់តំណែង។

ឃុំ សង្កាត់នីមួយៗ មានក្រុមប្រឹក្សាមួយហៅថា ក្រុមប្រឹក្សាឃុំ សង្កាត់។ ក្រុមប្រឹក្សាឃុំ

[៥] មាត្រា២ ច្បាប់ ស្តីពី ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់

សង្កាត់ មានសមាជិកប្រែប្រួលទៅតាមប្រជាសាស្ត្រ និងភូមិសាស្ត្រ គឺមានចំនួនពី៥រូប ទៅ ១១រូប (៥រូប ៧រូប ៩រូប និង១១រូប)។

អំណាចដឹកនាំ និងគ្រប់គ្រងឃុំ សង្កាត់ ត្រូវបានមកដោយការបោះឆ្នោតជាទូទៅ ជាសកល ដោយសេរី ត្រឹមត្រូវនិងយុត្តិធម៌ ដោយស្មើភាព ដោយចំពោះ ដោយសម្ងាត់ក្នុងក្របខ័ណ្ឌឃុំ សង្កាត់នីមួយៗ។

រដ្ឋបាលឃុំ សង្កាត់ត្រូវដឹកនាំគ្រប់គ្រងដោយក្រុមប្រឹក្សាឃុំ សង្កាត់។ ក្រុមប្រឹក្សាឃុំ សង្កាត់មានប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ ហើយប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ ជាមេឃុំ ចៅសង្កាត់។

ការចូលកាន់តំណែងរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ផ្អែកតាមច្បាប់គ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ «ក្នុងអំឡុង១៤ថ្ងៃ ក្រោយពីបានប្រកាសលទ្ធផលផ្លូវការនៃការបោះឆ្នោត ចាត់ឱ្យមានការប្រជុំជាលើកដំបូងនៃក្រុមប្រឹក្សាឃុំ សង្កាត់ ក្រោមអធិបតីភាពមន្ត្រីម្នាក់ ដែលចាត់តាំងដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃដើម្បីប្រកាសសុពលភាពក្រុមប្រឹក្សាឃុំ សង្កាត់ និងប្រកាសឈ្មោះប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ មេឃុំ ចៅសង្កាត់ ជំទប់ និងចៅសង្កាត់រង»។ ក្នុងគោលបំណងបង្ហាញជាសធារណៈអំពីការចូលកាន់តំណែង និងត្រៀមលក្ខណៈអភិវឌ្ឍឃុំ សង្កាត់ អាណត្តិចាស់ក្រសួងមហាផ្ទៃធ្វើសេចក្តីណែនាំគ្រប់បណ្តាខេត្ត ក្នុងការរៀបចំចាត់ចែងធ្វើការប្រជុំលើកដំបូងរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិថ្មីស្របតាមនីតិវិធី នៃសេចក្តីណែនាំលេខ០០៦ស.ណ.ន. ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ ២០០៧ របស់ក្រសួងមហាផ្ទៃ ស្តីពី ការប្រជុំលើកដំបូង ដើម្បីប្រកាសសុពលភាពសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ប្រកាសឈ្មោះប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ មេឃុំ ចៅសង្កាត់ ជំទប់ ចៅសង្កាត់រង និងការចាប់ផ្តើមបំពេញការងារបន្ទាប់ពីកិច្ចប្រជុំលើកដំបូង។

ក្រុមប្រឹក្សាឃុំ សង្កាត់ ជានីតិបុគ្គលដែលកើតឡើងដោយការបោះឆ្នោតផ្ទាល់ពីប្រជាពលរដ្ឋនៅមូលដ្ឋានរបស់ខ្លួន។ ក្រុមប្រឹក្សាឃុំ សង្កាត់មានអាណត្តិប្រាំឆ្នាំ ហើយត្រូវផុតកំណត់នៅពេលមានក្រុមប្រឹក្សាឃុំ សង្កាត់ថ្មីចូលកាន់តំណែង។ ក្នុងការបន្តនិរន្តរភាពការងាររបស់ក្រុមប្រឹក្សាពីអាណត្តិមួយ ទៅអាណត្តិមួយចាំបាច់ត្រូវមាននីតិវិធីផ្ទេរការងាររបស់ក្រុមប្រឹក្សាឃុំ សង្កាត់ចាស់ទៅក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិថ្មី ដើម្បីក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិចាស់ធ្វើការបូកសរុបលទ្ធផលការងារនៅក្នុងអាណត្តិ ដែលសម្រេចបាន និងការងារទាំងឡាយណាដែលនៅសេសសល់ដូចជា ដំណើរការដឹកនាំរដ្ឋបាលឃុំ សង្កា-ត់។ ការអភិវឌ្ឍន៍ឃុំ សង្កាត់ រួមទាំងបញ្ជីឯកសារទាំងអស់សម្រាប់ឱ្យក្រុមប្រឹក្សាអាណត្តិថ្មី ដែលត្រូវទទួលការងារបន្តមានមូលដ្ឋានចាប់ផ្តើមបំពេញការងាររបស់ខ្លួន ដែលមានកំណត់តាមនីតិវិធីនៃសេចក្តីណែនាំ លេខ០០៥ស.ណ.ន. ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០០៨ ស្តីពី ការ

ត្រៀមរៀបចំការផ្ទេរសម្រាប់ផ្ទេរពីក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិចាស់ទៅឱ្យក្រុមប្រឹក្សាអាណត្តិថ្មី។

សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ក្រុមប្រឹក្សាឃុំសង្កាត់កើតឡើងដោយការបោះឆ្នោតជាទូទៅជាសកល ដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ ដោយសេរីដោយចំពោះ ដោយសម្ងាត់ ក្នុងក្របខណ្ឌនៃឃុំ សង្កាត់នីមួយៗ។ ក្រុមប្រឹក្សាឃុំ សង្កាត់ មានសមាជិកពី៥រូប ទៅ ១១រូប ផ្អែកតាមប្រជាសាស្ត្រ និង ភូមិសាស្ត្រ។ ចំនួនជាក់ស្តែងនៃសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗត្រូវកំណត់ដោយ អនុក្រិត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហារផ្ទៃ។ ចំនួនសមាជិកក្រុមប្រឹក្សា ឃុំ សង្កាត់ដែលបានកំនត់រួច ហើយអាចធ្វើការផ្លាស់ប្តូរបានដោយ អនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អាស្រ័យការផ្លាស់ប្តូរប្រជាសាស្ត្រ ភូមិសាស្ត្រ ដើម្បីក្លាយជាក្រុមប្រឹក្សាឃុំសង្កាត់ ប្រជាជនខ្មែរទាំងពីប្រភេទ ត្រូវទៅឈរឈ្មោះឱ្យគេបោះឆ្នោតនៅតាមឃុំ សង្កាត់ ដែលខ្លួនមានបំណងចង់ឈរឈ្មោះ។

យោងតាមមាត្រា១៤ នៃច្បាប់ ស្តីពី ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ដែលប្រជាពលរដ្ឋទាំងពីប្រភេទដែលមានសិទ្ធនិងមានបំណងឈរឈ្មោះ ជាបេក្ខជនឱ្យគេបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវបំពេញលក្ខខណ្ឌ ដូចខាងក្រោម ៖

- មានសញ្ជាតិខ្មែរទាំងពីកំណើត

- ចេះអាន និងសរសេរអក្សរខ្មែរ

-បានចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោតក្នុងឃុំ សង្កាត់ ដែលខ្លួនមានបំណងឈរឈ្មោះ។

បើមានលក្ខខណ្ឌគ្រប់គ្រាន់ដែលកំណត់ដោយច្បាប់ ស្តីពី ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់។ យោងតាមមាត្រា ១៦ នៃច្បាប់ដែលសមាជិកក្រុមកប្រឹក្សា ឃុំ សង្កាត់ត្រូវបាត់បង់សមាជិកភាពរបស់ខ្លួន ក្នុងករណីដូចជាសាមីខ្លួនទទួលមរណភាព បាត់បង់កាយសម្បទាសុំលាលែងតុលាការផ្តន្ទាទោស ការបណ្តេញចេញ ការរំសាយ និង ការបាត់បង់សមាជិកភាពពីគណបក្សនយោបាយ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅក្រុមប្រឹក្សា និងអភិបាលអំពីសកម្មភាព ឬសេចក្តីសម្រេចមិនស្រលាញ់ណាមួយ ដែលធ្វើឡើងដោយក្រុមប្រឹក្សាឬសមាជិកក្រុមប្រឹក្សាឬគណៈកម្មាធិការឬគណៈភិបាល ឬអភិបាល ឬបុគ្គលិកក្រុមប្រឹក្សានោះ។

ក្រោយទទួលបានការជូនដំណឹងជាលាយលក្ខណ៍អក្សរពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃក្រុមប្រឹក្សា ឬគណៈអភិបាល ត្រូវឆ្លើយបំភ្លឺតបវិញក្នុងរយៈពេលយ៉ាងយូរមួយ(០១)ខែ។ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវឆ្លើយតបវិញក្នុងរយៈពេលយ៉ាងយូរ(០១)ខែ បើសិនក្រសួងយល់ឃើញថាទង្វើនោះមិនស្របច្បាប់។

ក្នុងករណីដែលក្រុមប្រឹក្សាបានអនុវត្ត រួចហើយនូវសកម្មភាពឬ សេចក្តីសម្រេចមិន ស្របច្បាប់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវណែនាំ ក្រុមប្រឹក្សា ឱ្យចាត់វិធានការចាំបាច់នានានៅ ក្នុងក្របខ័ណ្ឌសិទ្ធិអំណាចរបស់ខ្លួន ដើម្បីធ្វើ សកម្មភាពឬ សេចក្តីសម្រេចឱ្យបានស្របច្បាប់ ឡើងវិញនៅក្នុងរយៈពេលមួយខែ (០១)។ ក្រុម ប្រឹក្សាត្រូវផ្សព្វផ្សាយ ជាសាធារណៈភ្លាមនូវ ការណែនាំរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ទាក់ទងនឹងបញ្ហានេះ នៅក្នុងដែនសមត្ថកិច្ច របស់ខ្លួន។

ក្នុងករណីដែលក្រុមប្រឹក្សាមិនអាច ធ្វើឱ្យសកម្មភាព ឬសេចក្តីសម្រេចមិនស្រប ច្បាប់ឱ្យស្របតាមច្បាប់ឡើងវិញនៅក្នុងសិទ្ធិ អំណាចរបស់ខ្លួននោះ ក្រុមប្រឹក្សាត្រូវលុប ចោលសកម្មភាព ឬសេចក្តីសម្រេចមិនស្រប ច្បាប់របស់ខ្លួន និងត្រូវផ្សព្វផ្សាយជាសាធារណៈ ពីការលុបចោលនោះ។

ចំពោះវិវាទនៅមូលដ្ឋាន គឺជាវិវាទមាន លក្ខណៈឯកជនរវាងប្រជាពលរដ្ឋដែលស្ថិត នៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាជាមួយ គ្នា ឬដែលស្ថិតក្នុងដែនសមត្ថកិច្ច របស់ក្រុម ប្រឹក្សាផ្សេងគ្នា។

ដើម្បីគ្រប់គ្រង ចាត់ចែងនិងអនុវត្ត មុខងារណាមួយឱ្យមានប្រសិទ្ធភាព និងមាន ចីរភាព គណៈកម្មាធិការជាតិសម្រាប់ការ អភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅថ្នាក់ក្រោម ជាតិ ឬក្រសួងស្ថាប័នរបស់រាជរដ្ឋាភិបាលអាច ប្រគល់ ឬ ធ្វើប្រតិភូកម្មឱ្យក្រុមប្រឹក្សាពីរឬ ច្រើន ដោយគំណត់អំពីធនធានដែលត្រូវចែក រំលែកជាមួយគ្នា និងត្រូវរួមចំនែកជាមួយគ្នា ដោយរួមទាំងបុគ្គលិកជំនាញ នៅក្នុងចំណោម ក្រុមប្រឹក្សាទាំងនោះផង។

ការប្រគល់មុខងារ ឬការធ្វើប្រតិភូកម្ម មុខងារគណៈកម្មាធិការជាតិសម្រាប់ការ អភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោម ជាតិ ត្រូវសម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល ដើម្បីដាក់ ចេញសេចក្តីសម្រេចដែលបញ្ជាក់៖

-ច្បាប់ ឬព្រះរាជក្រឹត្យ ឬអនុក្រឹត្យ ឬ ប្រកាសដែលបានធ្វើការប្រគល់ ឬធ្វើប្រតិភូកម្ម

-កាលបរិច្ឆេទចូលជាធរមាននូវការ ប្រគល់ ឬការធ្វើប្រតិភូកម្ម

-កំណត់បញ្ជាក់មុខងារនោះ មាន លក្ខណៈជាកាតព្វកិច្ច ឬជាជម្រើស

-កំណត់បញ្ជាក់មុចងារនោះ ជាមុខងារ ត្រូវបានប្រគល់ ឬ ធ្វើប្រតិភូកម្ម។

-ក្រុមប្រឹក្សានៅថ្នាក់ក្រោមជាតិ ត្រូវ មានធនធានហិរញ្ញវត្ថុសមស្រប ដើម្បី៖

-គ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារ ជាកាតព្វកិច្ចរបស់ខ្លួន

-ធ្វើការជ្រើសរើសក្នុងការគ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារជាជម្រើស របស់ ខ្លួន អនុវត្តតួនាទី ភារកិច្ចតាមច្បាប់កំណត់។

ចំណាយផ្នែករដ្ឋបាលរបស់ខ្លួននិងអនុ វត្តមុខងារ ភារកិច្ចសម្រាប់ជំរុញដល់ការ

អភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលមិនគោរពបទបញ្ញត្តិនៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ត្រូវពិន័យដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ដូចជា ៖

-ស្តីបន្ទោសក្នុងអង្គប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ដោយមានកំណត់ហេតុច្បាស់លាស់

- ករណីនៅតែប្រព្រឹត្តកំហុស ត្រូវកាត់មួយផ្នែកឬទាំងអស់នូវប្រាក់ឧបត្ថម្ភ។ ប្រាក់ដែលកាត់នេះ ត្រូវបានមកជាប្រយោជន៍នៃថវិការឃុំ សង្កាត់។

សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់អាចបាត់បង់សមាជិកភាពក្នុងករណី ៖

- សាមីខ្លួនទទួលមរណៈភាព

-សាមីខ្លួនបាត់បង់សម្បទាវិជ្ជាជីវៈដោយមានលិខិតបញ្ជាក់ពីក្រសួង ឬស្ថាប័នមានសមត្ថកិច្ច

- សាមីខ្លួនសុំលាលែងជាលាយលក្ខណ៍អក្សរ

-សាមីខ្លួនត្រូវតុលាការផ្តន្ទាទោសដាក់ពន្ធនាគារពីបទឧក្រិដ្ឋ ឬមជ្ឈិមណាមួយ

-សមាជិកត្រូវបានបណ្តេញចេញដោយប្រព្រឹត្តផ្ទុយពីបទបញ្ជាផ្ទៃក្នុងនៃក្រុមប្រឹក្សាឃុំ សង្កាត់តាមលក្ខខណ្ឌដែលមានចែងនៅក្នុងមាត្រា៨២ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់

-ក្រុមប្រឹក្សាឃុំ សង្កាត់ទាំងមូលត្រូវបានរំលាយ

-សាមីខ្លួនបាត់បង់សមាជិកភាពពីគណៈបក្សនយោបាយរបស់ខ្លួន។

សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់មានសេរីភាពក្នុងការបញ្ចេញមតិ ក្នុងអង្គប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់។ សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់រូបណាក៏ដោយ មិនអាចត្រូវបានចោទប្រកាន់ ចាប់ខ្លួន ឃាត់ខ្លួន ឬឃុំខ្លួនដោយហេតុពីសម្តែងយោបល់ ឬបញ្ចេញមតិក្នុងអង្គប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ឡើយ។

### ២.២.២- តួនាទីមេឃុំ ចៅសង្កាត់

មេឃុំ ចៅសង្កាត់ ជាអ្នកតំណាងឃុំ សង្កាត់ដែលជានីតិបុគ្គល។ មេឃុំ ចៅសង្កាត់ត្រូវត្រួតឃុំ សង្កាត់ និងធ្វើតាមសេចក្តីសម្រេចនៃក្រុមប្រឹក្សាឃុំ សង្កាត់។ ម្យ៉ាងទៀត មេឃុំ ចៅសង្កាត់ ជាអ្នកតំណាងរដ្ឋក្នុងឃុំ សង្កាត់ចំពោះការប្រតិបត្តិច្បាប់ បទបញ្ជា និងសេចក្តីសម្រេចរាជការជាន់ខ្ពស់ មានមុខងាររពន្ធដារ និងក្រុមនគរបាល ជាដើម។

ការរាជការទូទៅ មេឃុំ ចៅសង្កាត់ត្រូវចុះហត្ថលេខាលើលិខិតឆ្លើយឆ្លង ជាមួយអភិបាលស្រុក ក្រុង ខណ្ឌ។

មេឃុំ ចៅសង្កាត់ជាអ្នកបើកការប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ ហើយត្រូវធ្វើជាប្រធាននៃការប្រជុំនេះ។

មេឃុំ ចៅសង្កាត់ ជាមន្ត្រីអត្រានុកូលដ្ឋាន ហើយជាអ្នករក្សានូវសៀវភៅអត្រានុកូលដ្ឋានរបស់ឃុំ សង្កាត់។ មេឃុំ ចៅសង្កាត់ត្រូវចេញសេចក្តីចម្លងអត្រានុកូលដ្ឋាន ហើយត្រូវមានសេចក្តីបញ្ជាក់ផង។ មេឃុំ ចៅសង្កាត់ត្រូវផ្សាយនូវច្បាប់ ក្រឹត្យ ប្រកាស ដីកា សារាចរ និងសេចក្តីសម្រេចពិសេសពីរាជការជាន់ខ្ពស់ ដែលទាក់ទងជាមួយប្រជាពលរដ្ឋ ហើយប្រតិបត្តិឱ្យបានសម្រេចតាមច្បាប់ទាំងនេះ។

មេឃុំ ចៅសង្កាត់ត្រូវជួយ និងទំនុកបម្រុងមន្ត្រី និងភ្នាក់ងាររាជការ ដែលធ្វើដំណើរជាផ្លូវការ ឬធ្វើបេសកកម្មក្នុងឃុំ សង្កាត់។

មេឃុំ ចៅសង្កាត់ត្រូវកាន់ ហើយរក្សាទុកនូវបញ្ជីកត់សត្វពាហនៈ។

ក្រុមនគរបាល មេឃុំ ចៅសង្កាត់ត្រូវរួមជាមួយនឹងកងកម្លាំង ក្រុមនគរបាល ដែលនៅក្រោមអំណាចរាជការជាន់ខ្ពស់ ដើម្បីរក្សាសន្តិសុខ និងសុវត្ថិភាពក្នុងឃុំ សង្កាត់។ មេឃុំ ចៅសង្កាត់ត្រូវការពារមិនឱ្យមានការប្រព្រឹត្តបទល្មើសច្បាប់ និងបទបញ្ជានានាជាធរមាន។

មេឃុំ ចៅសង្កាត់ត្រូវចាប់បញ្ជូនអ្នកប្រព្រឹត្តបទល្មើសទៅតុលាការ។ មេឃុំ ចៅសង្កាត់ត្រូវការពារ និងបង្ក្រាបនូវអំពើចោរកម្មក្នុងតួនាទីឃុំ សង្កាត់ ក្រោមអំណាចអភិបាលស្រុក ក្រុង ខណ្ឌ។

ក្នុយន័យនេះ មេឃុំ ចៅសង្កាត់ត្រូវ ៖

-រៀបចំក្រុមស៊ើបព័ត៌មាន ដោយទាក់ទងជាមួយមេឃុំ ចៅសង្កាត់នៅជិតខាង

-តាមមើលសកម្មភាពនៃកងរក្សារាជធានី ខេត្ត ឬកងកម្លាំងក្រុមនគរបាល ឯទៀត ដែលធ្វើបេសកកម្មក្នុងក្រុង ស្រុក ខណ្ឌ ហើយត្រូវរាយការណ៍ទៅអភិបាលក្រុង ស្រុក ខណ្ឌ អំពីសកម្មភាពនេះ។

-ក្នុងភូមិភាគដែលតែងតែមានចោរកម្មធក់ប្លន់ ដូចនេះត្រូវរៀបចំឱ្យមានការយាមល្បាត ដោយសហការជាមួយប្រជាការពារ និងពលរដ្ឋទាំងអស់។

តុលាការ មេឃុំ ចៅសង្កាត់ត្រូវធ្វើជាតំណាងឃុំ សង្កាត់ នៅចំពោះមុខតុលាការទាំងអស់ ក្រោយពីបានទទួលការអនុញ្ញាតពីក្រុមប្រឹក្សាឃុំ សង្កាត់ ដោយមានការយល់ព្រមពីអភិបាលខេត្ត ក្រុងផង។

មេឃុំ ចៅសង្កាត់ ជាមន្ត្រីនគរបាលយុត្តិធម៌ និងជាជំនួយតុលាការក្នុងព្រំដែនឃុំ សង្កាត់។

មេឃុំ ចៅសង្កាត់ មានគុណសម្បត្តិ នឹងធ្វើឱ្យលិខិតទាំងឡាយ មានចារឹកត្រឹមត្រូវតាមច្បាប់ តាមលក្ខខណ្ឌ ដែលមានចែងក្នុងច្បាប់រដ្ឋប្បវេណី។

ហិរញ្ញវត្ថុ មេឃុំត្រូវធ្វើបញ្ជីពន្ធទាំងអស់ ដែលជាប្រយោជន៍ថវិការជាតិ និងថវិការខេត្ត លើកលែងតែពន្ធណាដែលជាកម្មវត្ថុ នៃបទបញ្ញត្តិនៃនីតិក្រមពិសេស។

ក្នុងឋានៈជាភ្នាក់ងារបន្តនៃរតនាគារ មេឃុំត្រូវទទួលប្រាក់ពន្ធ និងអាករ ហើយត្រូវចេញបង្កាន់ដៃឱ្យ។ នៅពេលទារប្រាក់ពន្ធមេឃុំត្រូវដាក់ប្រាក់ដែលទារបាន ហើយទទួលបង្កាន់ដៃ។

មេឃុំ ចៅសង្កាត់ និងជំនួយការ ចំណែកជំពូកទី៣ របនាសម្ព័ន្ធរដ្ឋបាលឃុំសង្កាត់ ត្រង់មាត្រា២៥ នៃច្បាប់ ស្តីពី ការគ្រប់គ្រងឃុំ សង្កាត់ បានកំណត់ថា រដ្ឋបាលឃុំសង្កាត់ ត្រូវដឹកនាំគ្រប់គ្រងដោយក្រុមប្រឹក្សាឃុំសង្កាត់។ ក្រុមប្រឹក្សាឃុំសង្កាត់ ត្រូវមានប្រធានក្រុមប្រឹក្សាឃុំ សង្កាត់។ ប្រធានក្រុមប្រឹក្សាឃុំសង្កាត់ ជាមេឃុំ ចៅសង្កាត់។

មេឃុំ ចៅសង្កាត់ មានអ្នកជំនួយការដូចខាងក្រោម ៖

ចំពោះមេឃុំ អ្នកជំនួយការ មានពីររូបៈ ជំទប់ទី១មួយរូប និងជំទប់ទី២មួយរូប។ ចំពោះចៅសង្កាត់ អ្នកជំនួយការ មានពីររូប ចៅសង្កាត់រងទី១ មួយរូប និងចៅសង្កាត់រងទី២ មួយរូប។

មេឃុំ ចៅសង្កាត់ មានសិទ្ធិចាត់តាំងគណៈកម្មាធិការនានា ដើម្បីផ្តល់យោបល់ និងជួយកិច្ចការនានា តាមការចាំបាច់។ គណៈកម្មាធិការខាងលើនេះ អាចយកសមាជិកណាម្នាក់ក្នុងក្រុមប្រឹក្សាឃុំសង្កាត់ ឱ្យធ្វើជាប្រធានក៏បាន ឬអាចយកប្រជាពលរដ្ឋ ដែលមានសិទ្ធិបោះឆ្នោតណាម្នាក់ក្នុងឃុំសង្កាត់របស់ខ្លួន ក្រៅពីសមាជិកក្រុមប្រឹក្សាឱ្យធ្វើជាប្រធានក៏បាន។

ប្រធានក្រុមប្រឹក្សាឃុំសង្កាត់ ដែលជាមេឃុំចៅសង្កាត់ ត្រូវជ្រើសរើសចេញពីបេក្ខជនលេខរៀងលើគេបង្អស់នៃបញ្ជីបេក្ខជន ដែលបានទទួលសម្លេងឆ្នោតច្រើនជាងគេបង្អស់។ ប្រធានក្រុមប្រឹក្សាឃុំសង្កាត់ ដែលជាមេឃុំ ចៅសង្កាត់ មានអាណត្តិស្មើនឹងអាណត្តិរបស់សមាជិកក្រុមប្រឹក្សាឃុំសង្កាត់។

ជំទប់ទី១ ចៅសង្កាត់រងទី១ ត្រូវជ្រើសរើសចេញពីបេក្ខជន ដែលមានឈ្មោះលេខរៀងលើគេនៃបញ្ជីបេក្ខជនដែលបានទទួលសម្លេងឆ្នោតលំដាប់ទី២។ ជំទប់ទី២ ចៅសង្កាត់រងទី២ ត្រូវជ្រើសរើសចេញពីបេក្ខជន ដែលមានឈ្មោះលេខរៀងលើគេ នៃបញ្ជីបេក្ខជនដែលបានទទួលសម្លេងឆ្នោតលំដាប់ទី៣។

ក្នុងករណីដែលលទ្ធផលជាផ្លូវការ នៃការបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ណាបានផ្តល់សម្លេងគាំទ្រដល់បញ្ជីបេក្ខជនតែមួយ ដែលមានលក្ខណៈសម្បត្តិទទួលបានអាសនៈទាំងអស់ ក្នុងក្រុមប្រឹក្សាត្រូវជ្រើសរើសក្រុមប្រឹក្សាពីក្នុងបញ្ជីតែមួយនោះ ឱ្យទទួលតំណែងជាមេឃុំ ឬចៅសង្កាត់ ជំទប់ទី១ ឬចៅសង្កាត់រងទី១ ជំទប់ទី២ ឬចៅសង្កាត់រងទី២។

មេឃុំ ចៅសង្កាត់ បំពេញតួនាទីភារកិច្ចដូចខាងក្រោម ៖

-អនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាឃុំសង្កាត់

-អនុវត្តនូវបទប្បញ្ញត្តិ និងគោលការណ៍នានាដែលបានទទួលពីក្រុមប្រឹក្សាឃុំសង្កាត់

-ធ្វើសេចក្ដីរាយការណ៍ អំពីសកម្មភាពការងារជូនក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួនយ៉ាងតិចឱ្យបានមួយដងក្នុងមួយខែ

-ផ្ដល់យោបល់ផ្សេងៗ និងជួយដល់ក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងការរៀបចំផែនការហិរញ្ញវត្ថុ និងក្នុងការចាត់ចែងអនុវត្តនូវតួនាទី មុខងារសិទ្ធិអំណាចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ព្រមទាំងកិច្ចការផ្សេងទៀត ដែលក្រុមប្រឹក្សាឃុំសង្កាត់របស់ខ្លួនប្រគល់ឱ្យ។

ជំទប់ឬចៅសង្កាត់រង ជាជំនួយការរបស់មេឃុំ ចៅសង្កាត់ ក្នុងការអនុវត្តភារកិច្ចដែលមេឃុំ ចៅសង្កាត់ប្រគល់ឱ្យ និងជំនួសមេឃុំ ចៅសង្កាត់ទៅតាមឋានានុក្រមនៃជំទប់ចៅសង្កាត់រង នៅពេលដែលមេឃុំចៅសង្កាត់អវត្តមាន។

ជំទប់ ឬចៅសង្កាត់រង ត្រូវធ្វើការបែងចែកភារកិច្ច ដូចខាងក្រោម៖

ជំទប់ទី១ឬចៅសង្កាត់រងទី១ទទួលជួយមេឃុំចៅសង្កាត់លើកិច្ចការសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ជំទប់ទី២ឬចៅសង្កាត់រងទី២ ទទួលជួយមេឃុំចៅសង្កាត់លើកិច្ចការរដ្ឋបាល សង្គមកិច្ច សេវាសាធារណៈ និងសណ្ដាប់ធ្នាប់សាធារណៈ។

មេឃុំ ចៅសង្កាត់ អាចប្រគល់ភារកិច្ចបន្ថែមពីលើភារកិច្ចដែលបានបែងចែកខាងលើនេះ ដល់ជំទប់ ឬចៅសង្កាត់រងរបស់ខ្លួន។ ក្រុមប្រឹក្សាឃុំ សង្កាត់អាចធ្វើប្រតិភូកម្មអំណាចឱ្យដល់មេឃុំ ចៅសង្កាត់តាមសេចក្ដីណែនាំរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ លើកលែងតែបញ្ហាទាំងឡាយ ដូចខាងក្រោម ៖

-ការអនុម័តលើគម្រោងថវិកាឃុំសង្កាត់

-ការកំណត់តម្លៃសារពើពន្ធមូលដ្ឋាន មិនមែនសារពើពន្ធមូលដ្ឋាន និងកម្រៃសេវាផ្សេងៗ

-ការបោះឆ្នោតអនុម័តបទបញ្ជាផ្ទៃក្នុង និងដីកាឃុំសង្កាត់

-ការអនុម័តលើគម្រោងផែនការអភិវឌ្ឍន៍ឃុំសង្កាត់

-បញ្ហាដទៃទៀត ដែលកំណត់ដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

មេឃុំ ចៅសង្កាត់ ដែលត្រូវបានក្រុមប្រឹក្សាឃុំ សង្កាត់ ធ្វើប្រតិភូកម្មអំណាចឱ្យ ពុំអាចផ្ទេរអំណាចនេះបន្តទៅឱ្យបុគ្គលដទៃទៀតបានឡើយ។

ក្រុមប្រឹក្សាឃុំសង្កាត់ ដែលបានធ្វើប្រតិភូកម្មអំណាចឱ្យដល់មេឃុំ ចៅសង្កាត់ នៅតែទទួលខុសត្រូវលើកិច្ចការដែលបានធ្វើប្រតិភូកម្មនោះ។

ការដកហូតនូវអំណាច ដែលបានធ្វើប្រតិភូកម្ម មិនធ្វើឱ្យប៉ះពាល់ដល់សុពលភាពនៃកិច្ចការ ដែលបានធ្វើរួចហើយនោះឡើយ។

## ២.៣- តួនាទីនិងអំណាចរបស់រដ្ឋបាលឃុំ សង្កាត់

យោងតាមច្បាប់ ស្តីពី ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ បានចែងអំពីរដ្ឋបាលឃុំ សង្កាត់មានតួនាទីជំរុញ និងគាំពារអភិបាលកិច្ចល្អ ដោយចាត់ចែងប្រើធនធាននានាដែលមានប្រកបដោយចិរភាពសម្រាប់បំពេញសេចក្តីត្រូវការជាមូលដ្ឋានក្នុងឃុំ សង្កាត់របស់ខ្លួនបម្រើផលប្រយោជន៍រួមរបស់ប្រជាពលរដ្ឋ និងគោរពផលប្រយោជន៍របស់ជាតិ ស្របតាមគោលនយោបាយរបស់ជាតិ។

រដ្ឋបាលឃុំ សង្កាត់ មានតួនាទីពីរប្រភេទគឺ៖

-តួនាទីបំរើកិច្ចការមូលដ្ឋានសំរាប់បំរើផលប្រយោជន៍ឃុំ សង្កាត់ និងប្រជាពលរដ្ឋក្នុង ឃុំ សង្កាត់របស់ខ្លួន។

-តួនាទីជាភ្នាក់ងារតំនាងរដ្ឋ ក្រោមការចាត់តាំង រឺការប្រគល់អំនាចរបស់អាជ្ញាធររដ្ឋ[៦]។

### ២-៣.១. តួនាទីបម្រើកិច្ចការមូលដ្ឋាន

នៅក្នុងតួនាទីបម្រើកិច្ចការមូលដ្ឋាន រដ្ឋបាលឃុំ សង្កាត់ មានភារកិច្ច ៖

-ធានារក្សាសន្តិសុខ សណ្តាប់ធ្នាប់ របៀបរៀបរយសាធារណ

-រៀបចំចាត់ចែងសេវាសាធារណ ចាំបាច់ និងមើលការខុសត្រូវអោយកិច្ចការទាំងនោះ ដំនើរការបានល្អ

-លើកទឹកចិត្តអោយមានការបង្កើនផាសុកភាព និងសុខុមាលភាពរបស់ប្រជាពលរដ្ឋ

-ជំរុញកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច និងលើកកំពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ

- ការពារ ថែរក្សាបរិស្ថាន ធនធានធម្មជាតិ វប្បធម៌ បេតិកភណ្ឌជាតិ

-សម្របសម្រួលទស្សនៈរបស់ប្រជាពលរដ្ឋដើម្បីអោយមានការយោគយល់អធ្យាស្រ័យទៅវិញទៅមក

-បំពេញកិច្ចការជាទូទៅដើម្បីឆ្លើយតបសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ[៧]។

ដូច្នេះ តួនាទីទីមួយនេះ ជាតួនាទីបម្រើកិច្ចការមូលដ្ឋានរបស់ឃុំ សង្កាត់ ដែលត្រូវនៅជាប់ជិតស្និទ្ធជាប្រចាំនៅក្នុងឃុំ សង្កាត់ដែលមានភារកិច្ចសំខាន់ៗមួយចំនួនដូចជា ធានារក្សាសន្តិសុខសណ្តាប់ធ្នាប់របៀបរៀបរយសាធារណៈ ការចាត់ចែងលើសេវាសាធារណៈដែលចាំបាច់ ហើយពិនិត្យមើលជាប្រចាំឱ្យបានដំណើរការល្អ។ ម្យ៉ាងទៀតឃុំ សង្កាត់ត្រូវជំរុញការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមកិច្ចសំដៅលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ និងការការពារបរិស្ថាន ធនធានធម្មជាតិ វប្បធម៌ បេតិកភណ្ឌជាតិ ជាពិសេសទៀតឃុំ សង្កាត់មានតួនាទីជួយធ្វើការសម្របសម្រួលលើ

[៦] មាត្រា៤២ ច្បាប់ ស្តីពី ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់

[៧] មាត្រា៤៣ ច្បាប់ ស្តីពី ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់

ទស្សនៈរបស់ប្រជាពលរដ្ឋ សំដៅឱ្យមានការសាមគ្គីយោគយល់គ្នាទៅវិញទៅមកអនុវត្តលទ្ធិប្រជាធិបតេយ្យ នៅថ្នាក់ក្រោមជាតិ។

### ២.៣.២- តួនាទីជាភ្នាក់ងារតំណាងរដ្ឋ

តួនាទីទីពីរ រដ្ឋបាលឃុំ សង្កាត់ មានតួនាទីសំខាន់មួយទៀត គឺជាភ្នាក់ងារតំណាងរដ្ឋ ដោយត្រូវអនុវត្តតាមច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ។

ក្នុងការគ្រប់គ្រង និងដំណើរការឃុំ សង្កាត់ មានសិទ្ធិអំណាចសំខាន់ៗចំនួនពីរគឺ អំណាចបញ្ញត្តិ និងអំណាចប្រតិបត្តិ។ អំណាចបញ្ញត្តិរបស់ឃុំ សង្កាត់ត្រូវធ្វើឡើងតាមរយៈដីការបស់ឃុំ សង្កាត់ដោយមានការសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ហើយត្រូវចុះហត្ថលេខាសម្រេចពីមេឃុំ ចៅសង្កាត់។ អំណាចប្រតិបត្តិរដ្ឋបាលឃុំ សង្កាត់ ជាអ្នកធ្វើការផ្សព្វផ្សាយ និងអនុវត្តរាល់ដីកាដែលមានស្របច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិ។

ទោះបីរដ្ឋបាលឃុំ សង្កាត់មានសិទ្ធិអំណាចមួយចំនួនសម្រាប់គ្រប់គ្រង និងអភិវឌ្ឍឃុំ សង្កាត់ដែលកំណត់ដោយច្បាប់ក៏ដោយ ក៏មានបញ្ញត្តិមួយដែលរដ្ឋបាលឃុំ សង្កាត់គ្មានអំណាចចាត់ចែង និងទទួលខុសត្រូវលើសេវាសាធារណៈ និងវិស័យមួយចំនួនដូចមានចែងក្នុងមាត្រា៤៥ នៃច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ដូចជា ព្រៃឈើ ប្រៃសណីយ៍ និងទូរគមនាគមន៍ ការពារប្រទេស និងសន្តិសុខជាតិនយោបាយក្រៅប្រទេស និងនយោបាយសារពើពន្ធ និងវិស័យផ្សេងទៀតដោយកំណត់ដោយច្បាប់ និងលិខិតបទដ្ឋាននានា។

នៅក្នុងតួនាទីជាភ្នាក់ងារតំណាងរដ្ឋ រដ្ឋបាលឃុំ សង្កាត់ មានភារកិច្ចអនុវត្តទៅតាមច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋានពាក់ព័ន្ធ។ ក្នុងករណីនេះ អាជ្ញាធររដ្ឋអាចធ្វើប្រតិភូកម្មអំនាចដល់ឃុំ សង្កាត់ ដោយភ្ជាប់ជាមួយនូវការបង្កើន សមត្ថភាព និងផ្ដត់ផ្គង់មធ្យោបាយ សំភារៈ ថវិកា សម្រាប់អនុវត្ត។ ប្រតិភូកម្មខាងលើនេះ ត្រូវផ្ដល់ចំពោះតែសមូហភាពរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ តែប៉ុណ្ណោះ[៨]។

ក្នុងការអនុវត្តតួនាទីជាភ្នាក់ងារតំណាងរដ្ឋ ដែលត្រូវកំណត់ដោយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិនោះ អាជ្ញាធររដ្ឋបានធ្វើប្រតិភូកម្មអំណាចដល់ឃុំ សង្កាត់។ ក្នុងអាណត្តិកន្លងមកនៃក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងការអនុវត្តគោលនយោបាយវិមជ្ឈការឃុំ សង្កត់ ដែលមានចែងក្នុងច្បាប់រដ្ឋបាលឃុំ សង្កាត់ ក្រសួងមហាផ្ទៃបានធ្វើប្រតិភូកម្មអំណាចដល់ក្រុមប្រឹក្សាឃុំ សង្កាត់ តាមប្រកាស លេខ២២ ប្រ.ក. ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ ២០០២ ស្ដីពី ការធ្វើវិមជ្ឈការអំណាចតួនាទី និងភារកិច្ចទៅឱ្យ

[៨] មាត្រា៤៤ ច្បាប់ ស្ដីពី ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់

ក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីផ្ទេរអំណាច និង ធនធានមួយចំនួនដល់ក្រុមប្រឹក្សាឃុំ សង្កាត់ឱ្យ ទទួលខុសត្រូវចំពោះប្រជាពលរដ្ឋ និងចំពោះ មុខស្ថាប័ន។ ម្យ៉ាងទៀតក្នុងការកាត់បន្ថយនូវ ការចំណាយពេល នៃការលើកសំណើ ឬការ សម្រេចពីស្ថាប័នកណ្តាល ឬពីស្ថាប័នពាក់ព័ន្ធ មួយចំនួន។ ក្រុមប្រឹក្សាឃុំ សង្កាត់ស្ថិតនៅជិត ប្រជាជនដែលជាតំណាង និងជាអ្នកបម្រើផល ប្រយោជន៍ទូទៅរបស់ប្រជាពលរដ្ឋទាំងអស់ ក្នុងឃុំ សង្កាត់ ហើយក្រុមប្រឹក្សាឃុំ សង្កាត់ធ្វើ ការសម្របសម្រួល និងលើកស្ទួយយ៉ាងសកម្ម នូវការអភិវឌ្ឍលទ្ធិប្រជាធិបតេយ្យក្នុងមូលដ្ឋាន ឃុំ សង្កាត់ ដោយបង្កើតនូវយន្តការដើម្បីធ្វើការ ពិគ្រោះយោបល់ផ្ទាល់ជាមួយប្រជាពលរដ្ឋ សង្គមស៊ីវិល និងសហគមន៍ក្នុងឃុំ សង្កាត់។

ក្នុងយន្តការជួយគាំទ្រដល់ក្រុមប្រឹក្សា ឃុំ សង្កាត់អនុវត្តតួនាទី ភារកិច្ចរបស់ខ្លួនដែល តំណាងឱ្យប្រជាពលរដ្ឋកើតឡើង ដោយការ បោះឆ្នោតនៅមូលដ្ឋានប្រកបដោយប្រសិទ្ធិ ភាព ដើម្បីទទួលសេវា និងផ្តល់សេវាផ្សេងៗ ដល់ប្រជាពលរដ្ឋស្របតាមច្បាប់គ្រប់គ្រងរដ្ឋ បាលឃុំ សង្កាត់។ ធ្វើការសម្របសម្រួលជួយ ដល់ក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការធ្វើផែនការ ហិរញ្ញវត្ថុ ការអនុវត្តគម្រោងនានាសំដៅលើក កម្ពស់ជីវភាពរបស់ប្រជាពលរដ្ឋ និងគាំទ្រ ពង្រឹងសមត្ថភាពរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ នៅមូលដ្ឋាន ព្រមទាំងលើកឡើងនូវយោបល់ ឬ កិច្ចការផ្សេងៗមកស្ថាប័នកណ្តាល និងធ្វើ ការសម្របសម្រួលជាមួយដៃគូរពាក់ព័ន្ធ អង្គការជាតិ អង្គការអន្តរជាតិ សមាគមដែល ជួយគាំទ្រដល់ឃុំ សង្កាត់។ ជាពិសេស អាជ្ញាធរ រាជធានីខេត្ត មានសិទ្ធិអំណាចធ្វើការសម្រេច នៅក្នុងសមត្ថកិច្ចដែនដីតាមរយៈការធ្វើប្រតិភូកម្ម អំណាចរបស់ក្រសួងមហាផ្ទៃ តាមប្រកាស លេខ១៨៨២ ប្រក ចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ ២០០២ស្តីពីការធ្វើប្រតិភូកម្មអំណាចដល់ អភិបាលខេត្ត ក្រុង ក្នុងការជួយគាំទ្រដល់ក្រុម ប្រឹក្សាឃុំ សង្កាត់។

## ៣- សេចក្តីសន្និដ្ឋាន

កំណែទម្រង់វិមជ្ឈការ បានចាប់ផ្តើម អនុវត្តតាំងពីឆ្នាំ២០០២ ក្នុងរូបភាពផ្តល់ ស្វ័យភាព ដល់ថ្នាក់មូលដ្ឋានឃុំ សង្កាត់ ក្រោម ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និង ច្បាប់ស្តីពី ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ឃុំ សង្កាត់ អនុម័តឆ្នាំ២០០១។

បច្ចុប្បន្ន ការបោះឆ្នោតជ្រើសរើសក្រុម ប្រឹក្សាឃុំសង្កាត់បានធ្វើឡើងចំនួនប្រាំលើករួច មកហើយ។ កំណែទម្រង់នេះត្រូវបានពង្រីក វិសាលភាពកាន់តែធំដល់ថ្នាក់ក្រោមជាតិ តាម ក្របខ័ណ្ឌយុតិសាស្ត្រ ស្តីពី កំណែទម្រង់ វិមជ្ឈការ និងវិសហមជ្ឈការ ដែលអនុម័តក្នុង ឆ្នាំ២០០៥។ គណនេយ្យភាព និងភាពឆ្លើយតប ក្រោយបានអនុវត្តកំណែទម្រង់ជិតពីរទសវត្ស មក គេអាចឃើញច្បាស់ពីការរីកចម្រើននៅ ក្នុងគណនេយ្យភាព និងការឆ្លើយតបរបស់

ក្រុមប្រឹក្សា ចំពោះតម្រូវការរបស់ប្រជាពលរដ្ឋ។ ទាំងក្រុមប្រឹក្សាឃុំ សង្កាត់និងប្រជាពលរដ្ឋបានរាយការណ៍អំពីភាពប្រសើរឡើងយ៉ាងច្បាស់ នៅក្នុងគណនេយ្យភាពនិងការផ្តល់សេវាកម្ម។ ក្រុមប្រឹស្របក្សាឃុំ សង្កាត់មានទំនួលខុសត្រូវចំពោះប្រជាពលរដ្ឋ ហើយអនុវត្តតួនាទី ឬអាណត្តិរបស់ខ្លួនដោយផ្អែកលើគោលការណ៍នៃគណនេយ្យភាព។ ប្រជាពលរដ្ឋមូលដ្ឋានយល់ថា ខ្លួនទទួលបានសិទ្ធិអំណាច និងដំណើការវិមជ្ឈការ ដោយអាចទាមទារគណនេយ្យភាពពីថ្នាក់ដឹកនាំ ដែលជាប់ឆ្នោតបាន តាមរយៈការប្រើប្រាស់សិទ្ធិស្របច្បាប់របស់ខ្លួន ក្នុងការបោះឆ្នោតទម្លាក់ពីតំណែងនូវសមាជិកក្រុមប្រឹក្សាណាដែលអសមត្ថភាព។ ស្របគ្នានេះដែរ គេសង្កេតឃើញថាមានកំណើនការឆ្លើយតបពីថ្នាក់ដឹកនាំទៅមូលដ្ឋាន។ ប៉ុន្តែ ការរីកចម្រើននៃគណនេយ្យភាព និងការឆ្លើយតបនេះ ប្លែកបន្តិចពីការសន្មតទូទៅ តាមទ្រឹស្តីនៃវិមជ្ឈការតាមបែបប្រជាធិបតេយ្យ។ វិធីប្រតិបត្តិរបស់រដ្ឋាភិបាលមូលដ្ឋាន នៅតែបន្តដូចមុនគឺ វិន័យគណបក្សនយោបាយនៅតែខ្លាំង ដែលជាសម្ពាធពីលើចុះក្រោម។ ការឆ្លើយតបរបស់ក្រុមប្រឹក្សាឃុំកន្លងមក ផ្អែកលើសមត្ថភាពផ្ទាល់ខ្លួន ក្នុងការប្រមែប្រមូលជំនួយពីខាងក្រៅដើម្បីបន្ថែមលើថវិកាឃុំ/សង្កាត់ ដែលពុំគ្រប់គ្រាន់សម្រាប់ការឆ្លើយតបនិងតម្រូវការអភិវឌ្ឍនៅមូលដ្ឋាន។ នៅចំពោះមុខកង្វះធនធានបែបនេះ លទ្ធភាពរបស់ថ្នាក់ដឹកនាំមូលដ្ឋានក្នុងការទទួលខុសត្រូវនិងការឆ្លើយតបនឹងតម្រូវការប្រជាពលរដ្ឋ ត្រូវពឹងផ្អែកលើបុគ្គលិកលក្ខណៈ និងជំនាញផ្ទាល់ខ្លួន ដើម្បីទទួលបានធនធានពីប្រភពផ្សេងទៀត សម្រាប់អនុវត្តគម្រោងអភិវឌ្ឍក្នុងមូលដ្ឋាន តាមរយៈការអំពាវនាវទៅគណបក្សនយោ បាយ សប្បុរសជន និងប្រភពដទៃទៀត។ ទំនាក់ទំនងបុគ្គលនិងបណ្តាញខ្សែខ្នង ដែលគេតែងតែគិតថា ជាប្រភពនៃអំពើពុករលួយក៏បានយកមកប្រើប្រាស់ដែរ ដើម្បីទទួលបានមូលនិធិសម្រាប់ការផ្តល់សេវាសាធារណៈ។ ប៉ុន្តែការពឹងផ្អែកលើមូលនិធិក្រៅផ្លូវការបែបនេះ បានចោទសំណួរជាច្រើនលលើការពង្រឹងគណនេយ្យភាពព្រោះគេមិនច្បាស់ទេថា តើមូលនិធិក្រៅផ្លូវការទាំងនោះ មានប្រភពមកពីណា។ ឧបសគ្គកាន់តែធំចំពោះការឆ្លើយតប និងគណនេយ្យភាពរបស់រដ្ឋបាលមូលដ្ឋាន តែងកើតមាននៅតំបន់សម្បូរធនធាន ច្រើនជាងតំបន់ខ្សត់ធនធាន។ តួយ៉ាងក្រុមប្រឹក្សាឃុំដែលយកចិត្តទុកដាក់ និងធានាឱ្យមានការប្រើប្រាស់ធនធានធម្មជាតិ ប្រកប ដោយនិរន្តរភាព និងគាំទ្រប្រជាពលរដ្ឋក្នុងការប្រឆាំងបទល្មើសធនធានធម្មជាតិ តាមជាក់ស្តែងពុំមានសិទ្ធិអំណាចពិតប្រាកដក្នុងការសម្រេចចិត្តនិងគ្រប់គ្រងទេ។ ការលំបាកភាគច្រើនលើបញ្ហាធនធានធម្មជាតិជារឿយៗស្ថិតនៅក្រៅក្របខណ្ឌនៃវិមជ្ឈការនិងសហមជ្ឈការ។

ការចូលរួមរបស់ប្រជាពលរដ្ឋ វិមជ្ឈការបានបើកផ្លូវឱ្យប្រជាពលរដ្ឋ ចូលរួមក្នុងកិច្ចការនយោបាយ និងសកម្មភាពអភិវឌ្ឍផ្សេងៗនៅមូលដ្ឋាន។ បច្ចុប្បន្នប្រជាពលរដ្ឋទទួលបានការអនុញ្ញាតឱ្យជ្រើសរើសថ្នាក់ដឹកនាំ និងបញ្ចេញគំនិតយោបល់ទាក់ទងនិងការអភិវឌ្ឍក្នុងមូលដ្ឋាន និងតម្រូវការរបស់សហគមន៍ ស្របតាមគោលការណ៍អភិបាលកិច្ចនៅមូលដ្ឋាន។ ជួយគាំទ្រក្រុមប្រឹក្សាឃុំ សង្កាត់អាចប្រើប្រាស់ធនធានរបស់ខ្លួន ដើម្បីធ្វើការអភិវឌ្ឍន៍កន្លែងនោះ។ ការផ្ទេរអំណាចទៅថ្នាក់ក្រោមជាតិ បានធ្វើឡើងជាបន្តបន្ទាប់។

## ឯកសារយោង

### ១- លិខិតបទដ្ឋានគតិយុត្ត


-រដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ឆ្នាំ១៩៨១

- រដ្ឋធម្មនុញ្ញ នៃរដ្ឋកម្ពុជា ឆ្នាំ១៩៩២

-រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា បច្ចុប្បន្នខែតុលា ឆ្នាំ២០១៤

- ច្បាប់ ស្តីពី ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់

- ច្បាប់ ស្តីពី របបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

- អនុក្រឹត្យ ស្តីពី ដំណើរការទូទៅ នៃការផ្ទេរមុខងារ និងធនធានដល់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ

- អនុក្រឹត្យ ស្តីពី ការផ្តល់សេវារដ្ឋបាលនៅរដ្ឋ បាលថ្នាក់ក្រោមជាតិ


### ២- ស្នាដៃនិពន្ធ


- ប៉ុល លឹម ៖ អំពីការរៀបចំប្រព័ន្ធគ្រប់គ្រងរដ្ឋបាលសាធារណៈ... ភាគទី២ ភ្នំពេញ ២០១៦

- សក់ សេដ្ឋា ៖ ប្រវត្តិនៃអភិបាលកិច្ចមូលដ្ឋាន វិមជ្ឈការ និងវិសហមជ្ឈការ និងក្របខណ្ឌច្បាប់សម្រាប់វិមជ្ឈការ និងវិសហមជ្ឈការនៅកម្ពុជា ភ្នំពេញ ២០០៨

- សាយ បូរី ៖ នីតិរដ្ឋបាលទូទៅ ភ្នំពេញ បោះពុម្ពលើកទី៣

# មូលដ្ឋានគ្រឹះនៃពុទ្ធសាសនា

*ដោយៈ លោក* **ឈុន ផារ៉េន**
*មន្ត្រីនាយកដ្ឋានទស្សនវិជ្ជា និង សង្គមវិទ្យា*
*នៃវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម*

## សេចក្ដីផ្ដើម

*ព្រះពុទ្ធសាសនាមានដើមកំណើតនៅប្រទេសឥណ្ឌាក្នុងសតវត្សរ៍ទី ៦ មុនគ.ស ប្រហែលគ្នានឹងសម័យទី២ នៃលទ្ធិសាសនាព្រាហ្មណ៍ ដោយព្រះសិទ្ធត្ថជាព្រះបុត្រានៃមហាក្សត្រព្រះអង្គបានត្រាស់ដឹងនូវព្រះធម៌ ហើយមានសង្ឃសាវ័កកាន់តែច្រើនបានដើរតាមមាគ៌ាជីវិតតាមព្រះអង្គ។ រហូតពេលបច្ចុប្បន្ន ពុទ្ធសាសនា ជាសាសនាមួយសំខាន់ក្នុងចំណោមសាសនាធំៗទាំងឡាយ នៅលើពិភពលោក។ ពុទ្ធសាសនាបាននិងកំពុងពង្រឹងអត្ថិភាពរបស់ខ្លួនយ៉ាងសកម្មតាមរយៈផ្សព្វផ្សាយមូលដ្ឋានគ្រឹះរបស់ខ្លួន។ តើអ្វីខ្លះជាមូលដ្ឋានគ្រឹះដ៏សំខាន់របស់ពុទ្ធសាសនា? ចម្លើយដ៏សាមញ្ញបំផុតទៅនឹងសំណួរនេះគឺៈ រតនត្រ័យ[i] មានព្រះពុទ្ធ ព្រះធម៌ និង ព្រះសង្ឃ ។*

## ១. ព្រះពុទ្ធ

*មុនពុទ្ធសករាជ៨០ឆ្នាំ មានព្រះរាជាណាចក្រតូចមួយឈ្មោះសក្កជនបទមានទីក្រុងកបិលវត្ថុ ឬជារាជធានីដែលស្ថិតនៅក្រោម អាណាគ្រប់គ្រងរបស់ព្រះបាទ បសេនទិ នាក្រុងសាវត្ថីក្នុងដែនកោសលកាលណោះព្រះបាទសុទ្ធោធនៈជារាជាធិបតេយ្យ បានរាជាភិសេកជាមួយព្រះនាងមាយាជាអគ្គមហេសី ហើយក្រោយមកក៏បានប្រសូតព្រះរាជបុត្រាមួយព្រះអង្គព្រះនាមសិទ្ធត្ថកុមារក្នុងព្រះរាជត្រកូលគោតម។ កាលព្រះជន្មាយុគ្រប់៨ វស្សា ព្រះកុមារតូចក៏បានទទួលការសិក្សានូវវិជ្ជាផ្សេងៗ ដូចជាអក្សរសាស្ត្រយុទ្ធសាស្ត្រ សិល្បៈ ក្នុងការគ្រប់គ្រង។ល។ លុះជន្មាយុគ្រប់ ១៦ ព្រះវស្សាព្រះរាជជនក ជននី ក៏បានរៀបចំព្រះរាជពិធីអភិសេកវិវាហមង្គល ព្រះរាជកុមាសិទ្ធត្ថ ជាមួយព្រះនាងយសោធរា (ពិម្ពា) ដែលជាបងប្អូនជីដូនមួយក្នុងវ័យ១៦ វស្សាដូចគ្នា ជាបុត្រីរបស់ព្រះបាទសុប្បពុទ្ធ នៃនគរកោលិយៈ។ នាព្រះជន្ម២៩វស្សា នៅថ្ងៃដែលរាហុលកុមារបុត្រារបស់ព្រះអង្គប្រសូត ព្រះសិទ្ធត្ថគោតម បានលះបង់ជីវភាព ដែលពោពេញដោយភាពស្កុកស្កម្ភនៃរាជវាំងមកធ្វើ ទុក្ករកិរិយា ដោយបង្អត់អាហារខ្លួនឯងអស់រយៈពេល ៦ឆ្នាំ។ ក្រោយពីបានលះបង់ចោលនូវ ទុក្ករកិរិយាដ៏តឹងរឹងតាមទំនៀមទម្លាប់ប្រពៃណីនៃព្រហ្មញ្ញសាសនាមកព្រះអង្គបានប្រតិបត្តិតាមមជ្ឈិមាបដិប្បទា ហើយក៏បានត្រាស់ដឹងនូវពុទ្ធិ ដោយបានរកឃើញនូវទ្រឹស្ដី ចតុរារិយសច្ច[ii] ដោយបញ្ញា*

ញាណព្រះអង្គផ្ទាល់។ព្រះពុទ្ធ ទ្រង់បានដឹងច្បាស់អំពីបញ្ហាទុក្ខលំបាកក្នុងការរស់នៅរបស់សត្វលោកដែលតែងតែវិលកើតស្លាប់ក្នុងវាលវដ្ដសង្សារឥតឈប់ឈរ។ ព្រះអង្គបានផ្ដល់គំនិតសំខាន់ៗ ដល់អ្នកមានឧបនិស្ស័យដើម្បីដោះស្រាយបញ្ហាទាំងនោះ។ ព្រះអង្គបានរស់នៅតាមព្រះធម៌ ដែលព្រះអង្គបានរកឃើញអស់ពេញមួយជីវិត និងបានផ្សព្វផ្សាយគោលគំនិតនោះដល់មនុស្សទូទៅ ឲ្យវៀរចាកផុតពីការយល់ខុសឆ្គង ខុះសច្ចភាព និងនាំឲ្យវិនាសអន្តរាយ បែរមកការយល់ត្រឹមត្រូវ ប្រកបដោយសច្ចភាពដែលនាំឲ្យបុគ្គលនិងសង្គមរស់នៅបានសុខចម្រើនមានសិរីសួស្ដី។

**១.២.ការផ្សព្វផ្សាយធម៌(ធម្មទាន)**

ក្រោយពីប្រោសបញ្ចវគ្គិយភិក្ខុឲ្យបានសម្រេចធម៌ [iii] ក្លាយជាព្រះអរហន្តរួចមក ព្រះអង្គបានប្រោស យសកុលបុត្រ និង មិត្តរបស់យសកុលបុត្រចំនួន៤អង្គទៀតឲ្យបានសម្រេចធម៌ជាន់ខ្ពស់ដែរ។បន្ទាប់មកព្រះអង្គទ្រង់បានប្រោសភិក្ខុ៥០អង្គទៀតឲ្យសម្រេចធម៌ជាព្រះអរហន្តតាមឧបនិស្ស័យរៀងៗខ្លួន។ ព្រះអរហន្តទាំង៦០រួមនិងព្រះពុទ្ធ១អង្គផងជា៦១អង្គបានចេញផ្សព្វផ្សាយធម្មទេសនាផ្ទាល់មាត់ តាមទិសដៅផ្សេងគ្នាយ៉ាងរួសរាន់ ដោយគ្មានបង្អង់ពេលវេលាឡើយដើម្បីប្រោសសត្វលោក។

នៅសម័យពុទ្ធកាល ដោយសារធម្មទេសនារបស់ព្រះអង្គ និង របស់សាវ័ក បានធ្វើឲ្យមានមនុស្សកាន់តែច្រើនបានយល់ដឹងនិងធ្វើការប្រតិបត្តិធម៌ដែលព្រះអង្គរកឃើញ ហើយមានមនុស្សកាន់តែច្រើនថែមទៀត បានក្លាយជា អរិយបុគ្គលជាបន្តបន្ទាប់។

នៅថ្ងៃមួយក្នុងដំណើរយាងបិណ្ឌបាតទៅកាន់ក្រុងកបិលពស្តុជាដំបូង ព្រះពុទ្ធ និងព្រះខីណាស្រព [iv] ជាពុទ្ធសាវកចំនួនពីរម៉ឺនអង្គទៀតនៅតាមដងផ្លូវនានិគ្រោធារាម ព្រះបាទសុទ្ធោទនមហារាជដែលជាព្រះពុទ្ធបិតា បានពោលទៅកាន់ព្រះពុទ្ធថា៖ បិតាខ្មាស់គេណាស់ត្រង់ដែលព្រះបុត្រាត្រាច់ទៅដើម្បីភិក្ខា, សុំអាហារអំពីអ្នកស្រុក, យ៉ាងដូច្នេះ។ ព្រះពុទ្ធបានប្រាប់អំពី ភិក្ខានោះថា នេះគឺជាបវេណីនៃអ្នកត្រាស់ដឹងជាព្រះពុទ្ធទាំងឡាយ បន្ទាប់មកព្រះអង្គក៏បានសម្ដែងធម៌ប្រារព្ធព្រះបិតាវិញថា៖ បុគ្គលអ្នកប្រព្រឹត្តធម៌ជាប្រក្រតីរមែងដេកជាសុខ ទាំងក្នុងលោកនេះផង ទាំងក្នុងលោកខាងមុខបរលោកផង។[1] ព្រះពុទ្ធបិតាស្ដាប់ប្រកបដោយសេចក្ដីពិចារណារួចហើយ ក៏បានសម្រេចមគ្គផល នៅតាមដងផ្លូវក្នុងក្រុងកបិលពស្តុ នាពេលនោះឯង ។

ឥទ្ធិពលនៃធម្មទានរបស់ព្រះពុទ្ធសមណគោតម បានធ្វើឲ្យអ្នកស្ដាប់មានសម្មាទិដ្ឋិ ឈប់ចាញ់បោកលើជំនឿខុះហេតុផល គ្មានការពិត

[1] សុត្តន្តបិដក ខុទ្ទកនិកាយ ធម្មបទគាថា លោកវគ្គទី១៣

ដូចជាមានការសែនព្រេន ការបួងសួងសុំសេចក្ដីសុខចម្រើនពីវត្ថុក្រៅខ្លួនដូចដែលមានក្នុងសាសនាដទៃ មានសាសនាព្រាហ្មណ៍ជាដើម។ ទង្វើបែបនេះបានផ្ដល់ផលប្រយោជន៍ច្រើនដល់ជនស្លូតត្រង់ ប៉ុន្តែអ្នកដែលធ្លាប់ទទួលលាភសក្ការៈពីការសែនព្រេនមានការខឹងសម្បារចំពោះព្រះពុទ្ធយ៉ាងខ្លាំង ពួកគេខំរិះគិតដើម្បីបំផ្លាញការងាររបស់ព្រះពុទ្ធដើម្បីកុំឲ្យផ្សព្វផ្សាយធម៌បន្តដល់មនុស្សច្រើនទៀត។ ទ្រឹស្តីទស្សនវិជ្ជាសង្គមនិងនយោបាយរបស់ព្រះពុទ្ធបានបង្កប់យ៉ាងជ្រៅក្នុងអរិយសច្ចទាំង៤។

សង្គមឥណ្ឌាមានទស្សនវិជ្ជាសង្គមនិងនយោបាយដ៏ចំណាស់យ៉ាងរឹងមាំគឺលទ្ធិសាសនាព្រាហ្មណ៍។ ទោះបីយ៉ាងនេះក៏ដោយ ក៏គោលគំនិតនៃពុទ្ធសាសនា[v] បានជះឥទ្ធិពលខ្លាំងក្នុងការកែប្រែការយល់ដឹងរបស់មនុស្សពាសពេញសង្គមឥណ្ឌានិងធ្លងចេញពីដែនដីឥណ្ឌាដោយសារពុទ្ធសាវ័កនិងពុទ្ធបរិស័ទ[vi] ទាំងឡាយបានផ្សព្វផ្សាយនិងសិក្សាជាបន្តពីមួយជំនាន់ទៅមួយជំនាន់។

## ១.៣.ពុទ្ធកិច្ច និង ពុទ្ធោវាទចុងក្រោយ

ព្រះបាទសប្បុពុទ្ធជាបិតាក្មេកបានខឹងយ៉ាងខ្លាំងដោយចាត់ទុកព្រះសិទ្ធត្ថ ថាជាមនុស្សដែលមិនគិតពីបុត្រនិងមហេសី ព្រោះព្រះសិទ្ធត្ថចាកចេញទៅស្វែងរកធម៌ ដោយលះបង់ចោលសម្បត្តិលោកិយមិនព្រមទទួលយកការសោយរាជ្យជាស្តេចដែលជាជីវិតពោរពេញដោយការសប្បាយដែលមនុស្សលើលោកតែងប្រាថ្នាចង់បាននោះ។ ទោះបីជួបឧបសគ្គដ៏ធំធេងយ៉ាងណាក៏ព្រះសិទ្ធត្ថ ខិតខំប្រឹងប្រែងព្យាយាមស្វែងរកលោកុត្តរធម៌ ដើម្បីការត្រាស់ដឹងជាព្រះពុទ្ធ រហូតបានសម្រេច ហើយបានជួយឲ្យមនុស្សគ្រប់ជំនាន់បានរស់នៅចាកផុតទុក្ខបានយ៉ាងពិតប្រាកដ។ក្នុងនាមជាអ្នកជួយប្រោសសព្វសត្វមនុស្ស ទេវតា ទោះបីមានអាពាធ ឈឺចង្កេះប្រចាំកាយក៏ដោយ ក៏ព្រះអង្គទ្រង់បំពេញពុទ្ធកិច្ចជាប់ជានិច្ចអស់រយៈពេល ៤៥វស្សា ដើម្បីបំភ្លឺសត្វលោក ឲ្យស្គាល់ជីវិតពិត និងអនុវត្តវិធីរស់នៅបានសុខស្ងប់ដូចព្រះអង្គដែរ។ធម៌របស់ព្រះអង្គគឺមិនមែនសម្រាប់តែខ្លួនព្រះអង្គឡើយគឺជាធម៌សកលសម្រាប់កែប្រែសង្គមមនុស្សទូទៅ។ការរស់នៅរបស់ព្រះពុទ្ធ មិនមែនអាត្មានិយមសោយសុខម្នាក់ឯងឡើយ គឺជីវិតព្រះអង្គកើតមកសម្រាប់ជួយអ្នកដទៃតាមរយៈពុទ្ធកិច្ច៥ប្រការៈ ១.ពេលទៀបភ្លឺ(បច្ឆិមយាម)ទ្រង់ប្រមើលមើលឧបនិស្ស័យសត្វ ២.ពេលព្រឹកទ្រង់និមន្តបិណ្ឌបាត។ ៣.ពេលរសៀល ព្រះអង្គទ្រង់សំដែងធម្មទេសនាប្រោសពុទ្ធបរិស័ទ៤.ពេលយប់ (បឋមយាម) ទ្រង់ប្រទានឱវាទ ចំពោះភិក្ខុសង្ឃសាវ័ក និង៥.ពេលពាក់កណ្ដាល អធ្រាត្រ(មជ្ឈិមយាម) ទ្រង់ដោះប្រស្នាទេវតា។

ព្រះអង្គមិនព្រមជ្រើសយកជីវិតរស់នៅជាស្តេចចក្រពត្តិ ព្រោះឈ្វេងយល់ថាតំណែងបែបនេះសង្គ្រោះបានត្រឹមតែជនមួយចំនួនមានដូចជា

ពួកព្រាហ្មណ៍ គហបតិ អ្នកនិគម អ្នកជនបទ ពួកស្មៀន ពួកសេនា ឆ្មាំទ្វារ អាមាត្យ រាជបរិស័ទ ស្តេចចំណុះ អ្នកមានភោគៈ និងរាជកុមារ បាន តែមួយជំនាន់ប៉ុណ្ណោះ។ ចំណែកការត្រាស់ដឹង គឺបានសង្គ្រោះដល់បរិស័ទគឺ ពួកភិក្ខុ ពួកភិក្ខុនី ឧបាសក ឧបាសិកា ទេវតា មនុស្ស អសុរ នាគ គន្ធព្វ ក្នុងចក្រវាឡច្រើនជំនាន់។ គោលដៅព្រះពុទ្ធគឺជួយមនុស្សជាតិឲ្យស្គាល់ការពិតនៃជីវិត និងការរស់នៅប្រកបដោយសុចរិត ចេះថែសុខភាពផ្លូវកាយផ្លូវចិត្ត មានគុណធម៌ខ្ពស់ ចេះប្រតិបត្តិសីល៥ សីល៨ សីល១០ និងសិក្ខាបទនានាទៅតាមវ័យ និងតួនាទីរៀងៗខ្លួន ជាដើម។

ព្រះពុទ្ធបានបន្សល់ទុកនូវឱវាទ(ពុទ្ធោវាទ) ដែលជាគោលគំនិតដ៏មានសារៈសំខាន់ សម្រាប់អប់រំជាប្រយោជន៍ដល់មនុស្សជាតិទូទៅយកទៅប្រតិបត្តិក្នុងការរស់នៅដើម្បីសេចក្តីសុខចម្រើនផ្ទាល់ខ្លួន សម្រាប់គ្រួសារ សហគមន៍ សង្គមជាតិ ពិភពលោក រហូតបរលោកទៀតផង។ ពុទ្ធោវាទទាំងនោះមានចែងយ៉ាងពេញលេញក្នុងចតុរារិយសច្ច ដែលជាមូលដ្ឋានគ្រឹះនៃទស្សនវិជ្ជាសង្គមនិងនយោបាយបែបពុទ្ធសាសនា។ ទ្រឹស្តីពុទ្ធសាសនារុងរឿងនៅគង់វង្ស ឬវិនាសសាបសូន្យ គឺអាស្រ័យលើការយល់ដឹងនិងការគោរពប្រតិបត្តិដោយត្រឹមត្រូវឬខុសឆ្គងរបស់ពុទ្ធបរិស័ទ[vii] ផងដែរ។ មុនបរិនិព្វាន ព្រះអង្គទ្រង់មានបន្ទូលថា អ្វីៗដែលកើតមានហើយផ្តុំឡើងហើយ តែងមានសភាវធម៌ និងរលត់ទៅវិញជាធម្មតា អ្នកទាំងឡាយចូរញុំាងប្រយោជន៍ឲ្យសំរេចដោយកិរិយាមិនប្រមាទចុះ។

ព្រះពុទ្ធប្រសើរដោយសីលាទិគុណ វិសុទ្ធិគុណ និងបញ្ញាទិគុណ។ ព្រះអង្គទ្រង់ប្រព្រឹត្តនូវប្រយោជន៍៣ប្រការមានប្រយោជន៍ដើម្បីបាននូវព្រះសម្មាសម្ពោធិញ្ញាណព្រះអង្គឯងផង ប្រយោជន៍ព្រះញាតិព្រះអង្គផង និងប្រយោជន៍ជួយស្រោចស្រង់សត្វលោកផង។ ម្យ៉ាងវិញទៀត ព្រះអង្គជាសាស្តាចារ្យនៃទេវតានិងមនុស្សទាំងឡាយផងព្រះអង្គបែងចែកចំណែកព្រះធម៌ពាក្យប្រៀនប្រដៅដល់សត្វលោកទូទៅស្មើៗគ្នាផង ព្រះអង្គប្រកបដោយទសពលញ្ញាណផង និងញាណដទៃទៀត។ ព្រះអង្គជាទីពឹងដ៏ប្រសើររបស់សត្វលោកផង ព្រះអង្គឆ្លៀវឈ្លាសក្នុងការសម្តែងធម៌ប្រោសវេនេយ្យសត្វផង។

ទោះបីព្រះពុទ្ធបរិនិព្វានទៅហើយក៏ដោយ ក៏ទ្រឹស្តីធម៌ដែលព្រះពុទ្ធបានទេសនា នៅតែមានឥទ្ធិពល និង បានផ្សព្វផ្សាយពាសពេញសាកលលោក។ ទ្រឹស្តីព្រះពុទ្ធសាសនា នៅតែមានអ្នកយល់ចូលចិត្ត និងយកទៅប្រើជាមាគ៌ាជីវិត សម្រាប់ជួយមនុស្សគ្រប់ប្រភេទ គ្រប់ជាតិសាសន៍ គ្រប់កាលៈទេសៈនិងគ្រប់ជំនាន់ ដោយសារទ្រឹស្តីប្រកបដោយហេតុផលគ្រប់គ្រាន់។

## ២.ព្រះធម៌

មូលដ្ឋានគ្រឹះដ៏រឹងមាំនៃព្រះពុទ្ធសាសនា គឺព្រះធម៌ ដែលទ្រឹស្តីអំពីជីវិតដែលមនុស្សគ្រប់វ័យ

គ្រប់ជាតិសាសន៍អាចរៀនសូត្រនិងប្រតិបត្តិបានគ្រប់សម័យកាយ។ ព្រះធម៌ទាំងឡាយរបស់ព្រះពុទ្ធត្រូវបានកត់ត្រាទុកគម្ពីរព្រះត្រៃបិដកជាភាសាបាលី និងភាសាដទៃយ៉ាងច្បាស់លាស់។

**២.១.គម្ពីរព្រះត្រៃបិដក**

គម្ពីរព្រះត្រៃបិដកជាឃ្លាំងផ្ទុកព្រះពុទ្ធវចនៈដែលព្រះសម្ពុទ្ធទេសនាទូន្មានរវាង៤៥វស្សា ចាប់តាំងពីទ្រង់បានត្រាស់ដឹងព្រះសម្មាសម្ពោធិញ្ញាណ រហូតមកដល់ទ្រង់បរិនិព្វាន។

បច្ចុប្បន្ន ដោយមានគម្ពីរព្រះត្រៃបិដកជាបង្អែកយ៉ាងសំខាន់ ព្រះពុទ្ធសាសនាបានផ្សព្វផ្សាយទ្រឹស្តីយ៉ាងទូលំទូលាយពេញពិភពលោក។ ពុទ្ធសាសនិកជន ជាពិសេសភិក្ខុសង្ឃ បានខិតខំសូត្រទន្ទេញចាំមាត់រហូតមានកត់ត្រាពុទ្ធោវាទដែលជាគោលគំនិតសំខាន់ៗ របស់ព្រះពុទ្ធនៅក្នុងគម្ពីរព្រះត្រៃបិដកយ៉ាងច្បាស់លាស់។

ព្រះថេរទាំងឡាយបានសង្គាយនាផ្ទៀងផ្ទាត់ចងក្រងពុទ្ធឱវាទដែលពន្យល់បញ្ជាក់និងការពារអរិយសច្ច សរុបមាន៨ម៉ឺន៤ពាន់ធម្មខន្ធក្នុងព្រះត្រៃបិដក។ គម្ពីរព្រះត្រៃបិដកមាន៣ចំណែកគឺៈ១.វិនយបិដកមាន១៣ភាគ ២.សុត្តន្តបិដកមាន៦៤ភាគ និង ៣.អភិធម្មបិដកមាន៣៣ភាគ។ គម្ពីរទាំង៣នេះ មានអដ្ឋកថា[viii] ដីកា[ix] យោជនា[x] ប្រកបទៀតផង។

**២.១.១.វិនយបិដក** ជាគម្ពីរស្តីពីច្បាប់ក្រឹត្យក្រមដែលអង្គព្រះសម្ពុទ្ធទ្រង់បញ្ញត្តិនិងអនុញ្ញាតទុកសម្រាប់ជាផ្លូវប្រតិបត្តិរបស់ ភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា។ គម្ពីរវិន័យនេះ មានសេចក្តីពិស្តារណាស់ ជាកញ្ចក់ឆ្លុះមើលជីវប្រវត្តិអង្គព្រះសម្ពុទ្ធ ក្នុងកាលដែលទ្រង់គង់ធរមាននៅឡើយ ព្រមទាំងហេតុការណ៍ផ្សេងៗ នៅប្រទេសឥណ្ឌានាសម័យព្រះអង្គដូចប្រវត្តិសាស្ត្រ ជំនឿ ទំនៀមទម្លាប់ ជាដើម។ បញ្ញត្តិនិងអនុញ្ញាតទាំងអស់សុទ្ធតែជាដំណោះស្រាយបញ្ហា ដែលតែងតែកើតឡើងក្នុងជីវិតរស់នៅប្រចាំថ្ងៃនៃពុទ្ធបរិស័ទផ្ទាល់តែម្តង ។

**២.១.២.សុត្តន្តបិដក** (ឬគម្ពីរសុត្តន្ត ឬគម្ពីរព្រះសូត្រ) ជាគម្ពីរស្តីពីសូត្រដែលអង្គព្រះសម្ពុទ្ធទ្រង់ត្រាស់ទេសនាក្នុងសម័យផ្សេងៗ។ មានសូត្រខ្លះ សម្តែងដោយព្រះអរិយសាវ័កដូចជាព្រះសារីបុត្តត្ថេរ ព្រះមោគ្គល្លានត្ថេរ ព្រះអានន្ទត្ថេរ។ សុត្តន្តបិដកជា វោហារទេសនា បែបអក្សរសិល្ប៍ ដែលអាចឆ្លុះបញ្ចាំងអំពីតថភាពសង្គមនិងជំនឿលទ្ធិផ្សេងៗមានលទ្ធិសាសនាព្រាហ្មណ៍ជាដើមទាំងក្នុងសម័យពុទ្ធកាល និងសម័យអតីតកាលដ៏យូរលង់។

**២.១.៣.អភិធម្មបិដក** ជាគម្ពីរស្តីពីធម៌ដ៏មានអាថ៌ជ្រាលជ្រៅ មានអត្ថល្អិតសុខុមបំផុត បានដល់ ទស្សនវិជ្ជានៃពុទ្ធសាសនា ដែលប្រកបដោយអាថ៌គម្ពីរភាព។ អភិធម្មបិដក ជាបរមត្ថទេសនា ស្តីអំពី ចិត្ត[xi] ចេតសិក[xii] រូប និព្វាន ដែលមានការពន្យល់យ៉ាងលំអិតក្នុងចតុរារិយសច្ច។ អភិធម្មបិដកបញ្ជាក់ អំពីគោលគំនិតទស្សនវិជ្ជាអំពីជីវិត ដោយពន្យល់ថាការកើតជីវិត(ជាតិ)

ទាំងឡាយ បណ្ដាលមកពីជាតុអវិជ្ជាដែលជាសង្ខតជាតុមានទឹកដីភ្លើងខ្យល់តាមអំពើកម្មនៃច្បាប់ធម្មជាតិ។អ្វីៗទាំងអស់តែងប្រែប្រួលមិនស្ថិតស្ថេរឡើយ វារងសម្ពាធជាទុក្ខ វាមិនមែនជាកម្មសិទ្ធិរបស់ខ្លួនវាឡើយ។ វដ្តសង្សារនៃជីវិតក្នុងចក្រវាឡត្រូវស្ថិតនៅក្រោមទ្រឹស្ដីបដិច្ចសមុប្បាទ មិនមានអាទិទេពជាអ្នកបង្កើតឡើយ គឺធម៌ឬធម្មជាតិទៅវិញទេដែលបង្កើតអាទិទេពទាំងនោះ។

ពុទ្ធបរិស័ទមានការប្រតិបត្តិធម៌ប្លែកគ្នាទៅតាមនិកាយរៀងខ្លួន។ និកាយថេរវាទប្រតិបត្តិធម៌ តាមឱវាទព្រះពុទ្ធ(ពុទ្ធោវាទ) ដូចដែលមានចែងក្នុងគម្ពីរព្រះត្រៃបិដក។ និកាយនេះជឿថាព្រះពុទ្ធសមណគោតមបានបរិនិព្វាន[xiii] រំលត់ខន្ធ៥អស់ហើយ គឺមិនទាក់ទងនឹងការបួងសួងបន់ស្រន់និងអង្វរកររបស់មនុស្សលោកឬអ្នកណាឡើយ។ បរិស័ទនិកាយថេរវាទនៅគោរពព្រះពុទ្ធដីកា ដែលព្រះអង្គបានផ្ដាំនៅមុនពេលបរិនិព្វាន។ ព្រះអង្គបានផ្ដាំថា៖ អ្នកណាប្រតិបត្តិធម៌ត្រឹមត្រូវតាមធម៌ ប្រតិបត្តិដោយភក្ដីភាព ប្រតិបត្តិតាមគន្លងធម៌ អ្នកនោះឈ្មោះថាបូជាតថាគត ធ្វើសក្ការៈគោរពពាប់អាន ដោយការបូជាប្រសើរបំផុត។ ពុទ្ធបរិស័ទនេះយល់ថាបើអ្នកណាប្រតិបត្តិតាមពុទ្ធវចនៈ ដោយគោរពតាមគោលការណ៍ត្រឹមត្រូវ អ្នកនោះនឹងបានឃើញធម៌ លុះនិព្វានឥតសង្ស័យឡើយ ។

ចំណែកនិកាយមហាយានវិញប្រតិបត្តិធម៌ទៅតាមរយៈពាក្យដឹកនាំទូន្មានប្រៀនប្រដៅរបស់អាចារ្យ (អាចរិយវាទ) រៀងៗខ្លួន ដោយជឿលើតួអង្គពោធិសត្វ[xiv] ថាជាអ្នកនៅតាមជួយថែរក្សានិងជួយសង្គ្រោះសត្វលោក នៅពេលសត្វលោកធ្វើពិធីបួងសួងបន់ស្រន់ អង្វរករ។ល។

ទោះយ៉ាងនេះក្ដី និកាយទាំងអស់ បានពឹងផ្អែកទៅលើ ចតុរារិយសច្ច (អរិយសច្ចទាំង៤) ថាជា គោលគំនិតសំខាន់ ឬជាទ្រឹស្ដីគ្រឹះនៃព្រះពុទ្ធសាសនា សម្រាប់ធ្វើជាមាគ៌ាដឹកនាំជីវិតរស់នៅទាំងក្នុងលោកនេះនិងបរលោក។

**២.២.ចតុរារិយសច្ច**[2]

ចតុរារិយសច្ច ឬអរិយសច្ច៤យ៉ាង ដែលជាការពិតពិតប្រាកដ ៤យ៉ាងដែលមានជម្រៅហួសពីសម្មតិសច្ចដែល សន្មតដោយបុគ្គល, គឺជាសច្ចសត្យានុម័ត ឬសច្ចបរានុម័ត៤យ៉ាងដែលជ្រៅជាងសច្ចអត្តនោម័ត។ ចំនុចពិសេសនៃចតុរារិយសច្ច ដែលព្រះពុទ្ធរកឃើញគឺ៖

១.ទុក្ខអរិយសច្ច សេចក្ដីលំបាកពិតប្រាកដ។ ២.ទុក្ខសមុទិយអរិយសច្ច ហេតុនៃសេចក្ដីលំបាកពិតប្រាកដ។ ៣.និរោធអរិយសច្ច សេចក្ដីសុខស្ងប់ពិតប្រាកដ។៤. មគ្គអរិយសច្ច មាគ៌ាត្រឹមត្រូវ

---

[2] សូមមើល សុត្តន្តបិដក ទីឃនិកាយ ចតុត្ថភាគ មហាវគ្គ បិដកលេខ១៧ ចាប់ពីទំព័រទី ២៤៤ ដល់ ៣០៤

ពិតបាកដសម្រាប់ប្រតិបត្តិទៅដល់សេចក្តីសុខស្ងប់ចាកទុក្ខទាំងពួង។

ការពិតទាំងនេះ មនុស្សសាមញ្ញមិនអាចយល់បានដោយប្រើចំណេះដឹងទូទៅធម្មតា ឬពុទ្ធិសាមញ្ញ ដើម្បីយល់ដឹងបែបស៊ីជម្រៅបានឡើយ។ អរិយសច្ចទាំង៤នេះ ត្រូវការចាំបាច់ប្រើនូវចំណេះដឹងវិទ្យាសាស្ត្រ ឬពុទ្ធិវិទ្យាសាស្ត្រ និងចំណេះដឹងទស្សនវិជ្ជា[xv]ឬពុទ្ធិទស្សនវិជ្ជា ដើម្បីយល់និងពន្យល់បង្ហាញល្អិតល្អន់។ ចតុរារិយសច្ច សង្ខេបខ្លីថា ទុក្ខ, សមុទិយ, និរោធ, មគ្គ គឺជាបរមត្ថធម៌ដែលពន្យល់ពីច្បាស់ពីធម្មជាតិពិតនៃមនុស្សសត្វដោយលើកឡើងពន្យល់ពីអត្តិភាពនៃបញ្ចខន្ធ ដោយបញ្ជាក់ថា នាមរូបំ អនិច្ចំ ទុក្ខំ អនត្តា ជាដើម។ នាមរូបំ អនិច្ចំ ទុក្ខំ អនត្តា មានន័យថា នាមនិងរូប (គឺចិត្ត ចេតសិក និងរូប) កើតឡើងពីទឹកដីភ្លើងខ្យល់តែងតែប្រែប្រួល រងការលំបាកនិងមិនមែនជាកម្មសិទ្ធរបស់ខ្លួនបុគ្គលណាមួយឡើយ។ គ្មានអ្វីនៅស្ថិតស្ថេរអមតៈនោះទេ។ បញ្ហាប្រឈមរបស់មនុស្សជាតិនៅក្នុងពេលបច្ចុប្បន្ន គឺការប្រកាន់ហួងហែង អស្មិះមានៈ លោភលន់កេងប្រវញ្ច លើទុក្ខវេទនាជីវិតសត្វនិងមនុស្សដូចគ្នា ដើម្បីមានបានផ្ទាល់ខ្លួន អាត្មានិយម គ្រួសារនិយម បក្សពួកនិយម នាំមកនូវជម្លោះ សង្គ្រាម កាប់ចាក់ប្រល័យគ្នាឥតឈប់ឈរតាំងពីអតីតកាលតរៀងមក។

ព្រះពុទ្ធសមណគោតមបានសម្រេចបាននូវញេយ្យធម៌ បានត្រាស់ដឹងនូវអរិយសច្ច៤យ៉ាងដែលហៅថា ចតុរារិយសច្ច។ បន្ទាប់មកព្រះអង្គបានទេសនាចែកជូនដល់សាវកឲ្យបានយល់ដឹងនិងប្រតិបត្តិតាមក្នុងការរស់នៅប្រចាំថ្ងៃទៅតាមឧបនិស្ស័យរៀងៗខ្លួន។

ចតុរារិយសច្ចមានៈ ១.ទុក្ខអរិយសច្ច ២.ទុក្ខសមុទយអរិយសច្ច ៣.ទុក្ខនិរោធអរិយសច្ច ៤.មគ្គអរិយសច្ច។

## ២.២.១.ទុក្ខអរិយសច្ច

ទុក្ខអរិយសច្ច គឺសេចក្តីលំបាកកាយ មិនសប្បាយចិត្តកើតមានដ៏ពិតប្រាកដ។ សព្វសត្វទាំងអស់ចាប់ពីពេលកើត(ភវង្គបដិសន្ធិ) រហូតដល់ពេលស្លាប់(ភវង្គចុតិ) បានបែកធ្លាយខន្ធ៥គឺតែងសោយទុក្ខវេទនាជាបន្តបន្ទាប់។ ទុក្ខវេទនាគឺការដឹងអំពីការពិបាកក្នុងការរស់នៅដូចជាទុក្ខនៅខណៈនៃការស្រេកឃ្លានអាហារ ការតម្រេកក្នុងកាមតណ្ហា ការដេកផ្ទុយ ការអស់កម្លាំង ជម្ងឺ ចាស់ជរាជាដើម។លើសពីនេះនៅមានទុក្ខផ្លូវចិត្តដោយការសោយសោក[xvi] បរិទេវទុក្ខ[xvii] ទោមនស្ស[xviii] ឧបាយាសៈ[xix]។ ទុក្ខទាំងនេះកើតមានដោយសារតែការជួបប្រទះនូវរបស់មិនជាទីស្រឡាញ់ ការប្រាសចាកនូវរបស់ជាទីស្រឡាញ់ ការមិនបានវត្ថុដែលជាទីស្រឡាញ់ ជាដើម ។

## ២.២.២. ទុក្ខសមុទយអរិយសច្ច

មូលហេតុនាំឲ្យមានទុក្ខ ដែលពុទ្ធបរិស័ទនិយមហៅថា ទុក្ខសមុទយអរិយសច្ច គឺជាហេតុបច្ច័យពិតប្រាដកដែលនាំឲ្យមានសេចក្តីលំបា

ក។ ហេតុពិតប្រាកដនៃទុក្ខគឺ ការកើត(ជាតិ) ដែលជាអត្ថិភាពជីវិត ជាការផ្សំឡើងដោយគំនរនៃបញ្ចខន្ធ (ខន្ធ៥) គឺ រូបក្ខន្ធ, វេទនាខន្ធ, សញ្ញាខន្ធ, សង្ខារក្ខន្ធ, វិញ្ញាណក្ខន្ធ ជាបរមត្ថ គឺ នាមរូបំ អនិច្ចំ ទុក្ខំ អនត្តា ដោយគោរពតាមច្បាប់កម្មផល គឺទ្រឹស្តីបដិច្ចសមុប្បាទ[xx]។

ការមានជីវិតឬ មានការកើត ឬមានជាតិ គឺមានទុក្ខ ហើយមូលហេតុនៃទុក្ខពិតប្រាកដ គឺបណ្តាលមកពីជាតុនៃអវិជ្ជាជាអាទិ៍ ដែលតាមទ្រឹស្តីបដិច្ចសមុប្បាទ (ធម៌ ឬសភាវៈ ដែលកើតមានឡើងដោយសារបច្ច័យ គឺគ្រឿងអាស្រ័យទាក់ទងតៗគ្នា) បានបញ្ជាក់ថា៖

១.អវិជ្ជា[xxi] ជាបច្ច័យ[xxii] ឲ្យកើតមាន សង្ខារ, ២. សង្ខារ[xxiii] ជាបច្ច័យឲ្យកើតមាន វិញ្ញាណ, ៣. វិញ្ញាណ[xxiv] ជាបច្ច័យឲ្យកើតមាន នាមរូប, ៤. នាមរូប[xxv] ជាបច្ច័យឲ្យកើតមាន អាយតនៈ, ៥. អាយតនៈ[xxvi] ជាបច្ច័យឲ្យកើតមាន ផស្សៈ,
៦.ផស្សៈ[xxvii] ជាបច្ច័យឲ្យកើតមាន វេទនា,
៧.វេទនា[xxviii] ជាបច្ច័យឲ្យកើត តណ្ហា
៨.តណ្ហា[xxix] ជាបច្ច័យឲ្យកើតមាន ឧបាទាន, ៩. ឧបាទាន[xxx] ជាបច្ច័យឲ្យកើតមាន ភព, ១០.ភព[xxxi] ជាបច្ច័យឲ្យកើតមាន ជាតិ, ១១.ជាតិ[xxxii] ជាបច្ច័យនៃ ជរា ព្យាធិ មរណៈ
១២.មរណៈ[xxxiii] ជាបច្ច័យឲ្យកើតអវិជ្ជា ។

ការជាប់ប្រទាក់គ្នាវិលវល់ជាបន្តបន្ទាប់ឥតដាច់ នៃច្រវាក់ទាំង ១២ កងនេះ ឈ្មោះថា បដិច្ចសមុប្បាទ។ ទុក្ខវេទនា ការដឹងអំពីទុក្ខ គឺការលំបាកខាងផ្លូវកាយ បណ្តាលមកអំពីការកើត (ជាតិ), ការចាស់(ជរា), ការឈឺ(ព្យាធិ) និងការស្លាប់(មរណៈ)។ចំណែកទោមនស្សវេទនា ឬទុក្ខវេទនាខាងផ្លូវចិត្ត មានដូចជាសេចក្តីសោកស្តាយ, ខ្សឹកខ្សួល, តូចចិត្ត, ទង្គឹះតានតឹងចិត្ត បណ្តាលមកអំពីកិលេសគឺមោហៈលោភៈទោសៈរបស់មនុស្សសត្វគ្រប់រូបក្នុងដំណើរជីវិត គឺ ការកើត (ជាតិ), ការចាស់(ជរា), ការឈឺ(ព្យាធិ) និងការស្លាប់(មរណៈ)នេះឯង។ ដើម្បីបំបាត់សេចក្តីសោកស្តាយ សេចក្តីទោមនស្ស សេចក្តីចង្អៀតចង្អល់ចិត្ត សេចក្តីខ្សឹកខ្សួល, សេចក្តីតូចចិត្ត, ទង្គឹះតានតឹងចិត្តទាំងនេះ គឺត្រូវបំបាត់អាសវក្កិលេសគឺ តណ្ហា ឧបាទាន ភព ជាតិ ជាដើម ផុតចាកចេញពីសន្តានចិត្តជាមុនសិន។ ចំពោះមនុស្សបុថុជ្ជន[xxxiv] មានទុក្ខខាងផ្លូវកាយផងថែមទាំងមានទោមនស្សដែលជាទុក្ខផ្លូវចិត្តថែមមួយកម្រិតទៀត។ រីឯអរិយបុគ្គល[xxxv]មានតែទុក្ខតាមផ្លូវកាយប៉ុណ្ណោះព្រោះបានលះអស់នូវ សំយោជនៈឬអាសវក្កិលេសដែលជាគ្រឿងត្រាំសៅហ្មងអស់ក្នុងសន្តាន ។

### ២.២.៣.ទុក្ខនិរោធអរិយសច្ច

ទុក្ខនិរោធអរិយសច្ច គឺជាការរម្ងត់ទុក្ខពិតប្រាដក, ឬដំណើរអស់ទុក្ខ(ទុក្ខក្ស័យ) ឬហៅថា ទុក្ខនិរោធ (សេចក្តីរលត់ទុក្ខ) ឬហៅថា និព្វាន (ឬ និរ្វាណ)។ និព្វាន គឺជាឈ្មោះធម្មជាតិឬចិត្តមួយបែបដែលចេញផុតស្រឡះចាកតណ្ហាដែល

ចាក់ស្រេះទាក់ទាក់រូបរឹតក្នុងចិត្ត គឺអស់មានកម្មដដែលៗ (បុនប្បុនក្កម្ម) តទៅទៀត ។

ទុក្ខនិរោធអរិយសច្ច ឬនិព្វាន ជាបរមត្ថធម៌ មានអត្ថន័យសុខុមល្អិតហួសវិស័យនៃបុថុជ្ជនលុះតែបុថុជ្ជនអ្នកធុញទ្រាន់នឿយណាយរសាយចិត្ត ឃ្លាតចាកកម្មដដែលៗទើបយល់ឃើញព្រឹលៗ ថាមាននិព្វានពិតមែន។

សម្រាប់ព្រះពុទ្ធ, ព្រះបច្ចេកពុទ្ធ, ព្រះអរហន្តខីណាស្រព ទាំងឡាយ មានគោលដៅខ្ពស់បំផុតគឺមិនត្រឹមតែនិព្វានប៉ុណ្ណោះទេ ប៉ុន្តែគឺបរិនិព្វានដែលជាការរម្ងត់អស់ខន្ធ៥(ខន្ធនិព្វាន) លែងកើតស្លាប់ក្នុងវាលវដ្តសង្សារទៀត មានតែបរមសុខ ហៅថា ឯកន្តបរមសុខ ។

**២.២.៤.មគ្គអរិយសច្ច**

មគ្គអរិយសច្ច ឬទុក្ខនិរោធគាមិនី ឬបដិបទាអរិយសច្ច ឬមគ្គសច្ច ឬសម្មាមគ្គ[xxxvi] គឺជាសេចក្តីប្រតិបត្តិ ជាផ្លូវ ជាវិធី ឬជាគន្លងឧបាយនាំឲ្យរម្ងត់ទុក្ខពិតប្រាកដ។ ផ្លូវជាឧបាយឲ្យរលត់ទុក្ខទាំងឡាយមានអង្គ៨ គឺ៖ ១.សម្មាទិដ្ឋិ[xxxvii] ២.សម្មាសង្កប្ប[xxxviii] ៣.សម្មាវាចា[xxxix] ៤.សម្មាកម្មន្ត[xl] ៥.សម្មាអាជីវៈ[xli] ៦.សម្មាវាយាមៈ[xlii], ព្យាយាមត្រឹមត្រូវ, ៧.សម្មាសតិ[xliii] ៨.សម្មាសមាធិ[xliv], ដំណើរតាំងចិត្តខ្ជាប់ខ្ជួនត្រូវ។ អដ្ឋង្គិកមគ្គគឺជាផ្លូវប្រតិបត្តិនៃបញ្ញា សីល សមាធិ ដែលមានលំដាប់ដូចតទៅ៖ **ក.បញ្ញា**[3] [xlv] គឺ ១.សម្មាទិដ្ឋិ ២.សម្មាសង្កប្ប **ខ.សីល**[xlvi] គឺ ៣.សម្មាវាចា, ៤.សម្មាកម្មន្ត, ៥.សម្មាអាជីវៈ **គ.សមាធិ**[xlvii] គឺ ៦.សម្មាវាយាមៈ ៧.សម្មាសតិ, ៨.សម្មាសមាធិ។

នៅពេលមានការចម្រើនបញ្ញាត្រឹមត្រូវគឺការយល់ដឹងត្រឹមត្រូវនិងមានការត្រិះរិះត្រឹមត្រូវមានឡើង ការប្រព្រឹត្តិសីលត្រឹមត្រូវ គឺអំពើ និងសកម្មភាពផ្លូវ កាយ វាចា ចិត្ត ត្រឹមត្រូវ នឹងកើតមាន ហើយសមាធិ គឺសេចក្តីសុខស្ងប់ចិត្ត ក៏នឹងកើតមានដែរ។ ដូចគ្នានេះដែរ ការប្រព្រឹត្តិសីលបានត្រឹមត្រូវ សម្មាសមាធិ នឹងកើតមាន ហើយឱកាសនៃការធ្វើវិបស្សនាដើម្បីចម្រើនបញ្ញាក៏អាចនឹងកើតមានឡើងដែរ។ សីល សមាធិ បញ្ញា ប្រៀបដូចជាមុំ៣នៃជើងក្រាន ខ្វះណាមួយមិនបាន គឺត្រូវសហការគ្នាជានិច្ច។

ការប្រតិបត្តិ សីល សមាធិ បញ្ញា និងការប្រតិបត្តិអដ្ឋង្គិកមគ្គ គឺមានន័យដូចគ្នា។ សីល សមាធិ បញ្ញា គឺជាមជ្ឈិមាបដិប្បទា(វិធីកណ្តាល) ដែលមនុស្សអាចយល់ និង ប្រតិបត្តិបានដោយមិនងាយស្រួលពេកហើយក៏មិនពិបាកហួសហេតុពេកដែរ។ វិធីកណ្តាលនេះ គឺជាទ្រឹស្តីដែលមនុស្សទូទៅអាចអនុវត្ត ប្រព្រឹត្តិទៅបានតាមឧបនិស្ស័យរៀងខ្លួន។ មូលដ្ឋានបដិបត្តិគោលការណ៍នេះអាចធ្វើជាប្រក្រតីក្នុងជីវិតប្រចាំថ្ងៃ។ គេអាចធ្វើការហ្វឹកហាត់តាមវិធីវិបស្សនា ដោយផ្តើមពីធម្មចរិយា នៃការប្រតិបត្តិ

[3] សូមមើល បិដក ភាគ ៨២ ចាប់ពីទំព័រទី ៨៣ ដល់ ៩៨

សីល ឲ្យត្រឹមត្រូវ។ ការប្រតិបត្តិ សីល ត្រឹមត្រូវ មូលដ្ឋានសម្រាប់ ចម្រើន សមាធិ ការធ្វើចិត្តឲ្យ មូល ហើយការធ្វើចិត្តឲ្យបរិសុទ្ធផូរផង់ នឹង សម្រេចឡើងបានដោយសារបញ្ញា គឺគតិបណ្ឌិត នៃការយល់ច្បាស់អំពីភាពពិតឥតបន្ទំ។ ការ ប្រតិបត្តតាមអដ្ឋង្គិកមគ្គ ឬ ប្រតិបត្តិ សីល សមាធិ បញ្ញា នាំឲ្យសម្រេចបាននូវ ឧត្តរិមនុស្សធម្ម មាន ដូចជា ៖

**១. ឈាន** [xlviii], គុណជាតសំរាប់ដុតបង់នូវកិលេស បានខាង បឋមជ្ឈាន ទុតិយជ្ឈាន តតិយជ្ឈាន ចតុត្ថជ្ឈាន។

**២. វិមោក្ខ**[xlix] គុណធម៌ដែលផុតស្រឡះចាករាគៈ ជាដើម) បានខាង សុញ្ញតវិមោក្ខ អនិមិត្តវិមោក្ខ អប្បណិហិតវិមោក្ខ។

**៣.សមាធិ**, សភាពដែលដំកល់ចិត្តស្មើមាំល្អក្នុង អារម្មណ៍ បានខាង សុញ្ញតសមាធិ អនិមិត្ត សមាធិ អប្បណិហិតសមាធិ។

**៤.សមាបត្តិ**[l], គុណជាតិដែលដល់ព្រម បានខាង សុញ្ញតសមាបត្តិ អនិមិត្តសមាបត្តិ អប្បណិហិត សមាបត្តិ។

**៥.ញាណទស្សនៈ**[li], កិរិយាឃើញដោយបញ្ញា បានខាង ត្រៃវិជ្ជា[lii] គឺសេចក្តីដឹងវិសេស៣យ៉ាង។

**៦.មគ្គភាវនា**, កិរិយាចំរើននូវមគ្គ បានខាង សតិប្បដ្ឋាន៤ សម្មប្បធាន៤ ឥទ្ធិបាទ៤ ឥន្ទ្រិយ៥ ពល៥ ពោជ្ឈង្គ៧ មគ្គប្រកបដោយអង្គ៨ដ៏ ប្រសើរ។

**៧. ផលសច្ឆិកិរិយា**, ដំណើរធ្វើឲ្យច្បាស់លាស់នូវ ផល បានខាង ធ្វើឲ្យច្បាស់លាស់នូវសោតាបត្តិ ផល ធ្វើឲ្យច្បាស់លាស់នូវសកទាគាមិផល ធ្វើឲ្យ ច្បាស់លាស់នូវនូវអនាគាមិផលធ្វើឲ្យច្បាស់ លាស់នូវអរហត្តផល។

**៨. កិលេសប្បហាន**, កិរិយាលះបង់កិលេសបាន ខាង កិរិយាលះបង់រាគៈ លះបង់ទោសៈ លះបង់ មោហៈ។

**៩. វិនីវរណតា ចិត្តស្ស**, ចិត្តមាននីវរណធម៌ ប្រាសហើយ បានខាង ការហាមឃាត់ចិត្តចាករាគៈ ហាមឃាត់ចិត្តចាកទោសៈ ហាមឃាត់ចិត្ត ចាកមោហៈ។

**១០. សុញ្ញាគារេ អភិរតិ**, សេចក្តីត្រេកអរក្នុងផ្ទះដ៏ស្ងាត់ បានខាង សេចក្តីត្រេកអរក្នុងផ្ទះស្ងាត់ ដោយបឋមជ្ឈាន សេចក្តីត្រេកអរក្នុងផ្ទះស្ងាត់ ដោយទុតិយជ្ឈាន សេចក្តីត្រេកអរក្នុងផ្ទះស្ងាត់ ដោយតតិយជ្ឈាន សេចក្តីត្រេកអរក្នុងផ្ទះស្ងាត់ ដោយចតុត្ថជ្ឈាន។

សម្រាប់ពុទ្ធបរិស័ទមានធុរៈ២ប្រភេទ៖ អ្នកប្រតិបត្តិគន្ថធុរៈ និង អ្នកវិបស្សនាធុរៈ។

គន្ថធុរៈជាដំណើរដំពាក់ដោយកិច្ច, ដំណើររវល់ជាប្រក្រតីផ្នែកកិច្ចការរៀនសូត្រ ខាងបរិយត្តិ ពោលគឺការហាត់រៀនសូត្រ ទន្ទេញឱ្យចាំចេះស្ទាត់មាត់នូវពុទ្ធដីកាដែលមានចែងក្នុងគម្ពីរពុទ្ធសាសនាមានព្រះត្រៃបិដកជាដើម។ ចំណែក វិបស្សនាធុរៈ គឺជាដំណើរដំពាក់ដោយកិច្ច ឬ រវល់ជាប្រក្រតីផ្នែកកិច្ចខាងវិបស្សនាគឺអប់រំកាយ

ចិត្ត សង្រួមឥន្ទ្រិយឱ្យបានត្រឹមត្រូវល្អ ដោយការពិនិត្យមើលជាប្រចាំនូវសភាពចិត្តរបស់ខ្លួន។ វិបស្សនាធុរៈប្រព្រឹត្តិទៅតាមសតិបដ្ឋានវិបស្សនា គឺមិនមែនតាមពិធីអធិកអធម[liii] ឬតាមពិធីអធិកអធម្ម(ឬ អធិកអធម៌)[liv] នោះឡើយ។

## ២.៣.សតិបដ្ឋានវិបស្សនា

សតិបដ្ឋានវិបស្សនា ជារបៀបហាត់ពិចារណាឲ្យឃើញច្បាស់នូវដំណើរសង្ខារធម៌ តាមការណ៍ពិត ដោយការតាំងស្មារតី(សតិ)នឹកដល់កាយ, វេទនា, ចិត្ត, និង ធម៌ ឲ្យឃើញច្បាស់តាមពិត។ សតិបដ្ឋានវិបស្សនា អាចធ្វើបានគ្រប់ពេលគ្រប់ទីកន្លែងនិងគ្រប់ឥរិយាបទ ប៉ុន្តែសតិ(ស្មារតី) ដែលប្រសើរបំផុត គឺនៅពេលអង្គុយនៅទីនិងពេលដ៏សមគួរ។

**១.សតិនឹកដល់កាយ៖**

ក.សតិក្នុងការដកដង្ហើម (អានាបានសតិ)

ខ.រលឹកដល់ឥរិយាបថដើរ ឈរ អង្គុយ ដេក

គ.នឹកអំពីសេចក្តីយល់ច្បាស់ សម្បជញ្ញៈ

ឃ.នឹកពិចារណាលើ ភាពមិនស្អាតរបស់កាយ (បដិកូលមនសិការៈ)

ង.នឹកពិចារណាលើ មហាភូតរូប៤គឺ៖ បឋវី (ដីអាបោ(ទឹក) តេជោ(ភ្លើង) និងវាយោ(ខ្យល់)។

ច.នឹកដល់ការស្មឹងស្មាតនៅទីស្មសាន (អសុភនិមិត្ត)

**២.សតិនឹកដល់វេទនា៖**

ក.សុខវេទនា ទុក្ខវេទនា ឬឥតសុខឥតទុក្ខវេទនា

ខ.វេទនាជាលោកិយ ឬវេទនាជាផ្លូវចិត្ត

**៣.សតិនឹកដល់ចិត្ត៖**

ក.សរាគំ (មានរាគៈ) ឬវីតរាគំ (គ្មានរាគៈ)

ខ.សទោសំ(មានទោសៈ)ឬវីតទោសំ(គ្មានទោសៈ)

គ.សមោហំ(មានមោហៈ)ឬវីតមោហំ(គ្មានមោហៈ)

ឃ.សង្ខិត្តំ (ចិត្តរួញថយ) ឬវិក្ខិត្តំ (ចិត្តរាយមាយ)

ង.មហគ្គតំ(ចិត្តដ៏ឧត្តម) ឬអមហគ្គតំ(ចិត្តមិនឧត្តម)

ច.សឧត្តរំ(ចិត្តដ៏ទៃខ្ពស់ជាង) ឬអនុត្តរំ(គ្មានចិត្តដ៏ទៃខ្ពស់ជាង)

ឆ.សមាហិតំ(ចិត្តស្ងប់ស្ងៀម) ឬអសមាហិតំ(ចិត្តមិនស្ងប់ស្ងៀម)

ជ.វិមុត្តំ(ចិត្តរួចរំដោះ) អវិមុត្តំ(ចិត្តមិនរួចរំដោះ)

**៤.សតិនឹកដល់ធម្ម(ឬធម៌)៖** ក.នីវរណធម៌ ខ.ឧបាទានក្ខន្ធ គ.អាយតនៈនិងសំយោជនៈ ឃ.កត្តានៃការត្រាស់ដឹងពោជ្ឈង្គ៧ ង.អរិយសច្ច៤

សតិបដ្ឋានវិបស្សនា ជាផ្លូវមួយដើម្បីសេចក្តីបរិសុទ្ធនៃសត្វទាំងឡាយ ដើម្បីឈ្នះលើសេចក្តីស្តាយស្រណោះនិងខ្សឹកខ្សួល ដើម្បីរំលត់បង់នូវសេចក្តីឈឺចាប់និង សេចក្តីសោក ដើម្បីដើរលើផ្លូវពិត ដើម្បីព្រះនិព្វាន ។

## ២.៤.សំយោជនៈ ១០

សំយោជនៈ(ស័ង-យោជៈនៈ)(ន.) (សំយោជន ឬសញ្ញោជន) កិលេសជាគ្រឿងប្រកបចិត្ត គឺកិលេសរឹងត្អឹងជាគ្រឿងទាក់ទ្វាក់រួបរឹត ដែលអាស្រ័យនៅនឹងចិត្ត។ សំយោជនៈ ជាគ្រឿងញាំងចិត្តឲ្យជាប់ដោយកិលេស ជាគ្រឿងចងក្រៀកសត្វឲ្យជាប់ក្នុងវដ្តសង្សារ គឺការវិលកើត

*វិលស្លាប់ឥតឈប់ឈរ។ សំយោជនៈអាចប្រៀបបានទៅនឹងខ្សែច្រវាក់ដែលចងភ្ជាប់កដៃ កជើងមិនឲ្យរួចខ្លួនទៅកាន់ព្រះនិព្វានបាន។ លុះត្រាតែបុគ្គលអ្នកប្រតិបត្តិធម៌ផ្តាច់សំយោជនៈឲ្យអស់រលីង នោះទើបអាចសម្រេចអរហត្តផលដែលជាទីបំផុតនៃសេចក្តីទុក្ខ ពោលគឺនិព្វាន។ សំយោជនៈ១០ប្រការៈ សំយោជនៈជាន់ទាប៥ និងជាន់ខ្ពស់៥។*

**២.៤.១.ឱរម្ភាគិយសញ្ញោជនៈ** *សំយោជនៈជាន់ទាបមាន៥គឺៈ ១-សក្កាយទិដ្ឋិ* [lv] *គឺការឃើញខន្ធ៥ថាជារបស់ខ្លួន ២-វិចិកិច្ឆា*[lvi] *គឺសេចក្តីសង្ស័យស្ទាក់ស្ទើរ ៣-សីលពត្តបរាមាស*[lvii] *គឺការជាប់ជំពាក់ចិត្តទៅក្នុងកិច្ចខាងសាសនា ការបួងសួងអបិ្បយជំនឿផ្សេងៗ ៤-កាមរាគៈ គឺសេចក្តីតម្រេកក្នុងកាម ៥.បដិឃៈ គឺសេចក្តីប្រាថ្នាការអាក្រក់ ថ្នាំងថ្នាក់ ទើសទាស់ក្នុងចិត្ត។*

**២.៤.២.ឧទ្ធម្ភាគិយសញ្ញោជនៈ** *សំយោជនៈជាន់ខ្ពស់មាន៥គឺៈ ៦-រូបរាគៈ គឺតម្រេកក្នុងរូបភព, ៧- អរូបរាគៈ គឺតម្រេកក្នុងអរូបភព, ៨-មានៈ គឺសេចក្តីប្រកាន់មាំ ៩- ឧទ្ធច្ចៈ គឺចិត្តរសាប់រសល់ ១០- អវិជ្ជា គឺសេចក្តីល្ងង់ ឬសេចក្តីមិនដឹង ។*

*មាគ៌ានាំទៅដល់ការអស់ទៅនៃសំយោជនៈជាន់ទាបទាំង៥ដំបូងគឺធ្វើឡើងតាមរយៈការប្រតិបត្តិឲ្យបានសម្រេចឈាននិងវិបស្សនា ដែលត្រូវតែធ្វើទាំង២ ជាមួយគ្នាដោយអាក់ខានមិនបាន។ ព្រះពុទ្ធបានសំដែងទុកថាៈ "ការលះកាត់ចោលនូវសំយោជនៈទាំងឡាយ នៅពេលដែលបុគ្គលម្នាក់ដឹងនិងមើលឃើញភាពប្រែប្រួលនៃអាយតនៈទាំង១២(អនិច្ចំអាយតនៈ១២) ពាក់ព័ន្ធនឹងវិញ្ញាណទាំង៦ នៃផស្សៈ និង វេទនា ។*[4] *ក្នុងន័យស្រដៀងនេះដែរ ព្រះពុទ្ធបានសំដែងទុកថាៈ "ការដកររំលើងសំយោជនៈ នៅពេលខ្លួនគេដឹងនិងមើលឃើញថា អនត្តានៃឥន្ទ្រិយទាំង៦ ឥន្ទ្រិយារម្មណ៍, ផស្សៈ និង អារម្មណ៍រំភើប។*

## ៣.ព្រះសង្ឃ

*ពុទ្ធបរស័ទ មានភិក្ខុ ភិក្ខុនី សាមណេឧបាសក ឧបាសិកា គឺចាត់ជាពុទ្ធសាវ័កដ៏សំខាន់សម្រាប់ពុទ្ធសាសនា។ ភិក្ខុ ឬព្រះសង្ឃ ឬព្រះភិក្ខុសង្ឃ គឺពួកក្រុមដែលប្រព្រឹត្តបតិបត្តិតាមគន្លងព្រះធម៌នៃព្រះសម្មាសម្ពុទ្ធ។ ព្រះសង្ឃ ជាពុទ្ធសាវ័ក ជាអ្នកប្រតិបត្តិល្អ ប្រតិបត្តិត្រង់តាមផ្លូវមជ្ឈិមាបដិបទា(អដ្ឋង្គិកមគ្គ) ដើម្បីចេញចាកទុក្ខ និងប្រតិបត្តិដ៏សមគួរដល់សាមីចិកម្ម*[lviii]*។ ព្រះសង្ឃមានពីរពួកគឺ អរិយសង្ឃ និង សម្មតិសង្ឃ។ អរិយសង្ឃឬអរិយបុគ្គល គឺសង្ឃជាព្រះអរិយៈទាំងឡាយបានដល់ សោតាបន្នបុគ្គល១ សកទាគាមិបុគ្គល១ អនាគាមិបុគ្គល១ អរហន្តាខីណាស្រព១។ ព្រះអរិយសង្ឃទាំង៤ពួកនេះលោកចាត់ទុកថាជាសង្ឃរតនៈដ៏ប្រសើរសម្រាប់*

[4] *សូមមើលគម្ពីរសំយុត្តនិកាយ*

សត្វលោក។ ចំណែក សម្មតិសង្ឃ គឺសង្ឃជាបុថុជ្ជននៅឡើយ មិនទាន់បានសម្រេចមគ្គផលអ្វីឡើយ គឺបួសជាសង្ឃដើម្បីរៀនសូត្រ ឬគ្រាន់តែគម្រប់កិច្ចតាមការសន្មតប៉ុណ្ណោះ ព្រោះបុគ្គលទាំងនេះនៅមានសំយោជនៈកិលេសដូចគ្រហស្ថជា ឧបាសក ឧបាសិកា និងបុថុជ្ជនទូទៅដែរ។

### ៣.១. អរិយសង្ឃ ឬ អរិយបុគ្គល[5]

ចំពោះគ្រហស្ថជាបុថុជ្ជនពិបាកលះបង់ដាច់នូវសំយោជនៈបានឡើយព្រោះចិត្តជាប់ស្អិតអារម្មណ៍លោកិយ ពោរពេញដោយលោកធម៌ទាំង៨គឺ៖ មានលាភអត់លាភ មានយសអត់យស សរសើរនិន្ទា សុខនិងទុក្ខ។ ប្រសិនបុគ្គលណាលះបង់ចោលបាន នោះនឹងក្លាយជាអរិយបុគ្គល មិនថាបុគ្គលនោះជាអ្នកបួសជាភិក្ខុសង្ឃ ឬជាឧបាសក ឧបាសិកា គ្រហស្ថធម្មតាឡើយ។ អរិយបុគ្គល មិនសម្គាល់លើទម្រង់នៃការស្លៀកពាក់ឬ ទម្រង់ណាមួយឡើយ។ អរិយបុគ្គល ឬ អរិយសង្ឃ គឺជាមនុស្សដែលបានលះចោលសំយោជនៈ។ ព្រះពុទ្ធសាសនា ចែកអរិយបុគ្គលមាន៤ ពួកគឺ៖

**៣.១.១.សោតាបន្នបុគ្គល** ជាអ្នកលះបង់ដាច់ស្រឡះសំយោជនៈ៣គឺ៖

1.សក្កាយទិដ្ឋិ, ប្រកាន់ខន្ធ៥ថាជារបស់ខ្លួន
2. វិចិកិច្ឆា, សេចក្ដីសង្ស័យលើព្រះធម៌
3.សីលព្វតបរាមាសអប្បិយជំនឿខុសពីការពិត

តាមពុទ្ធសាសនាសោតាបន្នបុគ្គល មានកម្មគឺកើតក្នុងឋានមនុស្សលោក ឬទេវលោក យ៉ាងច្រើន៧ជាតិទៀតប៉ុណ្ណោះ។

**៣.១.២.សកទាគាមិបុគ្គល** ជាលះសំយោជនៈ៥ (គឺ៣ខាងដើម និងថែម២ទៀត) គឺ៖

4.កាមរាគ, ត្រេកត្រអាលក្នុងកាមទាំងឡាយ
5.បដិឃៈ, ចង្អៀតទើសចិត្តដោយក្តីក្រោធខឹង

ប៉ុន្តែ នៅសល់ រាគៈ ទោសៈ មោហៈ ស្តួចស្តើងបំផុតដែលលះមិនទាន់អស់។ សកទាគាមិបុគ្គលមានកម្មគឺកើតក្នុងឋានមនុស្សលោក យ៉ាងច្រើន១ជាតិទៀតប៉ុណ្ណោះ។

**៣.១.៣.អនាគាមិបុគ្គល** ជាអ្នកដែលលះបង់សំយោជនៈដាន់ទាបទាំង៥ខាងលើ បានដាច់ស្រឡះ គ្មាននៅសេសសល់ រាគៈ ទោសៈ មោហៈ អ្វីឡើយ។ អនាគាមិបុគ្គ នៅសល់ ១ជាតិកំណើតក្នុង សុទ្ធាវាសព្រហ្មប៉ុណ្ណោះ។

**៣.១.៤.អរហត្តបុគ្គល**

អរហត្តបុគ្គល(អៈរ៉ៈហ័ត បុក-គល់) ឬព្រះអរហន្តាខីណាស្រព ជាអ្នកសម្រេចលោកុត្តរធម៌ថ្នាក់ខ្ពស់បំផុត, គឺជាអ្នកបានលះបង់សំយោជនៈទាំង១០ ដាច់ស្រឡះគ្មានសេសសល់(គឺ៥ខាងដើម និងថែម៥ទៀត) គឺ៖

6. រូបរាគៈ, ជាប់ជំពាក់នឹងរូប

[5] សុត្តន្តបិដក ខុទ្ទកនិកាយ បដិសម្ភិទាមគ្គ ទិដ្ឋិកថា សក្កាយទិដ្ឋិនិទ្ទេស បិដកលេខ ៧០ ទំព័រ ៤៨-៤៩

7. អរូបរាគៈ, ជាប់ជំពាក់នឹងអរូប
8. មានៈ, សេចក្តីប្រកាន់ និង រឹងត្អឹង
9. ឧទ្ធច្ចៈ, សេចក្តីរាយមាយ
10. អវិជ្ជា, ភាពងងឹតល្ងង់ មិនយល់ការពិត

## ៣.២. ឧបាសក ឧបាសិកា

*ឧបាសក ឧបាសិកា ជាពុទ្ធបរិស័ទ[6]ទាំងឡាយណាដែលស្មគ្រចិត្តសមាទាន នូវសិក្ខាបទ [7]គឺចេតនាជាហេតុវៀរចាកកិរិយាធ្វើនូវអំពើបាបសៅហ្មងទាំងឡាយ តាមឧបនិស្ស័យរៀងខ្លួន។*

## ៣.២.១. ឧបាសក ឧបាសិកាកាន់សីល៥

*គឺពុទ្ធបរិស័ទជាគ្រហស្ថ បុថុជ្ជនដែលស្មគ្រចិត្តសិក្សារក្សានូវនិច្ចសីល ឬសីល៥(បញ្ចសីល) បានដល់អង្គនៃសិក្ខាបទប្រាំ គឺវៀរចាកៈ ១.បាណាតិបាត[lix]ការសម្លាប់សត្វ។២.អទិន្នាទាន[lx] ការកាន់យករបស់ដែលគេមិនបានឲ្យដោយកាយ ឬវាចា ពោលគឺការលួចទ្រព្យគេ។ ៣.កាមេសុមិច្ឆាចារ[lxi] ការប្រព្រឹត្តខុសក្នុងកាមគុណទាំងឡាយ ។៤.មុសាវាទ[lxii] ការពោលពាក្យមិនពិត គឺពោលពាក្យកុហក។ ៥.សុរាមេរយ ការសេពនូវទឹកស្រវឹងគឺសុរា និងមេរ័យ។ [lxiii]*

*អ្នកប្រព្រឹត្តិល្មើសកន្លងសិក្ខាបទទាំង៥នេះ នឹងធ្លាក់ទៅអបាយភូមិណាមួយជាមិនខាន។ អបាយភូមិ គឺជាទីឬស្ថានដែលមិនមានសេចក្តីចម្រើន មាន៤យ៉ាងគឺៈ នរកឬនិរយភូមិ១[lxiv] បេត្តវិស័យ១[lxv] អសុរកាយ១[lxvi] តិរច្ឆាន១[lxvii] ។*

## ៣.២.២. ឧបាសក ឧបាសិកាកាន់សីល៨

*ឧបាសក ឧបាសិកាខ្លះទៀត ជាពុទ្ធបរិស័ទកាន់សីល៨ ជារៀងរាល់ថ្ងៃ ឬរៀងរាល់ថ្ងៃសីល។ អ្នកកាន់សីល៨ ត្រូវថែមសិក្ខាបទ៣ទៀតទៅលើសិក្ខាបទ៥ខាងដើម។សិក្ខាបទទាំង៣នោះគឺៈ ៦.វិកាលភោជនា កិរិយាបរិភោគនូវភោជនាហារក្នុងកាលខុស។ ៧.នច្ចគីតវាទិតវិសូកទស្សនា កិរិយារាំច្រៀងប្រគំនិងការមើលល្បែងផ្សេងៗ ដែលជាសត្រូវដល់កុសលធម៌។ ៨.មាលាគន្ធវិលេបនធារណមណ្ឌនវិភូសនដ្ឋានា ការទ្រទ្រង់ ការប្រដាប់ និងការតាក់តែងស្អិតស្អាងរាងកាយដោយផ្កាកម្រង គ្រឿងក្រអូប និងគ្រឿងលាបផ្សេងៗ ។*

**៣.២.៣. ឧបាសក ឧបាសិកាកាន់សីល១០** *គឺគ្រហស្ថដែលភាគច្រើនជាមនុស្សវ័យចាស់ដែលគេច្រើនហៅថាដូនជី តាជី ។ ដូនជី តាជី អ្នកកាន់សីល១០ត្រូវថែមសិក្ខាបទ២ទៀតទៅលើសិក្ខាបទ៨ខាងលើ គឺៈ ៩. ឧច្ចាសយនមហាសយនា ការស្នាក់នៅសេនាសនៈដ៏ខ្ពស់ហួសប្រមាណ និងសេនាសនៈដ៏ប្រសើរ ។ ១០.ជាតរូបរជតប្បដិគ្គហណា ការកាន់យកនូវមាសនិងប្រាក់ដោយ*

[6] *សុត្តន្តបិដក មជ្ឈិមនិកាយ មូលបណ្ណាសក ភាគ២០ ទំព័រ ៣២១ និង៣២២។*

[7] *បិដក លេខ៨២ អភិធម្មភាជនីយ ទំព័រ ១ ដល់១៦*

ខ្លួនឯង ឬប្រើអ្នកដទៃឲ្យទទួលកាន់យក ហើយត្រេកអរចំពោះមាសនិងប្រាក់នោះ ។

**៣.២.៤.សាមណេរ**

សាមណេរ ឬលោកនេន ជាកូនចៅឬផៅពង្សភេទប្រុសនៃសមណៈ ដែលបានលាចាកផ្ទះសម្បែង ទៅបួសជាបព្វជិតរស់នៅក្នុងវត្តអារាម គឺជាពុទ្ធសាសនិកអ្នកកាន់សីល ១០ដូចដូនជីតាជីដែរ ។

**៣.២.៥. ភិក្ខុ**

ព្រះសម្មាសម្ពុទ្ធ ហៅថាភិក្ខុទាំងឡាយដែលបួសក្នុងសាសនាព្រះអង្គថាជាអរិយសាវ័ក[8]ដោយត្រូវប្រកាន់យកវិន័យ២២០សិក្ខាបទ។ អរិយសាវ័ក ឬសង្ឃសាវ័ក គឺជាសាវ័កកម្រិតខ្ពស់ជាឧបាសកឧបាសិកា។ អរិយសាវ័ក មិនលុះអគតិទាំង៤និងមិនៈ ១.សេពនូវការផឹកទឹកស្រវឹង គឺសុរា និងមេរ័យ ២.ការត្រាច់ទៅតាមច្រកល្ហកខុសកាល ៣.ការដើរមើលមហោស្រព ៤.លេងល្បែងភ្នាល់ ៥.ការសេពគប់បាបមិត្ត៦. សេចក្ដីខ្ជិល។ ភិក្ខុសង្ឃ គឺជាអ្នកបួសរស់ក្នុងវត្តអារាម មានភេទឧត្ដមជាងសាមណេរ, ជាអ្នកសូមរស់ដោយបិណ្ឌបាត,ជាសមណដែលសង្វេគក្នុងវដ្ដសង្សារ, អ្នកខ្លាចបាបជានិច្ច ជាអ្នកព្យាយាមដុតបំផ្លាញកិលេសដែលជាអំពើអាក្រក់។ ភិក្ខុសង្ឃ គឺជាអ្នកស្មគ្រចិត្តកាន់វិន័យដែលមានចំនួន ២២០សិក្ខាបទ[9] ក្នុងការរស់នៅប្រចាំថ្ងៃនិងថ្ងៃឧបោសថ ក្នុងនោះក៏មានរួមបញ្ចូលសិក្ខាបទ១០ដូចដូនជីតាជីដែរ។ សិក្ខាបទរបស់ភិក្ខុមាន២២០ គឺៈ បារាជិក៤ សង្ឃាទិសេស១៣ អនិយត២ និស្សគ្គិយៈ៣០ ខុទ្ទកៈ(បាចិត្តិយៈ) ៩២ បាដិទេសនីយៈ៤ សេក្ខិយៈ៧៥។ ទីនេះ សូមលើកយកតែអាបត្តិសំខាន់គឺ បរាជិក៤ សង្ឃាទិសេស១៣ និងអនិយត២ មកបង្ហាញប៉ុណ្ណោះ។

**ក.បរាជិក៤** គឺការប្រព្រឹត្តិកំហុសធ្ងន់៤យ៉ាងដែលមិនអាចកែបាន គឺកំហុសមិនអាចអត់ឱនបាន ដែលនាំឲ្យសង្ឃអស់ខ្ទឹមសារជាភិក្ខុ ត្រូវបរាជ័យគឺត្រូវបង្ខំឲ្យសឹកលាចាកសិក្ខាបទជាភេទសង្ឃមកគ្រហស្ថវិញ។ បរាជិក៤ គឺៈ

១.**មេថុនធម្ម** ភិក្ខុសេពមេថុនធម្ម។

២.**អទិន្នាទាន** ភិក្ខុយកទ្រព្យដែលគេមិនបានប្រគេន គឺលួចទ្រព្យគេ ។

៣.**មនុស្សវិគ្គហ** ភិក្ខុក្លែងសម្លាប់មនុស្ស។

៤.**ឧត្តរិមនុស្សធម្ម** ភិក្ខុពោលអួតពីឧត្តរិមនុស្សធម្ម គឺធម៌របស់មនុស្សក្រៃលែងដែលមិនមានក្នុងខ្លួន។

**ខ.សង្ឃាទិសេស ១៣** គឺកងអាបត្តិឬកំហុស១៣ដែលមានកម្រិតទាបជាងអាបត្តិបារាជិក។ ក្រុមភិក្ខុសង្ឃនឹងប្រជុំគ្នាដើម្បីវាយតម្លៃពីភាពធ្ងន់

[8] សូមមើល បិដក ភាគ ១៩ - ទំព័រទី ៧១

[9] សូមមើល បិដក ភាគ ១៣ - ទំព័រទី ១២៩

ស្រាលនៃបទល្មើសដែលភិក្ខុបានធ្វើទាស់នឹងវិន័យទាំង២២០ សិក្ខាបទដើម្បីឲ្យភិក្ខុនោះទទួលកំហុស និង កែប្រែ ទើបសង្ឃអាចទទួលឲ្យចូលក្នុងគណៈវិញ ។ សង្ឃាទិសេស ១៣ គឺ៖

**១.សុក្កចិសដ្ឋិ** ក្លែងញុំាងទឹកសុក្កៈឲ្យកម្រើកឃ្លាតចាកទី។ **២.កាយសំសគ្គ** មានតម្រេកចាប់ពាល់កាយស្ត្រី។ **៣.ទុដ្ឋុល្លវាចា** មានតម្រេក និយាយពាក្យអាក្រក់ចំពោះនិមិត្តស្ត្រី។ **៤.អត្តកាមបារិចរិយា** មានតម្រេក និយាយល្បួងស្ត្រីឲ្យបម្រើខ្លួនដោយកាម។ **៥.សញ្ចរិត្ត** និយាយដឹកនាំឲ្យបុរស និង ស្ត្រីបានគ្នាជាប្ដីប្រពន្ធ។ **៦.សញ្ញាចិកា** ភិក្ខុធ្វើកុដិបូកដោយកំបោរឬដីស្អិតដែលមិនមានអ្នកណាជាម្ចាស់របស់សម្រាប់ជាទីនៅរបស់ខ្លួន។ ត្រូវធ្វើឲ្យត្រូវនឹងប្រមាណគឺបណ្ដោយ១២ ចំអាមទទឹង៧ចំអាម ដោយចំអាមព្រះសុគត។ កាលដែលនឹងធ្វើនោះ ត្រូវឲ្យសង្ឃសំដែងទីឲ្យជាមុនសិន បើមិនបានឲ្យសង្ឃសំដែងឲ្យក្ដីធ្វើឲ្យកន្លងហួសប្រមាណក្ដី។សិក្ខាបទនេះហៅថាកុដិការក៏បាន។

**៧.មហល្លក** បើកុដិដែលធ្វើនោះ មានទាយកជាម្ចាស់របស់ ធ្វើឲ្យកន្លងហួសប្រមាណនោះបាន ប៉ុន្តែត្រូវឲ្យសង្ឃសំដែងទីឲ្យជាមុនហើយមិនបានឲ្យសង្ឃសំដែងទីឲ្យ។ **៨.អមូលក** ភិក្ខុក្រោធខឹងនឹងភិក្ខុឯទៀត ហើយក្លែងចោទគេដោយអាបត្តិបារាជិកមិនមានមូល។ **៩.អញ្ញភាគិយ** ភិក្ខុក្រោធខឹងភិក្ខុឯទៀត ហើយក្លែងរកលេសមកចោទគេដោយអាបត្តិបារាជិក។ **១០.សង្ឃភេទ** ភិក្ខុព្យាយាមបំបែកសង្ឃឲ្យបែកគ្នា ភិក្ខុដទៃហាមប្រាមមិនស្ដាប់។ សង្ឃបានសូត្រសមនុភាសនកម្មដើម្បីឲ្យលះបង់តែមិនលះបង់។ **១១.ភេនាវត្ដក** ភិក្ខុប្រព្រឹត្តតាមភិក្ខុដែលបំបែកសង្ឃនោះ ភិក្ខុដទៃហាមប្រាមមិនស្ដាប់។ សង្ឃបានសូត្រសមនុភាសនកម្មដើម្បីឲ្យលះបង់ តែមិនលះបង់។ **១២.ទុព្វចជាតិក** ភិក្ខុមានជាតិជាអ្នកប្រដៅក្រភិក្ខុឯទៀតឃាត់មិនស្ដាប់។ សង្ឃបានសូត្រសមនុភាសនកម្មដើម្បីឲ្យលះបង់ ហើយមិនលះបង់។ **១៣.កិលទូសក** ភិក្ខុទ្រុស្តត្រកូល គឺភិក្ខុដែលប្រចុបប្រចែងគ្រហស្ថ។ សង្ឃបានបណ្ដេញចេញពីវត្ត ហើយត្រឡប់ជាតិះដៀលសង្ឃវិញ សង្ឃបានសូត្រសមនុភាសនកម្មដើម្បីឲ្យលះបង់ ហើយមិនលះបង់ ។

**គ.អនិយត២**

**១.អលំកម្មនិយ** ភិក្ខុអង្គុយក្នុងទីកំបាំងភ្នែកតែពីរនាក់ និងស្ត្រី បើមានមនុស្សដែលគួរជឿ បានពោលពាក្យចោទដោយអាបត្តិបីយ៉ាងគឺ បារាជិក សង្ឃាទិសេស ឬ បាចិត្តិយ អាបត្តិណាមួយ បើភិក្ខុទទួលប្ដេជ្ញាដោយអាបត្តិណា ឬគេចោទចំពោះអាបត្តិណា អោយវិន័យធម៌ កាត់ទោសចំពោះ អាបត្តិនោះ។

**២.នាលំកម្មនិយ** ភិក្ខុអង្គុយក្នុងទីកំបាំងត្រចៀកតែពីរនាក់នឹងស្ត្រីបើមានមនុស្សដែលគួរជឿបានពោលដោយអាបត្តិពីរយ៉ាង គឺសង្ឃាទិសេស ឬ បាចិត្តិយ អាបត្តិណាមួយ បើភិក្ខុទទួលប្ដេជ្ញា

ដោយអាបត្តិណា ឬគេចោទចំពោះអបត្តិណា អោយវិន័យធម៌កាត់ទោស ចំពោះអាបត្តិនោះ។

### ៣.២.៦. ភិក្ខុនី [10]

ភិក្ខុនីសង្ឃ គឺជាស្នមភេទស្រី ដែលបានបោះបង់ជីវភាពជាគ្រហស្ថ រស់នៅដោយបិណ្ឌបាតចង្ហាន់ រស់នៅក្នុងអាស្រម ឬកុដិ ក្នុងភាពក្រីក្រនិងជាអ្នករក្សាព្រហ្មចរិយាធម៌ ជាអចិន្ត្រៃយ៍។ វិន័យសម្រាប់ភិក្ខុនីសង្ឃ ត្រូវគោរព និង ប្រតិបត្តិសរុបទាំងអស់មាន ៣១១ សិក្ខាបទ។

ស្ត្រីដំបូងគេ ដែលបានបួសជាភិក្ខុនី នៅពុទ្ធកាល គឺព្រះមហាជាបតីគោតមី ជាម្តាយមីង (ព្រះមាតុច្ឆា) ជាព្រះមាតាចិញ្ចឹមរបស់ព្រះពុទ្ធ បន្ទាប់មកមានស្ត្រីជាច្រើនទៀតចូលមកបួស ជាបន្តបន្ទាប់។ ដោយវិន័យសិក្ខាបទ និងបញ្ញាប្រឈមខ្លាំងក្លាពេក សម័យក្រោយមក ភិក្ខុនីមិនមានវត្តមានទៀតឡើយ។

## សេចក្តីសន្និដ្ឋាន

ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ គឺ ជាមូលដ្ឋានគ្រឹះនៃពុទ្ធសាសនា។ ព្រះពុទ្ធ និងព្រះសង្ឃ គឺជាមនុស្សពិតៗដែលបានប្រតិបត្តិនូវព្រះធម៌ ហើយបានសម្រេចនូវគុណប្រយោជន៍ គឺសេចក្តីសុខ-ចម្រើនដែលបានពីការប្រព្រឹត្តតាមព្រះធម៌នេះ។ ពុទ្ធសាសនាដើរតួសំខាន់ក្នុងជីវភាពសង្គមនិងនយោបាយក្នុងការរស់នៅប្រចាំថ្ងៃសម្រាប់ពុទ្ធសាសនិកជន។ ចំណែកមនុស្សទូទៅដែលកាន់សាសនាផ្សេងក៏ អាចនឹងសម្រេចនូវអានិសង្សបានដែរ ប្រសិនបើអនុវត្តបានត្រឹមត្រូវតាមព្រះធម៌គឺចតុរារិយសច្ច។

ការសិក្សារៀនសូត្រ ព្រះធម៌ និងការចម្រើនសតិបដ្ឋានវិបស្សនាតាមមាគ៌ាដ៏ត្រឹមត្រូវរបស់ព្រះសម្មាសម្ពុទ្ធ ត្រូវពឹងលើគម្ពីរពុទ្ធសាសនា ជាពិសេសគម្ពីរព្រះត្រៃបិដក និងពឹងលើព្រះភិក្ខុសង្ឃឬអ្នកមានចំណេះដឹងត្រឹមត្រូវខាងពុទ្ធសាសនា និងខិតប្រឹងប្រែងប្រតិបត្តិដោយខ្លួនឯងផ្ទាល់។ គេមិនត្រូវយកពុទ្ធសាសនាធ្វើជាល្បែងជំនឿដើម្បីបន់ស្រន់ដោយងងឹតងងុលឬយកពុទ្ធសាសនាធ្វើជាមុខរបរជំនួញដើម្បីបោកប្រាស់កោសកៀររកប្រយោជន៍ពីមនុស្សដូចគ្នាឡើយ ផ្ទុយទៅវិញគួរលើកទឹកចិត្តដល់អ្នកមានសទ្ធាក្នុងពុទ្ធសាសនាឱ្យចម្រើននូវបញ្ញាតាមគន្ធធុរៈឬវិបស្សនាធុរៈទៅតាមឧបនិស្ស័យរៀងខ្លួន។

[10] សូមមើល គម្ពីរ ភិក្ខុនីវិភង្គ

**ឯកសារយោង/គន្ថនិទ្ទេស**


១-ជួន ណាត : *វចនានុក្រមខ្មែរ*, ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ បោះពុម្ពលើកទី៥ ឆ្នាំ១៩៦៧

២-ស្រុង ចាន់ណា, *គេហទំព័រ៥០០០ឆ្នាំ* (https://5000-years.org/kh/)

៣- https://km.wikipedia.org/wiki/ព្រះពុទ្ធសាសនា

៤-យ័ញ មិញ គៀង (ភិក្ខុ គុណឃោសោ, វត្តស្វាយ ខេត្តគៀងយ៉ាង, វៀតណាម) (http://m.ti-kh.org/)

៥-ព្រះត្រៃបិដក ឈូកក្រហម (https://chhouk-krohom.com/)

៦-បណ្ឌិត ធម្មណាត, (ទីប្រឹក្សា គណៈកម្មការ ពុទ្ធិកសមាគមខ្មែរ វត្តខេមរតនារាម), (https://watkhmers.org/)


---

[i] ពាក្យថា រតនត្រ័យ មកពីពាក្យ រតនៈ+ត្រ័យ។ រតនៈ (រៈតៈន័ៈ) រត្ន; រតន "វត្ថុឬរបស់ដែលញុំាងចិត្តឲ្យរីករាយ; ..." ត្បូង , កែវ; + ត្រ័យ (ត្រៃ, ៣)។ ពាក្យ រតនត្រ័យ ក្នុងពុទ្ធសាសនាត្រូវបានកំណត់ន័យយ៉ាងច្បាស់គឺសំដៅដោយត្រង់ចំពោះអង្គជាទីពឹង ទីរឭកទាំង៣គឺៈ ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ។ ចំណែកកែវមួយដោយឡែកៗ ហៅថា ពុទ្ធរតនៈ, ធម្មរតនៈ, សង្ឃរតនៈ, ឬថា ព្រះពុទ្ធរ័ត្ន, ព្រះធម៌រ័ត្ន, ព្រះសង្ឃរ័ត្ន ។ គេអាច ជំនួសពាក្យ រតនត្រ័យ ដោយពាក្យ ថា សរណត្រ័យ ដែលមានន័យថា ប្រជុំបីនៃសរណៈ គឺព្រះពុទ្ធ, ព្រះធម៌, ព្រះសង្ឃ បាន ប៉ុន្តែវាអាចប្រទាំនឹងតួអង្គជាទីពឹងនៃលទ្ធិព្រាហ្មណ៍។ តាមលទ្ធិព្រាហ្មណ៍ថា ប្រជុំបីនៃសរណៈ គឺព្រះព្រហ្ម, ព្រះសិវៈ, ព្រះវិស្ណុ។

[ii] ចតុរារិយសច្ច (ន.) អរិយសច្ច៤យ៉ាង ដែលជាការពិតពិតប្រាកដ ៤យ៉ាងដែលមានជម្រៅហួសពីសម្មតិសច្ចដែលសន្មតដោយបុគ្គល, គឺជាសច្ចសត្យានុម័តឬសច្ចបរានុម័ត៤យ៉ាងដែលជ្រៅជាងសច្ចអត្តនោម័ត។ ចតុរារិយសច្ចគឺៈ ១.សេចក្តីលំបាកពិតប្រាកដ (ទុក្ខអរិយសច្ចៈ) ២.ហេតុនៃសេចក្តីលំបាកពិតប្រាកដ (ទុក្ខសមុទិយអរិយសច្ចៈ) ៣.សេចក្តីសុខស្ងប់ពិតប្រាកដ(និរោធអរិយសច្ចៈ) ៤.របៀបត្រឹមត្រូវពិតបាកដដើម្បីវត្តប្រតិបត្តិទៅដល់សេចក្តីសុខស្ងប់(មគ្គអរិយសច្ចៈ)។ ការពិតទាំងនេះ គេមិនអាចយល់បានដោយប្រើចំណេះដឹងទូទៅធម្មតា(ពុទ្ធិសាមញ្ញ)ឡើយ គឺគេត្រូវការចាំបាច់នូវចំណេះដឹងវិទ្យាសាស្រ្ត(ពុទ្ធិវិទ្យាសាស្រ្ត) និងចំណេះដឹងទស្សនវិជ្ជា(ពុទ្ធិទស្សនវិជ្ជា)ដើម្បីយល់ និងបកស្រាយបំភ្លឺ ពន្យល់បង្ហាញ។ ចតុរារិយសច្ច (ទុក្ខ សមុទិយ និរោធ មគ្គ) និង បរមត្ថធម៌ (នាមរូបំ អនិច្ចំ ទុក្ខំ អនត្តា) ជាដើម។ នាមរូបំ អនិច្ចំ ទុក្ខំ អនត្តា គឺអ្វីៗតែងតែប្រែប្រួល ហើយរងការលំបាកដោយសម្ពាធ ហើយមិនមែនជារបស់ខ្លួនឡើយ គឺមានន័យថា បន្ទាប់ពីស្លាប់ ជីវិតមិនរលត់សូន្យឡើយ គឺបន្តភពថ្មី មិនមែនក្នុងន័យថា ព្រលឹងអចិន្ត្រៃយ៍ អមតៈនោះទេ។ បញ្ហាប្រឈមរបស់មនុស្សជាតិ គឺនៅក្នុងពេលបច្ចុប្បន្ន មិនមែននៅក្នុងអតីតកាល ឬអនាគតកាលឡើយ។ សមាទិដ្ឋិ បដិសេធសកាយទិដ្ឋី និងមិនទទួលយកទិដ្ឋិហួសហេតុទាំង២យ៉ាងៈ គឺសស្សតទិដ្ឋិ (Eternalism) និងឧច្ឆេទទិដ្ឋិ (Nihilism) ។ សស្សតទិដ្ឋិជាទ្រឹស្តី ឬជំនឿដែលទាក់ទងទៅនឹងជីវិតអចិន្ត្រៃយ៍ ឬរបស់អចិន្ត្រៃយ៍។ ចំណែកឧច្ឆេទទិដ្ឋិ ថា មនុស្សស្លាប់ទៅសូន្យមិនកើតទៀត ។ ទាំងសកាយទិដ្ឋិនិយម, សស្សតទិដ្ឋិនិយម និងឧច្ឆេទទិដ្ឋិនិយម មិនអាចជួយ មនុស្សឲ្យលះបង់សំយោជនៈកិលេស ដែលចង

*មនុស្សទៅនឹងភព ហើយដែលជាប្រភព នៃទោមនស្សទាំងឡាយដែលកើតឡើយ។ ផ្លូវទៅកាន់ព្រះនិព្វានដែលជាសេចក្ដីស្ងប់ចិត្ត គឺត្រូវមានសម្មាទិដ្ឋិជាមុនសិន។*

[iii] *ធម៌(ធ័រ) ឬ ធម្ម(ធ័ម ឬ ធ័ម-ម:) (ន.)សភាវៈដែលទ្រទ្រង់សត្វលោក,ឬបរិយត្តិ ឬក្រឹត្យក្រមធម្មជាតិ ឬច្បាប់ធម្មជាតិ ។ ពុទ្ធបរិស័ទ ប្រើពាក្យ ធម៌ ឬ ធម្ម សំដៅលើ ឱវាទរបស់ព្រះពុទ្ធ ឬ ពុទ្ធវចនៈដែលត្រូវបានអ្នកប្រាជ្ញខាងពុទ្ធសាសនាចារទុកក្នុងគម្ពីរព្រះត្រៃបិដក មាន៨ម៉ឺន ៤ពាន់ធម្មក្ខន្ធ។*

[iv] *ព្រះខីណាស្រព (ន.) អរិយបុគ្គលដែលអស់អាសវៈ។ ខីណាស្រព (ខីណា-ស្រប់) (ន.) < ខីណៈ "ការអស់" + អាស្រវ; អាសវ " គ្រឿងត្រាំសៅហ្មង " ៖ ការអស់គ្រឿងត្រាំសៅហ្មង ។ អាសវៈ ទីនេះសំដៅ អាសវក្កិលេស គឺកិលេសជាគ្រឿងត្រាំក្នុងសន្តាន ។ កិលេសជាគ្រឿងត្រាំនៅក្នុងសន្តាន មាន៤គឺ ១-កាម ហៅថា កាមាសវៈ; ២-ភព ហៅ ភវាសវៈ; ៣-ទិដ្ឋិ ហៅ ទិដ្ឋាសវៈ; ៤- អវិជ្ជា ហៅ អវិជ្ជាសវៈ ។ ពាក្យ អាសវៈ ក៏អាចមានន័យស្រដៀងនឹងពាក្យ ឱឃ ដែរ ។ ឱឃ (ឱឃៈ) (ន.) អន្លង់; ជំនន់។ កិលេសដែលពន្លង់សត្វ មាន៤គឺ ១- កាម ហៅថា កាមោឃៈ អន្លង់កាម; ២- ភព ហៅថា ភវោឃៈ អន្លង់ភពៈ ៣- ទិដ្ឋិ ហៅថា ទិដ្ឋោឃៈ អន្លង់ទិដ្ឋិ; ៤- អវិជ្ជា ហៅថា អវិជ្ជោឃៈ អន្លង់អវិជ្ជា។ ដូចនេះ ព្រះខីណាស្រព សំដៅ ព្រះអរហន្ត ឬអរិយបុគ្គលដែលអស់គ្រឿងត្រាំសៅហ្មង ឬបុគ្គលដែលមិនលង់ក្នុងកិលេស ឬអ្នកដែលអស់កិលេស មិនលង់ក្នុង កាម, ភព, ទិដ្ឋិ, អវិជ្ជា។*

[v] *ពុទ្ធសាសនា (ន.) ពាក្យបណ្ដាំរបស់ព្រះពុទ្ធ(ពុទ្ធវចនៈ) ឬពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ, ឬលទ្ធិរបស់ព្រះពុទ្ធ។*

[vi] *សាវ័កព្រះពុទ្ធ(ន.)សិស្សស្ដាប់ឱវាទព្រះពុទ្ធ, ឬអ្នកសិក្សារៀនសូត្រ និងធ្វើការប្រតិបត្តិតាមធម៌ព្រះពុទ្ធ។*

[vii] *ពុទ្ធបរិស័ទ (ពុត -បរិស័ត) ន. ពួកជនដែលស្ម័គ្រចិត្តរួមគំនិតតាមពុទ្ធសាសនា។ ពុទ្ធបរិស័ទមាន៤ជំពូក គឺ ១.ភិក្ខុ ២.ភិក្ខុនី ៣.ឧបាសក និង៤.ឧបាសិកា ។ ព្រះបរមសាស្ដាត្រាស់ថា ហេតុដែលនាំឱ្យសាសនាព្រះអង្គរុងរឿងមានប្រាំយ៉ាង និង ហេតុដែលនាំសាសនាវិនាសសាបសូន្យក៏មានប្រាំដូចគ្នា ។ ហេតុដែលនាំឱ្យសាសនារុងរឿងគឺបរិស័ទទាំង៤៖ ១- ស្ដាប់ធម៌ដោយគោរព ២- រៀនធម៌ដោយគោរព ៣- ទ្រទ្រង់ធម៌ដោយគោរព ។ ៤-ពិចារណានូវសេចក្ដីនៃធម៌ដែលទ្រទ្រង់ខ្លួនឱ្យយល់ច្បាស់។ ៥-ដឹងសេចក្ដីអធិប្បាយនៃធម៌ហើយប្រតិបត្តិតាមដោយគោរព។ ចំណែកហេតុសាសនារលាយសាបសូន្យក៏ដោយសារបរិស័ទទាំង៤ពួក៖ ១- មិនស្ដាប់ធម៌ដោយគោរព ។ ២-មិនរៀនធម៌ដោយគោរព ។ ៣-មិនទ្រទ្រង់ធម៌ដោយគោរព។ ៤-មិនពិចារណានូវសេចក្ដីនៃធម៌ដែលខ្លួនទ្រទ្រង់ហើយគឺមិនដឹងសេចក្ដីអធិប្បាយនៃធម៌នោះដោយមិនយកចិត្តទុកដាក់។ ៥-មិនដឹងសេចក្ដីនៃធម៌ មិនប្រតិបត្តិតាមធម៌ដោយគោរព។ ហេតុទាំងដប់នេះជាកិច្ចដែលបរិស័ទ៤ពួកពិសេសគឺអ្នកបួសរស់អាស្រ័យនឹងព្រះពុទ្ធសាសនាផ្ទាល់ត្រូវកាន់យក ហើយពិចារណាឱ្យបានស៊ីជម្រៅ ហេតុទាំងឡាយណាដែលនាំឱ្យចម្រើនគួរប្រតិបត្តិឱ្យណាស់ ចំណែកឯហេតុទាំងឡាយណាដែលនាំឱ្យវិនាសគួរវៀរឱ្យឆ្ងាយ ទើបសាសនាចម្រុងចម្រើន។ នៅក្នុងសម័យពុទ្ធកាលបរិស័ទ៤ពួកសំដៅលើ ភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា ។ ទោះបីក្រោយព្រះពុទ្ធបរិនិព្វាន ភិក្ខុនីពុំទទួលបានបព្វជ្ជាក៏ដោយ ក៏ពាក្យថា បរិស័ទ៤ពួក ក្នុងពុទ្ធសាសនានៅតែមានប្រើដដែល ព្រោះបានជំនួស ភិក្ខុនីដោយ សាមណេរ វិញ។ ដូចនេះ បរិស័ទ៤ពួក គឺមាន ភិក្ខុ សាមណេរ ឧបាសក ឧបាសិកា ដែលជាគ្រឹះដ៏សំខាន់សម្រាប់ទ្រទ្រង់ព្រះពុទ្ធសាសនាឱ្យស្ថិតស្ថេររុងរឿងតទៅ ឬវិនាសបាន។*

[viii] អដ្ឋកថា  អ័ត-ថ:ក:ថា (ន.) ពាក្យអធិប្បាយសេចក្តីឲ្យងាយយល់។

[ix] ដីកា (ន.) គម្ពីរកែខៃ បញ្ជាក់អត្ថន័យរបស់បាលីបិដកខ្លះ របស់អដ្ឋកថាបាលីខ្លះ របស់ដីកាមុនៗខ្លះ អាងដល់អត្ថន័យរបស់គម្ពីរឯទៀត ។ ឧទា.គម្ពីរសារត្ថទីបនី ជាមូលដីកាឬដីកាដើម ចំណែកគម្ពីរវិមតិវិនោទនី ជាអនុដីកាឬដីកាបន្ទាប់ រីឯ វជិរពុទ្ធិ ជាអន្វានុដីកាឬដីកាបន្ទាប់ពីអនុដីកាមកទៀត នៃវិនយបិដក ។ ឯដីកាដែលកើតមានថ្មីៗ តៗមកទៀតហៅថា នវដីកាឬដីកាថ្មី ។

[x] យោជនា  យោជ:នា  បា. (ន.) ឈ្មោះគម្ពីរបាលីភាសាប្រាប់ដំណើរប្រយោគនិងសម្ពន្ធបាលីជាដើម ។

[xi] ចិត្ត (ន.)  នាម, មនោ, វិញ្ញាណ, ធម្មជាតិសម្រាប់សន្សំអារម្មណ៍, សម្រាប់គិត ។ ចិត្តមាន៣ខណៈ៖ ១.ឧប្បាទ - កើត ២.ឋីតិ - តាំងនៅ ៣.ភង្គ: - រលត់។ ចិត្ត៨៩ដួង ឬ ចិត្ត១២១ដួង  គឺកាមាវចរចិត្ត៥៤ + រូបាវចរចិត្ត១៥ + អរូបាវចរចិត្ត១២ + លោកុត្តរចិត្ត៨ = ៨៩ ។ ចិត្តកើតមានដោយអាស្រ័យប្រកបនឹងចេតសិក និងវិញ្ញាណ៦។ វិញ្ញាណ៦គឺ៖ វិញ្ញាណទាំង៥កើតឡើងអាស្រ័យនឹងអាយតនៈគឺទ្វារវិញ្ញាណ៥ ចំណែក មនោវិញ្ញាណ ជាការដឹងរបស់ចិត្ត កើតនៅមនោទ្វារ អាស្រ័យនឹងហទយៈវត្ថុ ក្នុងបេះដូង។ លើសពីនេះ ចិត្តនៅគ្រប់ទីកន្លែង។ ចិត្តដឹង(វិញ្ញាណ)នៅទីតាំងណា គេហៅឈ្មោះចិត្ត(វិញ្ញាណ)តាមទីតាំងនោះ ឧ.ចក្ខុវិញ្ញាណ គឺចិត្តដឹងដោយភ្នែក ជាដើម។ ជីវិតរបស់សត្វមានជីវិតនិមួយៗ ចាប់ផ្ដើមពីចិត្តនៃការកើត (បដិសន្ធិចិត្ត) បន្ទាប់ពីបដិសន្ធិចិត្តរលត់ទៅ ភវង្គចិត្តតឡើង ហើយបន្តការកើតរលត់ៗតទៅ រហូតដល់ចុតិចិត្ត(មរណៈចិត្ត) កើតឡើងទទួលមុខងារ ជំនួសភវង្គចិត្ត។ ភវង្គចិត្តចុងក្រោយបង្អស់ គឺចុតិចិត្តដែលបំពេញ មុខងារនៃសេចក្ដីស្លាប់ ។ ចំពោះសត្វមានជីវិត ចិត្តទាំង៣នេះ គឺបដិសន្ធិចិត្ត ភវង្គចិត្ត និងចុតិចិត្ត ជាចិត្តតែមួយក្នុងជាតិ (កំណើត) ក្នុងចេតសិកនិងអារម្មណ៍ ដែលវាតោងយក។ ចំពោះមនុស្សជម្មតា ចិត្ត១ក្នុងមហាវិបាកចិត្ត៨ បំពេញមុខងារជា បដិសន្ធិចិត្ត ភវង្គចិត្ត និងចុតិចិត្ត ។ អារម្មណ៍ដែលចិត្ត តោងយក គឺមរណាសន្ននិមិត្ត ដែលកើតឡើងនៅពេល រៀបនឹងស្លាប់ ក្នុងអតីតជាតិ (មុនជាតិនេះ១ជាតិ)។ មរណាសន្ននិមិត្ត ជាអារម្មណ៍របស់កម្ម នៅពេលរៀបស្លាប់។ មុននឹងកម្មដែលជាគ្រឿងឧបត្ថម្ភរលត់ទៅ ក្នុងចំណោមកុសលកម្ម និងអកុសលកម្ម ដែលប្រជែងគ្នា យកឈ្នះឲ្យបានជាកម្មវិបាក(ផល) កម្មណាមួយនឹងបានឈ្នះ។ កម្មដែលឈ្នះនេះ អាចកើតឡើងជាអារម្មណ៍ របស់ភវង្គចិត្ត។ កាលណាហេតុនេះ កើតឡើងមនុស្សនោះអាចតោងយក កម្មល្អឬអាក្រក់ ដែលខ្លួនបានធ្វើពីមុន ដែលជាប់ទាក់ទងនឹង កម្មឈ្នះនោះ។ កុសលចិត្ត ឬអកុសលចិត្ត ដែលគេពិសោធន៍ឃើញក្នុងពេលនោះ ក៏កើតឡើងប្រាកដក្នុងចិត្តជាថ្មី។ ជាញឹកញយ និមិត្តឬនិមិត្តរូបណាមួយ ដែលទាក់ទង នឹងកម្មឈ្នះនោះ កើតឡើង ក្នុងទ្វារវិញ្ញាណណាមួយ។ វាអាចជាអារម្មណ៍មួយ ក្នុងអារម្មណ៍៥ របស់បញ្ចវិញ្ញាណ ទទួលក្នុងទ្វារណាមួយ ក្នុងចំណោមទ្វារវិញ្ញាណ៥ ជាអារម្មណ៍បច្ចុប្បន្ន ឬទទួលក្នុងមនោទ្វារ ជាអារម្មណ៍អតីត។ អារម្មណ៍អតីតឬបច្ចុប្បន្ននេះ ដែលទាក់ទងនឹងកម្មឈ្នះ មានឈ្មោះថា កម្មនិមិត្ត ។

[xii] ចេតសិក (ន.) សភាវៈដែលប្រកបផ្សំនឹងចិត្ត កើតរលត់ព្រមជាមួយនឹងចិត្ត ឬធាតុផ្សំនៃចិត្ត។ ចេតសិកមាន៥២៖ ក-អញ្ញសមានាចេតសិក១៣ (គឺសព្វចិត្តសាធារណចេតសិក៧ និង បកិណ្ណកចេតសិក៦), ខ-អកុសលចេតសិក

១៤ (គឺមោចតុក្កៈ៤, លោភិកៈ៣, ទោចតុក្កៈ៤, ថីទុកៈ២ និង វិចិកិច្ឆា១) និង គ-សោភណចេតសិក២៥(គឺ សោភណសាធារណចេតសិក១៩, វិរតិចេតសិក៣, អប្បមញ្ញាចេតសិក២ និង បញ្ញិន្ទ្រិយចេតសិក១)។

ក-អញ្ញសមានាចេតសិក១៣គឺ បានដល់ សព្វចិត្តសាធារណចេតសិក៧ គឺ ១-ផស្សៈ (ប៉ះខ្ទប់អារម្មណ៍) ២-វេទនា (សោយអារម្មណ៍) ៣-សញ្ញា (សម្គាល់ចំណាំអារម្មណ៍) ៤-ចេតនា (គិតចាត់ចែងអារម្មណ៍) ៥-ឯកគ្គតា(ផ្តងចិត្តក្នុងមានអារម្មណ៍តែមួយ) ៦-ជីវិតិន្ទ្រិយ (ញ៉ាំងសហជាតធម៌អោយរស់នៅ) ៧-មនសិការោ (យកចិត្តធ្វើទុកក្នុងចិត្ត) និង បកិណ្ណកចេតសិក៦ គឺ ៨-វិតក្កៈ(ត្រិះរិះនូវអារម្មណ៍) ៩-វិចារៈ( ពិចារណាអារម្មណ៍) ១០-អធិមោក្ខៈ(ចុះស៊ប់ក្នុងអារម្មណ៍) ១១-វីរិយៈ(ព្យាយាម) ១២-បីតិ(ឆ្អែតក្នុងកាយក្នុងចិត្ត) ១៣-ឆន្ទៈ(បំណងក្នុងអារម្មណ៍)

ខ-អកុសលចេតសិក១៤ បានដល់ មោចតុក្កៈ៤ គឺ ១-មោហៈ( វង្វេងភ្លេចក្នុងអារម្មណ៍) ២-អហិរិកៈ( មិនខ្មាសបាប) ៣-អនោត្តប្បៈ( មិនតក់ស្លុតខ្លាចក្នុងបាប) ៤-ឧទ្ធច្ចៈ( រវើរវាយក្នុងអារម្មណ៍), លោភិកៈ៣គឺ ៥-លោភៈ( លោភជាប់ជំពាក់ក្នុងអារម្មណ៍) ៦-ទិដ្ឋិ (ការយល់ខុស) ៧-មានៈ(ប្រកាន់ រឹងត្អឹង), ទោចតុក្កៈ៤គឺ ៨-ទោសៈ( ប្រទូស្តក្នុងអារម្មណ៍) ៩-ឥស្សា (ច្រណែន) ១០មច្ឆរិយៈ( កំណាញ់)១១-កុក្កុច្ចៈ (ក្តៅក្រហាយស្តាយក្រោយ), ថីទុកៈ២គឺ ១២-ថីនៈ( រួញរាចំពោះកុសល) ១៣-មិទ្ធៈ( ងងុយងោកងក់) និង ១៤-វិចិកិច្ឆា (សង្ស័យក្នុងអារម្មណ៍)។

គ-សោភណចេតសិក ២៥ បានដល់ សោភណសាធារណចេតសិក១៩ គឺៈ ១-សទ្ធា (ជឿកម្មផល) ២-សតិ (រលឹកដឹងទាន់ខុសត្រូវ) ៣-ហិរិ (ខ្មាសចំពោះបាប) ៤-ឱត្តប្បៈ( តក់ស្លុតខ្លាចក្នុងអំពើបាប) ៥-អលោភៈ (មិនជាប់ជំពាក់ក្នុងលោភ) ៦-អទោសៈ( មិនក្រោធប្រទូស្ត) ៧-តត្រមជ្ឈត្តតា (សម្ញឹងអារម្មណ៍កណ្តាល) ៨-កាយបស្សទ្ធិ (ស្ងប់កាយ) ៩-ចិត្តបស្សទ្ធិ (ស្ងប់ចិត្ត) (ចេតសិកពីរនេះបដិបក្ខនឹងឧទ្ធច្ចៈ) ១០-កាយលហុតា (ស្រាលកាយ) ១១-ចិត្តលហុតា (ស្រាលចិត្ត ) ចេតសិកពីរនេះបដិបក្ខនឹង(ថីនំ-មិទ្ធំ) ១២-កាយមុទុតា (កាយទន់ភ្លន់) ១៣-ចិត្តមុទុតា (ចិត្តទន់ភ្លន់) ចេតសិកពីរនេះបដិបក្ខនឹង(ទិដ្ឋិ មានៈ) ១៤-កាយកម្មញ្ញតា (កាយគួរដល់ការងារ) ១៥-ចិត្តកម្មញ្ញតា (ចិត្តគួរដល់ការងារ) ចេតសិកពីរនេះបដិបក្ខនឹង(នីវរណៈ) ១៦-កាយបាគុញ្ញតា (កាយស្ទាត់ជំនាញ) ១៧-ចិត្តបាគុញ្ញតា (ចិត្តស្ទាត់ជំនាញ) ចេតសិកពីរនេះបដិបក្ខនឹង(អសទ្ធា) ១៨-កាយុជុកតា កាយ(ត្រង់ត្រឹមត្រូវ) ១៩-ចិត្តុជុកតា (ចិត្តត្រង់)ចេតសិក ពីរនេះបដិបក្ខនឹង(កិលេសជាគ្រឿងវៀចវេរ ), វិរតិចេតសិក៣ គឺ ២០-សម្មាវាចា (សម្តីត្រូវ) ២១-សម្មាកម្មន្តោ (ការងារត្រូវ) ២២-សម្មាអាជីវោ (ចិញ្ចឹមជីវិតត្រូវ), អប្បមញ្ញាចេតសិក២ គឺ ២៣-ករុណា (សេចក្តី អាណិត) ២៤-មុទិតា (ទន់ភ្លន់ត្រេកអរតាម) និង និង បញ្ញិន្ទ្រិយចេតសិក១ គឺ ២៥-បញ្ញា (ចេតសិកដែលគ្រប់គ្រងលើសហជាតិធម៌ទាំងពួង) ។

xiii បរិនិព្វាន គឺរំលត់ខន្ធ៥លែងកើតស្លាប់ទៀតហើយ។

xiv ពោធិសត្វ (អាន ពោធិស័ត )(ន.)អ្នកដែលមានចិត្តឬមានសេចក្តីប្រាថ្នាជាប់នៅក្នុងពោធិ គឺអ្នកដែលកំពុងខំប្រឹងបំពេញបារមី បម្រុងនឹងបានត្រាស់ជាព្រះសម្មាសម្ពុទ្ធ; បើទុកជាក្លាត់ជាតិទៅកើតជាតិរច្ឆាន ក៏គង់នៅហៅថា ពោធិសត្វ ដែរ ព្រោះមានបំណងជាប់មិនបាត់នឹង ពោធិ ដែលជាការត្រាស់ដឹងលោកុត្តរធម៌ដោយសម្មាសម្ពោធិញ្ញាណ។

[xv] ទស្សនវិជ្ជា (ន.) គឺជាការសិក្សាអំពីទស្សនៈ មតិ យោល់របស់អ្នកប្រាជ្ញ បណ្ឌិតស្ដីអំពីហេតុផល សច្ចភាពសាកល និងផលប្រយោជន៍សម្រាប់មនុស្ស។ ពុទ្ធិទស្សនវិជ្ជាមិនត្រឹមតែផ្អែកលើពុទ្ធិវិទ្យាសាស្ត្រដែលផ្ដោតលើការពិសោធ បែបរូបជាតុនិយមប៉ុណ្ណោះទេ ប៉ុន្តែទស្សនវិជ្ជាផ្នែកខ្លះ បានផ្ដោតលើអស្តិរូប(ឬហៅថាបរមត្ថ) ដែលហួសឆ្ងាយពីពិភពរូបជាតុទៀតផង។ ពុទ្ធិទស្សនវិជ្ជា មានលក្ខណៈជ្រៅជ្រះជាងគេ បើប្រៀបធៀបនឹងពុទ្ធិឥន្ទ្រិយ(ឬហៅថាពុទ្ធិសាមញ្ញ) ដែលមនុស្សទូទៅទទួលបានពីឥន្ទ្រិយារម្មណ៍ និង ពុទ្ធិសាស្ត្រដែលផ្ដោតលើសច្ចភាពរូបជាតុតាមពិសោធជាក់ស្ដែង។

[xvi] សោក ( ន. ) សេចក្ដីឈឺផ្សាចិត្ត; សេចក្ដីសង្រេង; សេចក្ដីស្ដាយស្រណោះឬស្ដាយអាល័យ។ សោយសោក ទទួលរងសេចក្ដីស្ដាយស្រណោះ ។

[xvii] បរិទេវទុក្ខ (ន.) ទុក្ខដោយយំ ខ្សឹកខ្សួល អណ្ដឺតអណ្ដក។

[xviii] ទោមនស្ស (ទោមៈនាស់) (ន.) សេចក្ដីតូចចិត្ត, សេចក្ដីអាក់អន់ចិត្ត, ចិត្តប្រកបដោយទោស មានចិត្តអាក់អន់ , ភាវៈនៃបុគ្គលមានចិត្តប្រទូស្ត ចិត្តអាក្រក់។

[xix] ឧបាយាស ( អ៊ុប៉ាយ៉ាស) (ន.) សេចក្ដីចង្អៀតចិត្ត, សេចក្ដីតឹងចិត្តខ្លាំង, សេចក្ដីតានតឹងចិត្ត ។ឧបាយាសកើតពីជរា-មរណៈដែលជាធម៌បរិត សម្មុទ្ទសាស្តាទ្រង់ពិនិត្យ ឃើញពិតឥតល្បៀងឃ្លៀងឃ្លាតឡើយ ។

[xx] បដិច្ចសមុប្បាទ ប៉ៈដិច-ចៈ- សៈម៉ុប-បាត បា. ( ន. ) ធម៌ឬសភាវៈដែលកើតមានឡើងដោយសារបច្ច័យ គឺគ្រឿងអាស្រ័យទាក់ទងតៗគ្នា ដូចជាសង្ខារកើតមានឡើងព្រោះមានអវិជ្ជាជាបច្ច័យ

[xxi] អវិជ្ជា អៈវិច-ជា (ន.) នៅទីនេះសំដៅ ធាតុដែលមិនដឹងអី បានដល់ធាតុទឹកដីភ្លើងខ្យល់ ពោលគឺមេជីវិតឈ្មោល (កាម៉ែតឈ្មោល, ស្ពែម៉ាតូសូអ៊ីត) និងស៊ុតញី (កាម៉ែតញី, អូវុល)។ ទឹកដីភ្លើងខ្យល់ផ្ដុំជាតុបង្កើតបានជាជីវិតសត្វលោក ។

[xxii] បច្ច័យ (ប៉័ច-ចៃ (ន.) (បច្ចយ; ប្រត្យយ) ហេតុជាទីអាស្រ័យតគ្នា; ទំនង, លំអាន; ហេតុដែលនាំឲ្យផលប្រព្រឹត្តទៅ ។ល។

[xxiii] សង្ខារ (សង់-ខា) (ន.) ការផ្សំផ្គុំជាអំប្រ៊ីយ៉ុង, សព៌ាង្គកាយ ការកកំណើត, តំណកំណើតសត្វ, ការចាប់កំណើត, បដិសន្ធិនៃអាយុជីវិត ។ សង្ខារ គឺជាការកកើតជីវិតសត្វលោក ដោយការផ្ដុំនៃជាតុទឹកដីភ្លើងខ្យល់។

[xxiv] វិញ្ញាណ វិញ-ញាន (ន.) (វិជ្ញាន) ធម្មជាតិដឹងច្បាស់នូវអារម្មណ៍ (ចិត្ត) ។

[xxv]នាមរូប(ន.)គឺនាមនិងរូប។ នាមរូបគឺជាបញ្ចខន្ធឬខន្ធ៥។ នាមសំដៅលើចេតសិកនិងចិត្ត។ ចេតសិកនៃបញ្ចខន្ធគឺ វេទនា, សញ្ញា, និង សង្ខារ ចំណែកចិត្តក្នុងបញ្ចខន្ធគឺវិញ្ញាណ។ មានន័យថា នាម គឺជាការកំណត់ដឹងដោយកិច្ចជារឿងរបស់ចេតសិក ចិត្ត ដែលជាវត្ថុឥតរូបរាងរួមមាន វេទនា សញ្ញា សង្ខារ និង វិញ្ញាណ។ ចំណែក រូប គឺជាកាយ ឬអ្វីៗដែលប្រាកដដល់ភ្នែក រួមមាន រាង សណ្ឋាន ទ្រង់ ទ្រង់ទ្រាយ ខ្លួនប្រាណ ដែលប្រែប្រួលឬវិនាសដោយហេតុផ្សេងៗមានក្ដៅនិងត្រជាក់ជាធម្មតា។

[xxvi] *អាយតនៈ(ឬអាយតន)អា-យ៉ៈតៈន៉ៈ(ន.) សរីរាង្គវិញ្ញាណដែលជាលំនៅនៃអារម្មណ៍ មានភ្នែក, ត្រចៀក, ច្រមុះ , អណ្ដាត, កាយ, មនោ, ទាំង៦នេះជា អាយតនៈខាងក្នុង ចំណែក អាយតនៈខាងក្រៅក៏មាន៦ដែរ គឺ រូប, សំឡេង, ក្លិន, រស, ផោដ្ឋព្វៈ, សភាវធម៌ ។*

[xxvii] *ផស្សៈ(ឬផស្ស)ផ័ស-សៈ(ន.) ផស្សព្វ, សម្ផស្ស, ការប៉ះប្រសព្វចួបគ្នានៃអាយតនៈខាងក្នុងទាំង៦មានភ្នែក, ត្រចៀក , ច្រមុះ, អណ្ដាត, កាយ, មនោ ជាមួយនឹង អាយតនៈខាងក្រៅទាំង៦មាន រូប, សំឡេង, ក្លិន, រស, ផោដ្ឋព្វៈ, សភាវធម៌ ក៏កើតអារម្មណ៍ដឹងឡើង។*

[xxviii] *វេទនា [វេត-ទៈ-នា] (សំ. បា.) (ន.) ជាចេតសិកមួយដែលនាំឲ្យដឹងនូវអារម្មណ៍ជា ១.សុខ ឬ ២.ទុក្ខ ឬ ៣.ឧបេក្ខា ឬ ៤.សោមនស្ស ឬ ៥.ទោមនស្ស។ ចំពោះមនុស្សច្រើនតែបញ្ចេញឲ្យដឹងនូវទុក្ខវេទនា ច្រើនជាងវេទនាដទៃ។*

[xxix] *តណ្ហា (តន់-ហា) បា.; សំ. (ន.) (តួស្ណា) ចំណង់, ការអន្ទះអន្ទែង, សម្រេកឃ្លាន, សេចក្ដីប្រាថ្នា។ តណ្ហាមាន ៣យ៉ាងគឺ ៖ ក.កាមតណ្ហា គឺ ចំណង់ ការអន្ទះអន្ទែង សម្រេកឃ្លាន សេចក្ដីប្រាថ្នាលើកាមគុណទាំង៥មាន រូប, សំឡេង, ក្លិន, រស និងសម្ផស្ស ខ. ភវតណ្ហា សេចក្ដីប្រាថ្នានៅក្នុងទីកើតស្លាប់ និង គ.វិភវតណ្ហា មិនមានចំណង់ឱ្យមានទីកកំណើតទៀត។*

[xxx] *ឧបាទាន (អ៊ុប៉ា-ទាន) សំ. បា. (ន.) ការប្រកាន់មាំ, ការប្រតោងចិត្តគំនិត, សេចក្ដីប្រកាន់ជាប់ស្អិត, សេចក្ដីជំពាក់ចិត្ត។ ឧបាទាន ជាគ្រឿងតោងនៃចិត្តទៅលើខន្ធ៥ (ឧបាទានខន្ធ) គឺ៖ រូបខន្ធ, វេទនាខន្ធ, សញ្ញាខន្ធ, សង្ខារខន្ធ, វិញ្ញាណខន្ធ។*

[xxxi] *ភព (ភប់) (ន.) (ភវ, វ > ព) សេចក្ដីចម្រើននៃ ដំណើរការកើតស្លាប់, ជម្រកសម្រាប់សត្វកើតស្លាប់។*

[xxxii] *ជាតិ (ជា-តិ ឬ ជាត) (ន.) កំណើត, ការកើតរស់រានមានជីវិត,ការមានអាយុរស់នៅ។*

[xxxiii] *មរណៈ គឺការបែកធ្លាយខន្ធ៥ទៅជាទឹកដីភ្លើងខ្យល់វិញ គឺជាការបញ្ចប់អត្ថិភាពជីវិតមួយ ទៅជាអត្ថិភាពជីវិតមួយផ្សេងទៀត។*

[xxxiv] *បុថុជ្ជន (ប៉ុថុច-ជន់) បា.; សំ.(ន.) (បុថុ "កាស់, ក្រាស់ក្រៃ; ច្រើន" + ជន "សត្វដែលកើត, សត្វលោក"; ប្ថុថគ្ជន) ជនមានកិលេសក្រាស់, ជនអ្នកមានសេចក្ដីសៅហ្មង, សត្វលោកក្រៅអំពីអរិយបុគ្គលទាំង៨ពួក។ បុថុជ្ជនមានច្រើនប្រភេទ មានកល្យាណបុថុជ្ជន, បាបបុថុជ្ជន; បណ្ឌិតបុថុជ្ជន, ពាលបុថុជ្ជន ជាដើម ។*

[xxxv] *អរិយបុគ្គល (ន.) បុគ្គលមានតម្លៃប្រសើរគួរគោរពរាប់អាន ជាមនុស្សចម្រើនដោយពុទ្ធិយល់ដឹងក្នុងអរិយសច្ច ជាមនុស្សឥតទោសក្នុងសង្សារវដ្ដ ព្រោះគ្មាននូវអាសវ និងបរិបូរដោយអរិយទ្រព្យ គឺ សទ្ធា, សីលៈ, ហិរិ, ឱត្តប្បៈ, សុតៈ, ចាគៈ, បញ្ញា ។ អរិយបុគ្គល ជាអ្នកដែលបានសម្រេចលោកុត្តរធម៌ តាំងពីថ្នាក់សោតាបត្តិមគ្គរៀងទៅដល់អរហត្តផល ។ បុគ្គល មាន៤ ប្រភេទគឺ ១- អាចារអរិយៈ ឬ អាចារារិយៈ អ្នកដែលមានមារយាទត្រឹមត្រូវ (សូម្បីសត្វតិរច្ឆាន បើមានមារយាទល្អត្រឹមត្រូវ ក៏ហៅថា អាចារអរិយៈ បានដែរ); ២- ទស្សនអរិយៈ ឬ ទស្សនារិយៈ អ្នកដែលមានរូបឆោមលោមព័ណ៌ល្អ មានឥរិយាបថស្រគត់ស្រគំសមរម្យ គួរឲ្យចង់ឃើញចង់មើល; ៣- លិង្គអរិយៈ ឬ លិង្គារិយៈ បព្វជិតដែលល្អតែភេទ គឺអ្នកបួសដែលផ្ចិតផ្ចង់ប្រុងប្រយ័ត្នតែត្រង់ការស្លៀកដណ្ដប់ឲ្យត្រឹមត្រូវតាម*

បែបបទជាសមណសារូប ប៉ុន្តែជាមនុស្សទ្រុស្តសីល; ៤- អរិយបុគ្គល ឬបដិវេធអរិយៈ ឬ បដិវេធារិយៈ លោកអ្នកបានលុះលោកុត្តរធម៌ (ពុទ្ធាទិបណ្ឌិត) ។

[xxxvi] សម្មាមគ្គ (អដ្ឋង្គិកមគ្គ) មាន ៨ យ៉ាង គឺ ១-សម្មាទិដ្ឋិ សេចក្ដីយល់ឃើញត្រូវ (ព. ផ្ទ. មិច្ឆាទិដ្ឋិ); ២-សម្មាសង្កប្ប ឬ--សង្កប្បៈ សេចក្ដីត្រិះរិះត្រូវ, តម្រិះត្រូវ (ព. ផ្ទ. មិច្ឆាសង្កប្បៈ); ៣-សម្មាវាចា សម្ដីត្រូវ; ប្រើជា សម្មាពាក្យក៏បាន (ព. ផ្ទ. មិច្ឆាវាចា) ឬ--ពាក្យ); ៤-សម្មាកម្មន្តៈ ការងារត្រូវ (ព. ផ្ទ. មិច្ឆាកម្មន្តៈ); ៥-សម្មាអាជីវៈ ការចិញ្ចឹមជីវិតត្រូវ; ប្រើជា សម្មាអាជីវោ ឬ សម្មាអាជីព, សម្មាជីព, សម្មាជីវៈ ក៏បាន (ព. ផ្ទ. មិច្ឆាអាជីវៈ ឬ មិច្ឆាអាជីវោ, មិច្ឆាអាជីព, មិច្ឆាជីព, មិច្ឆាជីវៈ); ៦-សម្មាវាយាមៈ ព្យាយាមត្រូវ; ប្រើជា សម្មាព្យាយាម ក៏បាន (ព. ផ្ទ. មិច្ឆាវាយាមៈ ឬ មិច្ឆាព្យាយាម); ៧-សម្មាសតិ ស្មារតីត្រូវ, ការរឭកត្រូវ (ព. ផ្ទ. មិច្ឆាសតិ); ៨-សម្មាសមាធិ សមាធិត្រូវ (ព. ផ្ទ. មិច្ឆាសមាធិ) ។

[xxxvii] សម្មាទិដ្ឋិ (ស័ម-ម៉ា-ទិត-ឋិ) ន. < សម្មា "ពិត, ត្រឹមត្រូវ" + ទិដ្ឋិ "ដំណើរយល់ឃើញ" ៖ ដំណើរយល់ឃើញ ត្រឹមត្រូវពិតប្រាកដ, បានដល់បញ្ញាយល់ឃើញច្បាស់នូវដំណើរសង្ខារធម៌តាមអរិយសច្ច, ឬដំណើរអស់ទៅនៃឧបាទានដោយបញ្ញាយល់ច្បាស់អំពីបរមត្ថនៃនាមរូបំ អនិច្ចំ ទុក្ខំ អនត្តា, ឬការដឹងយ៉ាងត្រឹមត្រូវអំពីវិធីបំផ្លាញកិលេសក្នុងខន្ធសន្តានគឺលោភៈ ទោសៈ មោហៈជាដើម។ ដើម្បីទទួលបាននូវសម្មាទិដ្ឋិ មនុស្សអាចប្រតិបត្តិគន្ថធុរៈ "កិច្ចខាងការសិក្សារៀនទន្ទេញ" និងបដិបត្តិវិបស្សនាធុរៈ "កិច្ចខាងការពិចារណាដើម្បីឃើញច្បាស់នូវដំណើរពិតនៃសង្ខារធម៌តាមរយៈសម្មាធិ" ជាដើម។

[xxxviii] សម្មាសង្កប្ប ជាសេចក្ដីត្រិះរិះត្រឹមត្រូវ, តម្រិះត្រឹមត្រូវ, បានដល់សេចក្ដីត្រិះរិះអំពី៖ ១.ការចេញចាកកាម(នេក្ខម្ម) ២.ការមិនព្យាបាទ(អព្យាបាទ) ៣.ការមិនបៀតបៀន(អវិហឹសា) និងត្រិះរិះអំពីកុសលកម្មបទ១០ ឬសុចរិត៣យ៉ាង គឺ៖ ១.កាយសុចរិត, សុចរិតដោយកាយ ២.វចីសុចរិត, សុចរិតដោយវាចា ៣.មនោសុចរិត, សុចរិតដោយចិត្ត ជាដើម។

[xxxix] សម្មាវាចា គឺការស្ដីនិយាយត្រឹមត្រូវ និយាយតែពាក្យដែលនាំឲ្យអ្នកស្ដាប់ទទួលបានប្រយោជន៍និងសប្បាយរីករាយ។ សំដីត្រឹមត្រូវហៅថាម្យ៉ាងទៀតថា វចីសុចរិត ដែលផ្ទុយពីវចីទុច្ចរិត។ វចីទុច្ចរិតមាន ៤យ៉ាងគឺ៖១.ពាក្យកុហស កុតករ(មុសាវាទ) ២.ពាក្យញុះញង់(បិសុនាវាទ) ៣.ពាក្យគំរោះគំរើយ(ផរុសវាទ) ៤.ពាក្យរឡេះរឡោះឥតប្រយោជន៍(សម្ផប្បលាបវាទ)

[xl] សម្មាកម្មន្ត ជាការប្រព្រឹត្តអំពើត្រឹមត្រូវដោយកាយ ឬហៅថាម្យ៉ាងទៀតថាកាយសុចរិត ដែលផ្ទុយពីកាយទុច្ចរិត។ កាយទុច្ចរិតមានដូចជា៖ ១.ការសម្លាប់សត្វ(បាណាតិបាត) ២.ការលួចទ្រព្យអ្នកដទៃ(អទិន្នាទាន) ៣.ការប្រព្រឹត្តខុសក្នុងកាមគុណទាំងឡាយ(កាមេសុមិច្ឆាចារ) ៤.ការសេពនូវទឹកស្រវឹងគឺសុរានិងមេរ័យ(សុរាមេរយមជ្ជប្បមាទដ្ឋានា)។

[xli] សម្មាអាជីវៈ (ន.) ការចិញ្ចឹមជីវិតត្រឹមត្រូវ ជាការមានមុខរបរចិញ្ចឹមជីវិតនិងការរស់នៅត្រឹមត្រូវ ដោយសុចរិតនិងចេះលៃប្រមាណក្នុងការបរិភោគ ស្នាក់នៅជាដើម។ របរសុចរិតត្រូវចៀសវាងជំនួញទុច្ចរិត៥ យ៉ាងគឺ៖ ១- ការជួញគ្រឿងសស្ត្រាវុធ(សត្ថវណិជ្ជា) ២- ការជួញមនុស្ស សត្វ(សត្តវណិជ្ជា) ៣- ការជួញសាច់(មំសវណិជ្ជា) ៤-ការ

ជួញគ្រឿងស្រវឹង(មជ្ជវណិជ្ជា) ៥-ការជួញថ្នាំពិស(វិសវណិជ្ជា)។ ក្រៅពីនេះ ត្រូវធ្វើនូវអាជីវបារិសុទ្ធិសីល គឺចិញ្ចឹមជីវិតដោយបច្ច័យ៤ដោយល្អត្រឹមត្រូវ និង វៀរចាកបាបធម៌ទាំង៥ និងតិរច្ឆានវិជ្ជា៨ជាដើម។ បច្ច័យ៤៖ សម្លៀកបំពាក់(ចីវរ), អាហារ(បិណ្ឌបាត), ទីស្នាក់នៅ(សេនាសនៈ) និងថ្នាំកែរោគព្យាបាលជម្ងឺ(គិលានភេសជ្ជ)។ បាបធម៌ ជាធម៌លាមក, អាក្រក់ គឺសភាវៈដែលជាជំនួយចិត្ត នាំចិត្តឲ្យហ៊ានធ្វើអំពើអាក្រក់ ដូចយ៉ាងសេចក្ដីប្រណៃនឈ្នានីស, ឥតអៀនខ្មាស ឥតរាងរអាទៅរកអំពើអាក្រក់ ជាដើម។ បាបធម៌ មានជាអាទិ៍៥គឺ ៖ ១.ការកុហកដោយឫកពា(កហនា), ២.ការនិយាយរាក់ទាក់ដោយវាចា(លបនា ), ៣.ការធ្វើនិមិត្ត គឺប្រើឧបាយកល ដោយកាយខ្លះ ដោយវាចារខ្លះ(នេមិត្តិកតា ), ៤.ការពោលគំរាម ឬសង្កត់ប្រើសំដីជាខ្នោសសម្រាប់កោសការយកលាភ(និប្បេសិកតា), ៥.ការរកលាភដោយលាភ គឺការយកលាភទៅទាក់លាភ(លាភេន លាភំ និជ្ជិគីសនតា) ។ តិរច្ឆានវិជ្ជា គឺចំណេះដែលថោកទាប ទុកដូចជាចំណេះរបស់សត្វតិរច្ឆាន ព្រោះមិនមានប្រយោជន៍។ ១.អង្គំ តម្រានិយាយអំពីសរីរាវយវៈមានដៃនិងជើងជាដើម។ ២.និមិត្តំ តម្រាសម្រាប់ទាយនូវហេតុផ្សេងៗ។ ៣.ឧប្បាតំ តម្រានិយាយអំពីឧប្បត្តិហេតុដូចធ្លាក់កេតុ មេឃក្រហមដាលឡើងក្នុងទិសផ្សេងៗនោះនិងផែនដីញ័រជាដើម។ ៤.សុបិនំ តម្រាសម្រាប់ទាយយល់សប្តិ។ ៥.លក្ខណំ តម្រាសម្រាប់ទាយលក្ខណៈរបស់ស្រ្តី និងបុរស។ ៦.មូសិកច្ឆិន្នំ តម្រាសម្រាប់ទាយនូវសំពត់ដែលកណ្ដុរកាត់។ ៧.អគ្គិហោមំ វិធីបូជាភ្លើង។ ៨.ទិព្វិហោមំ វិធីបូជាវែក។

xlii សម្មាវាយាម, ព្យាយាមត្រឹមត្រូវ ៤ យ៉ាងគឺ៖ ១- ព្យាយាមប្រយ័ត្នមិនឲ្យបាបកើតឡើង(សំវរប្បធាន)។ ២-ព្យាយាមលះបាបដែលបានកើតឡើងហើយ(បហានប្បធាន)។ ៣-ព្យាយាមរក្សាកុសលដែលមានហើយ(អនុរក្ខនាបធាន)។ ៤-ព្យាយាមចម្រើននូវកុសលធម៌ដែលមិនធ្លាប់មាន(ភាវនាបធាន)។

xliii សម្មាសតិ ជាស្មារតីរឭកនឹកឃើញត្រឹមត្រូវ មិនភ្ញាត់គំនិត មិនវង្វេងស្មារតី ដែលជាដំណើរស្វាងរុងរឿងនៃគំនិតសតិសម្បជញ្ញៈ ដោយផ្អែកលើសតិបដ្ឋាន៤ យ៉ាងគឺ ការតាំងស្មារតីនឹកដល់កាយ, ដល់វេទនា, ដល់ចិត្ត, ដល់ធម៌ជាដើមដើម្បីឲ្យឃើញច្បាស់តាមការណ៍ពិត។ សតិបដ្ឋាន គឺការតាំងសតិ សម្បជញ្ញៈ ព្យាយាមពិចារណា កាយ វេទនា ចិត្ត និង ធម៌ ដើម្បីកំចាត់បង់អភិជ្ឈា និង ទោមនស្ស គឺ: ១) កាយានុបស្សនា ២) វេទនានុបស្សនា ៣) ចិត្តានុបស្សនា ៤) ធម្មានុបស្សនា ។

១-កាយានុបស្សនា ការពិចារណាឃើញកាយ ក្នុងកាយចែកជា ៦ បព្វៈគឺ៖ ១) អានាបាណបព្វៈ ដង្ហើមចេញចូល ២) ឥរិយាបថបព្វៈ ការពិចារណាឥរិយាបថទាំង ៤ គឺ ដេកដើរឈរអង្គុយ ៣) សម្បជញ្ញបព្វៈ ការពិចារណាដោយសតិសម្បជញ្ញៈ គឺសេចក្ដីដឹងខ្លួនក្នុងការការដើរ ការឈរ ការអង្គុយ ការដេក ការភ្ញាក់ ការនិយាយ ការនៅស្ងៀម។ ៤) មនសិការបព្វៈ គឺការពិចារណាឃើញនូវអាការៈ ៣២ ប្រការ ដែលមានក្នុងកាយនេះ ចាប់តាំងពីបាតជើង រហូតដល់ចុងសក់ ពីចុងសក់ចុះមកដល់បាតជើង មានស្បែក ហ៊ុមព័ទ្ធជុំវិញពេញទៅដោយវត្ថុមិនស្អាតដោយប្រការផ្សេងៗ គឺសក់ រោម ក្រចក ធ្មេញ ស្បែក សាច់ សរសៃ ឆ្អឹង ខួរក្នុងឆ្អឹង តម្រងនោម (ទាច) បេះដូង ថ្លើម វាវ ក្រពះ សួត ពោះវៀនធំ ពោះវៀនតូច អាហារថ្មី អាហារចាស់ ប្រមាត់ ស្លេស្ម ខ្ទុះ ឈាម ញើស ខ្លាញ់ខាប់ ទឹកភ្នែក ខ្លាញ់រាវ ទឹកមាត់ ទឹកសំបោរ ទឹករំអិល និង ទឹកមូត្រ ។ ៥) ធាតុមនសិការបព្វៈ គឺពិចារណាឃើញកាយ

នេះតាមដែលតាំងនៅ តាមដែលស្ថិតនៅដោយភាពជាធាតុថា ក្នុងកាយនេះមាន ធាតុដី ទឹក ភ្លើង ខ្យល់ ។ ៦) នវសីវតិកាបព្វៈ គឺពិចារណាលក្ខណៈផ្សេងៗនៃសាកសព។

២-វេទនានុបស្សនា ការពិចារណាវេទនាក្នុងវេទនាទាំងឡាយ គឺការពិចារណាការសោយនូវសេចក្តីសុខ ទុក្ខ មិនសុខ មិនទុក្ខក្នុងខ្លួនឯង ចែកចេញជា៩ ប្រភេទគឺៈ ១- ពេលសោយសុខវេទនា ទុក្ខវេទនា អទុក្ខមសុខវេទនា។ មានឬមិនមានអាមិស ។ ក្នុងវេទនាទាំង ៩ប្រការនេះ ទ្រង់បង្រៀនឲ្យភិក្ខុពិចារណា វេទនា ជា ៣ លំដាប់គឺៈ មានជាប្រក្រតីក៏ត្រឹមតែសម្រាប់ចម្រើនញាណ និងការចម្រើនសតិប៉ុណ្ណោះ មិនអាស្រ័យតណ្ហា និង ទិដ្ឋិ ឬប្រកាន់មាំអ្វីៗក្នុងលោកឡើយ ។ ព្រះអង្គត្រាស់សរុបថា "ម្នាលភិក្ខុទាំងឡាយ ភិក្ខុពិចារណាឃើញ វេទនាក្នុងវេទនាទាំងឡាយ ជាប្រក្រតី យ៉ាងនេះឯង" ។

៣-ចិត្តានុបស្សនា ការពិចារណាឃើញចិត្តក្នុងចិត្ត គឺពិចារណាចិត្តរបស់ខ្លួន ឲ្យឃើញសភាវៈ ដែលប្រាកដក្នុងខណៈនោះ និងដឹងច្បាស់តាមសេចក្តីពិត ដោយការតាមដានចិត្ត ៨គូ គឺៈ ចិត្តប្រកបដោយឬមិនប្រកបដោយរាគៈ ទោស មោហៈ ថីនមិទ្ធៈ ជាមហគ្គតៈ ក្រៃលែង, សមាធិ រួចផុត។

៤-ធម្មានុបស្សនា ការពិចារណាឃើញធម៌ក្នុងធម៌ទាំងឡាយជាប្រក្រតី គឺ ពិចារណាថា ក្នុងខណៈនេះ មានធម៌អ្វីនៅក្នុងចិត្តរបស់ខ្លួន ក៏ដឹងច្បាស់ធម៌នោះៗ ដោយពិចារណាធម៌ទាំងជាកុសល អកុសល និង អព្យាក្រិត ដោយបែងចែកការពិចារណាជា៥ពួកគឺៈ ពួកទី១ នីវរណបព្វៈ នីវរណៈគឺពួកធម៌ដែលរារាំងចិត្តមិនឲ្យសម្រេចនូវកុសលធម៌ មាន ៥ប្រការគឺៈ ១) កាមច្ឆន្ទៈ ការត្រេកអរក្នុងកាម ។ ២) ព្យាបាទៈ ការព្យាបាទ ។ ៣) ថីនមិទ្ធៈ ការរុញរាងោកងុយ ងុយដេក ។ ៤) ឧទ្ធច្ចកុក្កុច្ចៈ សេចក្តីរាយមាយអណ្តែតអណ្តូង ។ ៥) វិចិកិច្ឆា ការសង្ស័យមិនចេះចប់ ។

xliv សម្មាសមាធិ (ស័ម-ម៉ា-សៈម៉ា-ធិ)(ន.) សមាធិត្រូវផ្លូវ, ត្រូវទំនង, ដំណើរតាំងចិត្តស្ងប់ស៊ប់មាំក្នុងគន្លងអារម្មណ៍ដែលនឹករំពឹងត្រឹមត្រូវ, ដំណើរស្ងប់ចិត្តស៊ប់ក្នុងអង្គឈានត្រឹមត្រូវ, សមាធិដែលចុះស្ងប់ស៊ប់ក្នុងអង្គឈានពេញបរិបូរ ។ សម្មាសមាធិ មាន២គឺៈ ឧបចារសមាធិ (ឧប៉ៈចារ៉ៈ-សៈម៉ា-ធិ) សមាធិដែលចុះស្ងប់ស៊ប់ក្នុងអង្គបឋមជ្ឈានប៉ុន្តែមិនទាន់ពេញបរិបូរ។ ពាក្យ សម្មាសមាធិ ផ្ទុយនឹង មច្ឆាសមាធិ ដែលជាសមាធិខុសផ្លូវខុសទំនង ។

xlv បញ្ញា (ប៉័ញ-ញ៉ា) (ន.) ការដឹងច្បាស់ បានដល់ការយល់ការដឹងហេតុផល ដោយវិនិច្ឆ័យបានអំពីភាពត្រឹមត្រូវនិងខុសឆ្គង ភាពពិតនិងមិនពិត ភាពល្អនិងអាក្រក់ ការគួរនិងមិនគួរ ជាគុណនិងជាទោស មានប្រយោជន៍និងមិនមានប្រយោជន៍ ជាដើម និង អាចដោះស្រាយបញ្ហាលំបាកស្មុគ្រស្មាញទាំងឡាយ ដោយសន្តិវិធីនិងសមហេតុផលតាមសភាវពិតតាមកាលៈទេសៈ។ បញ្ញាយល់ដឹងច្បាស់អំពី រូប វេទនា សញ្ញា សង្ខារ វិញ្ញាណជាថាសភាវមិនទៀង។ បញ្ញាយល់ច្បាស់អំពីបដិច្ចសមុប្បាទធម៌ ដឹងនូវអរិយសច្ចធម៌មានការគិតពិចារណានូវហេតុផលដែលមិនត្រូវអកុសលនីវរណៈគ្របសង្កត់ និងកំចាត់អស់អាសវកិលេសដែលដេកត្រាំក្នុងសន្តានជាដើម។ បញ្ញាធ្វើឲ្យសទ្ធាខ្ចាក់ក្លាយជាសទ្ធាត្រឹមត្រូវទៅតាមសេចក្តីពិត មិនភ្ញាំងភ្ញាត់ទៅជាជឿរឿងភ្ញាក់ផ្អើលផ្សេងៗ ដោយចេះតែជឿខុសហេតុផលនោះឡើយ។ បញ្ញាធ្វើឲ្យសីល ជាសីលដែលជាទីត្រេកអរនៃព្រះអរិយៈ មិនក្លាយទៅជាសីលព្វតបរាមាស។ បញ្ញាធ្វើឲ្យចាគៈ ជាចាគៈដែលលះបង់ពិតប្រាកដ។ បញ្ញាជាខ្ទឹម និងជាតួឃុំគ្រងនូវគុណសម្បត្តិដទៃៗ។ បញ្ញាជាគុណសម្បត្តិដ៏សំខាន់បំផុតរបស់ព្រះអរិយសាវ័ក និងជាចំណុចទិសដៅនៃការហ្វឹកហាត់អប់រំខ្លួនរបស់

ព្រះអរិយសាវ័កជាបន្តទៅ រហូតដល់អស់អវិជ្ជា។ អ្នកមានបញ្ញា ជាអ្នកយល់ដឹងនិងរៀបចំដំណើរជីវិតនិងការរស់នៅសម្រាប់ខ្លួនឯង និងសង្គមបានល្អត្រឹមត្រូវដែលចៀសទុក្ខទៅរកសុខ។ គេអាចបណ្ដុះបញ្ញាដោយសង្កេត ស្ដាប់ គិត សួរ កត់ត្រា ដោយវិធីសមាធិចិត្ត គឺចិត្តមិនប្រកបជាមួយអកុសលចេតសិក ទាំងឡាយ មានមោហៈ លោភៈ ទោសៈ ថីន មិទ្ធ វិចិកិច្ឆា ជាដើម។ បញ្ញាមានជាអាទិ៍៖ បញ្ញាសុតមយប្បញ្ញា (សុ-តៈមៈយ័ប-ប៉័ញ-ញ៉ា) ប្រាជ្ញា ឈ្វេងយល់ដឹងច្បាស់ដែលកើតអំពីការស្ដាប់។ ទានមយប្បញ្ញា បញ្ញាដឹងច្បាស់ ឃើញត្រូវណា កើតឡើងព្រោះប្រារព្ធទាន។ សីលមយប្បញ្ញា បញ្ញា ដឹងច្បាស់ មិនវង្វេងព្រោះប្រារព្ធសីល។ ចិន្តាមយប្បញ្ញា បញ្ញាឈ្វេងយល់ពិតក្នុងចិត្តដោយខ្លួនឯង។ ភាវនាមយប្បញ្ញា គឺជាប្រាជ្ញារបស់បុគ្គលចូលកាន់ឈានសមាបត្តិ ។

xlvi សីល (អានថា សិល) (ន.) ជាវិរតិចេតនាដែលវៀរចាកអំពើអាក្រក់, ការកាន់ឬប្រព្រឹត្តល្អដោយកាយវាចា, ការមិនប្រព្រឹត្តកន្លងសិក្ខាបទឬវិនយប្បញ្ញត្តិ។ ការកាន់ចរិយាល្អ; ការសង្រួម; អង្គនៃចរិយា; ចរិត, ចរិយា; មារយាទល្អ; សេចក្ដីល្អ; គតិ; លក្ខណៈ; និស្ស័យ; អធ្យាស្រ័យ; សភាព; ប្រក្រតី; ទម្លាប់; សណ្ដាប់ធ្នាប់; ធម្មជាតិ; ធម្មតា ។ល។ សីលនៅទីនេះ សំដៅសីលនិងធម៌ ដែលទូទៅហៅថា សីលធម៌ ឬសីលធម្ម ។ សីលធម៌ គឺសីលដែលជាធម៌(របស់សត្វលោក) ពោលគឺនិយាមឬក្បួនកិរិយាមារយាទដើម្បីសណ្ដាប់ធ្នាប់ក្នុងការរស់នៅ ឬថាដំបូន្មានដែលនាំឲ្យចៀសវាងអំពើអាក្រក់ហើយឲ្យប្រព្រឹត្តតែអំពើល្អត្រឹមត្រូវទាំងកាយ វាចា ចិត្តក្នុងជីវភាពរស់នៅ ទៅតាមសម្មាវាចា សម្មាកម្មន្ត សម្មាអាជីវៈ។ សម្មាវាចា គឺការស្ដីនិយាយត្រឹមត្រូវ និយាយតែពាក្យដែលនាំឲ្យអ្នកស្ដាប់ទទួលបានប្រយោជន៍និងសប្បាយរីករាយ។ សំដីត្រឹមត្រូវហៅថាម្យ៉ាងទៀតថា វចីសុចរិត ដែលផ្ទុយពីវចីទុច្ចរិត។ វចីទុច្ចរិតមាន ៤យ៉ាងគឺ៖១.ពាក្យកុហស ភូតភរ(មុសាវាទ) ២.ពាក្យញុះញង់(បិសុនាវាទ) ៣.ពាក្យគំរោះគំរើយ(ផរុសវាទ) ៤.ពាក្យរឡេះរឡោះឥតប្រយោជន៍(សម្ផប្បលាបវាទ)។ សម្មាកម្មន្ត ជាការប្រព្រឹត្តអំពើត្រឹមត្រូវដោយកាយ ឬហៅថាម្យ៉ាងទៀតថា កាយសុចរិត ដែលផ្ទុយពីកាយទុច្ចរិត។ កាយទុច្ចរិតមានដូចជា៖ ១.ការសម្លាប់សត្វ(បាណាតិបាត)២. ការលួចទ្រព្យអ្នកដទៃ(អទិន្នាទាន) ៣.ការប្រព្រឹត្តខុសក្នុងកាមគុណទាំងឡាយ(កាមេសុមិច្ឆាចារ) ៤.ការសេពនូវទឹកស្រវឹងគឺសុរានិងមេរ័យ(សុរាមេរយមជ្ជប្បមាទដ្ឋានា)។ សម្មាអាជីវៈ(ន.)ការចិញ្ចឹមជីវិតត្រឹមត្រូវ ជាការមានមុខរបរចិញ្ចឹមជីវិតនិងការរស់នៅត្រឹមត្រូវ ដោយសុចរិតនិងចេះលៃប្រមាណក្នុងការបរិភោគ ស្នាក់នៅជាដើម។ របរសុចរិតត្រូវចៀសវាងជំនួញទុច្ចរិត៥ យ៉ាងគឺ៖ ១- ការជួញគ្រឿងសស្ត្រាវុធ(សត្ថវណិជ្ជា) ២- ការជួញមនុស្ស សត្វ(សត្តវណិជ្ជា) ៣- ការជួញសាច់(មំសវណិជ្ជា) ៤-ការជួញគ្រឿងស្រវឹង(មជ្ជវណិជ្ជា) ៥-ការជួញថ្នាំពិស(វិសវណិជ្ជា)។ ក្រៅពីនេះ ត្រូវធ្វើនូវអាជីវបារិសុទ្ធិសីល គឺ ចិញ្ចឹមជីវិតដោយបច្ច័យ៤ ដោយល្អត្រឹមត្រូវ និង វៀរចាកបាបធម៌ទាំង៥ និងតិរច្ឆានវិជ្ជា៨ ជាដើម ។

xlvii សមាធិ (សៈម៉ា-ធិ) (ន.) ដំណើរតាំងស៊ប់មាំនៃចិត្ត, ការចុះចិត្តស៊ប់ឬស្ងប់ចិត្តក្នុងគន្លងអារម្មណ៍ដែលរំពឹង, ការនឹករំពឹងស្ងប់ចិត្ត; ដំណើរស្ងប់ចិត្តស៊ប់ក្នុងអង្គឈាន ។ ឈាន (ន.)(ឬធ្យាន) ការសម្លឹងអារម្មណ៍ ដែលជាអប្បនាសមាធិ។ ឈានមាន៤ថ្នាក់ គឺថ្នាក់ទី១ហៅ បឋមជ្ឈាន មានអង្គ៥គឺ ១- វិតក្កៈ សេចក្ដីនឹកសំដៅឆ្ពោះទៅរកអារម្មណ៍ដែលកំពុងភាវនា; ២- វិចារៈ សេចក្ដីរំពឹងពិចារណាអារម្មណ៍ដែលកំពុងភាវនា; ៣- បីតិ សេចក្ដីឆ្អែតចិត្តពេញចិត្ត; ៤- សុខៈ សេចក្ដីសប្បាយក្នុងចិត្ត; ៥- ឯកគ្គតា ដំណើរមូលចិត្តស្ងប់ទៅក្នុងអារម្មណ៍តែមួយ (អង្គទាំង

៥ នេះ សំដៅចំពោះអារម្មណ៍ ដែលស្ងប់ស្ងាត់ចាកកាមគុណ); ថ្នាក់ទី ២ ហៅ ទុតិយជ្ឈាន មានអង្គ ៣ គឺលះ វិតក្កៈ វិចារៈ ចេញ នៅសល់តែ បីតិ និង សុខៈ ដែលកើតមកជាប់មកអំពីសមាធិរបស់បឋមជ្ឈាន ជា ៣ នឹង ឯកគ្គតា, ថ្នាក់ទី ៣ ហៅ តតិយជ្ឈាន មានអង្គ២គឺលះ បីតិ ចេញ នៅសល់តែ សុខៈ និង ឯកគ្គតា; ថ្នាក់ទី ៤ ហៅ ចតុត្ថជ្ឈាន មានអង្គ ២ ដែរ លះ សុខៈ ចេញ ចិត្តក្លាយទៅជា ឧបេក្ខា គឺដើយព្រងើយ ជា ២ នឹង ឯកគ្គតា ។ ឈានទាំងបួនថ្នាក់នេះ ហៅថា រូបជ្ឈាន មានរូបធម៌ជាអារម្មណ៍រាប់បញ្ចូលក្នុងរូបាវចរភូមិ ។ បុគ្គលអ្នកចម្រើនភាវនា បានសម្រេចផ្លូវឈាន សូម្បីត្រឹមតែបឋមជ្ឈានប៉ុណ្ណោះ ក៏ចូបប្រទះសេចក្ដីសុខសប្បាយធម្មតា ឆ្ងាញ់ពិសាជាងរសជាតិអ្វីៗ ទាំងអស់ ។ ឧបចារសមាធិ (ឧប៉:ចារ៉:--) សមាធិដែលចុះស្ងប់ក្នុងអង្គបឋមជ្ឈាន ប៉ុន្តែមិនទាន់ពេញបរិបូរ។ អប្បនាសមាធិ (អ័ប-ប៉ៈ ន៉ា--) សមាធិដែលចុះស្ងប់ក្នុងអង្គឈានពេញបរិបូរ ។ អ្វីដែលគ្រោះថ្នាក់ពិបាកស្គារ គឺសមាធិខុសផ្លូវ ខុសទំនងសមាធិ(មច្ឆាសមាធិ )។ សមាធិត្រូវផ្លូវ ត្រូវទំនង(សម្មាសមាធិ) មាន៣ដំណាក់កាល គឺសម្មាវាយាមៈ, សម្មាសតិ, សម្មាសមាធិ។ សម្មាវាយាម ព្យាយាមត្រឹមត្រូវ ៤ យ៉ាងគឺ៖ ១-មិនឲ្យបាបកើតឡើង(សំវរប្បធាន) ២-លះបាបមាន(បហានប្បធាន) ៣-រក្សាកុសល(អនុរក្ខនាបធាន) ៤-ចម្រើននូវកុសលធម៌(ភាវនាបធាន)។ សម្មាសតិ ជាស្មារតីរឭកនឹកឃើញត្រឹមត្រូវដោយផ្អែកលើសតិបដ្ឋាន៤ យ៉ាងគឺ ការតាំងស្មារតីនឹកដល់កាយ, វេទនា, ចិត្ត, ធម៌ ជាដើមដើម្បីឲ្យឃើញច្បាស់តាមការណ៍ពិត។ សតិបដ្ឋាន គឺការតាំងសតិ សម្បជញ្ញៈ ព្យាយាមពិចារណា កាយ វេទនា ចិត្ត និង ធម៌ ដើម្បីកំចាត់បង់អភិជ្ឈា និង ទោមនស្សដោយវិបស្សនា គឺ៖ ១) កាយានុបស្សនា ២) វេទនានុបស្សនា ៣) ចិត្តានុបស្សនា ៤) ធម្មានុបស្សនា ។

[xlviii] ឈាន បា.; សំ. ( ន. ) (ធ្យាន) ការសម្ងឹងអារម្មណ៍ ដែលជាអប្បនាសមាធិ។ ឈានមាន ៤ ថ្នាក់ គឺ ៖ ថ្នាក់ទី ១ ហៅ បឋមជ្ឈាន មានអង្គ៥ គឺ ១- វិតក្កៈ សេចក្ដីនឹកសំដៅឆ្ពោះទៅរកអារម្មណ៍ដែលកំពុងភាវនា; ២- វិចារៈ សេចក្ដីរំពឹងពិចារណាអារម្មណ៍ដែលកំពុងភាវនា; ៣- បីតិ សេចក្ដីឆ្អែតចិត្ត; ៤- សុខៈ សេចក្ដីសប្បាយក្នុងចិត្ត; ៥- ឯកគ្គតា ដំណើរមូលចិត្តស្ងប់ទៅក្នុងអារម្មណ៍តែមួយ (អង្គទាំង ៥ នេះ សំដៅចំពោះអារម្មណ៍ ដែលស្ងប់ស្ងាត់ចាកកាមគុណ); ថ្នាក់ទី២ ហៅ ទុតិយជ្ឈាន មានអង្គ៣ គឺលះ វិតក្កៈ វិចារៈ ចេញ នៅសល់តែ បីតិ និង សុខៈ ដែលកើតមកជាប់មកអំពីសមាធិរបស់បឋមជ្ឈាន ជា៣ នឹង ឯកគ្គតា, ថ្នាក់ទី៣ ហៅ តតិយជ្ឈាន មានអង្គ២ គឺលះ បីតិ ចេញ នៅសល់តែ សុខៈ និង ឯកគ្គតា; ថ្នាក់ទី ៤ ហៅ ចតុត្ថជ្ឈាន មានអង្គ២ដែរ លះ សុខៈ ចេញ ចិត្តក្លាយទៅជា ឧបេក្ខា គឺដើយព្រងើយ ជា ២ នឹង ឯកគ្គតា ។ ឈានទាំងបួនថ្នាក់នេះ ហៅថា រូបជ្ឈាន មានរូបធម៌ជាអារម្មណ៍រាប់បញ្ចូលក្នុងរូបាវចរភូមិ ។ បុគ្គលអ្នកចម្រើនភាវនា បានសម្រេចផ្លូវឈាន សូម្បីត្រឹមតែបឋមជ្ឈានប៉ុណ្ណោះ ក៏ចូបប្រទះសេចក្ដីសុខសប្បាយធម្មតា ឆ្ងាញ់ពិសាជាងរសជាតិអ្វីៗ ទាំងអស់ ។

[xlix] វិមោក្ខ (វិ-មោក-ខៈ) បា. ឬ សំ. (ន.)ឬ វិមោក្ស, ការរួចឬផុតស្រឡះ, កិរិយារួចស្រឡះចាកសេចក្ដីសៅហ្មងចិត្ត (និព្វាន)។ វិមោក្ខ៣ (កិរិយារួចផុត, ប្រភេទនៃការរួចផុត បែងចែកតាមលក្ខណៈនៃការឃើញត្រៃលក្ខណ៍ ប្រភេទដែលឱ្យដល់នូវឥស្សរភាព ( Vimokkha: liberation; aspects of liberation)។ ១. សុញ្ញតវិមោក្ខ (ការរួចផុតដោយឃើញភាពសោះសូន្យទទេ អស់ការប្រកាន់មាំ បានដល់ ការរួចផុតដែលកើតអំពីបញ្ញាពិចារណាឃើញនាមរូបដោយភាវៈជាអនត្តា គឺរួចផុតដោយឃើញអនត្តា ហើយដកហូតការប្រកាន់មាំចេញបាន ពោលគឺអាស្រ័យអនត្តា

នុបស្សនា ដកហូតអត្តាភិនិវេសចេញ (Suññata-vimokkha: liberation through voidness; void liberation)។ ២. អនិមិត្តវិមោក្ខ(ការរួចផុតដោយមិនប្រកាន់និមិត្ត បានដល់ ការរួចផុតដែលកើតអំពីបញ្ញាពិចារណាឃើញនាមរូបដោយភាវៈជាអនិច្ចំ គឺរួចផុតដោយឃើញអនិច្ចតា ហើយដកហូតនិមិត្តចេញបាន ពោលគឺអាស្រ័យអនិច្ចានុបស្សនា ដកហូតវិបល្លាសនិមិត្តចេញ (Animitta-vimokkha: liberation through signlessness; signless liberation)។ ៣.អប្បណិហិតវិមោក្ខ (ការរួចផុតដោយមិនធ្វើសេចក្តីប្រាថ្នា បានដល់ ការរួចផុតដែលកើតអំពីបញ្ញាពិចារណាឃើញនាមរូប ដោយភាវៈជាទុក្ខ គឺរួចផុតដោយឃើញទុក្ខតា ហើយដកហូតសេចក្តីប្រាថ្នាចេញបាន ពោលគឺអាស្រ័យទុក្ខានុបស្សនា ដកហូតតណ្ហាបណិធិចេញ(Appaṇihita-vimokkha: liberation through dispositiolessness; desireless liberation)។

[i] សមាបត្តិ (ស:ម៉ាប័ត) សំ. បា. ( ន. ) ការដល់ព្រម; ការបណ្តាលឲ្យកើតមានឡើង; ការសមប្រកប; ការចួបប្រទះ , ការចួបប្រសព្វ; ការបានសម្រេច ។ ព. ពុ. ការចូលឈានតាមលំដាប់ថ្នាក់ទាំង ៨ គឺ រូបជ្ឈាន ៤ អរូបជ្ឈាន ៤ : ព្រះអរហន្តចូលសមាបត្តិ, ព្រះបច្ចេកពុទ្ធចេញចាកសមាបត្តិ ។ និរោធសមាបត្តិ ការចូលឈានដល់ថ្នាក់រម្ងត់ឲ្យខ្យល់ដកដង្ហើមចេញចូល តាំងនៅបានអស់កាលកំណត់យ៉ាងយូរត្រឹម ៧ ថ្ងៃ ទើបចេញវិញ... (ព. ពុ.) ។

[ii] ញាណទស្សន ឬ ញាណទស្សនៈ (--ទ័ស-ស:-ន៉ៈ; បា. ញាណទស្សន; សំ. ជ្ញានទស៌ន) ប្រាជ្ញាដែលដឹង ដែលឃើញនូវសេចក្តីពិត ដូចឃើញច្បាស់នូវសេចក្តីមិនទៀងនៃរូបកាយជាដើម។

[iii] ត្រៃវិជ្ជា ន. (សំ. ត្រៃវិទ្យា; បា. តេវិជ្ជា) ប្រជុំឬការរួបរួមនៃវិជ្ជា ៣ ប្រភេទ ១- សេចក្តីដឹងជាតិកំណើតដែលធ្លាប់កើតស្លាប់ពីមុនៗរៀងមកមានច្រើនជាអនេកកប់មិនអស់; ២- សេចក្តីដឹងដំណើរអន្ទោលស្លាប់កើតនៃខ្លួនឯងនិងពួកសត្វដទៃ ដែលបណ្តាលមកអំពីអំពើអាក្រក់ល្អផ្សេងៗ; ៣- សេចក្តីដឹងធម៌ជាឧបាយឲ្យអស់អាសវក្កិលេស ទាំងបានញុំាងអាសវក្កិលេសនោះឲ្យអស់ជ្រះស្រឡះពីសន្តានលែងត្រឡប់កើតទៀត ។

[iiii] អធិកអធម (អ:ធឹក-អ:ធំ) សំ. បា. ( គុ. ) (អធិក "ក្រៃលែង, លើសលែង, លើសលន់, រុងរឿង, ហ៊ឹកហ៊ាក់" + អធម "ថយថោក, ថោកទាប; មិនរុងរឿង, រម៉េះរម៉ោះ, របុិចរបុី, ភយរង, បន្ទាប់បន្សំ;...) ។ ពិធីអធិកអធម សំដៅពិធីបុណ្យឬពិធីអ្វីមួយ ដែលរុងរឿងផង រម៉េះរម៉ោះឬរបុិចរបុីភយរងខ្លះផង។ ឧទាហរណ៍៖ ធ្វើបុណ្យសីមាអធិកអធម៧យប់គម្រប់៧ថ្ងៃ គឺធ្វើបុណ្យសីមានោះ មានរបៀបរៀបចំរុងរឿងហ៊ឹកហ៊ាក់ផង មានល្បែងរបាំរម៉េះរម៉ោះនិងការលក់ដូរចេកអំពៅនំចំណីជាដើម របុិចរបុី ភយរង ពេញពាសនៅទីជិតៗនោះផង; គេធ្វើបុណ្យសពយ៉ាងអធិកអធម មានអ្វីទាំងគ្រប់ ទាំងថ្ងៃទាំងថោក តាមគេនិយម អ្នកតូចអ្នកធំ ឈូចរតាមពេល ។

[iiv] អធម្ម (អ:ធ័ម)បា.; សំ.(គុ.) អធម៌, ដែលពុំមែនធម៌, ដែលខុសធម៌, ក្រៅគន្លងធម៌, ខុសច្បាប់; អាក្រក់, ពុំប្រសើរ។ (ន.)ដំណើរខុសធម៌, ខុសច្បាប់; ការពុំប្រសើរ; ទុច្ចរិត។ ពិធីអធិកអធម្ម គឺកម្មវិធីប្រព្រឹត្តិទៅខុសធម៌យ៉ាងក្រៃលែង ។

[iv] សក្កាយទិដ្ឋិ២០៖ ១.រូបំ អត្តតោ សមនុបស្សតិ ឃើញរូបថាជាខ្លួន ២.រូបវន្តំ អត្តានំ សមនុបស្សតិ ឃើញខ្លួនមានរូប ៣.អត្តនិ រូបំ សមនុបស្សតិ ឃើញរូបក្នុងខ្លួន ៤.រូបស្មឹ អត្តានំ សមនុបស្សតិ ឃើញខ្លួនក្នុងរូប។
៥. វេទនំ អត្តតោ សមនុបស្សតិ ឃើញវេទនាថាជាខ្លួន ៦. វេទនាវន្តំ អត្តានំ សមនុបស្សតិ ឃើញខ្លួនមានវេទនា

៧. អត្តនិ វេទនំ សមនុបស្សតិ ឃើញវេទនាក្នុងខ្លួន ៨. វេទនាយ អត្តានំ សមនុបស្សតិ ឃើញខ្លួនក្នុងវេទនា ៩.សញ្ញំ អត្តតោ សមនុបស្សតិ ឃើញសញ្ញាថាជាខ្លួន ១០.សញ្ញាវន្តំ អត្តានំ សមនុបស្សតិ ឃើញខ្លួនមានសញ្ញា ១១. អត្តនិ សញ្ញំ សមនុបស្សតិ ឃើញសញ្ញាក្នុងខ្លួន ១២. សញ្ញាយ អត្តានំ សមនុបស្សតិ ឃើញខ្លួនក្នុងសញ្ញា ១៣.សង្ខារេអត្តតោ សមនុបស្សតិ ឃើញសង្ខារថាជាខ្លួន ១៤.សង្ខារវន្តំ អត្តានំ សមនុបស្សតិ ឃើញខ្លួនមានសង្ខារ ១៥. អត្តនិ សង្ខារេ សមនុបស្សតិ ឃើញសង្ខារក្នុងខ្លួន ១៦. សង្ខារេសុ អត្តានំ សមនុបស្សតិ ឃើញខ្លួនក្នុងសង្ខារ ១៧.វិញ្ញាណំ អត្តតោ សមនុបស្សតិ ឃើញវិញ្ញាណថាជាខ្លួន ១៨.វិញ្ញាណវន្តំ អត្តានំ សមនុបស្សតិឃើញខ្លួនមានវិញ្ញាណ

១៩.អត្តនិ វិញ្ញាណំ សមនុបស្សតិ ឃើញវិញ្ញាណក្នុងខ្លួន ២០.វិញ្ញាណស្មឹំ អត្តានំ សមនុបស្សតិ ឃើញខ្លួនក្នុងវិញ្ញាណ

[lvi] វិចិកិច្ឆា (វិ-ចិ-កិច-ឆា)(ន.) វិចិកិត្សា, សេចក្តីសង្ស័យ, សេចក្តីសន្ទិះ; ដំណើរមិនអស់ចិត្ត, ការមិនដាច់ស្រេច, មិនអស់មិនហើយក្នុងចិត្ត, ដំណើរមិនស្រឡះចិត្ត ។

[lvii] សីលព្វតបរាមាស (សីល័ុប-ព:ត:ប៉:រ៉ាម៉ាស)(ន.) ការស្ទាបស្ទង់ព្រយុងចិត្តទៅរកសីលព្វ័ត គឺទម្លាប់និងវត្តប្រតិបត្តិខុសទំនងដែលអ្នកប្រព្រឹត្តជឿថាជាផ្លូវបរិសុទ្ធនាំឲ្យរួចចាកទុក្ខ។

[lviii] សាមីចិកម្ម (សា-ម៉ី-ចិ-កាំ) បា.(ន.) កិច្ចការត្រឹមត្រូវ; ការគោរព, ការគប្បី ។

[lix] បាណាតិបាត មានអង្គ៥ ៖ ១-បាណោ សត្វមានជីវិត។ ២-បាណសញ្ញិតា សេចក្តីដឹងថា សត្វមានជីវិត។ ៣-វធកចិត្តំ ចិត្តគិតនឹងសម្លាប់។ ៤-ឧបក្កមោ ព្យាយាមនឹងសម្លាប់។ ៥-តេនមរណំ សត្វស្លាប់ដោយការព្យាយាមនោះ។

[lx] អទិន្នាទាន មានអង្គ៥ ៖ ១-បរបរិគ្គហិតំ ទ្រព្យដែលមានម្ចាស់គេហួងហែងរក្សា។ ២-បរបរិគ្គហិតសញ្ញិតា សេចក្តីដឹងថា ទ្រព្យមានម្ចាស់គេហួងហែងរក្សា។ ៣-ថេយ្យចិត្តំ ចិត្តគិតនឹងលួច។ ៤-ឧបក្កមោ ព្យាយាមនឹងលួច។ ៥-តេនហរណំ លួចបានមកដោយការព្យាយាមនោះ។

[lxi] កាមេសុមិច្ឆារ: មានអង្គ៤ ៖ ១-អគមនីយដ្ឋានំ ស្រ្តីដែលមិនគួរនឹងគប់រក គឺស្រ្តីដែលមានគេហួងហែងរក្សា។ ២-តស្មឹសេវនចិត្តំ គិតនឹងសេពមេថុនធម្មនឹងស្រ្តីនោះ។ ៣-ឧបក្កមោ ព្យាយាមនឹងសេពមេថុនធម្ម។ ៤-មគ្គេនមគ្គបដិបាទនំ ញុំាងមគ្គនិងមគ្គឲ្យដល់គ្នា។

[lxii] មុសាវាទ មានអង្គ៤ ៖ ១-អតថំវត្ថុ វត្ថុមិនពិត។ ២-វិសំវាទនចិត្តំ ចិត្តគិតនឹងពោលឲ្យខុស។ ៣-តជ្ជោវាយាមោ ព្យាយាមនឹងពោលឲ្យខុស។ ៤-បរស្សតទត្ថវិជាននំ ញុំាងអ្នកដទៃឲ្យដឹងច្បាស់នូវសេចក្តីនោះ។

[lxiii] សុរាមេរយ: មានអង្គ៤ ៖ ១-មជ្ជនីយវត្ថុ វត្ថុជាទីតាំងនៃសេចក្តីស្រវឹង គឺសុរា និងមេរ័យ។ ២-បាតុកម្យតាចិត្តំ ចិត្ដគិតបម្រុងនឹងផឹក។ ៣-តជ្ជោវាយាមោ ព្យាយាមនឹងផឹកនូវទឹកស្រវឹងនោះ។ ៤-តស្សបានំ បានផឹកនូវទឹកស្រវឹងនោះឲ្យកន្លងបំពង់កចូលទៅ។

[lxiv] និរយភូមិ (ន.)ទីប្រាសចាកសេចក្តីចម្រើន គឺសេចក្តីសុខ។ និរយភូមិ បានដល់នរក មហានរក (នរករណ្តៅធំ) និងចូឡនរក(នរករណ្តៅតូច) ឬហៅថា ឧស្សទនរក។ ពួកសត្វនរកបានទទួលសេចក្តីទុក្ខធរមាន ទៅតាម ទោសដែលបានប្រព្រឹត្តល្មើសមក ពួកខ្លះត្រូវភ្លើងនរកដុតម្តងហើយម្តងទៀត ពួកខ្លះត្រូវបានធ្វើទុក្ខទោសសម្លាប់ដោយយមបាល ដូចជាកាត់ដៃ កាត់អវយវផ្សេងៗជាដើម ហើយពួកខ្លះត្រូវឆ្កែរបស់យមរាជដេញតាមខាំអិត

ស្រាកស្រានឡើយ។ មនុស្សដែលមានសេចក្តីក្រោធខឹង ច្រើនចូលចិត្តបៀនបៀនអ្នកដទៃដោយផ្លូវកាយ និងវាចា ពួកនេះរមែង បានទៅកើតជាសត្វនរក។

lxv បេត្តិវិស័យ បានដល់ភូមិនៃប្រេត ។ ប្រេតមានច្រើនប្រភេទ ពួកខ្លះមានឫទ្ធិ មានអំណាច អាចបណ្តាលឲ្យឃើញវត្ថុឥដ្ឋារម្មណ៍ និងអនិដ្ឋារម្មណ៍បាន ។ ប្រេតពួកខ្លះ ពេលយប់ជាទេវតា សោយសុខសម្បត្តិក្នុងវិមាន ពេលថ្ងៃជាប្រេត សោយទុក្ខវេទនាយ៉ាងសែនខ្លោចផ្សា, ពួកខ្លះអត់ឃ្លាន មានមាត់ប៉ុនម្ជុល, ពួកខ្លះត្រូវស៊ីរបស់បដិកូល (របស់មិនស្អាត) មានសាកសពសត្វជាដើម ។ ដូចប្រេតជាញាតិរបស់ព្រះបាទពិម្ពិសារ ដែលមានសំដែងក្នុងអដ្ឋកថា បរមត្ថទីបនី ខុទ្ទកនិកាយ បេត្តវត្ថុ ក្នុងតិរោកុឌ្ឌបេត្តវត្ថុថា៖ មនុស្សដែលមានសេចក្តីលោភលន់មិនចេះពេញដោយទ្រព្យ កោងឆបោកអ្នកដទៃអោយក្តៅក្រហាយ បៀតបៀនអ្នកដទៃអោយដល់នូវហាយនភាព ពួកនេះរមែងបានទៅកើតជាប្រេត។

lxvi អសុរកាយជាសត្វមួយជំពូកកើតក្នុងអបាយភូមិ ដែលមានតែសេចក្តីស្រេកឃ្លានជានិច្ច

lxvii តិរច្ឆាន, តិរច្ឆានយោនិ កំណើតសត្វតិរច្ឆាន។ តិរច្ឆានមានពីរប្រភេទ គឺប្រភេទដែលឃើញដោយភ្នែកតាមប្រក្រតី និងប្រភេទដែលមិនឃើញដោយភ្នែកតាមប្រក្រតី, មួយទៀត សត្វតិរច្ឆានដែលមានអត្តភាពធំ និងដែលមានអត្តភាពតូច។ សត្វតិរច្ឆានទាំងអស់ចែកជា៤ប្រភេទគឺ អបាទតិរច្ឆាន សត្វមិនមានជើង មានត្រីនិងពស់ជាដើម។ ទ្វិបាទតិរច្ឆាន សត្វមានជើងពីរ មានបក្សីជាដើម។ ចតុបាទតិរច្ឆាន សត្វមានជើងបួន មានគោជាដើម។ពហុបាទតិរច្ឆាន សត្វមានជើងច្រើន មានក្អែបជាដើម។ សត្វតិរច្ឆានពួកខ្លះមានឫទ្ធិ មានអានុភាពច្រើន ដូចជា ស្តេចនាគ ស្តេចគ្រុឌ ស្តេចដំរី និងស្តេចរាជសីហ៍ជាដើម។ សត្វទាំងអស់ វៀរតែព្រះពោធិសត្វ រមែងមានកាមសញ្ញា (ការសេពកាម) គោចរសញ្ញា(ការស្វែងរកអាហារ) និងមរណសញ្ញា(ការខ្លាចស្លាប់)ដោយច្រើន។ ចំណែកព្រះពោធិសត្វប្រកបដោយសញ្ញាវិសេស ហៅថា ធម្មសញ្ញា និងចាប់តាំងពីទទួលព្យាករណ៍ គឺជានិយតពោធិសត្វហើយ មិនកើតជាសត្វដែលតូចជាងសត្វចាប និងមិនធំជាងសត្វដំរី។ បានឮថា ស្តេចកាឡនាគរាជ មានអាយុវែងបានឃើញព្រះពុទ្ធមក៤ព្រះអង្គហើយ មានព្រះពុទ្ធកុក្កុសន្ធោជាដើម ហើយស្តេចនាគនេះនឹងបានឃើញព្រះសិរអារ្យមេត្រីសម្មាសម្ពុទ្ធទៀត។

# ទស្សនវិជ្ជាសង្គម

*ដោយៈ លោក **ឈុន ផារ៉េង***
*មន្ត្រីនាយកដ្ឋានទស្សនវិជ្ជា និង សង្គមវិទ្យា*
*នៃវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម*

*មនុស្សជាតិទូទៅ ទោះចង់ឬមិនចង់ តែង បានអនុវត្តទ្រឹស្តីទស្សនវិជ្ជាសង្គម ដោយចៀស មិនរួច។ ទស្សនវិទូជាច្រើនបានកំណត់សកម្ម ភាពមួយចំនួនសម្រាប់ សម្គាល់ថាមនុស្សជាតិ ពិតជាបាននិងកំពុងរស់នៅដោយប្រើប្រាស់ ទស្សនវិជ្ជាសង្គម។ តើទស្សនវិជ្ជាសង្គមមាន ជាតុនិងខ្លឹមសារសំខាន់អ្វីខ្លះ សម្រាប់ជួយកែប្រែ មនុស្សក្នុងសង្គមឲ្យមានការរស់នៅកាន់តែ ប្រសើរឡើង?*

## ១-អត្ថន័យនៃពាក្យ ទស្សនវិជ្ជា

*តាមអត្ថន័យជាភាសាខ្មែរ ពាក្យ ទស្សន វិជ្ជា = ទស្សនៈ + វិជ្ជា ។ ទស្សនៈ គឺជាមតិ យោបល់ ការយល់ឃើញ សំណើ ញត្តិ គំនិត។ វិជ្ជា គឺជា ការសិក្សា ការរៀនសូត្រ ។*

*ទស្សនវិជ្ជា ន. (បា.) វិជ្ជាដែលកើតឡើង ដោយទស្សនៈ; វិទ្យាសាស្ត្រថែងអំពីគោល ការណ៍សំខាន់ៗ និងបុព្វហេតុផ្សេងៗ ឬអំពីជីវិត នៃមនុស្សនិងសត្វ : ទស្សនវិជ្ជា ជាគុណជាតិ វិសេសមួយចំណែក[1]។*

*ទស្សនវិជ្ជា គឺជាមុខវិជ្ជាមួយលើកយកមតិ យោបល់ ការយល់ឃើញ ទស្សនៈ សំណើ ញត្តិ គំនិត ទ្រឹស្តី សុភាសិត មនោគមវិជ្ជា លទ្ធិមកធ្វើ ជាកម្មវត្ថុសិក្សា។ យើងអាចនិយាយថា ទស្សន វិជ្ជា ជាមុខវិជ្ជាមួយសិក្សាពីទស្សនៈឬជាវិជ្ជា សម្រាប់ពិចារណារកការពិត និងភាពត្រឹមត្រូវ ដើម្បីស្វែងរកប្រយោជន៍ដល់មនុស្សទូទៅ។*

*យើងអាចកំណត់បានថា ទស្សនវិជ្ជា គឺ ជាវិស័យវប្បធម៌មួយដែលបង្កើតឡើងដើម្បី បម្រើសេចក្តីត្រូវការរបស់មនុស្ស ដោយការ ខិតខំស្រាវជ្រាវនិងត្រិះរិះពិចារណាលើបញ្ហា របស់មនុស្សប្រកបដោយវិចារណញ្ញាណ ពី ជំនាន់មួយទៅជំនាន់។*

## ២-អត្ថន័យនៃពាក្យ ទស្សនវិទូ

*ទស្សនវិទូ ន. (បា.) អ្នកប្រាជ្ញខាងទស្សន វិជ្ជា។ ឧទាហរណ៍ ព្រះពុទ្ធជាទស្សនវិទូឯកក្នុង លោក[2]។ ទស្សនវិទូ គឺជាអ្នកចូលចិត្តបំពេញ*

---

[1] *ជួន ណាត, វចនានុក្រមខ្មែរ, ការផ្សព្វផ្សាយដោយពុទ្ធ សាសនបណ្ឌិត្យ, បោះពុម្ពគ្រាទី៥, ឆ្នាំ១៩៦៧ ទំព័រ ៤១៦*

[2] *ជួន ណាត, វចនានុក្រមខ្មែរ, ការផ្សព្វផ្សាយដោយពុទ្ធ សាសនបណ្ឌិត្យ, បោះពុម្ពគ្រាទី៥, ឆ្នាំ១៩៦៧ ទំព័រ ៤១៦*

ការកិច្ចស្វែងរកពុទ្ធិនិងសច្ចភាពស្របតាមមនោគតិ និង លក្ខណៈវិទ្យាសាស្ត្ររបស់ខ្លួន ដើម្បីប្រយោជន៍មនុស្សជាតិក្នុងសង្គម និងសាកលលោក។ ជាទូទៅទស្សនវិទូទាំងឡាយតែងតែឯកភាពថា វិទ្យាសាស្ត្រ និង ទស្សនវិជ្ជា ត្រូវតែនៅជាមួយគ្នា។ មានតែចំណេះដឹងទូលំទូលាយពិតប្រាកដទេ ដែលអាចនាំសង្គមមនុស្សរស់នៅក្នុងជីវិតប្រកបដោយកុសល។ ទស្សនវិទូជាមនុស្សដែលយកចិត្តទុកដាក់លើ ការស្វែងយល់អំពីបញ្ហារបស់មនុស្ស និងផ្តល់នូវដំណោះស្រាយ។ យើងអាចកត់សម្គាល់បានខ្លះថាៈ

**ក**- ផ្តើមពីការជឿងឆ្ងល់, ការសង្ស័យ, ភាពមិនច្បាស់លាស់នៅក្នុងវត្ថុឬបាតុភូតណាមួយ ទស្សនវិទូបង្កើតចំណោទបញ្ហា។

**ខ**-ផ្តើមពីចំណោទបញ្ហា ទស្សនវិទូវិភាគតាមបែបតក្កវិជ្ជាចំពោះ ភាសា ដោយបញ្ជាក់អត្ថន័យជា បញ្ញត្តិ វិនិច្ឆ័យ និង វិចារ ទាក់ទងនឹងកម្មវត្ថុដែលត្រូវពិចារណា និងពន្យល់បកស្រាយដល់មហាជន។

**គ**-ទស្សនវិទូ អាចប្រើវិធីទស្សនវិជ្ជាដើម្បីបកស្រាយចំណោទបញ្ហា ឬប្រធានបទ។

**ឃ**-ជាទូទៅ ទស្សនវិទូ ឆ្លើយតបនឹងចំណោទបញ្ហាតាមលក្ខខណ្ឌ ការគិតស្របនឹងតថភាព និង ការគិតស្របនឹងការគិត ហើយយកចំលើយនោះមករិះគន់ជាបន្តបន្ទាប់ដើម្បីបញ្ជាក់ពីសច្ចភាព។

**ង**-ទស្សនវិទូ តែងផ្តល់អនុសាសន៍ ដល់សាធារណជននូវការអនុវត្តគំនិតសាកលឱ្យទៅជាសកម្មភាពប្រតិបត្តិជាក់ស្តែង ក្នុងគោលបំណងកែប្រែឥរិយាបថមនុស្សនិងសង្គមឱ្យកាន់តែប្រសើរ។

ទស្សនវិទូជាអ្នកពិចារណា តាមហេតុផលតម្រង់ទៅរកសច្ចភាពនិងប្រយោជន៍ដែលជាគោលដៅខ្ពស់បំផុត ហើយសច្ចភាព និង ប្រយោជន៍ទាំងនោះទាក់ទងទៅនឹងតថភាពនិងសក្តានុពលនៃបទពិសោធន៍ មធ្យោបាយ និងលទ្ធភាពនានាដែលគេមាន។ សច្ចភាពគឺជាភាពពិតដែលទាក់ទងនឹងច្បាប់ធម្មជាតិ រីឯប្រយោជន៍ទាក់ទងនឹង សេចក្តីសុខចម្រើនសុភមង្គល នៃជីវិតមនុស្ស។ ទស្សនវិទូសង្គមយកចិត្តទុកដាក់និងចំណាយពេលវេលាលើប្រយោជន៍មនុស្សក្នុងសង្គមច្រើនជាងសច្ចភាពបរានុម័តិ។ ទស្សនវិទូសង្គម រួមមានៈ

**ក**.សម័យបុរាណមានលោកអារីស្តូតនិង ប្លាតុង

**ខ**.សម័យមជ្ឈិមមានលោកអូហ្គុស្ទីននិងអាខ្វៃណា

**គ**.សម័យទំនើបមានលោកម៉ាចាវិលី ហុប្បស៍ ឡុក្ខ រ៉ូស្សូ ស្មីត វិការដូ ម៉ាលថឹស មិល្ល បិនថឹម កុម្ត ម៉ាក្ស ឡេនីន

**ឃ**.សម័យក្រោយទំនើបមានលោក ម៉ារគឹស ហាប៊ែរម៉ាស ហ្វូកាល្ស ដេនិដា ជាដើម។

## ៣-អត្ថន័យនៃទស្សនវិជ្ជាសង្គម

*ពាក្យទស្សនវិជ្ជាសង្គម មកពីទស្សនវិជ្ជា+សង្គម។ សង្គមគឺជាការប្រមូលផ្តុំនៃរចនាសម្ព័ន្ធក្រុមមនុស្ស។ រចនាសម្ព័ន្ធក្រុមមនុស្សមាន ក្រុមគ្រួសារ ក្រុមញាតិមិត្ត និងក្រុមការងារ។ ទស្សនវិជ្ជាសង្គម គឺជាគោលគំនិតប្រកបដោយគតិបណ្ឌិតដែលពិចារណាជាចម្បងទៅដាក់លើបញ្ហា និង ឥរិយាបទសង្គម មនុស្ស ដោយពិនិត្យតាមដានមើល របៀបរបប គោលបំណងដំណើរការសង្គម និងផលប្រយោជន៍នៃរចនាសម្ព័ន្ធក្រុមមនុស្សដែលមាន ក្រុមគ្រួសារ ក្រុមញាតិមិត្ត និងក្រុមការងារ ជាដើម។ ទស្សនវិជ្ជាសង្គមមានវិសាលភាពគ្របដណ្តប់គោលគំនិតសង្គមដែលក្នុងនោះមាន ទ្រឹស្តីកិច្ចសន្យាសង្គម វប្បធម៌ អត្តសញ្ញាណជាតិ លក្ខខណ្ឌសេដ្ឋកិច្ចសង្គម ទំនាក់ទំនងរវាងបុគ្គលនិងសង្គមនិងជីវិតឯកជនជាដើម។*

*ទស្សនវិជ្ជាសង្គមពាក់ព័ន្ធនឹងវិស័យទស្សនវិជ្ជាផ្សេងទៀតដែលមានទស្សនវិជ្ជាពុទ្ធិ អស្តិរូបវិជ្ជា សីលវិជ្ជា ទស្សនវិជ្ជានយោបាយជាដើម។ លើសពីនេះទៀតទស្សនវិជ្ជាសង្គមតែងរួមបញ្ចូលសង្គមវិទ្យា នរវិទ្យា និងចិត្តសាស្ត្រ។ ទស្សនវិទូសង្គមទាមទារនូវពុទ្ធិវិទ្យាសាស្ត្រនិងការពិសោធន៍ដើម្បីសញ្ជឹងគិតលើវិស័យទាំងនេះ។ ការផ្តល់ការពិភាក្សាឬទ្រឹស្តី គឺជាធាតុចាំបាច់នៃទស្សនវិជ្ជាសង្គមនិងវិទ្យាសាស្ត្រសង្គមដែរ។ ទស្សនវិជ្ជាសង្គមទាក់ទងយ៉ាងជិតស្និទនឹងទស្សនវិជ្ជានយោបាយ ជាពិសេសលើបញ្ហា សិទ្ធិ អំណាច របៀបគ្រប់គ្រង បដិវត្តន៍កម្មសិទ្ធិទ្រព្យសម្បត្តិ សោភណវិជ្ជានិងសីលវិជ្ជា ជាដើម។*

## ៤-អត្ថន័យនៃសង្គមវិទ្យា

*សង្គមវិទ្យាមាន និយមន័យផ្សេងៗគ្នាទៅតាមសង្គមវិទូម្នាក់ៗ។ យើងឃើញមាននិយមន័យសង្គមវិទ្យាដូចជា៖ ក)សង្គមវិទ្យាគឺជាប្រព័ន្ធនៃការសិក្សាសង្គម ខ)សង្គមវិទ្យាគឺជាការសិក្សាអន្តរកម្មទំនាក់ទំនងលក្ខណៈសម្បត្តិនិងផលវិបាករបស់មនុស្ស គ)សង្គមវិទ្យាគឺជាការសិក្សាអំពីអាកប្បកិរិយារបស់មនុស្សក្នុងក្រុម និង ឃ) កម្លាំងអន្តរកម្មដែលបានជះឥទ្ធិពលលើផ្នត់គំនិតបុគ្គលនិងការធ្វើចំណាត់ថ្នាក់សង្គម។*[3]

## ៥-ទ្រឹស្តីទស្សនវិជ្ជាសង្គម

*ការជាមនុស្សមិនអាចរស់នៅឯកោដាច់ចេញពីគ្នាបានឡើយ។ គេត្រូវការរស់នៅក្នុងកិច្ចសហប្រតិបត្តិការនិងសំដែងសញ្ចេតនាក្នុងជីវភាពរស់នៅដល់គ្នាទៅវិញទៅមក ពោលគឺគេត្រូវរស់ក្នុងសង្គមដែលស្ថិតក្នុងរចនាសម្ព័ន្ធក្រុម*

---

[3] *យោងតាមលោក អេមីល ឌឺខេម* (Durkheim Émile Durkheim, 1858 - 1917)*។ ឌឺខេម ជាសង្គមវិទូ ជនជាតិបារាំងដែលបានបង្កើតវិធីសាស្ត្រសម្រាប់ការស្រាវជ្រាវជាក់ស្តែងទៅលើទ្រឹស្តីសង្គមវិទ្យា។*

មានក្រុមគ្រួសារ ក្រុមញាតិមិត្តនិងក្រុមការងារ។

## ៩.១-ធម្មជាតិមនុស្ស

ការស្គាល់ពីធម្មជាតិមនុស្ស ធ្វើឱ្យយល់ដឹងពីមូលហេតុនៃការគិត និងការប្រតិបត្តិក្នុងជីវិតរស់នៅរបស់មនុស្ស។ សារសំខាន់នៃការសិក្សាអំពីធម្មជាតិមនុស្ស គឺកំណត់ទ្រឹស្ដីជាច្រើនអំពីមនុស្ស ដែលទ្រឹស្ដីទាំងនោះមិនគ្រាន់តែជះឥទ្ធិពលលើទ្រឹស្ដីសង្គម នយោបាយ និងប្រវត្តិសាស្ត្រប៉ុណ្ណោះទេ ប៉ុន្តែវាថែមទាំងជះឥទ្ធិពលទៅលើទ្រឹស្ដីពុទ្ធិ តម្លៃ សីលធម៌ សិល្បៈ ភាសានិងសាសនាទៀតផង។ មានទស្សនៈបួនយ៉ាងស្ដីពីធម្មជាតិរបស់មនុស្ស៖

ទស្សនៈទី១៖ អះអាងថាធម្មជាតិមនុស្សគឺអាក្រក់។ ទស្សនៈនេះគាំទ្រដោយសាវ័កគ្រិស្តសាសនា មានសន្តបុគ្គល អូហ្គូសស្ទីន ជាដើម។ ដោយសារតែភាពពោរពេញដោយអំពើបាបរបស់ពួកគេនោះ គ្រប់បុគ្គលទាំងអស់មានសារជាតិពុករលួយ ឬបាបពីកំណើតពីព្រោះមនុស្សបានទទួលមរតកគឺអំពើបាបពីបុព្វបុរសរបស់ពួកខ្លួន។

ទស្សនៈទី២៖ អះអាងថាធម្មជាតិមនុស្សគឺល្អ។ ទស្សនៈនេះបានគាំទ្រនិងការពារយ៉ាងខ្លាំងក្លាដោយលោករូស្សូ។ លោកជឿថាធម្មជាតិមនុស្សកើតមកល្អ ប៉ុន្តែអារ្យធម៌សង្គមទេដែលពុករលួយ អំពើពាលាអាវ៉ាសែ ហើយបានកែប្រែមនុស្សឱ្យទៅជាអាត្មានិយមក្រអឺតក្រទម មិនទុកចិត្តគ្នា និងប្រទូសរ៉ាយ។ លោកហឺប៊ឺតស្បិនស័រ(Herbert Spencer) បាននិយាយថាមាគ៌ានៃការវិវត្តគឺជាការប្រែប្រួលទៅរកភាពល្អប្រសើរជាង។ ដូច្នេះមនុស្សគួរតែឈរមកម្ខាងហើយទុកឱ្យធម្មជាតិអភិវឌ្ឍទៅរកគោលដៅរបស់វា ព្រោះបន្តិចម្តងៗ វានឹងនាំមកនូវការអភិវឌ្ឍទាំងស្រុងទៅលើសមត្ថភាពរបស់មនុស្ស និងការសម្របសម្រួលនឹងបរិស្ថានជុំវិញខ្លួនទៅរកសុខដុមរមនា។

ទស្សនៈទី៣៖ អះអាងថាធម្មជាតិរបស់មនុស្សគឺអព្យាក្រឹត គឺថាមិនល្អ ហើយក៏មិនអាក្រក់ដែរ ប៉ុន្តែប្រកបដោយសក្តានុភាពដ៏ធំធេងចំពោះអំពើល្អនិងអាក្រក់។ មិនដូចសត្វថ្នាក់ទាបផ្សេងៗនោះទេមនុស្សមានទំនោរបត់បែន ហើយមានសមត្ថភាពរៀនសូត្រថែមទៀត។ ការក្លាយទៅជាមនុស្សល្អ ឬអាក្រក់គឺជាលទ្ធផលនៃឥទ្ធិពលបរិស្ថានរស់នៅ និងដំណើរនៃគំនិតរបស់គេ។ គេជាភាវៈនៃការគិត ជាភាវៈមានវិចារណញ្ញាណ។

ទស្សនៈទី៤៖ អះអាងថា ធម្មជាតិរបស់មនុស្សគឺល្អផងនិងអាក្រក់ផង។ ពុំមាននរណាម្នាក់មាន សុក្រឹតភាពទាំងស្រុងឡើយ ព្រោះមនុស្សមានលក្ខណៈសភាវគតិស្រេកឃ្លាននិងតម្រេកតណ្ហាដូចសត្វ លើសតែវិចារណញ្ញាណប៉ុណ្ណោះ។

## ៩.២-ទស្សនវិស័យស្តីពីមនុស្ស

### ៩.២.១-សមាសភាគរបស់មនុស្ស

មានទស្សនៈពីរ ដែលបានអះអាងទាក់ទងទៅនឹងធាតុដែលផ្សំបង្កើតមនុស្សគឺ ទស្សនៈឯកនិយម(Monism) និងទស្សនៈទ្វិកនិយម(Dualism)។ ទស្សនៈឯកនិយមមាន២ប្រភេទ។ ឯកនិយមទី១យល់ថា មនុស្សមិនមានព្រលឹងទេ ដោយពន្យល់ថាអ្វីដែលគេស្មានថាវាជាព្រលឹងនោះគឺវាគ្រាន់តែជាធាតុកួតកើតពីរាងកាយប៉ុណ្ណោះ។ ទស្សនៈនេះយល់ថា កាលណារាងកាយស្លាប់ គ្មានបន្សល់ទុកព្រលឹងអ្វីឡើយ គឺស្លាប់ទៅសូន្យសុង គ្មានព្រលឹងអមតៈអ្វីឡើយ។ រីឯឯកនិយមទី២យល់ថា មនុស្សផ្សំឡើងដោយរាងកាយនិងព្រលឹង។ ព្រលឹងមានអត្ថិភាពអមតៈ។ កាលរាងកាយស្លាប់ ព្រលឹងមិនស្លាប់ទេ គឺព្រលឹងរង់ចាំចាប់បដិសន្ធិជាមួយរាងកាយថ្មី ហើយការកើតស្លាប់របៀបនេះវិលវល់ដដែលៗ គ្មានទីបញ្ចប់។ ចំណែកទស្សនៈទ្វិកនិយមយល់ថា មនុស្សមាន២ផ្នែក គឺទាំងរាងកាយនិងព្រលឹង។ គេជឿថា សមាសភាគមនុស្សគឺ រាងកាយព្រលឹង។ កាលរាងកាយស្លាប់ព្រលឹងក៏ស្លាប់ដែរ។

### ៥.២.២-ប្រភពកំណើតរបស់មនុស្ស

មានទ្រឹស្តីពីរ ស្តីអំពីប្រភពកំណើតមនុស្សគឺ៖ ទ្រឹស្តីវិវត្តន៍(Theory of Evolution) និងទ្រឹស្តីអាទិទេព។ ទ្រឹស្តីវិវត្តន៍ យល់ថា សរីរាង្គមានជីវិតបានអភិវឌ្ឍតាមក្រឹត្យក្រមនៃជម្រើសធម្មជាតិ។ ចំណែកទ្រឹស្តីទ្រឹស្តីអាទិទេព(សាសនា យូដា គ្រិស្ត អ៊ិស្លាម ហិណ្ឌូ ជាដើម) បញ្ជាក់ថា មនុស្សកើតឡើងពីព្រលឹងវិញ្ញាណរបស់ទិទេព។ ក្នុងសាសនា យូដា គ្រិស្ត អ៊ិស្លាម ជឿថា ព្រះបានបង្កើតមនុស្សពីធូលីដីហើយបានផ្លុំព្រលឹងវិញ្ញាណចូល រូបនេះក៏មានជីវិតរស់រវើកឡើង។ ហិណ្ឌូសាសនា ជឿថា មនុស្ស កើតពីអាត្ម័នដែលជាព្រលឹងតូចបែកចាកពីព្រហ្ម័នដែលជាព្រលឹងធំ។ កាលណារាងកាយស្លាប់អាត្ម័នមិនស្លាប់ទេ វានៅវិលវល់កើតស្លាប់ក្នុងវាលវដ្តសង្សារលុះត្រាទៅវាបានទៅជួបព្រហ្ម័នវិញ។

### ៥.២.៣-សារជាតិរបស់មនុស្ស

មានទស្សនៈបួនក្រុម ដែលនិយាយពីសារជាតិរបស់មនុស្ស គឺ៖

១.ទ្រឹស្តីវិចារណញ្ញាណនិយម យល់ថា សារជាតិមនុស្សស្ថិតលើសមត្ថភាពនៃការគិតពិចារណានិងយល់ដឹងរបស់មនុស្ស។ ផ្លាតូយល់ថា វិចារណញ្ញាណគឺជាផ្នែកមួយនៃព្រលឹង ព្រលឹងជាផ្នែកមួយខ្ពស់បំផុតដែលមានឯករាជ្យមិនចេះស្លាប់ ហើយវាគឺជាសតិតែមួយគត់ដែលវាអាចជួយឱ្យមនុស្សយល់ដឹងពីធម្មជាតិនៃភាវៈទាំងឡាយ។ អារីស្តូតអះអាងបន្ថែមថា វិចារណញ្ញាណជាទ្រព្យមានតម្លៃរបស់មនុស្សដែលបែងចែកមនុស្សខុសពីសត្វនានា។ លោករ៉ូប៊ីនស៊ុន (Robinson)យល់ថា គំនិតត្រូវគេចាត់ទុកថាជាកិត្តិយសដ៏សំខាន់និងជាឧបករណ៍របស់មនុស្សដែលអាចជួយមនុស្សឱ្យសម្រេចបាននូវអ្វីៗ ដែលអស្ចារ្យនៅក្នុងអារ្យធម៌របស់ខ្លួន។ មនុស្សអាចគិតពិចារណា តែសត្វដទៃមិនអាចពិចារណាបានទេ។ ដូច្នេះមនុស្សបានបង្កើត

សាសនា សិល្បៈ ស្ថាប័ន ប្រព័ន្ធទស្សនវិជ្ជា និងទេវវិទ្យាជាដើម។ មនុស្សទទួលបានពុទ្ធិ រួចស្វែងរកនិងច្នៃបង្កើតថ្មី ដើម្បីមានអាហារចិញ្ចឹមជីវិត ស្លៀកពាក់ការពារខ្លួន តុបតែងលម្អនិងដើម្បីរីករាយសប្បាយ។ ដូច្នេះដំណើរនៃគំនិតជាធាតុដ៏សំខាន់នៅក្នុងអារ្យធម៌ រីឯវិចារណញ្ញាណគឺជាមោទកភាពនិងភាពរុងរឿងរបស់មនុស្ស។

២-ទស្សនៈពាហិរសាសនាស្តីពីសារជាតិមនុស្ស យល់ថា មនុស្សគឺជាភាវៈពិសិដ្ឋដែលបង្កើតដោយអាទិទេព។ លក្ខណៈពិសិដ្ឋរបស់មនុស្សគឺព្រលឹងវិញ្ញាណ។ ព្រលឹងវិញ្ញាណមនុស្ស ផ្តល់ឱ្យមនុស្សនូវតម្លៃ និងលទ្ធភាពគ្មានព្រំដែន។

៣-ទស្សនៈពុទ្ធសាសនាស្តីពីសារជាតិមនុស្ស យល់ថា មនុស្សគឺជាភាវៈធម្មជាតិដែលផ្សំឡើងដោយទឹកដីភ្លើងខ្យល់ គ្មានអាទិទេពណាជាអ្នកបង្កើតឡើងទេ។ លក្ខណៈពិសេសរបស់មនុស្សគឺ បញ្ញា។ បញ្ញារបស់មនុស្សអាចនាំមនុស្សរំដោះខ្លួនទៅរកសុខស្ងប់ចាកទុក្ខបាន។

៤-ទស្សនៈវិទ្យាសាស្ត្របែកចេញជាពីរផ្នែកគឺៈ ទស្សនៈជីវសាស្ត្រ និងទស្សនៈអាកប្បកិរិយានិយម។ ទស្សនៈជីវសាស្ត្រ ចាត់ទុកមនុស្សថា មនុស្សជាផ្នែកមួយនៃលំដាប់រូបសាស្ត្រធម្មជាតិដូចវត្ថុផ្សេងៗទៀតដែរគឺមនុស្សមានទំហំទម្ងន់រាងរៅនិងពណ៌សម្បុរ។ មនុស្សរស់នៅក្នុងលំហនិងកាលហើយស្ថិតនៅក្រោមច្បាប់នៃរូបវិទ្យាដូចជាច្បាប់ទំនាញផែនដីជាដើម។ ចំណែកទស្សនៈអាកប្បកិរិយានិយម យល់ឃើញថា មនុស្សគឺជាភាវៈដែលអាចត្រូវបានគេប្រើប្រាស់ អាចត្រូវបានគេបង្កើត និងអាចត្រូវបានគេធ្វើឱ្យអភិវឌ្ឍជាច្រើនបែបដូចគ្នាទៅនឹងសត្វដទៃមួយចំនួនទៀតដែរ។ ពួកអាកប្បកិរិយានិយមអះអាងថា "ចូរឱ្យទារកម្នាក់មកខ្ញុំនិងពិភពរបស់ខ្ញុំដើម្បីចិញ្ចឹមទារកនេះហើយខ្ញុំនឹងបង្រៀនទារកនេះឱ្យចេះវារនិងចេះដើរចេះឡើងហើយនិងចេះប្រើប្រាស់ដៃទាំងទ្វេរបស់គេក្នុងការកសាងផ្ទះ ដែលធ្វើអំពីថ្មឬឈើ ហើយខ្ញុំនឹងធ្វើឱ្យគេក្លាយទៅជាចោរអ្នកកាន់កាំភ្លើងឬធ្វើឱ្យទៅជាអ្នកញៀនថ្នាំ។ លទ្ធភាពនៃការតម្រង់ទិសដៅគឺស្ទើរតែគ្មានទីបញ្ចប់"។

## ៥.២.៤-លក្ខណៈពិសេសរបស់មនុស្ស

មនុស្សមានលក្ខណៈពិសេសខុសពីសត្វនិងភាវៈផ្សេងទៀត ដោយគេមានអំណាចក្នុងការគិតពិចារណាដែលធ្វើឱ្យខ្លួនខ្ពស់ជាងអម្បូរនៃសត្វដទៃទៀត។ លក្ខណៈផ្សេងទៀតដែលញែកមនុស្សឱ្យខ្ពស់ជាងទម្រង់នៃសត្វដទៃទៀតគឺមនុស្សមានបញ្ញាបង្កើតសង្គមនិងវប្បធម៌។ ខាងរាងកាយមនុស្ស មានរបៀបឈរឬអង្គុយរបស់មនុស្សគឺត្រង់ឆ្អឹងទៅលើដែលការឈរត្រង់ហ្នឹងអាចជួយគេឱ្យប្រើប្រាស់ដៃ និងប្រអប់ដៃដោយសេរីក្នុងការរកស៊ីនិងការប្រើប្រាស់។ មនុស្សមានម្រាមដៃដាច់ៗពីគ្នានិងមេដៃដែលចេះចាប់វត្ថុផ្សេងៗបាន។ មនុស្សមានម្រាមដៃដែលអាចប្រើបានច្រើនយ៉ាងផ្តល់ឱ្យគេនូវភាព

បត់បែនបានដោយសេរី។ អំណោយទានធម្មជាតិផ្តល់ឱ្យនិងមានតម្លៃបំផុតសម្រាប់មនុស្ស គឺខួរក្បាលធំទូលាយនិងប្រព័ន្ធប្រសាទដែលមានភាពសាំញ៉ាំនិងដែលបានរៀបចំយ៉ាងខ្ពង់ខ្ពស់។ អំណោយទានធម្មជាតិផ្តល់ឱ្យទាំងនេះ អនុញ្ញាតឱ្យមនុស្សមានអាកប្បកិរិយាប៉ិនប្រសប់ផ្សេងៗពីគ្នា។ លក្ខណៈពិសេសដោយឡែកទៀតរបស់មនុស្ស គឺជាលក្ខណៈពិសេសខាងសង្គម វប្បធម៌ និងបញ្ញា។ មនុស្សអាចមានសមត្ថភាពប្រើប្រាស់ភាសាដើម្បីនិយាយទាក់ទងគ្នាពន្យល់គ្នាជាឃ្លាប្រយោគ។ មនុស្សចេះច្នៃបង្កើតឧបករណ៍ប្រើប្រាស់និងបង្កើតម៉ាស៊ីនផ្សេងៗ។ មនុស្សរស់នៅជាក្រុម តាមលក្ខណៈសង្គមនិងនយោបាយ ដោយបង្កើតនិងអនុម័តច្បាប់នៃការប្រព្រឹត្តហើយមានកិច្ចសហប្រតិបត្តិការនៅក្នុងទិដ្ឋភាពសំខាន់ៗ។ មនុស្សអាចយល់ដឹងពីប្រវត្តិសាស្ត្រនិងមានការប្រមូលចងក្រងនូវប្រពៃណីវប្បធម៌។ មនុស្សស្គាល់ពីសោភ័ណនិងបង្កើតសោភ័ណភាពហើយរីករាយនឹងសោភ័ណភាពនោះ។ មនុស្សចេះដឹងអំពីតម្លៃ ត្រូវនិងខុស ល្អនិងអាក្រក់ គឺជាសត្វមានសីលធម៌និងមានមនសិការសីលធម៌។ មនុស្សថែមទាំងចេះបង្កើតសាសនា និងគោរពប្រតិបត្តិពិធីទំនៀមទម្លាប់នានា។ល។

## ៩.២.៩-សមត្ថភាពរបស់មនុស្ស

មានទស្សនៈពីរស្តីអំពីសមត្ថភាពមនុស្ស គឺទស្សនៈបុរាណ និងទស្សនៈទំនើប។ ទស្សនៈបុរាណស្តីពីមនុស្ស យល់ថាមនុស្សមិនមានសមត្ថភាព ឬគំនិតដ៏ភ្លឺស្វាងឯករាជពីព្រហ្មលិខិតឬអាទិទេពឡើយ។ គំនិតមនុស្សជាធនធានដ៏សំខាន់របស់មនុស្សសុទ្ធតែជាអំណោយទានពីអាទិទេព។ ការច្នៃបង្កើត ការប្រើប្រាស់ភ្លើង ការកសាងជម្រក ការផ្សាំងសត្វ វិធីផលិតលោហៈធាតុ កសិកម្ម សុខាភិបាល នាវាចរណ៍ ភាសា គណិតវិទ្យា តារាវិទ្យា សិល្បៈ ទស្សន៍ទាយ ទាំងអស់នេះចាត់ទុកថាជាផលិតផលនៃបញ្ញាដែលអាទិទេពផ្តល់ឱ្យ។

ចំណែកទស្សនៈទំនើបអំពីមនុស្ស (Modern Views of Man) យល់ថាមនុស្សជាភាវៈដែលបានសម្រេចនិងរីករាយចំពោះគោលជំហរអត្ថិភាពនៃអំណាចនិងឥទ្ធិពលបច្ចុប្បន្នរបស់ខ្លួន។ គោលជំហរបែបនេះគឺមិនមែនអាទិទេពផ្តល់មនុស្សទេគឺ ដោយសមត្ថភាពពីធម្មជាតិរបស់មនុស្សផ្ទាល់តែម្តង។ មនុស្សគឺជាភាវៈមានសញ្ញាខុសប្លែកគេនៅត្រង់មនុស្សមានសមត្ថភាព ជ្រើសរើសដោយសេរី។ យោងតាមលោករូស្សូ គឺសមត្ថភាពក្នុងការជ្រើសរើសរបស់មនុស្សហ្នឹងហើយ ដែលកំណត់នូវប្រភេទនៃមនុស្សដែលនឹងក្លាយទៅជាមនុស្សបែបណា។ មនុស្សមានធម្មជាតិល្អពីកំណើត។ ប្រសិនបើគេក្លាយជាអាក្រក់គឺដោយសារការជ្រើសរើសឬអនុញ្ញាតឱ្យកម្លាំងណាមួយនៃបរិស្ថានជុំវិញ។ គេអាចមានសមត្ថភាពធ្វើឱ្យខ្លួនសុក្រឹតប៉ុន្តែវាទាមទារនូវអំណាចនៃ

ឆន្ទៈនិងការជ្រើសរើសរបស់គេដើម្បីទទួលបាននូវសុក្រឹតភាពនោះ។

លោក កាល់ ម៉ាក្ស យល់ថា មនុស្សជា៖ "សត្វដែលមានសមត្ថភាពពិសេសសម្រាប់បង្កើត និងប្រើប្រាស់ឧបករណ៍"។ ពេលផ្តោតដាក់ស្តែងលើការច្នៃបង្កើតរបស់មនុស្ស ការច្នៃបង្កើតនេះតម្រង់តែមួយគត់ទៅលើផលិតកម្មសម្ភារៈ។ មនុស្សគឺជាសត្វផលិតកម្មជាចម្បង។ ចំពោះលោក កាល់ម៉ាក្ស ប្រព័ន្ធទូទៅនៃផលិតកម្មទំនិញគឺជាគន្លឹះចំពោះលក្ខណៈនៃស្ថាប័នសង្គមនយោបាយនិងតម្លៃវប្បធម៌។ ទស្សនៈលេចធ្លោស្តីពីមនុស្ស គឺយកចិត្តទុកដាក់លើការច្នៃបង្កើតរបស់មនុស្ស។ ទស្សនៈនេះមើលឃើញអំណាចរបស់មនុស្សនៃការច្នៃបង្កើត និងប្រឌិតញាណ គឺជាកត្តារួមនៅក្នុងគ្រប់សកម្មភាពរបស់មនុស្ស។ នោះគឺការយល់ដឹងទង្វើនិងការបង្កើតរបស់ខ្លួននៅក្នុងគ្រប់ស្ថានភាព។ លោកពៀកស៍ (C.S. Pierce) និងចនដេវី (John Dewey) បង្ហាញពីសារសំខាន់នៃប្រឌិតញាណនេះថាជាអំណាចដែលប្រមើលមើលពីលទ្ធភាពក្នុងការច្នៃបង្កើតរបស់មនុស្សនិងការពង្រីកពុទ្ធិវិទ្យាសាស្ត្រ ។

## ៩.២.៦-ការប្រែប្រួលចរិតធម្មជាតិមនុស្ស

ចរិតធម្មជាតិរបស់មនុស្សអាចកែប្រែបាន។ ការផ្លាស់ប្តូរឬការកែប្រែធម្មជាតិរបស់មនុស្សនេះអាចប្រដូចបានទៅនឹងសារធាតុដែលអាចសូនបានដូចជាប្លាស្ទិច ដែលអាចត្រូវបានគេកែច្នៃជារាងពៅផ្សេងៗតាមដែលគេចង់បាន។ សាស្ត្រាចារ្យហុកគីង (Hocking) យល់ថា ធម្មជាតិរបស់មនុស្ស គ្មានអ្វីដែលគួរឱ្យសង្ស័យទេ គឺជាជ័រប្លាស្ទិចនៃពិភពមានជីវិតដែលអាចសម្របបាននិងអប់រំបាន។

## ៩.២.៧-មនុស្សជាភាវៈទំនាក់ទំនង

មនុស្សជាភាវៈទំនាក់ទំនងពីព្រោះគេមិនគ្រាន់តែទាក់ទងជាមួយមនុស្សដទៃទេ តែថែមទាំងទាក់ទងទៅនឹងភាវៈមានជីវិត ភាវៈគ្មានជីវិត ព្រឹត្តិការណ៍នានានិងទាក់ទងនឹងភាវៈខ្ពស់បំផុត (ឬព្រះអាទិទេព)ទៀតផង។ ជាភាវៈមានជីវិតមួយ មនុស្សខ្វល់ខ្វាយពីម្ហូបអាហារដើម្បីធំធាត់និងបន្តការរស់នៅ គេយកចិត្តទុកដាក់ពីសុខភាពនិងជម្រករបស់គេ។ ជាផ្នែកមួយនៃលំដាប់រូបសាស្ត្រធម្មជាតិមនុស្សត្រូវគោរពច្បាប់គីមីវិទ្យានិងរូបវិទ្យាជាដើម។ ក្នុងឋានៈជាភាវៈសង្គមជីវិតមនុស្សត្រូវគេរួមបញ្ចូលគ្នាជាមួយមនុស្សផ្សេងៗទៀតយ៉ាងជិតស្និទ្ធ។ ធម្មតាគេចំណាយជីវិតគេទាំងមូលផ្សារភ្ជាប់ជាមួយមនុស្សដទៃទៀតហើយគេជាសមាជិកសង្គមដែលត្រូវបានគេរៀបចំឡើងផ្សេងៗគ្នា។ ដើម្បីឱ្យការរស់នៅនិងសម្រាប់ជីវិតរបស់គេមានប្រយោជន៍មនុស្សត្រូវការអន្តរកម្មជាមួយមិត្តរបស់គេ។ គេត្រូវការមនុស្សផ្សេងទៀតដើម្បី ជួយគេ និងសរសើរពីសមិទ្ធផលរបស់គេ។ លោកទីទុសនិងស្មីតបញ្ជាក់ថា "ប្រសិនបើគេរស់នៅដាច់ដោយឡែកពីមនុស្សដទៃគឺគេគ្មានអភិវឌ្ឍអ្វីទាំងអស់ សូម្បី

តែកាសាក៏គ្មានដែរ។ គេមិនអាចរស់នៅដោយចាត់ទុកថាជីវិតល្អដោយផ្ដាច់ចេញទាំងស្រុងពីមិត្តរបស់គេនោះទេ។ សហគមន៍និងសង្គមធំធេងរបស់គេអាចដឹកនាំគេឱ្យសាងជីវិតប្រកបដោយខ្លឹមសារ ការឈឺចាប់និងសោកនាដកម្មផងដែរ។ ពុទ្ធិស្ដីពីអតីតកលរបស់មនុស្សមានតម្លៃមិនគ្រាន់តែក្នុងការយល់ដឹងនិងក្នុងការរស់នៅនាពេលបច្ចុប្បន្នប៉ុណ្ណោះទេ តែថែមទាំងក្នុងការធ្វើគម្រោងផែនការនិងការបង្កើតសម្រាប់អនាគតផងដែរ។ យោងតាមលោក ដេវី មនុស្សខុសពីសត្វដែលស្ថិតក្នុងថ្នាក់ទាបជាង ពីព្រោះមនុស្សថែរក្សាទុកនូវបទពិសោធន៍អតីតកាល អ្វីដែលបានកើតមានឡើងនៅអតីតកាលត្រូវគេធ្វើឱ្យរស់រវើកឡើងវិញនៅក្នុងការចងចាំរបស់គេ។ អ្វីៗដែលបន្តអត្ថិភាពសព្វថ្ងៃគឺបានពីការចងក្រងភាពរសាត់អណ្ដែតនៃការគិតដែលទាក់ទងទៅនឹងវត្ថុស្រដៀងគ្នាដែលបានទទួលក្នុងពេលកន្លងទៅហើយ។[4]

## ៥.២.៨-ទំនោធម្មជាតិរបស់មនុស្ស

ទំនោរបង្កើតតម្រូវការ ចំណង់ចំណូលចិត្តឧត្តមគតិ និងលោកទស្សនៈមានឥទ្ធិពលធំធេងដល់បុគ្គល គ្រួសារនិងសង្គមជាតិទាំងមូល។

ទំនោរ គឺជាចរិតលក្ខណៈនៃសភាវធម្មជាតិដែលធ្វើឱ្យមានចំណង់ក្នុងការគិតនិងប្រព្រឹត្តអ្វីមួយ។ វាជាប្រព័ន្ធនៃកម្លាំងចលករកំណត់អត្តចរិតសកម្មឬអំពើរបស់បុគ្គលនិងឥរិយាបថសង្គម។ ការព្យាយាមធ្វើគ្រប់មធ្យោបាយដើម្បីតម្រង់ទិសទៅរកវត្ថុបំណងណាមួយតែងតែជំរុញដោយកម្លាំងចលករផ្សេងៗនៃទំនោរ។ ឧទាហរណ៍៖ ការខិតខំព្យាយាមយកចិត្តទុកដាក់រៀនសូត្រ បណ្ដាលមកពីកម្លាំងចលករនៃការចង់ដឹងការពិត។ ចំណង់ចំណូលចិត្តក្នុងការងារគ្រូបង្រៀន ជំនឿចំពោះទង្វើល្អក្នុងវិស័យអប់រំ និងបំណងប្រាថ្នាផ្សេងៗទៀត ធ្វើឱ្យនិស្សិតសាស្ត្រាចារ្យ ខិតខំធ្វើឱ្យប្រសើរឡើងទៅតាមទស្សនៈនៃវិជ្ជាជីវៈរបស់ខ្លួន។ ក្នុងជីវភាពរស់នៅក្នុងសង្គម គេអាចចែកទំនោរជា៣ប្រភេទគឺ៖ ១) ទំនោរខាងសីលធម៌-នយោបាយ ២)ទំនោរខាងវិជ្ជាជីវៈ និង៣)ទំនោរបុគ្គល។

ទំនោរខាងសីលធម៌នយោបាយ ជាបាតុភូតចិត្តដែលស្ដែងឡើងជាចរិកពេញចិត្តប្រកាន់យកមនោគមវិជ្ជានយោបាយ ស្ថិរភាពនយោបាយ ភាពស្មោះត្រង់ចំពោះមាតុភូមិ និងកក្ដីភាពចំពោះស្នាដៃកសាងសង្គមថ្មី។ ទំនោរខាងវិជ្ជាជីវៈ ជាទំនោរដែលស្ដែងចេញឱ្យឃើញនូវភាពស្វាហាប់ក្នុងការដក់ចិត្តជាប់នឹងមុខរបរណាមួយ ដែលបុគ្គលប្រាថ្នាចង់ធ្វើនិងចង់បាន។ ទំនោរបុគ្គល(ឬទំនោរខាងជីវភាពរស់នៅរបស់បុគ្គល) ជាបាតុភូតចិត្ត ពេញដោយបំណងប្រាថ្នារបស់បុគ្គល ទៅលើឧបករណ៍សម្ភារៈ វប្បធម៌

[4] ក្រុមសាស្ត្រាចារ្យសាកលវិទ្យាល័យ បៀលប្រាយ ៖ មនុស្សនិងសង្គម ភ្នំពេញ ឆ្នាំ២០១៣, ទំព័រ ៣៣

និងសីលវិជ្ជា។ ទំនោរនេះអាចកើតមានព្រមគ្នានឹងទំនោរវិជ្ជាជីវៈ និងទំនោរសីលធម៌នយោបាយដែរ។

ទំនោរបុគ្គលគឺជាសភាពចិត្តមានលក្ខណៈស្មុគស្មាញ។វាមានជាតុផ្សេងៗគ្នាជាច្រើនផ្សារភ្ជាប់គ្នា។ ជាតុទាំងនោះរួមមាន បំណងប្រាថ្នា ការគិត ឬការស្រមៃ ចំណង់ចំណូលចិត្ត ការលំអៀង ឧត្តមគតិ ទស្សនៈ និងជំនឿ។ ជាតុទាំងនោះអភិវឌ្ឍពីកម្រិតទាបទៅកម្រិតខ្ពស់ ដោយយោងទៅតាមកម្លាំងនៃវត្ថុបំណង ទស្សនៈនៃសញ្ចេតនា ការជំរុញឱ្យមានទង្វើ និងការកំណត់បាននូវសច្ចភាពនៅក្នុងជីវភាពរបស់បុគ្គល។

ទំនោរបុគ្គលអាស្រ័យលើគុណសម្បត្តិទាំងឡាយដូចជាៈ ១.កម្រិតអាយុទំនោរ ២.ទំហំទំនោរ ៣.ឥទ្ធិពលទំនោរ ៤.ស្ថិរភាពសីលធម៌ទំនោរ និង ៦.ប្រសិទ្ធភាពទំនោរ។ កម្រិតអាយុទំនោរកំណត់នូវបំណងប្រាថ្នាដែលជាមូលដ្ឋានឧត្តមគតិនៃបុគ្គលម្នាក់ៗ ដែលទាក់ទងនឹងកម្រិតមនោគមវិជ្ជា និងទម្រង់សីលធម៌របស់បុគ្គលដែរ។ ទំហំទំនោរគឺជាលទ្ធភាពបង្កើតអ្វីមួយទៅតាមបំណងប្រាថ្នារបស់បុគ្គល។ ឥទ្ធិពលទំនោរ គឺជាកម្លាំងថាមពលធំធេងមួយដែលអាចកែប្រែបំណងប្រាថ្នាឱ្យក្លាយជាឆន្ទៈភ្ញាក់រលឹកសកម្មដ៏និងផុះផុល។ ស្ថិរភាពសីលធម៌ទំនោរ គឺជាភាពគង់វង្សនៃមនោរគមវិជ្ជា ដែលទ្រទ្រង់បុគ្គលមិនឱ្យឃ្លីងឃ្លោងនិងជៀសផុតពីទំនាស់ខាងសីលធម៌នៅក្នុងបុគ្គលខ្លួនឯង។ ចំណែកប្រសិទ្ធភាពទំនោរ គស្តុតាងដែលស្តែងឱ្យឃើញនៅក្នុងឥរិយាបថវិជ្ជមានរបស់បុគ្គលនៅពេលសម្រេចតាមបំណងប្រាថ្នា។ ប្រសិទ្ធភាពនៃទំនោរបែបនេះ មានបន្ទាស់ប្តូរមនោគមវិជ្ជារបស់បុគ្គល ឈានទៅរកភាពទាន់សម័យ។

ជាទូទៅគុណសម្បត្តិនៃទំនោរបុគ្គលមានប្រយោជន៍ច្រើនក្នុងរចនាសម្ព័ន្ធនៃបុគ្គលិកលក្ខណៈរបស់មនុស្ស។ គុណសម្បត្តិនេះ អាចសម្គាល់តាមរយៈទឹកមុខ ឬកាយវិការ។ សកម្មភាព និងអំពើដែលប្រកបដោយសីលធម៌ និងតម្លៃសង្គមរបស់បុគ្គលម្នាក់ៗគឺជាគុណសម្បត្តិនៃទំនោរបុគ្គល។ ហេតុដូច្នេះ ភារកិច្ចចម្បងចាំបាច់បំផុតនៅក្នុងវិស័យអប់រំគឺការបណ្តុះបណ្តាលធនធានមនុស្សឱ្យក្លាយជាពលរដ្ឋល្អដែលមានទំនោរវិជ្ជាជីវៈប្រកបដោយស្ថិរភាពរឹងមាំ កម្លាំងខ្លាំងក្លា និងប្រសិទ្ធភាពខ្ពស់។

ទំនោររបស់មនុស្ស ស្តែងឱ្យឃើញសារៈសំខាន់ក្រោមទិដ្ឋភាពនៃតម្រូវការ ចំណង់ចំណូលចិត្ត ឧត្តមគតិ និងលោកទស្សនៈរបស់បុគ្គល។ ទិដ្ឋភាពនៃតម្រូវការគឺជាកត្តាចាំបាច់ដើម្បីអត្ថិភាពនិងអភិវឌ្ឍជីវិតបុគ្គល។ ដើម្បីអត្ថិភាពគេប្រឹងប្រែងបំពេញតម្រូវការចាំបាច់មួយចំនួនដូចជា តម្រូវការម្ហូបអាហារ ទីជម្រកសម្លៀកបំពាក់ ការសិក្សា ទំនាក់ទំនង និងតម្រូវការផ្សេងៗទៀត។ ទិដ្ឋភាពនៃចំណង់ចំណូលចិត្តរបស់បុគ្គល គឺជាឥរិយាបថរបស់បុគ្គលនោះចំពោះវត្ថុដែលមានអត្ថន័យសំខាន់ក្នុងការផ្តល់

លទ្ធភាពធ្វើឱ្យសប្បាយរីករាយ និងពេញចិត្ត សម្រាប់ការរស់នៅរបស់ខ្លួន។ ទិដ្ឋភាពនៃឧត្តមគតិ គឺជាបំណងដ៏ថ្លៃថ្នូរ ដែលឆ្លុះបញ្ចាំងឱ្យឃើញនៅក្នុងមនសិការរបស់មនុស្សក្រោមទម្រង់នៃរូបតំណាងដ៏ល្អឥតខ្ចោះនិងជាគំរូដ៏ល្អប្រពៃ ដែលមានអានុភាពទាក់ទាញរាល់កម្លាំងទ្រទ្រង់ជីវិតបុគ្គលក្នុងការសម្រេចបានតាមបំណងក្នុងរយៈពេលមួយដ៏យូរ។ ចំណែកឯទិដ្ឋភាពនៃលោកទស្សនៈវិញគឺជាសំណុំនៃការយល់ដឹង ឬទស្សនៈរបស់បុគ្គលណាម្នាក់ ស្តីពីបាតុភូតធម្មជាតិ បាតុភូតសង្គម និងអំពើនៃសកម្មភាពរបស់ខ្លួន។ ការបណ្តុះបណ្តាល និងការពង្រីកលោកទស្សនៈរបស់សិស្ស គឺជាភារៈដ៏សំខាន់របស់គ្រូ អាណាព្យាបាល និងសង្គម។ និន្នាការ ឬទំនោររបស់បុគ្គល គឺជាលក្ខណៈចិត្តដែលមានមូលដ្ឋានត្រឹមត្រូវ ហើយវាជាស្នូលនៃជីវិតផ្លូវចិត្តរបស់បុគ្គល។ និន្នាការនេះ បំពេញតួនាទីជាកម្លាំងចលករដាច់ខាត ដែលកំណត់បាននូវចរិតសកម្ម និងជម្រើសឥរិយាបថរបស់បុគ្គលចំពោះតថភាព។ ទំនោរនេះ ស្តែងចេញឱ្យឃើញតាមរយៈតម្រូវការ ចំណង់ចំណូលចិត្ត ឧត្តមគតិ និងលោកទស្សនៈរបស់បុគ្គលម្នាក់ៗ។ ការពង្រឹង និងការបណ្តុះទំនោរតាមគ្រប់រូបភាពជាពិសេសស ឧត្តមគតិ និងលោកទស្សនៈ គឺជាភារៈមួយយ៉ាងសំខាន់របស់ក្រសួងអប់រំជាពិសេស សាលារៀនមធ្យមសិក្សា ក្នុងការបណ្តុះបណ្តាលធនធានមនុស្សទៅតាមតម្រូវការរបស់សង្គម។

## ៦-រចនាសម្ព័ន្ធក្រុមមនុស្សក្នុងសង្គម

សង្គមវិទូអាមេរិក លោក ឆាល ហ៊ រថុន ខូឡៃ (Charles Horton Cooley ១៨៦៤-១៩២៩) ដែលសិក្សាពីសង្គមមនុស្ស បានផ្តល់ទស្សនៈថា បុគ្គលម្នាក់ៗមានទំនាក់ទំនងគ្នាជាអន្តរកម្មសង្គម ដែលលោកហៅថាក្រុម។ លោកបែងចែកមនុស្សក្នុងសង្គមមានបីក្រុមៈ ១.ក្រុមគ្រួសារ ២.ក្រុមញាតិមិត្ត ៣.ក្រុមការងារ។

## ៧-ដំណើរការសង្គម

ដំណើរការសង្គមគឺជាទម្រង់ឥរិយាបថនៃរចនាសម្ព័ន្ធក្រុមមនុស្ស ដែលកើតឡើងនៅក្នុងជីវភាពប្រចាំថ្ងៃរបស់សង្គម។ វាជា "គំរូនៃឥរិយាបថសង្គម ឬអន្តរកម្មសង្គមកើតមានជាប់លាប់ ហើយវាអាចក្លាយជាអត្តសញ្ញាណ របស់សង្គមមួយ"[5]។ ដំណើរការសង្គមចែកជាពីរផ្នែក គឺៈ ១.ដំណើរការសង្គមឯកភាព និង ២.ដំណើរការសង្គមមិនឯកភាព។ ដំណើរការសង្គមឯកភាព គឺជាអំពើនិងសកម្មភាពដែលបង្កើតឱ្យមានការសហការ សមាហរណកម្ម ការយល់ចិត្តគ្នា និងមានឯកភាពគ្នា។ ទម្រង់នៃអន្តរកម្មសង្គមបែបនេះ នាំសមាជិក និងក្រុមក្នុងសង្គមឱ្យមានឯកភាពគ្នា យោគយល់គ្នា ការជួយគ្នាទៅវិញ

[5] Horton & Hunt, *Sociology and Society*, 1968, p. 53

ទៅមក ធ្វើឱ្យមានការចុះសម្រុងគ្នា និងការកាត់បន្ថយរាល់ការលំបាកទាំងឡាយ ហើយនាំមកនូវទំនាក់ទំនងសង្គមមួយដែលល្អប្រសើរ។

ចំណែក ដំណើរការសង្គមមិនឯកភាពគឺជាដំណើរការប្រកួតប្រជែងនិងទំនាស់។ ទម្រង់នៃអន្តរកម្មសង្គមបែបនេះ ត្រូវគេចាត់ទុកថាជាអន្តរកម្មបែបអវិជ្ជមានពីព្រោះវាបានបង្ការអ្នកដទៃមិនចូលរួមសម្រេចបំណងប្រាថ្នានៅទីបញ្ចប់។ ទម្រង់នៃអន្តរកម្មសង្គមបែបនេះបង្កើតឱ្យមានការបែកបាក់សាមគ្គី ឬទាស់ទែងគ្នាច្រើនជាងការចុះសម្រុង និងឯកភាពគ្នា។

### ៨-គណបក្សនយោបាយក្នុងសង្គម

មនុស្សដែលរស់នៅក្នុងសង្គមនិមួយៗតែងតែមានទស្សនៈផ្សេងៗគ្នា អំពីដំណើរការការពារ និងអភិវឌ្ឍន៍សង្គមរបស់ខ្លួន តាមរបៀបខុសៗគ្នា ដោយជៀសមិនរួច។ ទស្សនៈទាំងនេះអាចត្រូវបានប្រមូលផ្តុំក្នុងអង្គការចាត់តាំងឬគណបក្សនយោបាយនានា ដែលត្រូវបង្កើតឡើងដើម្បីរួមកម្លាំងតស៊ូមតិតទល់នឹងគណបក្សមួយទៀតដើម្បីមានឥទ្ធិពលអនុវត្តន៍ទស្សនៈគំនិតរបស់ខ្លួន។

គោលបំណងនៃគណបក្សនយោបាយគឺដើម្បីដណ្តើមយកតួនាទីដឹកនាំគ្រប់គ្រងរដ្ឋាភិបាល ដែលធម្មតាធ្វើឡើងតាមរយៈការបោះឆ្នោត។ គណបក្សនយោបាយ នីមួយៗមានមុខងារសំខាន់ក្នុងការជ្រើសរើសជនជានមនុស្សសម្រាប់តួនាទីក្នុងរចនាសម្ពន្ធនៃការដឹកនាំនិងការប្រព្រឹត្តិទៅនៃរដ្ឋាភិបាល។ ទោះបីជាប់បានឬមិនបានជាប់ឆ្នោត បានដឹកនាំរដ្ឋាភិបាលក៏ដោយ ក៏គណបក្សមានភារកិច្ច តាក់តែង និងអនុវត្តគោលនយោបាយរបស់ខ្លួនដើម្បីបម្រើប្រយោជន៍សាធារណជន និង ភ្ជាប់ទំនាក់ទំនងរវាងពលរដ្ឋទៅនឹងស្ថាប័នរដ្ឋ។

ជាទូទៅ គណបក្សនយោបាយមានអាយុកាលដូចប្រព័ន្ធនយោបាយដឹកនាំរដ្ឋដែរ។

គណបក្សនយោបាយមានទម្រង់ផ្សេងៗគ្នា។ គណបក្សខ្លះត្រូវបានរៀបចំឡើងដើម្បីគាំទ្រក្រុមឥស្សរជននយោបាយណាមួយ ក្នុងគោលបំណងជំរុញគោលនយោបាយដោយឡែកឬជំហរមនោគមន៍វិជ្ជាណាមួយ ផ្តល់ជាជំនួយដល់ក្រុមឬផ្នែកនៃសង្គមដ៏ជាក់លាក់ណាមួយ។ គណបក្សនយោបាយ ត្រូវបានបង្កើតឡើងតាមវិធីជាច្រើនខុសៗគ្នា។ គណបក្សនយោបាយខ្លះ ប្រគល់អំណាចត្រួតត្រាឱ្យស្ថិតក្នុងកណ្តាប់ដៃក្រុមឆ្នើមនៃគណៈកម្មការកណ្តាលដែលត្រូវបានជ្រើសតាំងឱ្យ ស្ថិតនៅក្នុងតំណែងជារៀងរហូត ក្នុងខណៈពេលដែលគណបក្សនយោបាយខ្លះទៀត ធ្វើវិមជ្ឈការអំណាច ដើម្បីជ្រើសរើសបេក្ខជននិងធ្វើសេចក្តីសំរេចចិត្តនៅអង្គភាពបក្សថ្នាក់មូលដ្ឋាន។

នាសតវត្សនេះ បណ្តាសង្គមជាតិជាច្រើនក្នុងពិភពលោក មានគណបក្សនយោបាយជឿនលឿនជាច្រើនត្រូវបានបង្កើតឡើងប្រកបដោយ

ភាពចាស់ទុំនយោបាយ ដែលស្របនឹងសម្ទុះកើនឡើងនៃមនោគមវិជ្ជាប្រជាធិបតេយ្យ ។ ការយល់ដឹងនិងការឱ្យតម្លៃលើយន្តការនៃការបោះឆ្នោតជាសកល ដោយសេរី ស្មើភាព តម្លាភាព និងយុត្តិធម៌ដើម្បីផ្លាស់ប្តូរ ឬរក្សាទុកនូវអង្គការចាត់តាំងឬក្បាលម៉ាស៊ីនដឹកនាំរដ្ឋ[6] គឺភាគច្រើនស្ថិតនៅលើឥទ្ធិពលនៃការឃោសនាអំពីការការពារអត្តសញ្ញាណជាតិស្របតាមវប្បធម៌និងការរីកចម្រើនជឿនលឿន ព្រមទាំងស្ថិតនៅលើឥទ្ធិពលនៃប្រសិទ្ធភាពនៃមធ្យោបាយផ្សព្វផ្សផ្សាយព័ត៌មាននិងសារគមនាគមន៍ដែលបាននិងកំពុងមានប្រជាប្រិយភាពកើនឡើងឥតឈប់ឈរ។ នៅក្នុងការប្រកួតប្រជែង អាចមានប្រព័ន្ធបក្សពីរ និងប្រព័ន្ធពហុបក្ស។ យុទ្ធសាស្ត្ររបស់គណបក្សនីមួយៗនៃប្រពន្ធ័បក្សពីរ ច្រើនមានភាពសម្របសម្រួល សំដៅធ្វើយ៉ាងណាឱ្យទទួលបានការគាំទ្រភាគច្រើនដាច់ខាត(៥០%បូក១)។ ចំណែកនៅក្នុងប្រព័ន្ធពហុបក្សលើសពីរ ភាពសម្របសម្រួលមានតិចជាង ហើយយុទ្ធសាស្ត្ររបស់គណបក្សគឺសង្កត់ធ្ងន់ទៅលើការរក្សាទុកឱ្យបាននូវការគាំទ្រនៃអ្នកបោះឆ្នោតគន្លឹះ ។

ដោយឡែកនៅក្នុងសង្គមឬប្រទេសដែលមានប្រព័ន្ធដឹកនាំដោយមានគណបក្សតែមួយ ឬប្រព័ន្ធមិនប្រកួតប្រជែង ជាធម្មតា គណបក្សតែងដើរតួនាទីជាឧបករណ៍របស់រដ្ឋ ក៏ដូចជារបស់រដ្ឋាភិបាល។ ក្នុងស្ថានភាពនេះ គណបក្សនយោបាយមានមុខនាទី ធ្វើយ៉ាងណារក្សាឱ្យបាននូវការគាំទ្រពីសាធារណជនចំពោះរបបដឹកនាំគ្រប់គ្រងរបស់ខ្លួន និងខំប្រឹងប្រែងលើកទឹកចិត្តប្រជាជនឱ្យចូលរួមក្នុងកម្មវិធីរដ្ឋាភិបាល និងផ្តល់សញ្ញាឱ្យរដ្ឋាភិបាលដោយធ្វើការផ្លាស់ប្តូរមតិជាសាធារណៈជារឿយៗតាមតែអាចធ្វើបានជាជាងការបំភិតបំភ័យនិងគាបសង្កត់ ដើម្បីបញ្ជៀសហារនិភ័យទាំងឡាយនៃការតស៊ូបដិវត្តរបស់ប្រជាជនជាយថាហេតុ។

ជាទូទៅរចនាសម្ព័ន្ធ និងអាកប្បកិរិយានៃគណបក្សនយោបាយក្នុងប្រទេសនីមួយៗ មានលក្ខណៈផ្សេងគ្នា អាស្រ័យជាសំខាន់លើគោលនយោបាយ និងលក្ខណៈប្រវត្តិសាស្ត្រ វប្បធម៌របស់ប្រទេសឬសង្គមនីមួយៗ។

## ៩-សង្គមកិច្ច និង វប្បធម៌ នៃសង្គម

សង្គមកិច្ច និង វប្បធម៌ គឺជាកត្តាចាំបាច់សម្រាប់ទ្រទ្រង់សង្គមមួយឲ្យមានសុខុមាលភាព សន្តិសុខ សណ្តាប់ របៀបរបរយ និងចម្រើនរុងរឿង។ សង្គមកិច្ច គឺជាអន្តរកម្មនៃសញ្ចេតនានិងកាតព្វកិច្ចការងាររបស់មនុស្សក្នុងសង្គមដែលត្រូវជួយសង្គ្រោះគ្នាទៅវិញទៅមក។ អ្នកមានលទ្ធភាពមានកាតព្វកិច្ចជួយចិញ្ចឹមថែរក្សាការពារអ្នកដទៃទៀតដែលទន់ខ្សោយ។ ក្នុងន័យនេះ

[6] អង្គការចាត់តាំង ឬក្បាលម៉ាស៊ីនដឹកនាំរដ្ឋ ជាស្ថាប័នរដ្ឋាភិបាលដែលមាននាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ ការបរទេស មហាផ្ទៃ សេដ្ឋកិច្ច ហិរញ្ញវត្ថុ អប់រំនិងកីឡា យុត្តិធម៌ ជាដើម។

ឪពុកម្តាយមានកាតព្វកិច្ចចិញ្ចឹមកូនដែលជាអនីតិជន លុះកូនធំ កូនមានករណីកិច្ចទទួលចិញ្ចឹមឪពុកម្តាយ ដែលចាស់ជរាវិញ។ អ្នកមានជំនាញវិជ្ជាជីវៈត្រូវជួយយិតយោងដោយផ្គត់ផ្គង់ចិញ្ចឹម សង្គ្រោះអ្នកក្រខ្សត់និងអ្នកសិក្សា និងជួយចូលរួមរក្សាថែរក្សាវិន័យសណ្តាប់ធ្នាប់សង្គម។

សង្គមកិច្ច គឺកិច្ចការទាំងឡាយក្នុងសង្គមដែលមានគោលដៅបម្រើផលប្រយោជន៍រួម។ ការចែកដីធ្លី ផ្ទះសម្បែង ការលើកផ្លូវថ្នល់ ការសង់ស្ពាន សាលារៀន មន្ទីរពេទ្យ ការជួយសង្គ្រោះជនរងគ្រោះដោយសង្គ្រាមឬដោយហានិភ័យធម្មជាតិ ការបង្ក្រាបល្បែងស៊ីសង ការបង្ក្រាបនិងកម្ចាត់ជនទុច្ចរិតជាដើម សុទ្ធតែជា កិច្ចការសម្រាប់សម្រាលទុក្ខវេទនាមនុស្សក្នុងសង្គម និងផ្តល់សេចក្តីស្រណុកសុខស្រួលដល់ពលរដ្ឋនៃសង្គមនេះទៀតផង ។

ចំណែកវប្បធម៌វិញ ក៏ជាកត្តាមួយជះឥទ្ធិពលស្មើរតែទាំងស្រុងទៅលើសកម្មភាព និងវិបាកនានានៃសមាជិកសង្គម ។ វប្បធម៌ ពិតជាបានជះឥទ្ធិពលដល់ការគិត ការសំដែងមនោសញ្ចេតនា ការបញ្ចេញឥរិយបថ ការជ្រើសរើសរបៀបរស់នៅជាដើម ។ មរតកវប្បធម៌តែងមានឥទ្ធិគ្របដណ្តប់ទៅលើទំនៀមទម្លាប់ ប្រពៃណីជំនឿ សាសនា ភាសា និងរបៀបរបបរស់នៅផ្ទាល់ខ្លួនក្នុងជីវភាពប្រចាំថ្ងៃ។ វប្បធម៌ គឺជាការសរុបរាល់អ្វីៗដែលយើងអាចរៀនសូត្រតាមរយៈការរស់នៅក្នុងក្រុម ឬសង្គមមួយជាមួយគ្នា។ លោក ប្រ៊ីនឃឺសហ្វ (Brinkersoff) អះអាងថា វប្បធម៌ គឺជារបៀបរបបនៃការរស់នៅរួមរបស់មនុស្ស ដែលត្រូវបានសមាជិកសង្គមរួមគ្នាបង្កើតឡើង(វប្បធម៌រូបី) និងគំរូនៃការគិត ការមានអារម្មណ៍ និងទង្វើដដែលៗ (វប្បធម៌អរូបី)។ រីឯ លោកភឺសែល (Persell )បានពិពណ៌នាវប្បធម៌ថាជា "ឥរិយាបថទាំងឡាយដែលមនុស្សបានរៀនពីសង្គម ដូចជា ជំនឿ អារម្មណ៍ និងតម្លៃដែលជាបទពិសោធន៍របស់ក្រុម ឬសង្គមមួយផ្តល់ឱ្យដល់សមាជិករបស់គេ។ ចំណែកលោក ហ៊រថុន និង ហ័ន្ទ(Horton &Hunt) បានអះអាងថា វប្បធម៌ គឺជាប្រព័ន្ធមួយដែលបរិយាយយ៉ាងល្អិតល្អន់អំពី ស្តង់ដាដែលគេរំពឹងទុកទៅលើរបៀបរបបនៃការមានអារម្មណ៍ និងរបៀបនៃការប្រព្រឹត្តរបស់សមាជិកដែលសង្គមទទួលស្គាល់ និងត្រូវបានសមាជិករបស់សង្គមអនុវត្តតាមជាទូទៅ។

សង្គមដែលគ្មានវប្បធម៌ គឺជាសង្គមដែលគ្មានអត្តសញ្ញាណ ហើយជាសង្គមមួយដែលងាយនឹងបាត់បង់។ ក្នុងន័យនេះ ពលរដ្ឋខ្មែរតែងពោលថា វប្បធម៌រលត់ជាតិរលាយ វប្បធម៌ពណ្ណរាយជាតិថ្កើងថ្កាន។

## សេចក្តីសន្និដ្ឋាន

ទស្សនវិជ្ជាសង្គមបានដោះបញ្ហារបស់មនុស្សប្រកបដោយវិចារណញ្ញាណ ពីជំនាន់

មួយទៅជំនាន់ៗ ទស្សនវិទូពិចារណាផ្អែកលើហេតុផលដើម្បីស្វែងរកសច្ចភាពនិងប្រយោជន៍ សេចក្ដីសុខចម្រើន សុភមង្គល ដល់សង្គមមនុស្ស។ ទស្សនវិទូសង្គម យកចិត្តទុកដាក់ខ្លាំងលើប្រយោជន៍មនុស្សក្នុងសង្គមច្រើនជាងសច្ចភាពបរានុម័តិ។

សង្គមមួយអាចផ្ដល់គុណភាពជីវិតដល់បុគ្គល, គូស្វាមីភរិយា, គ្រួសារ, ក្រុម, និងសហគមន៍បានលុះត្រាតែ រៀបចំសង្គមកិច្ចបានល្អ ដោយចេះរៀបចំធ្វើផែនការ គោលនយោបាយ អភិវឌ្ឍសហគមន៍ដោយដោះស្រាយជីវភាពរស់នៅទាំងចំណីអាហារ សម្លៀកបំពាក់ ទីជម្រក និងអន្តរាគមន៍ដោះស្រាយវិបត្តិនានា ដើម្បីជានាសុខុមាលភាពសង្គមនិងសន្តិសុខប្រកបដោយយុត្តិធម៌ ដោយផ្ដោតលើវិស័យសំខាន់ៗ ដូចជា រដ្ឋបាល សេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ អប់រំ សីលធម៌ ច្បាប់ សុខាភិបាល និង នយោបាយជាដើម។ ម្យ៉ាងទៀត សង្គមមួយអាចដំណើរការបានល្អ លុះត្រាសមាជិកសង្គមទាំងអស់រួបរួមសាមគ្គីគ្នាប្រកបដោយគុណធម៌ គឺមានព្រហ្មវិហារធម៌ សុចរិតធម៌ និងចេះអធ្យាស្រ័យ សន្ដោសប្រោសប្រណី សមដូចពាក្យស្លោកខ្មែរថា ឈើកោងធ្វើកង់ ឈើត្រង់ធ្វើកាំ ជាដើម ។

**ឯកសារយោង/គន្ថនិទ្ទេស**


១-ជួន ណាត : *វចនានុក្រមខ្មែរ* ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ បោះពុម្ពលើកទី៥ ឆ្នាំ១៩៦៧

២-លី ជានី និងអ្នកផ្សេងទៀត : *ទស្សនវិជ្ជា* ភ្នំពេញ វិទ្យាស្ថានជាតិ ខេមរយានកម្ម ឆ្នាំ១៩៧៣

៣-សុង ស៊ីវ : *ចលនាអារ្យធម៌* ភ្នំពេញ ១៩៧១

៤- សាកលវិទ្យាល័យ បៀលប្រាយ : *មនុស្សនិងសង្គម* ភ្នំពេញ ឆ្នាំ២០១៣

# របបមាតាធិបតេយ្យក្នុងសង្គមខ្មែរ

ដោយៈ **លោក ឈុន ផាវ៉េង**
មន្ត្រីនាយកដ្ឋានទស្សនវិជ្ជា និង សង្គមវិទ្យា
នៃវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម
រាជបណ្ឌិត្យសភាកម្ពុជា

## ១. សេចក្តីផ្តើម

ចាប់តាំងពីសម័យដើមនៃប្រវត្តិសាស្ត្ររហូតមកដល់សព្វថ្ងៃនេះ ឥទ្ធិពលនៃព្រលឹងមាតាធិបតេយ្យ បានរស់រវើកនៅក្នុងសង្គមខ្មែរ ទោះបីកាលៈទេសៈខ្លះបានធ្លាក់ចុះឥទ្ធិពលរបស់ខ្លួនក៏ដោយ។ ព្រលឹងមាតាធិបតេយ្យដែលមានក្នុងវប្បធម៌ខ្មែរនឹងបន្តអនុវត្តទស្សនៈយេនឌ័រ ដែលតែងតែអប់រំបុរសស្ត្រី ទទួលយកតួនាទីភារកិច្ចជាគ្រួសារល្អ ញាតិមិត្តល្អ និងពលរដ្ឋល្អ។ ស្ត្រីខ្លួនត្រូវដឹងពង្រីកពង្រឹងគុណភាពធនធានមនុស្សរបស់ខ្លួនឲ្យកាន់តែប្រសើរ។ ស្ត្រីគួរតែឆ្លងកាត់ការអប់រំសីលធម៌និងវិជ្ជាមេផ្ទះពីគ្រួសារនិងមុខវិជ្ជាសង្គមផ្សេងៗដើម្បីសក្តិសមជាមាតា ជាដៃគូដ៏ល្អរបស់ប្តី និងសង្គមជាតិ។

ប្រជារាស្ត្រខ្មែរ ចាត់ទុកព្រលឹងមាតាធិបតេយ្យជារបៀបរៀបរយមួយនាំឲ្យសុខចម្រើន ព្រមទាំងនាំគ្នាខំជួយថែរក្សាការពារ ដោយប្រតិបត្តិតាមជំនឿទំនៀមទម្លាប់ប្រពៃណី អក្សរសាស្ត្រ វប្បធម៌ និងសង្គមធម៌ ជាដើម។ ទន្ទឹមនេះដែរ របបបិតាតេយ្យនិងទស្សនៈយេនឌ័រ ក៏បាននឹងកំពុងផ្សព្វផ្សាយយ៉ាងសកម្ម ក្នុងជីវភាពរស់នៅក្នុងសង្គមខ្មែរតាំងពីអតីតកាលរហូតដល់បច្ចុប្បន្នដែរ ដោយទស្សនៈជំនឿនៃជនអន្តោប្រវេសន៍ និងឥទ្ធិពលនៃប្រព័ន្ធផ្សព្វផ្សាយនានា។ លទ្ធិទាំងពីរក្រោយនេះបានត្រូវប្រត្តិប្រតិបត្តិដោយជនបរទេសដែលមានវប្បធម៌ផ្អែកលើគំនិតសាសនាខុសពីវប្បធម៌ខ្មែរដែលប្រកាន់របបមាតាធិបតេយ្យតាំងពីយូរយាណាស់មកហើយដែរ។ ប្រឈមនឹងឥទ្ធិពលបិតាធិបតេយ្យ និងយេនឌ័រ តើរបបមាតាធិបតេយ្យមានជំហរដូចម្តេច? អត្ថបទនេះនឹងបង្ហាញអំពី អត្ថន័យ, ប្រវត្តិ, និង ឥទ្ធិពល នៃរបបមាតាធិបតយ្យខ្មែរ តាមរយៈវប្បធម៌ និងសង្គមធម៌ខ្មែរ ដូចតទៅៈ

## ២. និយមន័យរបបមាតាធិបតេយ្យ

របបមាតាធិបតេយ្យចេញមកពីពាក្យបីម៉ាត់គឺ ៖ របប (ន.) របៀបរៀបរយ, សណ្តាប់ធ្នាប់។

*មាតា (អានថា មាដា) បា.; សំ.(ន.) (< មាតុ,) ម្ដាយ, ម៉ែ, មេ, ចំណែកពាក្យ អធិបតេយ្យ (អានថា អៈធិប៉ៈតៃ) បា.(ន.) អធិបតីភាព, "ភាវៈនៃ...ជាអធិបតី" ឬ ភាពជាអ្នកធំ ឬភាពជាម្ចាស់ ឬភាពជាឥស្សរជន។*

*ដូច្នេះអាចកំណត់បានថា របបមាតាធិបតេយ្យមានន័យថា របៀបរៀបរយដែលកំណត់យកភាពនៃម្ដាយជាធំលើសគេ។ និយាយដោយខ្លីថា របៀបដែលចាត់ទុកមេជាធំ ឬថា លទ្ធិដែលចាត់ទុកស្ត្រីជាធំ ជាអ្នកដឹកនាំ ជាមេ។*

*មាតាធិបតេយ្យមានន័យថា មាតាអធិបតីភាពនៃម្ដាយជាធំ ម្ចាស់លើគេជាប្រមុខជាប្រធាន។ ក្នុងន័យទូលាយមាតាធិបតេយ្យជារបបមួយដែលឱ្យតម្លៃទៅលើម្ដាយក្នុងការដឹកនាំគ្រួសារ សង្គមទាំងមូល ។ ដូនកាល គេនិយមប្រើពាក្យមេដែលមានន័យថា យកមជាធំក្នុងគ្រួសារនិងសង្គម[1]។*

## ៣. អត្ថន័យនៃពាក្យ មេ

*ពាក្យ មេ នៅក្នុងវប្បធម៌ខ្មែរបានក្លាយជាន័យពិសេស សម្រាប់អ្នកដែលមាននាទីសំខាន់ក្នុងការគ្រប់គ្រងក្នុងផ្ទះ ក្នុងសហគមន៍ ក្នុងប្រទេស ដែលហៅថា មេដឹកនាំ។ លើសពីនេះ មេសម្គាល់លើមនុស្សសត្វឬអ្វីដែលជាធំ ជាប្រធានជាចម្បងលើគេ ដូចជា មេកង មេពួក មេការ មេកោយ មេផ្ទះ មេវត្ត មេក្រុម ឬ មេគណ មេទ័ព មេទាហាន មេព្រៃ មេខ្លោង មេចង្ហាន់ មេចោរ មេជើង មេដែក មេដៃ មេដំបូល មេទឹក មេបទ មេបន្ទុក មេពាក្យ មេលេខ មេសូត្រ។ល។*

*មេ(ន.) ម្ដាយ, អ្នកបង្កើត, ឬសំដៅលើមនុស្សសត្វ ឬអ្វីដែលជាធំ, ជាប្រធាន, ជាចម្បងលើគេ ដូចជា៖*

*មេការ អ្នកដែលជាមេលើកិច្ចការនីមួយៗ។*

*មេក្រាន មេចង្ក្រាន គឺមេគ្រួឬមេផ្ទះមួយៗ របស់ជាតិពន្ធុ (ជនជាតិដើមភាគតិច) ព្នង គឺខ្មែរលើសព្វថ្ងៃនេះ។*

*មេក្រុម ឬ មេគណៈ អ្នកដែលជាប្រធានលើក្រុម ឬពួកមួយៗ។*

*មេខ្លោង មនុស្សដែលមានរូបរាងធំខ្ពស់ជ្រងោ កាលបើដើរចេញទៅណាឃើញចង្ក្រោងជាងគេរាល់គ្នា។*

*មេគណ (-មេគន់) មន្ត្រីសង្ឃដែលមានសមណស័ក្តិខ្ពស់ជាងអនុគណគ្រប់ស្រុកក្នុងខេត្ត។*

*មេគយ អធិបតីក្នុងរាជការគយ។*

*មេគ្រែ ឈើបួនកំណាត់ដែលផ្គុំភ្ជាប់នឹងគ្រែ។*

*មេចង្ហាន់ ស្ត្រីអ្នកផ្គត់ផ្គង់ចង្ហាន់។*

[1] *ក្រសួងអប់រំយុវជននិងកីឡា, សិក្សាសង្គមថ្នាក់ទី១០, គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ, បោះពុម្ពលើកទី៦ ឆ្នាំ ២០១៥, ភ្នំពេញ, ទំព័រ ២៣៩*

មេចោរ ចោរដែលជាប្រធានលើអស់ចោរក្នុងពួកណាមួយ ។

មេជើង មេម្រាមជើង គឺម្រាមជើងដែលធំជាងគេ។

មេដៃ មេម្រាមដៃ គឺម្រាមដៃដែលធំជាងគេ។

មេដែក ដែកមួយប្រភេទដែលស្រូបដែកដទៃបាន។

មេដំបូល មេរបស់ដំបូល គឺឈើដាក់បណ្ដោយ លើក្បាលសសរទ្រូងឬចុងជើងគក

មេទ័ព មេរបស់កងទ័ព គឺមន្ត្រីដែលជាអធិបតីត្រួតត្រាពួកទ័ព។

មេទាហាន មន្ត្រីដែលមានអំណាចត្រួតត្រាលើពួកទាហានមានកំណត់ចំនួនប៉ុណ្ណោះៗ ក្នុងបន្ទាយមួយៗឬក្នុងក្រុមមួយៗ។

មេទឹក ទឹកអន្ទង់ជាដើមសម្រាប់បើក, បង្ហូរឬបាចដាក់ស្រែ។

មេបទ អ្នកដែលជាមេបើកបទពំនោលល្ខោន ឬជាមេតាំងផ្ដើមមុនក្នុងការសូត្របទឬច្រៀង ។

មេបន្ទុក អ្នកដែលជាប្រធានក្នុងការទទួលរងបន្ទុក (អ្នកចិញ្ចឹមរក្សាគេ) ។

មេផ្ទះ ស្ត្រីដែលជាប្រធានក្នុងការចាត់ចែងកិច្ចការក្នុងផ្ទះ (ប្រពន្ធ) ។

មេពាក្យ ពាក្យដែលរៀបរៀងជាមេតាមលំដាប់អក្សរ (ដូចយ៉ាងរបៀបពាក្យក្នុងវចនានុក្រមនេះ) ។

មេព្រើល មេនាំឲ្យព្រើល។ មេព្រៃ ឈ្មោះក្រុមរាជការត្រួតត្រាខាងឈើព្រៃចម្រើនប្រយោជន៍ក្នុងរដ្ឋមណ្ឌល។

មេលេខ ឬ មេនព្វន្ត ពាក្យដែលចងជាមេទន្ទេញចំនួនសំខ្យាមានវិធីផ្សំជាដើម សម្រាប់ប្រើក្នុងវិជ្ជានព្វន្ត ។

មេវត្ត ចៅអធិការវត្ត៖ លោកមេវត្ត។ មេសូត្រ ពាក្យដែលចងជាមេទន្ទេញប្រាប់វិធីវេយ្យាករណ៍បាលីសម្រាប់ប្រើក្នុងការរៀនបាលីភាសា (ខាងវេយ្យាករណ៍សំស្ក្រឹតបែបបុរាណ ក៏មានមេសូត្រដែរ)។

មេស្រុក ឬ មេឃុំ មន្ត្រីជាអធិបតីក្នុងឃុំ គឺពញារក្សាភិបាល (ក្នុងសម័យឥឡូវហៅថា នាយសង្កាត់...)។

មេស្រែ អ្នកដែលកាន់កាប់រក្សាស្រែព្រះកេរ្តិ៍ឬអ្នកដែលមានស្រែច្រើនជួលឲ្យគេធ្វើ។

មេអ្នកបាអ្នក (ព. សា.) មនុស្សដែលមានអានុភាពស្មើនឹងគេពល់គ្នា ឥតមានអ្នកណាសន្មតទុកដាក់ឲ្យជាប្រធានលើគេទេ ក៏ស្រាប់តែចេញទែង សម្ដែងអាការជាអ្នកត្រួតត្រាហៃហៃលើគេក្នុងកិច្ចការអ្វីមួយ គឺតាំងខ្លួនឯងជាមេជាបាលើអ្នកទាំងអស់ៗល។ មេខូច មេនាំឲ្យខូចខ្លួនផង។

ព្រះមេ (ព. ប្រ.) ស្រូវ, អង្ករ, បាយ (ហៅដោយទុកដាក់ថាជាមេនៃអាហារ)។

លើសពីនេះ ពាក្យ ថា មេ ឃើញមាននៅតាមលំដាប់ឋានានុក្រមដូចជា មេ បា តា ព្រះ ចៅ ដែលជាទស្សនវិជ្ជាខ្មែរស្តីអំពីគោលគំនិតស្តីពីរចនាសម្ព័ន្ធគ្រប់គ្រងសង្គម ដែលបញ្ជាក់ថា ខ្មែរនិយមគោរព មេ ជាចម្បងបំផុត។

## ៤. អត្ថន័យនៃមាតាធិបតេយ្យក្នុងសង្គមខ្មែរ

វប្បធម៌ខ្មែរគោរព របបមាតាធិបតេយ្យ ពោលគឺលើកតម្លៃរបបមេជាធំ[2]។ មេ ឬម៉ែ ឬមាតា ឬមាតុ ឬម្តាយ មានន័យថា ស្ត្រីអ្នកបង្កើតកូន។ មេជាអ្នកបង្កើតកូនពូនជាចៅ មាននាទីដឹកនាំពូជពង្សវង្សត្រកូល ជាធម្មតាមានឥទ្ធិពលខ្លាំងច្រើនជាងបិតា (ឪពុកឬបា)។

ក្នុងនាមជាករិយារបស់ស្វាមី និងជាមាតារបស់បុត្រ ស្ត្រីមាននាទីទទួលខុសត្រូវខ្ពស់ចំពោះគ្រួសារ។ ទស្សនៈ ក្រមុំដណ្តឹងម្តាយមេម៉ាយដណ្តឹងចិត្ត មានន័យថាមាតាមានសិទ្ធិអំណាចខ្ពស់ក្នុងការសម្រេចស្ទើរគ្រប់កិច្ចការទាំងអស់ ជាពិសេសរឿងទុកដាក់កូនចៅក្នុងបន្ទុកឱ្យមានគូស្រករ។ នៅពេលកូនស្រីចេះដឹងខុសត្រូវហើយ ទើបម្តាយបានផ្តល់នូវសេរីភាពពេញលេញដល់កូនក្នុងការសម្រេចជោគវាសនាអនាគតរបស់ខ្លួនដោយខ្លួនឯង។ ពាក្យស្លោកថា សូវស្លាប់បាកុំឱ្យស្លាប់មេ សូវលិចទូកកណ្តាលទន្លេកុំឱ្យតែភ្លើងឆេះផ្ទះ កាន់តែបញ្ជាក់ថា មេ(ឬម៉ែ) មានភាពឆ្លាតពូកែ និងដើរតួនាទីសំខាន់ក្នុងការចិញ្ចឹមបីបាច់កូនបានល្អជាងឪពុក ព្រោះខ្មែរជឿជាក់ថា សម្ផាញ់ដោយសារគ្រឿង គ្រួសាររុងរឿងដោយសារករិយាជា។ ស្ត្រីខ្មែរដើរតួនាទីជាមេគ្រួសារ មានតម្លៃជាមាតុករិយា(ប្រពន្ធមាននាទីទុកស្មើម្តាយ)។ ភាគច្រើនប្តីមាននាទីធ្វើការរកលុយ ចំណែកប្រពន្ធមាននាទីជាអ្នកចាត់ចែងទុកដាក់លុយកាក់ទាំងនោះ។ ពេលរៀបអាពាហ៍ពិពាហ៍ ខ្មែរបានរៀបចំពិធីមួយហៅថា ព្រះថោងតោងស្បៃនាងនាគ ដែលជាទស្សនវិជ្ជាសង្គមមួយសំខាន់ចង់ឱ្យបុរសជាប្តីត្រូវចេះស្តាប់មតិយោបល់ប្រពន្ធមិនត្រូវរឹងរូសតវ៉ាប្រឆាំងប្រជែងប្រដាំងខ្វះហេតុផលនោះឡើយ។ ភស្តុតាងខ្លះទៀតដែលបង្ហាញរបបមេជាធំ(ឬមាតាធិបតេយ្យ) មានដូចតទៅ៖ នាងគង្ហីង(មេ) និងក្រពើ(បា)ដែលជានិមិត្តរូបតំណាងឥទ្ធិពលធាតុស្រីនិងប្រុសរួមសាមគ្គីគ្នា និងរឿងភ្នំស្រីភ្នំប្រុសដែលជារឿងនិទានបែបប្រវត្តិសាស្ត្រលើកកម្ពស់ឥទ្ធិពលនិងភាភាពវៃឆ្លាតរបស់ស្ត្រី។ល។

## ៥. ប្រវត្តិនៃរបបមាតាធិបតេយ្យខ្មែរ

មានកត្តាជាច្រើនដែលជម្រុញខ្មែរប្រកាន់របបមាតាធិបតេយ្យ។ ខ្មែរបានប្រកាន់យករបបមាតាធិបតេយ្យ តាំងពីសម័យបុរេប្រវត្តិមកម្ល៉េះ គឺឆ្លងកាត់សម័យនៃអាណាចក្រហ្វូណន អាណាចក្រចេនឡា អាណាចក្រអង្គរ មកដល់បច្ចុប្បន្ន។ ស្តេចសោយរាជ្យនៅសម័យគោកធ្លក គឺនាងនាគ

[2] របបមេជាធំ ឬរបបមាតាធិបតេយ្យ .អ )Matriachal regime / បារ .Régime Matriacal (កម្រមាននៅប្រទេសដទៃក្រៅពីនៅខ្មែរណាស់ ។

(ព្រះនាងសោមា ឬលីវយី)។ ព្រះរាជាខ្មែរដែលត្រូវឡើងសោយរាជ្យ ត្រូវជ្រើសរើសឡើងតាមរយៈការស្នងរាជ្យពីបិតាទៅបុត្រាជាដើម។ បុរសមានឥទ្ធិពលអំណាចគ្រប់គ្រងដោយសារស្ត្រី ឧទាហរណ៍ ប្រសិនបើស្តេចមានតែបុត្រីនោះ បុត្រសុណិសា(កូនប្រសាប្រុស)មានតួនាទីជាអ្នកសោយរាជ្យ។ ស្ត្រីមានឋាមពលអាថ៌កំបាំងក្នុងការជួយបុរសឱ្យបំពេញការងារធំៗឱ្យសម្រេចជោគជ័យ ហេតុនេះទើបព្រះរាជាត្រូវមានអគ្គមហេសីជួយប្រឹក្សាយោបល់និងជំនួយការផ្សេងៗទៀត។ បុរសអាងកម្លាំង ចេញបរបាញ់ នេសាទ ធ្វើការធ្ងន់ និងជាអ្នកការពារ ចំណែកស្ត្រីនៅចាំផ្ទះមើលថែខ្លួន កូនចៅទ្រព្យ ដំណាំ។ល។ ដំណើរយល់ដឹងពីធម្មជាតិ នៃសម្ព័ន្ធភាពជីវិតបុរសនិងស្ត្រីតាមបែបជីវសាស្ត្រ គឺជាដំណើរប្រវត្តិសាស្ត្រធម្មជាតិដែលមនុស្សជាតិតំបន់សុវណ្ណភូមិមានតាំងពីសម័យបុព្វកាលមកម្ល៉េះ។ ការទទួលស្គាល់កំរិតខ្ពស់អំពីតម្លៃស្ត្រី គឺជា ទស្សនវិជ្ជាសង្គមនិងនយោបាយពិសេសមួយរបស់ខ្មែរ។

## ៦. ព្រលឹងមាតាធិបតេយ្យក្នុងវប្បធម៌ខ្មែរ

តាមរយៈអរិយធម៌ខ្មែរ ឃើញថា សង្គមខ្មែរបានរក្សាជំនឿលើមាតាធិបតេយ្យដោយឱ្យតម្លៃស្ត្រីពីរយ៉ាងគឺៈស្ត្រីជាធំនិងស្ត្រីជាមង្គល។ ស្ត្រីជាធំ ជាប្រមុខ ជាអ្នកដឹកនាំ ជាមេគំនិតក្នុងការចូលរួមដោះស្រាយបញ្ហាផ្សេងៗ នៅក្នុងគ្រួសារ និងនៅក្នុងសង្គមខ្មែរតាំងពីការកកើតទឹកដីខ្មែរដំបូងម៉្លេះ។ ស្ត្រីមានអំណាចលើប្តីនិងលើកូន មានន័យថា ស្ត្រីអាចជាអ្នកដឹកនាំគ្រួសារឱ្យសម្រេចគោលដៅក្នុងគ្រួសារ។ បច្ចុប្បន្ន ស្ត្រីកាន់តែមានចំនួនច្រើនឡើងៗដែលកំពុងតែចូលរួមនៅក្នុងសកម្មភាពសេដ្ឋកិច្ច សង្គមកិច្ច និងនយោបាយនៅក្នុងសង្គម ហើយស្ត្រីនៅរក្សាបានអំណាចរបស់ខ្លួនក្នុងគ្រួសារទៀតដូចជា ការសម្រេចកិច្ចការផ្សេងៗនៅក្នុងផ្ទះនិងក្នុងសង្គម។

ស្ត្រីជាមង្គលផ្តល់សិរីសួស្តី ជោគជ័យដល់គ្រួសារនិងសង្គមថែមទៀតផង ដូចពាក្យស្លោកបានពោល ថាសំណាបយោងដី ស្រីយោងបុរស និងស៊ូស្លាប់បាកុំឱ្យស្លាប់មេ[3]។ អំណាចនិងមង្គលទាំងនេះវាជាលទ្ធផលនៃការចូលរួមផ្តល់តម្លៃពីសំណាក់ស្ត្រីគ្នាឯងនិងជាពិសេសភាគីបុរស។

តម្លៃស្ត្រីតាមរយៈទំនៀមទម្លាប់ប្រពៃណីមានដូចជា ក្នុងពិធីឡើងផ្ទះ ពិធីសែនមេបា ពិធីចូលម្លប់ និងពេលមានគភ៌ឆ្លងទន្លេជាដើម។ តាមទំនៀមទម្លាប់ នៅពេលសង់ផ្ទះថ្មី ស្ត្រីត្រូវបានប្រគល់ភារៈត្រឹមតែការងារស្រាល ដូចជាចាត់ចែង

[3] ក្រសួងអប់រំយុវជននិងកីឡា, *សិក្សាសង្គមថ្នាក់ទី១០*, គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ, បោះពុម្ពលើកទី៦ ឆ្នាំ ២០១៥, ភ្នំពេញ, ទំព័រ ២៣៩

ទិញសម្ភារៈសំណង់ រៀបចំចម្អិនម្ហូបអាហារ គឺហាមប្រាមមិនឱ្យម្ចាស់ផ្ទះស្រីធ្វើការក្នុងការងារសំណង់ទេ ដូចជាលីសែង ដើរចុះឡើងក្រោមសំណង់ឡើយ ប៉ុន្តែនៅពេលរៀបចំពិធីឡើងផ្ទះដើម្បីសិរីសួស្តី គេអញ្ជើញមនុស្សស្រីឲ្យចូលផ្ទះមុនគេ។

ចំណែកផ្នែកជំនឿវិញខ្មែរបានច្នៃរូបសំណាកអ្នកតាឱ្យទៅជានិមិត្តរូបទេវៈដែលមានស្នាដៃការពារទឹកដី ដូចជា មេ-ស[4]នៅបាភ្នំ ដែលមានរូបរាងជាព្រះនាង ឧមា មហេសីព្រះឥសូរជាដើម។ លើសពីនេះខ្មែរបុរាណបានជឿលើព្រលឹងមេបា។ ប្រសិនបើកូនចៅជំនាន់ណាដែលប្រព្រឹត្តខុសពីសីលធម៌របស់មេបានោះ ព្រលឹងមេបានឹងខឹងសម្បារតាមមកកាច់ដាក់ទារុណកម្មឲ្យឈឺដល់សមាជិកគ្រួសារណាមួយ ដើម្បីឲ្យតាមស្រាវជ្រាវរកអ្នកដែលបានប្រព្រឹត្តកំហុស។ ក្រៅពីនេះខ្មែរនៅជឿពីការបួងសួងបន់ស្រន់ ឲ្យអ្នកតា ជួយគេឲ្យបានសុខចម្រើនផងដែរ ដូចជាបន់សូមឲ្យយាយម៉ៅ និង យាយយាតជួយតាមថែរក្សាជាដើម។ យាយម៉ៅជាវីរៈនារីក្នុងទេវកថាពីបុរាណដ៏ពេញនិយមរបស់ប្រជាជនខ្មែរ ដែលនិទានអំពីស្ត្រីមានកក្តីទន្ទឹងចាំស្វាមីឯនាយសមុទ្រនៅទិសខាងលិចត្រូវបានគេគោរពបូជា ធ្វើសក្ការៈនៅតាមឆ្នេរសមុទ្រ ឬច្រាំងសមុទ្រ ក៏ដូចជានៅចន្លោះផ្លូវពីក្រុងភ្នំពេញ ទៅកំពង់ផែក្រុងព្រះសីហនុ កំពត និងក្រុងកែប។ ចំណែកយាយយ៉ាត ជាអ្នកល្បីពូកែនៅប៉ៃលិន មានបារមីថែរក្សាទឹកដីត្បូងពេជ្រឱ្យទទួលបានតែសេចក្តីសុខ និងចម្រុងចម្រើន។

## ៧. ជំហរមាតាធិបតេយ្យ និង ឥទ្ធិពលបិតាធិបតេយ្យក្នុងសង្គមខ្មែរ

សង្គមខ្មែរក៏ដូចសង្គមនានាដែរតែងមានរចនាសម្ព័ន្ធ៣គឺៈ ក្រុមគ្រួសារ ក្រុមញាតិមិត្ត ក្រុមការងារ។ យើងអាចសង្កេតជំហរមាតាធិបតេយ្យខ្មែរ នៅក្នុងសង្គមខ្មែរតាមរយៈរចនាសម្ព័ន្ធក្រុមទាំងនេះដូចតទៅៈ

### ៧. ១. ជំហរមាតាធិបតេយ្យខ្មែរក្រុមគ្រួសារ

នៅកម្ពុជាសម័យបុរាណ ស្ត្រីអាចយកប្តីច្រើនក្នុងពេលតែមួយ។ សម័យនគរភ្នំ ស្ត្រីត្រូវទៅដណ្តឹងប្រុស[5] តែចាប់ពីសម័យចេនឡាមកប្រុសៗត្រូវទៅដណ្តឹងស្រី ហើយតាមសិលាចារឹកអោយដឹងថាគេនិយមរាប់ញាតិដោយយកខ្សែតាមម្តាយ[6]។

សម័យបុរាណជាធម្មតា មុននឹងសម្រេចផ្សំផ្គុំ ទុកដាក់កូនចៅឲ្យមានគូរស្រករ ឪពុកម្តាយ ឬអាណាព្យាបាលបានប្រើប្រាស់តួនាទីរបស់ខ្លួនដើម្បីជ្រើសរើសយ៉ាងសម្រិតសម្រាំងរកកូនប្រសារ

[4] មេ-ស (អានថា មេ-ស) (ន.) បិសាចស្រី, យាយទេព, អ្នកតាស្រីៈដូចជា មេ-សជ្រៃ, មេ-សប្រចណ្ឌ ។ល។

[5] ត្រឹង ង៉ា ១៩៧៣, ប្រវត្តិសាស្ត្រខ្មែរ ទំព័រ ៩៨

[6] ត្រឹង ង៉ា ១៩៧៣, ប្រវត្តិសាស្ត្រខ្មែរ ទំព័រ ១២៦

ប្រុសឬស្រីរបស់ខ្លួនដោយហ្មត់ចត់បំផុត[7] ដោយប្រើសុភាសិទថា ធ្វើស្រែឲ្យមើលស្មៅ ទុកដាក់កូនចៅមើលផៅសន្តាន[8]។

ឪពុកម្តាយមានតួនាទី ហាមឃាត់កូនចាកអំពើអាក្រក់ ឲ្យកូនតម្កល់នៅក្នុងអំពើល្អ ឲ្យកូនរៀនសូត្រសិល្បសាស្ត្រ ដណ្តឹងកិរិយាស្វាមីសមគួរឲ្យ ចែកទ្រព្យឲ្យកូនក្នុងសម័យគួរ[9] មុនសម្រេចថាឲ្យរៀបការជាប្តីប្រពន្ធ គេត្រូវអង្កេតមើលកិរិយាមាយាទ សម្តីសំដៅ ចិត្តគំនិត តាមរយៈការពិនិត្យដាក់ស្តែងលើសាមីជនផ្ទាល់ ស៊ើបសួរចាស់ទុំជិតខាង និងរហូតដល់ទៅរកគ្រូទាយធ្វើការគន់គូរលេខអត្ថៈ ដើម្បីឲ្យប្រាកដថា អ្នកទាំងពីរនាក់កូនកម្លោះនិងកូនក្រមុំ ជាគូព្រេងនឹងគ្នាពិតប្រាកដ ចៀសវាងគូកម្ម ទើបអាចអនុញ្ញាតឲ្យរៀបការបាន។

ទ្រឹស្តីនំមិនធំជាងនាឡិ ដែលជាអន្តរាគមន៍របស់ឪពុកម្តាយចំពោះជីវិតគ្រួសារគូស្រករលើកូនដោយអំណាចមេបាខ្លាំងដោយមិនបានផ្តល់សិទ្ធិដល់កូនត្រូវបានយកមកប្រើ។ មុននឹងសម្រេចថាឲ្យរៀបការជាមួយកូនស្រីខ្លួន កូនកម្លោះត្រូវទៅនៅបម្រើខាងស្រីដើម្បីឲ្យឪពុកម្តាយខាងស្រីដឹងច្បាស់ពីអត្តចរិកជាមុនសិន។ លុះកាលៈទេសៈក្រោយមកទៀត ការទៅនៅបម្រើក៏ត្រូវកាត់បន្ថយដោយសារការវិវត្តនៃវិស័យការងារនិងរបៀបរស់នៅ។ ទោះយ៉ាំនេះក្តី ក៏ចាស់ទុំពោលថា ក្រមុំដណ្តឹងម្តាយ ម៉េម៉ាយដណ្តឹងចិត្ត។

សម័យសង្គមរាស្ត្រនិយមរបបមាតាធិបតេយ្យមានភាពអាប់អួរ ដោយច្បាប់រដ្ឋប្បវេណីអនុញ្ញាតឲ្យ ស្ត្រីយកប្តីបានតែមួយនាក់ នៅខណៈដែលបុរសអាចយកប្រពន្ធបានច្រើននាក់ ក្នុងពេលតែមួយ ហើយកមណត់ឲ្យប្រពន្ធទាំងឡាយត្រូវទទួលស្តាប់ឱវាទប្តី ត្រូវឱនលំទោន ហើយស្លូតត្រង់នឹងប្តីផង ចំណែក ប្តីត្រូវទំនុកបម្រុងប្រពន្ធទាំងឡាយឲ្យចាយវាយតាមសមគួរដល់មុខរបរនិងធនធានដែលខ្លួនមាន[10] ។ ស្ត្រី ខំតស៊ូខាំមាត់សង្កត់ចិត្ត ទ្រាំទ្រការលំបាកសព្វបែបយ៉ាង តាមទស្សនៈស៊ូលំបាកផ្លូវកាយ កុំឲ្យតែលំបាកផ្លូវចិត្ត។ ស្ត្រីខ្មែរខ្លាចណាស់ការរិះគន់ពីញាតិជិតឆ្ងាយ, ខ្លាចណាស់ពាក្យថាមេម៉ាយ ព្រោះមេម៉ាយចាយ

---

[7] អង្គការទិន្នន័យអំពីអភិវឌ្ឍ, ប្រជាជន និង ជំរឿន ២០១៥ https://opendevelopmentcambodia.net/km/topics/population-and-censuses/

[8] អ៊ុក ជា *លោកនីតិបករណ៍*, ១៩៥៣ http://5000year.space/0datacenter/book/28072017/ពុទ្ធសាសនា/លោករណ៍.pdf

[9] ព្រះត្រៃបិដក សិង្គាលកសូត្រ ខ.៧០ https://5000-years.org/kh/read/275។

[10] រដ្ឋសភា, ១៩៦៧, *ក្រមរដ្ឋប្បវេណីឆ្នាំ១៩៦៧* មាត្រា ១៤០, ១៤១, ១៨៧, និង១៩៣ http://cdslawcambodia.com/wp-content/uploads/2018/12/ក្រមរដ្ឋប្បវេណី-១៩៦៧.pdf

មាត់ញាតិ ជាពិសេសមេម៉ាយប្តីលែង និងមេម៉ាយលែងប្តី។

ក្នុងសម័យខ្មែរក្រហមយុវជនយុវនារីខ្មែរជាច្រើនម៉ឺននាក់ ត្រូវបានអង្គការខ្មែរក្រហមចាប់បង្ខំឲ្យយកគ្នាជាប្តីប្រពន្ធ ដោយមិនបានរៀបការតាមប្រពៃណីខ្មែរ ដែលមានតាំងពីដូនតាយូរលង់ណាស់មកហើយនោះទេ។

ពិធីរៀបការតាមរបបនយោបាយកុម្មុយនិស្តថ្មីបែបលទ្ធិម៉ៅនិយម ដែលគេរៀបការម្តងៗមានចំនួនមនុស្សចាប់ពី ២០គូ ដល់ ១០០គូ។អង្គការខ្មែរក្រហមមិនអនុញ្ញាតឲ្យកូនកំលោះក្រមុំស្ម័គ្រចិត្តរើសគូប្រចាំជីវិតដោយខ្លួនឯងទេ គឺអង្គការផ្គូផ្គងគូស្រករដែលពួកគេមិនដែលស្គាល់គ្នា ឬក៏មិនបានស្រឡាញ់គ្នា ហើយបើអ្នកណាម្នាក់ហ៊ានប្រកែក អង្គការចោទថាខ្មាំងប្រឆាំងបដិវត្ត ហើយត្រូវកងឈ្លបខ្មែរក្រហមចាប់ចងស្លាបសេកយកទៅសម្លាប់ចោល។ ខណៈនេះស្ត្រីរងគ្រោះថ្នាក់ជាងបុរស អង្គការពិនិត្យតាមដានយ៉ាងយកចិត្តទុកដាក់ បន្ទាប់ពីបានផ្សំផ្គុំអស់រយៈពេលខ្លី ២ ឬ ៣ម៉ោងរួចមក ដោយអង្គការខ្មែរក្រហមចាត់តាំងកងឈ្លបតាមដានស៊ើបការណ៍ការផ្សំដំណេករបស់គូស្រករទាំងនោះយ៉ាងជិតដល់បំផុត។ សាមីខ្លួនភាគច្រើនលើសលប់មិនបានពេញចិត្តដៃគូជីវិតដែលខ្មែរក្រហមរៀបឲ្យនោះទេ តែពួកគេមិនហ៊ានប្រកែក ព្រោះខ្លាចអង្គការចោទថា ខ្មាំង ហើយសម្លាប់ចោល។

នៅឆ្នាំ១៩៧៩ របបកម្ពុជាប្រជាធិបតេយ្យបានដួលរលំ ប្តីប្រពន្ធដែលខ្មែរក្រហមបានផ្សំផ្គុំភាគច្រើន ក៏បានលែងលះគ្នាផងដែរ ហើយសិទ្ធិសេរីភាពនៃជំនឿមនោសញ្ចេតនាស្នេហា ដែលអង្គការខ្មែរក្រហមបានបំបិទសិទ្ធិជាង ៣ឆ្នាំមកហើយនោះ ក៏បានកើតមាននៅក្នុងអារម្មណ៍របស់ពលរដ្ឋខ្មែរយើងផងដែរ។ សម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា ក៏ដូច រដ្ឋកម្ពុជា បានផ្តល់សិទ្ធិស្មើគ្នាដល់បុរសនិងស្ត្រី ដូចប្រទេសនានាជឿនលឿន និងគោរពសិទ្ធិមនុស្សលើសកលលោកក្នុងសតវត្សរ៍ទី២០ កំពុងប្រឹងប្រែងអភិវឌ្ឍប្រទេសជាតិ លើកស្ទួយជីវភាពប្រជាជនរបស់គេឲ្យបានប្រសើរ។ អាពាហ៍ពិពាហ៍អាចធ្វើឡើងដោយបុរសម្នាក់និងស្ត្រីម្នាក់ ប៉ុណ្ណោះ[11] ។

បច្ចុប្បន្ន ប្រជាពលរដ្ឋខ្មែរទាំងពីរភេទដែលមានបំណងអាពាហ៍ពិពាហ៍ ត្រូវគោរពគោលការណ៍ឯកពន្ធភាពដោយស្ម័គ្រចិត្ត ប្តីមួយប្រពន្ធមួយ ដោយមានចុះបញ្ជីអាពាហ៍ពិពាហ៍ ចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន ស្របតាមលក្ខខណ្ឌដែលមានចែងក្នុងច្បាប់ស្តីពីអាពាហ៍ពិពាហ៍និងគ្រួសារ[12] ច្បាប់មានការហាមឃាត់មិនឱ្យមានទ្វេពន្ធភាពបុគ្គលដែលមានសហព័ទ្ធហើយពុំអាច

[11] *រដ្ឋសភា, ច្បាប់ស្តីពី អាពាហ៍ពិពាហ៍ និងគ្រួសារ ១៩៨៩* មាត្រា៣

[12] *រដ្ឋសភា, ច្បាប់ស្តីពី ឯកព័ន្ធភាព ២០០៦* មាត្រា២

រៀបអាពាហ៍ពិពាហ៍ទៀត បានឡើយ[13]។ ទោះបីមានគ្រួសារមួយចំនួនជ្រើសរើសគូស្រករតាមរយៈម្ដាយឪពុកក៏ដោយ ក៏សាមីខ្លួនភាគច្រើនបានធ្វើការសម្រេចចិត្តដោយខ្លួនគេផ្ទាល់ក្នុងការជ្រើសរើសគូអនាគតដែរ[14] ។

ស្ថិតនៅក្នុងរចនាសម្ព័ន្ធគ្រួសារ ស្ត្រីដើរតួជាមេផ្ទះដឹកនាំផ្ទះសម្លេងមើលថែទាំប្ដីនិងកូន។ បើប្ដីមានតួនាទីខ្ពស់នៅក្នុងក្រុមការងារ ប្រពន្ធនៅផ្ទះក៏ឡើងបុណ្យតាមនោះដែរ។ បើប្ដីសក្តិ៤នៅក្នុងក្រុមការងារ នោះប្រពន្ធសក្តិ៥នៅផ្ទះ ឬបើប្ដីជាឯកឧត្តមក្នុងក្រុមការងារ នោះប្រពន្ធក្លាយជាជំទាវក្នុងក្រុមគ្រួសារ។ បុរសច្រើនស្ថាប់រស់ក្រោមកន្ទុយក្បិន ហើយជាទូទៅញាតិមិត្តខាងម្ដាយមានភាពស្និទ្ធស្នាលជាងសាច់ញាតិខាងឪពុក។ រូបភាពអំពើហិង្សាក្នុងគ្រួសាររួមមានហិង្សាសេដ្ឋកិច្ច ហិង្សាភេទ ហិង្សាពាក្យសំដី ហិង្សារូបកាយនិងរូបភាពហិង្សាខ្វះទៀតទៅលើស្ត្រី នៅពេលបុរសជាប្ដីមិនបានយល់ដឹងនិងប្រតិបត្តិតាមគោលការណ៍មាតាធិបតេយ្យរបស់ខ្មែរ។ ប្ដីកាន់លុយ(ប្ដីមិនប្រគល់តួនាទីឱ្យប្រពន្ធមានសិទ្ធិគ្រប់គ្រងចំណូលចំណាយ) គឺជារូបភាពហិង្សាសេដ្ឋកិច្ចមួយក្នុងសង្គមខ្មែរ។ ទោះយ៉ាងណាក៏ដោយ ក៏ស្ត្រីដែលឆ្លាតមានសមត្ថភាពយល់ដឹងពីអត្តចរិកប្ដី អាចដោះស្រាយស្ថានភាពទាំងនេះបាន តាមរយៈទស្សនវិជ្ជា ទន់បង្ក្រាបរឹង ឬទន់ភ្លន់មិនទន់ជ្រាយ រឹងប៉ឹងមិនរឹងទទឹង។ វប្បធម៌ខ្មែរ (ដូចមានចែងក្នុងច្បាប់ស្រី ឬបណ្ដាំក្រមង៉ុយជាដើម) បានបង្រៀនស្ត្រីខ្មែរឱ្យមានចរិយាសម្បត្តិសុភាពរៀបសារ ទន់ភ្លន់ រួសរាយរាក់ទាក់ប្រកបដោយភាពថ្លៃថ្នូរ។ ខ្មែរយល់ថា សម្ផ្លាញ់ដោយសារគ្រឿង គ្រួសាររុងរឿងដោយករិយាជា។ ប៉ុន្តែក៏មានស្ត្រីខ្វះលក្ខណៈ (ស្រីខាតលក្ខណ៍) មានចរិយាសម្បទាមិនគ្រប់គ្រាន់ស្របតាមគោលការណ៍មាតាធិបតេយ្យរបស់ខ្មែរ ដែលនាំឱ្យមានការវាយតម្លៃទាបលើភាពជាស្ត្រីរបស់គាត់ព្រោះមាយាទថយថោក អន់ដូចកញ្ជើធ្លុះជាដើម។

### ៧. ២. ជំហរមាតាធិបតេយ្យខ្មែរក្នុងទំនាក់ទំនងញាតិមិត្ត

តាមចិត្តសាស្ត្រគេសង្កេតឃើញថា ស្ត្រីមានឥទ្ធិពលទំនាក់ទំនងប្រសើរជាងបុរស។ ទំនាក់ទំនងរវាងស្ត្រីមេផ្ទះនិងស្ត្រីមេផ្ទះមានភាពស្និទ្ធស្នាលនិងចាំបាច់ជាងទំនាក់ទំនងបុរសជាប្ដីនិងបុរសដទៃ។ ដោយសារតែស្ត្រីពូកែឈានមុខ

---

[13] រដ្ឋសភា, ច្បាប់ស្តីពីក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា ៩៤៩

[14] UNHR K, ១៩៤៨ សេចក្ដីប្រកាសជាសាកលស្ដីអំពីសិទ្ធមនុស្ស, ឆ្នាំ១៩៤៨ មាត្រា ១៦។ https://www.ohchr.org/sites/default/files/UDHR/Documents/UDHR_Translations/khm.pdf

ខាងទំនាក់ទំនង ជាហេតុនាំឱ្យបុរសភាគច្រើនបានយកស្ត្រីធ្វើជាមុខ អាងតែស្រីព្រោះស្ត្រីពូកែដោះស្រាយឬចរចារដោយសន្តិវិធីបានល្អជាងបុរស។ ស្ត្រីខ្មែរអាចចេះដឹងពីការរីករាយរាក់ទាក់រាប់អានគ្នាដោយមិនរើសអើងពីមរតកវប្បធម៌របស់ខ្លួន។ ស្ត្រីខ្មែរមានទម្លាប់ចូលចិត្តរាប់អានសាច់ញាតិ មិត្តភ័ក្តិ ពូជពង្សវង្សត្រកូល ប្រកបដោយមនោសញ្ចេតនាដ៏ជ្រាលជ្រៅបំផុត ប៉ុន្តែក៏ចិត្តដាច់ណាស់ដែរប្រសិនបើនរណាម្នាក់ធ្វើឱ្យខកបំណងឬខូចចិត្ត។ ខ្មែរមានពោលថា មានកម្លាំងដូចខ្មោច មានរិទ្ធិដូចខ្មោច មានចិត្តដូចមនុស្សស្រី ព្រោះស្ត្រីចិត្តដាច់ជាងបុរស (សម្រេចចិត្តផាច់និងច្បាស់លាស់)ក្នុងការទំនាក់ទំនង គឺផាច់ឈ្មោះហើយក៏ផាច់ជានាត្រូវរ៉ូវនឹងគ្នាវិញដែរ។ ជាទូទៅស្ត្រីខ្មែរចូលចិត្តរក្សាញាត្តិច្រើនជាងការបង្កើនសត្រូវ។ ទៅដល់ទីណាចូលចិត្តជជែកពិភាក្សារៀបរាប់បូរបាច់នៅទីនោះ ដែលជួនកាលជជែកខ្វែងគំនិតគ្នាខ្វះរហូតមានជម្លោះ ទំនាស់ខ្វះ ប៉ុន្តែផាច់សះជាគ្នាវិញ បើប្រៀបនឹងបុរស។

## **៧.៣.ជំហរមាតាធិបតេយ្យខ្មែរក្នុងវិស័យការងារ**

ទស្សនៈមេនិយម មានតាំងពីសម័យនគរភ្នំរហូត ដល់បច្ចុប្បន្ន។ ស្ត្រីមានតួនាទីសំខាន់នៅក្នុងសង្គមខ្មែរហើយត្រូវបានគេលើកតម្កើងទុកជាមេដឹកនាំ, ស្ត្រីអាចឡើងសោយរាជ្យជាមហាក្សត្រិយានី ជាកវី ជាអ្នកនិពន្ធ ជាអ្នកដឹកនាំការងារ ជាអ្នកទទួលខុសត្រូវក្នុងផ្ទះ(មេផ្ទះ) ជាដើម។ នៅសម័យនគរភ្នំ(ហ្វូណន) ព្រះនាងលីវយីជារាជនី, សម័យអង្គរព្រះនាងឥន្ទ្រទេវីជាអ្នកនិពន្ធ ជាសកលវិទ្យាធិការិនីនៃសកលវិទ្យាល័យជ័យស្រី ជាដើម។ រឿងភ្នំប្រុសភ្នំស្រីបានបង្ហាញឱ្យឃើញពីសមត្ថភាព ការឈ្លាសវៃ និង ល្បិចរបស់នារីដែលអាចដណ្តើមយកជោគជ័យក្នុងការពូនភ្នំ ។

បច្ចុប្បន្ន ស្ត្រីត្រូវបានលើកតម្កើងក្នុងសង្គម ដោយស្ត្រីមានសេរីភាពសមត្ថភាពចូលរួមចំណែក អភិវឌ្ឍប្រទេសជាតិដូចបុរសដែរ ។ ស្ត្រីបានកាន់តំណែងខ្ពស់ៗ ចូលរួមក្នុងជីវភាពនយោបាយ សង្គម កិច្ច សេដ្ឋកិច្ច និងវប្បធម៌ប្រទេសជាតិរបស់ខ្លួនក្នុងលក្ខណៈស្មើភាពនិងសមស្របពាក្យស្លោកពិភព លោកកំណត់ថា ស្ត្រីជាមាតានៃពិភពលោក មានន័យថា ស្ត្រីដើរតួសំខាន់ក្នុងការបង្កើតធនធានមនុស្ស ជាអ្នកអប់រំមនុស្សជំនាន់ក្រោយឱ្យមានអត្តចរិតល្អថ្លៃថ្នូរ មានជំនាញ និងក្លាយជាពលរដ្ឋល្អក្នុងសង្គម។[15]
សម័យបុរាណស្ត្រីខ្មែរភាគច្រើនចូលចិត្តទទួលយកការងារផ្ទះជាងការងារក្រៅផ្ទះ។ បច្ចុប្បន្ន ផ្ទត់

[15]ក្រសួងអប់រំយុវជននិងកីឡា, សិក្សាសង្គមថ្នាក់ទី១០, មេរៀនទី៣ របបមាតាធិបតេយ្យ, គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ, បោះពុម្ពលើកទី៦ ឆ្នាំ២០១៥, ភ្នំពេញ, ទំព័រ ២៤២

គំនិតនេះបានអស់ឥទ្ធិពលជាបន្តបន្ទាប់។ ស្ត្រីខ្លះដែលមានសមត្ថភាព អាចមានឱកាសដឹកនាំអង្គភាពស្ថាប័នកំពូលដូចជាស្ថាប័ន អាជ្ញាធរដែនដី មន្ទីរ ក្រសួង និងរដ្ឋសភាជាដើម។

ថ្វីត្បិតស្ត្រីខ្មែរ ពុំមានសូវតួនាទីឋានៈជាអ្នកដឹកនាំកំពូលក្នុងក្រុមការងារក៏ដោយ ក៏ស្ត្រីភាគច្រើនដើរតួរជាលេខា ជាជំនួយការ ជាអ្នកសម្របសម្រួលដែលជាកត្តាចាំបាច់មិនអាចខ្វះបានសម្រាប់គ្រប់អង្គភាព ព្រោះស្ត្រីខ្មែរជាមនុស្សពូកែព្យាយាមម៉ត់ចត់ តស៊ូអំណត់ក្នុងការងារពោរពេញទៅដោយចំណេះដឹងទូទៅ។ បើអ្នកដឹកនាំមានស្ត្រីជាប្រពន្ធដែលមានគំនិតជាតិនិយម នោះប្រទេសជាតិជួបប្រទះភាពរុងរឿងរីកចម្រើនតាមនោះដែរ។ ផ្ទុយទៅវិញ ប្រសិនបើស្ត្រីមានគំនិតគ្រួសារនិយមហើយចូលជ្រៀតជ្រែកក្នុងការងារប្តីដែលមាននាទីតំណែងខ្ពស់នោះប្រទេសក៏ជួបវិបត្តិផ្សេងៗច្រើនដែរ។ គេតែរិះគន់ខ្លាំងអំពីផ្នត់គំនិតក្នុងសង្គម ដែលតែងកើតមានថា ប្តីសក្តិ៤ប្រពន្ធសក្តិ៥។ គំនិតនេះ មានន័យថាកិច្ចការនានាត្រូវប្រពន្ធដែលគ្មានតំណែងតួនាទីជាអ្នកសម្រេចទៅវិញ ជាពិសេសអំពើពុករលួយស៊ីសំណូក ជាដើម។

ជាទូទៅក្នុងក្រុមការងារ ស្ត្រីខ្មែរមានអំណាចស្រមោល ក្នុងការសម្រេចចិត្តនិងការផ្តល់គំនិតទស្សនៈ។ នៅក្នុងវិស័យការងារ គំនិតស្ត្រីត្រូវបានយកចិត្តទុកដាក់ តែងដាក់ចូលទៅក្នុងរបៀបវារៈពិភាក្សានិងយកទៅអនុវត្ត។ អ្វីដែលជាគោលបំណង និងគោលដៅរបស់ស្ត្រី តែងត្រូវមនុស្សប្រុសយកមកពិចារណា។ ស្ត្រីខ្មែរភាគច្រើនមានការសម្រេចចិត្តច្បាស់លាស់ មានឥទ្ធិពល និងអំណាចខាងក្នុង ដែលជាអំណាចដ៏អាថ៌កំបាំង ពោរពេញទៅដោយថាមពលដ៏អស្ចារ្យដូចពរជ័យពោលថា៖ «សូមឲ្យមានកម្លាំងដូចស្រមោច សូមឲ្យមានឫទ្ធិដូចខ្មោច សូមឲ្យមានចិត្តមុតដូចមនុស្សស្រី»[16]។ បុរសដែលឱ្យតម្លៃស្ត្រីកម្រហ៊ានឈ្លោះជាមួយស្រីណាស់ ព្រោះមានពាក្យស្លោកមួយពោលថា «កុំឈ្លោះនឹងស្រី កុំក្តីនឹងចិន» ជាដើម។

ដោយសារសង្គមខ្មែរបច្ចុប្បន្ន មានការវិវត្តឥតឈប់ឈរ ស្ត្រីមានភារកិច្ចត្រូវធ្វើច្រើនដូចបុរសដែរ គឺរៀនសូត្រនិងបំពេញការងារជាមុខរបរចិញ្ចឹមជីវិតដោយខ្លួនឯងមិនរង់ចាំតែដេកស៊ីកម្លាំងពលកម្មនរណាឡើយដូច្នេះពិធីទំនៀមទម្លាប់ខ្លះក៏ត្រូវកាត់បន្ថយដែរ ដូចជា ពិធីចូលម្លប់ជាដើម។

16 យោងតាមសៀវភៅ ប្រជុំរឿងព្រេងខ្មែរភាគទី៦ និងសិលាចារឹករបស់បណ្ឌិតសិលាចារ្យនៅប្រាសាទភ្នំជីសូរ ក្នុងរជ្ជកាលព្រះបាទសុរ្យវរ្ម័នទី១ គ. ស.១០១៧

## ៨. គោលគំនិតយេនឌ័រ

យេនឌ័រ គឺជាដំណើរស្មើមុខគ្នារវាងបុរស និងស្ត្រីក្នុងសង្គមក្នុងការប្រើសិទ្ធិសេរីភាពសមត្ថភាព និងតួនាទីរបស់ខ្លួន។ តាមគោលគំនិតយេនឌ័រ សមាជិកសង្គមម្នាក់ៗ ទាំងបុរសនិងស្ត្រី មានឱកាសដូចគ្នាក្នុងការចូលរួមសកម្មភាពសង្គម។ ទស្សនៈស្តីពីយេនឌ័រ បាននិងកំពុងមានការពេញនិយមនិងរីកដុះដាលនៅបស្ចឹមប្រទេសនិងរីករាលដាលដល់តំបន់ផ្សេងៗទៀតជាបន្តបន្ទាប់។ សង្គមវិទូចាត់ទុកថា ការសិក្សាអំពីទំនាក់ទំនងយេនឌ័របានក្លាយជាផ្នែកមួយដ៏សំខាន់បំផុតសម្រាប់ពិភពលោកបច្ចុប្បន្ន។

គោលគំនិតយេនឌ័រយល់ថាស្ត្រីនិងបុរសគួរមានសិទ្ធិអំណាចស្មើគ្នាក្នុងការទទួលខុសត្រូវក្នុងការសម្រេចចិត្តនិងធ្វើសកម្មភាពនានាក្នុងសង្គមដើម្បីជោគវាសនានៃជីវិតរបស់ខ្លួន។ ប្រសិនបើសមត្ថភាពដូចគ្នា ការងារដូចគ្នា តួនាទីដូចគ្នា នោះសមាជិកសង្គមម្នាក់ត្រូវទទួលផលប្រយោជន៍ប្រាក់កម្រៃ និងផលលាភដូចគ្នា ដោយមិនត្រូវបែងចែករើសអើងថាជាបុរសឬស្ត្រី ឬភេទអ្វីឡើយ។

គួររំលឹកថា នាចុងសតវត្សទី ១៩ នៅស.រ.អ. និងនៅបណ្តាប្រទេសឧស្សាហកម្មរីកចំរើន នារី និង កុមារ ត្រូវគេបង្ខំឲ្យធ្វើការជាទម្ងន់ក្នុងមួយថ្ងៃពី ១២ ទៅ ១៦ ម៉ោង ដោយឲ្យប្រាក់ ឈ្នួលទាបបំផុត ពោលគឺទាបជាងបុរសដែលធ្វើការដូចគ្នា។ ដោយមានកំហឹងចំពោះការគាបសង្កត់នេះ នៅថ្ងៃ ៨ មីនា ១៨៩៩ កម្មការនីផ្នែកតំបាញ និងកាត់ដេរនៅស៊ីកាកូ និងញូយ៉ក បានក្រោកតស៊ូទាមទារបន្ថយម៉ោងធ្វើការ និង តំលើងប្រាក់ឈ្នួល។ ចលនានេះរាលដាលដល់ប្រទេសអាឡឺម៉ង់ និង ប្រទេសរុស្ស៊ី។ ឆ្នាំ ១៩១០ សន្និសីទអន្តរជាតិនារីដែលមានប្រទេស១៧ ចូលរួមប្រជុំនៅក្រុងគូពនហាក បានសំរេចយកថ្ងៃ៨ មីនា ជា "ទិវានារីអន្តរជាតិ " ជាមហាសាមគ្គីតស៊ូរបស់នារីពលករសកលលោកដើម្បីសិទ្ធិ សេរីភាព ប្រជាធិបតេយ្យ និងវឌ្ឍនសង្គម ភ្ជាប់ជាមួយពាក្យស្លោកៈ ១-ធ្វើការមួយថ្ងៃ៨ម៉ោង ២-ធ្វើការស្មើគ្នា ប្រាក់ឈ្នួលស្មើគ្នា ៣- ធានាសុខភាពមាតា និងទារក។ ក្នុងប្រតិទិនឈប់សម្រាកប្រចាំឆ្នាំ ក្នុងនោះក៏មានថ្ងៃ ៨ មីនា មួយដែរ ដែលរដ្ឋាភិបាលបាន អនុញ្ញាតឲ្យពលរដ្ឋទាំងអស់បានឈប់សម្រាក១ថ្ងៃ ដើម្បីអបអរសាទរទិវាសិទ្ធិនារីអន្តរជាតិនេះជាដរាបរៀងមក។

## ៩. គោលគំនិតបិតាធិបតេយ្យ

គំនិតបិតាធិបតេយ្យដែលបាននិងកំពុងប្រតិបត្តិនៅក្នុងបណ្តាប្រទេសមួយចំនួន ដូចជា ចិន ឥណ្ឌា អារ៉ាប់ និងនៅតាមតំបន់ខ្លះដូចជា មជ្ឈិមបូព៌ា អាស៊ីអាគ្នេយ៍ អាព្រិក មានអត្ថិភាពនៅក្នុងស្ទើរគ្រប់លទ្ធិសាសនាទាំងអស់ ដូចជា ឥស្លាមសាសនា គ្រិស្តសាសនា ព្រហ្មញ្ញសាសនា ជាដើម។

តាមការសង្កេតក្នុងលទ្ធិសាសនាស្ទើរទាំងអស់ អាទិទេពធំៗ មានភេទជាបុរស ដូចជា ព្រះអាឡាហ៍ ក្នុងឥស្លាមសាសនា ព្រះវរបិតា (ឬព្រះបុត្រា) ក្នុងគ្រិស្តសាសនា ព្រះសិវៈ វិស្ណុ ព្រះព្រហ្មញ្ញ ក្នុងព្រាហ្មណ៍សាសនាជាដើម។ ពុទ្ធសាសនាពុំបានលើកតំកើងតម្លៃអាទិទេពជាភេទប្រុសឡើយ ប៉ុន្តែអ្នកបួសបុរស និងស្ត្រីមានឋានៈពុំស្មើគ្នាឡើយ។ ភិក្ខុនី(អ្នកបួសភេទជាស្ត្រី) ពុំមានឋានៈស្មើភិក្ខុ(អ្នកបួសភេទជាបុរស)ឡើយ ទោះបីភិក្ខុនីបួសច្រើនព្រះវស្សាយ៉ាងណាក៏ដោយ ក៏មានឋានៈទាបជាងភិក្ខុដែលទើបតែបួសបានមួយថ្ងៃដែរ។ ភិក្ខុនីត្រូវប្រតិបត្តិសិក្ខាបទហ្មឺងម៉ាត់ច្រើនលើសលប់ជាងភិក្ខុ ប្រហែលដោយហេតុនេះ ទើបគេកម្រឃើញមានវត្តមានភិក្ខុនីណាស់ ហើយសម័យកាលខ្លះគឺគ្មានភិក្ខុនីសោះតែម្តង។

ដោយឡែកក្នុងវិស័យសាសនានៅកម្ពុជា យុវជនពេញវ័យដែលចង់សិក្សាធម៌វិន័យទ្រឹស្តីទស្សនវិជ្ជាពុទ្ធសាសនា ឬចង់បន្តរស់នៅក្នុងជីវភាពស្ងប់ស្ងាត់អាចទៅនៅជ្រកកោនតាមអារាមបាន។ ចំពោះបុរសជាអ្នកបួសដែលទៅជ្រកកោនក្នុងពុទ្ធសាសនាមិនត្រឹមតែទទួលបានជីវភាពប្រសើរប៉ុណ្ណោះទេ គឺថែមទាំងទទួលបានការគោរពយ៉ាងខ្ពស់ពីសំណាក់ពុទ្ធបរិស័ទទូទៅទៀតផង។ ចំណែកស្ត្រីពុំមានវាសនាអាចបួសជាសង្ឃដូចសម័យពុទ្ធកាលទេ ព្រោះគ្មានឧបជ្ឈាយ៍ដែលជាភិក្ខុនីសម្រាប់បំបួសឡើយ។ ប៉ុន្តែថ្មីៗនេះ ភិក្ខុនីជនជាតិចិនតៃវ៉ាន់ជាច្រើនអង្គមានវត្តមាននៅក្នុងប្រទេសខ្មែរ ដោយគេបានសាងសង់វត្តអារាមដ៏ធំមួយក្នុងក្រុងភ្នំពេញ។ យើងមិនទាន់ដឹងច្បាស់ថា តើមានស្ត្រីខ្មែរប៉ុន្មាននាក់មានឧបនិស្ស័យបានបួសនៅទីនោះឡើយ ប៉ុន្តែកន្លងមកឧបាសិកាជាជនជាតិខ្មែរដែលជ្រះថ្លាចង់បួសជាសង្ឃមិនអាចសម្រេចបានឡើយ គឺអាចបួសបានត្រឹមតែដូនជីតែប៉ុណ្ណោះ។ ដូនជីភាគច្រើនស្នាក់នៅក្នុងវត្តត្រូវបម្រើសាមណេរនិងភិក្ខុ។ នេះអាចបញ្ជាក់ថា ក្នុងពុទ្ធសាសនាតម្លៃរបស់ស្ត្រីមានកំរិតទាបជាងបុរស។

នៅក្នុងសង្គមដែលប្រកាន់របបបិតាធិបតេយ្យ[17] តែងលើកតម្កើងតម្លៃមនុស្សប្រុសខ្ពស់ជាងមនុស្សស្រី។ ក្នុងគ្រួសារ បុរសមានតម្លៃក្នុងការរក្សានាមត្រកូល។ ឥទ្ធិពលនៃគំនិតបិតាធិបតេយ្យនាំឱ្យបុរសជាប្តីភាគច្រើនមិនលើកកម្តើងស្ត្រីជាប្រពន្ធ និងកូនស្រីឡើយ។ ស្ត្រីជាប្រពន្ធមានឋានៈហាក់ដូចជាអ្នកបម្រើ(ទាសករិយា)។ បុរសជាប្តីក្តោបក្តាប់ប្រាក់ចំណូលចំណាយនិងមានអំណាចត្រួតត្រាលើប្រពន្ធ។ ឧទាហរណ៍ ស្ត្រីដែលរៀបការជាមួយបុរសចិនត្រូវទៅរស់នៅផ្ទះ

17 របបបិតាធិបតេយ្យ .អ)Patriarch regime / បារ. régime partriarcalមានក្នុងស្ទើរគ្រប់សាសនា ។(

ខាងប្ដី ហើយជាធម្មតាធ្វើការងារគ្រប់ប្រភេទដើម្បីបម្រើបងប្អូនឪពុកម្ដាយខាងប្ដី ហើយតាមទម្លាប់ថ្ងៃទី២នៃចូលឆ្នាំ ទើបប្រពន្ធអាចទៅលេងផ្ទះម្ដាយបង្កើតរបស់ខ្លួនបាន។ ការនិយមឱ្យតម្លៃមនុស្សប្រុស បូករួមផ្សំជាមួយគោលនយោបាយកូនមួយរបស់ប្រទេសចិន(ឆ្នាំ១៩៧៩ដល់ឆ្នាំ២០១៦) ការរំលូតគភ៌ទារិកាកើតមានជារឿយៗ។ លោក Jiang Quanbao សាស្ត្រាចារ្យផ្នែកប្រជាសាស្ត្រនៃសាកលវិទ្យាល័យ Xian Jiaotong បាននិយាយថា៖ «គេប៉ាន់ប្រមាណថានៅចន្លោះ ឆ្នាំ ១៩៨០ និង ២០២០ មានមនុស្សប្រុសប្រហែលជា ៣០ លានទៅ ៤០ លាននាក់ច្រើនជាងកើតនៅប្រទេសចិន ជាងស្ត្រី ដែលធ្វើឱ្យមានកង្វះនៃមនុស្សសម្រាប់រៀបអាពាហ៍ពិពាហ៍»[18]។

គំនិតបិតាតេយ្យដែលមាននៅក្នុងស្ទើរគ្រប់លទ្ធិសាសនាទាំងអស់តែងតែលើកតម្កើងអាទិទេព ហើយអាទិទេពកំពូលសុទ្ធសឹងតែជាភេទប្រុស។ ក្នុងព្រហ្មញ្ញសាសនា អាទិទេព១អង្គមានទេពអប្សរជាច្រើនជាប្រពន្ធ។ ចំណែកពុទ្ធសាសនាដែលផ្អែកលើទ្រឹស្ដីកម្មផល និងមនុស្សនិយម បានឲ្យដឹងថាទេព្ដា១អង្គមានទេពធីតាជាប្រពន្ធចាំបម្រើជាច្រើនអង្គដែរ។ ពុទ្ធសាសនាលើកឡើងថា គឺភិក្ខុនីពុំមានឋានៈស្មើភិក្ខុឡើយ។ ទោះបីភិក្ខុនីបួសច្រើនព្រះវស្សាយ៉ាងណាកដោយ ក៏មានឋានៈទាបជាងភិក្ខុដែលទើបតែបួសបានមួយថ្ងៃដែរ។ ចំណែកគំនិតយេនឌ័រ សមាជិកសង្គមម្នាក់ៗ ទាំងបុរសនិងស្ត្រី មានឱកាសដូចគ្នាក្នុងការចូលរួមសកម្មភាពសង្គម។ ស្ត្រីនិងបុរសទទួលខុសត្រូវដូចគ្នាក្នុងការសម្រេចចិត្តនិងធ្វើសកម្មភាពដើម្បីជោគវាសនានៃជីវិតរបស់ខ្លួន។ ដោយឡែក វប្បធម៌ខ្មែរ ឬទស្សនវិជ្ជាខ្មែរនិយមគោរពរបបមាតាធិបតេយ្យ ពោលគឺខ្មែរលើកតម្លៃរបបមេជាធំ។ ស្ត្រីខ្មែរដើរតួនាទីជាមេគ្រួសារ មានតម្លៃជាមាតាភរិយាគឺ ប្ដីមាននាទីធ្វើការរកលុយ ចំណែកប្រពន្ធមាននាទីជាអ្នកចាត់ចែងទុកដាក់លុយកាក់ទាំងនោះ។ ខ្មែរបានប្រកាន់យករបបមាតាធិបតេយ្យតាំងពីសម័យបុរេប្រវត្តិរហូតមកដល់បច្ចុប្បន្ន។ ស្ត្រីខ្មែរមានថាមពលអាថ៌កំបាំងក្នុងការជួយបុរសឱ្យបំពេញការងារធំៗបានសម្រេចជោគជ័យ។ ស្ថិតនៅក្នុងរចនាសម្ព័ន្ធគ្រួសារ ស្ត្រីដើរតួជាមេផ្ទះដឹកនាំផ្ទះសម្បែងមើលថែទាំងប្ដីនិងកូន។ ញាតិមិត្តខាងម្ដាយមានភាពស្និទ្ធស្នាលជាងសាច់ញាតិខាងឪពុក។ ប្ដីកាន់លុយគឺជារូបភាពហិង្សាសេដ្ឋកិច្ចមួយក្នុសង្គមខ្មែរ។ ច្បាប់ស្រី បណ្ដាំក្រមង៉ុយ បានបង្រៀនស្ត្រីខ្មែរឱ្យមានចរិយាសម្បត្តិសុភាពរៀប

[18] ប្រទេសចិន មានបុរសច្រើនជាងស្ត្រី ដែលបណ្ដាលឱ្យមានមនុស្សប្រុសជាច្រើននៅលីវ https://www.postkhmer.com/អន្តរជាតិ/ប្រទេសចិន-មានបុរសច្រើនជាងស្ត្រី-ដែលបណ្ដាលឱ្យមានមនុស្សប្រុសជាច្រើននៅលីវ

សារ ទន់ភ្លន់ រួសរាយ និងរាក់ទាក់ប្រកបដោយភាពថ្លៃថ្នូរ ដើម្បីទទួលបានការគោរពឲ្យតម្លៃពីបុរសស្ត្រីគ្រប់រូប សក្តិសមជាស្ត្រីក្នុងរបបមាតាធិបតេយ្យពិតប្រាកដ។ ថ្វីត្បិតស្ត្រីខ្មែរ ពុំមានតួនាទីឋានៈជាអ្នកដឹកនាំកំពូលក្នុងក្រុមការងារក៏ដោយ ក៏ស្ត្រីមានអំណាចស្រមោលក្នុងការសម្រេចចិត្ត និងការផ្តល់គំនិតទស្សនៈនៅក្នុងវិស័យការងារ។ ទាំងនេះអាចបញ្ជាក់ថាការទទួលស្គាល់តម្លៃស្ត្រីខ្ពស់ជាងបុរស គឺជាទស្សនវិជ្ជាពិសេសរបស់ខ្មែរ។ សម្រាប់ស្ត្រីខ្មែរពូកែអត់ធ្មត់ ប្រសិនបើ ចេះរើសដៃគូប្តី សហព័ទ្ធបានត្រឹមត្រូវ ចេះរៀបចំផែនការគ្រួសារ ចេះពិភាក្សាដើម្បីយល់ចិត្តថ្លើមគ្នាមុនរៀបការ មានសមត្ថភាពក្នុងការងារមុខរបរចិញ្ចឹមជីវិតច្បាស់លាស់ មិនពឹងផ្អែកដេកស៊ីលើកម្លាំងញើសឈាមភាគីម្ខាង នោះសុភមង្គលច្បាស់ជាកើតមានឡើង។ ជាពិសេស សម្រាប់បុរសជាប្តីត្រូវអប់រំឲ្យយល់ដឹង ប្រើទស្សនវិជ្ជាទន់បង្ក្រាបរឹង ឬទន់ភ្លន់ មិនទន់ជ្រាយ រឹងប៉ឹងមិនរឹងទទឹង និងសណ្តោសគ្នា ដូចមានចែងក្នុងច្បាប់ស្រីឬបណ្តាំក្រមង៉ុយ និងពាក្យសុភាសិតខ្លះដូចជា សម្ងំឆ្ងាញ់ដោយសារគ្រឿងគ្រួសារុងរឿងដោយកិរិយាជា, សំណាបយោងដី ស្រីយោងបុរសជាដើម។

ខណៈពេលដែលពេលពលរដ្ឋខ្មែរភាគច្រើនមានការយល់ដឹង និងអនុវត្តច្បាប់មួយចំនួនដូចជា ច្បាប់ស្តីពីអាពាហ៍ពិពាហ៍និងគ្រួសារឆ្នាំ១៩៨៩, ច្បាប់ស្តីពីឯកពន្ធភាព២០០៦, ក្រមរដ្ឋបវេណីឆ្នាំ២០០៧, ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋបវេណីឆ្នាំ២០១១ និងក្រមព្រហ្មទណ្ឌជាដើម ដែលឲ្យតម្លៃលើសមភាពបុរសស្ត្រីតាមទស្សនៈយេនឌ័រ ជាហេតុនេះជំរុញឲ្យព្រលឹងមាតាធិបតេយ្យមានឱកាសបន្តរស់រវើកមួយកម្រិតថែមទៀត ទោះបីឥទ្ធិពលបិតាធិបតេយ្យដែលបង្កប់ក្នុងស្មារតីនៃវប្បធម៌បរទេស និងក្រមរដ្ឋប្បវេណីខ្មែរ ឆ្នាំ១៩៦៧ ដែលបានកំណត់ឲ្យបុរសជាប្តីអាចមានប្រពន្ធច្រើន មានប្រៀបជាងស្ត្រី នៅតែជិតដាមជាប់មិនទាន់ជ្រះស្រឡះក្នុងផ្នត់គំនិតមនុស្សខ្មែរមួយចំនួននៅឡើយ ក៏ដោយ។

## សេចក្តីសន្និដ្ឋាន

ជនជាតិខ្មែរតែងលើកតម្កើងផ្តល់តម្លៃខ្ពស់ដល់ស្ត្រី ក្នុងការគ្រប់គ្រងថែរក្សាក្រុមគ្រួសារ ក្នុងការងារប្រឹក្សាផ្តល់យោបល់បញ្ចុះបញ្ចូលនិងទំនាក់ទំនងការងារនិងញាតិមិត្ត។ ចំណែក ទស្សនៈយេនឌ័រ មានបំណងឱ្យស្ត្រីចាកចេញពីការងារផ្ទះសម្បែងទៅរកការងារខាងក្រៅ ដោយចុះប្រឡូកក្នុងការងារសង្គមដើម្បីបានឋានៈតួនាទីខ្ពស់ ជាអ្នកដឹកនាំ។ នេះជាជាចរន្តគំនិតសម្រាប់មនុស្សជំនាន់ថ្មី ដើម្បីជៀសវាងជំនឿលថា ស្ត្រីបង្វិលជើងក្រានមិនជុំ។ ការណ៍នេះនាំឱ្យស្ត្រីខ្មែរជំនាន់ថ្មីកាន់តែមានចំនួនច្រើនឡើងបានពង្រឹងនិងពង្រីកសមត្ថភាពទេពកោសល្យជំនាញចំណេះដឹងការងាររបស់ខ្លួនឱ្យមានលក្ខណៈកាន់តែប្រសើរ ដែលធ្វើឱ្យតម្លៃស្ត្រីខ្មែរកាន់តែកើនឡើងខ្ពស់ថែមទៀត។ គោលគំនិតយេនឌ័រនៅកម្ពុជា

បានជម្រុញរបបមាតាមាតាធិបតេយ្យឱ្យកាន់មាន ជំហររឹងមាំខ្លាំងក្លាថែមទៀតប្រឈមតទល់យ៉ាង ស្វិតស្វាញនឹងលទ្ធិបិតាធិបតេយ្យ។ យើងអាច និយាយបានថា ព្រលឹងមាតាធិបតេយ្យនៅតែរស់ រវើកនៅក្នុងសង្គមខ្មែរទោះបីលទ្ធិបិតាធិបតេយ្យ ដែលមាននៅក្នុងលទ្ធិសាសនាធំៗកំពុងមាន អត្ថិភាពពេញពិភពលោកយ៉ាងណាក៏ដោយ។ នៅក្នុងកម្ពុជារបបបិតាធិបតេយ្យគ្រាន់តែមាន ទម្រង់ខាងក្រៅប៉ុណ្ណោះ មិនអាចកាច់បំបាក់ ឥទ្ធិពលមាតាធិបតេយ្យខ្មែរបានឡើយ។ ថ្វីត្បិត មាន ស្ថាប័នមួយចំនួនមានការព្រួយបារម្ភខ្លាំង លើអំពើហិង្សាខ្លះដែលរំលោភបំពានសិទ្ធិរបស់ ស្ត្រី ក៏យើងអាចដោះស្រាយបានជាប្រព័ន្ធតាម គោលការណ៍ច្បាប់និងវប្បធម៌បាន ព្រោះអំពើ ហឹង្សាទាំងនោះមិនមែនមានតែលើស្ត្រីទេ គឺវា កើតមានលើបុរសច្រើនជាងស្ត្រីទៅទៀត។ ដូច ច្នេះគួរយកចិត្តទុកដាក់និងដោះស្រាយករណី ទាំងនេះតាមរយៈចលនាមហាជនទាំងមូលឱ្យ យល់ពីសមភាពយេនឌ័រ និងលទ្ធិមាតាធិបតេយ្យ របស់ខ្មែរ ឱ្យបានត្រឹមត្រូវ និងទូលំទូលាយថែម ទៀត។

## គន្ថនិទ្ទេស

### ក-ឯកសារជាភាសាខ្មែរ

1. ក្រសួងអប់រំយុវជននិងកីឡា, *សិក្សាសង្គមថ្នាក់ទី១០*,គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ, បោះពុម្ពលើកទី៦ ភ្នំពេញ, ឆ្នាំ២០១៥
2. ខ្ចូត ធីតា, *ព្រះពុទ្ធសាសនានិងការអភិវឌ្ឍសង្គមខ្មែរ* គ.ស. ១៩៩៦
3. ងួន ញ៉ិល *ព្រលឹងមាតាធិបតេយ្យក្នុងសង្គមខ្មែរ* ភ្នំពេញ ១៩៩២
4. ជួនណាត *វចនានុក្រមខ្មែរ ភាគ១ ភាគ២* ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ ១៩៦៧
5. ត្រឹង ងា, *ប្រវត្តិសាស្ត្រខ្មែរ* ១៩៧៣
6. ត្រឹង ងា *អរិយធម៌ខ្មែរ* ភ្នំពេញ បោះពុម្ពឆ្នាំ១៩៧៤
7. ពុទ្ធសាសនបណ្ឌិត្យ, *ព្រះត្រៃបិដក* ភ្នំពេញ ព.ស.២៤៩៧
8. រដ្ឋសភា, *រដ្ឋធម្មនុញ្ញ* ឆ្នាំ១៩៩៣
9. រដ្ឋសភា, *ក្រមរដ្ឋប្បវេណី* ឆ្នាំ១៩៦៧
10. រដ្ឋសភា, *ច្បាប់ស្តីពី ឯកព័ន្ធភាព* ២០០៦
11. រដ្ឋសភា, *ក្រមរដ្ឋប្បវេណី* ឆ្នាំ២០០៧
12. រដ្ឋសភា, *ច្បាប់ស្តីពីអនុវត្តក្រមរដ្ឋប្បវេណី* ឆ្នាំ២០១១
13. លី ដានីនិងអ្នកផ្សេងទៀត, *ទស្សនវិជ្ជា*, ភ្នំពេញ វិទ្យាស្ថានជាតិ ខេមរយានកម្ម ឆ្នាំ១៩៧៣
14. វិទ្យាស្ថានខុងជឺនៃរាជបណ្ឌិត្យសភាកម្ពុជា *ពិធីបុណ្យទំនៀមទម្លាប់ប្រពៃណីជនជាតិចិន* ភ្នំពេញ ២០១១
15. សរ សារុន *សង្គមវិជ្ជាខ្មែរ* ភ្នំពេញ ១៩៧៣
16. សុង ស៊ីវ *ចលនាអារ្យធម៌* ភ្នំពេញ ១៩៧១។
17. សាកលវិទ្យាល័យ បៀលប្រាយ មនុស្សនិងសង្គម ភ្នំពេញ ឆ្នាំ២០១៣
18. ឱម ឧត្តម, *ឥទ្ធិពលបរទេសមកលើប្រពៃណីរៀបការរបស់ខ្មែរ*, វិទ្យុអាស៊ីសេរី ២០១០។

### ខ-ឯកសារតាមប្រព័ន្ធអ៊ីនធឺណិត

19. ស្រុង ចាន់ណា, *គេហទំព័រ៥០០០ឆ្នាំ* (https://5000-years.org/kh/)
20. *វិទ្យុអាស៊ីសេរី*, https://www.rfa.org
21. *វិទ្យុបារាំងអន្តរជាតិជាភាសាខ្មែរ*

22. https://www.rfi.fr/km

23. https://km.wikipedia.org

24. http://khmer.voanews.com

25. www.thmeythmey.com

26. http://vodhotnews.com

ទ្រឹស្ដីផ្សារភ្ជាប់នឹងការអនុវត្ត ចងភ្ជាប់ដោយលទ្ធផល
ហើយត្រូវមានក្រមសីលធម៌វិជ្ជាជីវៈ